# សេចក្តីព្រាង

# ក្រមបរិស្ថាន និងធនធានធម្មជាតិ

## កំណែទី១០ ថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០១៨

# ដំណើរការតាក់តែងសេចក្តីព្រាងក្រមបរិស្ថាន និងធនធានធម្មជាតិ

សេចក្តីព្រាងក្រមបរិស្ថាន និងធនធានធម្មជាតិ ដែលសម្រេចបានរហូតមកដល់ពេលបច្ចុប្បន្ននេះ ជាលទ្ធផលនៃការងារអស់រយៈពេលជាង២ឆ្នាំ របស់ក្រសួងបរិស្ថាន ក្រោមការផ្តួចផ្តើមគំនិតរបស់ **ឯកឧត្តម បណ្ឌិត សាយ សំអាល់** រដ្ឋមន្ត្រីក្រសួងបរិស្ថាន ក្នុងការអនុវត្តគោលនយោបាយកំណែទម្រង់ លើវិស័យបរិស្ថាន និងធនធានធម្មជាតិ ស្របតាមគោលនយោបាយយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាល ដោយមានការឯកភាព និងការគាំទ្រដ៏ខ្ពង់ខ្ពស់ពី **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា និងបានធ្វើកិច្ចសហការផ្តល់ជំនួយបច្ចេកទេសពី ក្រុមមេធាវី វីស្ត្ក ។

ចាប់តាំងពីដើមឆ្នាំ២០១៥មក ក្រសួងបរិស្ថាន បានចាប់ផ្តើមរៀបចំឱ្យមានសេចក្តីព្រាងក្រមបរិស្ថាន និងធនធានធម្មជាតិមួយ ដើម្បីឆ្លើយតបទៅនឹងស្ថានភាពជាក់ស្តែងនៃព្រះរាជាណាចក្រកម្ពុជា ដែលតម្រូវឱ្យមានក្រមបរិស្ថាន និងធនធានធម្មជាតិមួយ មានលក្ខណៈច្បាស់លាស់ និងពេញលេញគ្រប់ជ្រុងជ្រោយ ដើម្បីធ្វើឱ្យមានប្រសិទ្ធភាពនៃការធ្វើកំណែទម្រង់ថ្មីលើវិស័យបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ ឱ្យស្របតាមបរិបទនៃការរីកចំរើនរបស់ព្រះរាជាណាចក្រកម្ពុជា ។

សេចក្តីព្រាងក្រមបរិស្ថាន និងធនធានធម្មជាតិ ជាសេចក្តីព្រាងក្រមមួយដែលមានលក្ខណៈចម្រុះ និងគ្រប់វិស័យ ដោយប្រមូលផ្តុំរាល់បទប្បញ្ញត្តិនៃច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានាពាក់ព័ន្ធនឹងវិស័យបរិស្ថាន និងធនធានធម្មជាតិ ដោយមានការបែងចែកជារចនាសម្ព័ន្ធត្រឹមត្រូវ ដើម្បីធានាឱ្យមានសង្គតិភាព និងភាពស៊ីសង្វាក់គ្នា និងព្រមទាំងបានបំពេញបន្ថែមនូវចំណុចខ្វះចន្លោះ ភាពមិនច្បាស់លាស់ ការត្រួតសមត្ថកិច្ចគ្នា នៃការគ្រប់គ្រងធនធានធម្មជាតិរបស់ក្រសួង ស្ថាប័នពាក់ព័ន្ធនានា នៃព្រះរាជាណាចក្រកម្ពុជា គឺធ្វើយ៉ាងណាឱ្យសេចក្តីព្រាងក្រមមួយនេះ ក្លាយជាលិខិតតូបករណ៍គតិយុត្តមួយយ៉ាងសំខាន់ សម្រាប់ក្រសួង ស្ថាប័នពាក់ព័ន្ធនឹងវិស័យបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ និងអ្នកអនុវត្តច្បាប់ផ្សេងទៀត មានភាពងាយស្រួលក្នុងការប្រើប្រាស់ និងអនុវត្តតួនាទី ភារកិច្ចរៀងៗខ្លួន ។

ក្នុងការរៀបចំតាក់តែងសេចក្តីព្រាងក្រមបរិស្ថាន និងធនធានធម្មជាតិនេះ ក្រសួងបរិស្ថាន បានបង្កើតក្រុមការងារចំនួន៤ ដូចខាងក្រោម៖

១- ក្រុមការងារតាក់តែងសេចក្តីព្រាងក្រមបរិស្ថានអន្តរក្រសួង

២- ក្រុមការងារបច្ចេកទេសតាក់តែងសេចក្តីព្រាងក្រមបរិស្ថាន

៣- លេខាធិការដ្ឋានអចិន្ត្រៃយ៍នៃក្រុមការងារបច្ចេកទេសតាក់តែងសេចក្តីព្រាងក្រមបរិស្ថាន

៤- ក្រុមការងារជំនាញបច្ចេកទេសតាក់តែសេចក្តីព្រាងក្រមបរិស្ថានចំនួន៧ មានជាអាទិ៍

ក្រុមការងារជំនាញនិរន្តរភាពទីក្រុង និងសេដ្ឋកិច្ចបៃតង ក្រុមការងារគ្រប់គ្រងសំណល់ និងការបំពុល ក្រុម

ការងារអភិរក្ស រុក្ខឧទ្យានសត្វព្រៃ និងជីវៈចម្រុះ ក្រុមការងារអភិរក្សបេតិកភណ្ឌ និងឧទ្យានធម្មជាតិ ក្រុមការងារគ្រប់គ្រងដីសើម និងអភិរក្សជីវៈចម្រុះទឹកសាប និងទឹកប្រៃ ក្រុមការងារគ្រប់គ្រង ការស្រាវជ្រាវ និងអាជីវកម្មរ៉ែ និងក្រុមការងារអភិរក្សកិច្ចការស្រាវជាវ អប់រំ និងផ្សព្វផ្សាយព័ត៌មានបរិស្ថាន ។

**ក្រុមការងារអន្តរក្រសួងទទួលបន្ទុកតាក់តែងសេចក្ដីព្រាងក្រមបរិស្ថានអន្តរក្រសួង** មានភារកិច្ច និងតួនាទីសម្របសម្រួលការងារពាក់ព័ន្ធនឹងដំណើរការនៃការសម្រេចចិត្តធំៗ ពាក់ព័ន្ធនឹងវិស័យបរិស្ថាន និងធនធានធម្មជាតិ ជាពិសេស ក្នុងករណីមានការខ្វែងគំនិតគ្នាក្នុងការបែងចែកសមត្ថកិច្ចគ្រប់គ្រងនានាលើធនធានធម្មជាតិ ។

**ក្រុមការងារបច្ចេកទេសតាក់តែងសេចក្ដីព្រាងក្រមបរិស្ថាន** ដើរតួនាទីយ៉ាងសំខាន់ក្នុងការរៀបចំការងារសម្របសម្រួលផ្នែកខ្លឹមសារបច្ចេកទេស ដែលសមាសភាពសមាជិកចម្រុះពីក្រសួង ស្ថាប័នរដ្ឋពាក់ព័ន្ធ ដែលសុទ្ធតែជាមន្ត្រីជំនាញបច្ចេកទេស ។

**លេខាធិការដ្ឋានអចិន្ត្រៃយ៍នៃក្រុមការងារតាក់តែងសេចក្ដីព្រាងក្រមបរិស្ថាន** មានតួនាទីយ៉ាងសំខាន់ក្នុងការសម្របសម្រួលការងាររបស់ក្រុមការងារជំនាញបច្ចេកទេស នៃក្រុមការងារតាក់តែងសេចក្ដីព្រាងក្រមបរិស្ថាន និងធនធានធម្មជាតិ ដែលមានសមាសភាពជាមេធាវី ចៅក្រមសាលាឧទ្ធរណ៍ និងអ្នកជំនាញការបច្ចេកទេសជាតិ និងអន្តរជាតិ ដែលទទួលបន្ទុកលើការងារតាក់តែងសេចក្ដីព្រាងក្រមបរិស្ថានឱ្យមានលក្ខណៈជាបច្ចេកទេសច្បាប់ ស្របតាមបរិបទនៃព្រះរាជាណាចក្រកម្ពុជា ។

**ក្រុមការងារជំនាញទាំង៧នៃក្រុមការងារតាក់តែងសេចក្ដីព្រាងក្រមបរិស្ថាន** គឺក្រុមការងារបឋម ដែលមានសមាជិកចម្រុះ ក្នុងនោះមានសមាជិកពីក្រសួងបរិស្ថាន ក្រសួងស្ថាប័នពាក់ព័ន្ធ វិស័យឯកជន និងអង្គការសង្គមស៊ីវិលជាតិ និងអន្តរជាតិ ។ ក្រុមការងារជំនាញនេះ ដើរតួនាទីចម្បងក្នុងការស្រាវជ្រាវ និងប្រមូលមតិយោបល់ពីគ្រប់ភាគីពាក់ព័ន្ធ ដើម្បីចងក្រងជាទិដ្ឋភាពរួមនៃគោលការណ៍បច្ចេកទេស និងបទពិសោធន៍នានាពាក់ព័ន្ធនឹងការអនុវត្តជាក់ស្ដែង ដែលជាបញ្ហាប្រឈម ដែលត្រូវយកមកដោះស្រាយ ដោយបទប្បញ្ញត្តិនៃសេចក្ដីព្រាងក្រមបរិស្ថាន និងធនធានធម្មជាតិ ។

ជាការកត់សម្គាល់ **ក្រុមមេធាវី វិស្ត្រ** គឺជាស្ថាប័នឯកជនតែមួយគត់ ដែលជាអ្នកប្រមូលយកមតិយោបល់ជាតុចូល និងអានុសាសន៍ទាំងអស់ ដែលទទួលបានពីក្រុមការងារជំនាញបច្ចេកទេសទាំង៧ខាងលើ និងមតិយោបល់ពីសិក្ខាសាលាពិគ្រោះយោបល់ជាច្រើនលើក ដើម្បីយកមករៀបចំតាក់តែង និងកែសម្រួលឱ្យចេញជារូបរាងនៃសេចក្ដីព្រាងក្រមបរិស្ថាន និងធនធានធម្មជាតិទាំងស្រុង តាំងពីសេចក្ដីព្រាងលើកទី១ ដែលបានចាប់ផ្ដើមក្នុងឆ្នាំ២០១៥ រហូតដល់សេចក្ដីព្រាងទី១០ ឆ្នាំ២០១៨នេះ ។ ក្នុងនោះដែរ ក្រុមការងារបច្ចេកនៃក្រុមមេធាវី វិស្ត្រ មានសមាសភាពជាអាទិ៍ មេធាវី មន្ត្រីច្បាប់ ចៅក្រមជំនាញមកពីសាលាឧទ្ធរណ៍ និងអ្នកជំនាញការអន្តរជាតិ ដែលជាអ្នករៀបចំ កែសម្រួលសេចក្ដីព្រាងក្រមនេះ ។ សេចក្ដីព្រាងលើកទី១០នៃក្រមនេះ បានធ្វើឡើងបន្ទាប់ពីបានដាក់បញ្ចូល

មតិយោបល់ដែលទទួលបានពីក្រុមការងារបច្ចេកទេស កម្មវិធីអង្គការសហប្រជាជាតិដើម្បីអភិវឌ្ឍន៍ ដែលហៅកាត់ថា"UNDP" និងរដ្ឋបាលថ្នាក់ក្រោមជាតិដែលពាក់ព័ន្ធដទៃទៀត ។

ក្រោយពីទទួលបានមតិយោបល់ និងធាតុចូលពីក្រសួង ស្ថាប័នពាក់ព័ន្ធ ក្រុមការងារនៃក្រុមមេធាវីវិស្ថ និងក្រុមការងារជំនាញបច្ចេកទេសរបស់ក្រសួងបរិស្ថាន បានសហការគ្នាក្នុងការពិនិត្យ និងដាក់បញ្ចូល នូវមតិយោបល់ និងធាតុចូលទាំងនោះ ទៅក្នុងសេចក្តីព្រាងលើកទី១០ នៃសេចក្តីព្រាងក្រមបរិស្ថាន និងធនធានធម្មជាតិ រហូតមកដល់ថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០១៨ ទើបសេចក្តីព្រាងលើកទី១០នេះសម្រេចបានជាផលផ្លែគួរឱ្យកត់សម្គាល់។ សម្រាប់សេចក្តីព្រាងលើកទី១០ផងដែរ ក្រសួងបរិស្ថានគ្រោងនឹងដាក់បញ្ជូនទៅក្រសួង ស្ថាប័ន ពាក់ព័ន្ធ ដើម្បីផ្តល់មតិយោបល់ និងធាតុចូលបន្ថែមទៀត ។

ក្រោយពីទទួលបានមតិយោបល់ និងធាតុចូល ពី ក្រសួង ស្ថាប័នពាក់ព័ន្ធ ក្រុមការងារនៃក្រុមមេធាវីវិស្ថ និងក្រុមការងារជំនាញរបស់ក្រសួងបរិស្ថាន គ្រោងនឹងដាក់បញ្ចូលមតិយោបល់ និងធាតុចូលទាំងនោះ ដើម្បីបង្កើតជាសេចក្តីព្រាងលើកទី១១ ។

# មាតិកា

**គន្លឹះទី១ បទប្បញ្ញត្តិទូទៅ**..........១
មាតិកាទី១ បទប្បញ្ញត្តិទូទៅ..........១
ជំពូកទី១ បទប្បញ្ញត្តិទូទៅ..........១
ជំពូកទី២ គោលការណ៍ទូទៅ..........២
ជំពូកទី៣ សមត្ថកិច្ចក្រសួង ស្ថាប័នពាក់ព័ន្ធនឹងបរិស្ថាន និងគ្រប់គ្រងធនធានធម្មជាតិ..........៥
មាតិកាទី២ ការចូលរួមជាសាធារណៈ..........៦
ជំពូកទី១ បទប្បញ្ញត្តិទូទៅ..........៦
ជំពូកទី២ ការចូលរួមជាសាធារណៈរបស់សហគមន៍ជនជាតិដើមភាគតិច..........៨
ជំពូកទី៣ វិធានការកាត់បន្ថយផលប៉ះពាល់..........៩
មាតិកាទី៣ សិទ្ធិទទួលបានព័ត៌មានបរិស្ថាន..........១០
ជំពូកទី១ បទប្បញ្ញត្តិទូទៅ..........១១
ជំពូកទី២ ការផ្តល់ព័ត៌មានដោយរាជរដ្ឋាភិបាល..........១៣
ផ្នែកទី១ ការផ្តល់ព័ត៌មានជាសាធារណៈ..........១៣
ផ្នែកទី២ បញ្ជីព័ត៌មានបរិស្ថានជាតិ..........១៤
ផ្នែកទី៣ មជ្ឈមណ្ឌលផែនទីបរិស្ថានជាតិ..........១៥
ផ្នែកទី៤ បញ្ជីលិខិតអនុញ្ញាតថ្នាក់ជាតិ..........១៦
ផ្នែកទី៥ បញ្ជីសវនកម្មបរិស្ថានថ្នាក់ជាតិ..........១៧
ជំពូកទី៣ ព័ត៌មានសម្ងាត់..........១៨
ជំពូកទី៤ ការស្នើសុំព័ត៌មាន..........១៩
**គន្លឹះទី២ ការវាយតម្លៃ និងការអង្កេតតាមដានបរិស្ថាន**..........២០
មាតិកាទី១ ការវាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្រ..........២០
ជំពូកទី១ បទប្បញ្ញត្តិទូទៅ..........២០
ជំពូកទី២ ដំណើរការវាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្រ..........២១
ជំពូកទី៣ ការចូលរួមជាសាធារណៈក្នុងនីតិវិធីនៃការវាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្រ..........២៣

ជំពូកទី៤ ការអនុវត្តការរៀបចំរបាយការណ៍វាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្រចំពោះគោលនយោបាយ ផែនការ និងកម្មវិធី ............ ២៤
មាតិកាទី២ ការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន............ ២៥
ជំពូកទី១ បទប្បញ្ញត្តិទូទៅ............ ២៥
ផ្នែកទី១ ក្របខ័ណ្ឌ និងវិសាលភាព ............ ២៥
ផ្នែកទី២ ការហាមឃាត់ចំពោះសកម្មភាពដែលមិនបានធ្វើការវាយតម្លៃបរិស្ថាន ............ ២៦
ជំពូកទី២ ប្រព័ន្ធវាយតម្លៃបរិស្ថាន ............ ២៧
ផ្នែកទី១ ក្រសួង ស្ថាប័នទទួលបន្ទុក............ ២៧
ផ្នែកទី២ គណៈកម្មាធិការជំនាញត្រួតពិនិត្យ ............ ២៩
ផ្នែកទី៣ ម្ចាស់គម្រោង ............ ៣០
ផ្នែកទី៤ ទីប្រឹក្សាវាយតម្លៃហេតុប៉ះពាល់បរិស្ថាន............ ៣២
ផ្នែកទី៥ ស្ថាប័នហិរញ្ញវត្ថុ ............ ៣៤
ជំពូកទី៣ កិច្ចដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន............ ៣៤
ផ្នែកទី១ ការវាយតម្លៃហេតុប៉ះពាល់បរិស្ថានចំពោះគម្រោងស្នើសុំ ............ ៣៤
ផ្នែកទី២ ការកំណត់វិសាលភាព............ ៣៦
ផ្នែកទី៣ ការសិក្សា និងការរៀបចំរបាយការណ៍ ............ ៣៧
ផ្នែកទី៤ ការវាយតម្លៃទៅលើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង ឬពេញលេញ និងកិច្ចសន្យាការពារបរិស្ថាន ............ ៣៩
ជំពូកទី៤ ការកំណត់រយៈពេលសម្រាប់នីតិវិធីនៃការពិនិត្យ និងផ្តល់យោបល់លើការវាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង ឬពេញលេញ និងកិច្ចសន្យាការពារបរិស្ថាន............ ៤២
ជំពូកទី៥ ការពិចារណាជាពិសេសនៅក្នុងប្រព័ន្ធវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ............ ៤៥
ផ្នែកទី១ ការវាយតម្លៃហេតុប៉ះពាល់បរិស្ថានចំពោះគម្រោងដែលមានស្រាប់ និងកំពុងដំណើរការ ... ៤៥
ផ្នែកទី២ ការវាយតម្លៃហេតុប៉ះពាល់ជាក់លាក់............ ៤៥
ផ្នែកទី៣ ជនជាតិដើមភាគតិច និងការផ្លាស់ទីលំនៅថ្មីដោយមិនស្ម័គចិត្ត............ ៤៨
ជំពូកទី៦ ការធ្វើបច្ចុប្បន្នភាពផែនការគ្រប់គ្រងបរិស្ថាន............ ៤៩
មាតិកាទី៣ សវនកម្មបរិស្ថាន ការអង្កេតតាមដាន និងការរៀបចំរបាយការណ៍ ............ ៥០
ជំពូកទី១ សវនកម្មបរិស្ថាន ............ ៥០

ជំពូកទី២ ការរៀបចំរបាយការណ៍ និងការអង្កេតតាមដានបរិស្ថាន ការគ្រប់គ្រងបរិស្ថាន និងយន្តការចីរភាព ......................................................................................................................... ៥២
**គន្លឹះទី៣ ការគ្រប់គ្រងបរិស្ថាន និងយន្តការចីរភាព** .......................................................... ៥៤
មាតិកាទី១ ការកាត់បន្ថយ និងការគ្រប់គ្រងហានិភ័យគ្រោះមហន្តរាយ ........................................ ៥៤
មាតិកាទី២ ការប្រែប្រួលអាកាសធាតុ........................................................................................ ៥៦
ជំពូកទី១ បទប្បញ្ញត្តិទូទៅ........................................................................................ ៥៦
ជំពូកទី២ គោលនយោបាយ យុទ្ធសាស្ត្រ ផែនការឆ្លើយតបចំពោះការប្រែប្រួលអាកាសធាតុ................. ៥៧
ជំពូកទី៣ ការអនុវត្តការឆ្លើយតបចំពោះការប្រែប្រួលអាកាសធាតុ.............................................. ៥៩
ជំពូកទី៤ ការអង្កេតតាមដាន និងការវាយតម្លៃការឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុ................ ៦១
ជំពូកទី៥ ព័ត៌មានស្ដីពីការប្រែប្រួលអាកាសធាតុ ....................................................................... ៦៤
ជំពូកទី៦ ក្របខ័ណ្ឌហិរញ្ញប្បទានសម្រាប់ការប្រែប្រួលអាកាសធាតុ............................................... ៦៧
ផ្នែកទី១ ថវិកាថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិសម្រាប់ការប្រែប្រួលអាកាសធាតុ.......................... ៦៨
ផ្នែកទី២ ការវិនិយោគដែលគិតគូរចំពោះការប្រែប្រួលអាកាសធាតុពីវិស័យឯកជន ..................... ៦៩
ផ្នែកទី៣ ការកៀងគរហិរញ្ញប្បទានការប្រែប្រួលអាកាសធាតុពីបរទេស.................................... ៦៩
ផ្នែកទី៤ ការលើកកម្ពស់យន្តការទូទាត់ថ្លៃលក់កាបូន............................................................ ៧០
មាតិកាទី៣ ផលិតកម្ម និងការប្រើប្រាស់ដោយចីរភាព............................................................. ៧១
ជំពូកទី១ បទប្បញ្ញត្តិទូទៅ........................................................................................ ៧១
ជំពូកទី២ ការលើកកម្ពស់ផលិតកម្ម និងការប្រើប្រាស់ដោយចីរភាព ........................................... ៧១
ជំពូកទី៣ លទ្ធកម្មដោយចីរភាព.................................................................................. ៧៤
មាតិកាទី៤ ការរៀបចំផែនការប្រើប្រាស់ដីដែលយកចិត្តទុកដាក់ដល់បរិស្ថាន និងទីក្រុងដោយចីរភាព............ ៧៧
ជំពូកទី១ បទប្បញ្ញត្តិទូទៅ........................................................................................ ៧៧
ជំពូកទី២ ការរៀបចំផែនការប្រើប្រាស់ដីដែលយកចិត្តទុកដាក់ដល់បរិស្ថាន ...................................... ៧៩
ផ្នែកទី១ ការរៀបចំផែនការប្រើប្រាស់ដីដែលយកចិត្តទុកដាក់ដល់បរិស្ថាន ...................................... ៧៩
ផ្នែកទី២ លក្ខខណ្ឌតម្រូវឱ្យមានការរៀបចំផែនការប្រើប្រាស់ដីដែលយកចិត្តទុកដាក់ដល់បរិស្ថាន....... ............................................................................................................ ៨២
ជំពូកទី៣ ទីក្រុងដោយចីរភាព .................................................................................... ៨៣
មាតិកាទី៥ ថាមពលដោយចីរភាព ............................................................................................ ៨៥

ជំពូកទី១ ថាមពលដោយចីរភាព ........ ៨៥
ជំពូកទី២ ការរៀបចំផែនការចីរភាពថាមពល ........ ៨៧
ជំពូកទី៣ ការលើកកម្ពស់បច្ចេកវិទ្យាមេត្រីបរិស្ថាន ........ ៨៩
ជំពូកទី៤ ការត្រួតពិនិត្យគុណភាពឧបករណ៍ផលិតថាមពលដោយចីរភាព ........ ៩១
ជំពូកទី៥ ការលើកទឹកចិត្តការប្រើប្រាស់ថាមពលពន្លឺព្រះអាទិត្យ ........ ៩២
ជំពូកទី៦ ប្រភពថាមពលផ្សេងទៀត ........ ៩២
មាតិកាទី៦ ឧស្សាហកម្មនិស្សារណកម្ម ........ ៩៣
ជំពូកទី១ ការរៀបចំផែនការបរិស្ថានសម្រាប់ឧស្សាហកម្មនិស្សារណកម្ម ........ ៩៣
ជំពូកទី២ បច្ចេកវិទ្យាល្អបំផុតដែលអាចស្វែងរកបានសម្រាប់ឧស្សាហកម្មនិស្សារណកម្ម ........ ៩៦
ជំពូកទី៣ ការប្រើប្រាស់ស្យានីត និងបារត នៅក្នុងការធ្វើអាជីវកម្មរ៉ែមាស និងប្រាក់ ........ ៩៧
ជំពូកទី៤ ការលាតត្រដាងព័ត៌មាន ........ ៩៩
**គន្ថីទី៤ ការគ្រប់គ្រងធនធានធម្មជាតិដោយចីរភាព** ........ ៩៩
មាតិកាទី១ ប្រព័ន្ធតំបន់ការពារធម្មជាតិ ........ ៩៩
ជំពូកទី១ ការរៀបចំប្រព័ន្ធតំបន់ការពារធម្មជាតិ ........ ៩៩
ជំពូកទី២ ការកំណត់អត្តសញ្ញាណ និងការវាយតម្លៃប្រព័ន្ធអេកូឡូស៊ី ........ ១០៣
ជំពូកទី៣ ការបង្កើតតំបន់ ........ ១០៥
ជំពូកទី៤ ការគ្រប់គ្រង ........ ១០៨
មាតិកាទី២ ការគ្រប់គ្រងរួមគ្នាលើធនធានធម្មជាតិ ........ ១១៣
ជំពូកទី១ ការរៀបចំយន្តការគ្រប់គ្រងរួមគ្នា ........ ១១៣
ជំពូកទី២ នីតិវិធីបង្កើតការគ្រប់គ្រងរួមគ្នា ........ ១១៤
ជំពូកទី៣ ការអនុវត្តការគ្រប់គ្រងរួមគ្នា ........ ១១៧
ជំពូកទី៤ រយៈពេលនៃការគ្រប់គ្រងរួមគ្នា និងសិទ្ធិដីធ្លី ........ ១១៨
ជំពូកទី៥ បទប្បញ្ញត្តិស្ដីពីហិរញ្ញវត្ថុនៃការគ្រប់គ្រងរួមគ្នា ........ ១២០
មាតិកាទី៣ ការគ្រប់គ្រងព្រៃឈើដោយចីរភាព ........ ១២១
ជំពូកទី១ បទប្បញ្ញត្តិទូទៅ ........ ១២១
ជំពូកទី២ ការរៀបចំផែនការគ្រប់គ្រងព្រៃឈើដោយចីរភាព ........ ១២៣
ជំពូកទី៣ លិខិតអនុញ្ញាត ........ ១២៧

មាតិកាទី៤ កិច្ចគាំពារ ការអភិរក្ស និងការគ្រប់គ្រងសត្វ និងរុក្ខជាតិព្រៃ ............................................ ១៣០
ជំពូកទី១ បទប្បញ្ញត្តិទូទៅ........................................................................................ ១៣០
ជំពូកទី២ ការធ្វើចំណាត់ថ្នាក់ប្រភេទសត្វ និងរុក្ខជាតិព្រៃ..................................................... ១៣១
ជំពូកទី៣ ផែនការគ្រប់គ្រង និងស្តារប្រភេទសត្វ និងរុក្ខជាតិព្រៃឡើងវិញ ការអង្កេតតាមដាន និងការរៀបចំរបាយការណ៍........................................................................................ ១៣៥
ជំពូកទី៤ ការគ្រប់គ្រងប្រភេទសត្វ និងរុក្ខជាតិព្រៃដែលរាតត្បាត........................................... ១៣៦
ជំពូកទី៥ ការបរបាញ់ ការប្រមូលយក និងការធ្វើពាណិជ្ជកម្ម................................................ ១៣៧
ជំពូកទី៦ ការគ្រប់គ្រងសត្វព្រៃ ............................................................................ ១៤៣
ផ្នែកទី១ ការអង្កេតតាមដានសុខភាពសត្វព្រៃ ....................................................... ១៤៣
ផ្នែកទី២ ការសម្រេចឱ្យសម្លាប់សត្វព្រៃ.............................................................. ១៤៤
ផ្នែកទី៣ ការប្តូរទីតាំង និងការចាប់សត្វព្រៃទាំងរស់ ............................................... ១៤៥
ជំពូកទី៧ ការគ្រប់គ្រង និងការចាត់ចែងវត្ថុតាងសត្វ និងរុក្ខជាតិព្រៃ......................................... ១៤៥
ជំពូកទី៨ ការគ្រប់គ្រងទីកន្លែងរក្សាសត្វព្រៃដែលនៅក្រៅទីជម្រកធម្មជាតិ ................................. ១៤៧
ផ្នែកទោល បទប្បញ្ញត្តិទូទៅ................................................................................ ១៤៧
ជំពូកទី៩ ការគ្រប់គ្រងកសិដ្ឋានចិញ្ចឹមសត្វព្រៃ.......................................................... ១៥០
ជំពូកទី១០ ការគ្រប់គ្រងសំណាកសត្វ និងរុក្ខជាតិព្រៃដែលរឹបអូសបាន .................................... ១៥២
ជំពូកទី១១ កិច្ចសហប្រតិបត្តិការអន្តរជាតិ .................................................................. ១៥៤
មាតិកាទី៥ ការគ្រប់គ្រងតំបន់ឆ្នេរ ........................................................................... ១៥៥
ជំពូកទោល បទប្បញ្ញត្តិទូទៅ .............................................................................. ១៥៥
មាតិកាទី៦ ការគ្រប់គ្រងធនធានទឹកដោយចីរភាព ............................................................ ១៥៨
ជំពូកទី១ បទប្បញ្ញត្តិទូទៅ.................................................................................... ១៥៨
ផ្នែកទី១ វិសាលភាព និងគោលការណ៍.................................................................... ១៥៨
ផ្នែកទី២ ម្ចាស់កម្មសិទ្ធិលើទឹក និងធនធានទឹក .......................................................... ១៥៩
ជំពូកទី២ ការទទួលខុសត្រូវធនធានទឹក ..................................................................... ១៦០
ផ្នែកទី១ ការទទួលខុសត្រូវរបស់ក្រសួង ស្ថាប័នមានសមត្ថកិច្ច............................................. ១៦០
ផ្នែកទី២ ការសម្របសម្រួលរបស់រាជរដ្ឋាភិបាល.......................................................... ១៦២
ជំពូកទី៣ ការរៀបចំផែនការធនធានទឹក...................................................................... ១៦៣

ផ្នែកទី១ ក្រសួង ស្ថាប័នទទួលបន្ទុក........................................................................ ១៦៣
ផ្នែកទី២ ផែនការយុទ្ធសាស្ត្រជាតិធនធានទឹក........................................................................ ១៦៥
ផ្នែកទី៣ ផែនការធនធានទឹកអាងទន្លេ........................................................................ ១៦៦
ជំពូកទី៤ ការចេញលិខិតអនុញ្ញាត........................................................................ ១៧២
ផ្នែកទី១ បទប្បញ្ញត្តិទូទៅ........................................................................ ១៧២
ផ្នែកទី២ លិខិតអនុញ្ញាតហេដ្ឋារចនាសម្ព័ន្ធ........................................................................ ១៧៤
ផ្នែកទី៣ សិទ្ធិទទួលបានទឹក........................................................................ ១៧៥
ផ្នែកទី៤ ការការពារទន្លេ និងស្ទឹង........................................................................ ១៧៨
ផ្នែកទី៥ អ្នកអភិវឌ្ឍទឹកក្រោមដី........................................................................ ១៧៩
ផ្នែកទី៦ ការដកហូតការអនុញ្ញាត........................................................................ ១៨១
ជំពូកទី៥ ការតម្រូវឲ្យមានការអនុញ្ញាត........................................................................ ១៨១
ជំពូកទី៦ ការរៀបចំផែនការធនធានទឹកអាងទន្លេអន្តរកាល........................................................................ ១៨២
**គន្ថីទី៥ ការអភិរក្ស និងការគ្រប់គ្រងបេតិកភណ្ឌវប្បធម៌ និងបេតិកភណ្ឌធម្មជាតិ** ............. ១៨៣
មាតិកាទោល ការអភិរក្ស និងការគ្រប់គ្រងបេតិកភណ្ឌវប្បធម៌ និងបេតិកភណ្ឌធម្មជាតិ ........................... ១៨៣
ជំពូកទី១ បទប្បញ្ញត្តិទូទៅ........................................................................ ១៨៣
ជំពូកទី២ ការគ្រប់គ្រងបេតិកភណ្ឌវប្បធម៌........................................................................ ១៨៧
ផ្នែកទី១ ក្រសួង ស្ថាប័នមានសមត្ថកិច្ច........................................................................ ១៨៧
ផ្នែកទី២ ក្រុមប្រឹក្សាជាន់ខ្ពស់ផ្នែកវប្បធម៌ជាតិ........................................................................ ១៨៨
ជំពូកទី៣ ការគ្រប់គ្រងបេតិកភណ្ឌធម្មជាតិ........................................................................ ១៩០
ជំពូកទី៤ បញ្ជីបេតិកភណ្ឌវប្បធម៌ជាតិ........................................................................ ១៩២
ជំពូកទី៥ ការធ្វើចំណាត់ថ្នាក់បេតិកភណ្ឌវប្បធម៌........................................................................ ១៩៣
ជំពូកទី៦ ការរៀបចំបង្កើតតំបន់ការពារបេតិកភណ្ឌវប្បធម៌........................................................................ ១៩៣
ជំពូកទី៧ ការបង្កើតតំបន់បេតិកភណ្ឌទីក្រុង........................................................................ ១៩៥
ជំពូកទី៨ កិច្ចការពារបេតិកភណ្ឌវប្បធម៌ជាតិ........................................................................ ១៩៧
ផ្នែកទោល ការប្រទះឃើញដោយចៃដន្យនូវសម្បត្តិវប្បធម៌........................................................................ ១៩៧
ជំពូកទី៩ ការធ្វើកំណាយ........................................................................ ១៩៨
ជំពូកទី១០ កំណាយបង្ការ........................................................................ ១៩៩

ជំពូកទី១១ កិច្ចការពារបេតិកភណ្ឌវប្បធម៌ក្រោមទឹក........................................................................ ២០១
ផ្នែកទោល លិខិតអនុញ្ញាតសម្រាប់គម្រោងអភិវឌ្ឍដែលបង្កផលប៉ះពាល់ដល់បេតិកភណ្ឌវប្បធម៌
..............................................................................................................................២០៣
ជំពូកទី១២ ការដោះស្រាយវិវាទ និងបទបញ្ជាបន្ទាន់..........................................................................២០៣
ជំពូកទី១៣ ការលើកកម្ពស់ និងការការពារបេតិកភណ្ឌវប្បធម៌អរូបិយ............................................ ២០៤
ជំពូកទី១៤ ការអប់រំ និងការយល់ដឹង .................................................................................................. ២០៥
ជំពូកទី១៥ បទប្បញ្ញត្តិប្រឆាំងនឹងការជួញដូរសម្បត្តិវប្បធម៌ ............................................................ ២០៦
**គន្ថីទី៦ ការគ្រប់គ្រងសំណល់ និងការបំពុលបរិស្ថាន**............................................................................២០៧
មាតិកាទី១ កាតព្វកិច្ចទូទៅចំពោះការត្រួតពិនិត្យការបំពុលបរិស្ថាន........................................................២០៧
ជំពូកទី១ ការហាមឃាត់ការបំពុលបរិស្ថាន........................................................................................២០៧
ជំពូកទី២ លិខិតអនុញ្ញាត........................................................................................................................២០៧
មាតិកាទី២ ស្តង់ដារបរិស្ថាន ............................................................................................................... ២០៨
ជំពូកទី១ បទប្បញ្ញត្តិទូទៅ...................................................................................................................... ២០៨
ជំពូកទី២ ការអនុវត្តស្តង់ដារបរិស្ថាន ................................................................................................. ២០៩
ជំពូកទី៣ ស្តង់ដារបរិស្ថានដែលនៅជាធរមាន ..................................................................................... ២១០
មាតិកាទី៣ ការគ្រប់គ្រងសារធាតុគ្រោះថ្នាក់ ...................................................................................... ២១១
ជំពូកទី១ បទប្បញ្ញត្តិទូទៅ...................................................................................................................... ២១១
ជំពូកទី២ ការហាមឃាត់សារធាតុគ្រោះថ្នាក់ .........................................................................................២១២
ជំពូកទី៣ ការចុះបញ្ជី និងការបង្ហាញព័ត៌មានអំពីសារធាតុគ្រោះថ្នាក់ ............................................. ២១៥
ជំពូកទី៤ ការដាក់ស្លាកសញ្ញាសារធាតុគ្រោះថ្នាក់............................................................................... ២១៨
ជំពូកទី៥ ការដឹកជញ្ជូន ការប្រើប្រាស់ និងការបោះបង់ចោលសារធាតុគ្រោះថ្នាក់ ............................ ២១៨
ជំពូកទី៦ សុវត្ថិភាពនៃសារធាតុគ្រោះថ្នាក់ ការទប់ស្កាត់គ្រោះថ្នាក់ ការត្រៀមលក្ខណៈ និងការឆ្លើយតបជាបន្ទាន់............................................................................................................................................. ២២១
មាតិកាទី៤ ការគ្រប់គ្រងសំណល់.............................................................................................................២២៣
ជំពូកទី១ បទប្បញ្ញត្តិទូទៅ.......................................................................................................................២២៣
ជំពូកទី២ ការធ្វើចំណាត់ថ្នាក់សំណល់.....................................................................................................២២៤
ជំពូកទី៣ ការគ្រប់គ្រងសំណល់រឹង.......................................................................................................... ២២៥

ជំពូកទី៤ ការគ្រប់គ្រងសំណល់គ្រោះថ្នាក់ ........ ២២៦
មាតិកាទី៥ ការត្រួតពិនិត្យការបំពុលទឹក ........ ២២៦
ជំពូកទី១ បទប្បញ្ញត្តិទូទៅ........ ២២៦
ជំពូកទី២ ការអង្កេតតាមដាន និងការត្រួតពិនិត្យប្រភពបំពុលទឹកជាក់លាក់ ........ ២២៧
ជំពូកទី៣ ការត្រួតពិនិត្យប្រភពបំពុលទឹកមិនជាក់លាក់ ........ ២៣០
ជំពូកទី៤ ការប្រើប្រាស់សារឡើងវិញនូវទឹកកខ្វក់ និងសំណល់........ ២៣០
ជំពូកទី៥ ការត្រួតពិនិត្យការបំពុលសមុទ្រ........ ២៣២
មាតិកាទី៦ ការត្រួតពិនិត្យការបំពុលខ្យល់ ........ ២៣២
ជំពូកទី១ បទប្បញ្ញត្តិទូទៅ........ ២៣២
ជំពូកទី២ ការបំពុលខ្យល់ពីប្រភពចល័ត ........ ២៣៣
ជំពូកទី៣ ការបំពុលខ្យល់ពីប្រភពអចល័ត........ ២៣៥
ជំពូកទី៤ លិខិតអនុញ្ញាតក្នុងការបញ្ចេញសារធាតុបំពុលខ្យល់ពីប្រភពអចល័ត ........ ២៣៧
ជំពូកទី៥ ការគ្រប់គ្រង និងការត្រួតពិនិត្យគុណភាពបរិយាកាស ........ ២៤០
ជំពូកទី៦ ការផ្តល់វិញ្ញាបនបត្រឱ្យប្រតិបត្តិករ ........ ២៤៣
ជំពូកទី៧ ការបំពុលខ្យល់ឆ្លងដែន........ ២៤៣
ជំពូកទី៨ សារធាតុបំផ្លាញស្រទាប់អូហ្សូន ........ ២៤៤
មាតិកាទី៧ ការត្រួតពិនិត្យសំឡេង និងរំញ័រ........ ២៤៥
ជំពូកទី១ បទប្បញ្ញត្តិទូទៅ........ ២៤៥
ជំពូកទី២ ការគ្រប់គ្រងសំឡេង និងរំញ័រ ........ ២៤៥
មាតិកាទី៨ ការស្តារឡើងវិញនូវទីតាំងដែលទទួលរងការបំពុល ........ ២៤៦
ជំពូកទី១ បទប្បញ្ញត្តិទូទៅ........ ២៤៦
ជំពូកទី២ ការកំណត់អត្តសញ្ញាណ និងការសិក្សាទីតាំងបំពុល........ ២៤៨
ជំពូកទី៣ ការស្តារឡើងវិញ និងការអង្កេតតាមដាន ........ ២៤៩
មាតិកាទី៩ ប្រព័ន្ធថ្នាក់ជាតិស្តីពីសារធាតុបំពុលដែលសាយភាយ និងផ្លាស់ទី ........ ២៥០
ជំពូកទី១ បទប្បញ្ញត្តិទូទៅ........ ២៥០
ជំពូកទី២ ការគ្រប់គ្រងប្រព័ន្ធទិន្នន័យជាតិស្តីពីការសាយភាយ និងការបំលាស់ទីសារធាតុបំពុល........ ២៥១
**គន្ថីទី៧ ការអប់រំ ស្រាវជ្រាវ និងយល់ដឹងពីបរិស្ថាន** ........ ២៥២

មាតិកាទោល ការអប់រំ ស្រាវជ្រាវ និងយល់ដឹងពីបរិស្ថាន ........ ២៥២
ជំពូកទី១ គោលនយោបាយ និងយុទ្ធសាស្ត្រអប់រំបរិស្ថាន ........ ២៥២
ជំពូកទី២ ការអប់រំ និងបណ្តុះបណ្តាលបរិស្ថាន ........ ២៥៤
ជំពូកទី៣ បណ្ឌិតសភាជាតិអប់រំ និងស្រាវជ្រាវបរិស្ថាន និងធនធានធម្មជាតិ ........ ២៥៥
ជំពូកទី៤ ការអប់រំបរិស្ថានក្នុងប្រព័ន្ធអប់រំ ........ ២៥៧
ជំពូកទី៥ ការលើកកម្ពស់ការយល់ដឹងពីបរិស្ថាន ........ ២៥៨
ជំពូកទី៦ ការស្រាវជ្រាវ និងនវានុវត្តន៍ ........ ២៦០
ជំពូកទី៧ ការលើកទឹកចិត្តសកម្មភាពអប់រំបរិស្ថាន ........ ២៦២
ជំពូកទី៨ មូលនិធិអប់រំ និងស្រាវជ្រាវបរិស្ថាន ........ ២៦៣
ជំពូកទី៩ ក្របខណ្ឌប្រតិបត្តិការ និងសេចក្តីអនុញ្ញាត ........ ២៦៥
**គន្ថីទី៨ វិធានការសេដ្ឋកិច្ច គណនី ប្រាក់កម្រៃ និងមូលនិធិផ្នែកបរិស្ថាន** ........ ២៦៥
មាតិកាទី១ វិធានការសេដ្ឋកិច្ច គណនី ........ ២៦៦
ជំពូកទី១ វិធានការសេដ្ឋកិច្ច ........ ២៦៦
ជំពូកទី២ គណនី ........ ២៦៩
មាតិកាទី២ ប្រាក់កម្រៃ មូលនិធិ និងការគ្រប់គ្រងមូលនិធិបរិស្ថាន ........ ២៧០
ជំពូកទី១ ប្រាក់កម្រៃ សួយសារ និងបុព្វលាភបរិស្ថាន ........ ២៧០
ជំពូកទី២ ការបន្តមូលនិធិបរិស្ថានដែលមានស្រាប់ និងការគ្រប់គ្រងមូលនិធិ ........ ២៧១
ផ្នែកទី១ ការបន្តមូលនិធិបរិស្ថានដែលមានស្រាប់ ........ ២៧១
ផ្នែកទី២ មូលនិធិបរិស្ថាន និងសង្គម ........ ២៧២
ជំពូកទី៣ ការបង្កើត និងការគ្រប់គ្រងមូលនិធិបរិស្ថាន ........ ២៧៣
ផ្នែកទី១ មូលនិធិបរធនបាលកិច្ច ........ ២៧៣
ផ្នែកទី២ មូលនិធិសម្រាប់ការដោះស្រាយវិវាទបរិស្ថាន និងធនធានធម្មជាតិ ........ ២៨០
ផ្នែកទី៣ មូលនិធិសម្រាប់លំហាប៉ៃតង ........ ២៨១
ផ្នែកទី៤ ហិរញ្ញប្បទានសម្រាប់ផែនការគ្រប់គ្រងបរិស្ថាន ........ ២៨២
**គន្ថីទី៩ នីតិវិធីដោះស្រាយបណ្តឹងបរិស្ថាន និងធនធានធម្មជាតិ** ........ ២៨៤
មាតិកាទី១ នីតិវិធីដោះស្រាយបណ្តឹងបរិស្ថាន និងធនធានធម្មជាតិ ........ ២៨៤

ជំពូកទី១ ការដោះស្រាយបណ្តឹងបរិស្ថាននិងធនធានធម្មជាតិដែលមានលក្ខណៈរដ្ឋប្បវេណី និងរដ្ឋបាល...... ............ ២៨៤
ផ្នែកទី១ បណ្តឹងបរិស្ថាន និងធនធានធម្មជាតិ............ ២៨៤
ផ្នែកទី២ ភាគីនៃបណ្តឹងបរិស្ថាន និងធនធានធម្មជាតិ............ ២៨៦
ផ្នែកទី៣ ការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ............ ២៨៨
ផ្នែកទី៤ ការដោះស្រាយវិវាទបរិស្ថាន និងធនធានធម្មជាតិក្នុងប្រព័ន្ធតុលាការ............ ២៩៩
ជំពូកទី២ ការចាត់ចែងរក្សាការពារក្នុងរឿងក្តីបរិស្ថាន និងធនធានធម្មជាតិ ............ ៣០៤
ជំពូកទី៣ នីតិវិធីដោះស្រាយបទល្មើសបរិស្ថាន និងធនធានធម្មជាតិដែលមានចរិកលក្ខណៈព្រហ្មទណ្ឌ...... ............ ៣០៧
ផ្នែកទី១ នីតិវិធីនៃការស៊ើបអង្កេត ការស៊ើបសួរ ការចោទប្រកាន់ និងការជំនុំជម្រះ ............ ៣០៧
ផ្នែកទី២ ភស្តុតាងក្នុងរឿងក្តីបរិស្ថាន និងធនធានធម្មជាតិ ............ ៣០៨
មាតិកាទី២ មន្ត្រីនគរបាលយុត្តិធម៌បរិស្ថាននិងធនធានធម្មជាតិ និងមន្ត្រីអធិការកិច្ចបរិស្ថាន និងធនធានធម្មជាតិ..... ............ ៣១០
ជំពូកទី១ នគរបាលយុត្តិធម៌បរិស្ថាន និងធនធានធម្មជាតិ............ ៣១០
ជំពូកទី២ មន្ត្រីអធិការកិច្ចបរិស្ថាន និងធនធានធម្មជាតិ ............ ៣១៣
មាតិកាទី៣ ការស្តារឡើងវិញ និងសំណងលើការខូចខាតបរិស្ថាន ............ ៣១៤
ជំពូកទី១ យន្តការវាយតម្លៃទំហំនៃការខូចខាតបរិស្ថាន............ ៣១៤
ជំពូកទី២ ការទទួលខុសត្រូវបរិស្ថាន ............ ៣១៥
ជំពូកទី៣ ការមិនទទួលខុសត្រូវចំពោះការខូចខាតបរិស្ថាន ............ ៣១៦
ជំពូកទី៤ សំណងការខូចខាតបរិស្ថាន............ ៣១៧
ជំពូកទី៥ ការរៀបចំផែនការស្តារការខូចខាតបរិស្ថានឡើងវិញ ............ ៣១៩
ជំពូកទី៦ សិទ្ធិអំណាចនៃការចេញបទបញ្ជាផ្នែករដ្ឋបាល ............ ៣២១
ជំពូកទី៧ ការទាមទារមកវិញននូវថ្លៃចំណាយលើការស្តារការខូចខាតបរិស្ថានឡើងវិញ............ ៣២២
**គន្ថីទី១០ ទោសប្បញ្ញត្តិ**............ ៣២៣
មាតិកាទី១ បទប្បញ្ញត្តិទូទៅ............ ៣២៣
ជំពូកទោល ទណ្ឌកម្ម ............ ៣២៣
មាតិកាទី២ បទល្មើសពាក់ព័ន្ធនឹងបរិស្ថាន និងធនធានធម្មជាតិ............ ៣២៨

ជំពូកទី១ បទល្មើសពាក់ព័ន្ធនឹងការចូលរួមជាសាធារណៈ..........................................................៣២៨
ជំពូកទី២ បទល្មើសពាក់ព័ន្ធនឹងការវាយតម្លៃ និងការអង្កេតតាមដានបរិស្ថាន ..................................៣២៩
ជំពូកទី៣ បទល្មើសពាក់ព័ន្ធនឹងការគ្រប់គ្រងបរិស្ថាន និងយន្តការចីរភាព......................................៣៣៤
ជំពូកទី៤ បទល្មើសពាក់ព័ន្ធនឹងការគ្រប់គ្រងធនធានធម្មជាតិដោយចីរភាព ...................................៣៣៥
ជំពូកទី៥ បទល្មើសពាក់ព័ន្ធនឹងការអភិរក្ស និងការគ្រប់គ្រងបេតិកភណ្ឌវប្បធម៌ និងបេតិកភណ្ឌធម្មជាតិ....... ........................................................................................................................ ៣៤១
ជំពូកទី៦ បទល្មើសពាក់ព័ន្ធនឹងការគ្រប់គ្រងសំណល់ និងការបំពុល............................................ ៣៤៤
ជំពូកទី៧ បទល្មើសពាក់ព័ន្ធនឹងមន្ត្រីនគរបាលយុត្តិធម៌ និងមន្ត្រីអធិការកិច្ចបរិស្ថាន និងធនធានធម្មជាតិ...... .........................................................................................................................៣៥២
**គន្ថីទី១១ អន្តរប្បញ្ញតិ**.........................................................................................................៣៥២
ជំពូកទោល អន្តរប្បញ្ញត្តិ ..........................................................................................................៣៥២
**គន្ថីទី១២ អវសានប្បញ្ញត្តិ**.....................................................................................................៣៥៣
ជំពូកទោល អវសានប្បញ្ញត្តិ ......................................................................................................៣៥៣

# គន្ថីទី១
# បទប្បញ្ញត្តិទូទៅ
## មាតិកាទី១
## បទប្បញ្ញត្តិទូទៅ
### ជំពូកទី១
### បទប្បញ្ញត្តិទូទៅ

**មាត្រា១** ._ គោលបំណង

ក្រមនេះ មានគោលបំណង ធានាឱ្យមានការអភិវឌ្ឍដោយចីរភាព នៃព្រះរាជាណាចក្រកម្ពុជា តាមរយៈកិច្ចគាំពារបរិស្ថាន ការអភិរក្ស ការគ្រប់គ្រង និងការស្តារឡើងវិញនូវធនធានធម្មជាតិ និងបេតិកភណ្ឌជាតិ ។

**មាត្រា២** ._ គោលដៅ

ក្រមនេះ មានគោលដៅ ដូចខាងក្រោម ៖

១- ការពារបរិស្ថាន ដើម្បីបញ្ចៀស និងកាត់បន្ថយគ្រោះមហន្តរាយ និងការខូចខាតបរិស្ថាន ។

២- អភិរក្ស ការពារ គ្រប់គ្រង និងស្តារឡើងវិញនូវធនធានធម្មជាតិ ជីវៈចម្រុះ និងសេវាកម្មប្រព័ន្ធអេកូឡូស៊ី ។

៣- លើកកម្ពស់ភាពស៊ាំទៅនឹងការប្រែប្រួលអាកាសធាតុ ការអភិវឌ្ឍបៃតង ដែលមានប្រសិទ្ធភាពថាមពល និងការប្រើប្រាស់ធនធាន និងថាមពល ដោយចីរភាព ។

៤- ថែរក្សា ការពារ អភិរក្ស ស្តារឡើងវិញ និងលើកកម្ពស់សម្បត្តិបេតិកភណ្ឌជាតិនៃព្រះរាជាណាចក្រកម្ពុជា ។

៥- លើកកម្ពស់សុខុមាលភាពសង្គម ។

៦- លើកកម្ពស់ និងការពារសិទ្ធិបុគ្គលគ្រប់រូប និងសិទ្ធិសមូហភាព របស់ជនជាតិដើមភាគតិចក្នុងដំណើរការនៃការការពារ ការអភិរក្ស ការគ្រប់គ្រង និងការស្តារធនធានធម្មជាតិ ។

៧- លើកទឹកចិត្ត និងលើកកម្ពស់សិទ្ធិរបស់អង្គការជាតិ និងអន្តរជាតិ នៅក្នុងកិច្ចដំណើរការនៃការការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ ។

៨- ដាក់បញ្ចូលនូវការយកចិត្តទុកដាក់អំពីបរិស្ថាន និងធនធានធម្មជាតិ ទៅក្នុងការរៀបចំផែនការ និងការធ្វើសេចក្តីសម្រេច ថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ទាក់ទងនឹងការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គម ។

៩- លើកកម្ពស់ការចូលរួមដោយតម្លាភាពរបស់រាជរដ្ឋាភិបាល ជនជាតិដើមភាគតិច និងជនងាយរងគ្រោះ និងអ្នកពាក់ព័ន្ធដទៃទៀត ក្នុងកិច្ចគាំពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ ។

១០- លើកកម្ពស់ការទទួលខុសត្រូវផ្នែកបរិស្ថានជាលក្ខណៈអន្តរជាតិរបស់ព្រះរាជាណាចក្រកម្ពុជា ។

១១- ពង្រឹងការអនុវត្តលិខិតតូបករណ៍គតិយុត្តអន្តរជាតិ ដែលព្រះរាជាណាចក្រកម្ពុជាជាភាគី ។

**មាត្រា៣** ._ វិសាលភាព

ក្រមនេះ មានវិសាលភាពអនុវត្តចំពោះ៖

១- រាល់សកម្មភាពទាំងឡាយណាដែលពាក់ព័ន្ធនឹងបរិស្ថាន ធនធានធម្មជាតិ និងបេតិកភណ្ឌជាតិ នៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

២- គោលនយោបាយ ផែនការសកម្មភាព និងវិធានការនានាដែលពាក់ព័ន្ធនឹងបរិស្ថាន ធនធានធម្មជាតិ និងបេតិកភណ្ឌជាតិ ។

៣- រាល់សកម្មភាពរបស់រូបវន្តបុគ្គល នីតិបុគ្គលសាធារណៈ នីតិបុគ្គលឯកជនដែលធ្វើប្រតិបត្តិការទាំងក្នុង និងក្រៅព្រះរាជាណាចក្រកម្ពុជា ដែលបង្កផលប៉ះពាល់ ឬជះឥទ្ធិពលទៅលើបរិស្ថាន ធនធានធម្មជាតិ និងបេតិកភណ្ឌជាតិ នៃព្រះរាជាណាចក្រកម្ពុជា ។

## ជំពូកទី២
## គោលការណ៍ទូទៅ

**មាត្រា៤** ._ គោលការណ៍បញ្ចៀសការខូចខាតបរិស្ថាន និងធនធានធម្មជាតិ

បុគ្គលគ្រប់រូបមិនត្រូវធ្វើសកម្មភាពណាមួយ ដែលបង្ក ឬអាចបង្ក ការខូចខាតបរិស្ថាន ធនធានធម្មជាតិ និងបេតិកភណ្ឌជាតិឡើយលើកលែងតែបុគ្គលនោះ បានចាត់វិធានការសមស្រប ក្នុងការ

ការពារបរិស្ថាន ធនធានធម្មជាតិ និងបេតិកភណ្ឌជាតិ និងបានទប់ស្កាត់ ឬ កាត់បន្ថយការខូចខាតទាំងនោះឱ្យដល់កម្រិតអប្បបរមា ។

**មាត្រា៥** ._ គោលការណ៍នៃការចូលរួមជាសាធារណៈ

បុគ្គលគ្រប់រូប ដែលអាចទទួលរងផលប៉ះពាល់ដោយផ្ទាល់ ឬប្រយោលដោយសារការធ្វើសេចក្តីសម្រេចណាមួយទាក់ទងនឹងបរិស្ថាន និងធនធានធម្មជាតិ មានសិទ្ធិចូលរួមផ្តល់មតិយោបល់ឱ្យទាន់ពេលវេលា និងបន្ទាប់ពីទទួលបានព័ត៌មាន មុនពេលដែលការធ្វើសេចក្តីសម្រេចនោះត្រូវបានធ្វើឡើង តាមរយៈដំណើរការចូលរួមពីគ្រប់បុគ្គលពាក់ព័ន្ធដោយមានតម្លាភាព និងគណនេយ្យភាព ។

**មាត្រា៦** ._ គោលការណ៍នៃការទទួលបានព័ត៌មានបរិស្ថាន និងធនធានធម្មជាតិ

បុគ្គលគ្រប់រូប មានសិទ្ធិទទួលបានព័ត៌មានទាក់ទងនឹងបរិស្ថាន និងធនធានធម្មជាតិ ។

រាល់ព័ត៌មានទាក់ទងនឹងបរិស្ថាន និងធនធានធម្មជាតិ ត្រូវធ្វើការផ្សព្វផ្សាយឱ្យបានទូលំទូលាយដល់សាធារណជន ។ សាធារណជន ត្រូវទទួលបានការផ្តល់ឱកាសជាអតិបរមាក្នុងការចូលរួមរៀបចំផែនការ និងការធ្វើសេចក្តីសម្រេច ដែលបង្កផលប៉ះពាល់ដល់បរិស្ថាន និងធនធានធម្មជាតិ ។

**មាត្រា៧** ._ គោលការណ៍នៃការទទួលបានដំណោះស្រាយប្រកបដោយប្រសិទ្ធភាព

បុគ្គលគ្រប់រូប មានសិទ្ធិទទួលបានដំណោះស្រាយផ្នែករដ្ឋបាល និងផ្នែកតុលាការ ឬក៏មធ្យោបាយសមស្របដទៃទៀត ដែលពាក់ព័ន្ធទៅនឹងវិវាទបរិស្ថាន និងធនធានធម្មជាតិ ប្រកបដោយប្រសិទ្ធភាព ។

យន្តការដោះស្រាយវិវាទ ប្រកបដោយប្រសិទ្ធភាព និងមិនលម្អៀង ត្រូវរៀបចំឡើង ដើម្បីលើកកម្ពស់ការអនុវត្តច្បាប់ និងផ្តន្ទាទោសចំពោះបុគ្គលគ្រប់រូប ដែលបង្កការខូចខាតដល់បរិស្ថាន និងធនធានធម្មជាតិ ។

**មាត្រា៨** ._ គោលការណ៍អ្នកបំពុលត្រូវទទួលខុសត្រូវលើតម្លៃនៃការបំពុល

បុគ្គលគ្រប់រូប ដែលបានបង្កឱ្យមានការខូចខាតចំពោះបរិស្ថាន និងធនធានធម្មជាតិ ត្រូវទទួលបន្ទុកបង់ថ្លៃចំណាយលើការជួសជុល និងវិធានការទប់ស្កាត់ បញ្ចៀស និងកាត់បន្ថយការខូចខាតបរិស្ថាន និងធនធានធម្មជាតិ ។

**មាត្រា៩ ._** គោលការណ៍នៃការប្រុងប្រយ័ត្នជាមុន

ក្នុងករណីដែលមានការគំរាមកំហែង ឬ ការខូចខាតយ៉ាងធ្ងន់ធ្ងរចំពោះបរិស្ថាន ដែលមិនអាចជួសជុលឡើងវិញបាន កង្វះខាតភាពប្រាកដប្រជាផ្នែកវិទ្យាសាស្ត្រ មិនត្រូវយកមកធ្វើជាមូលហេតុក្នុងការពន្យារពេលនៃការចាត់វិធានការ ដើម្បីទប់ស្កាត់ការខូចខាតដល់បរិស្ថានបានឡើយ ។

**មាត្រា១០ ._**គោលការណ៍នៃការទប់ស្កាត់

វិធានការនៃការកាត់បន្ថយ ឬ ការទប់ស្កាត់ ការខូចខាតបរិស្ថាន ត្រូវធ្វើឡើងមុនពេលការខូចខាតបរិស្ថាននោះកើតឡើង ។ វិធានការនេះ ត្រូវធ្វើឡើងជាមុន ប្រសើរជាងធ្វើការជួសជុលការខូចខាតដែលមិនអាចជួសជុលឡើងវិញបាន ។

**មាត្រា១១ ._** គោលការណ៍សមធម៌រវាងជំនាន់បច្ចុប្បន្ន និងអនាគត

សិទ្ធិក្នុងការធ្វើការអភិវឌ្ឍ ដែលអាចបង្កផលប៉ះពាល់បរិស្ថាន និងធនធានធម្មជាតិ ត្រូវអនុវត្តដោយសមធម៌ ដើម្បីបំពេញតម្រូវការរបស់មនុស្សជំនាន់បច្ចុប្បន្ន និងអនាគត ។

**មាត្រា១២ ._** គោលការណ៍នៃការធ្វើសេចក្តីសម្រេចដោយផ្អែកលើភស្តុតាង

ព័ត៌មានដ៏ប្រសើរបំផុតដែលអាចស្វែងរកបាន មានលក្ខណៈវិទ្យាសាស្ត្រ ឬបច្ចេកទេស និងដែលប្រមូលបានពីសហគមន៍ ចំណេះដឹងរបស់ជនជាតិដើមភាគតិច ត្រូវយកមកធ្វើជាមូលដ្ឋាននៃភស្តុតាង ក្នុងការធ្វើសេចក្តីសម្រេចប្រកបដោយតម្លាភាព ទាក់ទងនឹងបរិស្ថាន និងធនធានធម្មជាតិ ។

**មាត្រា១៣ ._** គោលការណ៍សមភាពយេនឌ័រក្នុងការធ្វើសម្រេចពាក់ព័ន្ធនឹងបរិស្ថាន និងធនធានធម្មជាតិ

សមភាពយេនឌ័រ និងការចូលរួមរបស់ស្ត្រីទាក់ទងនឹងការធ្វើសេចក្តីសម្រេចពាក់ព័ន្ធនឹងបរិស្ថាន និងធនធានធម្មជាតិ ត្រូវទទួលបានការលើកកម្ពស់ និងការលើកទឹកចិត្ត ។

**មាត្រា១៤ ._** គោលការណ៍ផលប្រយោជន៍សាធារណៈ

ផលប្រយោជន៍សាធារណៈ ត្រូវមានឧត្តមភាពជាងប្រយោជន៍បុគ្គលឯកជន ឬ នីតិបុគ្គលឯកជន នៅក្នុងដំណើរនៃការធ្វើសេចក្តីសម្រេច ដែលពាក់ព័ន្ធនឹងបរិស្ថាន និងធនធានធម្មជាតិ ។

**មាត្រា១៥** ._ គោលការណ៍សមាហរណកម្មផ្នែកបរិស្ថាន

គោលបំណងនៃកិច្ចគាំពារបរិស្ថាន និងការអភិវឌ្ឍដោយចីរភាព ត្រូវដាក់បញ្ចូលទៅក្នុងការរៀបចំផែនការអភិវឌ្ឍ និងការធ្វើសេចក្ដីសម្រេច ទាំងក្នុងដំណាក់កាលដំបូង និងដំណាក់កាលអនុវត្តគោលនយោបាយ និងច្បាប់ ។

**មាត្រា១៦** ._ គោលការណ៍ អ្នកប្រើប្រាស់ជាអ្នកបង់ថ្លៃ

អ្នកប្រើប្រាស់ធនធានធម្មជាតិ ត្រូវបង់ថ្លៃចំណាយទាំងអស់ដែលពាក់ព័ន្ធនឹងការប្រើប្រាស់ ឬផលប៉ះពាល់ដែលកើតចេញពីការប្រើប្រាស់ធនធានធម្មជាតិទាំងនោះ ។

**មាត្រា១៧** ._ គោលការណ៍នៃការយល់ព្រមជាមុន ដោយសេរី និងបន្ទាប់ពីទទួលបានព័ត៌មានគ្រប់ជ្រុងជ្រោយ សម្រាប់សហគមន៍ជនជាតិដើមភាគតិច

សកម្មភាព ឬ គម្រោងស្នើសុំ ដែលអាចប៉ះពាល់ដល់ដីធ្លី ឬធនធានដទៃទៀត របស់ជនជាតិដើមភាគតិច ដែលទាក់ទងទៅនឹងការអភិវឌ្ឍ ការប្រើប្រាស់ និងការធ្វើអាជីវកម្មលើធនធានធម្មជាតិ ត្រូវទទួលនូវការយល់ព្រមជាមុន ដោយសេរី និងបន្ទាប់ពីទទួលបានព័ត៌មានគ្រប់ជ្រុងជ្រោយ របស់ជនជាតិដើមភាគតិច ។

## ជំពូកទី៣
## សមត្ថកិច្ចក្រសួង ស្ថាប័នពាក់ព័ន្ធនឹងបរិស្ថាន និងគ្រប់គ្រងធនធានធម្មជាតិ

**មាត្រា១៨** ._ ការអនុវត្តភារកិច្ច និងតួនាទី របស់ក្រសួង ស្ថាប័នមានសមត្ថកិច្ច

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងក្រសួង ស្ថាប័នមានសមត្ថកិច្ចដទៃទៀត មានសិទ្ធិអំណាចក្នុងការអនុវត្តភារកិច្ច និងតួនាទីរបស់ខ្លួន ដូចមានចែងក្នុងក្រមនេះ និងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តតាមវិស័យ ដែលជាសមត្ថកិច្ចរបស់ក្រសួង ស្ថាប័ននីមួយៗ ។

ក្នុងករណីបទប្បញ្ញត្តិនៃក្រមនេះ ចែងអំពីសមត្ថកិច្ចរបស់ក្រសួង ស្ថាប័ននីមួយៗ មិនស្របគ្នា ឬមានភាពមិនច្បាស់លាស់ជាមួយនឹងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តតាមវិស័យ នីមួយៗផ្សេងទៀត នោះបទប្បញ្ញត្តិដែលមានចែងក្នុងក្រមនេះ ត្រូវមានអានុភាពជាង ។

**មាត្រា១៩ ._** ការទទួលខុសត្រូវរបស់ក្រសួង ស្ថាប័នពាក់ព័ន្ធនឹងកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ

ក្រសួង ស្ថាប័នមានសមត្ថកិច្ចធ្វើការពាក់ព័ន្ធ មានការទទួលខុសត្រូវ ដូចខាងក្រោម៖

១- អនុវត្តបទប្បញ្ញត្តិនានានៃក្រមនេះ ។

២- ចាត់វិធានការចាំបាច់ ក្នុងការដោះដូរព័ត៌មាន ជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ ។

៣- កសាងសមត្ថភាព និងការយល់ដឹងអំពីខ្លឹមសារនៃក្រមនេះ ដល់មន្ត្រីក្រោមឱវាទ ។

៤- លើកកម្ពស់ប្រសិទ្ធភាពនៃសិទ្ធិទទួលបានព័ត៌មានបរិស្ថាន និងការចូលរួមជាសាធារណៈពាក់ព័ន្ធនឹងបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ ។

៥- រៀបចំយន្តការដោះស្រាយវិវាទ និងផ្តល់ដំណោះស្រាយចំពោះបណ្តឹងពាក់ព័ន្ធនឹងបរិស្ថាន និងធនធានធម្មជាតិ ដែលស្ថិតក្រោមសមត្ថកិច្ចរបស់ខ្លួន និងគ្រប់គ្រងធនធានធម្មជាតិ ក្នុងករណីដែលក្រមនេះ និងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តដទៃទៀត ផ្តល់អំណាចឱ្យ ។

៦- សម្របសម្រួលចំពោះការរៀបចំផែនការ ការដាក់ចេញកម្មវិធី ការធ្វើសេចក្តីសម្រេច និងការអនុវត្តការងារពាក់ព័ន្ធនឹងវិស័យបរិស្ថាន និងធនធានធម្មជាតិ ជាមួយក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងក្រសួង ស្ថាប័នពាក់ព័ន្ធដទៃទៀត ដើម្បីធានាថា គ្រប់សកម្មភាពទាំងអស់ឆ្លើយតបទៅនឹងគោលបំណងនៃក្រមនេះ ។

## មាតិកាទី២
## ការចូលរួមជាសាធារណៈ
### ជំពូកទី១
### បទបញ្ញត្តិទូទៅ

**មាត្រា២០ ._** វិសាលភាព

មាតិកានេះមានវិសាលភាពអនុវត្តចំពោះ សេចក្តីសម្រេច វិធានការ កិច្ចព្រមព្រៀង គោលនយោបាយ កម្មវិធី គម្រោង ផែនការ សកម្មភាព ការឯកភាព ការរៀបចំច្បាប់ និងលិខិតបទដ្ឋានគតិយុត្តដែលពាក់ព័ន្ធនឹងក្រមនេះ។

**មាត្រា២១ ._** សិទ្ធិក្នុងការចូលរួមជាសាធារណៈ

បុគ្គលគ្រប់រូប មានសិទ្ធិចូលរួមជាសាធារណៈ និងអាចអនុវត្តសិទ្ធិរបស់ខ្លួន ដូចខាងក្រោម ៖

១- រាយការណ៍ទៅកាន់អាជ្ញាធរពាក់ព័ន្ធ និងផ្សព្វផ្សាយព័ត៌មានអំពីសកម្មភាព ឬការធ្វើសេចក្ដីសម្រេចណាមួយ ដែលអាចនឹងមានផលប៉ះពាល់ទៅលើបរិស្ថាន និងធនធានធម្មជាតិ ។

២- លើកឡើងនូវសំណួរ ស្នើឱ្យមានការបកស្រាយ ធ្វើការតវ៉ា និងចូលរួមពិភាក្សា អំពីសកម្មភាព ឬ សេចក្ដីសម្រេចណាមួយ ដែលអាចបង្កឱ្យមានផលប៉ះពាល់ដល់បរិស្ថាន និងធនធានធម្មជាតិ ។

៣- ដាក់ពាក្យបណ្ដឹង ឬប្ដឹងតវ៉ានឹងសកម្មភាព ឬសេចក្ដីសម្រេច ស្របតាមយន្តការដោះស្រាយវិវាទបរិស្ថាន និងធនធានធម្មជាតិ ដូចមានចែងក្នុង គន្ថីទី៩នៃក្រមនេះ ។

**មាត្រា២២** ._ សិទ្ធិទទួលបានការការពារ

បុគ្គលគ្រប់រូបដែលអនុវត្តសិទ្ធិក្នុងការចូលរួមជាសាធារណៈ ដូចមានចែងក្នុងមាត្រា២១ខាងលើ ត្រូវរួចផុតពីការគំរាមកំហែង និងការសងសឹកតាមគ្រប់មធ្យោបាយនានា ។ រាល់សកម្មភាពក្នុងការចូលរួមជាសាធារណៈដែលស្របតាមមាតិកានេះ មិនត្រូវទទួលរងការចោទប្រកាន់ពីបទព្រហ្មទណ្ឌ ឬប្រឈមនឹងបណ្ដឹងទាមទារផ្នែករដ្ឋប្បវេណីណាមួយឡើយ ។

សិទ្ធិក្នុងការទទួលបានការការពារពីការគំរាមកំហែង ឬ ការសងសឹក ចំពោះការចូលរួមជាសាធារណៈ មិនត្រូវរួចផុតពីការចោទប្រកាន់ពីបទព្រហ្មទណ្ឌ ឬកំហុសផ្នែករដ្ឋប្បវេណីឡើយ ក្នុងករណីដែលបុគ្គលដែលបានចូលរួមជាសាធារណៈប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌណាមួយ ដូចមានចែងក្នុងក្រមនេះ ឬ ក្រមព្រហ្មទណ្ឌ ឬ ក្រមរដ្ឋប្បវេណី ឬ ច្បាប់ពាក់ព័ន្ធដទៃទៀតជាធរមាន ។

**មាត្រា២៣** ._ លក្ខខណ្ឌតម្រូវសម្រាប់ការចូលរួមជាសាធារណៈ

មុននឹងធ្វើសេចក្ដីសម្រេច ឬឯកភាពលើបញ្ហាណាមួយពាក់ព័ន្ធនឹងក្រមនេះ ក្រសួង ស្ថាប័នពាក់ព័ន្ធ និងម្ចាស់គម្រោងទាំងអស់ ត្រូវបំពេញតាមលក្ខខណ្ឌតម្រូវ សម្រាប់ការចូលរួមជាសាធារណៈ ដូចខាងក្រោម៖

១- អ្នកពាក់ព័ន្ធត្រូវទទួលបានការជូនដំណឹង និងពេលវេលាគ្រប់គ្រាន់ សម្រាប់ចូលរួមនៅក្នុងដំណើរការនៃការធ្វើសេចក្ដីសម្រេចដែលពាក់ព័ន្ធ ។

២- អ្នកពាក់ព័ន្ធទាំងអស់ត្រូវទទួលបានព័ត៌មានចាំបាច់ ។ ការផ្ដល់ព័ត៌មានទាំងនោះត្រូវយកចិត្តទុកដាក់អំពីភាសាដែលអាចយល់បាន និងវប្បធម៌របស់អ្នកពាក់ព័ន្ធ ។

៣- ចំណេះដឹងខាងផ្នែកបច្ចេកទេស វិទ្យាសាស្ត្រ និងចំណេះដឹងលក្ខណៈប្រពៃណីនៃសហគមន៍មូលដ្ឋាន និងជនជាតិដើមភាគតិច ត្រូវយកជាមូលដ្ឋានក្នុងការបង្កើតគម្រោង ផែនការសកម្មភាព និងការធ្វើសេចក្តីសម្រេច ។

៤- កិច្ចដំណើរការនៃការចូលរួមជាសាធារណៈ ត្រូវយកចិត្តទុកដាក់អំពីតម្រូវការ និងតម្លៃ របស់អ្នកពាក់ព័ន្ធ ។

៥- អ្នកពាក់ព័ន្ធត្រូវទទួលបានពេលវេលាសមស្រប និងត្រឹមត្រូវ ដើម្បីធ្វើការវាយតម្លៃ និងឆ្លើយតបចំពោះព័ត៌មានទាក់ទងនឹងគម្រោងស្នើសុំ សកម្មភាព ផែនការ ឬសេចក្តីសម្រេចណាមួយ ។

៦- កម្រិតនៃការចូលរួមជាសាធារណៈ ត្រូវស្របតាមកម្រិតនៃការចាប់អារម្មណ៍របស់អ្នកពាក់ព័ន្ធ។

៧- ដំណើរការនៃការចូលរួមជាសាធារណៈ ត្រូវមានភាពបត់បែន និងអាចកែសម្រួលបាន ដើម្បីឆ្លើយតបទៅនឹងការរំពឹងទុកដែលសមហេតុផលរបស់អ្នកពាក់ព័ន្ធ ។

៧- កិច្ចដំណើរនៃការចូលរួមជាសាធារណៈ ត្រូវមានលក្ខណៈបត់បែន និងអាចសម្របសម្រួលបាន ស្របតាមការរំពឹងទុករបស់អ្នកពាក់ព័ន្ធ ។

៨- គ្រប់មតិយោបល់របស់សាធារណជន ត្រូវទទួលបានការពិចារណានៅក្នុងដំណើរការនៃការធ្វើសេចក្តីសម្រេច ។ ការទទួលយក ឬ បដិសេធចំពោះមតិយោបល់ខាងលើនេះ ត្រូវបញ្ជាក់ហេតុផលសមរម្យ ។

**មាត្រា២៤ ._** នីតិវិធីសម្រាប់ការចូលរួមជាសាធារណៈ

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន ត្រូវរៀបចំលិខិតបទដ្ឋានគតិយុត្តស្តីពីនីតិវិធីសម្រាប់ការចូលរួមសាធារណៈ ។ ក្រសួង ស្ថាប័នពាក់ព័ន្ធផ្សេងទៀត ត្រូវរៀបចំលិខិតបទដ្ឋានគតិយុត្តស្តីពីនីតិវិធីសម្រាប់ការចូលរួមជាសាធារណៈ ទាក់ទងនឹងវិស័យនីមួយៗរបស់ខ្លួន ស្របតាមបទប្បញ្ញត្តិនៅក្នុងមាតិកានេះ ។

## ជំពូកទី២
## ការចូលរួមជាសាធារណៈរបស់សហគមន៍ជនជាតិដើមភាគតិច

**មាត្រា២៥ ._** ការពិគ្រោះយោបល់របស់សហគមន៍ជនជាតិដើមភាគតិច

ក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវពិគ្រោះយោបល់ជាមួយសហគមន៍ជនជាតិដើមភាគតិច លើគោលនយោបាយ ផែនការ ឬ កម្មវិធី ដែលអាចប៉ះពាល់ដោយផ្ទាល់ចំពោះ ដីធ្លី និងធនធាននានា របស់ជនជាតិដើមភាគតិច ។

**មាត្រា២៦ ._** ការយល់ព្រមជាមុន ដោយសេរី និងបន្ទាប់ពីទទួលបានព័ត៌មានគ្រប់ជ្រុងជ្រោយ

ក្រសួង ស្ថាប័នមានសមត្ថកិច្ច មិនត្រូវឯកភាពលើគម្រោងស្នើសុំ ដែលអាចប៉ះពាល់ដោយផ្ទាល់ចំពោះ ដីធ្លី និងធនធានរបស់ជនជាតិដើមភាគតិច ដោយគ្មានការយល់ព្រមជាមុន ដោយសេរី និងបន្ទាប់ពីទទួលបានព័ត៌មានគ្រប់ជ្រុងជ្រោយបានឡើយ ។ ការយល់ព្រមរបស់ជនជាតិដើមភាគតិច ត្រូវធ្វើឡើងដោយមតិភាគច្រើនដាច់ខាតនៃជនជាតិដើមភាគតិច ដែលអាចទទួលរងផលប៉ះពាល់ពីគម្រោងស្នើសុំ ឬការធ្វើសេចក្តីសម្រេចនេះ ។

**មាត្រា២៧ ._** ការចូលរួមរបស់ជនជាតិដើមភាគតិច

ម្ចាស់គម្រោង ឬក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវផ្តល់ឱកាសឱ្យមានការចូលរួមប្រកបដោយប្រសិទ្ធភាពរបស់ជនជាតិដើមភាគតិច ដែលអាចទទួលរងផលប៉ះពាល់ពីសេចក្តីសម្រេចទាក់ទងនឹងបរិស្ថាន និងធនធានធម្មជាតិ ។

ការចូលរួមត្រូវធ្វើឡើងដោយគ្មានការគំរាមកំហែង ការបោកបញ្ឆោត ឬការបង្ខិតបង្ខំ និងត្រូវផ្តល់ឱកាសឱ្យមានការចូលរួមឱ្យបានទាន់ពេលវេលា ហើយអ្នកចូលរួមត្រូវទទួលបានការជូនដំណឹងពេញលេញអំពីព័ត៌មានទាំងអស់ក្នុងទម្រង់ និងភាសាដែលសមស្រប។

**មាត្រា២៨ ._** នីតិវិធីនៃការចូលរួមរបស់សហគមន៍ជនជាតិដើមភាគតិច

នីតិវិធីនៃការពិគ្រោះយោបល់ ការចូលរួម និងយល់ព្រមចំពោះការធ្វើសេចក្តីសម្រេច ដែលប៉ះពាល់ចំពោះដីធ្លី និងធនធានរបស់សហគមន៍ជាតិដើមភាគតិច ត្រូវកំណត់ដោយលិខិតបទដ្ឋានគតិយុត្តរបស់ក្រសួង ស្ថាប័នពាក់ព័ន្ធ ។

## ជំពូកទី៣
## វិធានការកាត់បន្ថយផលប៉ះពាល់

**មាត្រា២៩ ._** លក្ខខណ្ឌតម្រូវសម្រាប់វិធានការកាត់បន្ថយផលប៉ះពាល់

ក្នុងករណីដែលការធ្វើសេចក្តីសម្រេចណាមួយ អាចបង្កឱ្យមានផលប៉ះពាល់ដល់សហគមន៍មូលដ្ឋាន ឬសហគមន៍ជនជាតិដើមភាគតិច ក្រសួង ស្ថាប័នពាក់ព័ន្ធ ឬម្ចាស់គម្រោង ត្រូវរៀបចំវិធានការកាត់បន្ថយផលប៉ះពាល់ ដោយពិគ្រោះយោបល់ជាមួយសហគមន៍មូលដ្ឋាន ឬជនជាតិដើមភាគតិច ដើម្បីកំណត់ឱ្យច្បាស់ពីផលប៉ះពាល់នោះ និងយល់ព្រមទៅលើវិធានការណ៍កាត់បន្ថយផលប៉ះពាល់ និងការចាត់ចែងបែងចែកផលប្រយោជន៍ ។

វិធានការកាត់បន្ថយផលប៉ះពាល់ត្រូវមានលក្ខណៈសមស្រប មានចីរភាព និងមិនមានការរើសអើង និងត្រូវយកចិត្តទុកដាក់ចំពោះជនងាយរងគ្រោះ និងជនងាយរងហានិភ័យខ្លាំងបំផុតពីផលប៉ះពាល់ដែលអាចកើតឡើងពីការធ្វើសេចក្តីសម្រេច។

**មាត្រា៣០** ._ ការផ្លាស់ទីលំនៅថ្មីដោយមិនស្ម័គ្រចិត្ត

ក្នុងករណីដែលតម្រូវឱ្យមានការផ្លាស់ទីលំនៅថ្មីដោយមិនស្មគ្រ័ចិត្តសម្រាប់គម្រោងស្នើសុំនោះម្ចាស់គម្រោង ឬក្រសួង ស្ថាប័នដែលពាក់ព័ន្ធ ត្រូវផ្តល់ឱកាសឱ្យសហគមន៍មូលដ្ឋាន និងជនជាតិដើមភាគតិច ចូលរួមក្នុងការពិចារណាអំពីជម្រើសផ្សេងៗ ដើម្បីបញ្ចៀស ឬកាត់បន្ថយជាអប្បបរមានូវការផ្លាស់ទីលំនៅថ្មី ដោយគ្មានការគំរាមកំហែង ការបោកបញ្ឆោត ឬការបង្ខិតបង្ខំ ។

**មាត្រា៣១** ._ ការៀបចំផែនការផ្លាស់ទីលំនៅថ្មី

ក្នុងករណីដែលការផ្លាស់ទីលំនៅថ្មី មិនអាចជៀសវាងបាន ម្ចាស់គម្រោង ឬក្រសួង ស្ថាប័នដែលពាក់ព័ន្ធ ត្រូវផ្តល់ឱកាសឱ្យសហគមន៍មូលដ្ឋាន និងជនជាតិដើមភាគតិច ដែលទទួលរងផលប៉ះពាល់ ចូលរួមរៀបចំផែនការផ្លាស់ទីលំនៅថ្មី ដើម្បី៖

១- កាត់បន្ថយជាអប្បបរមានូវផលប៉ះពាល់ជាអវិជ្ជមាននៃការផ្លាស់ទីលំនៅថ្មី ។

២- ទទួលបានជីវភាពរស់នៅនាពេលអនាគត និងសេវាសង្គមស្មើ ឬប្រសើរជាងលក្ខខណ្ឌមុនពេលធ្វើការផ្លាស់ទីលំនៅថ្មី ។

៣- ទទួលសំណងដោយយុត្តិធម៌ សមធម៌ និងអាចទទួលយកបានស្របតាមតម្លៃទីផ្សារ ចំពោះទ្រព្យដែលបាត់បង់ និងផលប៉ះពាល់ទៅលើជីវភាពរស់នៅ ពីម្ចាស់គម្រោង ឬក្រសួង ស្ថាប័នពាក់ព័ន្ធ ។

## មាតិកាទី៣
## សិទ្ធិទទួលបានព័ត៌មានបរិស្ថាន

# ជំពូកទី១
# បទប្បញ្ញត្តិទូទៅ

**មាត្រា៣២** ._ វិសាលភាព

មាតិកានេះមានវិសាលភាពអនុវត្តចំពោះព័ត៌មានទាំងអស់ដែលពាក់ព័ន្ធនឹងបរិស្ថាន និង ធនធានធម្មជាតិ ដែលត្រូវដាក់ឱ្យសាធារណជនអាចស្វែងរកបាន ។

**មាត្រា៣៣** ._ កាតព្វកិច្ចក្នុងការបើកបង្ហាញ និងដាក់ព័ត៌មានឱ្យសាធារណជនអាចស្វែងរកបាន

គ្រប់ម្ចាស់គម្រោង ឬក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវបើកបង្ហាញព័ត៌មានដូចមានចែងក្នុងមាត្រា ៣៥ នៃក្រមនេះ ឱ្យសាធារណជនអាចស្វែងរកបាន មុនពេលចេញ៖

១- សេចក្តីសម្រេច ឬការឯកភាពណាមួយ ដែលពាក់ព័ន្ធទៅនឹងបរិស្ថាន ឬធនធានធម្មជាតិ ។

២- វិធានការផ្នែករដ្ឋបាល និងវិធានការច្បាប់ ។

៣- កិច្ចព្រមព្រៀងផ្នែកបរិស្ថាន ។

៤- សំណើគោលនយោបាយ ច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត ។

៥- កម្មវិធី ផែនការ សកម្មភាព ឬសេចក្តីសម្រេចផ្សេងទៀតស្របតាមក្រមនេះ ។

ទម្រង់បែបបទ និងនីតិវិធីនៃការបើកបង្ហាញព័ត៌មាន ត្រូវកំណត់ដោយក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងក្រសួង ស្ថាប័នពាក់ព័ន្ធដទៃទៀត ។

**មាត្រា៣៤** ._សិទ្ធិស្នើសុំព័ត៌មាន

បុគ្គលគ្រប់រូបមានសិទ្ធិស្នើសុំព័ត៌មាន ពីក្រសួង ស្ថាប័ន និងម្ចាស់គម្រោងស្របតាមមាត្រា៣៥ នៃក្រមនេះ លើកលែងតែព័ត៌មានសម្ងាត់ដូចមានចែងក្នុងក្រមនេះ ។

**មាត្រា៣៥** ._ ព័ត៌មានពាក់ព័ន្ធនឹងបរិស្ថាន និងធនធានធម្មជាតិ

ព័ត៌មានពាក់ព័ន្ធនឹងបញ្ហាបរិស្ថាន និងធនធានធម្មជាតិមានដូចខាងក្រោម៖

១- ស្ថានភាពនៃធាតុផ្សំរបស់បរិស្ថាន រួមមាន ខ្យល់ បរិយាកាស ទឹក ដី ផ្ទៃដី តំបន់ទេសភាព និងតំបន់ធម្មជាតិ អាកាសធាតុ ជីវៈចម្រុះ និងធាតុផ្សំនៃជីវៈចម្រុះ ។

២- កត្តានានាដែលប៉ះពាល់ ឬអាចប៉ះពាល់ដល់ធាតុផ្សំទាំងឡាយនៃបរិស្ថាន។ កត្តាទាំងនេះរួមមាន សារធាតុ ថាមពល សំឡេង វិទ្យុសកម្ម សំណល់ ការបំភាយឧស្ម័ន ការបង្ហូរចេញ និងការបញ្ចេញចោលចូលទៅក្នុងបរិស្ថាន ។

៣- វិធានការដែលប៉ះពាល់ ឬអាចប៉ះពាល់ ឬកាត់បន្ថយការប៉ះពាល់ដូចមានចែងក្នុងកថាខ័ណ្ឌទី១ និងទី២ ខាងលើ។ វិធានការទាំងនេះ រួមមាន គោលនយោបាយ ច្បាប់ ផែនការ កម្មវិធី កិច្ចព្រមព្រៀងផ្នែកបរិស្ថាន និងសកម្មភាពនានា ។

៤- សនិទានភាពសម្រាប់សេចក្ដីសម្រេចលើវិធានការដូចមានចែងក្នុងកថាខ័ណ្ឌទី៣ ខាងលើនេះ រួមមាន ការវិភាគអំពីវដ្ដជីវិត ការវាយតម្លៃបរិស្ថាន ការវាយតម្លៃអំពីភាពងាយរងគ្រោះ និងការវិភាគអំពីតម្លៃនៃការខូចខាត និងផលចំណេញផ្នែកសេដ្ឋកិច្ច ។

៥- ព័ត៌មានពាក់ព័ន្ធនឹងការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងការវាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្រ ។

៦- ទំនាក់ទំនងជាលក្ខណៈបុគ្គល និងធុរៈកិច្ចរបស់ម្ចាស់គម្រោងជាមួយសហគ្រាហពាណិជ្ជកម្ម ឬស្ថាបន័ផ្ដល់កម្ចីជាតិ ឬអន្តរជាតិដទៃទៀត ដែលគាំទ្រដល់គម្រោង ឬសកម្មភាពដែលពាក់ព័ន្ធ តាមរយៈកម្ចីឥណទាន ឬជំនួយផ្នែកបច្ចេកទេស ។

៧- ការមិនអនុលោមតាម ឬការបំពានច្បាប់បរិស្ថាន គោលនយោបាយ លិខិតបទដ្ឋាន និងកិច្ចព្រមព្រៀង ។

៨- របាយការណ៍អង្កេតតាមដាន និងសវនកម្មបរិស្ថាន ។

៩- លិខិតអនុញ្ញាត និងការឯកភាពដែលតម្រូវឱ្យមានស្របតាមក្រមនេះ និងលក្ខខណ្ឌនានាដែលភ្ជាប់ទៅនឹងលិខិតអនុញ្ញាត និងការឯកភាពទាំងនេះ ។

១០- ព័ត៌មានទាំងឡាយស្ដីពីហានិភ័យនៃអាកាសធាតុ និងបរិស្ថាន ដែលប៉ះពាល់ដល់ស្ថានភាពនៃសុខភាព និងសុវត្ថិភាពរបស់មនុស្ស ទីតាំងបេតិកភណ្ឌវប្បធម៌ និងរចនាសម្ព័ន្ធនៃសំណង់នានា ។

១១- របាយការណ៍ពាក់ព័ន្ធនឹងការអនុវត្តវិធានការ ដូចមានចែងក្នុងចំណុចទី៣ ខាងលើ និងការអនុវត្តកិច្ចព្រមព្រៀងបរិស្ថានពហុភាគី ។

១២- ព័ត៌មានពាក់ព័ន្ធនឹងការធ្វើចំណាត់ការនានា ទាំងនីតិវិធីរដ្ឋបាល និងតុលាការពាក់ព័ន្ធនឹងបញ្ហាបរិស្ថាន ស្របតាមច្បាប់ជាធរមាន ។

១៣- រាល់ព័ត៌មានពាក់ព័ន្ធផ្សេងទៀត ដែលកំណត់ដោយក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន ។

**មាត្រា៣៦**._ ព័ត៌មានសាធារណៈ

ព័ត៌មានពាក់ព័ន្ធនឹងបរិស្ថាន និងធនធានធម្មជាតិ ដូចមានចែងក្នុងមាត្រា៣៥ នៃមាតិកានេះ ដែលត្រូវផ្តល់ជូនទៅម្ចាស់គម្រោង ឬអង្គភាពរាជរដ្ឋាភិបាលដែលពាក់ព័ន្ធស្របតាមក្រមនេះ ត្រូវកំណត់ថាជាព័ត៌មានសាធារណៈ លើកលែងតែព័ត៌មាននោះជាព័ត៌មានសម្ងាត់ ដូចមានចែងក្នុងជំពូកទី៣ នៃមាតិកានេះ ។

**មាត្រា៣៧**._ សិទ្ធិក្នុងការដាក់ពាក្យបណ្តឹង

រូបវន្តបុគ្គល ឬនីតិបុគ្គល ដែលមិនពេញចិត្តចំពោះសេចក្តីសម្រេចដែលធ្វើឡើងដោយម្ចាស់គម្រោង ឬក្រសួង ស្ថាប័នពាក់ព័ន្ធ ទាក់ទងនឹងការផ្តល់ព័ត៌មានបរិស្ថាន ឬការកំណត់អំពីភាពសម្ងាត់នៃព័ត៌មានបរិស្ថានណាមួយ បុគ្គលនោះមានសិទ្ធិប្តឹងតវ៉ា តាមយន្តការដូចមានចែងក្នុងគន្ថីទី៩ នៃក្រមនេះ ។

## ជំពូកទី២
## ការផ្តល់ព័ត៌មានដោយរាជរដ្ឋាភិបាល
### ផ្នែកទី១
### ការផ្តល់ព័ត៌មានជាសាធារណៈ

**មាត្រា៣៨**._ ការផ្តល់ព័ត៌មានជាសាធារណៈ

គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវផ្តល់ព័ត៌មានជាសាធារណៈ ដូចមានចែងក្នុងមាត្រា៣៥ នៃក្រមនេះ ។

**មាត្រា៣៩**._ របាយការណ៍បរិស្ថានជាតិ

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន ត្រូវរៀបចំរបាយការណ៍បរិស្ថានជាតិ រៀងរាល់ប្រាំ(៥)ឆ្នាំម្តង។ របាយការណ៍បរិស្ថានជាតិ ត្រូវរួមបញ្ចូលព័ត៌មានបរិស្ថានពាក់ព័ន្ធ និងការវាយតម្លៃការអនុវត្តគោលនយោបាយ និងច្បាប់បរិស្ថាននៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

របាយការណ៍បរិស្ថានជាតិត្រូវដាក់ឱ្យសាធារណជនអាចស្វែងរកបានស្របតាមបទប្បញ្ញត្តិស្តីពីព័ត៌មានបរិស្ថាន នៅក្នុងគន្ថីទី១ មាតិកាទី៣ នៃក្រមនេះ ។

នីតិវិធី និងខ្លឹមសារនៃរបាយការបរិស្ថានជាតិ ត្រូវកំណត់ដោយលិខិតបទដ្ឋានគតិយុត្តរបស់ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន ។

**មាត្រា៤០** ._ ប្រព័ន្ធ និងនីតិវិធីនៃការផ្តល់ព័ត៌មានសាធារណៈ

គ្រប់ក្រសួង ស្ថាប័នសមត្ថកិច្ច ត្រូវបង្កើតប្រព័ន្ធផ្តល់ព័ត៌មានសាធារណៈ ដល់សាធារណជនដូចមានចែងក្នុងក្រមនេះ ។

ក្រសួង ស្ថាប័នមានសមត្ថកិច្ច ត្រូវរៀបចំលិខិតបទដ្ឋានគតិយុត្តស្តីពីនីតិវិធីផ្តល់ព័ត៌មានសាធារណៈ នៅលើប្រព័ន្ធផ្តល់ព័ត៌មានសាធារណៈ ។

**មាត្រា៤១** ._ នីតិវិធីនៃការសំយោគព័ត៌មាន

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន ត្រូវពិគ្រោះយោបល់ជាមួយក្រសួង ស្ថាប័នសមត្ថកិច្ច ដើម្បីរៀបចំនីតិវិធីនៃការសំយោគព័ត៌មានទាំងឡាយ ដែលទទួលបានពីពីប្រភពផ្សេងៗ និងត្រូវផ្តល់ព័ត៌មានសំយោគនោះដល់សាធារណជន និងអ្នកធ្វើសេចក្តីសម្រេចនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ។

## ផ្នែកទី២
## បញ្ជីព័ត៌មានបរិស្ថានជាតិ

**មាត្រា៤២** ._ ការរៀបចំបញ្ជីព័ត៌មានបរិស្ថានជាតិ

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន ដោយសហការជាមួយក្រសួង ស្ថាប័នសមត្ថកិច្ច ត្រូវរៀបចំបញ្ជីព័ត៌មានបរិស្ថានជាតិ ដែលពាក់ព័ន្ធនឹងបរិស្ថាន និងធនធានធម្មជាតិ និងសកម្មភាពដែលប៉ះពាល់ដល់ស្ថានភាពបរិស្ថាន និងធនធានធម្មជាតិ ។

**មាត្រា៤៣** ._ ប្រភេទព័ត៌មាន នៃបញ្ជីព័ត៌មានបរិស្ថានជាតិ

បញ្ជីព័ត៌មានបរិស្ថានជាតិនេះ ត្រូវដាក់បញ្ចូលនូវព័ត៌មានទាំងអស់ដែលផ្តល់ឱ្យដោយក្រសួង ស្ថាប័នសមត្ថកិច្ច ស្របតាមលក្ខខណ្ឌតម្រូវនៃក្រមនេះ ។

ប្រភេទព័ត៌មានបរិស្ថាន និងធនធានធម្មជាតិ រួមមាន ស្ថិតិ របាយការណ៍ និងព័ត៌មានភូមិសាស្ត្រស្ដីពីបរិស្ថាន ស្ថានភាពនៃប្រព័ន្ធអេកូឡូស៊ី ជីវៈចម្រុះ និងធនធានធម្មជាតិ សកម្មភាពអភិវឌ្ឍ និងសិទ្ធិកាន់កាប់ដីធ្លីរបស់សហគមន៍មូលដ្ឋាន ជនជាតិដើមភាគតិច ជាអាទិ៍ ។

**មាត្រា៤៤** ._ ការទទួលបានព័ត៌មានជាសាធារណៈ ពីបញ្ជីព័ត៌មានបរិស្ថានជាតិ

បញ្ជីព័ត៌មានបរិស្ថានជាតិ ជាព័ត៌មាន ដែលសាធារណជនអាចស្វែងរកបាន លើកលែងតែព័ត៌មានទាំងឡាយណា ដែលជាព័ត៌មានសម្ងាត់ សម្រាប់ការការពារដល់ប្រភេទសត្វ និងរុក្ខជាតិព្រៃ ឬបេតិកភណ្ឌវប្បធម៌ និងបេតិកភណ្ឌធម្មជាតិ ដែលកំណត់ដោយក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន ។

ក្នុងករណីនេះ ក្រសួង ស្ថាប័នទទួលបន្ទុកលើបញ្ជីបរិស្ថានជាតិ ត្រូវផ្ដល់ការបកស្រាយ និងការពន្យល់ជាលាយលក្ខណ៍អក្សរជាក់លាក់ ។

**មាត្រា៤៥** ._ នីតិវិធីប្រមូល និងចែកចាយព័ត៌មានពាក់ព័ន្ធនឹងបញ្ជីព័ត៌មានបរិស្ថានជាតិ

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន ដោយសហការជាមួយក្រសួង ស្ថាប័នសមត្ថកិច្ច ត្រូវរៀបចំលិខិតបទដ្ឋានគតិយុត្តស្ដីពីនីតិវិធីប្រមូល និងចែកចាយព័ត៌មានដែលត្រូវដាក់ឱ្យសាធារណជនអាចស្វែងរកបានតាមរយៈបញ្ជីព័ត៌មានបរិស្ថានជាតិពីក្រសួង ស្ថាប័នមានសមត្ថកិច្ច ។

## ផ្នែកទី៣
## មជ្ឈមណ្ឌលផែនទីបរិស្ថានជាតិ

**មាត្រា៤៦** ._ ការបង្កើតមជ្ឈមណ្ឌលផែនទីបរិស្ថានជាតិ

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន ត្រូវបង្កើតមជ្ឈមណ្ឌលផែនទីបរិស្ថានជាតិ។ ការរៀបចំ និងការប្រព្រឹត្តទៅរបស់មជ្ឈមណ្ឌលផែនទីបរិស្ថានជាតិ ត្រូវកំណត់ដោយលិខិតបទដ្ឋានគតិយុត្ត តាមសំណើរបស់ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន ។

**មាត្រា៤៧** ._ ការទទួលខុសត្រូវរបស់មជ្ឈមណ្ឌលផែនទីបរិស្ថានជាតិ

ការទទួលខុសត្រូវរបស់មជ្ឈមណ្ឌលផែនទីបរិស្ថានជាតិ មានដូចខាងក្រោម៖

១- គ្រប់គ្រងបញ្ជីព័ត៌មានបរិស្ថានជាតិ ដោយថែរក្សា និងធ្វើបច្ចុប្បន្នភាពប្រព័ន្ធទិន្នន័យ និងទទួលព័ត៌មានពាក់ព័ន្ធមកពីក្រសួង ស្ថាប័នពាក់ព័ន្ធ ។

២- មានមុខងារក្នុងការសម្រិតសម្រាំងស្ថិតិ ទិន្នន័យភូមិសាស្ត្រនៃការប្រើប្រាស់ដី និងព័ត៌មានផែនទី ដែលផ្តល់ឱ្យដោយក្រសួង ស្ថាប័នពាក់ព័ន្ធដទៃទៀត រៀបចំ និងរក្សាបញ្ជីទិន្នន័យ ព័ត៌មានសម្រាប់ទំនាក់ទំនង និងបែបបទក្នុងសម្រាប់ការស្នើសុំទិន្នន័យ ។

៣- ធ្វើការវិភាគទិន្នន័យ ឬព័ត៌មានដែលប្រើប្រាស់ជាមូលដ្ឋានក្នុងការធ្វើសេចក្តីសម្រេចដែលពាក់ព័ន្ធនឹងបរិស្ថាន និងធនធានធម្មជាតិ ។

៤- ចងក្រង និងបញ្ចូលទិន្នន័យភូមិសាស្ត្រនៃការប្រើប្រាស់ដី និងរបាយការណ៍ពាក់ព័ន្ធនឹងការកំណត់ផែនទីបរិស្ថាន និងធនធានធម្មជាតិ ដែលរៀបចំដោយក្រសួង ស្ថាប័នពាក់ព័ន្ធទៅក្នុងបញ្ជីព័ត៌មានបរិស្ថានជាតិ ។

៥- រៀបចំស្តង់ដារនានាសម្រាប់ការប្រមូល ការគ្រប់គ្រង ការវិភាគ និងការបែងចែកព័ត៌មានភូមិសាស្ត្រនៃការប្រើប្រាស់ដី ។

៦- កំណត់ទម្រង់ស្តង់ដារបច្ចេកទេសសម្រាប់ក្រសួង ស្ថាប័នពាក់ព័ន្ធ ក្នុងការផ្តល់ទិន្នន័យ ។

៧- កំណត់ទិន្នន័យភូមិសាស្ត្រនៃការប្រើប្រាស់ដី ដោយមានការធានាគុណភាព និងដោយភ្ជាប់មកជាមួយនូវបណ្តុំទិន្នន័យដែលមានស្រាប់។

៨- ប្រមូលទិន្នន័យភូមិសាស្ត្រនៃការប្រើប្រាស់ដី និងទិន្នន័យពាក់ព័ន្ធនឹងវិស័យជាក់លាក់ណាមួយ ។ ការប្រមូលនេះ មិនត្រូវជាន់គ្នានឹងព័ត៌មាន ឬទិន្នន័យ ក្នុងចំណោមក្រសួង ស្ថាប័ននានាឡើយ ។

**មាត្រា៤៨** ._ ការទទួលបានព័ត៌មានជាសាធារណៈ ពីបញ្ជីព័ត៌មានបរិស្ថានជាតិ

ទិន្នន័យទាំងអស់ ដែលរៀបចំដោយមជ្ឈមណ្ឌលផែនទីបរិស្ថានជាតិ ត្រូវដាក់ឱ្យសាធារណជនអាចស្វែងរកបាន លើកលែងតែទិន្នន័យ ដែលចាត់ទុកជាព័ត៌មានសម្ងាត់ សម្រាប់ការពារប្រភេទសត្វ និងរុក្ខជាតិព្រៃ ឬបេតិកភណ្ឌវប្បធម៌ និងបេតិកភណ្ឌធម្មជាតិ ។ ក្នុងករណីនេះ ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន ត្រូវផ្តល់ការបកស្រាយ និងការពន្យល់ជាលាយលក្ខណ៍អក្សរជាក់លាក់ ។

## ផ្នែកទី៤
## បញ្ជីលិខិតអនុញ្ញាតថ្នាក់ជាតិ

**មាត្រា៤៩** ._ ការរៀបចំបញ្ជីលិខិតអនុញ្ញាតថ្នាក់ជាតិ

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន ដោយសហការជាមួយក្រសួង ស្ថាប័នមានសមត្ថកិច្ច ត្រូវរៀបចំបញ្ជីលិខិតអនុញ្ញាតថ្នាក់ជាតិ ។

**មាត្រា៥០** ._ ប្រភេទលិខិតអនុញ្ញាត

បញ្ជីលិខិតអនុញ្ញាតថ្នាក់ជាតិ ដែលចេញដោយក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន ឬ ក្រសួង ស្ថាប័នពាក់ព័ន្ធដទៃទៀត ស្របតាមក្រមនេះ មានដូចខាងក្រោម៖

១- លិខិតអនុញ្ញាត ។

២- អាជ្ញាបណ្ណ ។

៣- លិខិតឯកភាព ។

**មាត្រា៥១** ._ ការស្វែងរកបាននូវបញ្ជីលិខិតអនុញ្ញាតថ្នាក់ជាតិរបស់សាធារណជន

បញ្ជីលិខិតអនុញ្ញាតថ្នាក់ជាតិ ត្រូវដាក់ឱ្យសាធារណជនអាចស្វែងរកបាន ។

**មាត្រា៥២** ._ នីតិវិធីផ្សព្វផ្សាយព័ត៌មានអំពីបញ្ជីលិខិតអនុញ្ញាតថ្នាក់ជាតិ

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន ដោយសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវរៀបចំលិខិតបទដ្ឋានគតិយុត្តស្ដីពីនីតិវិធីផ្សព្វផ្សាយព័ត៌មានអំពីបញ្ជីលិខិតអនុញ្ញាតថ្នាក់ជាតិ។

## ផ្នែកទី៥
## បញ្ជីសវនកម្មបរិស្ថានថ្នាក់ជាតិ

**មាត្រា៥៣** ._ ការរៀបចំបញ្ជីសវនកម្មបរិស្ថានថ្នាក់ជាតិ

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន ដោយសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវរៀបចំបញ្ជីសវនកម្មបរិស្ថានថ្នាក់ជាតិ ។

**មាត្រា៥៤** ._ ប្រភេទនៃសវនកម្មបរិស្ថាន

បញ្ជីសវនកម្មបរិស្ថានថ្នាក់ជាតិ ត្រូវរាប់បញ្ចូលគ្រប់សវនកម្មដែលតម្រូវឱ្យធ្វើលើគ្រប់សកម្មភាព ឬការអភិវឌ្ឍនានា ដូចមានចែងក្នុងក្រមនេះ និងរាល់លក្ខខណ្ឌ ដូចមានភ្ជាប់ទៅនឹងលិខិតអនុញ្ញាត ។

**មាត្រា៥៥** ._ ការស្វែងរកបានជាសាធារណៈនៃបញ្ជីសវនកម្មបរិស្ថានថ្នាក់ជាតិ

បញ្ជីសវនកម្មបរិស្ថានថ្នាក់ជាតិ ត្រូវដាក់ឱ្យសាធារណជនអាចស្វែងរកបាន ។

**មាត្រា៥៦** ._ នីតិវិធីផ្សព្វផ្សាយបញ្ជីសវនកម្មបរិស្ថានថ្នាក់ជាតិ

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន ដោយសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវរៀបចំលិខិតបទដ្ឋានគតិយុត្តស្ដីពីនីតិវិធីផ្សព្វផ្សាយព័ត៌មាន អំពីបញ្ជីសវនកម្មបរិស្ថានថ្នាក់ជាតិ ។

## ជំពូកទី៣
## ព័ត៌មានសម្ងាត់

**មាត្រា៥៧** ._ សិទ្ធិស្នើសុំឱ្យមានការកំណត់ជាព័ត៌មានសម្ងាត់

រូបវន្តបុគ្គល និងនីតិបុគ្គលទាំងឡាយណា ដែលតម្រូវឱ្យផ្ដល់ព័ត៌មានពាក់ព័ន្ធដូចមានចែងក្នុងមាត្រា៣៥ នៃក្រមនេះ មានសិទ្ធិស្នើសុំទៅកាន់ក្រសួង ស្ថាប័នពាក់ព័ន្ធ ដើម្បីចាត់ទុកព័ត៌មានមួយចំនួន ឬព័ត៌មានទាំងអស់ ជាព័ត៌មានសម្ងាត់ ។

ការស្នើសុំឱ្យរក្សាភាពសម្ងាត់នេះ ត្រូវបញ្ជាក់អំពីមូលហេតុ ដែលចាត់ទុកព័ត៌មានណាមួយជាព័ត៌មានសម្ងាត់ ។

**មាត្រា៥៨** ._ លក្ខណៈវិនិច្ឆ័យអប្បបរមាសម្រាប់ព័ត៌មានសម្ងាត់

ការស្នើសុំចាត់ទុកព័ត៌មានណាមួយជាព័ត៌មានសម្ងាត់ ត្រូវបង្ហាញថាការខូចខាតដែលកើតឡើងដោយសារការបង្ហាញព័ត៌មាននោះជាសាធារណៈ មានទំហំធំជាងផលប្រយោជន៍សាធារណៈដែលត្រូវការពារ ។

**មាត្រា៥៩** ._ ការកំណត់អំពីព័ត៌មានសម្ងាត់

ក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវសម្រេចយល់ព្រម ឬបដិសេធលើសំណើសុំចាត់ទុកព័ត៌មានណាមួយជាព័ត៌មានសម្ងាត់ ដោយត្រូវបញ្ជាក់ហេតុផលជាលាយលក្ខណ៍អក្សរ។ ការធ្វើសេចក្ដីសម្រេចនេះត្រូវដាក់ឱ្យសាធារណជនអាចស្វែងរកបាន ។

នីតិវិធីសម្រាប់ការកំណត់ព័ត៌មានណាមួយជាព័ត៌មានសម្ងាត់ ត្រូវកំណត់ដោយលិខិតបទដ្ឋានគតិយុត្តរបស់ក្រសួង ស្ថាប័នពាក់ព័ន្ធ ។

## ជំពូកទី៤
## ការស្នើសុំព័ត៌មាន

**មាត្រា៦០** ._ សិទ្ធិស្នើសុំព័ត៌មានសាធារណៈ

រូបវន្តបុគ្គល ឬនីតិបុគ្គល មានសិទ្ធិស្នើសុំព័ត៌មានពីម្ចាស់គម្រោង ឬក្រសួង ស្ថាប័នពាក់ព័ន្ធ ដូចមានចែងក្នុងមាត្រា៣៥ នៃក្រមនេះ លើកលែងតែព័ត៌មាននោះ ជាព័ត៌មានសម្ងាត់ ។

**មាត្រា៦១** ._ លក្ខខណ្ឌក្នុងការបដិសេធសំណើដោយក្រសួង ស្ថាប័នពាក់ព័ន្ធ

ក្រសួង ស្ថាប័នពាក់ព័ន្ធ មានសិទ្ធិបដិសេធការស្នើសុំព័ត៌មាន ក្នុងករណី ដូចខាងក្រោម៖

១- មិនមានព័ត៌មានដែលបានស្នើសុំ ។

២- សំណើសុំមិនមានបញ្ជាក់ហេតុផលត្រឹមត្រូវ ។

៣- សំណើសុំមានលក្ខណៈទូទៅពេក ។

ក្រសួង ស្ថាប័នពាក់ព័ន្ធ មិនត្រូវបដិសេធសំណើសុំព័ត៌មាន ក្នុងករណីដូចខាងក្រោម៖

១- ព័ត៌មានដែលបានស្នើសុំនោះធ្លាប់ត្រូវបានផ្តល់ពីមុនរួចហើយ ។

២- ព័ត៌មានដែលបានស្នើសុំនោះ មិនទាន់ចាត់ទុកថា ជាព័ត៌មានសម្ងាត់។

ក្នុងករណីក្រសួង ស្ថាប័នពាក់ព័ន្ធ បដិសេធសំណើសុំបង្ហាញព័ត៌មាន ដូចមានចែងក្នុងមាត្រានេះ ក្រសួង ស្ថាប័ននោះ ត្រូវបញ្ជាក់ហេតុផលជាលាយលក្ខអក្សរទៅកាន់អ្នកស្នើសុំ ។

**មាត្រា៦២** ._ លក្ខខណ្ឌក្នុងការបដិសេធសំណើដោយម្ចាស់គម្រោង

ម្ចាស់គម្រោងអាចបដិសេធចំពោះសំណើសុំបង្ហាញព័ត៌មាន ដោយរូបវន្តបុគ្គល ឬនីតិបុគ្គល ក្នុងលក្ខខណ្ឌដូចខាងក្រោម៖

១- គ្មានព័ត៌មានដែលបានស្នើសុំ ។

២- សំណើសុំមិនមានបញ្ជាក់ហេតុផលត្រឹមត្រូវ ។

៣- សំណើសុំមានលក្ខណៈទូទៅពេក ។

ម្ចាស់គម្រោង មិនត្រូវបដិសេធសំណើសុំព័ត៌មាន ក្នុងករណីដូចខាងក្រោម៖

១- ព័ត៌មានដែលបានស្នើសុំនោះធ្លាប់ត្រូវបានផ្តល់ពីមុនរួចហើយ ឬ

២- ព័ត៌មានដែលបានស្នើសុំនោះ មិនទាន់ចាត់ទុកថាជាព័ត៌មានសម្ងាត់។

ក្នុងករណីម្ចាស់គម្រោងបដិសេធសំណើសុំបង្ហាញព័ត៌មាន ដូចមានចែងក្នុងមាត្រានេះ ម្ចាស់គម្រោងត្រូវបញ្ជាក់ហេតុផលជាលាយល័ក្ខអក្សរទៅកាន់អ្នកស្នើសុំ ។

**មាត្រា៦៣** ._ នីតិវិធីស្នើសុំព័ត៌មាន

ក្រសួង ស្ថាប័នពាក់ព័ន្ធអាចរៀបចំលិខិតបទដ្ឋានគតិយុត្តស្តីពីនីតិវិធីស្នើសុំព័ត៌មាន ។

នីតិវិធីស្នើសុំព័ត៌មាន ត្រូវកំណត់ដោយលិខិតបទដ្ឋានគតិយុត្តរបស់ក្រសួង ស្ថាប័នពាក់ព័ន្ធ ។

## គន្ថីទី២

## ការវាយតម្លៃ និងការអង្កេតតាមដានបរិស្ថាន

## មាតិកាទី១

## ការវាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្រ

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**មាត្រា៦៤** ._ ក្របខ័ណ្ឌនៃការវាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្រ

គោលនយោបាយ ផែនការ និងកម្មវិធីនានា ដែលបានរៀបចំឡើងដោយក្រសួង ស្ថាប័នមានសមត្ថកិច្ច ត្រូវធ្វើការវាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្រ ស្របតាមបទប្បញ្ញត្តិនៃក្រមនេះ មុនបញ្ជូនទៅរាជរដ្ឋាភិបាលសម្រេច ។

**មាត្រា៦៥** ._ វិសាលភាព

ការវាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្រ មានវិសាលភាពអនុវត្តចំពោះគោលនយោបាយ ផែនការ និងកម្មវិធីដូចខាងក្រោម៖

១. អាចបង្កផលប៉ះពាល់គួរឱ្យកត់សម្គាល់ចំពោះបរិស្ថាន ។

២. ពាក់ព័ន្ធនឹងវិស័យដែលកំណត់ដោយលិខិតបទដ្ឋានគតិយុត្តស្តីពីលក្ខណៈវិនិច្ឆ័យនៃការធ្វើចំណាត់ថ្នាក់ របស់ក្រសួង ស្ថាប័នទទួលបន្ទុកអភិវឌ្ឍន៍ដោយចីរភាព ។

**មាត្រា៦៦** ._ ក្រសួង ស្ថាប័នទទួលបន្ទុក

ក្រសួង ស្ថាប័នទទួលបន្ទុកអភិវឌ្ឍន៍ដោយចីរភាព ត្រូវទទួលខុសត្រូវចំពោះ ៖

១- ការពិនិត្យ ផ្តល់យោបល់ និងឯកភាព លើដំណើរការ និងរបាយការណ៍ វាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្រ ។

២- សហការជាមួយក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន ដើម្បីពង្រឹងការអនុវត្តតាមបទប្បញ្ញត្តិស្តីពីការវាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្រ ។

**មាត្រា៦៧** ._ ការអនុវត្ត

ក្រសួង ស្ថាប័នទទួលបន្ទុកអភិវឌ្ឍន៍ដោយចីរភាព ដោយសហការជាមួយក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន ត្រូវរៀបចំលិខិតបទដ្ឋានគតិយុត្ត ស្តីពីការវាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្រ ដែលត្រូវដាក់បញ្ចូលនូវចំណុចដូចខាងក្រោម ៖

១- នីតិវិធីលម្អិតស្តីពីការវាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្រ

២- លក្ខណៈវិនិច្ឆ័យនៃការធ្វើចំណាត់ថ្នាក់ ដើម្បីកំណត់ពីសក្តានុពលនៃគោលនយោបាយ ផែនការ និងកម្មវិធីដែលអាចបង្កផលប៉ះពាល់គួរឱ្យកត់សម្គាល់ដល់បរិស្ថាន

៣- ដំណើរនៃការចូលរួមជាសាធារណៈ និងសិទ្ធិទទួលបានព័ត៌មានបរិស្ថាន ស្របតាមបទប្បញ្ញត្តិនៃក្រមនេះ

៤- ខ្លឹមសារ និងទម្រង់នៃរបាយការណ៍វាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្រ និង

៥- វិធីសាស្ត្រ និងនីតិវិធីសម្រាប់ការអង្កេតតាមដាន ការវាយតម្លៃ និងការរៀបចំរបាយការណ៍ស្តីពីការអនុវត្តអនុសាសន៍ដែលទទួលបានការឯកភាពនៅក្នុងការវាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្រ ។

## ជំពូកទី២
## ដំណើរការវាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្រ

**មាត្រា៦៨** ._ ការរៀបចំគោលនយោបាយ ផែនការ និងកម្មវិធី

ការវាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្រ ត្រូវធ្វើឡើងដំណាលគ្នាជាមួយនឹងការរៀបចំគោលនយោបាយ ផែនការ និងកម្មវិធីដែលត្រូវធ្វើការវាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្រ ។

**មាត្រា៦៩ ._** នីតិវិធីនៃការវាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្រ

នីតិវិធីនៃការវាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្រ ត្រូវអនុវត្តតាមដំណាក់កាល ដូចខាងក្រោម៖

១- ការធ្វើចំណាត់ថ្នាក់

២- ការកំណត់វិសាលភាព

៣- ការរៀបចំរបាយការណ៍ការវាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្រ

៤- ការពិនិត្យ ផ្តល់យោបល់ និងឯកភាពលើរបាយការណ៍ការវាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្រ

៥- ការអនុវត្តរបាយការណ៍វាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្រ ចំពោះគោលនយោបាយ ផែនការ និងកម្មវិធី និង

៦- ការអង្កេតតាមដាន ការវាយតម្លៃ និងការរៀបចំរបាយការណ៍ស្តីពីការអនុវត្តរបាយការណ៍វាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្រ ចំពោះគោលនយោបាយ ផែនការ និងកម្មវិធី ។

**មាត្រា៧០ ._** ក្រសួង ស្ថាប័នទទួលបន្ទុករៀបចំរបាយការណ៍វាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្រ

ក្រសួង ស្ថាប័នមានសមត្ថកិច្ចតាមវិស័យ ត្រូវរៀបចំរបាយការណ៍វាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្រ និងដាក់ជូនក្រសួង ស្ថាប័នទទួលបន្ទុកអភិវឌ្ឍន៍ដោយចីរភាព ដើម្បីពិនិត្យ ផ្តល់យោបល់ និងឯកភាព ។

ក្រសួង ស្ថាប័នមានសមត្ថកិច្ចតាមវិស័យ អាចរៀបចំរបាយការណ៍វាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្រដោយខ្លួនឯង ឬជួលទីប្រឹក្សាដែលទទួលស្គាល់ដោយក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន ដើម្បីរៀបចំរបាយការណ៍វាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្រ ។

**មាត្រា៧១ ._** ការធ្វើសេចក្តីសម្រេចលើរបាយការណ៍វាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្រ

បន្ទាប់ពីបានធ្វើការពិនិត្យ និងផ្តល់យោបល់លើរបាយការណ៍វាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្រ ក្រសួង ស្ថាប័នទទួលបន្ទុកអភិវឌ្ឍន៍ដោយចីរភាព ត្រូវធ្វើសេចក្តីសម្រេច ដូចខាងក្រោម ៖

១- ផ្តល់យោបល់ និងបង្គាប់ឱ្យកែសម្រួល ឬកែតម្រូវរបាយការណ៍វាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្រជាមុនសិន មុនពេលបញ្ជូនរបាយការណ៍វាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្រសាជាថ្មី ដើម្បីពិនិត្យ និងផ្តល់យោបល់ម្តងទៀត ឬ

២- ផ្តល់ការឯកភាពលើរបាយការណ៍វាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្រ ។

**មាត្រា៧២** ._ ការវិភាគអំពីការប្រែប្រួលអាកាសធាតុនៅក្នុងការវាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្រ

ក្រសួង ស្ថាប័នមានសមត្ថកិច្ច ដោយសហការជាមួយក្រសួង ស្ថាប័នទទួលបន្ទុកអភិវឌ្ឍន៍ដោយចីរភាព និងក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន ត្រូវដាក់បញ្ចូលការវិភាគលើការប្រែប្រួលអាកាសធាតុ ទៅក្នុងការវាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្រ ។

**មាត្រា៧៣** ._ ការពិនិត្យ ផ្តល់យោបល់ និងឯកភាពលើរបាយការណ៍វាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្រ

ក្រសួង ស្ថាប័នទទួលបន្ទុកអភិវឌ្ឍន៍ដោយចីរភាព ត្រូវពិនិត្យ និងផ្តល់យោបល់លើរបាយការណ៍វាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្រ ក្នុងរយៈពេល ៩០ (កៅសិប) ថ្ងៃ នៃថ្ងៃធ្វើការ គិតចាប់ពីថ្ងៃទទួលបានរបាយការណ៍ ។

រយៈពេល ៩០ (កៅសិប) ថ្ងៃ សម្រាប់ការពិនិត្យ និងផ្តល់យោបល់ខាងលើនេះ ត្រូវរាប់សាជាថ្មី នៅពេលដែលក្រសួង ស្ថាប័នមានសមត្ថកិច្ច បានដាក់ពាក្យស្នើសុំពិនិត្យ និងផ្តល់យោបល់លើរបាយការណ៍វាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្រដែលបានកែតម្រូវ ឬកែសម្រួល ស្របតាមសេចក្តីបង្គាប់ ឬការណែនាំ របស់ក្រសួង ស្ថាប័នទទួលបន្ទុកអភិវឌ្ឍន៍ដោយចីរភាព ។

## ជំពូកទី៣
## ការចូលរួមជាសាធារណៈក្នុងនីតិវិធីនៃការវាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្រ

**មាត្រា៧៤** ._ ការចូលរួមជាសាធារណៈ និងសិទ្ធិទទួលបានព័ត៌មាន

ដំណើរការរៀបចំរបាយការណ៍វាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្រ ត្រូវអនុវត្តតាមបទប្បញ្ញត្តិស្តីពីការចូលរួមជាសាធារណៈ និងសិទ្ធិទទួលបានព័ត៌មានបរិស្ថាន ដូចមានចែងក្នុងក្រមនេះ ។

**មាត្រា៧៥** ._ ការយកចិត្តទុកដាក់ជាពិសេស

ដំណើរការរៀបចំរបាយការណ៍វាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្រ ត្រូវយកចិត្តទុកដាក់ជាពិសេស និងផ្តល់ឱកាសឱ្យមានការចូលរួមពីជនងាយរងគ្រោះ ជនជាតិភាគតិច និងជនជាតិដើមភាគតិច ។

**មាត្រា៧៦** ._ ពេលវេលាសម្រាប់ការចូលរួមជាសាធារណៈ

ក្រសួង ស្ថាប័នទទួលបន្ទុកអភិវឌ្ឍន៍ដោយចីរភាព ត្រូវធ្វើសេចក្ដីសម្រេចលើរបាយការណ៍វាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្រ ដែលក្រសួង ស្ថាប័នមានសមត្ថកិច្ចបានស្នើមក បន្ទាប់ពីបានដាក់ឱ្យសាធារណជនអាចស្វែងរកបាន និងផ្តល់យោបល់ ក្នុងរយៈពេល យ៉ាងហោចណាស់ ៩០ (សែសិប) ថ្ងៃ នៃថ្ងៃធ្វើការ ។

## ជំពូកទី៤
## ការអនុវត្តការរៀបចំរបាយការណ៍វាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្រ ចំពោះ គោលនយោបាយ ផែនការ និងកម្មវិធី

**មាត្រា៧៧ .**_ ការដាក់បញ្ចូលលទ្ធផលនៃការរៀបចំរបាយការណ៍វាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្រ

ក្រសួង ស្ថាប័នមានសមត្ថកិច្ច ដែលរៀបចំរបាយការណ៍វាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្រត្រូវ ៖

១- ត្រូវដាក់បញ្ចូលលទ្ធផលនៃការរៀបចំរបាយការណ៍វាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្រ និងមតិយោបល់កែសម្រួលរបស់ក្រសួង ស្ថាប័នទទួលបន្ទុកអភិវឌ្ឍន៍ដោយចីរភាពទៅក្នុងគោលនយោបាយ ផែនការ និងកម្មវិធី មុននឹងបញ្ចប់របាយការណ៍វាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្រ និង

២- បង្ហាញអំពីរបៀបដែលលទ្ធផលនៃការរៀបចំរបាយការណ៍ និងមតិយោបល់អំពីការកែសម្រួល ឬមិនកែសម្រួល ត្រូវបានដាក់បញ្ចូលទៅក្នុងគោលនយោបាយ ផែនការ និងកម្មវិធីចុងក្រោយ ។

**មាត្រា៧៨ .**_ ការអង្កេតតាមដាន

ក្រសួង ស្ថាប័នទទួលបន្ទុកអភិវឌ្ឍន៍ដោយចីរភាព ដោយសហការជាមួយក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន ត្រូវរៀបចំកម្មវិធីដើម្បីអង្កេតតាមដានហេតុប៉ះពាល់បរិស្ថាន នៅក្នុងការអនុវត្តគោលនយោបាយ ផែនការ និងកម្មវិធី ដូចមានកំណត់នៅក្នុងរបាយការណ៍វាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្រ និងលិខិតបទដ្ឋានគតិយុត្តស្តីពីការអង្កេតតាមដានការវាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្រនៃក្រមនេះ ។

**មាត្រា៧៩ .**_ លទ្ធផលអង្កេតតាមដាន

លទ្ធផលអង្កេតតាមដាន ត្រូវដាក់ឱ្យក្រសួង ស្ថាប័នមានសមត្ថកិច្ច និងសាធារណជនអាចស្វែងរកបាន ។

## មាតិកាទី២
## ការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន
## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ
## ផ្នែកទី១
## ក្របខ័ណ្ឌ និងវិសាលភាព

**មាត្រា៨០**._ ក្របខ័ណ្ឌនៃការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន

គម្រោងអភិវឌ្ឍន៍ទាំងអស់នៅក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវធ្វើការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ដើម្បីគាំទ្រដល់ការអភិវឌ្ឍដោយចីរភាព តាមរយៈ ៖

១- ការកំណត់ឱ្យមានការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ចំពោះគម្រោងអភិវឌ្ឍន៍ ទាំងសាធារណៈ និងឯកជន មុននឹងដាក់ជូនអង្គភាពមានសមត្ថកិច្ច ឬក្រសួងសាមី ឬ/និង រាជរដ្ឋាភិបាលសម្រេច ។

២- ការរៀបចំនីតិវិធីដែលមានភាពច្បាស់លាស់ មានតម្លាភាព និងមានប្រសិទ្ធភាពសម្រាប់ការវាយតម្លៃហេតុប៉ះពាល់បរិស្ថានដែលកើតចេញពីគម្រោងអភិវឌ្ឍន៍ ។

៣- ការអនុវត្តបច្ចេកទេសដ៏ប្រសើរបំផុតដែលអាចស្វែងរកបាន និងទម្លាប់អនុវត្តល្អៗជាអន្តរជាតិ ដើម្បីវាយតម្លៃផលប៉ះពាល់លើសុខុមាលភាពមនុស្ស ធនធានធម្មជាតិ និងបេតិកភណ្ឌវប្បធម៌ ។

៤- លើកកម្ពស់ការចូលរួមជាសាធារណៈ នៅក្នុងការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ។

៥- លើកកម្ពស់ប្រសិទ្ធភាពនៃការរៀបចំ ការអនុវត្ត និងតាមដានការអនុវត្តវិធានការបង្ការ បញ្ចៀស ឬ កាត់បន្ថយផលប៉ះពាល់អវិជ្ជមាន និងវិធានការជួសជុល ស្តារឡើងវិញ ឬសងសំណងការខូចខាតទាំងឡាយដែលបង្កឡើងដោយគម្រោងអភិវឌ្ឍន៍ ។

**មាត្រា៨១**._ វិសាលភាព

មាតិកានេះមានវិសាលភាពអនុវត្តចំពោះគម្រោងឯកជន និងសាធារណៈ ដែលជាគម្រោងស្នើសុំ គម្រោងដែលមានស្រាប់ ឬគម្រោងកំពុងដំណើការ ដែលមិនទាន់បានធ្វើការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ។

លក្ខណៈវិនិច្ឆ័យ និងចំណាត់ថ្នាក់ប្រភេទគម្រោង ដែលត្រូវធ្វើការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ត្រូវកំណត់ដោយលិខិតបទដ្ឋានគតិយុត្តរបស់ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន ស្របតាមបទប្បញ្ញត្តិនៃក្រមនេះ ។

**មាត្រា៨២** ._ គម្រោងលើកលែង

ក្រមនេះមិនអនុវត្តចំពោះគម្រោងអភិវឌ្ឍ ឬសកម្មភាពរបស់រដ្ឋ ដែលបានអនុម័តដោយរាជរដ្ឋាភិបាល ឬរដ្ឋសភា ហើយដែលចាត់ទុកជាគម្រោងចាំបាច់ និងបន្ទាន់ទាក់ទងនឹងសន្តិសុខជាតិ បូរណភាពទឹកដី អធិបតេយ្យជាតិ ឬការគ្រប់គ្រងគ្រោះមហន្តរាយនានា ។

## ផ្នែកទី២
## ការហាមឃាត់ចំពោះសកម្មភាពដែលមិនបានធ្វើការវាយតម្លៃបរិស្ថាន

**មាត្រា៨៣** ._ គោលការណ៍គ្រឹះនៃការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន

រាល់គម្រោង ត្រូវធ្វើការវាយតម្លៃហេតុប៉ះពាល់ទៅលើបរិស្ថាន សុខភាព សង្គម សេដ្ឋកិច្ច ធនធានធម្មជាតិ និងវប្បធម៌ ដោយមានការឯកភាពពីក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថានជាមុនសិន មុននឹងបញ្ជូនទៅរាជរដ្ឋាភិបាលសម្រេច ។

**មាត្រា៨៤** ._ ការចេញលិខិត និងវិញ្ញាបនបត្រឯកភាព

ម្ចាស់គម្រោង មិនត្រូវចាប់ផ្តើមសកម្មភាពគម្រោង ឬប្រតិបត្តិការគម្រោងឡើយ លុះត្រាតែក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន បានចេញលិខិត និងវិញ្ញាបនបត្រឯកភាពលើ របាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង ឬពេញលេញ ឬកិច្ចសន្យាការពារបរិស្ថាន ។

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន មានសិទ្ធិអំណាចព្យួររាល់សកម្មភាពសាងសង់ ឬប្រតិបត្តិការគម្រោង ដែលមិនមានលិខិត និងវិញ្ញាបនបត្រឯកភាពលើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង ឬពេញលេញ ឬកិច្ចសន្យាការពារបរិស្ថាន ។

**មាត្រា៨៥** ._លិខិតអនុញ្ញាត

ក្រសួង ស្ថាប័នដែលចេញលិខិតអនុញ្ញាតលើគម្រោង ត្រូវគោរពតាមលក្ខខណ្ឌកំណត់នៅក្នុងលិខិត ឬវិញ្ញាបនបត្រឯកភាពលើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង ឬពេញលេញ ឬកិច្ចសន្យាការពារបរិស្ថាន ។ រាល់លិខិតអនុញ្ញាតទាំងឡាយណាដែលផ្ទុយនឹងលក្ខខណ្ឌដែលមានកំណត់នៅក្នុងលិខិត និងវិញ្ញាបនបត្រឯកភាពលើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង ឬពេញលេញ ឬកិច្ចសន្យាការពារបរិស្ថាន ត្រូវចាត់ទុកជាមោឃៈ ។

**មាត្រា៨៦** ._ គោលការណ៍ទូទៅ

កិច្ចដំណើរការនៃការវាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង ឬពេញលេញ ឬកិច្ចសន្យាការពារបរិស្ថាន មិនមានសុពលភាពទេ លុះត្រាតែកិច្ចដំណើរការនោះបានធ្វើឡើងស្របតាមលក្ខខណ្ឌ និងគោលការណ៍ទូទៅ ដូចមានចែងក្នុងក្រមនេះ ។

## ជំពូកទី២
## ប្រព័ន្ធវាយតម្លៃហេតុប៉ះពាល់បរិស្ថាន
### ផ្នែកទី១
### ក្រសួង ស្ថាប័នទទួលបន្ទុក

**មាត្រា៨៧** ._ ការទទួលខុសត្រូវរបស់ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន ត្រូវទទួលបន្ទុកគ្រប់គ្រងលើការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ។

**មាត្រា៨៨** ._ ការរៀបចំលិខិតបទដ្ឋានគតិយុត្តស្ដីពីការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន ត្រូវរៀបចំលិខិតបទដ្ឋានគតិយុត្ត ដើម្បីគាំទ្រការអនុវត្តការវាយតម្លៃហេតុប៉ះពាល់បរិស្ថានដោយដាក់បញ្ចូលចំណុចដូចខាងក្រោមៈ

១- កំណត់លក្ខណៈវិនិច្ឆ័យនៃការធ្វើចំណាត់ថ្នាក់គម្រោង ដើម្បីកំណត់អំពីកម្រិតនៃការវាយតម្លៃហេតុប៉ះពាល់បរិស្ថានសម្រាប់គម្រោងដែលមានស្រាប់ ឬគម្រោងកំពុងដំណើរការ និងគម្រោងស្នើសុំ ក្រោយពេលក្រមនេះចូលជាធរមាន ។

២- នីតិវិធី លក្ខខណ្ឌតម្រូវ ខ្លឹមសារអប្បបរមា និងទម្រង់បែបបទ សម្រាប់ការរៀបចំការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន របាយការណ៍នៃការកំណត់វិសាលភាពគម្រោង លក្ខខណ្ឌការងារ ការវាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង ការរៀបចំផែនការគ្រប់គ្រងបរិស្ថាន កិច្ចសន្យាការពារបរិស្ថាន និងផែនការគាំពារបរិស្ថាន ។

៣- នីតិវិធី លក្ខខណ្ឌតម្រូវ និងលក្ខណៈវិនិច្ឆ័យ ខ្លឹមសារ និងទម្រង់បែបបទសម្រាប់ការរៀបចំរបាយការណ៍វាយតម្លៃហានិភ័យ ការទទួលខុសត្រូវរបស់ក្រសួង ស្ថាប័នមានសមត្ថកិច្ច និងគុណវិឌ្ឍិរបស់ទីប្រឹក្សាវាយតម្លៃហានិភ័យដែលមានការទទួលស្គាល់ក្នុងការរៀបចំរបាយការណ៍វាយតម្លៃហានិភ័យ ដោយប្រើប្រាស់ទម្លាប់អនុវត្តល្អបំផុត និងគោលការណ៍នៃការវាយតម្លៃហានិភ័យដែលមានលក្ខណៈវិទ្យាសាស្ត្រ ។ ការវាយតម្លៃហានិភ័យជាផ្នែកមួយនៃរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន ។

៤- នីតិវិធី លក្ខខណ្ឌតម្រូវ និងលក្ខណៈវិនិច្ឆ័យ ខ្លឹមសារ និងទម្រង់បែបបទធ្វើសវនកម្មបរិស្ថាន ការទទួលខុសត្រូវរបស់ក្រសួង ស្ថាប័នមានសមត្ថកិច្ច និងគុណវុឌ្ឍិសម្រាប់ការចុះបញ្ជី និងការទទួលស្គាល់សវនករបរិស្ថាន ។

៥- នីតិវិធី លក្ខខណ្ឌតម្រូវ និងលក្ខណៈវិនិច្ឆ័យ ខ្លឹមសារ និងទម្រង់បែបបទសម្រាប់ការរៀបចំរបាយការណ៍វាយតម្លៃហានិភ័យដោយចីរភាព ។

៦- ការបង្កើត និងមុខងាររបស់គណៈកម្មាធិការជំនាញត្រួតពិនិត្យ ។

៧- នីតិវិធី និងលក្ខខណ្ឌតម្រូវសម្រាប់ការចូលរួមជាសាធារណៈ និងសិទ្ធិទទួលបានព័ត៌មាន ។

៨- នីតិវិធីសម្រាប់ការផ្លាស់ទីលំនៅថ្មី និងការសងសំណងការខូចខាតចំពោះអ្នកទទួលរងផលប៉ះពាល់ពីគម្រោង ។

៩- កំណត់លក្ខខណ្ឌ គុណវុឌ្ឍិ ទម្រង់បែបបទ និងនីតិវិធីសម្រាប់ការចុះបញ្ជីទីប្រឹក្សាវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ។

១០- រៀបចំ បង្កើតក្របខ័ណ្ឌគតិយុត្ត សម្រាប់ការវាយតម្លៃហេតុប៉ះពាល់បរិស្ថានឆ្លងដែន រួមមាន លិខិតបទដ្ឋានគតិយុត្ត គោលការណ៍ណែនាំ និងវិធីសាស្ត្រនៃការវាយតម្លៃហេតុប៉ះពាល់បរិស្ថានឆ្លងដែន ។

១១- ការណែនាំ និងលក្ខខណ្ឌតម្រូវសម្រាប់ម្ចាស់គម្រោង និងស្ថាប័នមានសមត្ថកិច្ចទាក់ទងនឹងសវនកម្មបរិស្ថាន ការអង្កេតតាមដាន និងការរៀបចំរបាយការណ៍ ។

**មាត្រា៨៩ ._** ការទទួលខុសត្រូវការធ្វើសវនកម្ម អធិការកិច្ច និងការអង្កេតតាមដាន

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន ត្រូវទទួលខុសត្រូវក្នុងការធ្វើសវនកម្ម អធិការកិច្ច និងអង្កេតតាមដានគម្រោង ស្របតាមបទប្បញ្ញត្តិនៃក្រមនេះ។

## ផ្នែកទី២
## គណៈកម្មាធិការជំនាញត្រួតពិនិត្យ

**មាត្រា៩០ ._** យោបល់ផ្នែកបច្ចេកទេស

គម្រោងស្នើសុំដែលតម្រូវឱ្យមានការវាយតម្លៃហេតុប៉ះពាល់បរិស្ថានពេញលេញ ត្រូវមានមតិយោបល់បច្ចេកទេសរបស់គណៈកម្មាធិការជំនាញត្រួតពិនិត្យ ។ ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន ត្រូវពិនិត្យ និងពិចារណាមតិយោបល់របស់គណៈកម្មាធិការជំនាញត្រួតពិនិត្យ មុនធ្វើសេចក្តីសម្រេចលើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានពេញលេញ ។

**មាត្រា៩១ ._** សមាសភាពនៃគណៈកម្មាធិការជំនាញត្រួតពិនិត្យ

សមាសភាពនៃគណៈកម្មាធិការជំនាញត្រួតពិនិត្យ រួមមាន៖

១- មន្ត្រីបច្ចេកទេសពីក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន ក្រសួង ស្ថាប័នមានសមត្ថកិច្ច និងរដ្ឋបាលថ្នាក់ក្រោមជាតិ ។

២- អ្នកជំនាញបច្ចេកទេសឯករាជ្យដែលមានគុណវុឌ្ឍិ និងបទពិសោធន៍ត្រួតពិនិត្យលើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន ។

៣- តំណាងពីក្រសួង ស្ថាប័នទទួលបន្ទុកកិច្ចការនារី ។

៤- តំណាងពីអង្គការមិនមែនរដ្ឋាភិបាល ។

សមាជិកគណៈកម្មាធិការជំនាញត្រួតពិនិត្យ អាចមានការប្រែប្រួលពីគម្រោងមួយទៅគម្រោងមួយ តាមការជ្រើសរើសរបស់ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន អាស្រ័យទៅតាមទិដ្ឋភាពបច្ចេកទេសនៃរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានពេញលេញ ។

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន ត្រូវរៀបចំលិខិតបទដ្ឋានគតិយុត្តស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការជំនាញត្រួតពិនិត្យ ស្របតាមបទប្បញ្ញត្តិនៃក្រមនេះ ។

**មាត្រា៩២ ._** ការទូទាត់ប្រាក់កម្រៃសេវាសម្រាប់សមាជិកគណៈកម្មាធិការជំនាញត្រួតពិនិត្យ

សមាជិកគណៈកម្មាធិការជំនាញត្រួតពិនិត្យ ត្រូវទទួលបានការទូទាត់ប្រាក់កម្រៃសេវា ដោយផ្អែកលើការព្រមព្រៀងរវាងក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន សមាជិកនីមួយៗ និងម្ចាស់គម្រោង ។

ការទូទាត់កម្រៃសេវាសម្រាប់ការចូលរួមរបស់គណៈកម្មាធិការជំនាញត្រួតពិនិត្យក្នុងការត្រួតពិនិត្យរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានពេញលេញ ត្រូវកំណត់ចំពោះតែសមាជិកគណៈកម្មការដែលធ្វើការក្រៅម៉ោងការងាររដ្ឋរបស់ខ្លួនតែប៉ុណ្ណោះ និងត្រូវកត់ត្រាចូលក្នុងកំណត់ត្រាការងាររដ្ឋ ។ បុគ្គលិក មន្ត្រីរាជការ ដែលមានកាតព្វកិច្ចក្នុងការចូលរួមនៅក្នុងដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថានពេញលេញ មិនត្រូវទទួលបានកម្រៃសេវាបន្ថែមលើការងារត្រួតពិនិត្យរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានពេញលេញនោះទេ ។

**មាត្រា៩៣**._ ការទទួលខុសត្រូវរបស់កម្មាធិការជំនាញត្រួតពិនិត្យ

គណៈកម្មាធិការជំនាញត្រួតពិនិត្យមានការទទួលខុសត្រូវ ដូចខាងក្រោម៖

១- ពិនិត្យ និងវាយតម្លៃរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានពេញលេញ ។

២- ពិចារណាលើមតិយោបល់ដែលទទួលបានពីដំណើរការនៃការចូលរួមជាសាធារណៈ និងផ្តល់ហេតុផលចំពោះការបញ្ចូល ឬមិនបញ្ចូលមតិយោបល់របស់សាធារណជនទៅក្នុងអនុសាសន៍ចុងក្រោយរបស់គណៈកម្មាធិការជំនាញត្រួតពិនិត្យដែលត្រូវបញ្ជូនទៅក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន។

៣- ផ្តល់យោបល់ និងអនុសាសន៍លើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានពេញលេញ ។

៤- ផ្តល់អនុសាសន៍ជាការឯកភាព ឬបដិសេធចំពោះរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានពេញលេញ ដោយបញ្ជាក់ពីលក្ខខណ្ឌនៃការឯកភាព និងមូលហេតុនៃការបដិសេធ ។

## ផ្នែកទី៣
## ម្ចាស់គម្រោង

**មាត្រា៩៤** ._ ការចំណាយសម្រាប់ការរៀបចំ និងការអនុវត្តផែនការគ្រប់គ្រងបរិស្ថាន

ម្ចាស់គម្រោងត្រូវទទួលបន្ទុកចំណាយ លើការរៀបចំ និងការអនុវត្តផែនការគ្រប់គ្រងបរិស្ថានរបស់គម្រោង ឬផែនការគាំពារបរិស្ថាន និងថ្លៃចំណាយលើការអនុវត្ត និងការអង្កេតតាមដានវិធានការ

កាត់បន្ថយហេតុប៉ះពាល់បរិស្ថាន និងសង្គម ដូចមានកំណត់នៅក្នុងផែនការគ្រប់គ្រងបរិស្ថាន ឬ ផែនការគាំពារបរិស្ថាន ។

**មាត្រា៩៥ ._** ការទទួលខុសត្រូវចំពោះការធ្វើ ឬមិនធ្វើសកម្មភាព

ម្ចាស់គម្រោងត្រូវទទួលខុសត្រូវផ្នែកហិរញ្ញវត្ថុ និងផ្លូវច្បាប់ចំពោះការធ្វើ ឬមិនធ្វើសកម្មភាព របស់ខ្លួន ។

ម្ចាស់គម្រោងត្រូវទទួលខុសត្រូវផ្នែកហិរញ្ញវត្ថុ និងផ្លូវច្បាប់ផងដែរ ចំពោះការធ្វើ ឬមិនធ្វើ សកម្មភាពរបស់អ្នកម៉ៅការ អ្នកម៉ៅការបន្ត មន្ត្រី កម្មករនយោជិក ភ្នាក់ងារ អ្នកតំណាង និងទីប្រឹក្សា ដែលម្ចាស់គម្រោងបានផ្តល់ការងារឱ្យ ឬជួល ឬផ្តល់សិទ្ធិអំណាចឱ្យអនុវត្តការងារគម្រោងជំនួសខ្លួន ។

**មាត្រា៩៦ ._** ការទទួលខុសត្រូវចំពោះការផ្លាស់ទីលំនៅថ្មីដោយមិនស្ម័គ្រចិត្ត និងផលប៉ះពាល់ចំពោះ ជីវភាពរស់នៅ

ក្នុងករណីដែលគម្រោងបង្កឱ្យមានការផ្លាស់ទីលំនៅថ្មីដោយមិនស្ម័គ្រចិត្ត និងបង្កផលប៉ះពាល់ ចំពោះជីវភាពរស់នៅ ម្ចាស់គម្រោងត្រូវទទួលខុសត្រូវផ្នែកហិរញ្ញវត្ថុ និងផ្លូវច្បាប់ចំពោះអ្នកដែលទទួល រងផលប៉ះពាល់ពីគម្រោង រហូតដល់ពេលអ្នកទទួលរងផលប៉ះពាល់ទទួលបានស្ថិរភាពផ្នែកសង្គម និង សេដ្ឋកិច្ច និងជីវភាពរស់នៅ យ៉ាងហោចណាស់ត្រឹមកម្រិតជីវភាពនៅមុនពេលចាប់ផ្តើមអនុវត្តគម្រោង ។

**មាត្រា៩៧ ._** ការទទួលខុសត្រូវចំពោះការរៀបចំ និងអនុវត្តកម្មវិធីគាំទ្រដល់ការស្តារជីវភាពរស់នៅ និងការផ្លាស់ទីលំនៅថ្មី

ម្ចាស់គម្រោងត្រូវទទួលខុសត្រូវផ្នែកហិរញ្ញវត្ថុ និងផ្លូវច្បាប់ ចំពោះការរៀបចំ និងអនុវត្តកម្មវិធី គាំទ្រដល់ការស្តារជីវភាពរស់នៅ និងការផ្លាស់ទីលំនៅថ្មី ដោយពិគ្រោះយោបល់ជាមួយអ្នកទទួលរង ផលប៉ះពាល់ពីគម្រោង ក្រសួង ស្ថាប័នមានសមត្ថកិច្ច និងអ្នកពាក់ព័ន្ធដទៃទៀត ។

**មាត្រា៩៨ ._** លិខិតអម

ម្ចាស់គម្រោងត្រូវចេញលិខិតអមទៅតាមទម្រង់ ដែលកំណត់ដោយក្រសួង ស្ថាប័នទទួលបន្ទុក បរិស្ថាន។ លិខិតនេះត្រូវភ្ជាប់ជាមួយរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង ឬពេញលេញ ឬកិច្ចសន្យាការពារបរិស្ថាន ដោយបញ្ជាក់ ដូចខាងក្រោម៖

១- ភាពត្រឹមត្រូវ និងភាពពេញលេញនៃឯកសារពាក់ព័ន្ធ។

២- ឯកសារបានរៀបចំ ដោយគោរពតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ ។

៣- គម្រោងត្រូវគោរពតាមការប្តេជ្ញាចិត្ត វិធានការកាត់បន្ថយហេតុប៉ះពាល់ ផែនការគាំពារបរិស្ថាន ឬផែនការគ្រប់គ្រងបរិស្ថាន និងផែនការដទៃទៀត និងលិខិត និងវិញ្ញាបនបត្រឯកភាពលើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង ឬពេញលេញ ឬកិច្ចសន្យាការពារបរិស្ថាន ។

**មាត្រា៩៩ .**_ កាតព្វកិច្ចក្នុងការអនុវត្តតាមលក្ខខណ្ឌនៃលិខិត និងវិញ្ញាបនបត្រឯកលើភាពរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង ឬពេញលេញ ឬកិច្ចសន្យាការពារបរិស្ថាន

ម្ចាស់គម្រោង ត្រូវអនុវត្តតាមការវាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង ឬពេញលេញ ឬកិច្ចសន្យាការពារបរិស្ថាន និងលក្ខខណ្ឌ និងការប្តេជ្ញាចិត្តពាក់ព័ន្ធនឹងគម្រោង ។

ម្ចាស់គម្រោង ត្រូវទទួលខុសត្រូវ និងតម្រូវឱ្យអ្នកម៉ៅការ និងអ្នកម៉ៅការបន្តនៃគម្រោងអនុលោមតាមកាតព្វកិច្ចទាំងអស់ ដូចមានកំណត់នៅក្នុងលិខិត និងវិញ្ញាបនបត្រឯកភាពលើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង ឬពេញលេញ ឬកិច្ចសន្យាការពារបរិស្ថាន ផែនការគ្រប់គ្រងបរិស្ថាន ផែនការគាំពារបរិស្ថាន លក្ខខណ្ឌ និងការប្តេជ្ញាចិត្តទាំងអស់របស់គម្រោង ។

**មាត្រា១០០ .**_ ការផ្ទេរ ឬផ្លាស់ប្តូរម្ចាស់គម្រោង

ក្នុងករណីមានការផ្ទេរ ឬផ្លាស់ប្តូរម្ចាស់គម្រោង ដោយហេតុផលណាមួយ នោះត្រូវអនុវត្តតាមលក្ខខណ្ឌដូចខាងក្រោម ៖

១- ម្ចាស់គម្រោងត្រូវជូនដំណឹងភ្លាមទៅកាន់ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន ។

២- លិខិត និងវិញ្ញាបនបត្រឯកភាពលើរបាយការណ៍តម្លៃហេតុប៉ះពាល់បរិស្ថានដំបូង ឬពេញលេញ ឬកិច្ចសន្យាការពារបរិស្ថាន និងលក្ខខណ្ឌទាំងអស់ ត្រូវផ្ទេរទៅឱ្យម្ចាស់គម្រោងថ្មីដោយស្វ័យប្រវត្តិ ។

កិច្ចសន្យាផ្ទេរ ឬផ្លាស់ប្តូរម្ចាស់គម្រោងមានសុពលភាពអនុវត្ត លុះត្រាតែការផ្ទេរ ឬការផ្លាស់ប្តូរនោះ ធ្វើឡើងបន្ទាប់ពីក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថានទទួលបានការជូនដំណឹងអំពីការផ្ទេរ ឬការផ្លាស់ប្តូរនោះ ។

## ផ្នែកទី៤
## ទីប្រឹក្សាវាយតម្លៃហេតុប៉ះពាល់បរិស្ថាន

**មាត្រា១០១ .**_ ការគ្រប់គ្រងទីប្រឹក្សាវាយតម្លៃហេតុប៉ះពាល់បរិស្ថាន

ទីប្រឹក្សាវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ដែលអាចជារូបវន្តបុគ្គល ឬនីតិបុគ្គល ត្រូវស្ថិតនៅក្រោមការគ្រប់គ្រងរបស់ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន។

**មាត្រា១០២ .**_ ក្រុមហ៊ុនទីប្រឹក្សាវាយតម្លៃហេតុប៉ះពាល់បរិស្ថាន

ក្រុមហ៊ុនទីប្រឹក្សាវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ត្រូវមានប្រធាន ឬបុគ្គលិក ដែលមានសញ្ជាតិខ្មែរ ។

**មាត្រា១០៣ .**_ ការចុះបញ្ជីទីប្រឹក្សា និងក្រុមហ៊ុនទីប្រឹក្សាវាយតម្លៃហេតុប៉ះពាល់បរិស្ថាន

ក្រុមហ៊ុនទីប្រឹក្សាវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ត្រូវចុះបញ្ជីដើម្បីទទួលបាននីតិសម្បទា នៅក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន ។

មានតែទីប្រឹក្សាវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ដែលបានចុះបញ្ជីជាមួយក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថានតែប៉ុណ្ណោះ ទើបអាចធ្វើការវាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង ឬពេញលេញ និងផែនការគ្រប់គ្រងបរិស្ថានស្របតាមបទប្បញ្ញត្តិនៃក្រមនេះ ។

**មាត្រា១០៤ .**_ ប្រធានក្រុមការងារវាយតម្លៃហេតុប៉ះពាល់បរិស្ថាន

ក្រុមហ៊ុនទីប្រឹក្សាវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ត្រូវមានទីប្រឹក្សាវាយតម្លៃហេតុប៉ះពាល់បរិស្ថានមួយរូប ដែលទទួលបាននីតិសម្បទាពីក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន ជាប្រធានក្រុមការងារទទួលបន្ទុករៀបចំរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន ស្របតាមបទប្បញ្ញត្តិនៃក្រមនេះ ។

**មាត្រា១០៥ .**_ ការមិនគោរពតាមលក្ខណៈវិនិច្ឆ័យនៃការចុះបញ្ជី

ទីប្រឹក្សាវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ដែលមិនគោរពតាមលក្ខណៈវិនិច្ឆ័យនៃការចុះបញ្ជីរបស់ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន ឬលក្ខខណ្ឌដែលភ្ជាប់ទៅនឹងការចុះបញ្ជី អាចត្រូវបានលុបឈ្មោះចេញពីបញ្ជីទីប្រឹក្សាវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងត្រូវហាមឃាត់មិនឱ្យចុះបញ្ជីសាជាថ្មី ។

**មាត្រា១០៦ .**_ សុពលភាពនៃការចុះបញ្ជី

ការចុះបញ្ជីជាទីប្រឹក្សាវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ត្រូវមានសុពលភាពសម្រាប់រយៈពេលអតិបរមា ៥ (ប្រាំ) ឆ្នាំ និងអាចបន្តសាជាថ្មីបាន ។

## ផ្នែកទី៥
## ស្ថាប័នហិរញ្ញវត្ថុ

**មាត្រា១០៧**._ វិសាលភាពនៃការវាយតម្លៃហានិភ័យដោយចីរភាព

ស្ថាប័ន ឬគ្រឹះស្ថានហិរញ្ញវត្ថុ និងនីតិបុគ្គល ដែលផ្តល់ការធានាផ្នែកហិរញ្ញវត្ថុ ធានារ៉ាប់រងផ្នែកហិរញ្ញវត្ថុ ឬហិរញ្ញប្បទានចំពោះគម្រោង ត្រូវធ្វើការវាយតម្លៃហានិភ័យដោយចីរភាព ដើម្បីពិនិត្យ និងកំណត់ថាម្ចាស់គម្រោងស្នើសុំ បានធ្វើការវាយតម្លៃ និងពិចារណាហេតុប៉ះពាល់បរិស្ថានដែលអាចកើតមានឡើងនៅក្នុងការរចនាគម្រោង ការគ្រប់គ្រងបរិស្ថាន ការប្រតិបត្តិគម្រោង និងការបិទគម្រោង ។

**មាត្រា១០៨**._ ការវាយតម្លៃលើថ្លៃចំណាយ

ការវាយតម្លៃហានិភ័យដោយចីរភាពសម្រាប់គម្រោងស្នើសុំ ត្រូវដាក់បញ្ចូល ៖

១- ថ្លៃចំណាយលើការវាយតម្លៃហេតុប៉ះពាល់បរិស្ថានពេញលេញ ។

២- មូលនិធិសម្រាប់វិធានការកាត់បន្ថយហេតុប៉ះពាល់បរិស្ថាន រួមមាន៖

- ថ្លៃចំណាយជាប្រចាំលើការអនុវត្តផែនការគ្រប់គ្រងបរិស្ថាន
- ការទទួលបន្ទុកចំណាយសម្រាប់ការផ្លាស់ទីលំនៅថ្មី និងសំណងខូចខាតបរិស្ថាន
- ថ្លៃចំណាយសម្រាប់សេវាកម្មប្រព័ន្ធអេកូឡូស៊ី និង
- ការធានាផ្នែកហិរញ្ញវត្ថុគ្រប់គ្រាន់សម្រាប់ការបិទគម្រោង ការស្តារឡើងវិញ និងការជួសជុលឱ្យស្របតាមលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ ។

## ជំពូកទី៣
## កិច្ចដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន
## ផ្នែកទី១
## ការវាយតម្លៃហេតុប៉ះពាល់បរិស្ថានចំពោះគម្រោងស្នើសុំ

**មាត្រា១០៩ ._** ការធ្វើចំណាត់ថ្នាក់គម្រោង

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន ត្រូវកំណត់ចំណាត់ថ្នាក់លើគម្រោងអភិវឌ្ឍន៍ ដើម្បីតម្រូវឱ្យម្ចាស់គម្រោងរៀបចំនូវឯកសារ ដូចខាងក្រោម ៖

១- របាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានពេញលេញ ។

២- របាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង ។

៣- កិច្ចសន្យាការពារបរិស្ថាន ភ្ជាប់ជាមួយផែនការគាំពារបរិស្ថាន ។

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន ត្រូវរៀបចំលិខិតបទដ្ឋានគតិយុត្តស្តីពីការធ្វើចំណាត់ថ្នាក់គម្រោង ដើម្បីកំណត់ពីកម្រិតនៃការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ស្របតាមបទប្បញ្ញត្តិនៃក្រមនេះ ។

**មាត្រា១១០._** តំបន់ដែលតម្រូវឱ្យមានការវាយតម្លៃបរិស្ថាន

ការវាយតម្លៃហេតុប៉ះពាល់បរិស្ថានពេញលេញ ត្រូវរៀបចំឡើងចំពោះគម្រោងស្នើសុំ ដែលអាចបង្កផលប៉ះពាល់អវិជ្ជមាន ដែលមានទីតាំងនៅក្នុងតំបន់ដែលមានតម្លៃអភិរក្សខ្ពស់ ដូចខាងក្រោម៖

១- តំបន់ការពារបេតិកភណ្ឌវប្បធម៌

២- សមាសភាគនៃប្រព័ន្ធតំបន់ការពារធម្មជាតិ

៣- ប្រព័ន្ធអេកូឡូស៊ីដែលបានកំណត់ថាកំពុងទទួលរងការវិនាស និងជម្រកសត្វព្រៃដែលស្ថិតនៅក្នុងបញ្ជីកំពុងរងគ្រោះថ្នាក់ ដូចមានចែងក្នុងគន្ថីទី៤នៃក្រមនេះ ។

៤- ព្រៃកោងកាង និងតំបន់ឆ្នេរ ។

៥-តំបន់ដែលផ្តល់ជីវភាពរស់នៅរបស់សហគមន៍មូលដ្ឋាន និងជនជាតិដើមភាគតិច ។

៦- ដីធ្លី ឬធនធាននានារបស់ជនជាតិដើមភាគតិច ។

**មាត្រា១១១ ._** កិច្ចព្រមព្រៀងសម្បទាន

រាល់កិច្ចព្រមព្រៀងសម្បទានទាំងអស់ ដែលផ្តល់ជូនដោយរាជរដ្ឋាភិបាលកម្ពុជាទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ត្រូវធ្វើការវាយតម្លៃហេតុប៉ះពាល់បរិស្ថានពេញលេញ និងទទួលបានលិខិត និងវិញ្ញាបនបត្រឯកភាពលើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន ។

**មាត្រា១១២._** នីតិវិធីសម្រាប់ការវាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង ឬពេញលេញ

គម្រោងដែលត្រូវធ្វើការវាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង ឬពេញលេញ ត្រូវអនុវត្តតាមនីតិវិធីដូចខាងក្រោម៖

១- ការកំណត់វិសាលភាពគម្រោង ។

២- ការពិនិត្យ និងឯកភាពលើរបាយការណ៍កំណត់វិសាលភាពគម្រោង និងលក្ខខណ្ឌការងារ ។

៣- ការសិក្សា និងរៀបចំរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង ឬពេញលេញ ។

៤- ការពិនិត្យ និងការធ្វើសេចក្តីសម្រេចលើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង ឬពេញលេញ ។

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន ត្រូវធ្វើការពិនិត្យ និងពិចារណាលើមតិយោបល់របស់គណៈកម្មាធិការជំនាញត្រួតពិនិត្យជាមុនសិន មុននឹងធ្វើការសម្រេចឯកភាពលើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានពេញលេញ ។

**មាត្រា១១៣**._ លក្ខខណ្ឌតម្រូវក្នុងការធ្វើកិច្ចសន្យាការពារបរិស្ថាន

រាល់គម្រោងស្នើសុំដែលមិនស្ថិតនៅក្នុងបញ្ជីដែលត្រូវធ្វើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង ឬពេញលេញ ត្រូវធ្វើកិច្ចសន្យាការពារបរិស្ថាន ស្របតាមបទប្បញ្ញត្តិនៃក្រមនេះ ។

ក្នុងករណីដែលគម្រោងស្នើសុំត្រូវធ្វើត្រឹមតែកិច្ចសន្យាការពារបរិស្ថាន ម្ចាស់គម្រោងត្រូវដាក់បញ្ជូនព័ត៌មានបច្ចេកទេស និងផែនការគាំពារបរិស្ថាន ដើម្បីសុំការឯកភាពពីក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន ។

## ផ្នែកទី២
## ការកំណត់វិសាលភាព

**មាត្រា១១៤**._ វិសាលភាព

រាល់គម្រោងដែលតម្រូវឱ្យធ្វើការវាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង ឬពេញលេញ ត្រូវកំណត់វិសាលភាព និងរៀបចំរបាយការណ៍កំណត់វិសាលភាព ស្របតាមបទប្បញ្ញត្តិនៃក្រមនេះ ហើយត្រូវដាក់ជូនក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថានដើម្បីសុំការឯកភាព ។

របាយការណ៍កំណត់វិសាលភាព ត្រូវដាក់បញ្ចូលនូវលក្ខខណ្ឌការងារសម្រាប់សិក្សាលើការវាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង ឬពេញលេញ ។

**មាត្រា១១៥** ._ ការចូលរួមជាសាធារណៈនៅក្នុងអំឡុងពេលកំណត់វិសាលភាពគម្រោង

ម្ចាស់គម្រោង និងទីប្រឹក្សាវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ត្រូវរៀបចំឱ្យមានដំណើរការចូលរួមជាសាធារណៈ នៅក្នុងអំឡុងពេលរៀបចំរបាយការណ៍កំណត់វិសាលភាពគម្រោង និងដាក់ព័ត៌មានឱ្យសាធារណជនអាចស្វែងរកបាន ស្របតាមបទបទប្បញ្ញត្តិនៃក្រមនេះ និងគោលការណ៍ណែនាំដទៃទៀត ដែលកំណត់ដោយក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន ។

**មាត្រា១១៦** ._ លក្ខខណ្ឌការងារ

ទីប្រឹក្សាវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ត្រូវធ្វើការសិក្សា និងរៀបចំរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង ឬពេញលេញ ដោយផ្អែកតាមលក្ខខណ្ឌការងារដែលទទួលបានការឯកភាពពីក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន ។

**មាត្រា១១៧** ._ ការបើកបង្ហាញព័ត៌មាន

របាយការណ៍កំណត់វិសាលភាព និងលក្ខខណ្ឌការងារ ដែលទទួលបានការឯកភាពពីក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន ត្រូវដាក់ឱ្យសាធារណជនអាចស្វែងរកបាន ស្របតាមបទប្បញ្ញត្តិនៃក្រមនេះ ។

## ផ្នែកទី៣
## ការសិក្សា និងការរៀបចំរបាយការណ៍

**មាត្រា១១៨** ._ លក្ខខណ្ឌតម្រូវនៃការសិក្សា

ម្ចាស់គម្រោងត្រូវធ្វើការសិក្សា និងរៀបចំរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង និងពេញលេញ ស្របតាមលក្ខខណ្ឌដូចខាងក្រោម៖

១- លក្ខខណ្ឌការងារ ។

២- បទប្បញ្ញត្តិស្ដីពីការចូលរួមជាសាធារណៈ និងសិទ្ធិទទួលបានព័ត៌មាននៃក្រមនេះ។

៣- លិខិតបទដ្ឋានគតិយុត្តស្តីពីកិច្ចដំណើរការនៃការវាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង ឬពេញលេញ ដែលកំណត់ដោយក្រមនេះ។

**មាត្រា១១៩** ._ ការបង្ហាញព័ត៌មានអប្បបរមា

ម្ចាស់គម្រោង ត្រូវដាក់ឱ្យសាធារណជនអាចស្វែងរកបានជាអប្បបរមា នូវរបាយការណ៍វាយតម្លៃបរិស្ថានដំបូង ឬពេញលេញ ផែនការគ្រប់គ្រងបរិស្ថាន ផែនទី ផែនការ វិធានការកាត់បន្ថយផលប៉ះពាល់ដែលបានស្នើឡើង នៅក្នុងដំណាក់កាលសិក្សា វាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង ឬពេញពេញ ដើម្បីផ្តល់ពេលវេលាគ្រប់គ្រាន់ដល់អ្នកពាក់ព័ន្ធ ដើម្បីពិនិត្យ និងផ្តល់យោបល់ ។

**មាត្រា១២០** ._ លក្ខខណ្ឌតម្រូវសម្រាប់កត់ត្រា និងឆ្លើយតបទៅនឹងមតិយោបល់របស់សាធារណជន

ការរៀបចំរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង និងពេញលេញត្រូវ៖

១- កត់ត្រាមតិយោបល់របស់សាធារណជន ហើយម្ចាស់គម្រោងត្រូវពិចារណាមតិយោបល់របស់សាធារណជន នៅក្នុងការរៀបចំផែនការ និងអនុវត្តការវាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង ឬពេញលេញ ។

២- ផ្តោតលើបញ្ហានានាដែលលើកឡើងដោយស្ត្រី និងជនដែលទទួលរងផលប៉ះពាល់ខ្លាំងបំផុតពីគម្រោងស្នើសុំ ។

៣- ដាក់បញ្ចូលសេចក្តីលម្អិតអំពីផលប៉ះពាល់របស់គម្រោងចំពោះសាធារណជន និងការទទួលយក ឬបដិសេធសំណើរបស់សាធារណជន និង

៤- ផ្តល់ហេតុផលនៃការបដិសេធឱ្យបានច្បាស់លាស់ នៅក្នុងករណីដែលម្ចាស់គម្រោងបដិសេធសំណើរបស់សាធារណជន ។

**មាត្រា១២១** ._ លក្ខខណ្ឌតម្រូវជាអប្បបរិមាសម្រាប់ការវិភាគអំពីជម្រើសផ្សេងទៀត

របាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង ឬពេញលេញ ត្រូវដាក់បញ្ចូល៖

១- ការពិចារណាទៅលើជម្រើសផ្សេងទៀតដែលអាចអនុវត្តបានសម្រាប់គម្រោងស្នើសុំ រួមមានសេចក្តីពិពណ៌នាអំពីជម្រើសនីមួយៗ និងជម្រើសមិនឱ្យមានគម្រោងស្នើសុំ ហើយត្រូវមានការបកស្រាយអំពីជម្រើសនីមួយៗ និងទាំងជម្រើសដែលមិនមែនគម្រោង ។

២- វាយតម្លៃ និងប្រៀបធៀបផលប៉ះពាល់បរិស្ថាន វិធានការកាត់បន្ថយផលប៉ះពាល់ និងផលប៉ះពាល់ដែលនៅសេសសល់ដែលកើតចេញពីជម្រើសនីមួយៗ ។

ការពិចារណាអំពីជម្រើសផ្សេងទៀតទាក់ទងនឹងគម្រោងស្នើសុំ យ៉ាងហោចណាស់ ត្រូវដាក់បញ្ចូលនូវភាពអាចអនុវត្តបាន និងភាពប្រាកដនិយម ដើម្បីបំពេញតាមគោលបំណងនៃលក្ខខណ្ឌតម្រូវរបស់គម្រោង ។

លក្ខខណ្ឌតម្រូវនៃការវិភាគលើជម្រើសគម្រោង ត្រូវដាក់បញ្ចូលនូវជម្រើសដែលបង្កផលប៉ះពាល់តិចចំពោះ៖

១- ទ្រព្យសម្បត្តិ ឬ ទីតាំង ដែលត្រូវប្រតិបត្តិការគម្រោងស្នើសុំ ។

២- ប្រភេទគម្រោង ។

៣- ការរចនាគម្រោង ។

៤- បច្ចេកវិទ្យាដែលប្រើប្រាស់ក្នុងប្រតិបត្តិការគម្រោង ។

៥- តម្រូវការចាំបាច់ចំពោះការផ្លាស់ទីលំនៅថ្មី ឬផលប៉ះពាល់ចំពោះជីវភាពរស់នៅ ។

៦- ផលប៉ះពាល់ចំពោះជនជាតិដើមភាគតិច និងសហគមន៍មូលដ្ឋាន ។

៧- ប្រតិបត្តិការគម្រោង និង

៨- លក្ខណៈ ឬទិដ្ឋភាពសំខាន់ដទៃទៀតនៃគម្រោង ដែលក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថានចាត់ទុកថាចាំបាច់ ។

**មាត្រា១២២** ._ ផែនការគ្រប់គ្រងបរិស្ថាន

ផែនការគ្រប់គ្រងបរិស្ថាន ដែលកំណត់នៅក្នុងរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង ឬពេញលេញ ត្រូវដាក់ឱ្យសាធារណជនអាចស្វែងរកបាន ដើម្បីពិនិត្យ និងផ្តល់យោបល់ ។

ផែនការគ្រប់គ្រងបរិស្ថាន ត្រូវដាក់បញ្ចូលនូវកិច្ចគាំពារបរិស្ថាន វិធានការកាត់បន្ថយផលប៉ះពាល់ ការអង្កេតតាមដាន យន្តការដោះស្រាយវិវាទ និងលក្ខខណ្ឌតម្រូវនៃការបិទ និងការស្តារបរិស្ថានឡើងវិញ និងលក្ខខណ្ឌតម្រូវនៃការគ្រប់គ្រង ដូចបានកំណត់នៅក្នុងរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង ឬពេញលេញ។

## ផ្នែកទី៤

## ការវាយតម្លៃទៅលើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង ឬពេញលេញ និងកិច្ចសន្យាការពារបរិស្ថាន

**មាត្រា១២៣** ._ ការចូលរួមជាសាធារណៈ និងសិទ្ធិទទួលបានព័ត៌មានបរិស្ថាន

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន ត្រូវរៀបចំឱ្យមានដំណើការចូលរួមជាសាធារណៈ នៅក្នុងការវាយតម្លៃលើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង ឬពេញលេញ ដោយៈ

១- អញ្ជើញឱ្យមានការចូលរួមពីតំណាងក្រសួង ស្ថាប័នមានសមត្ថកិច្ច អង្គការមិនមែនរដ្ឋាភិបាល អ្នកពាក់ព័ន្ធ និងអ្នកទទួលរងផលប៉ះពាល់ពីគម្រោង និងជនងាយរងគ្រោះ ។

២- ផ្តល់យោបល់លើគម្រោងស្នើសុំ ។

៣- អនុវត្តតាមបទបញ្ញត្តិស្តីពីការចូលរួមជាសាធារណៈ និងសិទ្ធិទទួលបានព័ត៌មាន នៃក្រមនេះ ។

**មាត្រា១២៤.**_ លក្ខខណ្ឌតម្រូវសម្រាប់ការពិនិត្យ និងផ្តល់យោបល់

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន ត្រូវពិនិត្យ និងផ្តល់យោបល់ទៅលើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង ឬពេញលេញ បន្ទាប់ពីៈ

១- បានស្តាប់ និងពិចារណាលើបទបង្ហាញ និងការការពារជាផ្លូវការរបស់ម្ចាស់គម្រោង និងទីប្រឹក្សាវាយតម្លៃហេតុប៉ះពាល់បរិស្ថាន។

២- ពិចារណាលើគុណសម្បត្តិ និងគុណវិបត្តិចំពោះបរិស្ថាន ដោយពិនិត្យលើវិសាលភាពគម្រោង ទីតាំងភូមិសាស្ត្រ ផលប៉ះពាល់ដែលអាចកើតឡើង និងលក្ខណៈពិសេសផ្សេងទៀតនៃគម្រោងនីមួយៗ ។

៣- បានពិចារណាអំពីផលប៉ះពាល់ដោយឡែក និងជាបណ្តុំ របស់គម្រោងស្នើសុំ ទៅលើសុខុមាលភាពមនុស្ស បរិស្ថាន និងធនធានធម្មជាតិ និងតម្លៃនៃលំហូរសេវាកម្មធនធានធម្មជាតិ។

៤- បានផ្តល់ការពិចារណាជាពិសេសចំពោះផលប៉ះពាល់អវិជ្ជមានទៅលើវប្បធម៌ ទំនៀមទម្លាប់ ប្រពៃណី ជីវភាពរស់នៅ និងទ្រព្យសម្បត្តិរបស់ជនជាតិដើមភាគតិច។

៥- បានពិចារណាមតិយោបល់ និងធាតុចូលដែលទទួលបានពីដំណើរការនៃការចូលរួមជាសាធារណៈ។

៧- បានពិចារណាមតិយោបល់របស់ក្រសួង ស្ថាប័នមានសមត្ថកិច្ច ។

៨- បានពិចារណាអនុសាសន៍របស់គណៈកម្មាធិការជំនាញត្រួតពិនិត្យ សម្រាប់ការវាយតម្លៃហេតុប៉ះពាល់បរិស្ថានពេញលេញ និង

៩- បានវាយតម្លៃភាពត្រឹមត្រូវ និងប្រសិទ្ធភាព នៃការរៀបចំវិធានការកាត់បន្ថយហេតុប៉ះពាល់ និងការអង្កេតតាមដានគម្រោង ដែលបានស្នើឡើង ។

**មាត្រា១២៥**._ ការធ្វើសេចក្ដីសម្រេច

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន បន្ទាប់ពីបានពិនិត្យរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង និងពេញលេញ កិច្ចសន្យាការពារបរិស្ថាន ត្រូវធ្វើសេចក្ដីសម្រេច ដូចខាងក្រោម៖

១- បដិសេធរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង ឬពេញលេញ ឬកិច្ចសន្យាការពារបរិស្ថាន ។

២- ចេញសេចក្ដីបង្គាប់ឱ្យធ្វើការកែសម្រួល ឬកែតម្រូវរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង ឬពេញលេញ ឬកិច្ចសន្យាការពារបរិស្ថាន ។

៣- ផ្ដល់លិខិត ឬវិញ្ញាបនបត្រឯកភាពលើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង ឬពេញលេញ ឬកិច្ចសន្យាការពារបរិស្ថាន ។

៤- តម្រូវឱ្យរៀបចំរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង ចំពោះកិច្ចសន្យាការពារបរិស្ថាន ក្នុងករណីដែលក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថានពិនិត្យឃើញថាគម្រោងនោះ បង្កឱ្យមានផលប៉ះពាល់ខ្លាំង ដែលអាចកើតមានឡើង ។

៥- តម្រូវឱ្យរៀបចំរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានពេញលេញ ចំពោះរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង ក្នុងករណីដែលក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថានពិនិត្យឃើញថាគម្រោងនោះ បង្កឱ្យមានផលប៉ះពាល់ខ្លាំង ដែលអាចកើតមានឡើង ។

**មាត្រា១២៦** ._ ការបដិសេធ ឬបង្គាប់ឱ្យកែតម្រូវ ឬកែសម្រួល

ក្នុងករណីដែលក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថានបដិសេធ ឬផ្ដល់យោបល់ និងបង្គាប់ឱ្យធ្វើការកែសម្រួល ឬកែតម្រូវលើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង ឬពេញលេញ ឬកិច្ចសន្យាការពារបរិស្ថាន ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន ត្រូវធ្វើសេចក្ដីសម្រេចបដិសេធ ឬសេចក្ដីបង្គាប់ឱ្យកែតម្រូវ ឬកែសម្រួលជាលាយលក្ខណ៍អក្សរ ដោយបញ្ជាក់ពីហេតុផល ឬលក្ខខណ្ឌ ឬចំណុចដែលត្រូវកែសម្រួល ឬកែតម្រូវ ទៅម្ចាស់គម្រោង ឬទីប្រឹក្សារៀបចំរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន ។

**មាត្រា១២៧** ._ ការឯកភាព

ក្នុងករណីដែលក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន ឯកភាពលើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង ឬពេញលេញ ឬកិច្ចសន្យាការពារបរិស្ថាន ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន ត្រូវចេញលិខិត និងវិញ្ញាបនបត្រឯកភាព សម្រាប់គម្រោងស្នើសុំនោះ ។

លិខិត និងវិញ្ញាបនបត្រឯកភាព ត្រូវមានលក្ខខណ្ឌតម្រូវ និងកាតព្វកិច្ចដែលត្រូវអនុវត្តគម្រោង រួមមាន ស្តង់ដារបញ្ចេញសារធាតុបំពុល វិធានការកាត់បន្ថយផលប៉ះពាល់ និងលក្ខខណ្ឌតម្រូវក្នុងការរៀបចំរបាយការណ៍ និងការអង្កេតតាមដាន ។

**មាត្រា១២៨** ._ ការផ្សព្វផ្សាយឯកសារវាយតម្លៃហេតុប៉ះពាល់បរិស្ថានដែលទទួលបានការឯកភាព

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន ត្រូវផ្ញើលិខិត ឬវិញ្ញាបនបត្រឯកភាពលើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង ឬពេញលេញ ឬកិច្ចសន្យាការពារបរិស្ថាន ជូនម្ចាស់គម្រោង ក្រសួង ស្ថាប័នមានសមត្ថកិច្ច រួមមាន ក្រសួង ស្ថាប័នទទួលបន្ទុកអនុម័តគម្រោង ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា និងរដ្ឋបាលថ្នាក់ក្រោមជាតិ ។

លិខិត ឬវិញ្ញាបនបត្រឯកភាពលើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង ឬពេញលេញ ឬកិច្ចសន្យាការពារបរិស្ថាន ត្រូវដាក់ឱ្យសាធារណជនអាចស្វែងរកបាន ។

## ជំពូកទី៤
## ការកំណត់រយៈពេលសម្រាប់នីតិវិធីនៃការពិនិត្យ និងផ្តល់យោបល់លើការវាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង ឬពេញលេញ និងកិច្ចសន្យាការពារបរិស្ថាន

**មាត្រា១២៩** ._ ការធ្វើចំណាត់ថ្នាក់គម្រោង

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន ត្រូវបញ្ចប់ដំណាក់កាលធ្វើចំណាត់ថ្នាក់គម្រោង សម្រាប់ការវាយតម្លៃបរិស្ថានដំបូង ឬពេញលេញ ក្នុងអំឡុងពេល ១៥ (ដប់ប្រាំ) ថ្ងៃ នៃថ្ងៃធ្វើការ គិតចាប់ពីថ្ងៃដែលម្ចាស់គម្រោងបានដាក់សំណើស្នើសុំធ្វើចំណាត់ថ្នាក់គម្រោង ។

**មាត្រា១៣០** ._ ការកំណត់វិសាលភាពគម្រោង

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន ត្រូវបញ្ចប់ការពិចារណាលើរបាយការណ៍កំណត់វិសាលភាព សម្រាប់ការវាយតម្លៃបរិស្ថានដំបូង ឬពេញលេញ ក្នុងរយៈពេល ១៥ (ដប់ប្រាំ) ថ្ងៃ នៃថ្ងៃធ្វើការ គិតចាប់ពីថ្ងៃដែលម្ចាស់គម្រោងបានដាក់សំណើសុំកំណត់វិសាលភាពគម្រោង ។

រយៈពេល ១៥ (ដប់ប្រាំ) ថ្ងៃនៃថ្ងៃធ្វើការ សម្រាប់ការកំណត់វិសាលភាពគម្រោងនេះ ត្រូវរាប់សាជាថ្មី នៅពេលដែលម្ចាស់គម្រោងបានដាក់សំណើសុំកែសម្រួលរបាយការណ៍កំណត់វិសាលភាពគម្រោង ស្របតាមការណែនាំ និងមតិយោបល់ របស់ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន ។

**មាត្រា១៣១.**_ រយៈពេលសម្រាប់ការពិនិត្យ និងផ្តល់យោបល់ លើកិច្ចសន្យាការពារបរិស្ថាន

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថានមានរយៈពេល ៣០ (សាមសិប) ថ្ងៃ នៃថ្ងៃធ្វើការ ដើម្បីពិនិត្យ ផ្តល់យោបល់ ឯកភាព បដិសេធ ឬបង្គាប់ឱ្យកែតម្រូវ ឬកែសម្រួល កិច្ចសន្យាការពារបរិស្ថាន គិតចាប់ពីថ្ងៃដែលទទួលបានកិច្ចសន្យាការពារបរិស្ថាន និងឯកសារពាក់ព័ន្ធ ។

រយៈពេល ៣០ (សាបសិប) ថ្ងៃនៃថ្ងៃធ្វើការ សម្រាប់ការពិនិត្យ ផ្តល់យោបល់ ឯកភាព បដិសេធ ឬបង្គាប់ឱ្យកែតម្រូវ ឬកែសម្រួល កិច្ចសន្យាការពារបរិស្ថាន ត្រូវរាប់សាជាថ្មី នៅពេលដែលម្ចាស់គម្រោងបានដាក់សំណើសុំកែតម្រូវ ឬកែសម្រួលកិច្ចសន្យាការពារបរិស្ថាន ស្របតាមការណែនាំ និងមតិយោបល់របស់ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន ។

**មាត្រា១៣២.**_ រយៈពេលសម្រាប់ការពិនិត្យ និងផ្តល់យោបល់លើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន ត្រូវពិនិត្យ និងផ្តល់យោបល់លើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូងក្នុងរយៈពេល ៦០ (ហុកសិប) ថ្ងៃនៃថ្ងៃធ្វើការ គិតចាប់ពីកាលបរិច្ឆេទទទួលបានរបាយការណ៍នោះ ។ រយៈពេល ៦០ (ហុកសិប) ថ្ងៃនេះ ត្រូវអស់សុពលភាព នៅពេលដែលក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថានបានផ្តល់យោបល់របស់ខ្លួន ទោះបីជាយោបល់នោះជាយោបល់បដិសេធ យោបល់ឯកភាព ឬជាយោបល់បង្គាប់ឱ្យមានការកែប្រែ ឬកែសម្រួល ឬកែតម្រូវរបាយការណ៍ដែលខ្លួនពិនិត្យក៏ដោយ ។

រយៈពេល ៦០ (ហុកសិប) ថ្ងៃនៃថ្ងៃធ្វើការ សម្រាប់ពិនិត្យ និងផ្តល់យោបល់ដូចមានចែងក្នុងកថាខណ្ឌខាងលើ ត្រូវចាប់ផ្តើមរាប់សាជាថ្មី នៅពេលដែលក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន បានទទួលបានពាក្យស្នើសុំឱ្យពិនិត្យរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង ដែលម្ចាស់គម្រោងបានធ្វើការកែតម្រូវ ស្របតាមសេចក្តីបង្គាប់ ឬសេចក្តីណែនាំ របស់ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន ។

**មាត្រា១៣៣ .**_ រយៈពេលសម្រាប់ការពិនិត្យ និងផ្តល់យោបល់លើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានពេញលេញ

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន ត្រូវពិនិត្យ និងផ្តល់យោបល់ លើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានពេញលេញ ក្នុងរយៈពេល ៩០ (កៅសិប)ថ្ងៃនៃថ្ងៃធ្វើការ គិតចាប់ពីកាលបរិច្ឆេទទទួលបានរបាយការណ៍នោះ។ រយៈពេល៩០ (កៅសិប) ថ្ងៃនេះ ត្រូវអស់សុពលភាព នៅពេលដែលក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថានបានផ្តល់យោបល់របស់ខ្លួន ទោះបីជាយោបល់នោះជាយោបល់បដិសេធ យោបល់ឯកភាព ឬជាយោបល់បង្គាប់ឱ្យមានការកែប្រែ ឬកែសម្រួល ឬកែតម្រូវរបាយការណ៍ដែលខ្លួនពិនិត្យក៏ដោយ ។

រយៈពេល ៩០ (កៅសិប) ថ្ងៃនៃថ្ងៃធ្វើការ សម្រាប់ពិនិត្យ និងផ្តល់យោបល់ដូចមានចែងក្នុងកថាខណ្ឌខាងលើ ត្រូវចាប់ផ្តើមរាប់សាជាថ្មី នៅពេលដែលក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថានទទួលបានពាក្យស្នើសុំឱ្យពិនិត្យរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន ដែលម្ចាស់គម្រោងបានធ្វើការកែតម្រូវ ស្របតាមសេចក្តីបង្គាប់ ឬការណែនាំរបស់ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន ។

**មាត្រា១៣៤ .**_ ការទទួលខុសត្រូវចំពោះការខូចខាត

ម្ចាស់គម្រោង ត្រូវទទួលខុសត្រូវចំពោះការខូចខាតបរិស្ថាន ដែលបង្កដោយកំហុស ឬការខកខានមិនបានកែសម្រួលរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង ឬពេញលេញ ឬកិច្ចសន្យាការពារ បរិស្ថាន ស្របតាមសេចក្តីណែនាំ របស់ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន ។

**មាត្រា១៣៥ .**_ រយៈពេលសុពលភាពនៃលិខិត និងវិញ្ញាបនបត្រឯកភាពលើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន

លិខិត និងវិញ្ញាបនបត្រឯកភាពលើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន មានសុពលភាពសម្រាប់រយៈពេលវដ្តនៃគម្រោង។ ក្នុងករណីក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថានពិនិត្យឃើញថាមានការផ្លាស់ប្តូរគម្រោង ឬរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង ឬពេញលេញ លែងមានលក្ខណៈសមស្រប ឬមិនមានប្រសិទ្ធភាពក្នុងការអនុវត្តវិធានការកាត់បន្ថយផលប៉ះពាល់ ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន មានអំណាចតម្រូវឱ្យម្ចាស់គម្រោងរៀបចំរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង ឬពេញលេញឡើងវិញ ឬធ្វើបច្ចុប្បន្នភាពរបាយការណ៍ដែលមានស្រាប់ ដើម្បីទទួលបានជាថ្មីនូវលិខិត និងវិញ្ញាបនបត្រឯកភាពលើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន ស្របតាមលក្ខខណ្ឌកំណត់ដោយក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន ។

## ជំពូកទី៥
## ការពិចារណាជាពិសេសក្នុងប្រព័ន្ធវាយតម្លៃហេតុប៉ះពាល់បរិស្ថាន
### ផ្នែកទី១
### ការវាយតម្លៃហេតុប៉ះពាល់បរិស្ថានចំពោះគម្រោងដែលមានស្រាប់ និងកំពុងដំណើរការ

**មាត្រា១៣៦ ._** គោលការណ៍ណែនាំសម្រាប់ការវាយតម្លៃហេតុប៉ះពាល់បរិស្ថានសម្រាប់គម្រោងដែលមានស្រាប់ និងកំពុងដំណើរការ

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន ត្រូវរៀបចំលិខិតបទដ្ឋានគតិយុត្តស្ដីពីគោលការណ៍ណែនាំសម្រាប់ប្រភេទគម្រោងដែលមានស្រាប់ និងកំពុងដំណើរការ ដែលមិនបានរៀបចំរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង និងពេញលេញ និងកិច្ចសន្យាការពារបរិស្ថាន ដើម្បីតម្រូវឱ្យម្ចាស់គម្រោងទាំងនោះ៖

១- ធ្វើសវនកម្មបរិស្ថានទៅលើប្រតិបត្តិការគម្រោងដែលមានស្រាប់ ស្របតាមបទប្បញ្ញត្តិនៃក្រមនេះ ។

២- រៀបចំរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង ឬពេញលេញ និងកិច្ចសន្យាការពារបរិស្ថាន ស្របតាមបទប្បញ្ញត្តិនៃក្រមនេះ ។

**មាត្រា១៣៧._** ការពិនិត្យឯកសាវាយតម្លៃហេតុប៉ះពាល់បរិស្ថានសម្រាប់គម្រោងដែលមានស្រាប់ និងកំពុងដំណើរការ

ម្ចាស់គម្រោងដែលមានស្រាប់ និងកំពុងដំណើរការ ត្រូវរៀបចំរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង ឬពេញលេញ និងកិច្ចសន្យាការពារបរិស្ថាន ស្របតាមលិខិតបទដ្ឋានគតិយុត្តដែលកំណត់ដោយក្រសួង ស្ថាប័ទទួលបន្ទុកបរិស្ថាន ដូចមានចែងក្នុងមាត្រា១៣៦ នៃក្រមនេះ ។

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន ត្រូវពិនិត្យ ផ្ដល់យោបល់ និងធ្វើសេចក្ដីសម្រេចលើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង ឬពេញលេញ និងកិច្ចសន្យាការពារបរិស្ថាន ស្របតាមបទប្បញ្ញត្តិនៃក្រមនេះ ។

### ផ្នែកទី២
### ការវាយតម្លៃហេតុប៉ះពាល់ជាក់លាក់

**មាត្រា១៣៨ ._** ការដាក់បញ្ចូលការប្រែប្រួលអាកាសធាតុនៅក្នុងការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន

ការវាយតម្លៃហេតុប៉ះពាល់បរិស្ថានពេញលេញ ត្រូវដាក់បញ្ចូលនូវការវាយតម្លៃហេតុប៉ះពាល់នៃគម្រោងស្នើសុំដែលបង្កឱ្យមានការប្រែប្រួលអាកាសធាតុ ដែលរួមមាន ការគណនាបរិមាណនៃការបញ្ចេញឧស្ម័នផ្ទះកញ្ចក់របស់គម្រោងអភិវឌ្ឍន៍ និងការវិភាគលើការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ នាពេលអនាគត ។

ម្ចាស់គម្រោងត្រូវវាយតម្លៃជម្រើសថាមពលដែលបញ្ចេញឧស្ម័នផ្ទះកញ្ចក់ទាប និងតម្រូវការក្នុងការកាត់បន្ថយការប្រែប្រួលចំពោះការផ្គត់ផ្គង់ទឹក ដែលបណ្ដាលមកពីកត្តាអាកាសធាតុ ។

**មាត្រា១៣៩ ._** ការវិភាគ និងវាយតម្លៃពីសក្ដានុពលនៃផលប៉ះពាល់ចំពោះការប្រែប្រួលអាកាសធាតុ

របាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានពេញលេញ ត្រូវវិភាគ និងវាយតម្លៃផលប៉ះពាល់ដែលអាចកើតឡើង និងភាពងាយរងគ្រោះនៃគម្រោង ដែលបណ្ដាលមកពីការប្រែប្រួលអាកាសធាតុ ដើម្បីកំណត់វិធានកាត់បន្ថយ និងបន្សាំនៅនឹងផលប៉ះពាល់លើការប្រែប្រួលអាកាសធាតុដែលកើតមានឡើង រួមមានការរៀបចំផែនការឆ្លើយតបជាបន្ទាន់ ។

**មាត្រា១៤០ ._** ការវាយតម្លៃហេតុប៉ះពាល់សុខភាព

ការរៀបចំរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង ឬពេញលេញ ត្រូវដាក់បញ្ចូលនូវការវាយតម្លៃហេតុប៉ះពាល់សុខភាព ដូចខាងក្រោម៖

១- ទិន្នន័យមូលដ្ឋានស្ដីពីសុខភាពនៅក្នុងតំបន់គម្រោង និងរបស់ប្រជាជនដែលរងផលប៉ះពាល់ ។

២- ការពិពណ៌នាអំពីផលប៉ះពាល់នៃគម្រោងដែលអាចកើតមាន ដោយសារការសាងសង់ លំហូរប្រជាជន និងការប្រែប្រួលបរិស្ថាន ។

៣- ហានិភ័យ និងផលប៉ះពាល់ដែលអាចកើតឡើងចំពោះសុវត្ថិភាព សុខភាពនៃសហគមន៍ដែលទទួលរងផលប៉ះពាល់ នៅក្នុងដំណាក់កាលរចនា សាងសង់ ប្រតិបត្តិការ និងបិទគម្រោង ។

៤- វិធានការកាត់បន្ថយផលប៉ះពាល់ ឬលុបបំបាត់ផលប៉ះពាល់អវិជ្ជមាននៃគម្រោង និងវិធានការដែលដាក់ឱ្យអនុវត្តដោយម្ចាស់គម្រោង ដើម្បីកែធ្វើឱ្យប្រសើរឡើងនូវសុខភាពរបស់សហគមន៍មូលដ្ឋាន ។

៥- គ្រប់ផែនការសុខភាព និងសុវត្ថិភាពសម្រាប់បរិយាកាសការងារ និងសម្រាប់វាយតម្លៃហានិភ័យ និងកម្រិតនៃគ្រោះថ្នាក់ នៅក្នុងតំបន់គម្រោងស្នើសុំ រួមមាន គ្រោះថ្នាក់ទាក់ទងគីមីសាស្ត្រ រូបសាស្ត្រ ជីវសាស្ត្រ និងវិទ្យុសកម្ម និង

៦- បញ្ហានានាទាក់ទងនឹងការអង្កេតតាមដានសុខភាព និងការគ្រប់គ្រងផលប៉ះពាល់ដែលនៅសល់ក្នុងរយៈពេលខ្លី និងវែង សម្រាប់គម្រោង ។

**មាត្រា១៤១** ._ ការវាយតម្លៃហេតុប៉ះពាល់បរិស្ថានជាបណ្តុំ

ការវាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង ឬពេញលេញ ត្រូវវាយតម្លៃពីបណ្តុំនៃផលប៉ះពាល់ដែលបង្កឡើងដោយគម្រោងដែលមានស្រាប់ និងគម្រោងក្នុងពេលអនាគត នៅជុំវិញទីតាំងគម្រោងទាំងនោះ ដែលអាចបង្កឱ្យមានផលប៉ះពាល់ដល់បរិស្ថាន ឬសង្គម។ ម្ចាស់គម្រោង ត្រូវវាយតម្លៃសមត្ថភាពនៃធនធានបរិស្ថានដែលទទួលរងផលប៉ះពាល់ពីគម្រោង ដើម្បីគិតគូរអំពីផលប៉ះពាល់បន្ថែមដែលកើតចេញពីគម្រោងដែលមានស្រាប់ និងគម្រោងស្នើសុំ ។

ម្ចាស់គម្រោងត្រូវពិចារណាអំពី ជម្រើសនៃវិធានការកាត់បន្ថយបណ្តុំនៃផលប៉ះពាល់ផ្សេងៗ ដើម្បីកាត់បន្ថយ ឬបញ្ចៀសបណ្តុំនៃផលប៉ះពាល់ដែលគួរឱ្យកត់សម្គាល់ទាំងនោះ ។

**មាត្រា១៤២** ._ ការវាយតម្លៃហេតុប៉ះពាល់បរិស្ថានឆ្លងដែន

គម្រោងស្នើសុំដែលអាចបង្កឱ្យមានហេតុប៉ះពាល់បរិស្ថានឆ្លងដែន ត្រូវធ្វើការវាយតម្លៃហេតុប៉ះពាល់បរិស្ថានឆ្លងដែន ស្របតាមកិច្ចព្រមព្រៀងទ្វេភាគី ឬពហុភាគី ឬសន្ធិសញ្ញាអន្តរជាតិស្តីពីការវាយតម្លៃហេតុប៉ះពាល់បរិស្ថានឆ្លងដែន ដែលព្រះរាជាណាចក្រកម្ពុជា ជាភាគីហត្ថលេខី ។

**មាត្រា១៤៣** ._ ការវាយតម្លៃហានិភ័យ

ការវាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង ឬពេញលេញ ត្រូវដាក់បញ្ចូលនូវការវាយតម្លៃហានិភ័យ ដូចខាងក្រោម៖

១- កំណត់អត្តសញ្ញាណ និងវាយតម្លៃហានិភ័យដែលអាចកើតឡើងចំពោះបរិស្ថាន សុវត្ថិភាពសាធារណៈ និងសុខភាពមនុស្ស ដែលអាចបង្កឡើងដោយគម្រោងស្នើសុំ ។

២- កំណត់អត្តសញ្ញាណ និងវាយតម្លៃហានិភ័យជាក់ស្តែងចំពោះបរិស្ថាន សុវត្ថិភាពសាធារណៈ និងសុខភាពមនុស្ស ដែលកើតចេញមកពីផលប៉ះពាល់លើបរិស្ថាន ដែលបង្កឡើងដោយគម្រោងស្នើសុំ ។

៣- ស្នើឡើងនូវជម្រើសផ្សេងទៀត ក្នុងករណីចាំបាច់ ឬកំណត់អត្តសញ្ញាណ និងកំណត់អាទិភាពនៃសកម្មភាពកាត់បន្ថយ និងស្តារបរិស្ថានឡើងវិញ ។

៤- ជួយក្នុងការបែងចែកធនធាន ដើម្បីកាត់បន្ថយជាអប្បបរមានូវការខូចខាតបរិស្ថាន និងស្តារបរិស្ថានឡើងវិញ ។

៥- កំណត់អំពីកម្រិតនៃការស្តារឡើងវិញ ដែលចាំបាច់ក្នុងការជួសជុលហេតុប៉ះពាល់បរិស្ថានជាអវិជ្ជមាន ។

៦- កំណត់អំពីពេលវេលា ដែលត្រូវបញ្ចប់នូវការស្តារបរិស្ថានឡើងវិញ ។

៧- កំណត់ឱ្យមានមូលនិធិ សម្រាប់ការស្តារឡើងវិញនូវការខូចខាតបរិស្ថាន ដែលបង្កឡើងដោយគម្រោង ។

៨- ជូនដំណឹងដល់សាធារណជន

៩- និងទប់ស្កាត់ និងកាត់បន្ថយជាអប្បបរមានូវផលប៉ះពាល់ជាអវិជ្ជមានផ្សេងទៀត ។

**មាត្រា១៤៤ ._** ការវាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្រ

ការវាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង និងពេញលេញ ត្រូវពិនិត្យ ពិចារណា និងដាក់បញ្ចូលនូវការវាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្រ ដែលទាក់ទងនឹងវិស័យដែលពាក់ព័ន្ធនឹងសំណើគម្រោង ឬពាក់ព័ន្ធទៅនឹងដី ឬតំបន់ ដែលគម្រោងស្នើសុំនោះស្ថិតនៅ ។

## ផ្នែកទី៣
## ជនជាតិដើមភាគតិច និងការផ្លាស់ទីលំនៅថ្មីដោយមិនស្ម័គ្រចិត្ត

**មាត្រា១៤៥ ._** ការផ្តល់លិខិត និងវិញ្ញាបនបត្រឯកភាពលើរបាយការណ៍ឯកភាពវាយតម្លៃហេតុប៉ះពាល់បរិស្ថានចំពោះទីតាំងនៃតំបន់ជនជាតិដើមភាគតិច

មុនធ្វើសេចក្តីសម្រេចផ្តល់លិខិតនិង វិញ្ញាបនបត្រឯកភាពលើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន សម្រាប់គម្រោងអាចបង្កឱ្យមានផលប៉ះពាល់ផ្ទាល់ចំពោះដី និងធនធានរបស់ជនជាតិដើមភាគតិច ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន សមាជិកនៃគណៈកម្មាធិការជំនាញត្រួតពិនិត្យ ឬអ្នកពាក់ព័ន្ធក្នុងការធ្វើសេចក្តីសម្រេច ត្រូវពិចារណាជាពិសេសចំពោះគម្រោងនោះ ដើម្បីបញ្ចៀសផលប៉ះពាល់ជាអវិជ្ជមានដល់វប្បធម៌ ប្រពៃណី ទំនៀមទំលាប់ ជីវភាពរស់នៅ និងទ្រព្យសម្បត្តិរបស់ជនជាតិដើមភាគតិច ។

**មាត្រា១៤៦ ._** ការយល់ព្រមជាមុន ដោយសេរី និងបន្ទាប់ពីទទួលបានព័ត៌មានគ្រប់ជ្រុងជ្រោយ

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន មិនត្រូវឯកភាពលើការវាយតម្លៃបរិស្ថានដំបូង ឬពេញលេញ ចំពោះគម្រោងស្នើសុំ ដែលអាចបង្កឱ្យមានផលប៉ះពាល់ចំពោះដី និងធនធានរបស់ជនជាតិដើមភាគតិចឡើយ លើកលែងតែម្ចាស់គម្រោងបង្ហាញថា ខ្លួនបានទទួលការយល់ព្រមជាមុន ដោយសេរី និងបន្ទាប់ពីទទួលបានព័ត៌មានគ្រប់ជ្រុងជ្រោយ របស់ជនជាតិដើមភាគតិចដែលទទួលរងផលប៉ះពាល់ ស្របតាមបទប្បញ្ញត្តិពាក់ព័ន្ធស្តីពីការចូលរួមជាសាធារណៈរបស់សហគមន៍ជនជាតិដើមភាគតិច នៃក្រមនេះ ។

**មាត្រា១៤៧ ._** ការផ្លាស់ទីលំនៅថ្មីដោយមិនស្ម័គ្រចិត្ត

ក្នុងករណី ដែលគម្រោងស្នើសុំតម្រូវឱ្យមានការផ្លាស់ទីលំនៅថ្មីដោយមិនស្ម័គ្រចិត្ត ដែលមិនអាចជៀសវាងបាន ម្ចាស់គម្រោងត្រូវៈ

១- ផ្តល់ឱកាសឱ្យអ្នកទទួលរងផលប៉ះពាល់ បានចូលរួមក្នុងការរៀបចំការផ្លាស់ទីលំនៅថ្មី ដើម្បីកាត់បន្ថយផលប៉ះពាល់នៃការផ្លាស់ទីលំនៅថ្មីឱ្យបានកម្រិតអប្បបរមា ។

២- ផ្តល់សំណងលើការបាត់បង់ទ្រព្យសម្បត្តិ ដោយយុត្តិធម៌ ត្រឹមត្រូវ និងអាចទទួលយកបានតាមតម្លៃទីផ្សារ ។

៣- កំណត់វិធានការកាត់បន្ថយផលប៉ះពាល់បរិស្ថានឱ្យបានត្រឹមត្រូវ និងមានចីរភាព ។

នីតិវិធីសម្រាប់ទូទាត់សំណងការខូចខាតចំពោះសហគមន៍ទទួលរងផលប៉ះពាល់ ត្រូវកំណត់ដោយលិខិតបទដ្ឋានគតិយុត្តអន្តរក្រសួង រវាងក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងក្រសួង ស្ថាប័នទទួលបន្ទុកសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

## ជំពូកទី៦
## ការធ្វើបច្ចុប្បន្នភាពផែនការគ្រប់គ្រងបរិស្ថាន

**មាត្រា១៤៨ ._** ការពិនិត្យឡើងវិញ និងធ្វើបច្ចុប្បន្នភាពផែនការគ្រប់គ្រងបរិស្ថាន

ផែនការគ្រប់គ្រងបរិស្ថាន ត្រូវត្រួតពិនិត្យឡើងវិញ និងធ្វើបច្ចុប្បន្នភាពជាប្រចាំ ដើម្បីពិចារណាលើការធ្វើវិសោធនកម្មស្តង់ដារបរិស្ថាន ឬការផ្លាស់ប្តូរចំពោះទម្លាប់អនុវត្តការគ្រប់គ្រងល្អ ឬកាលៈទេសៈប្រែប្រួលនៃគម្រោង ។

**មាត្រា១៤៩ .**_ ផលប៉ះពាល់ដែលធំជាងការវាយតម្លៃ

ក្នុងករណីដែលហេតុប៉ះពាល់បរិស្ថានជាក់ស្តែងធំជាងហេតុប៉ះពាល់ដែលបានវាយតម្លៃនៅក្នុងរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង ឬពេញលេញ ឬកិច្ចសន្យាការពារបរិស្ថាន ក្រសួងស្ថាប័នទទួលបន្ទុកបរិស្ថាន ត្រូវតម្រូវឱ្យម្ចាស់គម្រោង ប្រតិបត្តិករ និង/ឬ អ្នកម៉ៅការ ចាត់វិធានការជាបន្ទាន់ ដើម្បីជួសជុលផលប៉ះពាល់ ឬកែសម្រួលផែនការគ្រប់គ្រងបរិស្ថាន ឬផែនការគាំពារបរិស្ថាន ។

**មាត្រា១៥០ .**_ ការកែសម្រួលផែនការគ្រប់គ្រងបរិស្ថាន

ផែនការគ្រប់គ្រងបរិស្ថានដែលកែសម្រួលរួច ត្រូវទទួលការឯកភាពពីក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន ។

ការកំណត់ពេលវេលាក្នុងការកែសម្រួល ឬការកែលម្អ ផែនការគ្រប់គ្រងបរិស្ថាន ត្រូវធ្វើឡើងដោយមានការព្រមព្រៀងជាលាយលក្ខណ៍អក្សររវាងក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងម្ចាស់គម្រោង។

## មាតិកាទី៣
## សវនកម្មបរិស្ថាន ការអង្កេតតាមដាន និងការរៀបចំរបាយការណ៍
## ជំពូកទី១
## សវនកម្មបរិស្ថាន

**មាត្រា១៥១ .**_ ការធ្វើសវនកម្មបរិស្ថាន

ការអនុវត្តគម្រោង ដែលទទួលបានការឯកភាព ឬលិខិតអនុញ្ញាត ត្រូវធ្វើសវនកម្មបរិស្ថានដែលមានលក្ខណៈឯករាជ្យ និងត្រូវបានចងក្រងទុកជាឯកសារ ។

ការធ្វើសវនកម្មបរិស្ថាន ត្រូវដាក់បញ្ចូលនូវចំណុច ដូចខាងក្រោម៖

១- ពិនិត្យ និងបញ្ជាក់ពីគម្រោង ឬសកម្មភាពណាមួយដែលគោរពតាមលក្ខខណ្ឌតម្រូវនៃក្រមនេះ និងច្បាប់និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ ។

២- កំណត់អត្តសញ្ញាណនៃផលប៉ះពាល់ជានិរន្តដល់បរិស្ថាន ។

៣- កំណត់អត្តសញ្ញាណនៃវិធានការណាមួយ ដើម្បីធ្វើការកែតម្រូវឱ្យស្របតាមលក្ខខណ្ឌតម្រូវនៃក្រមនេះ និងច្បាប់និងលិខិតបទដ្ឋានគតិយុត្ត ។

៤- កាត់បន្ថយហេតុប៉ះពាល់បរិស្ថានជាអប្បបរិមា ។

**មាត្រា១៥២** ._ ក្រសួង ស្ថាប័នទទួលបន្ទុក

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន ត្រូវរៀបចំលិខិតបទដ្ឋានគតិយុត្ត ចំពោះគម្រោង និងសកម្មភាពដែលត្រូវធ្វើសវនកម្មបរិស្ថាន ។

**មាត្រា១៥៣** ._ ថ្លៃចំណាយចំពោះការធ្វើសវនកម្មបរិស្ថាន

ថ្លៃចំណាយទាំងអស់ ដែលទាក់ទងនឹងការធ្វើសវនកម្មបរិស្ថាន ត្រូវជាបន្ទុករបស់ម្ចាស់គម្រោង ។

**មាត្រា១៥៤** ._ ការខកខាន មិនបានធ្វើតាមបទបញ្ជា ឬលក្ខខណ្ឌតម្រូវ

ក្នុងករណីដែលគម្រោង ខកខានមិនបានធ្វើតាមបទបញ្ជា ឬលក្ខខណ្ឌតម្រូវក្នុងការធ្វើសវនកម្មបរិស្ថាន ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន ឬសវនករបរិស្ថានដែលទទួលបាននីតិសម្បទា និងត្រូវបានតែងតាំងដោយក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន ត្រូវបានអនុញ្ញាតឱ្យធ្វើសវនកម្មបរិស្ថាន ។

ម្ចាស់គម្រោង ត្រូវទូទាត់សងជូន ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថានវិញ សម្រាប់ថ្លៃចំណាយដែលទាក់ទងទៅនឹងការធ្វើសវនកម្មបរិស្ថាន ដែលបានធ្វើឡើងដោយក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន ឬសវនករបរិស្ថានដែលបានតែងតាំងដោយក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន ។

**មាត្រា១៥៥** ._ ការជួសជុលការខូចខាត

ក្នុងករណីដែលសវនកម្មបរិស្ថានបង្ហាញឱ្យឃើញថា ផលប៉ះពាល់នៃសកម្មភាពគម្រោង ធំជាងការប៉ាន់ប្រមាណទុកនៅក្នុងរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង ឬពេញលេញ និងកិច្ចសន្យាការពារបរិស្ថានក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថានត្រូវចាត់វិធានការជាបន្ទាន់ ដើម្បីជួសជុលការខូចខាតទាំងនោះ និងបញ្ជាឱ្យធ្វើការកែតម្រូវលើផែនការគ្រប់គ្រងបរិស្ថាន ឬផែនការគាំពារបរិស្ថាន ដើម្បីបញ្ចៀសផលប៉ះពាល់នៅពេលអនាគត ។

**មាត្រា១៥៦** ._ សិទ្ធិទទួលបានព័ត៌មាន

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន ត្រូវដាក់របាយការណ៍សវនកម្មបរិស្ថានឱ្យសាធារណជនអាចស្វែងរកបាន ។

**មាត្រា១៥៧ .**_ លក្ខខណ្ឌតម្រូវក្នុងការទទួលបាននីតិសម្បទាជាសវនករបរិស្ថាន

បុគ្គលគ្រប់រូបដែលទទួលបាននីតិសម្បទាជាសវនករបរិស្ថាន ត្រូវអនុញ្ញាតឱ្យធ្វើសវនកម្មបរិស្ថាន ។

ម្ចាស់គម្រោង ឬម្ចាស់ទីតាំងត្រូវសហការ និងអនុញ្ញាតអោយសវនករបរិស្ថានចូលអាគារ ឬបរិវេណដើម្បីធ្វើសវនកម្មបរិស្ថាន ។

## ជំពូកទី២
## ការរៀបចំរបាយការណ៍ និងការអង្កេតតាមដានបរិស្ថាន

**មាត្រា១៥៨.**_វិសាលភាព

រាល់គម្រោង និងសកម្មភាពទាំងអស់ ដែលទទួលបានលិខិតអនុញ្ញាត ឬការឯកភាពត្រូវធ្វើការអង្កេតតាមដានបរិស្ថាន ស្របតាមលក្ខខណ្ឌតម្រូវដែលកំណត់នៅក្នុងលិខិត និងវិញ្ញាបនបត្រឯកភាពលើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង ឬពេញលេញ ឬកិច្ចសន្យាការពារបរិស្ថាន និងលិខិតបទដ្ឋានគតិយុត្តស្តីពីការរៀបចំរបាយការណ៍ និងការអង្កេតតាមដានបរិស្ថាន ដែលកំណត់ដោយក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន ។

**មាត្រា១៥៩ .**_ ស្ថាប័នទទួលបន្ទុកធ្វើការអង្កេតតាមដានបរិស្ថាន

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន ដោយសហការជាមួយក្រសួង ស្ថាប័នមានសមត្ថកិច្ច និងអ្នកពាក់ព័ន្ធ ត្រូវទទួលបន្ទុកក្នុងការអង្កេតតាមដានការអនុវត្តតាមលិខិត និងវិញ្ញាបនបត្រឯកភាពលើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង ឬពេញលេញ ឬកិច្ចសន្យាការពារបរិស្ថាន ។

**មាត្រា១៦០ .**_ ការរៀបចំរបាយការណ៍អង្កេតតាមដានបរិស្ថាន

រាល់គម្រោង និងសកម្មភាពទាំងអស់ ដែលទទួលបានលិខិតអនុញ្ញាត ឬការឯកភាព ត្រូវរៀបចំរបាយការណ៍អង្កេតតាមដានបរិស្ថាន និងដាក់បញ្ជូនទៅក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន ដូចខាងក្រោម៖

១- របាយការណ៍ប្រចាំត្រីមាស ដែលទាក់ទងទៅនឹងលទ្ធផលនៃការអង្កេតតាមដាន និងការគ្រប់គ្រងបរិស្ថាន ។

២- របាយការណ៍ប្រចាំឆមាស ដែលទាក់ទងទៅនឹងលទ្ធផលនៃការអង្កេតតាមដាន និងការគ្រប់គ្រងបរិស្ថាន ។

៣- ក្នុងរយៈពេល ៣ (បី) ខែ បន្ទាប់ពីបញ្ចប់ឆ្នាំសារពើពន្ធនីមួយៗ ម្ចាស់គម្រោង ត្រូវរៀបចំ និងបញ្ជូនរបាយការណ៍បរិស្ថានប្រចាំឆ្នាំ ដែលសង្ខេបអំពីការអនុវត្តការទទួលខុសត្រូវផ្នែកបរិស្ថាន និងដាក់បញ្ចូលមតិយោបល់របស់សវនករបរិស្ថាន ។

**មាត្រា១៦១** ._ លក្ខខណ្ឌតម្រូវក្នុងការឆ្លើយតប

ក្នុងករណីដែលក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន ពិនិត្យលើរបាយការណ៍អង្កេតតាមដានបរិស្ថានរបស់គម្រោង ហើយបានផ្តល់យោបល់ និងបានកំណត់ពីភាពខ្វះចន្លោះនៅក្នុងរបាយការណ៍នោះ ម្ចាស់គម្រោងត្រូវឆ្លើយតប និងកែតម្រូវចំណុចខ្វះខាតនៅក្នុងរបាយការណ៍អង្កេតតាមដាន ។

**មាត្រា១៦២** ._ ការបង្ហាញរបាយការណ៍អង្កេតតាមដានបរិស្ថាន

របាយការណ៍អង្កេតតាមដានបរិស្ថានទាំងអស់ ត្រូវដាក់ឱ្យសាធារណជនអាចស្វែងរកបាន ។

**មាត្រា១៦៣** ._ ការរៀបចំលិខិតបទដ្ឋានគតិយុត្តស្តីពីការអង្កេតតាមដាន

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន ត្រូវរៀបចំលិខិតបទដ្ឋានគតិយុត្តស្តីពីការអង្កេតតាមដានបរិស្ថាន រួមមាន វិធីសាស្ត្រនៃការអង្កេតតាមដាន វិធីសាស្ត្ររក្សាទុកកំណត់ត្រា និងខ្លឹមសារអប្បបរមានៃរបាយការណ៍អង្កេតតាមដានបរិស្ថាន និងកាតព្វកិច្ចឆ្លើយតប និងដាក់បញ្ចូលមតិយោបល់របស់ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន នៅក្នុងរបាយការណ៍អង្កេតតាមដានបរិស្ថាន ។

**មាត្រា១៦៤** ._ កាតព្វកិច្ចក្នុងការរៀបចំរបាយការណ៍អង្កេតតាមដានបរិស្ថាន

ម្ចាស់គម្រោង ត្រូវរៀបចំរបាយការណ៍អង្កេតតាមដានបរិស្ថាន និងដាក់ជូនក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន ក្រសួង ស្ថាប័នមានសមត្ថកិច្ច និងដាក់ឱ្យសាធារណជនអាចស្វែងរកបាននូវបញ្ហាដូចខាងក្រោម៖

១- បញ្ហាបរិស្ថានដែលប្រឈមនឹងការខូចខាតខ្លាំង ឬ

២- ការបំពានលើលិខិត និងវិញ្ញាបនបត្រឯកភាពលើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង ឬពេញលេញ ឬកិច្ចសន្យាការពារបរិស្ថាន ។

**មាត្រា១៦៥** ._ ការធ្វើអធិការកិច្ចទីតាំង

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន ត្រូវធ្វើអធិការកិច្ចដល់ទីតាំងគម្រោង និងផ្ទៀងផ្ទាត់ទិន្នន័យនៃការអង្កេតតាមដាន ដែលមានចែងនៅក្នុងរបាយការណ៍អង្កេតតាមដានបរិស្ថាន ។

**មាត្រា១៦៦ .**_ សិទ្ធិក្នុងការការតវ៉ា

បុគ្គលដែលទទួលរងផលប៉ះពាល់ពីគម្រោង និងអ្នកពាក់ព័ន្ធទាំងអស់ ត្រូវរាយការណ៍អំពីការតវ៉ា និងការបារម្ភទៅម្ចាស់គម្រោងស្របតាមយន្តការដោះស្រាយវិវាទជាក់លាក់តាមគម្រោងនីមួយៗ ដែលបានរៀបចំឡើងនៅក្នុងផែនការគ្រប់គ្រងបរិស្ថាន និងត្រូវរាយការណ៍ទៅក្រសួង ស្ថាប័នមានសមត្ថកិច្ច ស្របតាមយន្តការដោះស្រាយវិវាទបរិស្ថាន និងធនធានធម្មជាតិនៃក្រមនេះ ។

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងក្រសួង ស្ថាប័នមានសមត្ថកិច្ច ត្រូវឆ្លើយតបចំពោះការតវ៉ា ឬ ការធ្វើញត្តិណាមួយ និងដោះស្រាយក្ដីកង្វល់អំពីបញ្ហាបរិស្ថាន នៅក្នុងរយៈពេលមួយសមស្រប និងជូនដំណឹងដល់អ្នកពាក់ព័ន្ធទាំងអស់ ។

## គន្ថីទី៣
## ការគ្រប់គ្រងបរិស្ថាន និងយន្តការចីរភាព
## មាតិកាទី១
## ការកាត់បន្ថយ និងការគ្រប់គ្រងហានិភ័យគ្រោះមហន្តរាយ

**មាត្រា១៦៧ .**_ វិសាលភាព

មាតិកានេះមានវិសាលភាពអនុវត្តចំពោះសកម្មភាព ការគ្រប់គ្រង និងការកាត់បន្ថយគ្រោះមហន្តរាយនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា១៦៨ .**_ កិច្ចសហការលើការគ្រប់គ្រងគ្រោះមហន្តរាយ

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន ត្រូវគាំទ្រ និងសហការជាមួយស្ថាប័នជាតិគ្រប់គ្រងគ្រោះមហន្តរាយ ដើម្បី៖

១- រៀបចំការគ្រប់គ្រង និងការកាត់បន្ថយ គ្រោះមហន្តរាយ ដើម្បីកាត់បន្ថយផលប៉ះពាល់នៃគ្រោះមហន្តរាយ ដែលបង្កឡើងដោយធម្មជាតិ ឬមនុស្ស ។

២- បង្ការ កាត់បន្ថយ និងរៀបចំ មុនពេលមានគ្រោះមហន្តរាយ ការឆ្លើយតប សង្គ្រោះបន្ទាន់ក្នុងពេលមានគ្រោះមហន្តរាយ និងការស្ដារឡើងវិញក្រោយពេលមានគ្រោះមហន្តរាយ។

៣- វាយតម្លៃមូលហេតុនៃឫសគល់នៃភាពងាយរងគ្រោះចំពោះគ្រោះមហន្តរាយដែលអាចកើតឡើង និងបានកើតឡើងរួចមកហើយ ។

៤- ពង្រឹងសមត្ថភាពស្ថាប័ន ដើម្បីគ្រប់គ្រង និងកាត់បន្ថយគ្រោះមហន្តរាយ ។

៥- ធ្វើការជាមួយសហគមន៍មូលដ្ឋាន ក្រសួង ស្ថាប័នមានសមត្ថកិច្ច និងអ្នកពាក់ព័ន្ធដទៃទៀត ដើម្បីបង្កើតភាពស៊ាំរបស់សហគមន៍មូលដ្ឋានទៅនឹងគ្រោះមហន្តរាយ រួមមានផលប៉ះពាល់ និងការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុជាអាទិ៍ ។

**មាត្រា១៦៩** ._ ការរៀបចំផែនការគ្រប់គ្រងគ្រោះមហន្តរាយ ដែលប៉ះពាល់ដល់បរិស្ថាន

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន ត្រូវគាំទ្រ និងសហការជាមួយ ស្ថាប័នជាតិគ្រប់គ្រងគ្រោះមហន្តរាយដើម្បី ៖

១- រៀបចំផែនការកាត់បន្ថយគ្រោះមហន្តរាយ ដែលបង្កឡើងដោយធម្មជាតិ ឬមនុស្សដែលប៉ះពាល់ដល់បរិស្ថាន ។

២- រៀបចំផែនការត្រៀមបម្រុង និងផែនការឆ្លើយតបសង្គ្រោះបន្ទាន់សម្រាប់គ្រោះមហន្តរាយ ដែលបង្កឡើងដោយធម្មជាតិ ឬមនុស្សដែលប៉ះពាល់ដល់បរិស្ថាន ។

៣- រៀបចំលិខិតបទដ្ឋានគតិយុត្តស្តីពីការវាយតម្លៃ ហានិភ័យ និងបច្ចេកទេស ដើម្បីបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ ។

**មាត្រា១៧០** ._ ការបណ្តុះបណ្តាល និងការអប់រំ

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន ត្រូវគាំទ្រ និងសហការជាមួយស្ថាប័នជាតិគ្រប់គ្រងគ្រោះមហន្តរាយ ដើម្បី៖

១- លើកកម្ពស់ការយល់ដឹងជាសាធារណៈអំពីការគ្រប់គ្រង និងកាត់បន្ថយគ្រោះមហន្តរាយ

២- រៀបចំ និងផ្តល់ការបណ្តុះបណ្តាល និងការអប់រំអំពីការគ្រប់គ្រង និងកាត់បន្ថយគ្រោះមហន្តរាយ និង

៣- លើកទឹកចិត្តឱ្យមានការចូលរួមចំពោះការទប់ស្កាត់ ការគ្រប់គ្រង និងការកាត់បន្ថយគ្រោះមហន្តរាយ ។

**មាត្រា១៧១** ._ សិទ្ធិទទួលបានព័ត៌មាន

សាធារណជនមានសិទ្ធិទទួលបានព័ត៌មានស្តីពីការរៀបចំផែនការ ការធ្វើបច្ចុប្បន្នភាព និងការចែករំលែកព័ត៌មាន អំពីការកាត់បន្ថយគ្រោះមហន្តរាយ ដូចមានចែងក្នុងគន្លឹះទី១ ស្តីពីសិទ្ធិទទួលបានព័ត៌មានបរិស្ថាននៃក្រមនេះ ។

**មាត្រា១៧២** ._ ការពិគ្រោះយោបល់ស្តីពីការគ្រប់គ្រង និងកាត់បន្ថយហានិភ័យ

ស្ថាប័នជាតិគ្រប់គ្រងគ្រោះមហន្តរាយ និងក្រសួង ស្ថាប័នមានសមត្ថកិច្ច ត្រូវពិគ្រោះយោបល់ជាមួយក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន ដើម្បីរៀបចំលិខិតបទដ្ឋានគតិយុត្ត និងផែនការគ្រប់គ្រង និងការកាត់បន្ថយគ្រោះមហន្តរាយបង្កឡើងដោយមនុស្ស ឬធម្មជាតិ ដែលបង្កផលប៉ះពាល់ដល់បរិស្ថាន ។

## មាតិកាទី២
## ការប្រែប្រួលអាកាសធាតុ
### ជំពូកទី១
### បទប្បញ្ញត្តិទូទៅ

**មាត្រា១៧៣** ._ វិសាលភាព

មាតិកានេះមានវិសាលភាពអនុវត្តចំពោះរាល់សកម្មភាព គោលនយោបាយ យុទ្ធសាស្ត្រ និងផែនការពាក់ព័ន្ធទៅនឹងការប្រែប្រួលអាកាសធាតុនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា១៧៤** ._ ភារកិច្ច និងតួនាទីរបស់ស្ថាប័នទទួលខុសត្រូវ

ស្ថាប័នទទួលបន្ទុកអភិវឌ្ឍន៍ដោយចីរភាព មានភារកិច្ច និងតួនាទី ដូចខាងក្រោម៖

១- រៀបចំ គ្រប់គ្រង និងសម្របសម្រួលសកម្មភាពដែលពាក់ព័ន្ធនឹងការប្រែប្រួលអាកាសធាតុ ។

២- ដឹកនាំកិច្ចចរចាអំពីការប្រែប្រួលអាកាសធាតុជាលក្ខណៈអន្តរជាតិ ។

៣- ផ្តល់ការគាំទ្រផ្នែកបច្ចេកទេសដល់ក្រសួង ស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធនឹងការប្រែប្រួលអាកាសធាតុ ។

៤- ដើរតួនាទីក្នុងនាមជាស្ថាប័នបង្គោល ក្នុងការរៀបចំកម្មវិធី និងគោលនយោបាយ ស្តីពីការប្រែប្រួលអាកាសធាតុជាមួយអ្នកពាក់ព័ន្ធ ។

៥- លើកអនុសាសន៍ចំពោះវិធានការ គោលនយោបាយស្តីពីការប្រែប្រួលអាកាសធាតុជូនរាជរដ្ឋាភិបាល ។

៦- ផ្តល់ការគាំទ្រផ្នែកបច្ចេកទេសស្តីពីការដាក់បញ្ចូលសកម្មភាពឆ្លើយតបចំពោះការប្រែប្រួលអាកាសធាតុ ទៅក្នុងក្របខ័ណ្ឌនៃការតាមដានការអនុវត្ត ថវិកា និងផែនការតាមវិស័យ ។

៧- ផ្តល់យោបល់ផ្នែកបច្ចេកទេសទៅកាន់ក្រសួង ស្ថាប័នមានសមត្ថកិច្ច អំពីការរៀបចំសកម្មភាពអនុវត្ត ។

៨- រៀបចំការបណ្តុះបណ្តាល អប់រំ និងកសាងសមត្ថភាពស្ថាប័ន និងសមត្ថភាពបុគ្គល ដើម្បីលើកកម្ពស់ការយល់ដឹង និងអនុវត្តការឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុ ។

៩- ធ្វើការវាយតម្លៃជាប្រចាំលើសមត្ថភាពស្ថាប័ន សម្រាប់អនុវត្តការឆ្លើយតបចំពោះការប្រែប្រួលអាកាសធាតុថ្នាក់ជាតិ ។

១០- ពង្រឹង និងអភិវឌ្ឍយន្តការ ដើម្បីបង្កើនការយល់ដឹង និងលើកកម្ពស់ការស្រាវជ្រាវបច្ចេកវិទ្យា និងទម្លាប់នៃការអនុវត្តវិធានការកាត់បន្ថយ និងការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ ។

## ជំពូកទី២

## គោលនយោបាយ យុទ្ធសាស្ត្រ ផែនការឆ្លើយតបចំពោះការប្រែប្រួលអាកាសធាតុ

**មាត្រា១៧៥** ._ ការឆ្លើយតបចំពោះការប្រែប្រួលអាកាសធាតុថ្នាក់ជាតិ

ក្រសួង ស្ថាប័នទទួលបន្ទុកអភិវឌ្ឍន៍ដោយចីរភាព ត្រូវរៀបចំ ធ្វើបច្ចុប្បន្នភាព និងសម្របសម្រួលលើការឆ្លើយតបចំពោះការប្រែប្រួលអាកាសធាតុថ្នាក់ជាតិរយៈពេលវែង ដើម្បីធ្វើការដោះស្រាយអំពី ៖

១- វិធានការពាក់ព័ន្ធ សម្រាប់ការកាត់បន្ថយការប្រែប្រួលអាកាសធាតុ ។

២- ការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ ។

៣- ការផ្តល់ហិរញ្ញប្បទាន ការអភិវឌ្ឍផ្នែកបច្ចេកទេស និងវិធីផ្ទេរបច្ចេកវិទ្យា និងការកសាងសមត្ថភាព ។

ការរៀបចំខាងលើនេះ ត្រូវធ្វើឡើងឱ្យស្របតាមគោលនយោបាយជាតិស្តីពីការប្រែប្រួលអាកាសធាតុ និងកិច្ចព្រមព្រៀងអន្តរជាតិស្តីពីការប្រែប្រួលអាកាសធាតុ និងការអភិវឌ្ឍដោយចីរភាព ដែលព្រះរាជាណាចក្រកម្ពុជាជាភាគីហត្ថលេខី ។

**មាត្រា១៧៦** ._ ការធ្វើផែនការយុទ្ធសាស្ត្រជាតិ

ក្រសួង ស្ថាប័នទទួលបន្ទុករៀបចំផែនការ ដោយសហការជាមួយក្រសួង ស្ថាប័នទទួលបន្ទុកអភិវឌ្ឍន៍ដោយចីរភាព ត្រូវដាក់បញ្ចូលការយកចិត្តទុកដាក់លើការប្រែប្រួលអាកាសធាតុទៅក្នុងផែនការ និងយុទ្ធសាស្ត្រថ្នាក់ជាតិដែលពាក់ព័ន្ធ និងដាក់ចេញនូវគោលការណ៍ណែនាំ និងការអនុវត្តសម្រាប់ក្រសួង ស្ថាប័នពាក់ព័ន្ធ ។

**មាត្រា១៧៧** ._ ផែនការ និងថវិកាតាមវិស័យ

គ្រប់ក្រសួង ស្ថាប័នមានសមត្ថកិច្ច ត្រូវកំណត់ ដាក់បញ្ចូល និងអនុវត្តសកម្មភាពឆ្លើយតបចំពោះការប្រែប្រួលអាកាសធាតុ ចូលទៅក្នុងផែនការតាមវិស័យ ក្នុងក្របខ័ណ្ឌនៃការតាមដានការអនុវត្ត និងក្នុងថវិកា ផែនការតាមវិស័យ ឱ្យស្របតាម ច្បាប់ លិខិតបទដ្ឋានគតិយុត្ត និងគោលនយោបាយជាតិស្តីពីការប្រែប្រួលអាកាសធាតុដែលចេញដោយក្រសួង ស្ថាប័នមានសមត្ថកិច្ច និងស្របតាមកិច្ចព្រមព្រៀងអន្តរជាតិស្តីពីការប្រែប្រួលអាកាសធាតុ និងការអភិវឌ្ឍដោយចីរភាព ដែលព្រះរាជាណាចក្រកម្ពុជាជាភាគីហត្ថលេខី ។

**មាត្រា១៧៨** ._ ការរៀបចំផែនការវិនិយោគ និងការអភិវឌ្ឍ

ក្រសួង ស្ថាប័នទទួលបន្ទុកសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួង ស្ថាប័នទទួលបន្ទុករៀបចំផែនការស្ថាប័នជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ និងក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ត្រូវយកចិត្តទុកដាក់អំពីផលប៉ះពាល់ និងដំណោះស្រាយនៃការប្រែប្រួលអាកាសធាតុ នៅក្នុងគ្រប់ផែនការវិនិយោគ និងអភិវឌ្ឍន៍ ។

រដ្ឋបាលថ្នាក់ក្រោមជាតិដោយសហការជាមួយមន្ទីររាជធានី ខេត្តចំណុះឱ្យក្រសួង និងស្ថាប័នមានសមត្ថកិច្ច ត្រូវដាក់បញ្ចូលផលប៉ះពាល់ និងវិធានការឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុទៅក្នុងគ្រប់ផែនការវិនិយោគ និងអភិវឌ្ឍន៍ ដោយរួមបញ្ចូលការរៀបចំផែនការប្រើប្រាស់ដីធ្លី ជាអាទិ៍ ។

**មាត្រា១៧៩** ._ ផែនការ និងយុទ្ធសាស្ត្រឆ្លើយតបចំពោះការប្រែប្រួលអាកាសធាតុ

រដ្ឋបាលថ្នាក់ក្រោមជាតិទាំងអស់ ដោយសហការជាមួយមន្ទីររាជធានី-ខេត្ត ចំណុះក្រសួង ស្ថាប័នមានសមត្ថកិច្ច ត្រូវរៀបចំ និងអនុវត្តផែនការ និងយុទ្ធសាស្ត្រនានា ដើម្បីឆ្លើយតបចំពោះការប្រែប្រួលអាកាសធាតុ ស្របតាមគោលនយោបាយជាតិពាក់ព័ន្ធស្តីពីការប្រែប្រួលអាកាសធាតុ ។

## ជំពូកទី៣
## ការអនុវត្តការឆ្លើយតបចំពោះការប្រែប្រួលអាកាសធាតុ

**មាត្រា១៨០ .**_ ការអនុវត្តការឆ្លើយតបចំពោះការប្រែប្រួលអាកាសធាតុ

ក្រសួង ស្ថាប័នទទួលបន្ទុកអភិវឌ្ឍន៍ដោយចីរភាព និងក្រសួង ស្ថាប័នមានសមត្ថកិច្ចទាំងអស់ ត្រូវសម្របសម្រួលជាមួយអ្នកពាក់ព័ន្ធទាំងអស់ ដើម្បីអនុវត្តការឆ្លើយតបចំពោះការប្រែប្រួលអាកាសធាតុ ដូចខាងក្រោម៖

ក- ការចាត់វិធានការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ មានជាអាទិ៍៖

១- វាយតម្លៃភាពងាយរងគ្រោះនៃប្រព័ន្ធជីវសាស្ត្រ សង្គម និងសេដ្ឋកិច្ចចំពោះការប្រែប្រួលអាកាសធាតុ រួមមាន វិស័យដែលងាយទទួលរងបញ្ហាអាកាសធាតុ និងតំបន់ភូមិសាស្ត្រ ដែលងាយទទួលរងគ្រោះមហន្តរាយដែលទាក់ទងនឹងអាកាសធាតុ និងកំណត់ឱកាសសម្រាប់ការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ ។

២- រៀបចំ និងអនុវត្តហេដ្ឋារចនាសម្ព័ន្ធដែលមានភាពធន់ស៊ាំទៅនឹងអាកាសធាតុ និងដែលបញ្ចេញកាបូនទាប រួមមាន សម្រាប់វិស័យកសិកម្ម ជលផល ដឹកជញ្ជូន និងថាមពល។

៣- រៀបចំ និងអនុវត្តវិធានការគ្រប់គ្រងសម្រាប់តំបន់ការពារធម្មជាតិ ដើម្បីបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ ។

៤- ធ្វើឱ្យប្រសើរឡើងនូវប្រព័ន្ធផ្តល់ព័ត៌មានជាមុន និងការផ្សព្វផ្សាយព័ត៌មានអាកាសធាតុទាន់ពេលវេលា ។

៥- លើកកម្ពស់ទម្លាប់នៃការរស់នៅដោយចីរភាព ដែលបង្កើនភាពធន់ស៊ាំទៅនឹងការប្រែប្រួលអាកាសធាតុ ។

៦- ធ្វើឱ្យប្រសើរឡើងនូវការទទួលបានសេវាថាមពល ទឹក ដឹកជញ្ជូន សុខភាព និង អនាម័យ ដែលមានតម្លៃសមរម្យអាចទទួលយកបាន ។

ខ- ចាត់វិធានការកាត់បន្ថយការប្រែប្រួលអាកាសធាតុ មានជាអាទិ៍៖

១- លើកកម្ពស់ និងធ្វើឱ្យប្រសើរឡើងនូវប្រសិទ្ធផលថាមពល ។

២- លើកកម្ពស់ការអភិវឌ្ឍ និងការប្រើប្រាស់ថាមពលកកើតឡើងវិញ គ្រប់វិស័យទាំងអស់ ។

៣- បង្កើនផលិតកម្មថាមពលតាមបណ្តាញវិមជ្ឈការ ដែលមានភាពធន់ស៊ាំ និង ផលិតកម្មថាមពលក្រៅបណ្តាញ ។

៤- លើកកម្ពស់ការអភិវឌ្ឍ និងការប្រើប្រាស់មធ្យោបាយដឹកជញ្ជូនសាធារណៈ និងការប្រើប្រាស់ការដឹកជញ្ជូនដែលសន្សំសំចៃឥន្ធនៈ និង ការដឹកជញ្ជូនដែលបញ្ចេញកាបូនទាប ។

៥- បង្កើនគម្របព្រៃឈើ និងការលើកកម្ពស់ការគ្រប់គ្រងព្រៃឈើដោយចីរភាព និងយន្តការដើម្បីលើកកម្ពស់ការអភិរក្សព្រៃឈើ រួមមាន

- ការកាត់បន្ថយការបញ្ចេញឧស្ម័នពីការបាត់បង់ និងការរេចរឹលព្រៃឈើ
- ការលើកកម្ពស់តួនាទីនៃការអភិរក្ស ការគ្រប់គ្រងព្រៃឈើដោយចីរភាព
- ការបង្កើនព្រៃឈើជាអាងស្តុកកាបូន

៦- លើកកម្ពស់ទម្លាប់គ្រប់គ្រងការប្រើប្រាស់ដីដោយត្រឹមត្រូវ ដើម្បីការពារអាងស្តុទុកកាបូន និងដាក់កម្រិតលើការបំភាយឧស្ម័នផ្ទះកញ្ចក់ និង

គ- អនុវត្តនូវសកម្មភាពបន្ថែម ដូចខាងក្រោម៖

១- ពង្រឹងសមត្ថភាពស្ថាប័ន និងបច្ចេកទេស ដើម្បីឆ្លើយតបចំពោះ ការប្រែប្រួលអាកាសធាតុ ។

២- ពង្រឹងចំណេះដឹង អំពីការបន្សាំ និងទម្លាប់អនុវត្តនូវការកាត់បន្ថយការប្រែប្រួលអាកាសធាតុ និងបច្ចេកវិទ្យានានាដែលសមរម្យបំផុតចំពោះបរិបទកម្ពុជា ។

៣- លើកកម្ពស់ការស្រាវជ្រាវ ការផ្ទេរបច្ចេកវិទ្យា ការអប់រំ និងកិច្ចសហការអន្តរជាតិ នៅក្នុងគ្រប់វិស័យនៃការប្រែប្រួលអាកាសធាតុ ។

៤- លើកកម្ពស់ការយល់ដឹងជាសាធារណៈអំពីការប្រែប្រួលអាកាសធាតុ ។

៥- កៀងគរហិរញ្ញប្បទានអាកាសធាតុ ។

**មាត្រា១៨១** ._ កិច្ចសហការ និងភាពជាដៃគូ

ក្រសួង ស្ថាប័នទទួលបន្ទុកអភិវឌ្ឍន៍ដោយចីរភាព ត្រូវ៖

១- សម្របសម្រួលកិច្ចសហការអន្តរក្រសួង និងការចូលរួមរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ក្នុងការរៀបចំ និងអនុវត្តសកម្មភាពពាក់ព័ន្ធនឹងការប្រែប្រួលអាកាសធាតុ ។

២- បង្កើតភាពជាដៃគូ និងអនុស្សារណៈយោគយល់សម្រាប់ការអនុវត្ត និងពង្រីកបន្ថែមនូវការឆ្លើយតប ចំពោះការប្រែប្រួលអាកាសធាតុ រវាងក្រសួង ស្ថាប័នមានសមត្ថកិច្ច និងអ្នកពាក់ព័ន្ធ ។

**មាត្រា១៨២ ._** ការធ្វើសេចក្ដីសម្រេច និងសកម្មភាពអនុវត្ត

ក្រសួង ស្ថាប័នមានសមត្ថកិច្ច ត្រូវ៖

១- ដាក់បញ្ចូលការយកចិត្តទុកដាក់អំពីការប្រែប្រួលអាកាសធាតុ ទៅក្នុងកិច្ចដំណើរការនៃការធ្វើការធ្វើសេចក្ដីសម្រេច និងការរៀបចំរាល់សកម្មភាពអនុវត្តទាំងអស់ និង

២- យកចិត្តទុកដាក់អំពីផលប៉ះពាល់នៃសកម្មភាព ដែលបញ្ចេញឧស្មន័ផ្ទះកញ្ចក់ ការប្រឈមទៅនឹងហានិភ័យអាកាសធាតុ និងសមត្ថភាពបន្សាំ ។

**មាត្រា១៨៣ ._** លិខិតបទដ្ឋានគតិយុត្តសម្រាប់ការបន្សាំនិងការកាត់បន្ថយការប្រែប្រួលអាកាសធាតុ

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន ត្រូវរៀបចំលិខិតបទដ្ឋានគតិយុត្ត សម្រាប់ការបន្សាំនិងការកាត់បន្ថយការប្រែប្រួលអាកាសធាតុ។ លិខិតបទដ្ឋានគតិយុត្តនេះ ត្រូវធ្វើបច្ចុប្បន្នភាពរៀងរាល់ ៥ (ប្រាំ) ឆ្នាំ ។

## ជំពូកទី៤
## ការអង្កេតតាមដាន និងការវាយតម្លៃការឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុ

**មាត្រា១៨៤ ._** ក្របខ័ណ្ឌអង្កេតតាមដាន និងការវាយតម្លៃថ្នាក់ជាតិ

ក្រសួង ស្ថាប័នទទួលបន្ទុកអភិវឌ្ឍន៍ដោយចីរភាព ដោយសហការជាមួយក្រសួង ស្ថាប័នទទួលបន្ទុករៀបចំផែនការ និងក្រសួង ស្ថាប័នមានសមត្ថកិច្ចដទៃទៀត ត្រូវរៀបចំ និងចាត់ចែងឱ្យមានក្របខ័ណ្ឌអង្កេតតាមដាន និងវាយតម្លៃថ្នាក់ជាតិមួយ ដើម្បីតាមដានវឌ្ឍនភាព ក្នុងការដោះស្រាយបញ្ហាប្រឈមដែលបង្កឡើងដោយការប្រែប្រួលអាកាសធាតុ និងជូនដំណឹងអំពីការពិនិត្យ និងការធ្វើបច្ចុប្បន្នភាព នៃការឆ្លើយតបទៅលើការប្រែប្រួលអាកាសធាតុ ។

ក្របខ័ណ្ឌនៃការអង្កេតតាមដាន និងការវាយតម្លៃថ្នាក់ជាតិស្តីពីការឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុ ត្រូវកំណត់ដោយលិខិតបទដ្ឋានគតិយុត្តដោយឡែករបស់ក្រសួង ស្ថាប័នទទួលបន្ទុកអភិវឌ្ឍន៍ដោយចីរភាព ក្នុងរយៈពេល ១ (មួយ)ឆ្នាំបន្ទាប់ពីក្រមនេះចូលជាធរមាន ។

**មាត្រា១៨៥** ._ ក្របខ័ណ្ឌនៃការអង្កេតតាមដាន និងវាយតម្លៃតាមវិស័យ

ក្រសួង ស្ថាប័នមានសមត្ថកិច្ច ដោយមានការគាំទ្រពីក្រសួង ស្ថាប័នទទួលបន្ទុកអភិវឌ្ឍន៍ដោយចីរភាព ត្រូវរៀបចំ និងចាត់ចែងឱ្យមានក្របខ័ណ្ឌនៃការអង្កេតតាមដាន និងវាយតម្លៃការប្រែប្រួលបរិស្ថានតាមវិស័យនីមួយៗ ស្របតាមលិខិតបទដ្ឋានគតិយុត្តស្តីពីការរៀបចំនិងចាត់ចែងឱ្យមានការអង្កេតតាមដាន និងវាយតម្លៃការប្រែប្រួលអាកាសធាតុតាមវិស័យនីមួយៗ ដើម្បីតាមដានប្រសិទ្ធភាពនៃវិធានការឆ្លើយតប ដែលមាននៅក្នុងផែនការឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុតាមវិស័យនីមួយៗ ។

ក្រសួង ស្ថាប័នទទួលបន្ទុកអភិវឌ្ឍន៍ដោយចីរភាព ត្រូវរៀបចំលិខិតបទដ្ឋានគតិយុត្តស្តីពីក្របខ័ណ្ឌនៃការអង្កេតតាមដាន និងវាយតម្លៃការប្រែប្រួលអាកាសធាតុតាមវិស័យនីមួយៗ ក្នុងរយៈពេល ១ (មួយ)ឆ្នាំបន្ទាប់ពីក្រមនេះចូលជាធរមាន ។

**មាត្រា១៨៦** ._ សកម្មភាពនៃការអង្កេតតាមដាន និងវាយតម្លៃ

ក្រសួង ស្ថាប័នទទួលបន្ទុកអភិវឌ្ឍន៍ដោយចីរភាព ត្រូវសម្របសម្រួល និងអនុវត្តសកម្មភាពអង្កេតតាមដាន និងវាយតម្លៃ ពាក់ព័ន្ធនឹងការប្រែប្រួលអាកាសធាតុ ស្របតាមលិខិតបទដ្ឋានគតិយុត្តស្តីពីក្របខ័ណ្ឌនៃការអង្កេតតាមដាន និងវាយតម្លៃការប្រែប្រួលបរិស្ថានតាមវិស័យនីមួយៗ ។

ក្រសួង ស្ថាប័នមានសម្ថកិច្ច រដ្ឋបាលថ្នាក់ក្រោមជាតិ ដោយសហការជាមួយមន្ទីររាជធានី-ខេត្តចំណុះស្ថាប័នមានសមត្ថកិច្ច និងក្រសួង ស្ថាប័នទទួលបន្ទុកអភិវឌ្ឍន៍ដោយចីរភាព ត្រូវអនុវត្តសកម្មភាពអង្កេតតាមដាន និងវាយតម្លៃការឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុ ឱ្យស្របទៅតាមលិខិតបទដ្ឋានគតិយុត្តថ្នាក់ជាតិស្តីពីក្របខណ្ឌនៃការអង្កេតតាមដាន និងវាយតម្លៃការប្រែប្រួលអាកាសធាតុ និងលិខិតបទដ្ឋានគតិយុត្តស្តីពីការអង្កេតតាមដាន និងការវាយតម្លៃ ការប្រែប្រួលអាកាសធាតុតាមវិស័យនីមួយៗ ។

**មាត្រា១៨៧** ._ ការរៀបចំរបាយការណ៍ស្តីពីការអង្កេតតាមដាន និងការវាយតម្លៃ

ក្រសួង ស្ថាប័នមានសមត្ថកិច្ច ត្រូវរៀបចំរបាយការណ៍ស្តីពី៖

១- សូចនករនានានៃក្របខ័ណ្ឌអង្កេតតាមដាន និងវាយតម្លៃថ្នាក់ជាតិស្តីពីការប្រែប្រួលអាកាសធាតុ ។

២- លិខិតបទដ្ឋានគតិយុត្តស្តីពីការអង្កេតតាមដាន និងវាយតម្លៃ ដែលពាក់ព័ន្ធនឹងការប្រែប្រួលអាកាសធាតុដទៃទៀត ។

៣- ក្របខ័ណ្ឌស្តីពីការអង្កេតតាមដាន និងវាយតម្លៃតាមវិស័យនីមួយៗ ។

របាយការណ៍ទាំងនេះ ត្រូវរៀបចំឱ្យបានទាន់ពេលវេលាទៅកាន់ក្រសួង ស្ថាប័នទទួលបន្ទុកអភិវឌ្ឍន៍ដោយចីរភាព ស្របតាមលិខិតបទដ្ឋានគតិយុត្តស្តីពីការអង្កេតតាមដាន និងការវាយតម្លៃ ការប្រែប្រួលអាកាសធាតុតាមវិស័យនីមួយៗ ។

**មាត្រា១៨៨** ._ កាតព្វកិច្ចរៀបចំរបាយការណ៍ជាអន្តរជាតិ

ក្រសួង ស្ថាប័នទទួលបន្ទុកអភិវឌ្ឍន៍ដោយចីរភាព ត្រូវរៀបចំរបាយការណ៍បញ្ជូនទៅកាន់អង្គការអន្តរជាតិ ស្តីពីការអនុវត្ត ការឆ្លើយតបចំពោះការប្រែប្រួលអាកាសធាតុ ស្របតាមកិច្ចព្រមព្រៀងអន្តរជាតិស្តីពីការប្រែប្រួលអាកាសធាតុ និងការអភិវឌ្ឍដោយចីរភាព ដែលព្រះរាជាណាចក្រកម្ពុជាជាភាគីហត្ថលេខី ។

**មាត្រា១៨៩** ._ ការរៀបចំលិខិតបទដ្ឋានគតិយុត្តទាក់ទងនឹងការប្រែប្រួលអាកាសធាតុ

ក្រសួង ស្ថាប័នទទួលបន្ទុកអភិវឌ្ឍន៍ដោយចីរភាព ដោយសហការជាមួយក្រសួង ស្ថាប័នមានសមត្ថកិច្ច ត្រូវរៀបចំលិខិតបទដ្ឋានគតិយុត្តស្តីពីការបង្កើត និងការរៀបចំលិខិតបទដ្ឋានគតិយុត្តទាក់ទងនឹងការវាយតម្លៃ ការផ្ទៀងផ្ទាត់ ការរៀបចំរបាយការណ៍ និងការកំណត់វិធានការ ។

លិខិតបទដ្ឋានគតិយុត្តនេះ ត្រូវអនុលោមតាមអនុសញ្ញាក្របខ័ណ្ឌអង្គការសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ និងលក្ខខណ្ឌតម្រូវនៃយន្តការទូទាត់ថ្លៃលក់កាបូន ។

ក្រសួង ស្ថាប័នមានសមត្ថកិច្ច ត្រូវរៀបចំ និងចាត់ចែងឱ្យមាននីតិវិធី និងឯកសារទាក់ទងនឹងការវាយតម្លៃ ការផ្ទៀងផ្ទាត់ ការរៀបចំរបាយការណ៍ និងការកំណត់វិធានការ ស្របតាមលិខិតបទដ្ឋានគតិយុត្តស្តីពីការវាយតម្លៃ ការផ្ទៀងផ្ទាត់ ការរៀបចំរបាយការណ៍ និងការកំណត់វិធានការ ។

គ្រប់ក្រសួង ស្ថាប័នមានសមត្ថកិច្ច ត្រូវរៀបចំបង្កើតនីតិវិធី ដែលទាក់ទងទៅនឹងការកំណត់វិធានការ ការរៀបចំរបាយការណ៍ និងការផ្ទៀងផ្ទាត់ ស្របតាមលិខិតបទដ្ឋានគតិយុត្តស្តីពីការអង្កេតតាមដាន ការរៀបចំរបាយការណ៍ ការផ្ទៀងផ្ទាត់ និងការវាយតម្លៃ ។

**មាត្រា១៩០ .**_ ការដាក់បញ្ចូលក្របខ័ណ្ឌនៃការអង្កេតតាមដាននិងវាយតម្លៃការប្រែប្រួលអាកាសធាតុ

គ្រប់ក្រសួង ស្ថាប័នមានសមត្ថកិច្ច ត្រូវដាក់បញ្ចូលក្របខ័ណ្ឌនៃការអង្កេតតាមដាន និងវាយតម្លៃការប្រែប្រួលអាកាសធាតុតាមវិស័យនីមួយៗ ទៅក្នុងលិខិតបទដ្ឋានគតិយុត្តរួមស្តីពីការអង្កេតតាមដាន និងការវាយតម្លៃការប្រែប្រួលអាកាសធាតុ ។

## ជំពូកទី៥
## ព័ត៌មានស្តីពីការប្រែប្រួលអាកាសធាតុ

**មាត្រា១៩១ .** _សកម្មភាព និងព័ត៌មានពាក់ព័ន្ធនឹងការប្រែប្រួលអាកាសធាតុ

ក្រសួង ស្ថាប័នទទួលបន្ទុកអភិវឌ្ឍន៍ដោយចីរភាព ដោយសហការជាមួយក្រសួង ស្ថាប័នទទួលបន្ទុករៀបចំផែនការ និងក្រសួង ស្ថាប័នមានសមត្ថកិច្ច ត្រូវប្រមូល ធ្វើបច្ចុប្បន្នភាព គ្រប់គ្រង និងដាក់ឱ្យសាធារណជនអាចស្វែងរកបាននូវព័ត៌មានស្តីពីការប្រែប្រួលអាកាសធាតុដែលពាក់ព័ន្ធទៅនឹងការអនុវត្តការឆ្លើយតបប្រកបដោយប្រសិទ្ធភាពចំពោះការប្រែប្រួលអាកាសធាតុ ។

ព័ត៌មានស្តីពីការប្រែប្រួលអាកាសធាតុ មានដូចខាងក្រោមៈ

១- ការរៀបចំផែនទីនៃហានិភ័យពាក់ព័ន្ធទៅនឹងអាកាសធាតុ សេណារីយ៉ូនៃការប្រែប្រួលអាកាសធាតុ ការវាយតម្លៃភាពងាយរងគ្រោះ និងជម្រើស និងសមត្ថភាពក្នុងការបន្សាំ ។

២- កត្តានានានៃការបញ្ចេញឧស្ម័ន និងកម្រិតបរិមាណព្រៃឈើ ។

៣- ប្រភព និងការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ ។

៤- ជម្រើសក្នុងការកាត់បន្ថយឧស្ម័នផ្ទះកញ្ចក់ និងការលើកកម្ពស់ការអភិវឌ្ឍភាពស៊ាំនឹងអាកាសធាតុ ដែលបញ្ចេញកាបូនទាប ។

៥- ការកាត់បន្ថយការបញ្ចេញឧស្ម័នពីការចូលរួមអនុវត្តយន្តការទូទាត់ថ្លៃលក់កាបូនរបស់ព្រះរាជាណាចក្រកម្ពុជា ។

៦- ការរៀបចំផែនទីនៃគម្រោង ដែលទាក់ទងទៅនឹងវិធានការកាត់បន្ថយ និងការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ ដែលអនុវត្តនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

៧- ទម្លាប់ល្អនៃការអនុវត្តការកាត់បន្ថយ និងការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុដែលបានអនុវត្តនៅក្នុងបរិបទនៃព្រះរាជាណាចក្រកម្ពុជា ។

៨- ការរៀបចំរបាយការណ៍ដោយផ្អែកលើឯកសារស្តីពីការអង្កេតតាមដាន និងវាយតម្លៃការប្រែប្រួលអាកាសធាតុ ។

**មាត្រា១៩២ ._** ព័ត៌មានអំពីការប្រែប្រួលអាកាសធាតុដែលសាធារណជនអាចស្វែងរកបាន

គ្រប់ក្រសួង ស្ថាប័នមានសមត្ថកិច្ច ដោយសហកាជាមួយក្រសួង ស្ថាប័នទទួលបន្ទុកអភិវឌ្ឍន៍ដោយចីរភាព ត្រូវប្រមូល ធ្វើបច្ចុប្បន្នភាព គ្រប់គ្រង និងដាក់ឱ្យសាធារណជន អាចស្វែងរកបាននូវព័ត៌មានអំពីការប្រែប្រួលអាកាសធាតុទៅតាមវិស័យនីមួយៗស្តីពីលទ្ធផលនៃការអនុវត្តការអង្កេតតាមដាន និងវាយតម្លៃ និងបទពិសោធន៍ស្តីពីការអនុវត្តសកម្មភាពសាកល្បង ។

**មាត្រា១៩៣ . _** ការរៀបចំព័ត៌មានស្តីពីការប្រែប្រួលអាកាសធាតុ

ក្រសួង ស្ថាប័នមានសមត្ថកិច្ចអភិវឌ្ឍន៍ដោយចីរភាព ត្រូវរៀបចំលិខិតបទដ្ឋានគតិយុត្តស្តីពីការផលិត និងការគ្រប់គ្រងទិន្នន័យ និងព័ត៌មានពាក់ព័ន្ធនឹងការប្រែប្រួលអាកាសធាតុ ។

**មាត្រា១៩៤ ._** កិច្ចព្រមព្រៀងស្តីពីការផលិត និងការចែករំលែកទិន្នន័យ

ក្រសួង ស្ថាប័នទទួលបន្ទុកអភិវឌ្ឍន៍ប្រកបដោយចីរភាព អាចចុះកិច្ចព្រមព្រៀងស្តីពីការផលិត និងការចែករំលែកទិន្នន័យ ជាមួយក្រសួង ស្ថាប័នមានសមត្ថកិច្ច និងនីតិបុគ្គលដទៃទៀត ដើម្បីពង្រឹង និងបង្កើនសិទ្ធិទទួលបានទិន្នន័យ និងព័ត៌មានស្តីពីការប្រែប្រួលអាកាសធាតុដែលពាក់ព័ន្ធនឹងការអនុវត្តការឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុនៃព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា១៩៥ ._** ការរៀបចំរបាយការណ៍ព័ត៌មានស្តីពីការប្រែប្រួលអាកាសធាតុ

គ្រប់ក្រសួង ស្ថាប័នមានសមត្ថកិច្ច និងនីតិបុគ្គលដទៃទៀតដោយសហការជាមួយក្រសួង ស្ថាប័នទទួលបន្ទុកអភិវឌ្ឍន៍ដោយចីរភាព ត្រូវ៖

១-រៀបចំរបាយការណ៍ស្តីពីការបញ្ចេញឧស្ម័នផ្ទះកញ្ចក់តាមវិស័យ និងតាមដែនសមត្ថកិច្ចរបស់ខ្លួន ។

២-រៀបចំរបាយការណ៍ស្តីពីការកាត់បន្ថយឧស្ម័នពីយន្តការទូទាត់ថ្លៃលក់កាបូន ។

ការរៀបចំរបាយការណ៍ខាងលើនេះ ត្រូវស្របតាមលិខិតបទដ្ឋានគតិយុត្ត ដូចមានចែងក្នុងមាត្រា១៩៨ នៃក្រមនេះ ។

គ្រប់ក្រសួង ស្ថាប័នមានសមត្ថកិច្ច ត្រូវរៀបចំរបាយការណ៍ជូនក្រសួង ស្ថាប័នទទួលបន្ទុកអភិវឌ្ឍន៍ដោយចីរភាពស្តីពីវឌ្ឍនភាពនៃការអនុវត្តការឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុ ។

**មាត្រា១៩៦**._ ប្រព័ន្ធព័ត៌មានដែលសាធារណជនអាចស្វែងរកបាន

ក្រសួង ស្ថាប័នទទួលបន្ទុកអភិវឌ្ឍន៍ដោយចីរភាព ត្រូវបង្កើត និងរៀបចំប្រព័ន្ធព័ត៌មានដែលសាធារណជនអាចស្វែងរកបាន ដើម្បីប្រមូលផ្តុំព័ត៌មានស្តីពីការប្រែប្រួលអាកាសធាតុ ដែលផលិតដោយ ក្រសួង ស្ថាប័នមានសមត្ថកិច្ច និងនីតិបុគ្គលពាក់ព័ន្ធ ។

**មាត្រា១៩៧**._ ការបង្កើតបញ្ជីសារពើភណ្ឌឧស្ម័នផ្ទះកញ្ចក់

ក្រសួង ស្ថាប័នទទួលបន្ទុកអភិវឌ្ឍន៍ដោយចីរភាព ត្រូវរៀបចំ និងគ្រប់គ្រងបញ្ជីសារពើភណ្ឌឧស្ម័នផ្ទះកញ្ចក់ថ្នាក់ជាតិ ដែលសាធារណជនអាចស្វែងរកបាន ស្របតាមបទប្បញ្ញត្តិ និងការណែនាំជាអន្តរជាតិដែលពាក់ព័ន្ធ ។

**មាត្រា១៩៨**._ លិខិតបទដ្ឋានគតិយុត្តស្តីពីសារពើភណ្ឌឧស្ម័នផ្ទះកញ្ចក់

ក្រសួង ស្ថាប័នទទួលបន្ទុកអភិវឌ្ឍន៍ដោយចីរភាព ត្រូវរៀបចំលិខិតបទដ្ឋានគតិយុត្ត ស្តីពីការប្រមូល ការផលិត និងការធានាគុណភាព និងបញ្ជូនទិន្នន័យសារពើភណ្ឌ ដែលទាក់ទងនឹងប្រភេទនៃអាងស្តុក និងប្រភពនៃការបញ្ចេញកាបូន កម្រិតបរិមាណព្រៃឈើ ការប្រមូលទិន្នន័យសកម្មភាព និងលក្ខខណ្ឌតម្រូវនៃការរៀបចំរបាយការណ៍ ។

**មាត្រា១៩៩**._ ការផ្តល់ព័ត៌មានស្តីពីបញ្ជីសារពើភណ្ឌឧស្ម័នផ្ទះកញ្ចក់

គ្រប់ម្ចាស់គម្រោង និងក្រសួង ស្ថាប័នមានសមត្ថកិច្ច ត្រូវផ្តល់ព័ត៌មានសម្រាប់ការរៀបចំបញ្ជីសារពើភណ្ឌឧស្ម័នផ្ទះកញ្ចក់ ដែលកំណត់ដោយក្រសួង ស្ថាប័នទទួលបន្ទុក អភិវឌ្ឍន៍ដោយចីរភាព ។

**មាត្រា២០០** ._ បញ្ជីថ្នាក់ជាតិសម្រាប់គម្រោងកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់

ក្រសួង ស្ថាប័នទទួលបន្ទុកអភិវឌ្ឍន៍ដោយចីរភាព ត្រូវរៀបចំ និងគ្រប់គ្រងបញ្ជីថ្នាក់ជាតិសម្រាប់គម្រោងកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ ដែលសាធារណជនអាចស្វែងរកបាន ។

បញ្ជីថ្នាក់ជាតិនេះ ត្រូវដាក់បញ្ចូលនូវ៖

១- បញ្ជីនានាដែលមានស្រាប់ ស្របតាមយន្តការទូទាត់ថ្លៃលក់កាបូនដែលពាក់ព័ន្ធ

២- និងយន្តការផលិតទានកាបូនដទៃទៀត ដែលស្របតាមលក្ខខណ្ឌតម្រូវក្រោមអនុសញ្ញាក្របខ័ណ្ឌអង្គការសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ ។

**មាត្រា២០១ ._** ការដាក់បញ្ចូលព័ត៌មានទៅក្នុងបញ្ជីថ្នាក់ជាតិសម្រាប់គម្រោងកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់

ក្រសួង ស្ថាប័នទទួលបន្ទុកអភិវឌ្ឍន៍ដោយចីរភាព ត្រូវរៀបចំលិខិតបទដ្ឋានគតិយុត្ត សម្រាប់ការដាក់បញ្ចូលព័ត៌មានទៅក្នុងបញ្ជីថ្នាក់ជាតិនៃគម្រោងកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ ស្របតាមបទប្បញ្ញត្តិ និងការណែនាំអន្តរជាតិពាក់ព័ន្ធ ។

**មាត្រា២០២ ._** ការអនុវត្តតាមបញ្ជីថ្នាក់ជាតិសម្រាប់គម្រោងកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់

អ្នកចូលរួមទាំងអស់ នៅក្នុងយន្តការទូទាត់ថ្លៃលក់កាបូន និងយន្តការដទៃទៀតដែលមិនត្រូវបានរៀបចំឡើងក្រោមអនុសញ្ញាក្របខ័ណ្ឌអង្គការសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ ត្រូវអនុវត្តតាមលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធស្តីពីការដាក់បញ្ចូលព័ត៌មានទៅក្នុងបញ្ជីព័ត៌មានថ្នាក់ជាតិសម្រាប់គម្រោងកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ ។

## ជំពូកទី៦
## ក្របខ័ណ្ឌហិរញ្ញប្បទានសម្រាប់ការប្រែប្រួលអាកាសធាតុ

**មាត្រា២០៣ ._** ការរៀបចំក្របខ័ណ្ឌហិរញ្ញប្បទាន

ក្រសួង ស្ថាប័នទទួលបន្ទុកអភិវឌ្ឍន៍ដោយចីរភាព ដោយសហការជាមួយនឹងក្រសួង ស្ថាប័នទទួលបន្ទុកសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវរៀបចំ និងគ្រប់គ្រងក្របខ័ណ្ឌហិរញ្ញប្បទាន សម្រាប់សកម្មភាពនៃការប្រែប្រួលអាកាសធាតុ ។

ក្របខ័ណ្ឌនេះ ត្រូវដាក់បញ្ចូលនូវ៖

១- ការវិភាគអំពីតម្រូវការហិរញ្ញប្បទាន ។

២- យុទ្ធសាស្ត្រក្នុងការបំពេញតម្រូវការហិរញ្ញប្បទាននេះ តាមរយៈការប្រើប្រាស់ប្រភពហិរញ្ញវត្ថុក្នុងស្រុក និងក្រៅស្រុកដែលអាចស្វែងរកបាន និង

៣- វិធានការនៃការអភិវឌ្ឍសមត្ថភាព ។

៤- កំណែទម្រង់ស្ថាប័ន ឬ យន្តការហិរញ្ញវត្ថុ ដើម្បីធ្វើការកៀងគរ និងគ្រប់គ្រងហិរញ្ញវត្ថុទាក់ទងនឹងការប្រែប្រួលអាកាសធាតុ ។

**មាត្រា២០៤ ._** ក្រុមប្រឹក្សាពិគ្រោះយោបល់

ក្រសួង ស្ថាប័នទទួលបន្ទុកអភិវឌ្ឍន៍ដោយចីរភាព អាចតែងតាំងក្រុមប្រឹក្សាពិគ្រោះយោបល់មួយ ដើម្បីរៀបចំ និងគ្រប់គ្រងក្របខ័ណ្ឌហិរញ្ញប្បទានសម្រាប់សកម្មភាពទាក់ទងនឹងការប្រែប្រួលអាកាសធាតុ ដូចមានចែងក្នុងមាត្រា២០៣ នៃក្រមនេះ ។

សមាសភាព តួនាទី និងភារកិច្ចរបស់ក្រុមប្រឹក្សាពិគ្រោះយោបល់ ត្រូវកំណត់ដោយលិខិតបទដ្ឋានគតិយុត្តរបស់ក្រសួង ស្ថាប័នទទួលបន្ទុកអភិវឌ្ឍន៍ដោយចីរភាព ។

**មាត្រា២០៥ ._** ហិរញ្ញប្បទានពិសេសតាមទីតាំង

ក្រសួង ស្ថាប័នទទួលបន្ទុកសេដ្ឋកិច្ច និងហិរញ្ញវត្ថុ តាមសំណើរបស់ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន ត្រូវបង្កើតគណនីមូលនិធិពិសេសតាមទីតាំង ដើម្បីឱ្យអ្នកពាក់ព័ន្ធចូលរួមក្នុងយន្តការហិរញ្ញវត្ថុបរិស្ថាន រួមមាន យន្តការកាត់បន្ថយការបញ្ចេញឧស្ម័នពីការបាត់បង់ និងការរេចរឹលព្រៃឈើ ការបាត់បង់មុខងារនៃការអភិរក្ស គម្រោងគ្រប់គ្រងព្រៃឈើដោយចីរភាព និងការលើកកម្ពស់គម្រោងព្រៃឈើសម្រាប់ធ្វើជាអាងស្តុកកាបូន ដោយអនុលោមតាមបទប្បញ្ញត្តិដូចមានចែងក្នុងគន្ថីទី៨ នៃក្រមនេះ ។

## ផ្នែកទី១
## ថវិកាថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិសម្រាប់ការប្រែប្រួលអាកាសធាតុ

**មាត្រា២០៦ ._** ថវិកាថ្នាក់ជាតិសម្រាប់ការប្រែប្រួលអាកាសធាតុ

ក្រសួង ស្ថាប័នទទួលបន្ទុកសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដោយមានការគាំទ្រផ្នែកបច្ចេកទេសពីក្រសួង ស្ថាប័នទទួលបន្ទុកអភិវឌ្ឍន៍ដោយចីរភាព ត្រូវយកចិត្តទុកដាក់អំពីផលប៉ះពាល់ និងដំណោះស្រាយផ្សេងៗនៃការប្រែប្រួលអាកាសធាតុនៅក្នុងដំណើរការរៀបចំថវិកាជាតិ ។

ក្រសួង ស្ថាប័នទទួលបន្ទុកអភិវឌ្ឍន៍ដោយចីរភាព ត្រូវផ្តល់ឱ្យក្រសួង ស្ថាប័នទទួលបន្ទុកសេដ្ឋកិច្ច និងហិរញ្ញវត្ថុនូវការវិភាគអំពីហានិភ័យ និងអាទិភាពនៃការប្រែប្រួលអាកាសធាតុប្រចាំឆ្នាំ។

ក្រសួង ស្ថាប័នទទួលបន្ទុកសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវយកចិត្តទុកដាក់ និងដាក់បញ្ចូល នូវ៖

១- ការវិភាគអំពីហានិភ័យ និងអាទិភាពនេះ ទៅក្នុងសារាចរណែនាំស្ដីពីការរៀបចំថវិកាប្រចាំឆ្នាំ ។

២- គោលការណ៍ណែនាំស្ដីពីការដាក់បញ្ចូលផលប៉ះពាល់ និងដំណោះស្រាយនៃការប្រែប្រួលអាកាសធាតុ ទៅក្នុងនីតិវិធី និងការណែនាំស្ដីពីការរៀបចំផែនការថវិកា ។

**មាត្រា២០៧ ._** ការលើកសំណើសុំថវិកាសម្រាប់ផលប៉ះពាល់ និងដំណោះស្រាយនៃការប្រែប្រួលអាកាសធាតុ

ក្រសួង ស្ថាប័នមានសមត្ថកិច្ច និងរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវដាក់បញ្ចូលនូវផលប៉ះពាល់ និងដំណោះស្រាយនៃការប្រែប្រួលអាកាសធាតុ នៅក្នុងការលើកសំណើសុំថវិការបស់ខ្លួន ស្របតាមលិខិតបទដ្ឋានគតិយុត្ត ដែលកំណត់ដោយក្រសួង ស្ថាប័នទទួលបន្ទុកសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

## ផ្នែកទី២
## ការវិនិយោគដែលគិតគូរចំពោះការប្រែប្រួលអាកាសធាតុពីវិស័យឯកជន

**មាត្រា២០៨ ._** ការលើកកម្ពស់ការវិនិយោគដែលគិតគូរចំពោះការប្រែប្រួលអាកាសធាតុ

ក្រសួង ស្ថាប័នទទួលបន្ទុកអភិវឌ្ឍន៍ដោយចីរភាព ដោយសហការជាមួយក្រសួង ស្ថាប័នទទួលបន្ទុកសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និង ក្រសួង ស្ថាប័នមានសមត្ថកិច្ច ត្រូវពិគ្រោះយោបល់ជាមួយអ្នកពាក់ព័ន្ធ អំពីវិធានការសារពើពន្ធ បទប្បញ្ញត្តិ ស្តង់ដារ និងយន្តការ ដែលផ្អែកលើទីផ្សារ ដើម្បីលើកកម្ពស់ការវិនិយោគដែលគិតគូរចំពោះការប្រែប្រួលអាកាសធាតុ ។

## ផ្នែកទី៣
## ការកៀងគរហិរញ្ញប្បទានការប្រែប្រួលអាកាសធាតុពីបរទេស

**មាត្រា២០៩._** ការសម្របសម្រួលអំពីហិរញ្ញប្បទានការប្រែប្រួលអាកាសធាតុពីបរទេស

ក្រសួង ស្ថាប័នទទួលបន្ទុកអភិវឌ្ឍន៍ដោយចីរភាព ត្រូវសម្របសម្រួលលើការកៀងគរហិរញ្ញប្បទានការប្រែប្រួលអាកាសធាតុពីបរទេស ឱ្យមានប្រសិទ្ធផល និងប្រសិទ្ធភាពបំផុត ។

**មាត្រា២១០._** ការត្រួតពិនិត្យហិរញ្ញប្បទានការប្រែប្រួលអាកាសធាតុពីបរទេស

ក្រសួង ស្ថាប័នទទួលបន្ទុកអភិវឌ្ឍន៍ដោយចីរភាព ដោយសហការជាមួយក្រសួង ស្ថាប័នទទួលបន្ទុកសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ត្រូវត្រួតពិនិត្យហិរញ្ញប្បទានការប្រែប្រួលអាកាសធាតុពីបរទេស និងធានាឱ្យមានការដាក់បញ្ចូលការប្រែប្រួលអាកាសធាតុទៅក្នុងកិច្ចចរចាជាមួយនឹងដៃគូអភិវឌ្ឍ ។

## ផ្នែកទី៤
## ការលើកកម្ពស់យន្តការទូទាត់ថ្លៃលក់កាបូន

**មាត្រា២១១._** យន្តការទូទាត់ថ្លៃលក់កាបូន

ក្រសួង ស្ថាប័នទទួលបន្ទុកអភិវឌ្ឍន៍ដោយចីរភាព ត្រូវពិនិត្យ ឯកភាព និងផ្តល់សុពលភាពចំពោះគម្រោងទាំងអស់ ដែលស្នើសុំការគាំទ្រពីរាជរដ្ឋាភិបាល ដើម្បីចូលរួមនៅក្នុងយន្តការទូទាត់ថ្លៃលក់កាបូន ដែលរួមមានយន្តការនានាដែលបានបង្កើតឡើងក្រោមកិច្ចព្រមព្រៀង អាកាសធាតុទីក្រុងប៉ារីស ។

**មាត្រា២១២ ._** ការលើកកម្ពស់ការចូលរួមនៅក្នុងយន្តការទូទាត់ថ្លៃលក់កាបូន

ក្រសួង ស្ថាប័នទទួលបន្ទុកអភិវឌ្ឍន៍ដោយចីរភាព ត្រូវលើកកម្ពស់ការចូលរួមនៅក្នុងយន្តការទូទាត់ថ្លៃលក់កាបូនតាមរយៈ ៖

១- ការចេញគោលការណ៍ណែនាំ ស្តីពីការទទួលបានហិរញ្ញប្បទានការប្រែប្រួលអាកាសធាតុតាមរយៈ ការចូលរួមនៅក្នុងយន្តការទូទាត់ថ្លៃលក់កាបូន ។

២- ការរក្សា និងការផ្សព្វផ្សាយព័ត៌មានស្តីពីប្រភពជម្រើសអាទិភាពផ្សេងៗ និងសក្តានុពលសម្រាប់ការកាត់បន្ថយការបញ្ចេញឧស្ម័ន ។

៣- ការរក្សា និងការផ្សព្វផ្សាយព័ត៌មានស្តីពីការកាត់បន្ថយការបញ្ចេញឧស្ម័ននៃគម្រោងដែលចូលរួមក្នុងយន្តការទូទាត់ថ្លៃលក់កាបូន តាមរយៈបញ្ជីថ្នាក់ជាតិស្តីពីគម្រោងកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ រួមមានព័ត៌មានអំពីទំហំនៃការផ្តល់ហិរញ្ញប្បទានការប្រែ

ប្រូលអាកាសធាតុ ដែលប្រមូលបានតាមរយៈការចូលរួមនៅក្នុងយន្តការទូទាត់ថ្លៃលក់កាបូន ។

## មាតិកាទី៣
## ផលិតកម្ម និងការប្រើប្រាស់ដោយចីរភាព
## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**មាត្រា២១៣ ._** វិសាលភាព

មាតិកានេះមានវិសាលអនុវត្តចំពោះសកម្មភាព និងការគ្រប់គ្រងលើផលិតកម្ម និងការប្រើប្រាស់ដោយចីរភាព នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

**មាត្រា២១៤ ._** តួនាទី និងការទទួលខុសត្រូវរបស់ក្រសួង ស្ថាប័នទទួលបន្ទុកអភិវឌ្ឍន៍ដោយចីរភាព

ក្រសួង ស្ថាប័នទទួលបន្ទុកអភិវឌ្ឍន៍ដោយចីរភាព ដោយសហការជាមួយក្រសួង ស្ថាប័នមានសមត្ថកិច្ច ត្រូវទទួលខុសត្រូវក្នុងការរៀបចំគោលនយោបាយ និងកម្មវិធីស្តីពីផលិតកម្ម និងការប្រើប្រាស់ដោយចីរភាព ។

## ជំពូកទី២
## ការលើកកម្ពស់ផលិតកម្ម និងការប្រើប្រាស់ដោយចីរភាព

**មាត្រា២១៥ ._** ការប្រើប្រាស់ដោយចីរភាព

ក្រសួង ស្ថាប័នទទួលបន្ទុកអភិវឌ្ឍន៍ដោយចីរភាព ដោយសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវរៀបចំគោលនយោបាយ និងកម្មវិធី ស្តីពីការប្រើប្រាស់ដោយចីរភាព ។ កម្មវិធីនិងគោលនយោបាយទាំងនេះ មានដូចខាងក្រោម៖

ក- កម្មវិធីធ្វើឱ្យប្រសើរឡើងលើគំរូនៃការអនុវត្តការប្រើប្រាស់ដោយយកចិត្តទុកដាក់ដល់បរិស្ថាន តាមរយៈការបង្កើនតម្រូវការ និងការផ្គត់ផ្គង់ផលិតផល សេវាកម្ម និងបច្ចេកវិទ្យាមេត្រីបរិស្ថាន ។

ខ- គោលនយោបាយ ដែលជំរុញឱ្យមានការចូលរួមពីវិស័យឯកជន អង្គការសង្គមស៊ីវិល ក្រសួង ស្ថាប័នមានសមត្ថកិច្ច និងប្រជាពលរដ្ឋ និងដើម្បីលើកកម្ពស់ការប្រើប្រាស់ធនធានប្រកបដោយប្រសិទ្ធផល និងបង្កការខូចខាតបរិស្ថានតិចតួច ទាក់ទងនឹង ៖

១- ការប្រើប្រាស់ថាមពល និងទឹក

២- ការបង្កើតសំណល់គ្រោះថ្នាក់

៣- ការគ្រប់គ្រងសំណល់

៤- ទេសចរណ៍

៥- និងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ ជាអាទិ៍ ។

**មាត្រា២១៦** ._ ផលិតកម្មដោយចីរភាព

ក្រសួង ស្ថាប័នទទួលបន្ទុកអភិវឌ្ឍន៍ដោយចីរភាព ដោយសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវរៀបចំគោលនយោបាយ និងកម្មវិធីស្តីពីផលិតកម្មដោយចីរភាព។ គោលនយោបាយ និងកម្មវិធីទាំងនេះ មានដូចខាងក្រោម ៖

១. កម្មវិធីដើម្បីលើកកម្ពស់ការអនុវត្តគំរូផលិតផល និងទម្លាប់ល្អនៃការអនុវត្តដំណើរការផលិតកម្មមេត្រីបរិស្ថាន ។

២. គោលនយោបាយដែលជំរុញឱ្យមានការចូលរួមពីវិស័យឯកជន អង្គការសង្គមស៊ីវិល ក្រសួង ស្ថាប័នមានសមត្ថកិច្ច និងប្រជាពលរដ្ឋដើម្បីលើកកម្ពស់ផលិតកម្មដែលប្រើប្រាស់ធនធានប្រកបដោយប្រសិទ្ធផល និងបង្កការខូចខាតបរិស្ថានតិចតួច ។

**មាត្រា២១៧** ._ ការផ្ទៀងផ្ទាត់បច្ចេកវិទ្យាមេត្រីបរិស្ថាន

ក្រសួង ស្ថាប័នទទួលបន្ទុកអភិវឌ្ឍន៍ដោយចីរភាព ដោយសហការជាមួយក្រសួង ស្ថាប័នទទួលបន្ទុកឧស្សាហកម្ម និងក្រសួង ស្ថាប័នមានសមត្ថកិច្ច ត្រូវរៀបចំ៖

១- កម្មវិធីសម្រាប់ធ្វើការផ្ទៀងផ្ទាត់បច្ចេកវិទ្យា ដែលអនុវត្តទៅលើបច្ចេកវិទ្យាមេត្រីបរិស្ថាន រួមមានបច្ចេកវិទ្យាដែលត្រូវប្រើប្រាស់ក្នុងវិស័យឧស្សាហកម្ម រុក្ខប្រម៉ាញ់ កសិកម្ម រ៉ែ ឧស្សាហកម្មសេវាកម្ម និងលំនៅឋាន ។

២- បញ្ជីសម្រាប់ផ្ទៀងផ្ទាត់បច្ចេកវិទ្យាមេត្រីបរិស្ថាន ដែលអាចឱ្យសាធារណជនអាចស្វែងរកបាន ។

**មាត្រា២១៨ .**_ ការទទួលខុសត្រូវបន្ថែមរបស់ផលិតករ

ក្រសួង ស្ថាប័នទទួលបន្ទុកអភិវឌ្ឍន៍ដោយចីរភាព ដោយសហការជាមួយក្រសួង ស្ថាប័នទទួលបន្ទុកឧស្សាហកម្ម និងក្រសួង ស្ថាប័នមានសមត្ថកិច្ច ត្រូវរៀបចំកម្មវិធីស្តីពីការទទួលខុសត្រូវបន្ថែមរបស់ផលិតករ ដើម្បីលើកកម្ពស់ការទទួលខុសត្រូវរបស់ផលិតករចំពោះការបង្កើតសំណល់ដោយអ្នកប្រើប្រាស់ ។

កម្មវិធីនេះ ត្រូវដាក់បញ្ចូលនូវចំណុចដូចខាងក្រោមៈ

១- លក្ខខណ្ឌតម្រូវសម្រាប់ការចូលរួមដោយស្ម័គ្រចិត្ត និងជាកំហិត សម្រាប់ផលិតផល ក្រុមផលិតផល និងលំហូរសំណល់ ។

២- គោលដៅសម្រាប់ការប្រមូល ការកែច្នៃឡើងវិញ ការចម្រាញ់ និងការប្រើប្រាស់ឡើងវិញ ។

៣- កូតាសម្រាប់ការយកផលិតផលត្រឡប់មកវិញ ។

៤- ការទទួលខុសត្រូវរបស់អ្នកពាក់ព័ន្ធ នៅក្នុងខ្សែសង្វាក់នៃការផ្គត់ផ្គង់ រួមមាន ផលិតករក្នុងស្រុក និងអ្នកនាំចូលបច្ចេកវិទ្យា និងផលិតផលពីបរទេស ។

៥- ការអភិវឌ្ឍសមត្ថភាពដល់អ្នកពាក់ព័ន្ធ ។

**មាត្រា២១៩ .**_ ការដាក់ស្លាកសញ្ញាបរិស្ថានដោយស្ម័គ្រចិត្ត

ក្រសួង ស្ថាប័នទទួលបន្ទុកអភិវឌ្ឍន៍ដោយចីរភាព ដោយសហការជាមួយក្រសួង ស្ថាប័នទទួលបន្ទុកឧស្សាហកម្ម និងក្រសួង ស្ថាប័នមានសមត្ថកិច្ច ត្រូវរៀបចំកម្មវិធីស្តង់ដារស្ម័គ្រចិត្តសម្រាប់ដាក់ស្លាកសញ្ញាបរិស្ថានលើផលិតផល និងសេវាកម្ម ដោយភ្ជាប់មកជាមួយព័ត៌មានស្តីពីបន្ទុកផ្នែកបរិស្ថាន ដែលរួមមានព័ត៌មានស្តីពីធាតុផ្សំនៃផលិតផល ប្រសិទ្ធផលថាមពល និងព័ត៌មានទាក់ទងនឹងការបង្កើតសំណល់ ។

**មាត្រា២២០ .**_ ការរៀបចំលិខិតបទដ្ឋានគតិយុត្តស្តីពីស្លាកសញ្ញាបរិស្ថាន

ក្រសួង ស្ថាប័នទទួលបន្ទុកអភិវឌ្ឍន៍ដោយចីរភាពដោយសហការជាមួយក្រសួង ស្ថាប័នមានសមត្ថកិច្ច ត្រូវរៀបចំលិខិតបទដ្ឋានគតិយុត្ត ដូចខាងក្រោមៈ

១- នីតិវិធីសម្រាប់ការរៀបចំ និងការប្រែសម្រួលប្រភេទ លក្ខណៈវិនិច្ឆ័យ និងស្តង់ដាសម្រាប់ផលិតផល និងសេវាកម្ម

២- នីតិវិធីសម្រាប់ ការចេញវិញ្ញាបនបត្របញ្ជាក់ និងការធ្វើសវនកម្ម

៣- វិធានសម្រាប់ប្រើប្រាស់ស្លាកសញ្ញាបរិស្ថាន

ក្រសួង ស្ថាប័នទទួលបន្ទុកអភិវឌ្ឍន៍ដោយចីរភាព ត្រូវពិនិត្យឡើងវិញ និងធ្វើបច្ចុប្បន្នភាពលើស្តង់ដារ និងលក្ខណៈវិនិច្ឆ័យនៃស្លាកសញ្ញាបរិស្ថាន ដោយផ្អែកលើភស្តុតាងបែបវិទ្យាសាស្ត្រ និង បច្ចេកវិទ្យាល្អបំផុតដែលអាចស្វែងរកបាន ។

**មាត្រា២២១** ._ ការអនុគ្រោះលើការធ្វើលទ្ធកម្ម

ក្រសួង ស្ថាប័នមានសមត្ថកិច្ច ត្រូវធានាថាផលិតផល និងសេវាកម្មដែលទទួលបានការចេញវិញ្ញាបនបត្របញ្ជាក់ពីស្លាកសញ្ញាបរិស្ថាន ត្រូវទទួលបានការអនុគ្រោះ នៅក្នុងការធ្វើសេចក្តីសម្រេចផ្នែកលទ្ធកម្ម ។

## ជំពូកទី៣
## លទ្ធកម្មដោយចីរភាព

**មាត្រា២២២** ._ ការរៀបចំលិខិតបទដ្ឋានគតិយុត្តស្តីពីលទ្ធកម្មដោយចីរភាព

ក្រសួង ស្ថាប័នទទួលបន្ទុក សេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដោយសហការជាមួយ ក្រសួង ស្ថាប័នទទួលបន្ទុកការអភិវឌ្ឍដោយចីរភាព ត្រូវរៀបចំលិខិតបទដ្ឋានគតិយុត្តស្តីពីលទ្ធកម្មដោយចីរភាព ដោយដាក់បញ្ចូលនូវលក្ខណៈវិនិច្ឆ័យផ្នែកបរិស្ថាន ពាក់ព័ន្ធនឹងវដ្តជីវិតនៃការធ្វើលទ្ធកម្មលើទំនិញ សេវាកម្ម និងការងារ ដើម្បីៈ

១- កាត់បន្ថយជាអប្បបរមានូវបន្ទុកផ្នែកបរិស្ថានពីការប្រើប្រាស់ និង

២- បំពេញតម្រូវការផលិតកម្ម និងសេវាកម្មមេត្រីបរិស្ថាន ។

**មាត្រា២២៣** ._ គោលបំណងនៃលិខិតបទដ្ឋានគតិយុត្តស្តីពីលទ្ធកម្មដោយចីរភាព

លិខិតបទដ្ឋានគតិយុត្តស្តីពីលទ្ធកម្មដោយចីរភាព ត្រូវៈ

១- លើកទឹកចិត្តចំពោះប្រសិទ្ធផលនៃការផលិតធនធាន និងផលិតកម្មស្អាតនៅគ្រប់ដំណាក់កាលទាំងអស់នៃវដ្តជីវិតរបស់ផលិតផល និងសេវាកម្ម ។

២- កំណត់ប្រភេទ និងលំដាប់អាទិភាពនៃផលិតផល និងសេវាកម្ម ដែលរួមមានបច្ចេកវិទ្យាមេត្រីបរិស្ថាន ហិរញ្ញវត្ថុបៃតង និងនីតិវិធីសម្រាប់ការពិនិត្យឡើងវិញ។

៣- កំណត់លក្ខខណ្ឌតម្រូវសម្រាប់ការអនុវត្ត និងលក្ខណៈវិនិច្ឆ័យអប្បបរមាផ្នែកបរិស្ថាន រួមមានប្រសិទ្ធផលធនធាន ការកាត់បន្ថយ ការប្រើប្រាស់ឡើងវិញ ការច្នៃសំណល់ ការគ្រប់គ្រងសំណល់ដែលមានលក្ខណៈចម្រុះ ផលិតកម្មស្អាត សម្រាប់ប្រភេទផលិតផល និងសេវាកម្មនីមួយៗ ដោយផ្អែកលើផលប៉ះពាល់បរិស្ថានចេញពីផលិតផល និងសេវាកម្មនោះ និងនីតិវិធីសម្រាប់ការពិនិត្យឡើងវិញ ។

៤- កំណត់លក្ខខណ្ឌតម្រូវក្នុងការរៀបចំរបាយការណ៍សម្រាប់ប្រភេទនៃផលិតផល សេវាកម្ម និងទំហំនៃលទ្ធកម្ម ។

៥- ផ្តល់ការណែនាំសម្រាប់ការជ្រើសរើសផលិតផល និងសេវាកម្ម ឱ្យបានត្រឹមត្រូវ ។

៦- ផ្តល់ការណែនាំសម្រាប់ការធ្វើសេចក្តីសម្រេចផ្នែកលទ្ធកម្ម ដោយកំណត់លក្ខណៈវិនិច្ឆ័យសម្រាប់ការអនុវត្តការងារទាក់ទងនឹងបរិស្ថាន ឱ្យមានសង្គតិភាពជាមួយនឹងលក្ខណៈវិនិច្ឆ័យសម្រាប់ការទិញលក់ដទៃទៀត ។

៧- កំណត់វិធានការសម្រាប់ក្រសួង ស្ថាប័នទទួលបន្ទុកអនុវត្តការងារលទ្ធកម្ម ដើម្បីលើកទឹកចិត្ត និងជួយដល់អ្នកពាក់ព័ន្ធ ក្នុងការអនុវត្តលទ្ធកម្មដោយចីរភាព ។

**មាត្រា២២៤**._ ការអនុវត្តទម្លាប់នៃការធ្វើលទ្ធកម្ម

ក្រសួង ស្ថាប័ន ទទួលបន្ទុកអនុវត្តការងារលទ្ធកម្ម ត្រូវអនុវត្តទម្លាប់នៃការធ្វើលទ្ធកម្ម ឱ្យស្របតាមលិខិតបទដ្ឋានគតិយុត្តស្តីពីលទ្ធកម្មដោយចីរភាពដូចមានចែងក្នុងមាត្រា២២៣ នៃក្រមនេះ ចំពោះផលិតកម្ម និងសេវាកម្ម ដូចខាងក្រោម ៖

១- ត្រូវធ្វើលទ្ធកម្មក្រោមថវិការបស់ក្រសួងស្ថាប័នថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ ។

២- ត្រូវធ្វើលទ្ធកម្មដោយក្រសួង ស្ថាប័នមានសមត្ថកិច្ច ដែលត្រូវអនុវត្តតាមបទប្បញ្ញត្តិស្តីពីលទ្ធកម្ម ។

៣- ត្រូវធ្វើលទ្ធកម្មក្រោមគម្រោងដែលទទួលបានមូលនិធិពីម្ចាស់ជំនួយ ។

**មាត្រា២២៥**._ ផែនការលទ្ធកម្មដោយចីរភាព

ក្រសួង ស្ថាប័នទទួលបន្ទុកអភិវឌ្ឍន៍ដោយចីរភាព ដោយសហការជាមួយ ក្រសួង ស្ថាប័នទទួលបន្ទុកសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវ៖

១- តម្រូវឱ្យគ្រប់ក្រសួង ស្ថាប័ន ទទួលបន្ទុកអនុវត្តការងារលទ្ធកម្ម ដាក់បញ្ចូល និងអនុវត្តលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធស្តីពីការធ្វើលទ្ធកម្មដោយចីរភាព ។

២- រៀបចំផែនការជាតិស្តីពីលទ្ធកម្មដោយចីរភាព និងត្រូវធ្វើបច្ចុប្បន្នភាពផែនការនេះជាទៀងរាល់ឆ្នាំ ។

ក្រសួង ស្ថាប័នទទួលបន្ទុកអនុវត្តការងារលទ្ធកម្ម ត្រូវរៀបចំផែនការលទ្ធកម្មដោយចីរភាព និងត្រូវធ្វើបច្ចុប្បន្នភាពផែនការនេះជាទៀងរាល់ឆ្នាំ ។

**មាត្រា២២៦** ._ ការបណ្តុះបណ្តាលអំពីលទ្ធកម្មដោយចីរភាព

ក្រសួង ស្ថាប័នទទួលបន្ទុកអភិវឌ្ឍន៍ដោយចីរភាព ដោយសហការជាមួយក្រសួង ស្ថាប័នទទួលបន្ទុកសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវផ្តល់ការបណ្តុះបណ្តាលស្តីពីការអនុវត្តលទ្ធកម្មដោយចីរភាពដល់គ្រប់ក្រសួង ស្ថាប័ន ដែលទទួលបន្ទុកអនុវត្តការងារលទ្ធកម្ម អ្នកផ្គត់ផ្គង់ និងអ្នកទិញមកពីវិស័យឯកជន ។

**មាត្រា២២៧** ._ ការរៀបចំរបាយការណ៍ប្រចាំឆ្នាំស្តីពីលទ្ធកម្មដោយចីរភាព

ក្រសួង ស្ថាប័នទទួលអនុវត្តការងារលទ្ធកម្ម ត្រូវរៀបចំរបាយការណ៍ប្រចាំឆ្នាំស្តីពីការអនុវត្តការងារលទ្ធកម្មដោយចីរភាព ដែលត្រូវដាក់បញ្ចូលចំណុចដូចខាងក្រោម៖

១- បញ្ជីនៃផលិតផល និងសេវាកម្មមេត្រីបរិស្ថាន ដែលបានទិញ ក្នុងអំឡុងពេលនៃឆ្នាំសារពើពន្ធ ។

២- ការវិភាគអំពីការដាក់បញ្ចូល និងការអនុវត្តលក្ខណៈវិនិច្ឆ័យផ្នែកបរិស្ថាននៅក្នុងការធ្វើលទ្ធកម្ម ។

៣- ផែនការប្រចាំឆ្នាំស្តីពីផលិតផល និងសេវាកម្មមេត្រីបរិស្ថាន នៅក្នុងបញ្ជីអាទិភាពដែលត្រូវធ្វើលទ្ធកម្ម ។

ក្រសួង ស្ថាប័ន ទទួលបន្ទុកអនុវត្តការងារលទ្ធកម្ម ត្រូវផ្តល់ របាយការណ៍នេះ ទៅក្រសួង ស្ថាប័នទទួលបន្ទុកអភិវឌ្ឍន៍ដោយចីរភាព និងក្រសួង ស្ថាប័នទទួលបន្ទុកសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

**មាត្រា២២៨** ._ ការវាយតម្លៃការអនុវត្តការងារលទ្ធកម្មដោយចីរភាព

ក្រសួង ស្ថាប័នទទួលបន្ទុកអភិវឌ្ឍន៍ដោយចីរភាព និងក្រសួង ស្ថាប័នទទួលបន្ទុកសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវ៖

១- ប្រើប្រាស់ព័ត៌មានដែលបានមកពីរបាយការណ៍ប្រចាំឆ្នាំស្តីពីទម្លាប់អនុវត្តលទ្ធកម្មដោយចីរភាពដើម្បីកំណត់បញ្ហា និងភាពគ្មានប្រសិទ្ធភាពនៃការអនុវត្តលទ្ធកម្មដោយចីរភាព និង

២- ពិគ្រោះយោបល់ជាមួយអ្នកពាក់ព័ន្ធ ដើម្បីកែសម្រួលលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ តាមការចាំបាច់ ។

**មាត្រា២២៩** ._ ផលិតផលមេត្រីបរិស្ថាន

ក្រសួង ស្ថាប័នមានសមត្ថកិច្ច មិនត្រូវបង្កជាឧបសគ្គ និងត្រូវលើកទឹកចិត្តដល់អ្នកផ្គត់ផ្គង់ ក្នុងការណែនាំឱ្យស្គាល់ ការទិញ ការប្រើប្រាស់ ការនាំចូល ការនាំចេញនូវផលិតផលមេត្រីបរិស្ថាន ។

## មាតិកាទី៤
## ការរៀបចំផែនការប្រើប្រាស់ដីដែលយកចិត្តទុកដាក់ដល់បរិស្ថាន និងទីក្រុងដោយចីរភាព
## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**មាត្រា២៣០** ._ វិសាលភាព

មាតិកានេះ មានវិសាលភាពអនុវត្តចំពោះ ទីប្រជុំជន និងជនបទដែលតម្រូវឱ្យមានការរៀបចំផែនការប្រើប្រាស់ដីធ្លី ស្របតាមច្បាប់ពិសេស និងលិខិតបទដ្ឋានគតិយុត្តដោយឡែក និងចំពោះការអភិវឌ្ឍទីក្រុងដោយចីរភាព ។

**មាត្រា២៣១** ._ តួនាទី និងការទទួលខុសត្រូវរបស់ក្រសួង ស្ថាប័នទទួលបន្ទុករៀបចំដែនដីនគរូបនីយកម្ម និងសំណង់

ក្រសួង ស្ថាប័នទទួលបន្ទុករៀបចំដែនដីនគរូបនីយកម្ម និងសំណង់ មានតួនាទី និងការទទួលខុសត្រូវដូចតទៅ៖

១- ការរៀបចំផែនការប្រើប្រាស់ដីដែលយកចិត្តទុកដាក់ដល់បរិស្ថាន ។

២- ការរៀបចំទីក្រុងដោយចីរភាព ដោយសហការជាមួយក្រសួង ស្ថាប័នទទួលបន្ទុកអភិវឌ្ឍន៍ដោយចីរភាព ។

**មាត្រា២៣២ .**_ តួនាទី និងការទទួលខុសត្រូវរបស់ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន ត្រូវផ្តល់ការគាំទ្រ និងការណែនាំផ្នែកបច្ចេកទេស ដល់ក្រសួង ស្ថាប័នទទួលបន្ទុករៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងក្រសួង ស្ថាប័នមានសមត្ថកិច្ចផ្សេងទៀត ដូចខាងក្រោម៖

១- ការធ្វើសុខដុមនីយកម្មដោយចីរភាពរវាងគោលដៅអភិវឌ្ឍន៍ជាតិ និងការអភិរក្ស និងកិច្ចគាំពារបរិស្ថាន ។

២- ការធានាការចាត់ចែងប្រើប្រាស់ធនធានដោយចីរភាពតាមរយៈការលើកទឹកចិត្តអ្នកគ្រប់គ្រងធនធាន និងអ្នកធ្វើសេចក្តីសម្រេចឱ្យពិនិត្យលើផលប៉ះពាល់ និងលក្ខណៈពាក់ព័ន្ធអន្តរ វិស័យ ។

៣- ការពង្រឹងកិច្ចសហប្រតិបត្តិការរវាងក្រសួង ស្ថាប័នមានសមត្ថកិច្ច និងអ្នកពាក់ព័ន្ធ ។

៤- ការបង្កើតឱ្យមានការចូលរួមរវាងក្រសួង ស្ថាប័នមានសមត្ថកិច្ច និងអ្នកពាក់ព័ន្ធមិនមែនរដ្ឋាភិបាល ដើម្បីធ្វើការផ្លាស់ប្តូរចំណេះដឹង ព័ត៌មាន និងកង្វល់ពាក់ព័ន្ធទៅនឹងផែនការប្រើប្រាស់ដីធ្លី និងការរៀបចំទីក្រុងដោយចីរភាព ។

៥- ការប្រមូលទិន្នន័យជាបរិមាណ និងជាគុណភាព និងការប្រើប្រាស់ប្រព័ន្ធគាំទ្រដល់ការធ្វើសេចក្តីសម្រេច ដើម្បីធានាបាននូវការយល់ដឹងអំពីបញ្ហាពាក់ព័ន្ធទៅនឹងការរៀបចំផែនការប្រើប្រាស់ និងការរៀបចំផែនការចីរភាពទីក្រុង ។

**មាត្រា២៣៣ .**_ ការរៀបចំផែនការប្រើប្រាស់ដីដែលយកចិត្តទុកដាក់ដល់បរិស្ថាន និងចីរភាពទីក្រុង

ក្រសួង ស្ថាប័នមានសមត្ថកិច្ចត្រូវដាក់បញ្ចូលទៅក្នុងនីតិវិធីនៃការរៀបចំផែនការប្រើប្រាស់ដីនិងចីរភាពទីក្រុង នូវចំណុចដូចខាងក្រោម៖

១- កិច្ចគាំពារបរិស្ថាន ការអភិរក្សធនធានធម្មជាតិ និងគោលដៅអភិវឌ្ឍដោយចីរភាព ។

២- ការចូលរួមជាសាធារណៈ និងសិទ្ធិទទួលបានព័ត៌មានបរិស្ថាន ។

៣- យន្តការការពារ គ្រប់គ្រង និងកាត់បន្ថយហានិភ័យផ្នែកបរិស្ថាន និងផលប៉ះពាល់នៃការអភិវឌ្ឍទីក្រុងឆាប់រហ័ស និងកង្វះខាតនៃការរៀបចំផែនការប្រើប្រាស់ដី ។

៤- ការរៀបចំទីក្រុងដោយចីរភាព ត្រូវផ្អែកលើភស្តុតាងផ្នែកវិទ្យាសាស្ត្រល្អបំផុតអាចរកបាន និងត្រូវប្រើប្រាស់ឧបករណ៍រៀបចំផែនការ និងបច្ចេកវិទ្យាដែលសមស្របតាមតំបន់ ។

## ជំពូកទី២
## ការរៀបចំផែនការប្រើប្រាស់ដីដែលយកចិត្តទុកដាក់ដល់បរិស្ថាន
### ផ្នែកទី១
### ការរៀបចំផែនការប្រើប្រាស់ដីដែលយកចិត្តទុកដាក់ដល់បរិស្ថាន

**មាត្រា២៣៤ .**_ ការរៀបចំផែនការប្រើប្រាស់ដីដែលយកចិត្តទុកដាក់ដល់បរិស្ថាន

គ្រប់ផែនការគោលរៀបចំប្រើប្រាស់ដីដែលស្នើឡើង ត្រូវស្របតាមលក្ខខណ្ឌតម្រូវនៃការរៀបចំផែនការប្រើប្រាស់ដីដែលយកចិត្តទុកដាក់ដល់បរិស្ថាន ដូចមានចែងក្នុងផ្នែកនេះ ។

**មាត្រា២៣៥ .**_ លក្ខខណ្ឌតម្រូវនៃការរៀបចំផែនការប្រើប្រាស់ដីដែលយកចិត្តទុកដាក់ដល់បរិស្ថាន

ក្រសួង ស្ថាប័នទទួលបន្ទុករៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ត្រូវរៀបចំលក្ខខណ្ឌតម្រូវនៃការរៀបចំផែនការប្រើប្រាស់ដីដែលយកចិត្តទុកដាក់ដល់បរិស្ថាន សម្រាប់ផែនការគោលប្រើប្រាស់ដីដូចខាងក្រោម៖

១-ការរៀបចំពិគ្រោះយោបល់ស្តីពីផែនការគោលរៀបចំប្រើប្រាស់ដីដែលបានស្នើឡើងជាមួយភាគីពាក់ព័ន្ធទាំងអស់។

២- ការរៀបចំផែនការគោលរៀបចំប្រើប្រាស់ដីដែលបានស្នើឡើង ត្រូវស្របគ្នាជាមួយនឹងផែនការអភិវឌ្ឍគោល និងផែនការយុទ្ធសាស្ត្រទីក្រុងដោយចីរភាពដែលមានស្រាប់ ឬកំពុងរៀបចំថ្មី។

៣- ការស្រាវជ្រាវ និងការប្រើប្រាស់ ទិន្នន័យដែលត្រូវសមស្របតាមភូមិសាស្ត្រជាក់ស្តែង ដែលមានលក្ខណៈលម្អិត និងប្រសើបំផុតដែលអាចរកបាន ពាក់ព័ន្ធទៅនឹងការប្រើប្រាស់ដីបច្ចុប្បន្ន និងពេលអនាគត រួមមាន ធនធានដី ការប្រើប្រាស់ដីបច្ចុប្បន្ន ហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ប្រជាពលរដ្ឋដែលរស់នៅជុំវិញ សហគមន៍ និងទំនៀមទម្លាប់ វប្បធម៌ ការចិញ្ចឹមជីវិត និងសិទ្ធិដីធ្លី ជាអាទិ៍ ។

៤- ការប្រើប្រាស់បច្ចេកវិទ្យាល្អបំផុតដែលមានស្រាប់ ដើម្បីរៀបចំផែនទីដីធ្លីចម្រុះនៃតំបន់ទេសភាព។

៥- ការរៀបចំដំណោះស្រាយអំពីផលប៉ះពាល់នៃផែនការគោលដែលបានស្នើឡើងទៅលើការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ និងអាងស្រូបកាបូន។

៦- ការព្យាករណ៍ទុកជាមុន ការយកចិត្តទុកដាក់ ការរៀបចំដំណោះស្រាយអំពីផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ ដែលអាចមានទៅលើការអនុវត្តផែនការគោលប្រើប្រាស់ដី។

៧- ការរៀបចំដំណោះស្រាយអំពីការទប់ស្កាត់គ្រោះទឹកជំនន់ និងផែនការរៀបចំប្រព័ន្ធបង្ហូរសំណល់ទឹកចេញ និងចូលនៅក្នុង និងក្រៅតំបន់នៃផែនការគោលប្រើប្រាស់ដី។

៨- ការរៀបចំប្រព័ន្ធផ្លូវ និងចំណតនៅក្នុងតំបន់នៃផែនការគោលប្រើប្រាស់ដី ត្រូវតភ្ជាប់ដោយសុវត្ថិភាព និងប្រសិទ្ធផលទៅនឹងផ្លូវក្រៅតំបន់ នៃផែនការគោលប្រើប្រាស់ដីថ្មីដែលបានស្នើឡើង។

៩- ការរៀបចំដំណោះស្រាយ និងដាក់បញ្ចូលវិធានការកាត់បន្ថយផលប៉ះពាល់ នៃផែនការគោលប្រើប្រាស់ដី ដែលអាចមានទៅលើតំបន់ដែលមានតម្លៃអភិរក្សខ្ពស់ រួមមាន៖

ក- តំបន់ការពារបេតិកភណ្ឌវប្បធម៌ ។

ខ- តំបន់នានានៃប្រព័ន្ធតំបន់ការពារថ្នាក់ជាតិ ។

គ- ប្រព័ន្ធអេកូឡូស៊ី ដែលបានកំណត់ថា កំពុងទទួលរងការវិនាស និងជម្រកសត្វព្រៃ ដែលស្ថិតនៅក្នុងបញ្ជី កំពុងរងគ្រោះថ្នាក់ ។

ឃ- តំបន់ព្រៃកោងកាង និងតំបន់ឆ្នេរ ។

ង- តំបន់ដែលផ្តល់ផ្តល់ជីវភាពរស់នៅដល់សហគមន៍មូលដ្ឋាន និងសហគមន៍ជនជាតិដើមភាគតិច ។

ច- ធនធាន ឬដីសហគមន៍ជនជាតិដើមភាគតិច ។

១០- ការរៀបចំដំណោះស្រាយ និងវិធានការអភិរក្ស និងលើកកម្ពស់តម្លៃធនធានធម្មជាតិ ឬបេតិកភ័ណ្ឌវប្បធម៌ ដែលស្ថិតនៅក្នុង ឬជាប់ទៅនឹងគ្រប់ដីដែលបានកំណត់ក្នុងផែនការគោលប្រើប្រាស់ដីដែលមានស្នើឡើង ។

១១- ការរៀបចំបម្រុងទុកផ្នែកខ្លះនៃដីដែលបានកំណត់ក្នុងផែនការគោលប្រើប្រាស់ដីដើម្បីបម្រុងទុកធ្វើជាលំហបៃតង ស្របតាមលិខិតបទដ្ឋានគតិយុត្តិស្តីពីមូលនិធិលំហបៃតងដែលបានបង្កើតឡើង ដូចមានចែងក្នុងមាត្រា៨៣១ មាត្រា៨៣២ នៃក្រមនេះ។

**មាត្រា២៣៦** ._ កិច្ចសហការរវាងក្រសួង ស្ថាប័នមានសមត្ថកិច្ច និងអ្នកពាក់ព័ន្ធ

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន ត្រូវផ្តល់ការគាំទ្រ និងសហការ ជាមួយក្រសួង ស្ថាប័នទទួលបន្ទុករៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ក្រសួង ស្ថាប័នមានសមត្ថកិច្ច សង្គមស៊ីវិល អង្គការមិនមែនរដ្ឋាភិបាល និងអ្នកពាក់ព័ន្ធក្នុងការអនុវត្ត និងពង្រឹងការអនុវត្តលក្ខខណ្ឌតម្រូវនៃផែនការ

ប្រើប្រាស់ដីដែលយកចិត្តទុកដាក់ដល់បរិស្ថាន។

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន ដោយសហការជាមួយរដ្ឋបាលថ្នាក់ក្រោមជាតិដែលពាក់ព័ន្ធត្រូវពិនិត្យផែនការប្រើប្រាស់ដីដែលយកចិត្តទុកដាក់ដល់បរិស្ថាន នៃផែនការគោលប្រើប្រាស់ដីទាំងអស់ ដែលបានដាក់ស្នើសុំការឯកភាពពីក្រសួង ស្ថាប័នមានសមត្ថកិច្ច។

**មាត្រា២៣៧** ._ សិទ្ធិទទួលបានព័ត៌មានអំពីផែនការប្រើប្រាស់ដីដែលយកចិត្តទុកដាក់ដល់បរិស្ថាន

គ្រប់ផែនការគោលប្រើប្រាស់ដី ផែនទីដីធ្លីចម្រុះ និងព័ត៌មានផែនការប្រើប្រាស់ដទៃទៀត ដែលបង្កើតឡើងជាផ្នែកមួយនៃដំណើរការផែនការប្រើប្រាស់ដី ត្រូវរក្សាទុកនៅឯក្រសួង ស្ថាប័នទទួលបន្ទុករៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន អាជ្ញាធរថ្នាក់ក្រោមជាតិដែលពាក់ព័ន្ធ ។ ព័ត៌មានទាំងនេះ ត្រូវដាក់ឱ្យសាធារណជនអាចស្វែងរកបាន។

**មាត្រា២៣៨** ._ ការកែសម្រួលផែនការគោលប្រើប្រាស់ដីដែលបានឯកភាព

រាល់ការកែសម្រួលផែនការគោលប្រើប្រាស់ដីដែលបានឯកភាព ត្រូវធ្វើឡើងស្របតាមលក្ខខណ្ឌតម្រូវនៃការរៀបចំផែនការប្រើប្រាស់ដីដែលយកចិត្តទុកដាក់ដល់បរិស្ថានបន្ថែម ។

ក្រសួង ស្ថាប័នមានសមត្ថកិច្ច ដែលធ្វើសំណើកែសម្រួលផែនការគោលប្រើប្រាស់ដី ត្រូវរៀបចំចងក្រងឯកសារដូចខាងក្រោម៖

១- ការបញ្ជាក់ពីហេតុផលផ្នែកសេដ្ឋកិច្ចសង្គម និងវិទ្យាសាស្ត្រសម្រាប់ការស្នើសុំកែសម្រួល ។

២- ការពន្យល់អំពីការខិតខំប្រឹងប្រែងដែលបានធ្វើដើម្បីរក្សាស្ថានភាពនៃការប្រើប្រាស់ដីបច្ចុប្បន្ន ។

៣- សេចក្តីពន្យល់អំពីផលប៉ះពាល់លើជីវភាពរស់នៅរបស់សហគមន៍មូលដ្ឋាន និងធុរកិច្ច ។

៤- ការផ្តល់ព័ត៌មានចាំបាច់ផ្សេងទៀតដែលបញ្ជាក់ពីហេតុផលត្រឹមត្រូវនៃការស្នើសុំកែសម្រួល ។

រាល់ការស្នើសុំឱ្យធ្វើការកែសម្រួលផែនការគោលប្រើប្រាស់ដីដែលបានទទួលការឯកភាព ត្រូវឱ្យមានការចូលរួមជាសាធារណៈ និងសិទ្ធិទទួលបានព័ត៌មានបរិស្ថាន ។

**មាត្រា២៣៩** ._ លក្ខខណ្ឌតម្រូវសម្រាប់ការវាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្រ

ក្រសួង ស្ថាប័នរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ មិនត្រូវផ្ដល់ការឯកភាពលើផែនការគោលប្រើប្រាស់ដីទាំងឡាយណាដែលមិនទាន់បានឆ្លងកាត់ការវាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្រ ស្របតាមបទប្បញ្ញត្តិស្ដីពីការវាយតម្លៃបរិស្ថានជាយុទ្ធាសាស្ត្រ ដូចមានចែងក្នុងគន្ថីទី២ នៃក្រមនេះ។

## ផ្នែកទី២
## លក្ខខណ្ឌតម្រូវឱ្យមានការរៀបចំផែនការប្រើប្រាស់ដីធ្លីដែលយកចិត្តទុកដាក់ដល់បរិស្ថាន

**មាត្រា២៤០**._ គម្រោងដែលស្នើសុំ

គ្រប់គម្រោងឯកជន ឬសាធារណៈដែលបានស្នើឡើង ត្រូវដាក់បញ្ចូល និងអនុវត្តតាមលក្ខខណ្ឌតម្រូវនៃការរៀបចំផែនការគោលប្រើប្រាស់ដីធ្លីដែលយកចិត្តទុកដាក់ដល់បរិស្ថាន។

**មាត្រា២៤១** ._ ការអនុលោមតាមលក្ខខណ្ឌតម្រូវ

គ្រប់លិខិតអនុញ្ញាត ឬការអនុញ្ញាត ដែលចេញដោយក្រសួង ស្ថាប័នមានសមត្ថកិច្ច ទៅលើគម្រោងស្នើសុំ ត្រូវស្របតាមលក្ខខណ្ឌតម្រូវនៃការរៀបចំផែនការប្រើប្រាស់ដីធ្លីដែលយកចិត្តទុកដាក់ដល់បរិស្ថាន។

**មាត្រា២៤២**._ លក្ខខណ្ឌតម្រូវទៅតាមគម្រោង

ក្រសួង ស្ថាប័នរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ត្រូវរៀបចំឱ្យមានលក្ខខណ្ឌតម្រូវនៃការរៀបចំផែនការប្រើប្រាស់ដីដែលយកចិត្តទុកដាក់ដល់បរិស្ថានសម្រាប់គ្រប់គម្រោងស្នើសុំដូចខាងក្រោម៖

១- គម្រោងស្នើសុំត្រូវស្របគ្នាជាមួយផែនការគោលប្រើប្រាស់ដី និងផែនការយុទ្ធសាស្ត្រទីក្រុងដោយចីរភាពដែលមានស្រាប់ និងផែនការដែលកំពុងត្រូវបានរៀបចំឡើង។

២- ការយល់ព្រមជាមុន ដោយសេរី និងបន្ទាប់ពីទទួលបានព័ត៌មានគ្រប់ជ្រុងជ្រោយដោយសហគមន៍ជនជាតិដើមភាគតិចលើគម្រោងស្នើសុំ ដែលអាចប៉ះពាល់ដោយផ្ទាល់ចំពោះដីធ្លី និងធនធានរបស់ជនជាតិដើមភាគតិច។ ការយល់ព្រមរបស់សហគមន៍ជនជាតិដើមភាគតិច ត្រូវធ្វើឡើងដោយមតិភាគច្រើនដាច់ខាតនៃជនជាតិដើមភាគតិច ដែលអាចទទួលរងផលប៉ះពាល់ពីគម្រោងស្នើសុំ ឬ ការធ្វើសេចក្ដីសម្រេចនេះ ។

៣- ការរៀបចំដំណោះស្រាយចំពោះបញ្ហាអព្យាក្រឹត្យកាបូន និងការបញ្ចេញកាកសំណល់ និងផែនការកាត់បន្ថយ និងទូទាត់ការបញ្ចេញកាបូន និងលំហូរកាកសំណល់ដែលពាក់ព័ន្ធទៅនឹងប្រតិបត្តិការគម្រោងទាំងអស់ ។

៤- គម្រោងស្នើសុំត្រូវអនុលោមតាមផែនការរួមសម្រាប់ទប់ស្កាត់គ្រោះទឹកជំនន់ ប្រព័ន្ធបង្ហូរសំណល់ទឹក នៃផែនការគោលប្រើប្រាស់ដី ដែលពាក់ព័ន្ធ ។

៥- ការរៀបចំវិធានការលើកម្ពស់ការគ្រប់គ្រងព្រៃឈើដោយចីរភាព ដែលស្ថិតនៅក្នុង ឬជាប់ទៅនឹងតំបន់ប្រតិបត្តិការគម្រោង ឬសកម្មភាពនានា ។

៦- គម្រោងស្នើសុំត្រូវអនុលោមតាមការរៀបចំផែនការ ឬប្រព័ន្ធចំណត ប្រព័ន្ធចរាចរណ៍ផ្លូវគោក ប្រព័ន្ធផ្លូវដឹកជញ្ជូននៃផែនការគោលប្រើប្រាស់ដី ។

៧- ការតម្រូវឱ្យមានកាតព្វកិច្ច និងការទទួលខុសត្រូវក្នុងដំណើរការអភិវឌ្ឍ និងប្រតិបត្តិការគម្រោងស្របតាមគោលការណ៍អ្នកបំពុលត្រូវទទួលខុសត្រូវលើតម្លៃនៃការបំពុល ។

៨- ការតម្រូវឱ្យគម្រោងឯកជនស្នើសុំខ្លះ រក្សាទុកមួយផ្នែកនៃតំបន់គម្រោងទាំងមូលជាលំហាបៃតង ស្របតាមលិខិតបទដ្ឋានគតិយុត្តស្ដីពីមូលនិធិលំហាបៃតង ដែលរៀបចំឡើងដូចមានចែងក្នុងមាត្រា៨៣១ មាត្រា៨៣២ នៃក្រមនេះ។

**មាត្រា២៤៣ .**_ លក្ខខណ្ឌតម្រូវឱ្យមានការឯកភាពទៅលើការវាយតម្លៃបរិស្ថាន

ក្រសួង ស្ថាប័នទទួលបន្ទុករៀបចំដែនដី នគរូបនីយកម្ម និងសំណង់ មិនត្រូវចេញលិខិតអនុញ្ញាត ឬការឯកភាពលើគម្រោងស្នើសុំណាមួយ ដែលមិនបានទទួល ឬមិនស្របតាមវិញ្ញាបនប័ត្រ ឬលិខិតឯកភាព ដូចមានចែងក្នុងបទបញ្ញត្តិស្ដីពីការវាយតម្លៃបរិស្ថាន គន្ថីទី២ នៃក្រមនេះឡើយ ។

## ជំពូកទី៣
## ទីក្រុងដោយចីរភាព

**មាត្រា២៤៤ .**_ ការរៀបចំផែនការយុទ្ធសាស្ត្រចីរភាពទីក្រុង

ក្រសួង ស្ថាប័នទទួលបន្ទុករៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ដោយសហការជាមួយនឹងក្រសួង ស្ថាប័នទទួលបន្ទុកអភិវឌ្ឍដោយចីរភាព ត្រូវរៀបចំ និងអនុវត្តផែនការយុទ្ធសាស្ត្រចីរភាពទីក្រុង ។

**មាត្រា២៤៥** ._ គណៈកម្មាធិការចីរភាពទីក្រុង

ក្រសួង ស្ថាប័នទទួលបន្ទុករៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ដោយសហការជាមួយក្រសួង ស្ថាប័នទទួលបន្ទុកអភិវឌ្ឍន៍ដោយចីរភាព ត្រូវរៀបចំគណៈកម្មាធិការចីរភាពទីក្រុងនិងលេខាធិការដ្ឋានសម្រាប់ទីប្រជុំជនរាជធានី ខេត្ត និងទីក្រុងផ្សេងទៀត ។

គណៈកម្មាធិការនីមួយៗត្រូវមានក្រុមការងារបច្ចេកទេសចម្បងចំនួន៤(បួន)មានដូចខាងក្រោម៖

១- ផ្នែករៀបចំផែនការទីក្រុង និងការដឹកជញ្ជូន ។

២- ផ្នែកថាមពល និងផលិតកម្ម ។

៣- ផ្នែកគ្រប់គ្រងសំណល់ និងភាពងាយរងគ្រោះនៃទីក្រុង ។

៤- ផ្នែកលំហសាធារណៈ បេតិកភណ្ឌវប្បធម៌ និងបរិស្ថានសំណង់ ។

សមាសភាព ភារកិច្ច ការទទួលខុសត្រូវ និងលក្ខខណ្ឌតម្រូវរបស់គណៈកម្មាធិការចីរភាពទីក្រុង និងក្រុមការងារបច្ចេកទេសចម្បង ត្រូវកំណត់ដោយលិខិតបទដ្ឋានគតិយុត្តរបស់ក្រសួង ស្ថាប័នទទួលបន្ទុករៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ។

**មាត្រា២៤៦** ._ ការរៀបចំផែនការយុទ្ធសាស្ត្រចីរភាពទីក្រុង

រាជធានី ខេត្ត និងទីក្រុង ផ្សេងទៀត ត្រូវរៀបចំផែនការយុទ្ធសាស្ត្រចីរភាពទីក្រុងលម្អិតដោយឡែកៗរបស់ខ្លួន ស្របតាមតាមស្ថានភាពភូមិសាស្ត្រ ប្រជាសាស្ត្រ និងស្ថានភាពជាក់ស្តែងនៃរាជធានី ខេត្ត ឬទីក្រុងនីមួយៗ ។

ក្រសួង ស្ថាប័នទទួលបន្ទុកអភិវឌ្ឍន៍ដោយចីរភាព ដោយសហការជាមួយក្រសួង ស្ថាប័នទទួលបន្ទុករៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ត្រូវរៀបចំលិខិតបទដ្ឋានគតិយុត្តស្តីពីដំណើរការនិងលក្ខខណ្ឌតម្រូវសម្រាប់ការរៀបចំផែនការយុទ្ធសាស្ត្រចីរភាពទីក្រុង សម្រាប់ប្រភេទនីមួយៗនៃទីក្រុង។

**មាត្រា២៤៧** ការរៀបចំផែនការយុទ្ធសាស្ត្រចីរភាពទីក្រុង និងការវាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្រ

ក្រសួង ស្ថាប័នទទួលបន្ទុករៀបចំដែនដី នគរូបនីយកម្ម និងសំណង់ មិនត្រូវចេញលិខិតឯកភាពលើផែនការយុទ្ធសាស្ត្រចីរភាពទីក្រុងណាមួយដែលមិនបានឆ្លងកាត់ការវាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្រ ដូចមានចែងក្នុងគន្ថីទី២ នៃក្រមនេះឡើយ។

**មាត្រា២៤៨** ការពិនិត្យ និងការកែសម្រួលផែនការយុទ្ធសាស្ត្រចីរភាពទីក្រុង

ការពិនិត្យ និងកែសម្រួលផែនការយុទ្ធសាស្ត្រចីរភាពទីក្រុង ត្រូវធ្វើឡើងយ៉ាងតិច ៥ (ប្រាំ) ឆ្នាំ អាស្រ័យតាមការផ្លាស់ប្តូរស្ថានភាពជាក់ស្តែង នៃការអភិវឌ្ឍសេដ្ឋកិច្ចសង្គម ។

## មាតិកាទី៥
## ថាមពលដោយចីរភាព
## ជំពូកទី១
## ថាមពលដោយចីរភាព

**មាត្រា២៤៩** ._ វិសាលភាព

មាតិកានេះ មានវិសាលភាពអនុវត្តទៅលើការផលិត ការបញ្ជូន និងការចែកចាយ និងការប្រើប្រាស់សេវាអគ្គិសនី។

**មាត្រា២៥០** ._ គោលការណ៍ចីរភាពថាមពល និងស្តង់ដារអន្តរជាតិ

ក្រសួង ស្ថាប័នទទួលបន្ទុកថាមពល ក្រសួង ស្ថាប័នមានសមត្ថកិច្ច និងនីតិបុគ្គលសាធារណៈដែលពាក់ព័ន្ធ ត្រូវអនុវត្តគោលការណ៍ថាមពលដោយចីរភាព និងស្តង់ដារអន្តរជាតិ នៅក្នុងសេចក្តីសម្រេចចិត្ត និងផ្តល់អាទិភាពលើគម្រោងដោយចីរភាពនៅកន្លែងដែលអាចធ្វើទៅបាន ដើម្បីបំពេញតាមតម្រូវការថាមពលបច្ចុប្បន្ន និងអនាគត។

ក្រសួង ស្ថាប័នមានសមត្ថកិច្ច ត្រូវតម្រូវឱ្យនីតិបុគ្គលឯកជនអនុវត្តគោលការណ៍ថាមពលដោយចីរភាពនៅក្នុងគម្រោងដែលខ្លួនបានស្នើសុំ។

**មាត្រា២៥១** ._ វិធីសាស្ត្រក្នុងការសម្រេចបាននូវថាមពលដោយចីរភាព

វិធីសាស្ត្រក្នុងការសម្រេចបានបាននូវចីរភាពថាមពល ត្រូវអនុវត្តដូចខាងក្រោម៖

១- គាំទ្រ និងលើកកម្ពស់គម្រោងចីរភាពថាមពល ។

២- ពិចារណាលើការប្រែប្រួលអាកាសធាតុជាតិនៅក្នុងវិស័យថាមពល ។

៣- អនុម័តយកនូវចីរភាពថាមពលស្អាតជាគោលដៅ ។

៤- ផ្តល់ការលើកទឹកចិត្តផ្នែកហិរញ្ញវត្ថុដើម្បីលើកកម្ពស់គម្រោងចីរភាពថាមពល ។

៥- លើកកម្ពស់បច្ចេកវិទ្យាមេត្រីបរិស្ថានទំនើប ។

៦- គាំទ្រវិមជ្ឈការប្រភពថាមពល និងប្រព័ន្ធបណ្ដាញអគ្គិសនីខ្នាតតូច និងតូចជាង ។

៧- លើកកម្ពស់ប្រព័ន្ធថាមពលពន្លឺព្រះអាទិត្យតាមផ្ទះ និងប្រព័ន្ធផលិត និងស្តុកថាមពលតាមផ្ទះ ។

**មាត្រា២៥២** ._ ការគ្រប់គ្រងអគ្គិសនីដែលសល់ពីការប្រើប្រាស់ទៅក្នុងបណ្តាញតចូល

អាជ្ញាធរទទួលបន្ទុកផលិត ចែកចាយ និងគ្រប់គ្រងការប្រើប្រាស់អគ្គិសនី ត្រូវរៀបចំលិខិតបទដ្ឋានគតិយុត្ត សម្រាប់គ្រប់គ្រង ការតភ្ជាប់អគ្គិសនីចូលទៅក្នុងបណ្តាញតចូលដើម្បីធានាបាននូវសុវត្ថិភាពក្នុងរយៈពេល ១ (មួយ) ឆ្នាំ បន្ទាប់ពីក្រមនេះចូលជាធរមាន។

**មាត្រា២៥៣** ._ សិទ្ធិតភ្ជាប់ទៅនឹងបណ្តាញតចូល និងការលក់អគ្គិសនីដែលសល់ពីការប្រើប្រាស់

អ្នកផលិតថាមពលអគ្គិសនីដោយចីរភាព រួមមាន គ្រួសារ រូបវន្តបុគ្គល ក្រុមហ៊ុន សហគមន៍ និងប្រតិបត្តិករនៃបណ្តាញតចូលតូច និងតូចជាង មានសិទ្ធិតភ្ជាប់ទៅនឹងបណ្តាញតចូល និងចុះកិច្ចព្រមព្រៀងជាមួយអ្នកផ្គត់ផ្គង់ចរន្តអគ្គិសនី ដើម្បីលក់អគ្គិសនីដែលសល់ពីការប្រើប្រាស់ ស្របតាមបទប្បញ្ញត្តិនៃក្រមនេះ ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធដទៃទៀត ។

**មាត្រា២៥៤** ._ តំបន់ហាមឃាត់មិនឱ្យមានគម្រោងថាមពល

ការតម្លើងសម្ភារៈបរិក្ខារ សម្រាប់ផលិតអគ្គីសនី ការបញ្ជូនអគ្គីសនី ឬការចែកចាយអគ្គីសនី ត្រូវហាមឃាត់មិនឱ្យមាននៅក្នុងតំបន់ដែលមានតម្លៃអភិរក្សខ្ពស់ដូចខាងក្រោម៖

១- ដីសាធារណៈរបស់រដ្ឋដែលកំណត់ជាតំបន់ការពារបេតិកភណ្ឌវប្បធម៌ និងប្រវត្តិសាស្ត្រ ។

២- តំបន់ស្នូល និងតំបន់អភិរក្សនៃសមាសភាគប្រព័ន្ធតំបន់ការពារធម្មជាតិនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ។

៣- តំបន់ដីសើម តំបន់បេតិកភណ្ឌធម្មជាតិ និងឋបនីយ៍ជីវមណ្ឌល និង

៤- ដែនដី ឬធនធានរបស់ជនជាតិដើមភាគតិច លើកលែងតែមានការយល់ព្រមជាមុនដោយសេរី និងបន្ទាប់ពីទទួលបានព័ត៌មានគ្រប់ជ្រុងជ្រោយពីជនជាតិដើមភាគតិចដែលទទួលរងផលប៉ះពាល់ ដែលបានដាក់បញ្ចូលជាតំបន់អង្គការសហប្រជាជាតិទទួលបន្ទុកអប់រំ វិទ្យាសាស្ត្រ និងវប្បធម៌។

៥- តំបន់ដែលប្រព័ន្ធអេកុឡូស៊ីដែលបានចុះបញ្ជីងាយរងគ្រោះថ្នាក់ ឬកំពុងវិនាស ឬជាជម្រកប្រភេទសត្វ ដូចបានកំនត់ក្នុងចំណាត់ថ្នាក់ក្រុមទី១ និងក្រុមទី២ នៃក្រមនេះ

៦- តំបន់ដែលបានចុះបញ្ជីនៅក្នុងលិខិតបទដ្ឋានកតិយុត្ត ជាតំបន់ដែលមាន៖

- ប្រព័ន្ធអេកូឡូស៊ីទឹកសាប សមុទ្រ ឬតំបន់ឆ្នេរសំខាន់ៗ
- តម្លៃអភិរក្សទេសភាពខ្ពស់ ជីវៈចម្រុះ សម្រាប់សត្វ និងរុក្ខជាតិ ឬតម្លៃអភិរក្សប្រព័ន្ធអេកូឡូស៊ី។

លើកលែងតែការហាមឃាត់ក្នុងចំណុចទី២ និងទី៤ខាងលើ ក្រសួង ស្ថាប័នទទួលបន្ទុកគ្រប់គ្រងតំបន់ទាំងនេះ អាចផ្តល់ការលើកលែងចំពោះការហាមឃាត់ សម្រាប់ហេដ្ឋារចនាសម្ព័ន្ធ ដែលតម្រូវឱ្យមាន ដើម្បីបញ្ជូនចរន្តអគ្គិសនីពីបណ្តាញតចូលទៅសហគមន៍មូលដ្ឋាន និងសម្រាប់គម្រោងអគ្គិសនីខ្នាតតូចដែលមិនមានផលប៉ះពាល់បរិស្ថានធ្ងន់ធ្ងរ ។

## ជំពូកទី២
## ការរៀបចំផែនការចីរភាពថាមពល

**មាត្រា២៥៥** ._ ផែនការចីរភាពថាមពេល និងអគ្គិសនីថ្នាក់ជាតិ

ក្រសួង ស្ថាប័នទទួលបន្ទុកថាមពល ដោយសហការជាមួយក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងក្រសួង ស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធ និងដោយមានការពិគ្រោះយោបល់ជាមួយអ្នកពាក់ព័ន្ធមិនមែនរាជរដ្ឋាភិបាល និងសហគមន៍ ដែលទទួលរងផលប៉ះពាល់ពីការបង្កើតគម្រោងអគ្គិសនី និងថាមពល ត្រូវរៀបចំផែនការអគ្គិសនី និងចីរភាពថាមពលជាតិ។

**មាត្រា២៥៦** ._ ការវាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្រ

ក្រសួង ស្ថាប័នទទួលបន្ទុកថាមពល ដោយសហការជាមួយក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន ត្រូវរៀបចំការវាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្រសម្រាប់ការរៀបចំផែនការអគ្គិសនី និងចីរភាពថាមពលជាតិ។

ការវាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្រ ត្រូវរៀបចំឡើងដោយកំណត់អំពីក្របខ័ណ្ឌសម្រាប់ម្ចាស់គម្រោងដាក់បញ្ចូលនូវវិធានការនានាក្នុងគ្រប់ដំណាក់កាលនៃការអភិវឌ្ឍគម្រោងដើម្បីបញ្ចៀស និងកាត់បន្ថយការប៉ះពាល់ដល់តំបន់ដែលមានតម្លៃអភិរក្សខ្ពស់ដូចខាងក្រោម៖

១- តំបន់ការពារបេតិកភណ្ឌវប្បធម៌ ។

២-តំបន់នានានៃប្រព័ន្ធតំបន់ការពារថ្នាក់ជាតិ ។

៣- ប្រព័ន្ធអេកូឡូស៊ី ដែលបានកំណត់ថា កំពុងទទួលរងការវិនាស និងជម្រកសត្វព្រៃ ដែលស្ថិតនៅក្នុងបញ្ជី កំពុងរងគ្រោះថ្នាក់ ។

៤- តំបន់ព្រៃកោងកាង និងតំបន់ឆ្នេរ ។

៥- តំបន់ដែលផ្តល់ជីវភាពរស់នៅដល់សហគមន៍មូលដ្ឋាន និងជនជាតិដើមភាគតិច ។

**មាត្រា២៥៧** ._ សមាសភាគនៃផែនការ

ផែនការអគ្គិសនី និងចីរភាពថាមពលជាតិ ត្រូវប្រើប្រាស់ជាមូលដ្ឋានសម្រាប់ការធ្វើសេចក្តីសម្រេច និងការណែនាំសម្រាប់សកម្មភាពរដ្ឋបាលនានា។ ផែនការនេះ មានសមាសភាគដូចខាងក្រោម ៖

១- ការរៀបចំគោលនយោបាយចីរភាពថាមពលដើម្បីបង្កើនចំនួន និងមានសមាមាត្ររវាងថាមពលដោយចីរភាពដែលផលិតបាន និងការប្រើប្រាស់។

២- ការវាយតម្លៃស្ថានភាពបច្ចុប្បន្ននៃការបញ្ជូន និងការផលិតអគ្គិសនី និងថាមពល ។

៣- សេចក្តីពិពណ៌នាអំពីគម្រោងដែលត្រូវបង្កើតឡើងសម្រាប់ផ្គត់ផ្គង់ប្រភពថាមពលផលិត និងការបញ្ជូនអគ្គិសនី ។

៤- គោលដៅជាក់លាក់សម្រាប់ការផលិតថាមពលដោយចីរភាព និងប្រសិទ្ធផលថាមពល ។

៥- ការពិនិត្យសំណល់ដែលបង្កើតដោយគម្រោងថាមពលដោយចីរភាព និងផែនការកែច្នៃឡើងវិញ ឬគ្រប់គ្រងសំណល់ដែលបង្កើតឡើងដោយការអភិវឌ្ឍថាមពលដោយចីរភាព ។

៦- ការរៀបចំផែនការប្រើប្រាស់ធនធានចម្រុះ ដោយផ្អែកលើការវាយតម្លៃផលចំណេញ និងខាតផ្នែកសេដ្ឋកិច្ច នៃធនធាននីមួយៗ ។

**មាត្រា២៥៨** ._ ការអនុលោមតាមផែនការ និងការរៀបចំរបាយការណ៍

ក្រសួង ស្ថាប័នទទួលបន្ទុកថាមពល ត្រូវអនុវត្តតាមតាមផែនការអគ្គិសនី និងចីរភាពថាមពលជាតិ។

ក្រសួង ស្ថាប័នទទួលបន្ទុកថាមពល ត្រូវផ្សព្វផ្សាយរបាយការណ៍ប្រចាំឆ្នាំស្តីពីការរៀបចំ និងការអនុវត្តផែនការអគ្គិសនី និងចីរភាពថាមពលជាតិ ។

## ជំពូកទី៣
## ការលើកកម្ពស់បច្ចេកវិទ្យាមេត្រីបរិស្ថាន

**មាត្រា២៥៩** ._ បច្ចេកវិទ្យាដែលមានការបញ្ចេញឧស្ម័នទាប សំណល់តិច និងដែលមានប្រសិទ្ធផល

ក្រសួង ស្ថាប័នទទួលបន្ទុកថាមពល ដោយសហការជាមួយក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន ត្រូវរៀបចំលិខិតបទដ្ឋានគតិយុត្តស្តីពីស្តង់ដារសម្រាប់បច្ចេកវិទ្យាដែលមានការបញ្ចេញឧស្ម័នទាប សំណល់តិច និងដែលមានប្រសិទ្ធផល ដែលត្រូវប្រើប្រាស់ក្នុងការផលិត ការបញ្ជូន និងការចែកចាយអគ្គិសនី ។

អជ្ញាធរទទួលបន្ទុកគ្រប់គ្រងការផលិត ការចែកចាយ និងការប្រើប្រាស់សេវាអគ្គិសនី ត្រូវត្រួតពិនិត្យការអនុលោមតាមការប្រើប្រាស់បច្ចេកវិទ្យាតាមស្តង់ដារដូចមានចែងខាងលើទៅលើគ្រប់គម្រោងដែលពាក់ព័ន្ធ លើកលែងតែមានការអនុញ្ញាតជាពិសេសឱ្យរួចផុតពីការត្រួតពិនិត្យខាងលើនេះ ដែលត្រូវកំណត់ដោយក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងក្រសួង ស្ថាប័នទទួលបន្ទុកថាមពល ។

**មាត្រា២៦០** ._ វិមជ្ឈការអគ្គិសនី

ក្រសួង ស្ថាប័នទទួលបន្ទុកថាមពល និងអាជ្ញាធរទទួលបន្ទុកផលិត ចែកចាយ និងគ្រប់គ្រងការប្រើប្រាស់អគ្គិសនី ត្រូវលើកកម្ពស់ការផ្គត់ផ្គង់អគ្គិសនីដែលមានប្រភពពីបណ្តាញតចូលជាតិ និងពីប្រភពវិមជ្ឈការ។ អ្នកប្រើប្រាស់អគ្គិសនី មានសិទ្ធិជ្រើសរើសប្រើប្រាស់អគ្គិសនីពីប្រភពផលិតអគ្គិសនីណាមួយ។

**មាត្រា២៦១** ._ ការលើកកម្ពស់ការផ្គត់ផ្គង់បណ្តាញតចូលខ្នាតតូច និងខ្នាតតូចជាង

ក្រសួង ស្ថាប័នមានសមត្ថកិច្ច ត្រូវគាំទ្រ ការផ្គត់ផ្គង់បណ្តាញតចូលខ្នាតតូច និងខ្នាតតូចជាង។ ប្រតិបត្តិករបណ្តាញតចូលតូចជាង មានជម្រើសដូចខាងក្រោម៖

១- ផ្គត់ផ្គង់ដល់អ្នកប្រើប្រាស់ ក្នុងពេលស្របគ្នាទៅនឹងការផ្គត់ផ្គង់របស់បណ្តាញតចូលជាតិ ។

២- ចុះកិច្ចព្រមព្រៀងជាមួយអ្នកផ្គត់ផ្គង់ដើម្បីលក់អគ្គិសនីដែលសល់ពីការប្រើប្រាស់ ។

**មាត្រា២៦២** ._ កម្រិតស្តង់ដារដែលត្រូវទទួលបានលិខិតអនុញ្ញាត

អាជ្ញាធរទទួលបន្ទុកផលិត ចែកចាយ និងគ្រប់គ្រងការប្រើប្រាស់អគ្គិសនី និងក្រសួង ស្ថាប័នមានសមត្ថកិច្ច មិនត្រូវកំណត់ព្រំដែននៃលក្ខខណ្ឌតម្រូវ ដើម្បីទទួលបានលិខិតអនុញ្ញាត ឬការយល់ព្រមមិនសមស្របដូចខាងក្រោម៖

១- មិនត្រូវកំណត់ព្រំដែន ធុរកិច្ច និងសហគមន៍ អ្នកអភិវឌ្ឍដទៃទៀត ដែលមានកិច្ចព្រមព្រៀងជាមួយសហគមន៍ រូបវន្តបុគ្គល ឬនីតិបុគ្គល ពីការអភិវឌ្ឍគម្រោងថាមពលដោយចីរភាព ក្នុងករណីដែលគម្រោងទាំងនេះ បានបង្កើតឡើង និងមានប្រតិបត្តិការស្របតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តដែលពាក់ព័ន្ធ ។

២- មិនត្រូវកំណត់ព្រំដែន នីតិបុគ្គលឯកជនក្នុងការទទួលបាននូវចំនួននៃលិខិតអនុញ្ញាតពីអាជ្ញាធរទទួលបន្ទុកផលិត ចែកចាយ និងគ្រប់គ្រងការប្រើប្រាស់អគ្គិសនី សម្រាប់គម្រោងខ្នាតតូចដែលមានសមត្ថភាពក្រោម ៥ (ប្រាំ) មេហ្គាវ៉ាត់ ។

**មាត្រា២៦៣** ._ ការពង្រីកបណ្តាញតចូល

រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា អាចបញ្ឈប់រាល់ការពង្រីកបណ្តាញតចូលទៅកាន់តំបន់ជាក់លាក់ណាមួយក្នុងប្រទេស ដោយផ្អែកលើកត្តាបរិស្ថាន សេដ្ឋកិច្ច និងសង្គម ។ ក្នុងករណីនេះ រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ត្រូវលើកកម្ពស់ និងអនុវត្តកម្មវិធីនានា ដើម្បីផ្តល់នូវដំណោះស្រាយវិមជ្ឈការ ដល់ក្រុមគ្រួសារទាំងឡាយ ដើម្បីផលិតថាមពល និងការផលិតអគ្គិសនីសម្រាប់តម្រូវការរបស់អ្នកប្រើប្រាស់ចុងក្រោយ។

**មាត្រា២៦៤** ._ ប្រព័ន្ធស្តង់ដារគ្រប់គ្រងថាមពល និងអគ្គិសនី

ក្រសួង ស្ថាប័នទទួលបន្ទុកថាមពល និងក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និង ក្រសួង ស្ថាប័នទទួលបន្ទុកឧស្សាហកម្ម ត្រូវរៀបចំលិខិតបទដ្ឋានគតិយុត្តស្តីពីស្តង់ដារប្រតិបត្តិ សម្រាប់ប្រព័ន្ធគ្រប់គ្រងថាមពល និងអគ្គិសនី ដោយផ្អែកលើស្តង់ដារ នៃគណៈកម្មការបច្ចេកទេសអេឡិចត្រូនិកអន្តរជាតិ និងអង្គការស្តង់ដារអន្តរជាតិ ៥០០០១ ក្នុងរយៈពេល ១ (មួយ) ឆ្នាំ បន្ទាប់ពីក្រមនេះចូលជាធរមាន ។

លិខិតបទដ្ឋានគតិយុត្តនេះ ត្រូវរួមបញ្ចូលនីតិវិធី និងលក្ខខណ្ឌតម្រូវ សម្រាប់អនុលោមតាមប្រព័ន្ធស្តង់ដារគ្រប់គ្រងអគ្គិសនី និងថាមពល។

**មាត្រា២៦៥** ._ ការហាមឃាត់លើឯកសិទ្ធិ

រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា មិនត្រូវឱ្យមាននីតិបុគ្គលឯកជនណាមានឯកសិទ្ធិលើសពីអ្នកដទៃឡើយ រួមបញ្ចូលទាំង ក្នុងការផ្ដល់លិខិតអនុញ្ញាត ឬការយល់ព្រមទាំងអស់ និងក្នុងការចរចាអំពីលក្ខខណ្ឌនៃកិច្ចសន្យា ដែលត្រូវទទួលបានការយល់ព្រមពីក្រសួង ស្ថាប័នមានសមត្ថកិច្ច ។

សេចក្ដីសម្រេចផ្ដល់លិខិតអនុញ្ញាត និងយល់ព្រម និងការបង្កើតលក្ខខណ្ឌពាក់ព័ន្ធសម្រាប់កិច្ចសន្យា ត្រូវធ្វើឡើងដោយផ្អែកលើភសត្ថុតាងផ្នែកសេដ្ឋកិច្ច និងបច្ចេកទេស ដូចត្រូវបានទទួលយកនៅក្រោមកាទម្លាប់រអនុវត្តដ៏ប្រសើរជាអន្តរជាតិ ។

នៅពេលជ្រើសរើសនីតិបុគ្គលឯកជនដើម្បីអភិវឌ្ឍថាមពល ឬ ផលិតអគ្គិសនី ឬគម្រោងចែកចាយអគ្គិសនីដែលពាក់ព័ន្ធ នៅក្នុងព្រះរាជាណាចក្រកម្ពុជា រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាត្រូវរៀបចំជ្រើសរើសតាមដំណើរការលទ្ធកម្ម ដែលមានលក្ខណៈប្រកួតប្រជែង និងតម្លាភាព។

## ជំពូកទី៤
## ការត្រួតពិនិត្យគុណភាពឧបករណ៍ផលិតថាមពលដោយនិរន្តរភាព

**មាត្រា២៦៦** ._ ស្តង់ដារគុណភាពឧបករណ៍ផលិតថាមពលដោយចីរភាព

ក្រសួង ស្ថាប័នទទួលបន្ទុកឧស្សាហកម្ម ដោយសហការជាមួយក្រសួង ស្ថាប័នទទួលបន្ទុកថាមពល និងក្រសួង ស្ថាប័ន មានសមត្ថកិច្ច ត្រូវរៀបចំលិខិតបទដ្ឋានគតិយុត្តស្ដីពីស្តង់ដារគុណភាព បរិស្ថាន សុវត្ថិភាព និងសុខភាព សម្រាប់ឧបករណ៍ផលិតថាមពលដោយចីរភាព ដែលត្រូវផ្គត់ផ្គង់ និងប្រើប្រាស់នៅលើទីផ្សារ ក្នុងរយៈពេល ១ (មួយ) ឆ្នាំ បន្ទាប់ពីក្រមនេះចូលជាធរមាន ។

**មាត្រា២៦៧** ._ ការបញ្ជាក់ និងការត្រួតពិនិត្យគុណភាព

អាជ្ញាធរទទួលបន្ទុកគ្រប់គ្រងការផលិត ការចែកចាយ និងការប្រើប្រាស់សេវាអគ្គិសនី មិនត្រូវចេញលិខិតអនុញ្ញាត ឬការយល់ព្រមលើគម្រោងឧបករណ៍ចីរភាពថាមពលដែលប្រើប្រាស់ឧបករណ៍ផលិត មិនស្របតាមស្តង់ដារគុណភាព បរិស្ថាន សុវត្ថិភាព និងសុខភាព ដូចមានចែងក្នុងលិខិតបទដ្ឋានគតិយុត្ត។

អាជ្ញាធរទទួលបន្ទុកត្រួតពិនិត្យការនាំចូលឧបករណ៍ផលិត ត្រូវត្រួតពិនិត្យឧបករណ៍ផលិតថាមពលដោយចីរភាព ដែលនាំចូលមកក្នុងព្រះរាជាណាចក្រកម្ពុជា ឱ្យស្របតាមស្តង់ដារដែលបានកំណត់ខាងលើ ។

## ជំពូកទី៥
## ការលើកទឹកចិត្តការប្រើប្រាស់ថាមពលពន្លឺព្រះអាទិត្យ

**មាត្រា២៦៨** _ វង្វាស់ថាមពល

អាជ្ញាធរទទួលបន្ទុកនិយ័តកម្មសម្រាប់ការផលិត ការចែកចាយ និងការប្រើប្រាស់សេវាអគ្គិសនី ត្រូវរៀបចំលិខិតបទដ្ឋានគតិយុត្តស្ដីពីវង្វាស់ថាមពល សម្រាប់ប្រព័ន្ធថាមពលពន្លឺព្រះអាទិត្យ តាមផ្ទះ ដែលបានតភ្ជាប់ទៅនឹងបណ្ដាញតចូល និងស្ដីពីអត្រាថ្លៃលក់អគ្គិសនីនេះ ទៅនីតិបុគ្គលសាធារណៈ ដែលទទួលបន្ទុកក្នុងការផលិត ចែកចាយ និងការគ្រប់គ្រងការប្រើប្រាស់សេវាកម្មអគ្គិសនី ឬអ្នកផ្គត់ផ្គង់សេវាអគ្គិសនីផ្សេងទៀត ។ ម្ចាស់ ឬកម្មសិទ្ធិករនៃប្រព័ន្ធពន្លឺព្រះអាទិត្យតាមផ្ទះ មានសិទ្ធិទទួលការបង់ថ្លៃប្រើប្រាស់អគ្គិសនី ដែលបានតភ្ជាប់ទៅបណ្ដាញតចូលខាងលើនេះ និងមានកាតព្វកិច្ចបង់ថ្លៃប្រើប្រាស់សេវាវង្វាស់ថាមពលខាងលើនេះ ។

លិខិតបទដ្ឋានគតិយុត្តខាងលើនេះ ត្រូវរៀបចំឡើងក្នុងរយៈពេល ១ (មួយ) ឆ្នាំ បន្ទាប់ពីក្រមនេះ ចូលជាធរមាន។

**មាត្រា២៦៩** ._ ប្រព័ន្ធអនុគ្រោះពន្ធចំពោះគម្រោងសាកល្បងប្រើប្រាស់ថាមពលដោយចីរភាព

ក្រសួង ស្ថាប័នទទួលបន្ទុកថាមពល ដោយសហការជាមួយអាជ្ញាធរទទួលបន្ទុកនិយ័តកម្មសម្រាប់ការផលិត ការចែកចាយ និងការប្រើប្រាស់សេវាអគ្គិសនី ត្រូវរៀបចំលិខិតបទដ្ឋានគតិយុត្តស្ដីអំពីប្រព័ន្ធអនុគ្រោះពន្ធចំពោះគម្រោងសាកល្បងប្រើប្រាស់ថាមពលដោយចីរភាព ដោយត្រូវកំណត់អាត្រាថេរ សម្រាប់ទិញអគ្គិសនីដែលផលិតបានពីទីតាំងផលិតថាមពលពន្លឺព្រះអាទិត្យ ឬពីប្រភពផលិតថាមពលដោយចីរភាព ក្នុងរយៈពេល ១ (មួយ) ឆ្នាំបន្ទាប់ពីក្រមនេះចូលជាធរមាន ។

## ជំពូកទី៦
## ប្រភពថាមពលផ្សេងទៀត

**មាត្រា២៧០** ._ ការគ្រប់គ្រងថាមពលនុយក្លេអ៊ែរ

ថាមពលនុយក្លេអ៊ែរ ត្រូវបង្កើតឡើងដោយស្ថិតនៅក្រោមការគ្រប់គ្រង និងកម្មសិទ្ធិផ្ដាច់មុខ

របស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងដោយមានការសហការពីស្ថាប័នអន្តរជាតិ និងអនុវត្តតាមស្តង់ដារគាំពារផ្នែកបរិស្ថាន សុខភាព និងសុវត្ថិភាព ។

រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ត្រូវរៀបចំលិខិតបទដ្ឋានគតិយុត្តស្តីពីថាមពលនុយក្លេអ៊ែរ និងសុវត្ថិភាព ។ លិខិតបទដ្ឋានគតិយុត្ត ត្រូវរួមមានលក្ខខណ្ឌតម្រូវសម្រាប់រចនាសម្ព័ន្ធ និងការរៀបចំរបស់ក្រសួង ស្ថាប័នមានសមត្ថកិច្ចសម្រាប់ធ្វើការត្រួតពិនិត្យគម្រោងផលិតថាមពលនុយក្លេអ៊ែរ ។

**មាត្រា២៧១** ._ ការបណ្តុះបណ្តាលស្តីពីថាមពលនុយក្លេអ៊ែរ

ក្រសួង ស្ថាប័នទទួលបន្ទុកថាមពល អាចរៀបចំកម្មវិធីបណ្តុះបណ្តាលបុគ្គលិក និងមន្ត្រីក្រោមឱវាទ ដែលធ្វើការលើថាមពលនុយក្លេអ៊ែរ ដោយសហការជាមួយទីភ្នាក់ងារថាមពលអាតូមិចអន្តរជាតិ ។

## មាតិកាទី៦
## ឧស្សាហកម្មនិស្សារណកម្ម
## ជំពូកទី១
## ការរៀបចំផែនការបរិស្ថានសម្រាប់ឧស្សាហកម្មនិស្សារណកម្ម

**មាត្រា២៧២** ._ វិសាលភាព

មាតិកានេះមានវិសាលភាពអនុវត្តលើសកម្មភាពនៃការរុករក និងការទាញយកធនធានប្រេងឥន្ធនៈ ឧស្ម័ន រ៉ែ លោហៈ វត្ថុធាតុភូគព្ភវិទ្យានានា និងធនធានដទៃទៀត នៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា២៧៣** ._ កាតព្វកិច្ចក្នុងការវាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្រ

ក្រសួង ស្ថាប័នទទួលបន្ទុករ៉ែ ត្រូវធ្វើការវាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្រ សម្រាប់សកម្មភាពរុករក និងការទាញយកធនធានឧស្សាហកម្មនិស្សារណកម្មជាក់លាក់ណាមួយ នៅក្នុងព្រះរាជាណាចក្រកម្ពុជា ស្របតាមបទប្បញ្ញត្តិស្តីពីការវាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្រ នៃក្រមនេះ ។

ការវាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្រ ត្រូវកំណត់ផ្តល់នូវក្របខ័ណ្ឌឱ្យម្ចាស់គម្រោងដាក់បញ្ចូលទៅក្នុងគ្រប់ដំណាក់កាលទាំងអស់នៃការរៀបចំគម្រោង វិធានការបញ្ចៀស និងកាត់បន្ថយការគំរាមកំហែងចំពោះតំបន់ដែលមានតម្លៃអភិរក្សខ្ពស់ ដែលរួមមាន ដូចខាងក្រោម៖

១- តំបន់ការពារបេតិកភណ្ឌវប្បធម៌

២- សមាសភាគនៃប្រព័ន្ធតំបន់ការពារធម្មជាតិនៅថ្នាក់ជាតិ

៣- ប្រព័ន្ធអេកូឡូស៊ីដែលបានកំណត់ថាកំពុងទទួលរងការវិនាស និងជម្រកសត្វព្រៃដែលស្ថិតនៅក្នុងបញ្ជីកំពុងរងគ្រោះថ្នាក់ ដូចមានចែងក្នុងគន្លឹះទី៤នៃក្រមនេះ ។

៤- ព្រៃកោងកាង និងតំបន់ឆ្នេរ ។

៥- តំបន់ដែលគាំទ្រដល់ការចិញ្ចឹមជីវិតរបស់សហគមន៍មូលដ្ឋាន និងជនជាតិដើមភាគតិច ។

៦- ដីធ្លី ឬធនធាននានារបស់ជនជាតិដើមភាគតិច ។

**មាត្រា២៧៤ .**_ការរុករក និងការទាញយកធនធានឧស្សាហកម្មនិស្សារណៈកម្មដែលនៅជាធរមាន

ក្នុងករណីដែលមានការអនុញ្ញាតឱ្យមានសកម្មភាពរុករក និងទាញយកធនធានឧស្សាហកម្មនិស្សារណកម្មជាក់លាក់ណាមួយមុនពេលក្រមនេះចូលជាធរមាន ហើយសកម្មភាពនោះបន្តសុពលភាពយ៉ាងហោចណាស់រយៈពេល២ឆ្នាំក្រោយពេលក្រមនេះចូលជាធរមាន ក្រសួង ស្ថាប័នទទួលបន្ទុករ៉ែ ត្រូវ៖

១- រៀបចំឱ្យបានចប់សព្វគ្រប់នូវការវាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្រ សម្រាប់ធនធានឧស្សាហកម្មនិស្សារណកម្មនោះ និង

២- ដាក់ការវាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្រនេះឱ្យសាធារណជនអាចស្វែងរកបាន ។

**មាត្រា២៧៥ .**_ ការរុករក និងការទាញយកធនធានឧស្សាហកម្មនិស្សារណកម្មថ្មី

ក្នុងករណីដែលមិនមានការអនុញ្ញាតឱ្យមានសកម្មភាពរុករក និងទាញយកធនធានឧស្សាហកម្មនិស្សារណកម្មជាក់លាក់ណាមួយមុនពេលក្រមនេះចូលជាធរមានទេ ក្រសួង ស្ថាប័នទទួលបន្ទុករ៉ែ មុននឹងចេញលិខិតអនុញ្ញាតលើសកម្មភាពរុករក និងទាញយកធនធានឧស្សាហកម្មនិស្សារណកម្មនោះ ត្រូវ៖

១- រៀបចំឱ្យបានចប់សព្វគ្រប់នូវការវាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្រ សម្រាប់ធនធានឧស្សាហកម្មនិស្សារណកម្មនោះ និង

២- ដាក់ការវាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្រនេះឱ្យសាធារណជនអាចស្វែងរកបាន ។

**មាត្រា២៧៦** ._ ការធ្វើអាជីវកម្មរ៉ែខ្នាតតូច និងលក្ខណៈសិប្បកម្ម

ក្រសួង ស្ថាប័នទទួលបន្ទុករ៉ែ ត្រូវរៀបចំលិខិតបទដ្ឋានគតិយុត្តស្តីពីការធ្វើអាជីវកម្មរ៉ែខ្នាតតូច និងលក្ខណៈសិប្បកម្ម ដើម្បីៈ

១- ផ្តល់សិទ្ធិក្នុងការធ្វើអាជីវកម្មរ៉ែខ្នាតតូច និងលក្ខណៈសិប្បកម្ម ។

២- តម្រូវឱ្យរាល់សកម្មភាពនៃការធ្វើអាជីវកម្មរ៉ែខ្នាតតូច និងលក្ខណៈសិប្បកម្ម ធ្វើឡើងដោយមានសុវត្ថិភាព ប្រសិទ្ធផល និងចីរភាពបរិស្ថាន ។

៣- លើកកម្ពស់ និងអនុវត្តតាមស្តង់ដារ និងទម្លាប់នៃការអនុវត្តល្អជាអន្តរជាតិ ក្នុងការគ្រប់គ្រងការធ្វើអាជីវកម្មរ៉ែខ្នាតតូច ឬលក្ខណៈសិប្បកម្ម ។

៤- រៀបចំដំណើរការសម្រាប់ការកំណត់តំបន់សម្រាប់ការធ្វើអាជីវកម្មរ៉ែលក្ខណៈសិប្បកម្ម ដោយពិគ្រោះយោបល់ជាមួយសហគមន៍មូលដ្ឋាន និងអ្នកពាក់ព័ន្ធដទៃទៀត និង

៥- តម្រូវ និងផ្តល់ជំនួយដល់អ្នកធ្វើអាជីវកម្មរ៉ែលក្ខណៈសិប្បកម្ម ដើម្បីរៀបចំ និងអនុវត្ត ផែនការសន្តិសុខ និងសុវត្ថិភាព ។

**មាត្រា២៧៧** ._ តំបន់ហាមឃាត់ចំពោះគម្រោងឧស្សាហកម្មនិស្សារណកម្ម

ត្រូវហាមឃាត់ចំពោះគម្រោងឧស្សាហកម្មនិស្សារណកម្មទាំងឡាយណា ដែលស្ថិតនៅក្នុងៈ

១- ដីសាធារណៈរបស់រដ្ឋដែលកំណត់ជាតំបន់ការពារបេតិកភណ្ឌវប្បធម៌ និងប្រវត្តិសាស្ត្រ ។

២- តំបន់ស្នូល និងតំបន់អភិរក្សនៃសមាសភាគនៃប្រព័ន្ធតំបន់ការពារធម្មជាតិនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ។

៣- តំបន់ដីសើម តំបន់បេតិកភណ្ឌធម្មជាតិ និងឋបនីយ៍ជីវមណ្ឌល និង

៤- ដែនដី ឬធនធានរបស់ជនជាតិដើមភាគតិច លើកលែងតែមានការយល់ព្រមជាមុនដោយសេរី និងបន្ទាប់ពីទទួលបានព័ត៌មានគ្រប់ជ្រុងជ្រោយពីជនជាតិដើមភាគតិចដែលទទួលរងផលប៉ះពាល់ ដែលបានដាក់បញ្ចូលជាតំបន់អង្គការសហប្រជាជាតិទទួលបន្ទុកអប់រំ វិទ្យាសាស្ត្រ និងវប្បធម៌ ។

៥- តំបន់ដែលប្រព័ន្ធអេកូឡូស៊ីដែលបានចុះបញ្ជីងាយរងគ្រោះថ្នាក់ ឬកំពុងវិនាស ឬជាទីជម្រកប្រភេទសត្វ នៃក្រុមប្រភេទទី១ និងក្រុមទី២ នៃក្រមនេះ ។

៦- តំបន់ដែលបានចុះបញ្ជីនៅក្នុងលិខិតបទដ្ឋានកតិយុត្ត ជាតំបន់ដែលមានៈ

- ប្រព័ន្ធអេកូឡូស៊ីទឹកសាប សមុទ្រ ឬតំបន់ឆ្នេរសំខាន់ៗ
- តម្លៃអភិរក្សទេសភាពខ្ពស់ ជីវៈចម្រុះ សម្រាប់សត្វ និងរុក្ខជាតិ ឬតម្លៃអភិរក្សប្រព័ន្ធអេកូឡូស៊ី ។

## ជំពូកទី២
## បច្ចេកវិទ្យាល្អបំផុតដែលអាចស្វែងរកបានសម្រាប់ឧស្សាហកម្មនិស្សារណកម្ម

**មាត្រា២៧៨** ._ បច្ចេកវិទ្យាល្អបំផុតដែលអាចស្វែងរកបាន

ក្រសួង ស្ថាប័នទទួលបន្ទុករ៉ែ ត្រូវតម្រូវឱ្យម្ចាស់គម្រោងប្រើប្រាស់បច្ចេកវិទ្យាល្អបំផុត និងការអនុវត្តល្អៗ ដែលអាចស្វែងរកបាន ដើម្បីបញ្ចៀសការបង្កឱ្យមានការបំពុល ឬ ការខូចខាតបរិស្ថាន និងដើម្បីបង្កើនប្រសិទ្ធផលជាអតិបរមា ក្នុងការអនុវត្តសកម្មភាព ឧស្សាហកម្មនិស្សារណកម្ម ។

**មាត្រា២៧៩** ._ បញ្ជីនៃបច្ចេកវិទ្យាល្អបំផុត និងការអនុវត្តល្អៗដែលអាចស្វែងរកបាន

ក្រសួង ស្ថាប័នទទួលបន្ទុករ៉ែ ដោយសហការជាមួយក្រសួង ស្ថាប័នទទួលបន្ទុក បរិស្ថាន ត្រូវរៀបចំលិខិតបទដ្ឋានគតិយុត្តស្តីពីបញ្ជីនៃបច្ចេកវិទ្យាល្អបំផុត និងការអនុវត្តល្អៗដែលអាចស្វែងរកបាន សម្រាប់ធនធានឧស្សាហកម្មនិស្សារណកម្មជាក់លាក់នីមួយៗ ក្នុងរយៈពេល១៨(ដប់ប្រាំបី)ខែ ក្រោយពេលក្រមនេះចូលជាធរមាន ។

**មាត្រា២៨០** ._ លក្ខខណ្ឌតម្រូវដើម្បីបញ្ចៀសការខូចខាតបរិស្ថាន

ម្ចាស់គម្រោងឧស្សាហកម្មនិស្សារណកម្ម ត្រូវមានកាតព្វកិច្ចអនុវត្តបច្ចេកវិទ្យាល្អបំផុតដែលមានចែងក្នុងមាត្រា២៧៨ ដូចខាងក្រោមៈ

១- គ្រប់គ្រងឱ្យបានត្រឹមត្រូវនូវសំណល់ថ្ម និងសំណល់ដទៃទៀតដែលកើតចេញពីការធ្វើអាជីវកម្មនីស្សារណកម្ម ដើម្បីធានាឱ្យបាននូវស្ថេរភាពនៃប្រព័ន្ធគ្រប់គ្រងនិងត្រួតពិនិត្យការបញ្ចេញសំណល់ និងទប់ស្កាត់ផលប៉ះពាល់ដែលអាចកើតចេញពីប្រព័ន្ធបង្ហូរសំណល់រ៉ែដែលមានសារធាតុអាស៊ីត ការលេចធ្លាយនូវសារធាតុលោហៈ និងការបាត់បង់ប្រព័ន្ធគ្រប់គ្រងសំណល់ ។

២- បញ្ចៀសការសាងសង់អាងស្តុកសំណល់រ៉ែ នៅជិតទន្លេ ឬ សមុទ្រ ដែលមានជម្រៅរាក់ពេក ។

៣- យកចិត្តទុកដាក់លើការសាងសង់អាងស្តុកសំណល់រ៉ែអេចិន្ត្រៃយ៍ ក្រោយពីការបញ្ចប់គម្រោង ។

## ជំពូកទី៣
## ការប្រើប្រាស់ ស្យានីត និងបារត នៅក្នុងការធ្វើអាជីវកម្មរ៉ែមាស និងប្រាក់

**មាត្រា២៨១**._ ការទទួលខុសត្រូវ

កិច្ចព្រមព្រៀងទិញលក់ ឬ កិច្ចព្រមព្រៀងដទៃទៀត និងការរៀបចំផែនការរវាងអ្នកផលិត អ្នកចែកចាយ អ្នកដឹកជញ្ជូន ប្រតិបត្តិករ ឬ ម្ចាស់គម្រោង ត្រូវកំណត់ និងបែងចែកការទទួលខុសត្រូវក្នុងការរក្សាឱ្យបាននូវសុវត្ថិភាព សន្តិសុខ ការទប់ស្កាត់ការបញ្ចេញសំណល់ ការបណ្តុះបណ្តាល និងការឆ្លើយតបចំពោះភាពអាសន្ន ទាក់ទងនឹងការប្រើប្រាស់ស្យានីត និងបារត នៅក្នុងគម្រោងអាជីវកម្មរ៉ែមាស ឬប្រាក់ ។

**មាត្រា២៨២**._ លក្ខខណ្ឌតម្រូវសម្រាប់ការប្រើប្រាស់ស្យានីត និងបារត

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន ត្រូវរៀបចំលិខិតបទដ្ឋានគតិយុត្ត ស្តីពីលិខិតអនុញ្ញាតសម្រាប់ប្រើប្រាស់ស្យានីត និងបារត នៅក្នុងគម្រោងអាជីវកម្មរ៉ែមាស ឬប្រាក់ ក្នុងរយៈពេល១ (មួយ) ឆ្នាំ ក្រោយពេលក្រមនេះចូលជាធរមាន ។

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន ត្រូវតម្រូវឱ្យមានការរៀបចំកន្លែងរក្សាទុកសារធាតុស្យានីត និងបារតឱ្យបានត្រឹមត្រូវ ស្របតាមបទប្បញ្ញត្តិស្តីពីការគ្រប់គ្រងសារធាតុគ្រោះថ្នាក់ដូចមានចែងនៅក្នុងគន្ថីទី៦ នៃក្រមនេះ និងក្រមស្តីពីការគ្រប់គ្រងស្យានីតអន្តរជាតិ និងគោរពតាមលក្ខខណ្ឌតម្រូវ ដូចខាងក្រោម៖

១- ការដាក់ចុះ ការធ្វើសន្និធិ និងឧបករណ៍សម្រាប់លាយ ត្រូវបានរចនា និងធ្វើប្រតិបត្តិការ ស្របតាមការអនុវត្តផ្នែកវិស្វកម្មដែលត្រឹមត្រូវ និងទទួលយកបាន ក៏ដូចជា ការត្រួតពិនិត្យគុណភាព និងនីតិវិធីនៃការធានាគុណភាព និងវិធានការ ការពារការបញ្ចេញ និងវិធានការទប់ទល់ ។

២- ការដាក់ចុះ ការធ្វើសន្និធិ និងឧបករណ៍សម្រាប់លាយ ត្រូវបានធ្វើប្រតិបត្តិការដោយប្រើប្រាស់ការធ្វើអធិការកិច្ច ការថែទាំដែលមានការការពារ និងផែនការបម្រុងទុកជាមុនដើម្បីការពារ និងទប់មិនឱ្យរាលដាលនូវការបញ្ចេញ និងត្រួតពិនិត្យ និងឆ្លើយតបចំពោះភាពងាយរងគ្រោះរបស់កម្មករ ។

៣- ឧបករណ៍ស្យានីត និងបារត ត្រូវបានធ្វើប្រតិបត្តិការ និងអង្កេតតាមដាន ដើម្បីការពារសុខភាព និងសុវត្ថិភាពកម្មករ ហើយប្រសិទ្ធភាពនៃវិធានការសុខភាព និងសុវត្ថិភាពត្រូវបានវាយតម្លៃជាប្រចាំ ។

៤- ប្រព័ន្ធគ្រប់គ្រង និងប្រតិបត្តិការ ត្រូវបានរចនា និងអនុវត្តន៍ ដើម្បីការពារសុខភាពមនុស្ស និងបរិស្ថាន រួមមាន ផែនការជាយថាភាព និងផែនការអធិការកិច្ច និងនីតិវិធីថែទាំតាមលក្ខណៈការពារ ។

៥- កម្មវិធីគ្រប់គ្រងទឹកលក្ខណៈគ្រប់ជ្រុងជ្រោយ ត្រូវអនុវត្តន៍ ដើម្បីការពារពីការបញ្ចេញ ដោយគ្មានចេតនា ។

៦- វិធានការក្នុងការការពារប្រភេទសត្វ និងរុក្ខជាតិ ពីផលប៉ះពាល់អវិជ្ជមានដែលអាចកើតឡើងនៃដំណើរការ ស្យានីត និងបារត ត្រូវបានអនុវត្ត ។

៧- វិធានការក្នុងការការពារប្រភេទសត្វ និងរុក្ខជាតិពីការបញ្ចេញចោលដោយផ្ទាល់ និងប្រយោល នៃដំណើរការស្យានីត និងបារតទៅក្នុងទឹកលើដី ត្រូវបានអនុវត្តន៍ ។

៨- កម្មវិធីអង្កេតតាមដាន ដើម្បីវាយតម្លៃផលប៉ះពាល់នៃការប្រើប្រាស់ស្យានីត និងបារតលើប្រភេទសត្វ និងរុក្ខជាតិ និងគុណភាពទឹកលើដីនិងក្រោមដី ត្រូវបានអនុវត្តន៍ ។

៩- ផែនការ និងនីតិវិធីឆ្លើយតបជាបន្ទាន់ ចំពោះភាពងាយរងគ្រោះរបស់កម្មករពីស្យានីត និងបារត ត្រូវបានបង្កើត និងអនុវត្តន៍ ។

១០- នីតិវិធីសម្រាប់ការជូនដំណឹងជាបន្ទាន់ផ្ទៃក្នុង និងខាងក្រៅ និងការរាយការណ៍ត្រូវបានអនុវត្តន៍ ។

១១- ការចូលរួមជាសាធារណៈដែលសមរម្យ ត្រូវបានអនុវត្តន៍ សម្រាប់អ្នកពាក់ព័ន្ធដើម្បីធ្វើការប្រាស្រ័យទាក់ទងអំពីបញ្ហា និងកង្វល់នានា ស្របតាមបទប្បញ្ញត្តិស្តីពី ការចូលរួមជាសាធារណៈនៃក្រមនេះ និង

១២- ព័ត៌មានអំពីប្រតិបត្តិការ និងព័ត៌មានបរិស្ថានដែលសមរម្យ ទាក់ទងនឹង ការគ្រប់គ្រងស្យានីត និងបារត ត្រូវដាក់ឱ្យអ្នកពាក់ព័ន្ធអាចស្វែងរកបាន ស្របតាម បទប្បញ្ញត្តិស្តីពីសិទ្ធិទទួលបានព័ត៌មានបរិស្ថាន នៃក្រមនេះ ។

## ជំពូកទី៤
## ការលាតត្រដាងព័ត៌មាន

**មាត្រា២៨៣**._ សិទ្ធិទទួលបានព័ត៌មានបរិស្ថានស្តីពីគម្រោងឧស្សាហកម្មនិស្សារណកម្ម

ក្រសួង ស្ថាប័នមានសមត្ថកិច្ច និងម្ចាស់គម្រោង ត្រូវដាក់បង្ហាញព័ត៌មានទាក់ទងនឹងគម្រោងឧស្សាហកម្ម និស្សារណកម្មទាំងអស់ ឱ្យសាធារណជនអាចស្វែងរកបាន លើកលែងតែព័ត៌មានសម្ងាត់ដូចមានចែងក្នុងក្រមនេះ ។

**មាត្រា២៨៤**._ ការលើកលែងជាព័ត៌មានសម្ងាត់

រាល់ទិន្នន័យដែលទាក់ទងនឹងគម្រោងឧស្សាហកម្មនិស្សារណកម្មណាមួយ មិនត្រូវចាត់ទុកថាជាព័ត៌មានសម្ងាត់ឡើយ ក្នុងករណីដែលទិន្នន័យនោះទាក់ទងទៅនឹងសុខភាពមនុស្ស ឬបរិស្ថាន។

## គន្ថីទី៤
## ការគ្រប់គ្រងធនធានធម្មជាតិដោយចីរភាព
## មាតិកាទី១
## ប្រព័ន្ធតំបន់ការពារធម្មជាតិ
## ជំពូកទី១
## ការរៀបចំប្រព័ន្ធតំបន់ការពារធម្មជាតិ

**មាត្រា២៨៥**._ វិសាលភាព

មាតិកានេះមានវិសាលភាពអនុវត្តចំពោះប្រព័ន្ធតំបន់ការពារធម្មជាតិ ដែលក្នុងនោះរាប់បញ្ចូលគ្រប់សមាសភាគនៃតំបន់ការពារធម្មជាតិ របៀងអភិរក្សជីវៈចម្រុះ និងតំបន់អភិរក្សដទៃទៀតនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា២៨៦**._ ផែនការយុទ្ធសាស្ត្រប្រព័ន្ធតំបន់ការពារធម្មជាតិ

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន ត្រូវរៀបចំផែនការយុទ្ធសាស្ត្រប្រព័ន្ធតំបន់ការពារធម្មជាតិ ។ ផែនការយុទ្ធសាស្ត្រនេះ ត្រូវស្របតាមផែនការប្រើប្រាស់ដី និងមានសង្គតិភាពជាមួយនឹងយុទ្ធសាស្ត្រ និងផែនការជាតិនានា ដោយមានការពិគ្រោះយោបល់ជាមួយអ្នកពាក់ព័ន្ធ ។

ផែនការយុទ្ធសាស្ត្រប្រព័ន្ធតំបន់ការពារធម្មជាតិ ត្រូវមានគោលដៅសម្រេចបាននូវបរិមាណតំណាងប្រភេទប្រព័ន្ធអេកូឡូស៊ី ដែលស្ថិតនៅក្នុងប្រព័ន្ធតំបន់ការពារធម្មជាតិ នៃដែនសមុទ្រ ដែនទឹកសាប និងដែនដីនៃប្រទេសកម្ពុជា ដូចខាងក្រោម ៖

១- រៀបចំគោលដៅកំណត់បរិមាណតំណាងប្រភេទប្រព័ន្ធអេកូឡូស៊ី នៃប្រព័ន្ធអេកូឡូស៊ីទាំងអស់នៅក្នុងប្រទេសកម្ពុជា ។

២- រក្សា និងធ្វើការជួសជុលប្រព័ន្ធតំបន់ការពារធម្មជាតិទាំងមូល និងតំបន់នីមួយៗដោយឡែក ។

៣- រៀបចំ និងអនុវត្តតាមគោលនយោបាយគ្រប់គ្រង គោលការណ៍ណែនាំ និងផែនការនានា ។

៤- គ្រប់គ្រងដោយប្រសិទ្ធភាព និងប្រសិទ្ធផល ។

៥- អភិវឌ្ឍសមត្ថភាពគ្រប់គ្រងដោយចីរភាព និងឱ្យបានគ្រប់គ្រាន់ ។

៦- ធ្វើឲ្យប្រសើរឡើងនូវអភិបាលកិច្ចសម្រាប់ប្រព័ន្ធតំបន់ការពារធម្មជាតិ និងសមាសភាគនៃប្រព័ន្ធតំបន់ការពារធម្មជាតិ និងបង្កើនឱ្យមានការចូលរួមធ្វើអភិបាលកិច្ចពីសហគមន៍មូលដ្ឋាន ។

៧- បញ្ចូលវិធីសាស្ត្រនៃការគ្រប់គ្រងរួមគ្នា និងវិធីសាស្ត្រនៃការគ្រប់គ្រងបែបនវានុវត្តន៍ផ្សេងទៀត ទៅក្នុងប្រព័ន្ធតំបន់ការពារធម្មជាតិ ។

៨- រៀបចំធនធានចីរភាពហិរញ្ញវត្ថុសម្រាប់ការរៀបចំ និងការថែរក្សាប្រព័ន្ធតំបន់ការពារធម្មជាតិ ។

៩- ធ្វើការស្រាវជ្រាវនៅក្នុងសមាសភាគនៃប្រព័ន្ធតំបន់ការពារធម្មជាតិ និងរៀបចំឲ្យមានប្រព័ន្ធទិន្នន័យដែលងាយស្រួលប្រើប្រាស់ ដែលក្នុងនោះ ត្រូវមាន លទ្ធផលស្រាវជ្រាវ និងព័ត៌មានអំពីមុខងារ តួនាទី តម្លៃ និងលក្ខខណ្ឌតម្រូវពាក់ព័ន្ធទៅនឹងប្រព័ន្ធតំបន់ការពារធម្មជាតិ និងសមាសភាគនៃប្រព័ន្ធតំបន់ការពារធម្មជាតិ ។

១០- ពង្រឹងបន្ថែមកិច្ចខិតខំប្រឹងប្រែងក្នុងការអនុវត្តច្បាប់ស្តីពីតំបន់ការពារធម្មជាតិរួមគ្នារវាងនៅថ្នាក់ជាតិ និងក្រោមជាតិ ។

**មាត្រា២៨៧ .**_ ការពិនិត្យឡើងវិញ និងការកែសម្រួលផែនការយុទ្ធសាស្រ្តប្រព័ន្ធតំបន់ការពារធម្មជាតិ

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន ត្រូវពិនិត្យ និងកែសម្រួលផែនការយុទ្ធសាស្រ្តប្រព័ន្ធតំបន់ការពារធម្មជាតិ នៅរៀងរាល់ ៥ (ប្រាំ) ឆ្នាំម្តង ឬធ្វើការកែសម្រួលនៅពេលមានករណីចាំបាច់ ដើម្បីបំពេញតាមគោលបំណង និងគោលដៅនៃការគ្រប់គ្រងប្រព័ន្ធតំបន់ការពារធម្មជាតិ និងសមាសភាគនៃប្រព័ន្ធតំបន់ការពារធម្មជាតិ។

ការពិនិត្យ និងកែសម្រួលផែនការយុទ្ធសាស្រ្តប្រព័ន្ធតំបន់ការពារធម្មជាតិ ត្រូវមានលក្ខណៈវិនិច្ឆ័យដូចខាងក្រោម៖

១- មានការវិវត្តទៅលើព័ត៌មានផ្នែកវិទ្យាសាស្រ្ត និងការយល់ដឹងផ្នែកធនធានធម្មជាតិ ជីវៈចម្រុះ សេវាកម្មប្រព័ន្ធអេកូឡូស៊ី និងបេតិកភណ្ឌវប្បធម៌នៃព្រះរាជាណាចក្រកម្ពុជា ។

២- មានការលេចឡើងថ្មីនូវការរងគ្រោះថ្នាក់ដល់ប្រព័ន្ធតំបន់ការពារធម្មជាតិ ។

៣-មានការធ្វើបច្ចុប្បន្នភាពទៅលើយុទ្ធសាស្រ្ត និងផែនការសកម្មភាពជាតិស្តីពីជីវៈចម្រុះ។

**មាត្រា២៨៨ .**_ តួនាទី និងការទទួលខុសត្រូវរបស់ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន ដោយសហការជាមួយក្រសួង ស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធ រដ្ឋបាលថ្នាក់ក្រោមជាតិ សហគមន៍មូលដ្ឋាន ជនជាតិដើមភាគតិច និងដៃគូបច្ចេកទេសពាក់ព័ន្ធ ត្រូវទទួលខុសត្រូវជារួម សម្រាប់ប្រព័ន្ធតំបន់ការពារធម្មជាតិ ។

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន ត្រូវមានភារកិច្ច ដូចតទៅ ៖

១-បង្កើត និងអង្កេតតាមដានការអនុវត្តផែនការយុទ្ធសាស្រ្តប្រព័ន្ធតំបន់ការពារធម្មជាតិ ។

២- ធ្វើការស្នើសុំកំណត់សមាសភាគនៃប្រព័ន្ធតំបន់ការពារធម្មជាតិ ស្របតាមការតម្រូវរបស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងស្របតាមលិខិតបទដ្ឋានគតិយុត្តអន្តរជាតិ ។

៣- ផ្តល់គោលការណ៍ណែនាំផ្នែកបច្ចេកទេស និងការគាំទ្រដល់ការបង្កើត និងការអនុវត្តផែនការគ្រប់គ្រងសម្រាប់សមាសភាគនៃប្រព័ន្ធតំបន់ការពារធម្មជាតិ ។

៤- កំណត់ព្រំប្រទល់សមាសភាគនៃប្រព័ន្ធតំបន់ការពារធម្មជាតិ និងតំបន់គ្រប់គ្រងទាំងអស់ដែលស្ថិតនៅក្នុងសមាសភាគនីមួយៗនៃប្រព័ន្ធតំបន់ការធម្មជាតិ ដោយប្រសិទ្ធភាព និងសមស្រប ។

៥- អង្កេតតាមដានការអនុវត្តផែនការគ្រប់គ្រងសមាសភាគនៃប្រព័ន្ធតំបន់ការពារធម្មជាតិ ។

៦- គ្រប់គ្រង និងផ្តល់ការគាំទ្រដល់ដំណើរការបញ្ចូលសហគមន៍តំបន់ការពារធម្មជាតិ សហគមន៍ព្រៃឈើ សហគមន៍ជលផល និងតំបន់មូលដ្ឋាន ដែលមានការគ្រប់គ្រងជាលក្ខណៈប្រពៃណី ទៅក្នុងប្រព័ន្ធតំបន់ការពារធម្មជាតិ ។

៧- អភិវឌ្ឍសមត្ថភាពរដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីចូលរួមគ្រប់គ្រងសមាសភាគនៃប្រព័ន្ធតំបន់ការពារធម្មជាតិ ស្របតាមការទទួលខុសត្រូវដែលបានធ្វើប្រតិភូកម្ម ។

៨- រៀបចំយន្តការចីរភាពហិរញ្ញប្បទាន សម្រាប់ប្រព័ន្ធតំបន់ការពារធម្មជាតិ ស្របតាមគន្ថីទី៨ នៃក្រមនេះ ។

៩- រៀបចំគោលការណ៍ណែនាំ និងនីតិវិធីស្តីពីការអនុវត្តមាតិកានេះ ។

១០- ដឹកនាំ និងគាំទ្រដល់ការយាមល្បាត របស់សមាជិកសហគមន៍មូលដ្ឋាននៅគ្រប់តំបន់ការពាររបស់សហគមន៍មូលដ្ឋាន ដោយសហការជាមួយអាជ្ញាធរអនុវត្តច្បាប់ ។

១១- ស៊ើបអង្កេតបទល្មើស ដែលកើតឡើងនៅក្នុងប្រព័ន្ធតំបន់ការពារធម្មជាតិ និងកសាងសំណុំរឿងដើម្បីឱ្យមានការចោទប្រកាន់ជនល្មើសទៅតាមនីតិវិធី ដោយសហការជាមួយអាជ្ញាធរអនុវត្តច្បាប់ពាក់ព័ន្ធ ។

១២-បង្កើតប្រព័ន្ធទិន្នន័យបទល្មើសដែលកើតឡើងក្នុងប្រព័ន្ធតំបន់ការពារធម្មជាតិដែលប្រមូលបានតាមរយៈការយាមល្បាត ។

១៣- លើកកម្ពស់ការស្រាវជ្រាវ ក្នុងប្រព័ន្ធតំបន់ការពារធម្មជាតិ និងការអនុវត្តលទ្ធផលនៃការស្រាវជ្រាវទាំងនោះ ។

១៤- លើកកម្ពស់ការអប់រំ និងការយល់ដឹងជាសាធារណៈ អំពីប្រព័ន្ធតំបន់ការពារធម្មជាតិ និងសមាសភាគនៃប្រព័ន្ធតំបន់ការពារធម្មជាតិទាំងអស់ និងតួនាទីអភិរក្សជីវៈចម្រុះនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា២៨៩** ._ សិទ្ធិ និងការទទួលខុសត្រូវរបស់មន្ត្រីទទួលបន្ទុកគ្រប់គ្រងប្រព័ន្ធតំបន់ការពារធម្មជាតិ

ការរៀបចំ និងការប្រព្រឹត្តទៅនៃតួនាទី និងភារកិច្ចរបស់មន្ត្រីទទួលបន្ទុកគ្រប់គ្រងប្រព័ន្ធតំបន់ការពារធម្មជាតិ និងសមាសភាគនៃប្រព័ន្ធតំបន់ការពារធម្មជាតិ ត្រូវកំណត់ដោយលិខិតបទដ្ឋានគតិយុត្តរបស់ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន ។

**មាត្រា២៩០** ._ តួនាទីរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ

រដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវមានតួនាទីដូចខាងក្រោម៖

១- ផ្សព្វផ្សាយព័ត៌មានអំពីច្បាប់ និងបទប្បញ្ញត្តិពាក់ព័ន្ធទៅនឹងការគ្រប់គ្រងតំបន់ការពារធម្មជាតិ នៅថ្នាក់មូលដ្ឋាន ។

២- រៀបចំ និងអនុវត្តផែនការពង្រឹងការគ្រប់គ្រងតំបន់ការពារធម្មជាតិថ្នាក់មូលដ្ឋាន និងអនុវត្តគោលនយោបាយភូមិឃុំមានសុវត្ថិភាព ដើម្បីលើកកម្ពស់ជីវភាពរស់នៅរបស់សហគមន៍មូលដ្ឋានដែលស្ថិតនៅក្នុង និងជាប់ទៅនឹងតំបន់ការពារធម្មជាតិ ។

៣- ពង្រឹងការគ្រប់គ្រងតំបន់ការពារធម្មជាតិថ្នាក់មូលដ្ឋានស្របតាមតួនាទី ភារកិច្ចដែលបានទទួលពីការធ្វើប្រតិភូកម្ម ដោយសហការជាមួយក្រសួង ស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធ សហគមន៍មូលដ្ឋាន ជនជាតិដើមភាគតិច និងដៃគូបច្ចេកទេសពាក់ព័ន្ធ ស្របតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តដែលពាក់ព័ន្ធ ។

៤- គ្រប់គ្រងសកម្មភាពរស់នៅរបស់ប្រជាជនដែលរស់នៅក្នុង និងជាប់ទៅនឹងសហគមន៍តំបន់ការពារថ្នាក់មូលដ្ឋាន ស្របតាមនីតិវិធីជាធរមាន ។

៥- គ្រប់គ្រងថវិកាដែលទទួលបានដោយប្រសិទ្ធភាព និងតម្លាភាព ។

៦- ធ្វើរបាយការណ៍វឌ្ឍនភាពប្រចាំឆ្នាំ ឆមាស និងត្រីមាសអំពីការបំពេញមុខងារដែលបានទទួលពីការធ្វើប្រតិភូកម្មរបស់ខ្លួន ដើម្បីបញ្ជូនតាមឋានានុក្រមទៅក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន ។

៧- ការទទួលខុសត្រូវផ្សេងទៀតដែលទទួលបានតាមការធ្វើប្រតិភូកម្ម ។

**មាត្រា២៩១** ._ អាជ្ញាធរទទួលបន្ទុកចេញលិខិតអនុញ្ញាត និងចុះកិច្ចព្រមព្រៀង ឬកិច្ចសន្យា

មន្ត្រីក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងមន្ត្រីប្រចាំសមាសភាគនៃប្រព័ន្ធតំបន់ការពារធម្មជាតិ ទទួលសិទ្ធិក្នុងការចេញលិខិតអនុញ្ញាត និងចុះកិច្ចព្រមព្រៀង ឬកិច្ចសន្យាសម្រាប់សកម្មភាពទាំងឡាយដែលត្រូវធ្វើឡើងនៅក្នុងសមាសភាគនៃប្រព័ន្ធតំបន់ការពារធម្មជាតិ និងទទួលសិទ្ធិព្យួរ ឬលុបចោលនូវលិខិតអនុញ្ញាត និងចុះកិច្ចព្រមព្រៀង ឬកិច្ចសន្យាទាំងឡាយណាដែលមិនបំពេញតាមលក្ខខណ្ឌដែលបានចុះរួចហើយ ។

## ជំពូកទី២
## ការកំណត់អត្តសញ្ញាណ និងការវាយតម្លៃប្រព័ន្ធអេកូឡូស៊ី

**មាត្រា២៩២** ._ ការវាយតម្លៃប្រព័ន្ធអេកូឡូស៊ី

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន ត្រូវកំណត់អត្តសញ្ញាណប្រព័ន្ធអេកូឡូស៊ីទាំងអស់តាមការវាយតម្លៃជាលក្ខណៈប្រព័ន្ធស្របតាមប្រព័ន្ធវាយតម្លៃតាមស្តង់ដារអន្តរជាតិ និងត្រូវបញ្ចូលលទ្ធផលនៃការកំណត់អត្តសញ្ញាណទាំងនោះចូលទៅក្នុងផែនការយុទ្ធសាស្ត្រប្រព័ន្ធតំបន់ការពារធម្មជាតិ ។

ប្រព័ន្ធអេកូឡូស៊ីនីមួយៗ ត្រូវកំណត់ប្រភេទស្របតាមលក្ខណៈវិនិច្ឆ័យនៃប្រព័ន្ធអេកូឡូស៊ី តាមចំណាត់ថ្នាក់តាមបញ្ជីអន្តរជាតិផ្សេងទៀតដែលព្រះរាជាណាចក្រកម្ពុជាទទួលស្គាល់ ។

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន ត្រូវរៀបចំលិខិតបទដ្ឋានគតិយុត្ត ស្តីពីការអនុវត្តតាមលក្ខណៈវិនិច្ឆ័យ និងការធ្វើចំណាត់ថ្នាក់ក្រុមប្រភេទ នៃបញ្ជីក្រហមស្តីពីប្រព័ន្ធអេកូឡូស៊ី និងនីតិវិធីស្តីពីការវាយតម្លៃប្រព័ន្ធអេកូឡូស៊ី និងលិខិតបទដ្ឋានគតិយុត្ត ស្តីពីការរៀបចំបង្កើតបញ្ជីថ្នាក់ជាតិ ស្តីពីប្រព័ន្ធអេកូឡូស៊ីដែលកំពុងវិនាស និងដំណើរការនៃការពិនិត្យ និងការធ្វើបច្ចុប្បន្នភាព ។

បន្ទាប់ពីការវាយតម្លៃប្រព័ន្ធអេកូឡូស៊ី បានបង្ហាញថា មានប្រព័ន្ធអេកូឡូស៊ី កំពុងវិនាសទាំងស្រុង ឬកំពុងវិនាសធ្ងន់ធ្ងរ ឬមានទីជម្រកសត្វ រុក្ខជាតិព្រៃ នៃក្រុមប្រភេទទី១ ឬទី២ ស្របតាមបញ្ជីជាតិសម្រាប់ប្រភេទសត្វ និងរុក្ខជាតិព្រៃដែលកំពុងរងគ្រោះថ្នាក់ ឬបញ្ជីអន្តរជាតិផ្សេងទៀតដែលព្រះរាជាណាចក្រកម្ពុជាទទួលស្គាល់ នោះក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន ត្រូវធ្វើការស្នើសុំកំណត់ប្រព័ន្ធអេកូឡូស៊ីនោះ ជាសមាសភាគនៃប្រព័ន្ធតំបន់ការពារធម្មជាតិ ។

**មាត្រា២៩៣**._ ផែនការគ្រប់គ្រង និងស្តារប្រព័ន្ធអេកូឡូស៊ីឡើងវិញ

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន ដោយសហការជាមួយក្រសួង ស្ថាប័នមានសមត្ថកិច្ច និងដៃគូបច្ចេកទេសពាក់ព័ន្ធ ត្រូវបង្កើតផែនការគ្រប់គ្រង និងស្តារប្រព័ន្ធអេកូឡូស៊ីឡើងវិញ បន្ទាប់ពីមានការវាយតម្លៃបង្ហាញថា កំពុងរងគ្រោះថ្នាក់ ឬជិតវិនាស នៃចំណាត់ថ្នាក់តាមបញ្ជីអន្តរជាតិផ្សេងទៀតដែលព្រះរាជាណាចក្រកម្ពុជាទទួលស្គាល់ ។

ផែនការគ្រប់គ្រង និងស្តារប្រព័ន្ធអេកូឡូស៊ីឡើងវិញ ត្រូវមានរយៈពេល ១០ (ដប់) ឆ្នាំ ។

ខ្លឹមសារនៃផែនការគ្រប់គ្រង និងស្តារប្រព័ន្ធអេកូឡូស៊ីឡើងវិញ ត្រូវកំណត់ដោយលិខិតបទដ្ឋានគតិយុត្តរបស់ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន ។

**មាត្រា២៩៤**._ ការវាយតម្លៃរបៀងអភិរក្សជីវៈចម្រុះ

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន ត្រូវរៀបចំឱ្យមានការវាយតម្លៃនានាពាក់ព័ន្ធនឹងដែនដី ដែនទឹក ធនធានធម្មជាតិ និងការតាំងទីលំនៅរបស់ប្រជាជន នៅក្នុងគ្រប់របៀងអភិរក្សជីវៈចម្រុះ ។

ក្នុងករណី ដែលលទ្ធផលនៃការវាយតម្លៃបង្ហាញថា មានតំបន់ណាមួយ ដែលស្ថិតនៅក្នុងរបៀងអភិរក្សជីវៈចម្រុះ មានប្រព័ន្ធអេកូឡូស៊ីដែលកំពុងវិនាសទាំងស្រុង ឬវិនាសធ្ងន់ធ្ងរ ឬមានទីជម្រកសត្វព្រៃ នៃក្រុមប្រភេទទី១ និងទី២ ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន ត្រូវរៀបចំការស្នើសុំបង្កើតតំបន់ទាំងនោះទៅជាសមាភាគនៃប្រព័ន្ធតំបន់ការពារធម្មជាតិ ។

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន អាចបង្កើតលិខិតបទដ្ឋានគតិយុត្ត ដែលកំណត់អំពីលក្ខខណ្ឌនៃការវាយតម្លៃជាក់លាក់ទៅលើរបៀងអភិរក្សជីវៈចម្រុះ ។

ក្នុងករណីការវាយតម្លៃបានកំណត់ថា តំបន់ណាមួយនៅក្នុងរបៀងអភិរក្សជីវៈចម្រុះដែលបានចុះបញ្ជីងាយរងគ្រោះថ្នាក់ ឬកំពុងវិនាស ឬជាទីជម្រកប្រភេទសត្វដូចបានកំណត់ក្នុងចំណាត់ថ្នាក់ក្រុមទី៣ នោះត្រូវអនុវត្តតាមមាត្រា២៩៣នៃក្រមនេះ ។

គ្រប់ផែនការគ្រប់គ្រង និងស្តារប្រព័ន្ធអេកូឡូស៊ីឡើងវិញ ដូចបានកំណត់ក្នុងមាតិការនេះ និងផែនការគ្រប់គ្រង និងស្តារឡើងវិញនូវប្រភេទដូចបានកំណត់ក្នុងគន្ថីនេះ ត្រូវដាក់បញ្ចូលទៅក្នុងផែនការគ្រប់គ្រងរបៀងអភិរក្សជីវៈចម្រុះ ។

## ជំពូកទី៣
## ការបង្កើតតំបន់

**មាត្រា២៩៥**._ ការបង្កើតសមាសភាគនៃប្រព័ន្ធតំបន់ការពារធម្មជាតិ

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន ត្រូវរៀបចំលិខិតបទដ្ឋានគតិតយុត្តស្តីពីការបង្កើតសមាសភាគនៃប្រព័ន្ធតំបន់ការពារធម្មជាតិ គ្រប់ប្រភេទទាំងអស់ ដែលមាននៅក្នុងព្រះរាជាណាចក្រកម្ពុជា រួមមានតំបន់ការពារធម្មជាតិ របៀងអភិរក្សជីវៈចម្រុះ តំបន់ដែលត្រូវធ្វើការអភិរក្សធនធានធម្មជាតិផ្សេងទៀត និងតំបន់ដែលបានកំណត់នៅក្នុងលិខិតបទដ្ឋានអន្តរជាតិដែលព្រះរាជាណាចក្រកម្ពុជាជាភាគីហត្ថលេខី ។

តំបន់អភិរក្ស ដែលបានបង្កើតឡើងតាមលិខិតបទដ្ឋានគតិយុត្តផ្សេងទៀត រួមមាន តំបន់សហគមន៍ព្រៃឈើ តំបន់សហគមន៍ជលផល តំបន់ការពារបេតិកភណ្ឌវប្បធម៌ តំបន់ផ្សេងទៀតដែលត្រូវធ្វើការអភិរក្សធនធានធម្មជាតិ សេវាកម្មប្រព័ន្ធអេកូឡូស៊ី ឬតំបន់សហគមន៍មូលដ្ឋាន និងជនជាតិដើមភាគតិច អាចជាតំបន់ដែលត្រូវរាប់បញ្ចូលទៅក្នុងប្រព័ន្ធតំបន់ការពារធម្មជាតិ ។

គ្រប់សហគមន៍តំបន់ការពារ ដែលបានបង្កើតនៅមុនពេលក្រមនេះចូលជាធរមាន ត្រូវមានអនុភាពផ្លូវច្បាប់ដូចដើម និងត្រូវបន្តអនុវត្តតាមការរៀបចំផែនការ និងដំណើរការសម្រាប់កំណត់តំបន់គ្រប់គ្រង ស្របតាមមាតិកានេះ ។

រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា អាចចុះកិច្ចព្រមព្រៀងជាមួយប្រទេសដទៃដើម្បីបង្កើត និងគ្រប់គ្រងតំបន់ការពារធម្មជាតិ និងរបៀងអភិរក្សជីវៈចម្រុះ ឆ្លងដែនបាន ។

**មាត្រា២៩៦** ._ ការកំណត់តំបន់ការពារធម្មជាតិ និងអចលនទ្រព្យរបស់ជនជាតិដើមភាគតិច

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន អាចបង្កើតសមាសភាគនៃប្រព័ន្ធតំបន់ការពារធម្មជាតិសម្រាប់តំបន់ណាដែលមានសារៈសំខាន់ជារួម ឬតំបន់ដែលមានសារៈប្រយោជន៍សំខាន់ដល់សហគមន៍ជនជាតិដើមភាគតិច តាមការស្នើសុំរបស់សហគមន៍ជនជាតិដើមភាគតិច ។

**មាត្រា២៩៧** ._ ការបង្កើតតំបន់ស្របតាមលិខិតបទដ្ឋានគតិយុត្តអន្តរជាតិ

រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា អាចកំណត់តំបន់ទាំងឡាយដែលស្ថិតនៅក្រោមសមត្ថកិច្ច ឬបូរណភាពដែនដីរបស់ខ្លួន ដែលមានសារៈសំខាន់ជាលក្ខណៈជាតិ និងអន្តរជាតិ ស្របតាមលក្ខណៈវិនិច្ឆ័យ ដូចមានចែងក្នុងលិខិតបទដ្ឋានអន្តរជាតិ ដែលព្រះរាជាណាចក្រកម្ពុជា ជាភាគីហត្ថលេខី ។

**មាត្រា២៩៨** ._ នីតិវិធីនៃការបង្កើតសមាសភាគនៃប្រព័ន្ធតំបន់ការពារធម្មជាតិ

ពាក្យស្នើសុំបង្កើតសមាសភាគនៃប្រព័ន្ធតំបន់ការពារធម្មជាតិ ត្រូវមានខ្លឹមសារ ដូចខាងក្រោម ៖

១- សេចក្តីពិពណ៌នាផ្នែកច្បាប់ពាក់ព័ន្ធទៅនឹងតំបន់ស្នើសុំ ដែលមានផែនទីកំណត់ពីមាត្រដ្ឋានត្រឹមត្រូវ និងច្បាស់លាស់ និងមានបញ្ជាក់អំពីទីតាំង ព្រំប្រទល់ ទំហំ និងប្រវត្តិនៃតំបន់នោះដែលបានរៀបរាប់នៅក្នុងផែនការប្រើប្រាស់ដីដែលពាក់ព័ន្ធ ។

២- ការវាយតម្លៃអំពីការប្រើប្រាស់ដី និងធនធានធម្មជាតិដែលមានស្រាប់ នៅក្នុងតំបន់ស្នើសុំ ។

៣- សេចក្តីលម្អិតអំពីការកែប្រែទៅលើការប្រើប្រាស់ដី ដែលត្រូវកើតឡើងបន្ទាប់ពីមានការបង្កើតជាសមាសភាគនៃប្រព័ន្ធតំបន់ការពារធម្មជាតិ ។

៤- សេចក្តីលម្អិតអំពីសារៈសំខាន់នៃតំបន់ស្នើសុំ ពាក់ព័ន្ធទៅនឹងតម្លៃជីវសាស្ត្រ ភូមិសាស្ត្រ ភូគព្ភសាស្ត្រ ប្រវត្តិសាស្ត្រ វប្បធម៌ និងតម្លៃអភិរក្ស ។

៥- សេចក្តីលម្អិតអំពីកម្រិតនៃការបែងចែកប្រព័ន្ធអេកូឡូស៊ី និងជម្រកសត្វ ក្នុងតំបន់ស្នើសុំ និងហានិភ័យនានាដល់តម្លៃអភិរក្ស នៅពេលកំពុងរៀបចំពាក្យស្នើសុំ ។

៦- ចរិតលក្ខណៈ និងទម្រង់នៃការបន្លាស់ទី និងចលនារបស់ប្រភេទសត្វសំខាន់ៗ និងការវាយតម្លៃអំពីផលប៉ះពាល់ដែលជាសក្តានុពល ទៅលើប្រភេទសត្វទាំងនោះ ក្នុងករណីមិនមានការបង្កើតតាមការស្នើសុំ ។

៧- ការប៉ាន់ប្រមាណអំពីសេវាកម្មប្រព័ន្ធអេកូឡូស៊ី ដែលតំបន់ស្នើសុំនោះបង្កើតឱ្យមាន ឬនឹងមាន ។

៨- ការវាយតម្លៃអំពីផលប៉ះពាល់អវិជ្ជមានដោយការប្រែប្រួលអាកាសធាតុ ទៅលើតំបន់ស្នើសុំ ។

៩- សេចក្តីពន្យល់អំពីរបៀបដែលបានស្នើសុំ ជួយសម្រេចបាននូវគោលដៅដូចបានកំណត់ក្នុងផែនការយុទ្ធសាស្ត្រប្រព័ន្ធតំបន់ការពារធម្មជាតិ ។

១០- លទ្ធផលនៃកិច្ចពិគ្រោះយោបល់ជាមួយតំណាងអាជ្ញាធរថ្នាក់ជាតិ និងក្រោមជាតិដែលមានសមត្ថកិច្ច និងអ្នកពាក់ព័ន្ធដែលរស់នៅក្នុង ឬជាប់ទៅនឹងតំបន់ស្នើសុំ ។

១១- ព័ត៌មានផ្សេងទៀតពាក់ព័ន្ធទៅនឹងតំបន់ស្នើសុំ ។

រាល់ព័ត៌មានដែលត្រូវមាននៅក្នុងពាក្យស្នើសុំបង្កើតសមាសភាគនៃប្រព័ន្ធតំបន់ការពារធម្មជាតិ ត្រូវផ្អែកលើឯកសារអំពីលទ្ធផលនៃការស្រាវជ្រាវ និងផ្អែកលើការពិនិត្យជាក់ស្តែងទៅលើទីតាំងនៃតំបន់ស្នើសុំ ។

**មាត្រា២៩៩** ._ ការកែប្រែទៅលើសមាសភាគនៃប្រព័ន្ធតំបន់ការពារធម្មជាតិ

រាល់ការស្នើសុំកាត់បន្ថយ ឬដកចេញ នូវសមាសភាគនៃប្រព័ន្ធតំបន់ការពារធម្មជាតិទាំងអស់ត្រូវភ្ជាប់មកជាមួយនូវការស្នើសុំពង្រីកសមាសភាគនៃប្រព័ន្ធតំបន់ការពារធម្មជាតិដែលមានប្រភេទដូចគ្នាស្រាប់ ឬសុំបង្កើតសមាសភាគថ្មី ដែលមានប្រភេទដូចគ្នា និងដែលគ្របដណ្តប់ទៅលើតំបន់ទេសភាព ឬទេសភាពសមុទ្រ ឬប្រព័ន្ធអេកូឡូស៊ី ឬជម្រកសត្វដែលមានលក្ខណៈស្រដៀងគ្នា ។

រាល់ការស្នើសុំខាងលើ ត្រូវដាក់ស្នើទៅកាន់ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថានដើម្បីធ្វើការពិនិត្យ និងសម្រេច ដោយពិគ្រោះយោបល់ជាមួយដៃគូបច្ចេកទេស និងអ្នកជំនាញការពាក់ព័ន្ធ ។

រាល់ការស្នើសុំកាត់បន្ថយ ឬដកចេញនូវមាសភាគនៃប្រព័ន្ធតំបន់ការពារធម្មជាតិ ត្រូវដាក់បញ្ចូល ៖

១- សេចក្តីពិពណ៌នាផ្អែកច្បាប់ពាក់ព័ន្ធទៅនឹងតំបន់ស្នើសុំកែប្រែដែលមានផែនទីកំណត់ ពីមាត្រដ្ឋានត្រឹមត្រូវ និងច្បាស់លាស់ និងមានបញ្ជាក់អំពីការចំណុចស្នើសុំធ្វើការកែប្រែ រួមមានទំហំ ព្រំប្រទល់ និងការកំណត់តំបន់គ្រប់គ្រង ។

២- សេចក្តីលម្អិតអំពីការកែប្រែទៅលើការប្រើប្រាស់ដី ដែលត្រូវកើតឡើងដោយសារការកែប្រែដែលបានស្នើសុំ ។

៣- ហេតុផលផ្នែកវិទ្យាសាស្ត្រ និងសេដ្ឋកិច្ច-សង្គម សម្រាប់ការស្នើសុំកែប្រែ ។

៤- កិច្ចខិតខំប្រឹងប្រែងដែលបានធ្វើឡើងដើម្បីរក្សាព្រំប្រទល់ដើម នៃតំបន់ស្នើសុំធ្វើការកែប្រែ ឬដកចេញ ។

៥- របៀបដែលការស្នើសុំកែប្រែលើកកម្ពស់ដល់ជីវភាពរស់នៅ និងសិទ្ធិប្រពៃណីរបស់សហគមន៍មូលដ្ឋាន និងជនជាតិដើមភាគតិច ។

៦- ការរៀបរាប់អំពីការទូទាត់ទៅលើការកែប្រែដែលបានស្នើសុំ ។

៧- ឯកសារលទ្ធផលនៃកិច្ចពិគ្រោះយោបល់ជាមួយសហគមន៍មូលដ្ឋាន និងអ្នកពាក់ព័ន្ធដែលបានរងផលប៉ះពាល់ និងឯកសារអំពីការយល់ព្រមរបស់សហគមន៍មូលដ្ឋានទៅលើការកែប្រែដែលបានស្នើសុំ ។

៨- គ្រប់ព័ត៌មានពាក់ព័ន្ធដទៃទៀត តាមការតម្រូវរបស់ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន ។

## ជំពូកទី៤
## ការគ្រប់គ្រង

**មាត្រា៣០០**._ តំបន់ដែលស្ថិតក្រោមលិខិតបទដ្ឋានគតិយុទ្ធអន្តរជាតិ

រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ត្រូវគ្រប់គ្រងតំបន់ដែលចាត់ជាតំបន់មានសារៈសំខាន់ចំពោះជាតិ និងអន្តរជាតិដែលស្ថិតនៅក្រោមលិខិតបទដ្ឋានគិតយុត្តអន្តរជាតិ ឱ្យស្របតាមលក្ខណៈវិនិច្ឆ័យ ដែលបានកំណត់ក្នុងលិខិតបទដ្ឋានគតិយុត្តបង្កើតតំបន់នោះ ។

**មាត្រា៣០១**._ ការផ្អាកសកម្មភាពអភិវឌ្ឍន៍ និងសកម្មភាពពាណិជ្ជកម្ម

ត្រូវហាមឃាត់ចំពោះសកម្មភាពអភិវឌ្ឍន៍ ឬសកម្មភាពពាណិជ្ជកម្មទាំងឡាយ នៅក្នុងសមាសភាគនៃប្រព័ន្ធតំបន់ការពារធម្មជាតិ ក្នុងករណីដែលមិនទាន់មានផែនការគ្រប់គ្រងដែលបានឯកភាពសម្រាប់សមាសភាគនៃប្រព័ន្ធតំបន់ការពារធម្មជាតិទាំងនោះនៅឡើយ ។

**មាត្រា៣០២**._ ប្រភេទតំបន់ការពារធម្មជាតិ

ប្រភេទតំបន់ការពារធម្មជាតិ ត្រូវបានកំណត់នៅក្នុងច្បាប់ស្តីពីតំបន់ការពារធម្មជាតិដែលមានជាធរមាន ។

គោលដៅ និងផែនការគ្រប់គ្រងប្រភេទតំបន់ខាងលើ ត្រូវកំណត់ដោយលិខិតបទដ្ឋានគតិយុត្តរបស់ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន ។

**មាត្រា៣០៣** ._ ការកំណត់ និងការបែងចែកតំបន់គ្រប់គ្រង

តំបន់ការពារធម្មជាតិនីមួយៗ ត្រូវបែងចែកជាបួនតំបន់គ្រប់គ្រងដូចមានកំណត់នៅក្នុងច្បាប់ស្តីពីតំបន់ការពារធម្មជាតិដែលនៅជាធរមាន លើកលែងតែ តំបន់ស្នូលនៃបមនីយជីវមណ្ឌល ដែលត្រូវបែងចែកជាបីតំបន់គ្រប់គ្រង ។

**មាត្រា៣០៤** ._ តំបន់ស្នូលនៃបមនីយជីវមណ្ឌល

តំបន់ស្នូលនៃបមនីយជីវមណ្ឌល មានតំបន់គ្រប់គ្រងដូចតទៅ ៖

១- តំបន់ស្នូល ៖ សំដៅដល់ប្រព័ន្ធអេកូឡូស៊ីដែលត្រូវបានការពារតឹងរ៉ឹង និងជាតំបន់ដែលជួយអភិរក្សតំបន់ទេសភាព ប្រព័ន្ធអេកូឡូស៊ី សត្វ និងរុក្ខជាតិ និងការប្រែប្រួលហ្សេនេទិច ។

២- តំបន់ទ្រនាប់ ៖ សំដៅដល់តំបន់ដែលនៅជុំវិញ ឬដែលតភ្ជាប់ទៅនឹងតំបន់ស្នូល ហើយប្រើសម្រាប់សកម្មភាពពាក់ព័ន្ធនឹងអេកូឡូស៊ី ដែលទ្រទ្រង់ដល់ការស្រាវជ្រាវផ្នែកវិទ្យាសាស្រ្ត ការអង្កេតតាមដាន ការបណ្តុះបណ្តាល និងការអប់រំ ។

៣- អន្តរតំបន់ ៖ ជាផ្នែកមួយនៃតំបន់បម្រុងទុក ដែលអនុញ្ញាតឲ្យមានសកម្មភាពជាអតិបរមា ដែលនាំឱ្យមានការអភិវឌ្ឍធនធានមនុស្ស និងសេដ្ឋកិច្ច នាំទៅរកចីរភាពផ្នែកអេកូឡូស៊ី វប្បធម៌ និងសង្គម ។

**មាត្រា៣០៥** ._ ការកែប្រែ និងការកំណត់តំបន់គ្រប់គ្រងឡើងវិញ

រាល់ការស្នើសុំកែប្រែ និងកំណត់តំបន់គ្រប់គ្រងឡើងវិញ សម្រាប់តំបន់ការពារធម្មជាតិ ត្រូវដាក់ទៅកាន់ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន ដើម្បីធ្វើការពិចារណា និងសម្រេច ដោយមានការពិគ្រោះយោបល់ជាមួយដៃគូជំនួយបច្ចេកទេស និងអ្នកជំនាញការបច្ចេកទេស ។

ការស្នើសុំនេះ ត្រូវមានខ្លឹមសារ ដូចខាងក្រោម ៖

១- សេចក្តីពិពណ៌នាផ្នែកច្បាប់ពាក់ព័ន្ធទៅនឹងតំបន់គ្រប់គ្រងដែលស្នើសុំកែប្រែ ដែលមានផែនទីកំណត់ពីមាត្រដ្ឋានត្រឹមត្រូវ និងច្បាស់លាស់ ។

២- សេចក្តីលម្អិតអំពីការកែប្រែទៅលើការប្រើប្រាស់ដី ដែលត្រូវកើតឡើងបន្ទាប់ពីមានការកែប្រែ និងការកំណត់តំបន់គ្រប់គ្រងឡើងវិញ

៣- បញ្ជាក់ហេតុផលផ្នែកវិទ្យាសាស្ត្រ និងផ្នែកសេដ្ឋកិច្ច-សង្គម សម្រាប់ការស្នើសុំកែប្រែ និងកំណត់តំបន់គ្រប់គ្រងឡើងវិញ ។

៤- កិច្ចខិតខំប្រឹងប្រែងកន្លងមកក្នុងការរក្សានូវសភាពដើមនៃតំបន់គ្រប់គ្រង ។

៥- របៀបដែលការកែប្រែ និងកំណត់តំបន់គ្រប់គ្រងឡើងវិញ លើកកម្ពស់ដល់ជីវភាពរស់នៅ និងសិទ្ធិប្រពៃណីរបស់សហគមន៍មូលដ្ឋាន និងជនជាតិដើមភាគតិច ។

៦- របៀបនៃការទូទាត់សម្រាប់ការកែប្រែ និងការកំណត់តំបន់គ្រប់គ្រងឡើងវិញ ។

៧- លទ្ធផលនៃកិច្ចពិគ្រោះយោបល់ ជាមួយសហគមន៍មូលដ្ឋាន និងអ្នកពាក់ព័ន្ធដែលទទួលរងផលប៉ះពាល់ រួមទាំងឯកសារដែលបញ្ជាក់ពីការយល់ព្រមរបស់សហគមន៍ទាំងនេះ ។

៨-រាល់ព័ត៌មានផ្សេងទៀត តាមការតម្រូវរបស់ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន ។

**មាត្រា៣០៦** ._ សកម្មភាពដែលត្រូវហាមឃាត់

សកម្មភាព ដែលត្រូវហាមឃាត់ក្នុងតំបន់គ្រប់គ្រងនៃតំបន់ការពារធម្មជាតិ ដោយលើកលែងតែតំបន់ស្នូលនៃបមនីយជីវមណ្ឌល ៖

១- តំបន់ស្នូល ៖ ហាមឃាត់ចំពោះសកម្មភាពពាណិជ្ជកម្មគ្រប់ប្រភេទ មានជាអាទ៍ ការរុករករ៉ែ ការបូមច្រោះ និងការទាញយកខ្សាច់ ការផលិតអគ្គិសនី ប្រព័ន្ធបញ្ជូន ឬចែកចាយអគ្គិសនី ការប្រើម៉ាស៊ីនដឹកជញ្ជូន ដំណាំកសិកម្ម វារីវប្បកម្មគ្រប់ប្រភេទ ហេដ្ឋារចនាសម្ព័ន្ធគ្រប់គ្រងធនធានទឹក រួមមាន ប្រព័ន្ធធារាសាស្ត្រ និងទំនប់ទឹកគ្រប់ប្រភេទ ការប្រើប្រាស់ដើម្បីចិញ្ចឹមជីវិត និងជាលក្ខណៈប្រពៃណី ឬការចិញ្ចឹមសត្វ ។

២- តំបន់អភិរក្ស ៖ ហាមឃាត់ចំពោះការរុករករ៉ែ ការបូមច្រោះ និងការទាញយកខ្សាច់ ការផលិតអគ្គិសនី ប្រព័ន្ធបញ្ជូន ឬចែកចាយអគ្គិសនី ការប្រើម៉ាស៊ីនដឹកជញ្ជូន ដំណាំកសិកម្ម វារីវប្បកម្មគ្រប់ប្រភេទ ហេដ្ឋារចនាសម្ព័ន្ធគ្រប់គ្រងធនធានទឹក រួមមាន ប្រព័ន្ធធារាសាស្ត្រ និងទំនប់ទឹកគ្រប់ប្រភេទ ការប្រើប្រាស់ដើម្បីចិញ្ចឹមជីវិត និងជាលក្ខណៈប្រពៃណី ឬការចិញ្ចឹមសត្វ និងគ្រប់សកម្មភាពពាណិជ្ជកម្មទាំងអស់ លើកលែងតែទេសចរណ៍ធម្មជាតិដែលមានផលប៉ះពាល់តិចតួចប៉ុណ្ណោះ ។

៣-តំបន់ប្រើប្រាស់ដោយចីរភាព និងតំបន់សហគមន៍ ៖ ហាមឃាត់ចំពោះសកម្មភាពពាណិជ្ជកម្មធំៗ រួមមាន ការកាប់ឆ្ការព្រៃ កសិពាណិជ្ជកម្មខ្នាតធំ និងពាណិជ្ជកម្មផ្នែកវារីវប្បកម្ម ។

លើកលែងតែករណីផលប្រយោជន៍ដល់សន្តិសុខជាតិ ដែលតម្រូវឱ្យកងកម្លាំងការពារ ត្រូវចូលទៅក្នុងតំបន់ស្នូល ឬតំបន់អភិរក្សនៃតំបន់ការពារធម្មជាតិ ឬតំបន់ស្នូលនៃតំបន់ស្នូលបមនីយជីវមណ្ឌល នោះនាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវផ្តល់ការអនុញ្ញាតជាលាយល័ក្ខណ៍អក្សរ និងត្រូវជូនដំណឹងដល់ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន ។

ផែនការគ្រប់គ្រងតំបន់គ្រប់គ្រងនៃតំបន់ការពារធម្មជាតិ និងផែនការគ្រប់គ្រងតំបន់គ្រប់គ្រងនៃតំបន់ស្នូលនៃបមនីយជីវមណ្ឌល និងផែនការគ្រប់គ្រងរួមគ្នា ដូចមានចែងក្នុងមាតិកាទី២ នៃគន្ថីនេះ អាចកំណត់អំពីការហាមឃាត់នូវសកម្មភាពជាក់លាក់ និងការចេញចូលក្នុងតំបន់គ្រប់គ្រង ។

**មាត្រា៣០៧.**_ សកម្មភាពដែលអាចត្រូវបានអនុញ្ញាតនៅក្នុងតំបន់គ្រប់គ្រងនៃតំបន់ការពារធម្មជាតិ

សកម្មភាពដែលអាចត្រូវបានអនុញ្ញាតនៅក្នុងតំបន់គ្រប់គ្រងនៃតំបន់ការពារធម្មជាតិ លើកលែងតែតំបន់ស្នូលនៃបមនីយជីវមណ្ឌល មានដូចតទៅ ៖

១- តំបន់ស្នូល ៖ អនុញ្ញាតចំពោះការស្រាវជ្រាវ ការឃាមល្បាត សំណង់ដែលមិនអចិន្ត្រៃយ៍ សំណង់សមស្របតាមតំបន់ ដែលសម្រួលដល់ការគ្រប់គ្រង និងកិច្ចការស្រាវជ្រាវ ។

២- តំបន់អភិរក្ស ៖ អនុញ្ញាតចំពោះ ការស្រាវជ្រាវ ការឃាមល្បាត និងប្រតិបត្តិការទេសចរណ៍ធម្មជាតិដែលមានហេដ្ឋារចនាសម្ព័ន្ធតូចតាច និងដែលមានផលប៉ះពាល់ទាប ការប្រើប្រាស់ផលឈើ អុស និងអនុផលព្រៃឈើ ជាលក្ខណៈគ្រួសារ និងប្រពៃណី សំណង់សមស្របតាមតំបន់ ដែលសម្រួលដល់ការគ្រប់គ្រង និងកិច្ចការស្រាវជ្រាវ ។

៣- តំបន់ប្រើប្រាស់ដោយចីរភាព ៖ អនុញ្ញាតចំពោះសកម្មភាពដូចមាននៅក្នុងតំបន់អភិរក្ស និងលើសពីនេះ រួមមាន ហេដ្ឋារចនាសម្ព័ន្ធទៅតាមតំបន់សម្រាប់ប្រតិបត្តិការទេសចរណ៍ធម្មជាតិ ការចិញ្ចឹមសត្វ ការប្រើប្រាស់ដើម្បីចិញ្ចឹមជីវិត សកម្មភាពប្រមូលផល និងផលិតខ្នាតតូច រួមមានកសិកម្មព្រៃឈើ និងរុក្ខវប្បកម្មរបស់សហគមន៍ និងការប្រមូលយកផល និងអនុផលព្រៃឈើ កសិកម្មចិញ្ចឹមជីវិតជាលក្ខណៈគ្រួសារ និងការដំឡើងបណ្តាញអគ្គិសនីក្រៅបណ្តាញតចូលកម្រិតគ្រួសារ និងកម្រិតភូមិ ។

៤- តំបន់សហគមន៍៖ អនុញ្ញាតចំពោះសកម្មភាពដូចមាននៅក្នុងតំបន់ប្រើប្រាស់ដោយចីរភាព និងលើសពីនេះ រួមមាន ដីដែលមានការតាំងទីលំនៅស្រាប់ ដីស្រែ ដីដាំដំណាំ និងដីចម្ការ ។

ផែនការគ្រប់គ្រងតំបន់គ្រប់គ្រងនៃតំបន់ការពារធម្មជាតិ និងផែនការគ្រប់គ្រងតំបន់គ្រប់គ្រងនៃតំបន់ស្នូលនៃបមនីយជីវមណ្ឌល និងផែនការគ្រប់គ្រងរួមគ្នា ដូចមានចែងក្នុងមាតិកាទី២ នៃគន្លឹនេះ អាចកំណត់អំពីការអនុញ្ញាតសម្រាប់សកម្មភាពជាក់លាក់ និងការចេញចូលក្នុងតំបន់គ្រប់គ្រង ។

**មាត្រា៣០៨.**_ សកម្មភាពដែលត្រូវហាមឃាត់ ឬអនុញ្ញាតនៅក្នុងតំបន់គ្រប់គ្រងពាក់ព័ន្ធទៅនឹងសត្វ និងរុក្ខជាតិព្រៃ

ការហាមឃាត់ និងការអនុញ្ញាត សម្រាប់គ្រប់សកម្មភាពពាក់ព័ន្ធនឹងសត្វ និងរុក្ខជាតិព្រៃ ត្រូវធ្វើឡើង ស្របតាមមាតិកាទី៤ គន្លឹនេះ ។

**មាត្រា៣០៩.**_ សកម្មភាពពាណិជ្ជកម្មនៅក្នុងតំបន់ប្រើប្រាស់ដោយចីរភាព និងតំបន់សហគមន៍

ស្របតាមផែនការគ្រប់គ្រងនៃមាតិកានេះ ឬផែនការគ្រប់គ្រងរួមគ្នានៃមាតិកាទី២ នៃគន្លឹនេះ អាជ្ញាធរគ្រប់គ្រងពាក់ព័ន្ធ សម្រាប់សមាសភាគនៃប្រព័ន្ធតំបន់ការពារធម្មជាតិ អាចកំណត់យកផ្នែកណាមួយនៃតំបន់ប្រើប្រាស់ដោយចីរភាព ឬតំបន់សហគមន៍ ដែលមានសក្តានុពលផ្នែកសេដ្ឋកិច្ច និងតម្លៃប្រព័ន្ធអេកូឡូស៊ី និងតម្លៃនៃការអភិរក្សទាប ធ្វើជាតំបន់សម្រាប់សកម្មភាពពាណិជ្ជកម្ម ។

បន្ទាប់ពីមានការកំណត់ដូចខាងលើ និងនៅមុនពេលផ្តល់ការអនុញ្ញាតសម្រាប់សកម្មភាពពាណិជ្ជកម្មបែបនេះ នីតិបុគ្គលដែលពាក់ព័ន្ធត្រូវ ៖

១- បើកកិច្ចពិគ្រោះយោបល់សមរម្យជាមួយដៃគូបច្ចេកទេសពាក់ព័ន្ធ អ្នកមានផលប្រយោជន៍ពាក់ព័ន្ធ សហគមន៍មូលដ្ឋានដែលរងផលប៉ះពាល់ និងត្រូវទទួលការយល់ព្រមជាមុនពីសហគមន៍ចំពោះសកម្មភាពដែលបានស្នើសុំ ។

២- បើកបង្ហាញឲឱ្យភាគីដែលមានផលប្រយោជន៍ពាក់ព័ន្ធ បានដឹងអំពីការរៀបចំឱ្យមានថវិកា និងចំណូលដូចបានព្យាករណ៍ ពីសកម្មភាពពាណិជ្ជកម្ម ដែលបានស្នើសុំ ។

ចំណូលដែលបង្កើតបានពីសកម្មភាពពាណិជ្ជកម្មខាងលើ ត្រូវដាក់ចូលទៅក្នុងមូលនិធិបរធនបាលកិច្ចបរិស្ថានប្រចាំតំបន់ ដែលបានរៀបចំ ស្របតាមបទប្បញ្ញត្តិដូចមានចែងក្នុងគន្លឹទី៨ នៃក្រមនេះ និងត្រូវប្រើប្រាស់សម្រាប់តែផលប្រយោជន៍របស់សហគមន៍មូលដ្ឋានប្រចាំតំបន់ និងការអភិរក្សសមាសភាគពាក់ព័ន្ធនៃប្រព័ន្ធតំបន់ការពារធម្មជាតិតែប៉ុណ្ណោះ ។

**មាត្រា៣១០ .**_ ដីសម្បទានសេដ្ឋកិច្ច

សម្រាប់ដីសម្បទានសេដ្ឋកិច្ចដែលនៅជាធរមាន ហើយដែលស្ថិតនៅក្នុង ឬជាប់ទៅនឹងសមាសភាគនៃប្រព័ន្ធតំបន់ការពារធម្មជាតិ ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន ដោយសហការជាមួយក្រសួង ស្ថាប័នទទួលបន្ទុកព្រៃឈើ ត្រូវប្រើប្រាស់ដើម្បីលើកកម្ពស់គោលបំណងនៃប្រព័ន្ធតំបន់ការពារធម្មជាតិបាន ដូចបានកំណត់ក្នុងមាតិកានេះ ។

**មាត្រា៣១១** ._ការលុបចោលនូវសម្បទានដីសេដ្ឋកិច្ច

ក្រោយពីសម្បទានដីសេដ្ឋកិច្ចនៅក្នុងតំបន់ការពារធម្មជាតិ ត្រូវបានលុបចោលដីសម្បទានសេដ្ឋកិច្ចនោះ ត្រូវកំណត់ចូលទៅក្នុងតំបន់គ្រប់គ្រង ស្របតាមបទប្បញ្ញត្តិនៃក្រមនេះ ។

ក្រោយពីសម្បទានដីសេដ្ឋកិច្ចនៅក្នុងរបៀងអភិរក្សជីវៈចម្រុះ ត្រូវបានលុបចោលក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន ត្រូវចាត់វិធានការ ស្របតាមបទប្បញ្ញត្តិនៃក្រមនេះ ។

ក្រោយពីសម្បទានដីសេដ្ឋកិច្ចនៅក្រៅរបៀងអភិរក្សជីវៈចម្រុះ ត្រូវបានលុបចោល ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន អាចធ្វើការស្នើសុំកំណត់តំបន់សម្បទានដីសេដ្ឋកិច្ចដែលបានលុបចោល ជាសមាសភាគនៃប្រព័ន្ធតំបន់ការពារធម្មជាតិ ។

## មាតិកាទី២
## ការគ្រប់គ្រងធនធានធម្មជាតិរួមគ្នា
## ជំពូកទី១
## ការរៀបចំយន្តការគ្រប់គ្រងរួមគ្នា

**មាត្រា៣១២** ._វិសាលភាព

មាតិកានេះមានវិសាលភាពអនុវត្តចំពោះតំបន់ទាំងអស់ដែលមានលក្ខណៈគ្រប់គ្រាន់សម្រាប់ការអនុវត្តការគ្រប់គ្រងរួមគ្នា។

**មាត្រា៣១៣** ._ សមាសភាគនៃតំបន់ដែលមានសក្តានុពល និងលក្ខណៈសម្បត្តិគ្រប់គ្រាន់ក្នុងការបង្កើតជាតំបន់គ្រប់គ្រងរួមគ្នា

សមាសភាគប្រព័ន្ធតំបន់ការពារធម្មជាតិ សហគមន៍តំបន់ការពារធម្មជាតិ សហគមន៍ព្រៃឈើ សហគមន៍ដែលបានដាក់ពាក្យស្នើសុំបង្កើតជាសហគមន៍ព្រៃឈើរួចហើយ ឬសហគមន៍ដែលបានរៀបចំឯកសាគ្រប់គ្រាន់ដើម្បីដាក់ពាក្យសុំបង្កើតជាសហគមន៍ព្រៃឈើ សហគមន៍នេសាទ ដីសាធារណៈរបស់រដ្ឋ ឬធនធានទឹកដែលមានតម្លៃសេវាកម្មប្រព័ន្ធអេកូឡូស៊ី ដីដែលបានធ្វើចំណាត់ថ្នាក់

សម្រាប់ការគ្រប់គ្រងព្រៃឈើដោយចីរភាព និងដីអភិរក្សជាលក្ខណៈប្រពៃណីរបស់ជនជាតិដើមភាគតិច ត្រូវកំណត់ជាសមាសភាគនៃតំបន់ដែលមានសក្តានុពល និងលក្ខណៈសម្បត្តិគ្រប់គ្រាន់ក្នុងការបង្កើតជាតំបន់គ្រប់គ្រងរួមគ្នា។

**មាត្រា៣១៤** ._ ការបន្តឋានៈផ្លូវច្បាប់នៃយន្តការគ្រប់គ្រងរួមគ្នាលើធនធានធម្មជាតិរបស់សហគមន៍

យន្តការគ្រប់គ្រងរួមគ្នាលើធនធានធម្មជាតិដោយផ្អែកលើសហគមន៍ រួមមាន សហគមន៍តំបន់ការពារធម្មជាតិ សហគមន៍ព្រៃឈើ សហគមន៍នេសាទដែលមានស្រាប់ ឬកំពុងស្ថិតក្នុងដំណើរការស្នើសុំ ត្រូវរក្សាឋានៈផ្លូវច្បាប់ដដែល រហូតដល់ពេលដែលសហគមន៍ទាំងនេះបានសម្រេចចិត្តដោយស្ម័គ្រចិត្ត ដើម្បីបង្កើត ឬរួមគ្នាជាតំបន់គ្រប់គ្រងរួមគ្នា ។

ក្នុងករណីដែលសហគមន៍បានសម្រេចចិត្តដោយស្ម័គ្រចិត្តបង្កើត ឬរួមគ្នា ឬផ្លាស់ប្តូរទៅជាតំបន់គ្រប់គ្រងរួមគ្នា ឋានៈផ្លូវច្បាប់នៃសហគមន៍ទាំងនេះ ត្រូវទទួលស្គាល់ដោយស្វ័យប្រវត្តិជាសមាសភាគនៃតំបន់គ្រប់គ្រងរួមគ្នា ហើយត្រូវអនុវត្តតាមវិធាន និងបទប្បញ្ញត្តិស្តីពីការគ្រប់គ្រងរួមគ្នា ។

**មាត្រា៣១៥** ._ គោលការណ៍ណែនាំស្តីពីការគ្រប់គ្រងរួមគ្នា

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន ត្រូវរៀបចំលិខិតបទដ្ឋានគតិយុត្តស្តីពីការគ្រប់គ្រងរួមគ្នាក្នុងរយៈពេល ៣ (បី) ឆ្នាំ ក្រោយពេលក្រមនេះចូលជាធរមាន ។

## ជំពូកទី២
## នីតិវិធីបង្កើតការគ្រប់គ្រងរួមគ្នា

**មាត្រា៣១៦** ._ សិទ្ធិដើម្បីធ្វើការគ្រប់គ្រងរួមគ្នា

សហគមន៍មូលដ្ឋាន ជនជាតិដើមភាគតិច និងអង្គការសង្គមស៊ីវិលពាក់ព័ន្ធ ដោយសហការជាមួយរដ្ឋបាលថ្នាក់ក្រោមជាតិ មានសិទ្ធិដើម្បីរៀបចំ និងធ្វើការគ្រប់គ្រងរួមគ្នាលើតំបន់ដែលត្រូវធ្វើការគ្រប់គ្រងរួមគ្នា ។

**មាត្រា៣១៧** ._ ការរៀបចំការគ្រប់គ្រងរួមគ្នា

តំណាងសហគមន៍មូលដ្ឋាន ជនជាតិដើមភាគតិច រដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវកំណត់លក្ខខណ្ឌនៃការគ្រប់គ្រងរួមគ្នា ដូចខាងក្រោម ៖

១- រចនាសម្ព័ន្ធនៃការគ្រប់គ្រងរួមគ្នា ។

២- សមាជិកភាព និងសិទ្ធិបោះឆ្នោតរបស់សមាជិកសហគមន៍គ្រប់គ្រងរួមគ្នា ។

៣- សំណើកំណត់តំបន់គ្រប់គ្រង សម្រាប់តំបន់គ្រប់គ្រងរួមគ្នា និងសំណើផែនការគ្រប់គ្រងរួមគ្នា ។ ឯកសារទាំងពីរនេះ ត្រូវរៀបចំទៅតាមស្តង់ដារដែលស្របតាមសមត្ថភាព និងធនធានមូលដ្ឋាន ដែលឆ្លុះបញ្ចាំងពីចំណេះដឹង និងចក្ខុវិស័យនៃអ្នកតំណាងសហគមន៍មូលដ្ឋាន ជនជាតិដើមភាគតិច និងរដ្ឋបាលថ្នាក់ក្រោមជាតិ ដែលទទួលខុសត្រូវក្នុងការអនុវត្តការគ្រប់គ្រងរួមគ្នា ។

លក្ខខណ្ឌនៃការគ្រប់គ្រងរួមគ្នា ត្រូវស្របតាមផែនការប្រើប្រាស់ដីធ្លីជាធរមាន ដែលទាក់ទងនឹងផ្នែកណាមួយនៃតំបន់ដែលត្រូវគ្រប់គ្រងរួមគ្នា ។

ការកំណត់តំបន់គ្រប់គ្រង និងផែនការគ្រប់គ្រងសម្រាប់ការគ្រប់គ្រងរួមគ្នា ត្រូវដាក់បញ្ចូលនូវការកំណត់តំបន់គ្រប់គ្រងដែលមានស្រាប់ ការកំណត់តំបន់គ្រប់គ្រងថ្មី និងផែនការគ្រប់គ្រងដែលត្រូវរៀបចំឡើង ត្រូវស្របតាមបទប្បញ្ញត្តិស្តីពីប្រព័ន្ធតំបន់ការពារធម្មជាតិនៃក្រមនេះ ។

**មាត្រា៣១៨** ._ ការគាំទ្រសម្រាប់ការគ្រប់គ្រងរួមគ្នា

តំណាងសហគមន៍មូលដ្ឋាន ជនជាតិដើមភាគតិច រដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវសហការជាមួយក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន មន្ត្រីរាជការពាក់ព័ន្ធមកពីសមាសភាគនៃប្រព័ន្ធតំបន់ការពារធម្មជាតិ និងក្រសួង ស្ថាប័នមានសមត្ថកិច្ច ដើម្បីគាំទ្រដល់ការរៀបចំលក្ខខណ្ឌនៃការគ្រប់គ្រងរួមគ្នា ។

ក្រសួង ស្ថាប័នមានសមត្ថកិច្ចទាំងអស់ត្រូវគាំទ្រដល់តំណាងសហគមន៍មូលដ្ឋាន ជនជាតិដើមភាគតិច រដ្ឋបាលថ្នាក់ក្រោមជាតិ ក្នុងការរៀបចំលក្ខខណ្ឌនៃការគ្រប់គ្រងរួមគ្នា ។

តំណាងសហគមន៍មូលដ្ឋាន ជនជាតិដើមភាគតិច រដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវប្រើប្រាស់យោបល់បច្ចេកទេសដែលបានមកពីដៃគូបច្ចេកទេស និងអ្នកពាក់ព័ន្ធដែលមានការចាប់អារម្មណ៍ ដើម្បីរៀបចំលក្ខខណ្ឌនៃការគ្រប់គ្រងរួមគ្នា ។ តួនាទីជាក់លាក់សម្រាប់ដៃគូបច្ចេកទេសពាក់ព័ន្ធ អាចដាក់បញ្ចូលនៅក្នុងលក្ខខណ្ឌនៃការគ្រប់គ្រងរួមគ្នា ។

**មាត្រា៣១៩** ._ ការពិនិត្យលក្ខខណ្ឌនៃការគ្រប់គ្រងរួមគ្នា

នៅពេលតំណាងសហគមន៍មូលដ្ឋាន ជនជាតិដើមភាគតិច រដ្ឋបាលថ្នាក់ក្រោមជាតិ បានបំពេញតាមលក្ខខណ្ឌនៃការគ្រប់គ្រងរួមគ្នា តំណាងសហគមន៍មូលដ្ឋាន ជនជាតិដើមភាគតិច រដ្ឋបាល

ថ្នាក់ក្រោមជាតិ ត្រូវដាក់សំណើដោយភ្ជាប់លក្ខខណ្ឌទាំងនេះទៅក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន ដើម្បីបង្កើតការគ្រប់គ្រងរួមគ្នា ។

ក្រសួង ស្ថាប័នទទួលបរិស្ថាន ត្រូវពិនិត្យ និងផ្តល់យោបល់លើលក្ខខណ្ឌនៃការគ្រប់គ្រងរួមគ្នា ស្របតាមលក្ខណៈវិនិច្ឆ័យ និងនីតិវិធី ក្នុងរយៈពេលបីខែ បន្ទាប់ពីទទួលបានសំណើសុំរៀបចំការគ្រប់គ្រងរួមគ្នា ។

មតិយោបល់ទាំងនេះ រួមមាន ៖

១- សេចក្តីសម្រេច ដើម្បីផ្តួចផ្តើមគំនិតក្នុងការគ្រប់គ្រងរួមគ្នាក្នុងតំបន់ស្នើសុំ ។

២- សេចក្តីសម្រេច ដើម្បីផ្តួចផ្តើមគំនិតក្នុងការគ្រប់គ្រងរួមគ្នា នៅក្នុងតំបន់ស្នើសុំ បន្ទាប់ពីបានដាក់បញ្ចូលមតិយោបល់របស់ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថានទៅក្នុងលក្ខខណ្ឌនៃការគ្រប់គ្រងរួមគ្នានោះ ឬ

៣- សេចក្តីណែនាំ ដើម្បីកែសម្រួលលើលក្ខខណ្ឌនៃការគ្រប់គ្រងរួមគ្នា ក្នុងការដាក់សំណើសុំពិនិត្យ និងផ្តល់យោបល់សាជាថ្មី ។

ក្នុងករណីមានការដាក់សំណើស្នើសុំពិនិត្យ និងផ្តល់យោបល់សាជាថ្មី ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន ត្រូវពិនិត្យលើលក្ខខណ្ឌនៃការគ្រប់គ្រងរួមគ្នាដែលបានកែសម្រួល ក្នុងរយៈពេលបីខែ បន្ទាប់ពីបានទទួលសំណើស្នើសុំនេះ ។

ឯកសារទាំងអស់ដែលទាក់ទងនឹងលក្ខខណ្ឌនៃការគ្រប់គ្រងរួមគ្នា ត្រូវដាក់ឱ្យសាធារណៈជនអាចស្វែងបាន ។

**មាត្រា៣២០** ._ លិខិតបទដ្ឋានគតិយុត្តស្តីពីការគ្រប់គ្រងរួមគ្នា

ក្រសួង ស្ថាប័នទទួលបរិស្ថាន ត្រូវរៀបចំសំណើស្នើសុំបង្កើតការគ្រប់គ្រងរួមគ្នា ទៅកាន់រាជរដ្ឋាភិបាល ក្នុងរយៈពេល ៣០ (សាមសិប) ថ្ងៃ បន្ទាប់ពីមានការផ្តួចផ្តើមគំនិតឱ្យមានការគ្រប់គ្រងរួមគ្នា ។

ក្រោយពីទទួលបានសំណើស្នើសុំបង្កើតការគ្រប់គ្រងរួមគ្នា រាជរដ្ឋាភិបាល ត្រូវចេញលិខិតបទដ្ឋានគតិយុត្ត ដូចខាងក្រោម ៖

១- បង្កើតអាជ្ញាធរគ្រប់គ្រងរួមគ្នា ជានីតិបុគ្គលសាធារណៈ ។

២- កំណត់ពីភារកិច្ច និងតួនាទីរបស់អាជ្ញាធរគ្រប់គ្រងរួមគ្នា រួមមានសិទ្ធិគ្រប់គ្រងមូលនិធិ ចុះកិច្ចព្រមព្រៀង ធ្វើប្រតិបត្តិការ និងបង្កើតប្រាក់ចំណូល និងចុះបញ្ជីដីធ្លីជាមួយរដ្ឋបាលសុរិយោដី ក្នុងនាមជាអាជ្ញាធរកាន់កាប់ដីរដ្ឋនៅក្នុងតំបន់គ្រប់គ្រងរួមគ្នា ។

៣- ទទួលស្គាល់តំបន់គ្រប់គ្រងរួមគ្នា ។

រាល់ការចុះកិច្ចព្រមព្រៀង ឬការផ្តល់ការធ្វើប្រតិបត្តិការផ្នែកពាណិជ្ជកម្ម ដែលអនុញ្ញាត ទៅឱ្យអ្នករស់នៅក្រៅតំបន់គ្រប់គ្រងរួមគ្នា ចេញចូលតំបន់គ្រប់គ្រងរួមគ្នា ក្នុងការធ្វើអាជីវកម្មលើធនធានធម្មជាតិ ត្រូវទទួលការអនុញ្ញាតពីក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន ។

អាណត្តិនៃអាជ្ញាធរគ្រប់គ្រងរួមគ្នាមានរយៈពេលមិនកំណត់ ។

**មាត្រា៣២១** ._ កិច្ចព្រមព្រៀងស្តីពីការគ្រប់គ្រងរួមគ្នា

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងអាជ្ញាធរគ្រប់គ្រងរួមគ្នា ត្រូវចុះកិច្ចព្រមព្រៀងគ្រប់គ្រងរួមគ្នា ក្នុងរយៈពេល ៣ (បី) ខែ បន្ទាប់ពីរាជរដ្ឋាភិបាលបានផ្តល់ការឯកភាពលើការគ្រប់គ្រងរួមគ្នា ។

ភារកិច្ច និងតួនាទីរបស់ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងអាជ្ញាធរគ្រប់គ្រងរួមគ្នានៅក្នុងតំបន់គ្រប់គ្រងរួមគ្នា ត្រូវកំណត់នៅក្នុងកិច្ចព្រមព្រៀងស្តីពីការគ្រប់គ្រងរួមគ្នា ។

កិច្ចព្រមព្រៀងស្តីពីការគ្រប់គ្រងរួមគ្នា មានរយៈពេលមិនកំណត់ ហើយអាចធ្វើការដកហូតវិញក្នុងករណីមានការបំពានលើលក្ខខណ្ឌដែលមានចែងនៅក្នុងកិច្ចព្រមព្រៀងស្តីពីការគ្រប់គ្រងរួមគ្នា ។

ឯកសារទាំងអស់ដែលទាក់ទងនឹងការឯកភាពលើលក្ខខណ្ឌនៃការគ្រប់គ្រងរួមគ្នា និងកិច្ចព្រមព្រៀងស្តីពីការគ្រប់គ្រងរួមគ្នា ត្រូវដាក់ឱ្យសាធារណៈជនអាចស្វែងបាន ។

## ជំពូកទី៣
## ការអនុវត្តការគ្រប់គ្រងរួមគ្នា

**មាត្រា៣២២** ._ ក្របខ័ណ្ឌនៃការអនុវត្តការគ្រប់គ្រងរួមគ្នា

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន មានសិទ្ធិពិនិត្យ និងអង្កេតតាមដានការអនុវត្តការគ្រប់គ្រងរួមគ្នា ។

អាជ្ញាធរគ្រប់គ្រងរួមគ្នា ត្រូវរៀបចំរបាយការណ៍ប្រចាំឆ្នាំជូនក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន ដោយពិពណ៌នាអំពីសកម្មភាព និងលទ្ធផលនៃការអនុវត្តការងាររបស់ខ្លួន ។

**មាត្រា៣២៣** ._ ការលើកកម្ពស់ និងការគាំទ្រការគ្រប់គ្រងរួមគ្នា

ក្រសួង ស្ថាប័នមានសមត្ថកិច្ច ត្រូវចាត់វិធានការចាំបាច់ ដើម្បីគាំទ្រការអនុវត្តការគ្រប់គ្រងរួមគ្នា នៅក្នុងតំបន់ដែលស្ថិតក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ឬ នៅក្នុងតំបន់ដែលក្រសួង ស្ថាប័នមានសមត្ថកិច្ចនោះ បែងចែកសិទ្ធិអំណាចជាមួយក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន ឬ រដ្ឋបាលថ្នាក់ក្រោមជាតិ ។

**មាត្រា៣២៤ .**_ ការហាមឃាត់ចំពោះសកម្មភាពដែលបំពានលើកិច្ចព្រមព្រៀងគ្រប់គ្រងរួមគ្នា

បុគ្គលគ្រប់រូបមិនត្រូវធ្វើសកម្មភាពណាមួយ ដែលផ្ទុយនឹងកិច្ចព្រមព្រៀងគ្រប់គ្រងរួមគ្នា ដែលទទួលបានការឯកភាពឡើយ ។

**មាត្រា៣២៥ .**_ ការលុបចោលកិច្ចព្រមព្រៀងស្តីការគ្រប់គ្រងរួមគ្នា និងការរំលាយអាជ្ញាធរគ្រប់គ្រងរួមគ្នា

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន មានសិទ្ធិលប់ចោលកិច្ចព្រមព្រៀងស្តីពីការគ្រប់គ្រងរួមគ្នា ឬតំបន់គ្រប់គ្រងរួមគ្នា ក្នុងករណីដូចខាងក្រោម ៖

១- មានការបំពានធ្ងន់ធ្ងរលើកិច្ចព្រមព្រៀងគ្រប់គ្រងរួមគ្នា ។

២- មានការបំពានច្បាប់ធ្ងន់ធ្ងរ នៅក្នុងការអនុវត្តការគ្រប់គ្រងរួមគ្នា ។

ក្នុងករណីដែលមានការលុបចោលកិច្ចព្រមព្រៀងរួមគ្នា ឬតំបន់គ្រប់គ្រងរួមគ្នា ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន មានសិទ្ធិស្នើសុំឱ្យរាជរដ្ឋាភិបាលរំលាយអាជ្ញាធរគ្រប់គ្រងរួមគ្នា ។

មុនពេលចេញសេចក្តីសម្រេចលុបចោលកិច្ចព្រមព្រៀងស្តីការគ្រប់គ្រងរួមគ្នា ឬតំបន់គ្រប់គ្រងរួមគ្នា និងការរំលាយអាជ្ញាធរគ្រប់គ្រងរួមគ្នា ភាគីពាក់ព័ន្ធទាំងអស់ត្រូវជួបគ្នាដើម្បីពិភាក្សា និងស្វែងរកដំណោះស្រាយដោយសន្តិវិធីជាមុនសិន ។

អាជ្ញាធរគ្រប់គ្រងរួមគ្នាដែលទទួលរងផលប៉ះពាល់ដោយសារការលុបចោលកិច្ចព្រមព្រៀងស្តីការគ្រប់គ្រងរួមគ្នា និងការរំលាយអាជ្ញាធរគ្រប់គ្រងរួមគ្នា មានសិទ្ធិធ្វើបណ្តឹងតវ៉ា ស្របតាមបទប្បញ្ញត្តិនៃក្រមនេះ ។

## ជំពូកទី៤
## រយៈពេលនៃការគ្រប់គ្រងរួមគ្នា និងសិទ្ធិលើដីធ្លី

**មាត្រា៣២៦ .**_ អាណត្តិកាន់កាប់ និងប្រើប្រាស់ដីរដ្ឋនៃតំបន់គ្រប់គ្រងរួមគ្នា

ក្រោយពេលទទួលបានការឯកភាពលើកិច្ចព្រមព្រៀងស្តីពីការគ្រប់គ្រងរួមគ្នា អាជ្ញាធរគ្រប់គ្រងរួមគ្នា មានសិទ្ធិកាន់កាប់ ប្រើប្រាស់ និងអាស្រ័យផលលើដីរដ្ឋនៅក្នុងតំបន់គ្រប់គ្រងរួមគ្នា។

អាណត្តិនៃការកាន់កាប់ ប្រើប្រាស់ និងអាស្រ័យផលលើដីរដ្ឋនៅក្នុងតំបន់គ្រប់គ្រងរួមគ្នា មិនត្រូវរារាំងសិទ្ធិរបស់មន្ត្រីនៃក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថានមិនឱ្យចូល និងអនុវត្តការងាររបស់ខ្លួននៅក្នុងតំបន់នៃការគ្រប់គ្រងរួមគ្នាឡើយ ។

អាជ្ញាធរគ្រប់គ្រងរួមគ្នា ពុំមានសិទ្ធិក្នុងការលក់ ផ្ទេរសិទ្ធិនៃការកាន់កាប់ ប្រើប្រាស់ អាស្រ័យផលលើដីរដ្ឋនេះទៅឱ្យតតិយជន ឬនីតិបុគ្គលណាមួយឡើយ ប៉ុន្តែអាជ្ញាធរគ្រប់គ្រងរួមគ្នាមានសិទ្ធិក្នុងការផ្ទេរការកាន់កាប់ ប្រើប្រាស់ និងអាស្រ័យផលទៅឱ្យសមាជិកដទៃទៀត ដែលរស់នៅក្នុងតំបន់គ្រប់គ្រងរួមគ្នា ដែលបានកំណត់នៅក្នុងកិច្ចព្រមព្រៀងស្តីពីការគ្រប់គ្រងរួមគ្នា ។

**មាត្រា៣២៧**._ ខ្លឹមសារនៃអាណត្តិកាន់កាប់ និងប្រើប្រាស់ដីរដ្ឋនៃតំបន់គ្រប់គ្រងរួមគ្នា

អាណត្តិកាន់កាប់ និងប្រើប្រាស់ដីរដ្ឋនៃតំបន់គ្រប់គ្រងរួមគ្នា រួមមាន សិទ្ធិរបស់សហគមន៍នៅក្នុងតំបន់គ្រប់គ្រងរួមគ្នា ក្នុងការរស់នៅ អភិរក្ស គ្រប់គ្រង ប្រើប្រាស់ និងទទួលផលពីការប្រើប្រាស់ធនធានធម្មជាតិដោយចីរភាព ស្របតាមលក្ខណៈប្រពៃណី នៅក្នុងតំបន់គ្រប់គ្រងរួមគ្នា និងផែនការគ្រប់គ្រងរួមគ្នាដែលទទួលបានការឯកភាព ។

អាជ្ញាធរគ្រប់គ្រងរួមគ្នា ដែលទទួលបានអាណត្តិកាន់កាប់ និងប្រើប្រាស់ដីរដ្ឋនៃតំបន់គ្រប់គ្រងរួមគ្នា មានសិទ្ធិក្នុងការហាមឃាត់បុគ្គលណាម្នាក់ មិនឱ្យធ្វើសកម្មភាពណាមួយ ដោយគ្មានការយល់ព្រមជាលាយលក្ខណ៍អក្សរជាមុនពីអាជ្ញាធរគ្រប់គ្រងរួមគ្នា ដូចខាងក្រោម ៖

១- ចេញចូលតំបន់គ្រប់គ្រងរួមគ្នា

២- ធ្វើសកម្មភាពពាណិជ្ជកម្មនៅក្នុងតំបន់គ្រប់គ្រងរួមគ្នា ឬ

៣- ប្រើប្រាស់ធនធាននៅក្នុងតំបន់គ្រប់គ្រងរួមគ្នា ចំពោះបុគ្គលដែលមិនមែនជាសមាជិកសហគមន៍គ្រប់គ្រងរួមគ្នា ។

សំណើស្នើសុំចេញចូល និងប្រើប្រាស់ធនធាននៅក្នុងតំបន់គ្រប់គ្រងរួមគ្នារបស់អ្នកក្រៅ ដែលមិនមែនជាសមាជិកសហគមន៍គ្រប់គ្រងរួមគ្នា ត្រូវអនុវត្តតាមបទប្បញ្ញត្តិស្តីពីការចូលរួមជាសាធារណៈ និងសិទ្ធិទទួលបានព័ត៌មាននៃក្រមនេះ ។

**មាត្រា៣២៨**._ រយៈពេលនៃអាណត្តិកាន់កាប់ និងប្រើប្រាស់ដីរដ្ឋនៃតំបន់គ្រប់គ្រងរួមគ្នា

រយៈពេលអាណត្តិកាន់កាប់ និងប្រើប្រាស់ដីរដ្ឋនៃតំបន់គ្រប់គ្រងរួមគ្នា មានសុពលដូចគ្នាទៅនឹងរយៈពេលនៃតំបន់គ្រប់គ្រងរួមគ្នា ។

**មាត្រា៣២៩ ._** ការលុបចោលអាណត្តិកាន់កាប់ និងប្រើប្រាស់ដីរដ្ឋនៃតំបន់គ្រប់គ្រងរួមគ្នា

ការលុបចោលកិច្ចព្រមព្រៀងគ្រប់គ្រងរួមគ្នា ឬតំបន់គ្រប់គ្រងរួមគ្នា នាំឱ្យមានការលុបចោលអាណត្តិកាន់កាប់ និងប្រើប្រាស់ដីរដ្ឋនៃតំបន់គ្រប់គ្រងរួមគ្នា ។

ប៉ុន្តែ ក្នុងករណីដែលភាគីណាមួយដែលមិនមែនជាសហគមន៍ មិនគោរពតាមផែនការគ្រប់គ្រងរួមគ្នា និងវិធាន និងបទប្បញ្ញត្តិផ្សេងទៀតស្តីពីការគ្រប់គ្រងរួមគ្នា ឬកិច្ចព្រមព្រៀងស្តីពីការគ្រប់គ្រងរួមគ្នា មិននាំឱ្យមានការលុបចោលអាណត្តិកាន់កាប់ និងប្រើប្រាស់ដីរដ្ឋនៃតំបន់គ្រប់គ្រងរួមគ្នានោះទេ ។

**មាត្រា៣៣០ ._** សិទ្ធិបន្ថែម

អាណត្តិកាន់កាប់ និងប្រើប្រាស់ដីរដ្ឋនៃតំបន់គ្រប់គ្រងរួមគ្នា ត្រូវជាសិទ្ធិបន្ថែមលើសិទ្ធិដទៃទៀតដែលសហគមន៍ជនជាតិដើមភាគតិចទទួលបាន ស្របតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន ។

**មាត្រា៣៣១ ._** ការរៀបចំសមាសភាគនៃប្រព័ន្ធតំបន់ការពារធម្មជាតិ

ការរៀបចំសមាសភាគនៃប្រព័ន្ធតំបន់ការពារធម្មជាតិនាពេលបច្ចុប្បន្ន និងក្នុងពេលអនាគតនៅក្នុងតំបន់ណាមួយដែលជនជាតិដើមភាគតិចរស់នៅ មិនត្រូវបង្កជាឧបសគ្គដល់ជនជាតិដើមភាគតិចក្នុងការធ្វើសកម្មភាពបណ្តឹងទាមទារចំពោះដីធ្លី ឬធនធានដទៃទៀត ក្នុងពេលបច្ចុប្បន្ន ឬក្នុងពេលអនាគត ស្របតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមានឡើយ ។

## ជំពូកទី៥
## បទប្បញ្ញត្តិស្តីពីហិរញ្ញវត្ថុនៃការគ្រប់គ្រងរួមគ្នា

**មាត្រា៣៣២ ._** មូលនិធិបរធនបាលកិច្ចបរិស្ថានសម្រាប់ការគ្រប់គ្រងរួមគ្នា

មូលនិធិបរធនបាលកិច្ចបរិស្ថាន ត្រូវរៀបចំឡើងស្របតាមបទប្បញ្ញត្តិស្តីពីមូលនិធិបរធនបាលកិច្ចបរិស្ថាននៃក្រមនេះ សម្រាប់តំបន់គ្រប់គ្រងរួមគ្នានីមួយៗ ដើម្បីគាំទ្រដល់ការអនុវត្តសកម្មភាពគ្រប់គ្រងរួមគ្នា ។

មូលនិធិបរធនបាលកិច្ចបរិស្ថាន ត្រូវស្ថិតក្រោមការត្រួតពិនិត្យ ការគ្រប់គ្រងដោយតម្លាភាពរបស់អាជ្ញាធរគ្រប់គ្រងរួមគ្នា នៃតំបន់គ្រប់គ្រងរួមគ្នានីមួយៗ ស្របតាមបទប្បញ្ញត្តិនៃក្រមនេះ ។

អាជ្ញាធរគ្រប់គ្រងរួមគ្នា អាចទទួលមូលនិធិ និងទទួលបានចំណូលពីប្រភពសាធារណៈ និងឯកជនដូចខាងក្រោម ៖

១- មូលនិធិបរិស្ថាន និងសង្គម ។

២- ពន្ធ ការជួល និងការប្រើប្រាស់ កម្រៃសេវានៃការកំសាន្ត ឬការចេញចូល ។

៣- អំណោយ ទាយជ្ជទាន និងជំនួយ ។

៤- យន្តការហិរញ្ញប្បទានដោយចីរភាព សម្រាប់ការបង់ថ្លៃសេវាកម្មប្រព័ន្ធអេកូឡូស៊ីដែលមានប្រភពមកពីតំបន់គ្រប់គ្រងរួមគ្នា ។

៥- ផ្សេងៗទៀត ។

**មាត្រា៣៣៣** ._ ការលើកលែងពន្ធ និងការប្រើប្រាស់ចំណូល ថ្លៃសេវា ឬការបរិច្ចាគ

ចំណូល ថ្លៃសេវា ឬការបរិច្ចាគ ដែលទទួលបានមកពីការអនុវត្តសកម្មភាពនៅក្នុងតំបន់គ្រប់គ្រងរួមគ្នា ត្រូវប្រើប្រាស់ផ្តាច់មុខ សម្រាប់ ៖

១- ជាប្រយោជន៍ដល់សហគមន៍មូលដ្ឋាននៅក្នុងតំបន់គ្រប់គ្រងរួមគ្នា ។

២- គាំទ្រសកម្មភាពគ្រប់គ្រងរួមគ្នា ។

៣- ការអភិរក្សតំបន់គ្រប់គ្រងរួមគ្នា និងតំបន់ក្បែរគ្នា ដែលមានមុខងារអភិរក្សដូចគ្នា ។

នីតិវិធីនៃការបែងចែកប្រាក់ចំណូល ថ្លៃសេវា ឬការបរិច្ចាគ ត្រូវកំណត់នៅក្នុងកិច្ចព្រមព្រៀងស្តីពីការគ្រប់គ្រងរួមគ្នា ។

ប្រាក់ចំណូល ថ្លៃសេវា ឬការបរិច្ចាគ ដែលទទួលបានមកពីការអនុវត្តសកម្មភាពនៅក្នុងតំបន់គ្រប់គ្រងរួមគ្នា ត្រូវទទួលបានលើកលែងពន្ធ និងអាករ សួយសារ និងថ្លៃសេវាផ្សេងៗទៀត ដែលបានកំណត់ដោយច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន ។

## មាតិកាទី៣
## ការគ្រប់គ្រងព្រៃឈើដោយចីរភាព
## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**មាត្រា៣៣៤** ._ វិសាលភាព

មាតិកានេះមានវិសាលភាពអនុវត្តចំពោះព្រៃដាំ ព្រៃធម្មជាតិ ដែលមានទីតាំងស្ថិតនៅក្រៅប្រព័ន្ធតំបន់ការពារធម្មជាតិ ។

មាតិកានេះមិនមានវិសាលភាពអនុវត្តចំពោះព្រៃលិចទឹក ឬព្រៃដែលកាន់កាប់ដោយជនជាតិដើមភាគតិច ស្របតាមសិទ្ធិសម្ភូហភាព និងសិទ្ធិប្រើប្រាស់ជាលក្ខណៈប្រពៃណី ។

**មាត្រា៣៣៥** ._ តួនាទី និងភារកិច្ចរបស់ក្រសួង ស្ថាប័នទទួលបន្ទុក

ក្រសួង ស្ថាប័នមានសមត្ថកិច្ច ដែលទទួលបន្ទុកគ្រប់គ្រងព្រៃឈើ ត្រូវសហការជាមួយរដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បី ៖

១- ត្រួតពិនិត្យការស្តារឡើងវិញ ការអភិរក្ស ការគ្រប់គ្រងព្រៃឈើដោយចីរភាព ។

២- ចុះបញ្ជិកាធនធានព្រៃឈើ វិភាគ និងរក្សាទុកទិន្នន័យ និងធ្វើបច្ចុប្បន្នភាពទិន្នន័យតាមពេលកំណត់ ដើម្បីរៀបចំស្តង់ដារដែលត្រូវប្រើប្រាស់ ដើម្បីធ្វើការគ្រប់គ្រងព្រៃឈើដោយចីរភាព ។

៣- ស្តារឡើងវិញនូវដីព្រៃរេចរឹល ដើម្បីផ្តល់សេវាកម្មប្រព័ន្ធអេកូឡូស៊ី និងធ្វើការដាំព្រៃឈើថ្មី និងដាំព្រៃឈើឡើងវិញ ដើម្បីលើកកម្ពស់ និងសម្រេចបាននូវយន្តការកាត់បន្ថយការបញ្ចេញឧស្ម័នពីការបាត់បង់ និងការរេចរឹលព្រៃឈើ និងគោលដៅអភិរក្ស ។

៤- កំណត់ និងធ្វើផែនទីព្រំប្រទល់ដីព្រៃ ដោយបញ្ជាក់ពីឋានៈផ្លូវច្បាប់នៃដីទាំងនេះ និងដាក់បញ្ចូលសិទ្ធិកាន់កាប់ និងប្រើប្រាស់ដីជាលក្ខណៈប្រពៃណីដែលមានស្រាប់ ។

៥- ជំរុញឱ្យមានការចូលរួមពីសហគមន៍មូលដ្ឋាន និងជនជាតិដើមភាគតិច និងលើកកម្ពស់ការចូលរួមជាសាធារណៈ នៅក្នុងការគ្រប់គ្រងព្រៃឈើដោយចីរភាព ។

៦- ធ្វើការពិគ្រោះយល់លើគម្រោងស្ថាបនាផ្លូវសាធារណៈ និងផ្លូវព្រៃ នៅក្នុងព្រៃ ។

៧- ចូលរួមនៅក្នុងកម្មវិធីផ្តល់វិញ្ញាបនបត្រគ្រប់គ្រង និងផលិតផលព្រៃឈើអន្តរជាតិ ។

៨- អនុវត្តនូវទម្លាប់នៃវិធីរក្សាភស្តុតាងទាក់ទងនឹងផល និងអនុផលព្រៃឈើ ស្របតាមស្តង់ដារ និងគោលការណ៍ណែនាំជាតិ និងអន្តរជាតិ ។

៩- រៀបចំ និងអនុវត្តវិធានការ ដោយសហការជាមួយក្រសួង ស្ថាប័នមានសមត្ថកិច្ច សហគមន៍មូលដ្ឋាន ដៃគូបច្ចេកទេស ដើម្បីការពារព្រៃឈើជាលក្ខណៈប្រព័ន្ធ ពីការតាំងទីលំនៅ និងការប្រើប្រាស់ដោយគ្មានការអនុញ្ញាត ឬដោយខុសច្បាប់ និងសកម្មភាពខុសច្បាប់ដទៃទៀត ។

១០- សម្របសម្រួល និងជួយក្នុងការស៊ើបអង្កេត ការទប់ស្កាត់ និងការបង្ក្រាបបទល្មើសព្រៃឈើ ។

១១- អភិវឌ្ឍសមត្ថភាពនៃការឆ្លើយតបជាបន្ទាន់ និងចាត់វិធានការទាន់ពេលវេលាបន្ទាប់ពីទទួលបានព័ត៌មានអំពីបទល្មើសព្រៃឈើ ។

១២- រៀបចំរបាយការណ៍ និងការអង្កេតតាមដានបទល្មើសព្រៃឈើ ។

១៣- បង្កើតយន្តការមូលនិធិថ្មី ដើម្បីគាំទ្រការអនុវត្តការគ្រប់គ្រងព្រៃឈើដោយចីរភាព និង

១៤- ធ្វើឱ្យមានតម្លាភាពក្នុងការគ្រប់គ្រងព្រៃឈើដោយចីរភាព ។

## ជំពូកទី២
## ការរៀបចំផែនការគ្រប់គ្រងព្រៃឈើដោយចីរភាព

**មាត្រា៣៣៦** ._ ការចុះបញ្ជិកា និងការធ្វើផែនទី

ក្រសួង ស្ថាប័នមានសមត្ថកិច្ចទទួលបន្ទុកគ្រប់គ្រងព្រៃឈើ ដោយសហការជាមួយរដ្ឋបាលថ្នាក់ក្រោមជាតិ សហគមន៍មូលដ្ឋាន ជនជាតិដើមភាគតិច និងដៃគូបច្ចេកទេស ត្រូវចុះបញ្ជិកាធនធានលក្ខខណ្ឌ និងសក្តានុពលព្រៃឈើ ដើម្បីបង្កើតព័ត៌មានជាមូលដ្ឋានដែលមានលក្ខណៈវិទ្យាសាស្ត្រ និងបច្ចេកទេសស្តីពីស្ថានភាពព្រៃឈើ និងរក្សាទុកទិន្នន័យទាំងនេះដើម្បីរៀបចំផែនការគ្រប់គ្រង ។ ការចុះបញ្ជិកាព្រៃឈើ ត្រូវអនុវត្តនៅថ្នាក់ក្រោមជាតិ ហើយត្រូវដាក់បញ្ចូលក្នុងបញ្ជិកាព្រៃឈើថ្នាក់ជាតិ ។

ក្រសួង ស្ថាប័នមានសមត្ថកិច្ចទទួលបន្ទុកគ្រប់គ្រងព្រៃឈើ ដោយសហការជាមួយក្រសួង ស្ថាប័នទទួលបន្ទុករៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងពិគ្រោះយោបល់ជាមួយរដ្ឋបាលថ្នាក់ក្រោមជាតិ សហគមន៍មូលដ្ឋាន ជនជាតិដើមភាគតិច និងដៃគូបច្ចេកទេស ត្រូវរៀបចំផែនទីថ្នាក់ជាតិស្តីពីដីព្រៃ ដោយផ្អែកលើបញ្ជិកាព្រៃឈើ ។ ផែនទីនេះត្រូវបង្ហាញពីប្រភេទនៃតំបន់ព្រៃឈើនីមួយៗស្របតាមបទប្បញ្ញត្តិនៃក្រមនេះ ។

ដំណើរការនៃការចុះបញ្ជិកា និងការធ្វើផែនទី ត្រូវផ្តល់ឱកាសឱ្យមានការចូលរួមជាសាធារណៈស្របតាមបទប្បញ្ញត្តិនៃក្រមនេះ ។

**មាត្រា៣៣៧** ._ ផែនការគ្រប់គ្រងព្រៃឈើ

ក្រសួង ស្ថាប័នមានសមត្ថកិច្ចទទួលបន្ទុកគ្រប់គ្រងព្រៃឈើ ត្រូវរៀបចំ និងត្រួតពិនិត្យលើការរៀបចំផែនការគ្រប់គ្រងព្រៃឈើសម្រាប់គ្រប់គ្រងព្រៃឈើដែលស្ថិតក្រោមសមត្ថកិច្ចរបស់ខ្លួន ។

ក្រសួង ស្ថាប័នមានសមត្ថកិច្ចទទួលបន្ទុកគ្រប់គ្រងព្រៃឈើ ត្រូវរៀបចំកិច្ចពិគ្រោះយោបល់ដោយឡែក និងពិសេសសម្រាប់តំបន់ដែលមានជនជាតិដើមភាគតិចរស់នៅ ឬដែលមានជាប់ពាក់ព័ន្ធនឹងផលប្រយោជន៍សម្ពហាភាពរបស់ជនជាតិដើមភាគតិចដើម្បីបញ្ជាក់ថាមានការឱ្យតម្លៃចំពោះផលប្រយោជន៍ និងសិទ្ធិជាលក្ខណៈប្រពៃណី និងទំនៀមទម្លាប់របស់ពួកគេ ។

សេចក្ដីលម្អិត និងដំណើការសម្រាប់ការរៀបចំ និងអនុវត្តផែនការគ្រប់គ្រងរួមគ្នាសម្រាប់តំបន់ព្រៃឈើនីមួយៗ ត្រូវកំណត់ដោយលិខិតបទដ្ឋានគតិយុត្តរបស់ក្រសួង ស្ថាប័នមានសមត្ថកិច្ចទទួលបន្ទុកគ្រប់គ្រងព្រៃឈើ ។

ដំណើរការនៃការរៀបចំ និងធ្វើបច្ចុប្បន្នភាពលើផែនការគ្រប់គ្រងព្រៃឈើ ត្រូវផ្ដល់ឱកាសឱ្យមានការចូលរួមជាសាធារណៈ ។

**មាត្រា៣៣៨** ._ សម្បទានដីសេដ្ឋកិច្ច

ក្រសួង ស្ថាប័នមានសមត្ថកិច្ចទទួលបន្ទុកគ្រប់គ្រងព្រៃឈើ ត្រូវតម្រូវឱ្យសម្បទានដីសេដ្ឋកិច្ចដែលនៅជាធរមាន នៅក្នុង និងក្បែរតំបន់ព្រៃឈើ អនុវត្តតាមបទប្បញ្ញត្តិស្ដីពីការគ្រប់គ្រងព្រៃឈើដោយចីរភាពនៃក្រមនេះ ។

**មាត្រា៣៣៩** ._ ការស្ដារព្រៃឈើឡើងវិញ ការដាំព្រៃឈើថ្មី និងការដាំព្រៃឈើឡើងវិញ

ក្រសួង ស្ថាប័នមានសមត្ថកិច្ចទទួលបន្ទុកគ្រប់គ្រងព្រៃឈើ ត្រូវស្ដារព្រៃឈើរេចរឹលឡើងវិញ និងធ្វើការដាំព្រៃឈើថ្មី និងការដាំព្រៃឈើឡើងវិញ ស្របតាមទម្លាប់ដែលទទួលស្គាល់ជាអន្តរជាតិ ។

ម្ចាស់គម្រោងដែលបានធ្វើសកម្មភាពនៅក្នុងតំបន់ព្រៃឈើ ហើយបានធ្វើឱ្យថយចុះនូវគម្របព្រៃឈើ ឬធ្វើឱ្យរេចរឹលព្រៃឈើ ត្រូវធ្វើការស្ដារព្រៃឈើឡើងវិញ ការដាំព្រៃឈើថ្មី និងការដាំព្រៃឈើឡើងវិញ ឱ្យបានសមាមាត្រទៅនឹងទំហំព្រៃឈើដែលបានថយចុះ ឬរេចរឹលនោះ ។

ក្រសួង ស្ថាប័នមានសមត្ថកិច្ចទទួលបន្ទុកគ្រប់គ្រងព្រៃឈើ ត្រូវផ្ដល់អាទិភាពលើការប្រើប្រាស់ប្រភេទឈើ និងសារពើរុក្ខជាតិក្នុងស្រុក ដើម្បីធ្វើការស្ដារព្រៃឈើឡើងវិញ ការដាំព្រៃឈើថ្មី និងការដាំព្រៃឈើឡើងវិញ ។

ក្រសួង ស្ថាប័នមានសមត្ថកិច្ចទទួលបន្ទុកគ្រប់គ្រងព្រៃឈើ ត្រូវរៀបចំលិខិតបទដ្ឋានគតិយុត្តដើម្បីកំណត់អំពីលក្ខខណ្ឌតម្រូវ និងនីតិវិធីក្នុងការស្ដារព្រៃឈើឡើងវិញ ការដាំព្រៃឈើថ្មី និងការដាំ

ព្រៃឈើឡើងវិញ ក្នុងរយៈពេល ១ (មួយ) ឆ្នាំ ក្រោយពេលក្រមនេះចូលជាធរមាន ។

**មាត្រា៣៤០** ._ កសិរុក្ខវប្បកម្ម

ក្រសួង ស្ថាប័នមានសមត្ថកិច្ចទទួលបន្ទុកគ្រប់គ្រងព្រៃឈើ ត្រូវលើកទឹកចិត្តចំពោះការអនុវត្ត កសិរុក្ខវប្បកម្ម ដើម្បីលើកកម្ពស់ការប្រើប្រាស់ដីព្រៃឱ្យកាន់តែមានចីរភាព និងមានផលិតភាពបន្ថែមទៀត ។

ក្រសួង ស្ថាប័នមានសមត្ថកិច្ចទទួលបន្ទុកគ្រប់គ្រងព្រៃឈើ ត្រូវរៀបចំលិខិតបទដ្ឋានគតិយុត្ត ស្តីពីលក្ខខណ្ឌតម្រូវ និងនីតិវិធីសម្រាប់ការអនុវត្តកសិរុក្ខវប្បកម្ម គ្រឿងលើកទឹកចិត្តផ្នែកហិរញ្ញវត្ថុ និង សារពើពន្ធ ។

**មាត្រា៣៤១** ._ ចម្ការព្រៃឈើ

ក្រសួង ស្ថាប័នមានសមត្ថកិច្ចទទួលបន្ទុកគ្រប់គ្រងព្រៃឈើ ត្រូវលើកទឹកចិត្តប្រជាពលរដ្ឋ និង ម្ចាស់គម្រោងឱ្យធ្វើការដាំ និងរក្សាទុកចម្ការព្រៃឈើ ដើម្បីផ្តល់ជាប្រភពផល និងអនុផលព្រៃឈើ និង ដើម្បីចូលរួមចំណែកក្នុងការអភិរក្សតម្លៃវប្បធម៌ សង្គមដែលមានទំនាក់ទំនងទៅនឹងព្រៃឈើនោះ ។

ក្រសួង ស្ថាប័នមានសមត្ថកិច្ចទទួលបន្ទុកគ្រប់គ្រងព្រៃឈើ ត្រូវរៀបចំលិខិតបទដ្ឋានគតិយុត្ត ស្តីពីលក្ខខណ្ឌតម្រូវ និងនីតិវិធីសម្រាប់ការរៀបចំ និងការរក្សាទុកចម្ការព្រៃឈើ ឱ្យស្របតាមគោល ការណ៍ដែលទទួលស្គាល់ជាលក្ខណៈអន្តរជាតិ ។

**មាត្រា៣៤២** ._ ការប្រើប្រាស់អុស និងធ្យូងដោយចីរភាព

ក្រសួង ស្ថាប័នមានសមត្ថកិច្ចទទួលបន្ទុកគ្រប់គ្រងព្រៃឈើ ត្រូវលើកកម្ពស់ផលិតកម្ម និងការ ប្រើប្រាស់អុស ធ្យូងដោយចីរភាព ។

ក្រសួង ស្ថាប័នមានសមត្ថកិច្ចទទួលបន្ទុកគ្រប់គ្រងព្រៃឈើ ដោយសហការជាមួយសហគមន៍ មូលដ្ឋាន ជនជាតិដើមភាគតិច និងដៃគូបច្ចេកទេស ត្រូវរៀបចំលិខិតបទដ្ឋានគតិយុត្តស្តីពីការរៀបចំយន្ត ការសម្រាប់ការចេញលិខិតបញ្ជាក់ និងគ្រឿងលើកទឹកចិត្តផ្នែកហិរញ្ញវត្ថុ និងសារពើពន្ធ ដល់ផលិតករ អុសធ្យូងដោយចីរភាពដែលទទួលបានលិខិតអនុញ្ញាត ។

**មាត្រា៣៤៣** ._ វិញ្ញាបនបត្រគ្រប់គ្រង និងផលិតផលព្រៃឈើអន្តរជាតិ

ក្រសួង ស្ថាប័នមានសមត្ថកិច្ចទទួលបន្ទុកគ្រប់គ្រងព្រៃឈើ ត្រូវចូលរួមក្នុងកម្មវិធីផ្តល់វិញ្ញាបនបត្រគ្រប់គ្រង និងផលិតផលព្រៃឈើអន្តរជាតិ ក្នុងការគ្រប់គ្រងព្រៃឈើដើម្បីអភិរក្សប្រព័ន្ធអេកូឡូស៊ីធម្មជាតិ និងផ្តល់អត្ថប្រយោជន៍ផ្នែកសេដ្ឋកិច្ច ដល់ការរស់នៅដោយចីរភាពរបស់ប្រជាពលរដ្ឋមូលដ្ឋាន។

ក្រសួង ស្ថាប័នមានសមត្ថកិច្ចទទួលបន្ទុកគ្រប់គ្រងព្រៃឈើ ត្រូវរៀបចំលិខិតបទដ្ឋានគតិយុត្តស្តីពីការតាមដាន និងវាយត្រាលើឈើហ៊ុប ផលិតផលឈើ និងសាច់ឈើ និងអនុផលព្រៃឈើ និងការអង្កេតតាមដាននីតិវិធីទាំងនេះ ដើម្បីធានាថាផលិតផលព្រៃឈើទាំងនេះគោរពតាមស្តង់ដារអន្តរជាតិ ។

**មាត្រា៣៤៤**._ កម្មវិធីពាណិជ្ជកម្ម អភិបាលកិច្ច និងការពង្រឹងការអនុវត្តច្បាប់ព្រៃឈើ

ក្រសួង ស្ថាប័នមានសមត្ថកិច្ចទទួលបន្ទុកគ្រប់គ្រងព្រៃឈើ ត្រូវរៀបចំ និងអនុវត្តកម្មវិធីពាណិជ្ជកម្ម អភិបាលកិច្ច និងការពង្រឹងការអនុវត្តច្បាប់ព្រៃឈើឱ្យបានគ្រប់ជ្រុងជ្រោយ ។

កម្មវិធីពាណិជ្ជកម្ម អភិបាលកិច្ច និងការពង្រឹងការអនុវត្តច្បាប់ព្រៃឈើ ត្រូវ ៖

១- រៀបចំយន្តការសម្របសម្រួល ដែលតម្រូវឱ្យក្រសួង ស្ថាប័នមានសមត្ថកិច្ចធ្វើការប្រាស្រ័យទាក់ទង និងចែករំលែកព័ត៌មានគ្នា ដើម្បីពង្រឹងការអនុវត្តច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធផ្សេងទៀត ។

២- កំណត់ឱ្យបានច្បាស់លាស់ ឱ្យមាន ៖

- ការទទួលត្រូវផ្នែកស្ថាប័ន
- ឯករាជ្យភាពនៃការពិនិត្យ និងអង្កេតតាមដានរបស់ក្រសួង ស្ថាប័នមានសមត្ថកិច្ច
- យន្តការលើកកម្ពស់គណនេយ្យភាព ។

៣- តម្រូវឱ្យក្រសួង ស្ថាប័នមានសមត្ថកិច្ច មានសមត្ថភាពក្នុងការគ្រប់គ្រង និងដោះស្រាយវិវាទ និងផ្តល់សិទ្ធិឱ្យបុគ្គលគ្រប់ដែលមានវិវាទទទួលបានដំណោះស្រាយដោយយុត្តិធម៌ ។

៤- ផ្តល់ឱ្យអ្នកពាក់ព័ន្ធ រួមមាន ក្រសួង ស្ថាប័នមានសមត្ថកិច្ច និងមន្ត្រីអនុវត្តច្បាប់មានពេលវេលា ថវិកា ជំនាញ និងចំណេះដឹងចាំបាច់ ក្នុងការធ្វើ និងអនុវត្តសេចក្តីសម្រេចពាក់ព័ន្ធនឹងព្រៃឈើ ។

៥- តម្រូវឱ្យលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ អនុវត្តដោយស្មើភាពគ្នាចំពោះអ្នកពាក់ព័ន្ធទាំងអស់ ដែលរួមមានវិធានការក្នុងការកាត់បន្ថយផលប៉ះពាល់អវិជ្ជមានចំពោះប្រជាពលរដ្ឋក្រីក្រ និងត្រូវមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ក្នុងការគាំទ្រកម្មវិធីទាំងនេះ ។

៦- កំណត់តួនាទី និងការទទួលខុសត្រូវផ្នែកស្ថាប័ននៅក្នុងលិខិតបទដ្ឋានគតិយុត្ត ឱ្យបានច្បាស់លាស់សម្រាប់អ្នកពាក់ព័ន្ធទាំងអស់ និងកំណត់អំពីតម្លាភាពនៃការពង្រឹងការអនុវត្តច្បាប់ ។

៧- តម្រូវឱ្យមានការគោរពតាមនីតិវិធីនៃការចូលរួមជាសាធារណៈ និងសិទ្ធិទទួលបានព័ត៌មាន ស្របតាមបទប្បញ្ញត្តិនៃក្រមនេះ ។

៨- កំណត់វិធានការដើម្បីស៊ើបអង្កេត អង្កេតតាមដាន និងបង្ក្រាបសកម្មភាពល្មើសច្បាប់ព្រៃឈើ ។

ក្រសួង ស្ថាប័នមានសមត្ថកិច្ចទទួលបន្ទុកគ្រប់គ្រងព្រៃឈើ ត្រូវរៀបចំលិខិតបទដ្ឋានគតិយុត្តស្តីពីការរៀបចំលិខិតបទដ្ឋានគតិយុត្តស្តីពីកម្មវិធីពាណិជ្ជកម្ម អភិបាលកិច្ច ការពង្រឹងការអនុវត្តច្បាប់ព្រៃឈើ ។

## ជំពូកទី៣
## លិខិតអនុញ្ញាត

**មាត្រា៣៤៥**._ លក្ខខណ្ឌតម្រូវនៃលិខិតអនុញ្ញាត

បុគ្គលគ្រប់រូបត្រូវដាក់ពាក្យស្នើសុំលិខិតអនុញ្ញាតពីក្រសួង ស្ថាប័នមានសមត្ថកិច្ចទទួលបន្ទុកគ្រប់គ្រងព្រៃឈើ ដើម្បីធ្វើសកម្មភាព ដូចខាងក្រោម ៖

១- ផលិតអុស ធ្យូង ។

២- ផលិត ផល និងផលអនុផលព្រៃឈើ សម្រាប់ការប្រើប្រាស់ក្នុងគោលដៅពាណិជ្ជកម្ម ។

៣- គ្រប់គ្រងផល និងអនុផលព្រៃឈើ សម្រាប់ការប្រើប្រាស់ក្នុងគោលដៅពាណិជ្ជកម្ម ។

៤- ប្រមូលផល និងលក់ផល និងអនុផលព្រៃឈើសម្រាប់គោលដៅពាណិជ្ជកម្ម ស្របតាមកូតាប្រមូលផលប្រចាំឆ្នាំ ។ លិខិតអនុញ្ញាតឱ្យប្រមូលផល និងលក់ផល និងអនុផលព្រៃ

ឈើសម្រាប់គោលដៅពាណិជ្ជកម្ម ត្រូវដាក់បញ្ចូលនូវការដាក់ប្រាក់តម្កល់ ដើម្បីធានាលើការបង់ប្រាក់កម្រៃសេវា និងបុព្វលាភ ដែលកំណត់ដោយក្រសួង ស្ថាប័នមានសមត្ថកិច្ច ។

៥- ដឹកជញ្ជូនផល និងអនុផលព្រៃឈើ ស្របតាមកូតាដឹកជញ្ជូនប្រចាំឆ្នាំ ដែលកំណត់ដោយក្រសួង ស្ថាប័នមានសមត្ថកិច្ច ។

៦- នាំចេញផល និងអនុផលព្រៃឈើ ស្របតាមកូតាអនុញ្ញាតនាំចេញប្រចាំឆ្នាំ ដែលកំណត់ដោយក្រសួង ស្ថាប័នមានសមត្ថកិច្ច ។

៧- ប្រើប្រាស់ព្រៃឈើ ដើម្បីធ្វើការសិក្សាស្រាវជ្រាវផ្នែកបច្ចេកទេស ឬវិទ្យាសាស្ត្រ រួមមាន ការយកព្រៃឈើមកធ្វើការស្រាវជ្រាវផ្នែករុក្ខវប្បកម្ម ឬការកែលម្អព្រៃឈើ ឬការអប់រំ ឬការបណ្តុះបណ្តាលវិស័យកសិកម្ម ឬការបង្កើតសួនរុក្ខជាតិតាមសាស្ត្រ ឬស្ថានីយពិសោធន៍ ឬការបង្កើតថ្នាលកូនឈើត្រូវផ្ទេរ ឬបង្កើតតំបន់សម្រាកលំហែ ទេសចរណ៍កំសាន្ត ឬការថតភាពយន្តឯកសារ ។

៨- បង្កើតរោងសន្និធិ លក់ ចែកចាយ ផល និងអនុផលព្រៃឈើ និងការបង្កើតមូលដ្ឋានឧស្សាហកម្មឈើ រោងចក្រអារឈើ សិប្បកម្មកែច្នៃផល អនុផលព្រៃឈើ ។

៩- បង្កើតឡគ្រប់ប្រភេទដែលប្រើប្រាស់ផល អនុផលព្រៃឈើជាវត្ថុធាតុដើម ។

១០- ការប្រើប្រាស់ធនធានទឹកសម្រាប់ប្រព័ន្ធស្រោចស្រព ឬគោលដៅកសិកម្ម ដោយមានការឯកភាពពីក្រសួង ស្ថាប័នទទួលបន្ទុកធនធានទឹក ។

១១- រាល់សកម្មភាពពាណិជ្ជកម្មផ្សេងទៀតដូចមានចែងនៅក្នុងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ ឬកំណត់ដោយក្រសួង ស្ថាប័នមានសមត្ថកិច្ចទទួលបន្ទុកគ្រប់គ្រងព្រៃឈើ ត្រូវស្របតាមបទប្បញ្ញត្តិនៃមាតិកានេះ ។

រាល់ការដាក់ពាក្យស្នើសុំលិខិតអនុញ្ញាត ត្រូវដាក់ឱ្យសាធារណជនអាចស្វែងរកបាន ស្របតាមបទប្បញ្ញត្តិនៃក្រមនេះ ។

**មាត្រា៣៤៦** ._ លក្ខណៈវិនិច្ឆ័យសម្រាប់ការឯកភាពលើលិខិតអនុញ្ញាត

ក្នុងការពិនិត្យពាក្យស្នើសុំលិខិតអនុញ្ញាត ក្រសួង ស្ថាប័នមានសមត្ថកិច្ចទទួលបន្ទុកគ្រប់គ្រងព្រៃឈើ ត្រូវកំណត់សកម្មភាពស្នើសុំ ៖

១- ត្រូវស្របតាមផែនការគ្រប់គ្រងព្រៃឈើ ។

២-ត្រូវស្របជាមួយផែនការគ្រប់គ្រងសមាសភាគនៃប្រព័ន្ធតំបន់ការពារធម្មជាតិដែលនៅក្បែរ ។

៣- ត្រូវស្របជាមួយផែនការប្រើប្រាស់ដីថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ។

៤- គាំទ្រ និងធ្វើឱ្យប្រសើរឡើងនូវជីវភាពរស់របស់ប្រជាពលរដ្ឋមូលដ្ឋាន ។

៥- កាត់បន្ថយផលប៉ះពាល់អវិជ្ជមានចំពោះជីវៈចម្រុះ ។

៦- អនុវត្តទម្លាប់ល្អនៅក្នុងដំណាក់កាលរៀបចំគម្រោង ប្រតិបត្តិការគម្រោង និងបិទគម្រោង ។

៧- អនុវត្តតាមប្រព័ន្ធតាមដាន ស្របតាមបទប្បញ្ញត្តិនៃក្រមនេះ និង

៨- បំពេញតាមលក្ខខណ្ឌតម្រូវដទៃទៀត ដែលកំណត់ដោយក្រសួង ស្ថាប័នមានសមត្ថកិច្ចទទួលបន្ទុកគ្រប់គ្រងព្រៃឈើ ស្របតាមបទប្បញ្ញត្តិនៃក្រមនេះ ។

ក្រសួង ស្ថាប័នមានសមត្ថកិច្ចទទួលបន្ទុកគ្រប់គ្រងព្រៃឈើ អាចបន្ថែមលក្ខខណ្ឌលើលិខិតអនុញ្ញាត ស្របតាមលក្ខខណ្ឌតម្រូវនៃក្រមនេះ ។

ក្រសួង ស្ថាប័នមានសមត្ថកិច្ចទទួលបន្ទុកគ្រប់គ្រងព្រៃឈើ អាចព្យួរ ឬលុបចោលលិខិតអនុញ្ញាត ក្នុងករណីមិនគោរពតាមលក្ខខណ្ឌដែលកំណត់នៅក្នុងលិខិតអនុញ្ញាត ។

ការដាក់ពាក្យស្នើសុំលិខិតអនុញ្ញាត ត្រូវអនុវត្តតាមបទប្បញ្ញត្តិស្តីពីការចូលរួមជាសាធារណៈ និងសិទ្ធិទទួលបានព័ត៌មាន នៃក្រមនេះ ។

ក្រសួង ស្ថាប័នមានសមត្ថកិច្ចទទួលបន្ទុកគ្រប់គ្រងព្រៃឈើ ត្រូវរៀបចំលិខិតបទដ្ឋានគតិយុត្ត ដើម្បីកំណត់ពីនីតិវិធី និងលក្ខខណ្ឌតម្រូវនៃដំណើរការផ្តល់លិខិតអនុញ្ញាត ។

**មាត្រា៣៤៧** ._ កម្រៃសេវា បុព្វលាភ និងសួយសារ

ក្រសួង ស្ថាប័នមានសមត្ថកិច្ចទទួលបន្ទុកគ្រប់គ្រងព្រៃឈើ ត្រូវរៀបចំលិខិតបទដ្ឋានគតិយុត្ត ដើម្បីកំណត់ពីលក្ខណៈវិនិច្ឆ័យ និងនីតិវិធី សម្រាប់ការបង់កម្រៃសេវា បុព្វលាភ និងសួយសារ សម្រាប់សកម្មភាពស្នើសុំលិខិតអនុញ្ញាត ។

**មាត្រា៣៤៨** ._ ប្រព័ន្ធអង្កេតតាមដាន និងផ្តល់លិខិតអនុញ្ញាតទូទាំងប្រទេស

ក្រសួង ស្ថាប័នមានសមត្ថកិច្ចទទួលបន្ទុកគ្រប់គ្រងព្រៃឈើ ត្រូវរៀបចំប្រព័ន្ធ និងទិន្នន័យនៃការអង្កេតតាមដាន និងការផ្តល់លិខិតអនុញ្ញាតទូទាំងប្រទេស នៅក្នុងរយៈពេល ១ (មួយ) ឆ្នាំ ក្រោយពេលក្រមនេះចូលជាធរមាន ។

**មាត្រា៣៤៩** ._ ការបែងចែកកម្រៃសេវា បុព្វលាភ និងសួយសារឱ្យសហគមន៍មូលដ្ឋាន

ចំនួនមួយផ្នែកនៃកម្រៃសេវា បុព្វលាភ និងសួយសារ ត្រូវធ្វើការបែងចែកទៅឱ្យសហគមន៍មូលដ្ឋាន ។ ក្រសួង ស្ថាប័នមានសមត្ថកិច្ចទទួលបន្ទុកគ្រប់គ្រងព្រៃឈើ ត្រូវរៀបចំលិខិតបទដ្ឋានគតិយុត្ត ដើម្បីកំណត់ពីភាគរយនៃកម្រៃសេវា បុព្វលាភ និងសួយសារ និងលក្ខណៈវិនិច្ឆ័យ និងនីតិវិធីសម្រាប់បែងចែងកម្រៃសេវា បុព្វលាភ និងសួយសារទៅឱ្យសហគមន៍មូលដ្ឋាន ។

## មាតិកាទី៤
## កិច្ចគាំពារ ការអភិរក្ស និងការគ្រប់គ្រងសត្វ និងរុក្ខជាតិព្រៃ
## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**មាត្រា៣៥០** ._ សត្វ និងរុក្ខជាតិព្រៃ

សត្វ និងរុក្ខជាតិព្រៃសំដៅដល់ពពួកសត្វ និងរុក្ខជាតិព្រៃដែលមានដើមកំណើត និងមិនមានដើមកំណើតនៅក្នុងព្រះរាជាណាចក្រកម្ពុជា ប៉ុន្តែស្ថិតនៅក្នុងទឹកដីនៃព្រះរាជាណាចក្រកម្ពុជា ។

សត្វ និងរុក្ខជាតិព្រៃគ្រប់ប្រភេទ ជាសម្បត្តិរដ្ឋ និងជាសមាសភាគនៃធនធានធម្មជាតិ។

**មាត្រា៣៥១** ._ តួនាទី និងការទទួលខុសត្រូវរបស់ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន មានតួនាទី និងការទទួលខុសត្រូវជារួម សម្រាប់កិច្ចគាំពារ ការអភិរក្ស និងការគ្រប់គ្រងប្រភេទសត្វ និងរុក្ខជាតិព្រៃនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

តួនាទី និងការទទួលខុសត្រូវនេះ ត្រូវកំណត់ដោយលិខិតបទដ្ឋានគតិយុត្តដោយឡែក ។

**មាត្រា៣៥២** ._ សហប្រតិបត្តិការរវាងក្រសួង ស្ថាប័នមានសមត្ថកិច្ច

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន ដោយពិគ្រោះយោបល់ជាមួយដៃគូបច្ចេកទេស និងជំនាញការបច្ចេកទេសពាក់ព័ន្ធ និងដោយសហការជាមួយក្រសួង ស្ថាប័នមានសមត្ថកិច្ច ត្រូវគ្រប់គ្រងឋានៈប្រភេទសត្វ និងរុក្ខជាតិព្រៃដែលមានក្នុងបញ្ជីចំណាត់ថ្នាក់ក្រុមប្រភេទទី១ ទី២ និងទី៣ ដើម្បីគាំពារ និងអភិរក្សប្រភេទសត្វ និងរុក្ខជាតិទាំងនោះ ។

គ្រប់ក្រសួង ស្ថាប័នមានសមត្ថកិច្ច ៖

១- ត្រូវផ្តល់ការសហការដើម្បីអភិរក្សប្រភេទសត្វ និងរុក្ខជាតិព្រៃ ស្របតាមបទប្បញ្ញត្តិនៃក្រមនេះ ។

២- ត្រូវសហការដើម្បីទប់ស្កាត់បទល្មើសពាក់ព័ន្ធទៅនឹងប្រភេទសត្វ និងរុក្ខជាតិ និងចែកចាយព័ត៌មានពាក់ព័ន្ធជាមួយក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន ។

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន ត្រូវរៀបចំលិខិតបទដ្ឋានគតិយុត្ត ស្តីពីនីតិវិធីនៃការសហការ និងចែកចាយព័ត៌មានពាក់ព័ន្ធទៅនឹងបទល្មើសប្រភេទសត្វ និងរុក្ខជាតិព្រៃ រវាងក្រសួង ស្ថាប័នពាក់ព័ន្ធ ។

**មាត្រា៣៥៣** ._ សកម្មភាពនៅក្នុងទីជម្រកសត្វ រុក្ខជាតិព្រៃដែលត្រូវហាមឃាត់

ត្រូវហាមឃាត់ចំពោះការបំផ្លាញ ឬការកែប្រែទីជម្រកធម្មជាតិរបស់ប្រភេទសត្វ រុក្ខជាតិព្រៃ ដូចបានកំណត់ក្នុងក្រុមប្រភេទទី១ ឬទី២ ដែលក្រសួង ស្ថាប័នមានសត្ថកិច្ចបានកំណត់ថា នាំឱ្យបាត់បង់ទៅលើប្រភេទទាំងនោះពីទីជម្រកធម្មជាតិ ។

**មាត្រា៣៥៤** ._ ការចេញលិខិតអនុញ្ញាតពាក់ព័ន្ធទៅនឹងពពួកសត្វ និងរុក្ខជាតិព្រៃ

ការចេញលិខិតអនុញ្ញាតសម្រាប់សកម្មភាពមានផលប៉ះពាល់អវិជ្ជមានខ្លាំង មកលើប្រភេទសត្វ និងរុក្ខជាតិព្រៃ និងជម្រករបស់ប្រភេទសត្វ និងរុក្ខជាតិព្រៃ ត្រូវធ្វើឡើងស្របតាមវិធានការដូចបានកំណត់ក្នុងផែនការគ្រប់គ្រងបរិស្ថាន ដែលបានឯកភាព ។

## ជំពូកទី២
## ការធ្វើចំណាត់ថ្នាក់សត្វ និងរុក្ខជាតិព្រៃ

**មាត្រា៣៥៥** ._ បញ្ជីជាតិសម្រាប់ប្រភេទសត្វ និងរុក្ខជាតិព្រៃដែលកំពុងរងគ្រោះថ្នាក់

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន ដោយសហការជាមួយក្រសួង ស្ថាប័នមានសមត្ថកិច្ច និងដៃគូបច្ចេកទេសពាក់ព័ន្ធ ត្រូវរៀបចំបញ្ជីជាតិសម្រាប់ប្រភេទសត្វ និងរុក្ខជាតិព្រៃដែលកំពុងរងគ្រោះថ្នាក់ ។

បញ្ជីនេះ ត្រូវមបញ្ចូល ដូចខាងក្រោម ៖

១- គ្រប់ប្រភេទសត្វ និងរុក្ខជាតិព្រៃដែលមាននៅក្នុងព្រះរាជាណាចក្រកម្ពុជា និងដែលត្រូវបានចុះក្នុងឧបសម្ព័ន្ធនៃអនុសញ្ញាស្តីពីពាណិជ្ជកម្មអន្តរជាតិលើប្រភេទសត្វ និងរុក្ខជាតិព្រៃដែលកំពុងរងគ្រោះថ្នាក់ ។

២- គ្រប់ប្រភេទសត្វ និងរុក្ខជាតិព្រៃដែលមាននៅក្នុងព្រះរាជាណាចក្រកម្ពុជា និងដែលមានក្នុងចំណាត់ថ្នាក់តាមបញ្ជីអន្តរជាតិផ្សេងទៀតដែលព្រះរាជាណាចក្រកម្ពុជាទទួលស្គាល់ ។

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន ដោយសហការជាមួយក្រសួង ស្ថាប័នមានសមត្ថកិច្ច និងដៃគូបច្ចេកទេសពាក់ព័ន្ធ ត្រូវរៀបចំលិខិតបទដ្ឋានគតិយុត្តស្តីពីការរៀបចំបញ្ជីជាតិសម្រាប់ប្រភេទសត្វ និងរុក្ខជាតិព្រៃដែលកំពុងរងគ្រោះថ្នាក់ ។

**មាត្រា៣៥៦**._ ប្រភេទសត្វ និងរុក្ខជាតិព្រៃ

ពពួកសត្វ និងរុក្ខជាតិព្រៃ ដែលមានក្នុងបញ្ជីជាតិសម្រាប់ប្រភេទសត្វ និងរុក្ខជាតិព្រៃដែលកំពុងរងគ្រោះថ្នាក់ ត្រូវបានបែងចែកជា ៤ (បួន) ប្រភេទដូចខាងក្រោម៖

១- ក្រុមប្រភេទទី១ ៖ គ្រប់ប្រភេទសត្វ និងរុក្ខជាតិព្រៃដែលមាន និងមិនមានដើមកំណើតនៅក្នុងព្រះរាជាណាចក្រកម្ពុជា ៖

- ដូចបានកំណត់ក្នុងឧបសម្ព័ន្ធទី១នៃប្រភេទសត្វ និងរុក្ខជាតិព្រៃក្នុងអនុសញ្ញាស្តីពីពាណិជ្ជកម្មអន្តរជាតិលើប្រភេទសត្វ និងរុក្ខជាតិព្រៃដែលកំពុងរងគ្រោះថ្នាក់ ។
- គ្រប់ប្រភេទសត្វ និងរុក្ខជាតិព្រៃ ដែលបានកំណត់ជាប្រភេទវិនាសផុតពូជទាំងស្រុង និងប្រភេទកំពុងរងគ្រោះថ្នាក់ឈានទៅរកការវិនាសផុតពូជ និង ប្រភេទកំពុងរងគ្រោះថ្នាក់ជិតផុតពូជ នៅក្នុងបញ្ជីនៃប្រភេទដែលកំពុងរងគ្រោះថ្នាក់នៃចំណាត់ថ្នាក់តាមបញ្ជីអន្តរជាតិផ្សេងទៀតដែលព្រះរាជាណាចក្រកម្ពុជាទទួលស្គាល់ ។
- គ្រប់ប្រភេទសត្វ និងរុក្ខជាតិព្រៃ ដែលតម្លៃធម្មជាតិ ឬតម្លៃបេតិកភណ្ឌវប្បធម៌ ឬមានសារៈសំខាន់ផ្នែកសេដ្ឋកិច្ច សម្រាប់ព្រះរាជាណាចក្រកម្ពុជា ។
- គ្រប់ប្រភេទសត្វ និងរុក្ខជាតិព្រៃដែលបានរកឃើញថ្មីនៅក្នុងព្រះរាជាណាចក្រកម្ពុជា និងដែលមិនទាន់ត្រូវបានធ្វើចំណាត់ថ្នាក់នៃការអភិរក្សនៅឡើយ ។

២- ក្រុមប្រភេទទី២ ៖ គ្រប់ប្រភេទសត្វ និងរុក្ខជាតិព្រៃដែលមាន និងមិនមានដើមកំណើតនៅក្នុងព្រះរាជាណាចក្រកម្ពុជា ៖

- ដូចបានកំណត់ក្នុងឧបសម្ព័ន្ធទី២ នៃប្រភេទសត្វ និងរុក្ខជាតិព្រៃក្នុងអនុសញ្ញាស្តីពីពាណិជ្ជកម្មអន្តរជាតិលើប្រភេទសត្វ និងរុក្ខជាតិព្រៃដែលកំពុងរងគ្រោះថ្នាក់ ។
- គ្រប់ប្រភេទសត្វ និងរុក្ខជាតិព្រៃ ដែលបានកំណត់ជាប្រភេទងាយរងគ្រោះថ្នាក់ និងប្រភេទជិតរងគ្រោះថ្នាក់ ប្រភេទពុំមានព័ត៌មានឬទិន្នន័យគ្រប់គ្រាន់ ឬមិនទាន់

សិក្សាវាយតម្លៃ ដោយផ្អែកលើបញ្ជីនៃប្រភេទសត្វ និងរុក្ខជាតិដែលកំពុងរងគ្រោះថ្នាក់ នៃចំណាត់ថ្នាក់តាមបញ្ជីអន្តរជាតិផ្សេងទៀតដែលព្រះរាជាណាចក្រកម្ពុជាទទួលស្គាល់ ។

៣- ក្រុមប្រភេទទី៣ ៖ គ្រប់ប្រភេទសត្វ និងរុក្ខជាតិព្រៃដែលមាន និងមិនមានដើមកំណើតនៅក្នុងព្រះរាជាណាចក្រកម្ពុជា ៖

-ដូចបានកំណត់ក្នុងឧបសម្ព័ន្ធទី៣ នៃប្រភេទសត្វ និងរុក្ខជាតិព្រៃ ក្នុងអនុសញ្ញាស្តីពីពាណិជ្ជកម្មអន្តរជាតិលើប្រភេទសត្វ និងរុក្ខជាតិព្រៃដែលកំពុងរងគ្រោះថ្នាក់ ។

- គ្រប់ប្រភេទសត្វ និងរុក្ខជាតិព្រៃដែលបានកំណត់ជាប្រភេទងាយរងគ្រោះថ្នាក់តិចតួចនៃបញ្ជីនៃប្រភេទសត្វ និងរុក្ខជាតិដែលកំពុងរងគ្រោះថ្នាក់ នៃចំណាត់ថ្នាក់តាមបញ្ជីអន្តរជាតិផ្សេងទៀតដែលព្រះរាជាណាចក្រកម្ពុជាទទួលស្គាល់ លើកលែងតែបានកំណត់ថាជាក្រុមប្រភេទទី៤ ខាងក្រោម ។

៤- ក្រុមប្រភេទទី៤ ៖ គ្រប់ប្រភេទសត្វ និងរុក្ខជាតិដែលមានកំណត់នៅក្នុងក្រុមប្រភេទទី៣ និងដែលត្រូវបានចាត់ទុកថា ជាប្រភេទទូទៅ ដែលត្រូវបានអនុម័តដោយក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន ដោយពិគ្រោះយោបល់ជាមួយដៃគូបច្ចេកទេស និងអ្នកជំនាញការបច្ចេកទេស ។

ក្នុងករណីមានចំណាត់ថ្នាក់ប្រភេទសត្វ និងរុក្ខជាតិព្រៃខុសគ្នារវាង ឧបសម្ព័ន្ធនៃអនុសញ្ញាស្តីពីពាណិជ្ជកម្មអន្តរជាតិលើប្រភេទសត្វ និងរុក្ខជាតិព្រៃដែលកំពុងរងគ្រោះថ្នាក់ និងចំណាត់ថ្នាក់តាមបញ្ជីអន្តរជាតិផ្សេងទៀតដែលព្រះរាជាណាចក្រកម្ពុជាទទួលស្គាល់ ក្រុមប្រភេទសត្វ និងរុក្ខជាតិព្រៃដែលមានឋានៈខ្ពស់ជាង ត្រូវមានអនុភាពអនុវត្ត។

ក្នុងករណីមានប្រភេទសត្វ និងរុក្ខជាតិព្រៃណាត្រូវបានរកឃើញថ្មី ហើយមិនទាន់បានកំណត់នៅក្នុងឧបសម្ព័ន្ធនៃអនុសញ្ញាស្តីពីពាណិជ្ជកម្មអន្តរជាតិលើប្រភេទសត្វ និងរុក្ខជាតិព្រៃដែលកំពុងរងគ្រោះថ្នាក់ ឬនៅក្នុងចំណាត់ថ្នាក់តាមបញ្ជីអន្តរជាតិផ្សេងទៀតដែលព្រះរាជាណាចក្រកម្ពុជាទទួលស្គាល់ នោះត្រូវកំណត់ចូលទៅក្នុងក្រុមប្រភេទទី១ លើកលែងតែមានការកំណត់ជាក្រុមប្រភេទផ្សេងដោយក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន ។

ក្រុមប្រភេទសត្វ និងរុក្ខជាតិព្រៃនៅក្នុងឧបសម្ព័ន្ធ នៃអនុសញ្ញាស្តីពីពាណិជ្ជកម្មអន្តរជាតិលើប្រភេទសត្វ និងរុក្ខជាតិព្រៃដែលកំពុងរងគ្រោះថ្នាក់ និងនៅក្នុងចំណាត់ថ្នាក់តាមបញ្ជីអន្តរជាតិផ្សេងទៀតដែលព្រះរាជាណាចក្រកម្ពុជាទទួលស្គាល់ ត្រូវមានអនុភាពអនុវត្ត រហូតដល់មានលិខិតបទដ្ឋាន

គតិយុត្តស្តីអំពីការរៀបចំបញ្ជីជាតិសម្រាប់ប្រភេទសត្វ និងរុក្ខជាតិព្រៃដែលកំពុងរងគ្រោះថ្នាក់ចូលជាធរមាន ។

**មាត្រា៣៥៧** ._ ការធ្វើបច្ចុប្បន្នភាពទៅលើបញ្ជីជាតិសម្រាប់ប្រភេទសត្វ និងរុក្ខជាតិព្រៃដែលកំពុងរងគ្រោះថ្នាក់

បញ្ជីជាតិសម្រាប់ប្រភេទសត្វ និងរុក្ខជាតិព្រៃដែលកំពុងរងគ្រោះថ្នាក់ ត្រូវធ្វើបច្ចុប្បន្នភាពជាទៀងទាត់ ក្នុងករណីដូចខាងក្រោម ៖

១- ប្រភេទសត្វ និងរុក្ខជាតិព្រៃ ដែលត្រូវបានរកឃើញក្នុងព្រះរាជាណាចក្រកម្ពុជា ដែលមិនទាន់ត្រូវបាន់កំណត់នៅក្នុងឧបសម្ព័ន្ធនៃអនុសញ្ញាស្តីពីពាណិជ្ជកម្មអន្តរជាតិលើប្រភេទសត្វ និងរុក្ខជាតិព្រៃដែលកំពុងរងគ្រោះថ្នាក់ ឬនៅក្នុងចំណាត់ថ្នាក់តាមបញ្ជីអន្តរជាតិផ្សេងទៀតដែលព្រះរាជាណាចក្រកម្ពុជាទទួលស្គាល់ ។

២- ប្រភេទសត្វ និងរុក្ខជាតិព្រៃ ដែលមិនមានកំណត់នៅក្នុងឧបសម្ព័ន្ធនៃអនុសញ្ញាស្តីពីពាណិជ្ជកម្មអន្តរជាតិលើប្រភេទសត្វ និងរុក្ខជាតិព្រៃដែលកំពុងរងគ្រោះថ្នាក់ ឬនៅក្នុងចំណាត់ថ្នាក់តាមបញ្ជីអន្តរជាតិផ្សេងទៀតដែលព្រះរាជាណាចក្រកម្ពុជាទទួលស្គាល់ ដែលតម្រូវឲ្យមានការគាំពារ ស្របតាមលក្ខណៈវិនិច្ឆ័យរបស់ចំណាត់ថ្នាក់តាមបញ្ជីអន្តរជាតិផ្សេងទៀតដែលព្រះរាជាណាចក្រកម្ពុជាទទួលស្គាល់ ។

**មាត្រា៣៥៨** ._ ការដំឡើងថ្នាក់នៃក្រុមប្រភេទសត្វ និងរុក្ខជាតិព្រៃ

គ្រប់ប្រភេទសត្វ និងរុក្ខជាតិ អាចត្រូវដំឡើងថ្នាក់នៃក្រុមប្រភេទ ដោយផ្អែកលើមូលដ្ឋានដូចខាងក្រោម ៖

១- កម្រិតហានិភ័យនៃគំរាមកំហែងខ្ពស់ ដល់បរិមាណនៃពពួកសត្វ និងរុក្ខជាតិព្រៃទាំងនោះ ។

២- ស្ថានភាពនៃពពួកសត្វ និងរុក្ខជាតិព្រៃទាំងនោះស្របតាមលក្ខណៈវិនិច្ឆ័យនៃបញ្ជីប្រភេទសត្វ និងរុក្ខជាតិដែលកំពុងរងគ្រោះថ្នាក់ឈានទៅរកការវិនាសផុតពូជ ឬប្រភេទកំពុងរងគ្រោះ ថ្នាក់ជិតផុតពូជ នៃចំណាត់ថ្នាក់តាមបញ្ជីអន្តរជាតិផ្សេងទៀតដែលព្រះរាជាណាចក្រកម្ពុជាទទួលស្គាល់ ។

៣- មានតម្លៃបេតិកភណ្ឌវប្បធម៌ ឬសារៈសំខាន់ផ្នែកសេដ្ឋកិច្ច ។

នីតិវិធីនៃការដំឡើងថ្នាក់ និងការកែប្រែចំណាត់ថ្នាក់នៃក្រុមប្រភេទសត្វ និងរុក្ខជាតិព្រៃ ត្រូវកំណត់ដោយលិខិតបទដ្ឋានគតិយុត្តរបស់ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន ។

**មាត្រា៣៥៩ .**_ ការស្នើសុំធ្វើបច្ចុប្បន្នភាពទៅលើបញ្ជីជាតិសម្រាប់ប្រភេទសត្វ និងរុក្ខជាតិព្រៃដែលកំពុងរងគ្រោះថ្នាក់

ការស្នើសុំធ្វើបច្ចុប្បន្នភាពលើចំណាក់ថ្នាក់ ឬបន្ថែមប្រភេទសត្វ និងរុក្ខជាតិព្រៃទៅក្នុងបញ្ជីជាតិសម្រាប់ប្រភេទសត្វ និងរុក្ខជាតិព្រៃដែលកំពុងរងគ្រោះថ្នាក់ ត្រូវធ្វើឡើងទៅកាន់ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន ។

នីតិវិធីនៃការស្នើសុំ និងការពិនិត្យនិងសម្រេចទៅលើការស្នើសុំ ត្រូវកំណត់ដោយលិខិតបទដ្ឋានគតិយុត្តរបស់ក្រសួងបរិស្ថាន ។

## ជំពូកទី៣
## ផែនការគ្រប់គ្រង និងស្តារប្រភេទសត្វ និងរុក្ខជាតិព្រៃឡើងវិញ ការអង្កេតតាមដាន និងការរៀបចំរបាយការណ៍

**មាត្រា៣៦០ .**_ ផែនការគ្រប់គ្រង និងស្តារប្រភេទសត្វ និងរុក្ខជាតិព្រៃឡើងវិញ

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន ដោយមានការគាំទ្រផ្នែកបច្ចេកទេសពីដៃគូអភិវឌ្ឍ ត្រូវរៀបចំផែនការគ្រប់គ្រង និងស្តារប្រភេទសត្វ និងរុក្ខជាតិព្រៃឡើងវិញសម្រាប់ក្រុមប្រភេទទី១ និងទី២ ។

នីតិវិធីនៃការរៀបចំផែនការគ្រប់គ្រង និងស្តារប្រភេទសត្វ និងរុក្ខជាតិព្រៃឡើងវិញ ត្រូវកំណត់ដោយលិខិតបទដ្ឋានគតិយុត្តរបស់ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន ។

ផែនការគ្រប់គ្រង និងស្តារប្រភេទសត្វ និងរុក្ខជាតិព្រៃឡើងវិញ អាចត្រូវបញ្ចូលទៅក្នុងផែនការគ្រប់គ្រងសមាសភាគនៃប្រព័ន្ធតំបន់ការពារធម្មជាតិ និងតំបន់គ្រប់គ្រងរួមគ្នា ។

**មាត្រា៣៦១ .**_ ការរៀបចំរបាយការណ៍ និងការអង្កេតតាមដាន

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន ដោយសហការជាមួយអ្នកពាក់ព័ន្ធ ត្រូវរៀបចំប្រព័ន្ធអង្កេតតាមដាន និងការរៀបចំរបាយការណ៍អំពីការអនុវត្តផែនការគ្រប់គ្រង និងស្តារប្រភេទសត្វ និងរុក្ខជាតិព្រៃឡើងវិញ ។

## ជំពូកទី៤
## ការគ្រប់គ្រងប្រភេទសត្វ និងរុក្ខជាតិព្រៃដែលរាតត្បាត

**មាត្រា៣៦២** ._ ផែនការគ្រប់គ្រងប្រភេទសត្វ និងរុក្ខជាតិព្រៃដែលរាតត្បាត

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន ដោយសហការជាមួយក្រសួង ស្ថាប័នមានសមត្ថកិច្ច ត្រូវរៀបចំផែនការគ្រប់គ្រងប្រភេទសត្វ និងរុក្ខជាតិព្រៃដែលរាតត្បាត ដើម្បីកំណត់ ៖

១- ផ្លូវដែលប្រភេទសត្វ រុក្ខជាតិព្រៃដែលរាតត្បាតនោះចូលមកកាន់ព្រះរាជាណាចក្រកម្ពុជា ។

២- វិធីនៃការគ្រប់គ្រងប្រភេទសត្វ និងរុក្ខជាតិព្រៃដែលរាតត្បាតទាំងនោះ ដែលមាននៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

៣- វិធីលុបបំបាត់ប្រភេទសត្វ និងរុក្ខជាតិព្រៃដែលរាតត្បាតដែលបង្កមហន្តរាយ ។

**មាត្រា២៦៣** ._ បញ្ជីជាតិសម្រាប់ប្រភេទសត្វ និងរុក្ខជាតិព្រៃដែលរាតត្បាត

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន ដោយសហការជាមួយក្រសួង ស្ថាប័នមានសមត្ថកិច្ច ត្រូវរៀបចំបញ្ជីជាតិសម្រាប់ប្រភេទសត្វ និងរុក្ខជាតិព្រៃដែលរាតត្បាត ដែលមាន ឬអាចបង្កគ្រោះថ្នាក់នៅក្នុងព្រះរាជាណាចក្រកម្ពុជា ក្នុងករណីមានការនាំចូលប្រភេទសត្វ រុក្ខជាតិទាំងនោះមកក្នុងព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា៣៦៤** ._ ផែនការលុបបំបាត់ប្រភេទសត្វ រុក្ខជាតិព្រៃដែលរាតត្បាត

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន ត្រូវរៀបផែនការលុបបំបាត់ប្រភេទសត្វ រុក្ខជាតិព្រៃដែលរាតត្បាតដើម្បីលុបបំបាត់ និងកាត់បន្ថយជាអប្បបរមានូវផលប៉ះពាល់ពីប្រភេទសត្វ រុក្ខជាតិព្រៃដែលរាតត្បាតទៅលើបរិស្ថាន សេដ្ឋកិច្ច និងសុខភាពមនុស្ស ។

**មាត្រា៣៦៥** ._ លក្ខខណ្ឌតម្រូវនៃការអនុញ្ញាត និងការហាមឃាត់

ការនាំប្រភេទសត្វ រុក្ខជាតិដែលរាតត្បាតណាមួយចូលទៅក្នុងបរិស្ថានធម្មជាតិក្រៅពីតំបន់ក្នុងប្រព័ន្ធតំបន់ការពារធម្មជាតិ ត្រូវមានលិខិតអនុញ្ញាតពីក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន ។

ត្រូវហាមឃាត់ចំពោះការនាំចូលប្រភេទសត្វ រុក្ខជាតិព្រៃដែលរាតត្បាត ទៅក្នុងផ្នែកណាមួយនៃប្រព័ន្ធតំបន់ការពារធម្មជាតិ ។

## ជំពូកទី៥
## ការបរបាញ់ ការប្រមូលយក និងការធ្វើពាណិជ្ជកម្ម

**មាត្រា៣៦៦** ._ ការមិនចេញលិខិតអនុញ្ញាត

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន មិនត្រូវចេញលិខិតអនុញ្ញាតក្រោមមាតិកានេះក្នុងករណីដែលមិនមានព័ត៌មានផ្នែកវិទ្យាសាស្ត្របញ្ជាក់គ្រប់គ្រាន់ដើម្បីកំណត់ពីផលប៉ះពាល់នៃសកម្មភាពទៅលើស្ថានភាពអភិរក្សនៃប្រភេទសត្វ រុក្ខជាតិនោះ លើកលែងតែការអនុញ្ញាតនោះ ធ្វើឡើងសម្រាប់តែគោលបំណងស្រាវជ្រាវផ្នែកវិទ្យាសាស្ត្រប៉ុណ្ណោះ ។

**មាត្រា៣៦៧**._ ការលើកលែង

សកម្មភាពខាងក្រោមនេះ មិនតម្រូវឱ្យមានលិខិតអនុញ្ញាត ៖

១- ការបរបាញ់ក្រៅប្រព័ន្ធតំបន់ការពារជាតិនូវប្រភេទសត្វ រុក្ខជាតិដែលបានធ្វើចំណាត់ថ្នាក់ក្រុមប្រភេទទី៣ ឬទី៤ សម្រាប់ការប្រើប្រាស់ក្នុងគ្រួសារ និងការប្រើប្រាស់ជាលក្ខណៈប្រពៃណី ។

២- ការប្រមូលយក ការធ្វើពាណិជ្ជកម្ម ការដឹកជញ្ជូន និងការប្រើប្រាស់ប្រភេទរុក្ខជាតិព្រៃដែលបានធ្វើចំណាត់ថ្នាក់ក្រុមប្រភេទទី៤ នៅក្រៅប្រព័ន្ធតំបន់ការពារធម្មជាតិសម្រាប់ការប្រើប្រាស់ក្នុងគ្រួសារ និងការប្រើប្រាស់ជាលក្ខណៈប្រពៃណីតែប៉ុណ្ណោះ ។

៣- ការប្រមូលយកផល និងអនុផលព្រៃឈើពីចម្ការដាំដុះលើដីឯកជន ។

**មាត្រា៣៦៨** ._ សកម្មភាពដែលតម្រូវឱ្យមានលិខិតអនុញ្ញាត

សកម្មភាពខាងក្រោម ត្រូវមានលិខិតអនុញ្ញាត ៖

១- ការប្រមូលយកប្រភេទរុក្ខជាតិព្រៃដែលមានក្នុងបញ្ជីក្រុមប្រភេទណាមួយ ពីតំបន់ណាមួយសម្រាប់គោលបំណងប្រើប្រាស់ផ្នែកវេជ្ជសាស្ត្រជាលក្ខណៈពាណិជ្ជកម្ម។

២- ការដឹកជញ្ជូន ការរក្សាទុក ឬការប្រមូលទុកក្នុងស្រុកនៃសំណាកសត្វព្រៃ ។

៣- សកម្មភាពនៅលើដីរដ្ឋក្រៅពីក្នុងតំបន់នៃប្រព័ន្ធតំបន់ការពារធម្មជាតិ ៖

- ការចាប់ ការកាន់កាប់ ការប្តូរទីតាំង និងការផ្ទេរសត្វព្រៃទាំងរស់ ដែលបានធ្វើចំណាត់ថ្នាក់ក្រុមប្រភេទទី១ និងទី២ សម្រាប់មជ្ឈមណ្ឌលសង្គ្រោះសត្វព្រៃ កន្លែងបង្កាត់ពូជអភិរក្ស ឬសម្រាប់ការគ្រប់គ្រងការអភិរក្ស ។

- ការចាប់ ការកាន់កាប់ ការប្តូទីតាំង និងការផ្ទេរសត្វព្រៃទាំងរស់ ដែលបានធ្វើចំណាត់ថ្នាក់ក្រុមប្រភេទទី៣ និងទី៤ សម្រាប់ស្ថាប័នឧទ្យានសួនសត្វ ។

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថានត្រូវរៀបចំលិខិតបទដ្ឋានគតិយុត្តស្តីពីនីតិវិធី និងលក្ខខណ្ឌនៃការផ្តល់ការអនុញ្ញាតសម្រាប់សកម្មភាពដូចមានចែងខាងលើ ។

**មាត្រា៣៦៩** ._ លិខិតអនុញ្ញាតសម្រាប់ពាណិជ្ជកម្មអន្តរជាតិ

ត្រូវមានលិខិតអនុញ្ញាត សម្រាប់គ្រប់សកម្មភាពពាក់ព័ន្ធទៅនឹងពាណិជ្ជកម្មអន្តរជាតិទៅលើប្រភេទសត្វ រុក្ខជាតិព្រៃដែលមានក្នុងបញ្ជីក្រុមប្រភេទទី១ ទី២ និងទី៣ និងសំណាកសត្វ រុក្ខជាតិទាំងនោះ ដូចខាងក្រោម ៖

១- ការកាន់កាប់ ។

២- ការដឹកជញ្ជូន ។

៣- ការតាំងពិព័រណ៍ ។

៤- ការស្តុកទុក ។

៥- ការផ្តល់ជាអំណោយ ។

៦- សកម្មភាពដែលធ្វើឡើងនៅក្នុងព្រះរាជាណាចក្រកម្ពុជា និងដែលពាក់ព័ន្ធទៅនឹងពាណិជ្ជកម្មអន្តរជាតិទៅលើសំណាក និងប្រភេទសត្វ រុក្ខជាតិព្រៃ ។

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន ដោយសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ និងដៃគូបច្ចេកទេស ត្រូវរៀបចំលិខិតបទដ្ឋានគតិយុត្តស្តីពីលក្ខខណ្ឌតម្រូវ និងនីតិវិធីនៃការផ្តល់លិខិតអនុញ្ញាតសម្រាប់ពាណិជ្ជកម្មអន្តរជាតិទៅលើប្រភេទសត្វ រុក្ខជាតិព្រៃ ។

**មាត្រា៣៧០** ._ លិខិតអនុញ្ញាតសម្រាប់ការផ្លាស់ប្តូរផ្នែកវិទ្យាសាស្ត្រ ការតាំងពិព័រណ៍ និងអំណោយថ្នាក់រដ្ឋ

នីតិវិធី និងលក្ខខណ្ឌតម្រូវសម្រាប់ផ្តល់ការអនុញ្ញាតសម្រាប់ការផ្លាស់ប្តូរផ្នែកវិទ្យាសាស្ត្រ ការតាំងពិព័រណ៍ និងអំណោយថ្នាក់រដ្ឋ ត្រូវកំណត់ដោយលិខិតបទដ្ឋានគតិយុត្តរបស់ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន ។

**មាត្រា៣៧១ .**_ ការហាមឃាត់ចំពោះសកម្មភាពក្នុងសមាសភាគនៃប្រព័ន្ធតំបន់ការពារធម្មជាតិ

ត្រូវហាមឃាត់ចំពោះសកម្មភាពដូចខាងក្រោម នៅក្នុងសមាសភាគនៃប្រព័ន្ធតំបន់ការពារធម្មជាតិ ៖

១- ការបំផ្លាញ ឬកែប្រែទីជម្រកធម្មជាតិរបស់ប្រភេទសត្វ និងរុក្ខជាតិព្រៃ នៃក្រុមប្រភេទទី១ ឬទី២ ។

២- រាល់ការបរបាញ់ និងការប្រមូលយកសត្វ រុក្ខជាតិព្រៃសម្រាប់គោលបំណងពាណិជ្ជកម្ម ។

៣- ការបរបាញ់ និងការប្រមូលយកសត្វ រុក្ខជាតិព្រៃ នៃក្រុមប្រភេទទី១ និងទី២ លែកលែងតែករណីដូចមានចែងក្នុងជំពូក នៃមាតិកានេះ ។

៤- ការបរបាញ់ និងបៀតបៀនសត្វបក្សីព្រៃគ្រប់ប្រភេទ កូនរបស់ពួកវា និងការប្រមូលយកស៊ុតនៃសត្វបក្សីព្រៃទាំងនោះ ។

៥- ការប្រមូលយក ឬការបំផ្លាញរុក្ខជាតិព្រៃគ្រប់ប្រភេទសម្រាប់គោលបំណងពាណិជ្ជកម្ម នៅក្នុងតំបន់ស្នូល និងតំបន់អភិរក្សនៃតំបន់ការពារធម្មជាតិ ។

៦- ការផលិត ការកាន់កាប់ ការកែច្នៃ ការទិញ ការដឹកជញ្ជូន និងការប្រើប្រាស់អាវុធ ឬឧបករណ៍បរបាញ់ដែលត្រូវបានហាមឃាត់។ បុគ្គល ដែលបាននាំយកនូវអាវុធ ឬឧបករណ៍បរបាញ់ ឬវត្ថុធាតុដែលត្រូវបានហាមឃាត់ ចូលមកក្នុងតំបន់ស្នូល ឬតំបន់អភិរក្សនៃតំបន់ការពារធម្មជាតិ ត្រូវចាត់ទុកថា មានពិរុទ្ធភាពក្នុងការបរបាញ់ ។

៧- រាល់ការបរបាញ់ និងការចាប់យកទាំងរស់ នូវសត្វព្រៃគ្រប់ប្រភេទទាំងនៅក្នុងតំបន់ស្នូល និងតំបន់អភិរក្សនៃតំបន់ការពារធម្មជាតិ និងនៅក្នុងសមាសភាគនៃប្រព័ន្ធតំបន់ការពារធម្មជាតិ ដូចបានកំណត់នៅក្នុងផែនការគ្រប់គ្រងដែលពាក់ព័ន្ធ ។

៨- ការបរបាញ់សត្វព្រៃ នៃក្រុមប្រភេទទី៣ និងទី៤ ដោយបុគ្គលដទៃ ក្រៅពីជនជាតិដើមភាគតិច និងសមាជិកសហគមន៍មូលដ្ឋាន ដែលត្រូវបានអនុញ្ញាតឱ្យបរបាញ់តែសត្វព្រៃនៃក្រុមប្រភេទទី៤ សម្រាប់ការប្រើប្រាស់ក្នុងគ្រួសារ និងជាលក្ខណៈប្រពៃណីប៉ុណ្ណោះ ។

៩- ការបរបាញ់សត្វព្រៃ នៃក្រុមប្រភេទទី១ និងទី២ ដើម្បីការពារដំណាំ នៅក្នុងតំបន់ប្រើប្រាស់ដោយចីរភាព និងតំបន់សហគមន៍ នៃតំបន់ការពារធម្មជាតិ ។

១០- ការចាប់ទាំងរស់នូវសត្វព្រៃគ្រប់ប្រភេទ សម្រាប់គ្រប់គោលបំណងដែលបានហាមឃាត់ នៅក្នុងតំបន់គ្រប់គ្រងរួមគ្នា ។

១១- ការនាំចូលនូវប្រភេទសត្វ និងរុក្ខជាតិព្រៃដែលរាតត្បាត ។

១២- សកម្មភាពទាំងឡាយដែលបំផ្លាញដល់ព្រៃធម្មជាតិ ដីសើ្មធម្មជាតិ តំបន់ដីសើម រុក្ខជាតិព្រៃ និងទីជម្រកសត្វព្រៃ ។

១៣- ការបង្កាត់ពូជនៃប្រភេទសត្វ រុក្ខជាតិព្រៃ ឬត្រីផ្សេងគ្នា ។

១៤- រាល់សកម្មភាពនេសាទ ដែលបានកំណត់ថា មិនស្របច្បាប់ ។

១៥- រាល់កសិកម្ម និងការកែច្នៃដើមម្រះព្រៅ និងវល្លិរមៀត ។

១៦- ការរំកិល ឬបំផ្លាញបង្គោល ឬសញ្ញាសសម្គាល់ព្រំប្រទល់ និងការដាក់បង្គោល ឬសញ្ញាសម្គាល់ព្រំប្រទល់ឯកជន ។

១៧- សកម្មភាពដែលបង្កឱ្យមានភ្លើងឆេះព្រៃ បណ្តាលឱ្យបំផ្លាញទីជម្រកសត្វព្រៃ សត្វ រុក្ខជាតិព្រៃ រឺព្រៃធម្មជាតិ ។

១៨-សកម្មភាពដទៃទៀតដែលកំណត់ដោយលិខិតបទដ្ឋានគតិយុត្តរបស់ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន ។

**មាត្រា៣៧២** ._ ការហាមឃាត់សកម្មភាពនៅក្រៅតំបន់នៃប្រព័ន្ធតំបន់ការពារធម្មជាតិ

ត្រូវហាមឃាត់សកម្មភាពនៅលើដីឯកជន និងដីរដ្ឋដែលស្ថិតនៅក្រៅប្រព័ន្ធតំបន់ការពារធម្មជាតិ ៖

១- ការបំផ្លាញ ឬការកែប្រែជម្រកធម្មជាតិនៃប្រភេទសត្វ រុក្ខជាតិព្រៃ នៃក្រុមប្រភេទទី១ ឬទី២ ។

២- ការផលិត ការកាន់កាប់ ការកែច្នៃ ការទិញ និងការដឹកជញ្ជូនអាវុធ និងឧបករណ៍បរបាញ់ដែលបានហាមឃាត់ ។

៣- ការបរបាញ់ និងការប្រមូលយកសម្រាប់គោលបំណងណាមួយទៅលើប្រភេទសត្វ រុក្ខជាតិទាំងអស់ ដែលមានក្នុងបញ្ជីថ្នាក់ទី១ និងទី២ លើកលែងតែស្ថិតក្រោមកាលៈទេសៈពិសេសដែលមានចែងក្នុងមាតិកានេះ ។

៤- ការបរបាញ់ និងការចាប់ប្រមូលសម្រាប់គោលបំណងពាណិជ្ជកម្មនូវប្រភេទសត្វ រុក្ខជាតិព្រៃទាំងអស់ដែលមានក្នុងបញ្ជីក្រុមប្រភេទទី១ ទី២ និងទី៣ ។

៥- ការបរបាញ់ ប្រភេទសត្វព្រៃដែលមានក្នុងបញ្ជីក្រុមប្រភេទទី១ ទី២ ទី៣ និងទី៤ ដោយប្រើប្រាស់អាវុធ និងឧបករណ៍បរបាញ់ដែលហាមឃាត់ ឆ្កែ និងយាន្តយន្តគ្រប់ប្រភេទ ។

**មាត្រា៣៧៣** ._ ការធ្វើពាណិជ្ជកម្មក្នុងស្រុក

ត្រូវហាមឃាត់រាល់ការធ្វើពាណិជ្ជកម្មក្នុងស្រុកទៅលើប្រភេទសត្វ និងរុក្ខជាតិព្រៃដូចមានក្នុងបញ្ជីក្រុមប្រភេទទី១ ទី២ និងទី៣ ដូចខាងក្រោម លើកលែងតែការធ្វើពាណិជ្ជកម្មសត្វព្រៃដែលមានប្រភពចេញពីកសិដ្ឋានចិញ្ចឹមសត្វព្រៃដូចមានចែងក្នុងមាតិកានេះ ៖

១-ការផលិតនូវផលិតផលដែលមានវត្ថុធាតុនៃសំណាកប្រភេទសត្វ រុក្ខជាតិនៃក្រុមប្រភេទទី១ ទី២ ឬទី៣ ។

២-ដាក់លក់ ឬផ្សព្វផ្សាយដើម្បីលក់ទំនិញណាមួយដែលមានវត្ថុធាតុនៃសំណាកប្រភេទសត្វ រុក្ខជាតិព្រៃ នៃក្រុមប្រភេទទី១ ទី២ ឬទី៣ ។

៣-ផ្តល់សេវាផលិតសត្វសិប្បនិម្មិត ដែលមានវត្ថុធាតុនៃសំណាកប្រភេទសត្វព្រៃនៃក្រុមប្រភេទទី១ ទី២ ឬទី៣ ។

៤-ទិញ ទទួល យកមកធ្វើជាកម្មសិទ្ធិ កាន់កាប់ ចម្អិន ឬលក់សាច់សត្វព្រៃនៃក្រុមប្រភេទទី១ ទី២ ឬទី៣ លើកលែងតែចំពោះកសិដ្ឋានសត្វព្រៃដែលត្រូវបានអនុញ្ញាតដែលមានសុពលភាពដែលអនុញ្ញាតឱ្យលក់សាច់សត្វព្រៃដែលចិញ្ចឹមក្នុងកសិដ្ឋានដែលមានក្នុងបញ្ជីក្រុមប្រភេទទី៣ និងទី៤តែប៉ុណ្ណោះ ។

៥- ធ្វើសកម្មភាពទាំងឡាយ ពាក់ព័ន្ធទៅនឹងការប្រើប្រាស់សំណាកប្រភេទសត្វ រុក្ខជាតិព្រៃ ដែលហាមឃាត់ដោយក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន ។

**មាត្រា៣៧៤ ._** ការផ្តល់លិខិតអនុញ្ញាតសម្រាប់គោលបំណងផ្នែកស្រាវជ្រាវវិទ្យាសាស្ត្រ

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន អាចផ្តល់ការអនុញ្ញាតចំពោះការចាប់សត្វព្រៃទាំងរស់ ឬប្រមូលយកប្រភេទរុក្ខជាតិព្រៃ ដែលមានក្នុងបញ្ជីក្រុមប្រភេទទី១ ទី២ ឬទី៣ ពីកន្លែងណាមួយសម្រាប់គោលបំណងស្រាវជ្រាវផ្នែកវិទ្យាសាស្ត្រ ក្នុងករណីការចាប់ ហើយការប្រមូលនោះ មិនបង្កផលប៉ះពាល់ខ្លាំងដល់ស្ថានភាពនៃការអភិរក្សពពួកប្រភេទសត្វ និងរុក្ខជាតិព្រៃនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

នីតិវិធី និងលក្ខខណ្ឌតម្រូវនៃការផ្តល់ការអនុញ្ញាតសម្រាប់គោលបំណងផ្នែកស្រាវជ្រាវវិទ្យាសាស្ត្រ ត្រូវកំណត់ដោយលិខិតបទដ្ឋានគតិយុត្តរបស់ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន ។

**មាត្រា៣៧៥ ._** ការកំណត់កូតាសម្រាប់ការបរបាញ់សត្វព្រៃ និងការប្រមូលយករុក្ខជាតិព្រៃ

កូតាសម្រាប់ការបរបាញ់សត្វព្រៃ និងការប្រមូលយករុក្ខជាតិព្រៃ ដែលមានក្នុងបញ្ជីក្រុមប្រភេទទី៣ និងទី៤ ត្រូវកំណត់ដោយលិខិតបទដ្ឋានគតិយុត្តស្តីពីការកំណត់កូតាបរបាញ់ និងប្រមូលយកតាមប្រភេទសត្វ រុក្ខជាតិព្រៃ និងតាមខេត្ត របស់ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន ។

**មាត្រា៣៧៦**._ លិខិតអនុញ្ញាតបបាញ់សត្វព្រៃ និងប្រមូលយករុក្ខជាតិព្រៃ

ការស្នើសុំលិខិតអនុញ្ញាតបរបាញ់សត្វព្រៃ និងប្រមូលយករុក្ខជាតិព្រៃ ត្រូវដាក់ទៅអាជ្ញាធរមានសមត្ថកិច្ចដូចខាងក្រោម ៖

១- មន្ទីរទទួលបន្ទុកបរិស្ថានខេត្ត ក្នុងករណីការស្នើសុំបរបាញ់សត្វព្រៃ និងប្រមូលយករុក្ខជាតិព្រៃ ក្នុងតំបន់ដែលនៅក្រៅតំបន់នៃប្រព័ន្ធតំបន់ការពារធម្មជាតិ ។

២- នាយកគ្រប់គ្រងសមាសភាគនៃប្រព័ន្ធតំបន់ការពារធម្មជាតិក្នុងករណីការស្នើសុំបរបាញ់សត្វព្រៃ និងប្រមូលយករុក្ខជាតិព្រៃ ក្នុងតំបន់ដែលស្ថិតនៅក្នុងសមាសភាគនៃប្រព័ន្ធតំបន់ការពារធម្មជាតិ ។

៣- អជ្ញាធរគ្រប់គ្រងរួមគ្នា ក្នុងករណីការស្នើសុំបរបាញ់សត្វព្រៃ និងប្រមូលយករុក្ខជាតិព្រៃ ក្នុងតំបន់ដែលស្ថិតក្នុងតំបន់គ្រប់គ្រងរួមគ្នា ។

នីតិវិធី និងលក្ខខណ្ឌតម្រូវនៃការស្នើសុំ ត្រូវកំណត់ដោយលិខិតបទដ្ឋានគតិយុត្តរបស់ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន ។

**មាត្រា៣៧៧** ._ ការព្យួរ និងការលុបចោលលិខិតអនុញ្ញាត

ក្រសួង ស្ថាប័នមានសមត្ថកិច្ច ត្រូវព្យួរ ឬលុបចោលលិខិតអនុញ្ញាតបរបាញ់សត្វព្រៃ ឬប្រមូលរុក្ខជាតិព្រៃ ក្នុងករណីដូចខាងក្រោម ៖

១- មានព័ត៌មាន ឬទិន្នន័យផ្អែកវិទ្យាសាស្ត្រថ្មី ឬមានភស្តុតាងថ្មីគ្រប់គ្រាន់ ដែលបញ្ជាក់អំពីការគំរាមកំហែងដល់ប្រភេទសត្វ និងរុក្ខជាតិព្រៃដែលមានក្នុងលិខិតអនុញ្ញាតនោះ ។

២- អ្នកកាន់លិខិតអនុញ្ញាតបានប្រើប្រាស់អាវុធ ឬឧបករណ៍បបាញ់ដែលត្រូវហាមឃាត់ ។

៣- អ្នកកាន់លិខិតអនុញ្ញាតបរបាញ់សត្វព្រៃ ឬប្រមូលរុក្ខជាតិព្រៃ បានប្រព្រឹត្តសកម្មភាពណាមួយដូចខាងក្រោម ៖

- បរបាញ់ ឬចាប់ប្រមូល ឬព្យាយាមបរបាញ់ ឬចាប់ប្រមូល ប្រភេទដែលមានក្នុងបញ្ជីថ្នាក់ទី១ ។

- បរបាញ់ ឬចាប់ប្រមូល ឬព្យាយាមបរបាញ់ ឬចាប់ប្រមូល ប្រភេទសត្វ រុក្ខជាតិ ក្នុងតំបន់ស្នូល ឬ តំបន់អភិរក្សនៃតំបន់ការពារធម្មជាតិ ។

- បរបាញ់ ឬចាប់ប្រមូល ឬព្យាយាមបរបាញ់ ឬចាប់ប្រមូល ប្រភេទដែលមានក្នុងបញ្ជីថ្នាក់ទី២ ។

- បរបាញ់ ឬចាប់ប្រមូល ឬព្យាយាមបរបាញ់ ឬចាប់ប្រមូល លើសពីកូតាដែលមានចែងក្នុងលិខិតអនុញ្ញាត ។

- បរបាញ់ ឬចាប់ប្រមូល ឬព្យាយាមបរបាញ់ ឬចាប់ប្រមូលប្រភេទដែលមានក្នុងបញ្ជីក្រុមប្រភេទថ្នាក់ទី៣។

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន ដោយការសហការពីក្រសួង ស្ថាប័នមានសមត្ថកិច្ច ត្រូវពិនិត្យលើរាល់ការព្យួរ និងការលុបចោលលិខិតអនុញ្ញាតខាងលើ ។

## ជំពូកទី៦
## ការគ្រប់គ្រងសត្វព្រៃ
### ផ្នែកទី១
### ការអង្កេតតាមដានសុខភាពសត្វព្រៃ

**មាត្រា៣៧៨ .**_ វិធីសាស្ត្រអង្កេតតាមដានសុខភាពសត្វព្រៃ

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន ដោយសហការជាមួយក្រសួង ស្ថាប័នមានសមត្ថកិច្ចត្រូវ ៖

១- កំណត់អត្តសញ្ញាណជំងឺសត្វព្រៃ និងត្រូវផ្សព្វផ្សាយជាសាធារណៈអំពីជំងឺដែលបានរកឃើញ ។

២- រៀបចំវិធីសាស្ត្រអង្កេតតានសុខភាព និងជំងឺសត្វព្រៃ ។

៣- ស៊ើបអង្កេត ចងក្រងឯកសារ និងឆ្លើយតបចំពោះការរាតត្បាតនៃជំងឺសត្វព្រៃ ។

៤- រាយការណ៍ឱ្យបានទាន់ពេលវេលាអំពីលទ្ធផលនៃសិក្សា ការអង្កេតតាមដានសុខភាពសត្វព្រៃ និងការស៊ើបអង្កេតជំងឺសត្វព្រៃ ។

**មាត្រា៣៧៩ .**_ ចត្តាឡីស័ក

ម្ចាស់សត្វព្រៃ និងម្ចាស់កសិដ្ឋានសត្វព្រៃ ត្រូវប្រគល់សត្វព្រៃឱ្យទៅក្រសួង ស្ថាប័នទទួលបន្ទុកដើម្បីធ្វើចត្តាឡីស័ក នៅមុនពេលដែលសត្វព្រៃទាំងនោះត្រូវបានប្តូរទីតាំង នាំមកបញ្ចូល ឬផ្ទេររវាងទីបង្ខាំង និងព្រៃ ឬរវាងកសិដ្ឋានចិញ្ចឹមសត្វព្រៃ កន្លែងបង្កាត់ពូជអភិរក្ស មជ្ឈមណ្ឌលសង្គ្រោះសត្វព្រៃ

និងគ្រឹះស្ថានឧទ្យានសួនសត្វ ។ ក្រោយពីការធ្វើចត្តាឡីស័ក ក្រសួង ស្ថាប័នមានសមត្ថកិច្ចត្រូវធ្វើការបញ្ជាក់ជាលាយល័ក្ខណ៍អក្សរដូចខាងក្រោម ៖

១- សត្វព្រៃត្រូវបានធ្វើចត្តាឡីស័កមិនឱ្យលើសពី១៤ (ដប់បួន) ថ្ងៃ និងត្រូវពិនិត្យនៅមុនពេលប្តូរទីតាំង នាំចូលទៅវិញ ឬផ្ទេរ ។

២- សត្វព្រៃនោះមិនបង្ហាញពីរោគសញ្ញាជំងឺ ឬមានរបួសនោះទេ ។

៣- សត្វព្រៃនោះត្រូវមានស្លាកសម្គាល់ដែលខុសពីគ្នារវាងសត្វដែលមានសុខភាពល្អ និងសត្វដែលមានជំងឺ ។

៤- សត្វព្រៃនោះត្រូវបានពិនិត្យសុខភាព ហើយឃើញថា មិនមានជំងឺដែលគួរឱ្យកត់សម្គាល់ណាមួយទេ ។

៥- ត្រូវជូនដំណឹងជាបន្ទាន់ទៅកាន់មន្ទីរទទួលបន្ទុកបរិស្ថានថ្នាក់ខេត្ត ក្នុងករណីដែលសត្វព្រៃនោះបានឆ្លងជំងឺ ឬស្លាប់ នៅក្នុងដំណើរការនៃការធ្វើចត្តាឡីស័កនោះ ។

**មាត្រា៣៨០** ._ ការតាមដានសុខភាពសត្វព្រៃ

ក្រសួង ស្ថាប័នមានសមត្ថកិច្ច អាចតម្រូវឱ្យអ្នកកាន់កាប់លិខិតអនុញ្ញាតបរបាញ់ និងប្រមូលយក ប្រគល់នូវសំណាកសត្វព្រៃដែលបរបាញ់ ឬប្រមូលបានដើម្បីធ្វើការអង្កេតតាមដានពីសុខភាពសត្វ ។ ការប្រគល់សំណាកសត្វព្រៃនេះ មិនទទួលបានសំណងផ្នែកហិរញ្ញវត្ថុឡើយ ។

## ផ្នែកទី២
## ការសម្រេចឱ្យសម្លាប់សត្វព្រៃ

**មាត្រា៣៨** ._ ការអនុញ្ញាតឱ្យសម្លាប់សត្វព្រៃ

នាយកសមាសភាគនៃប្រព័ន្ធតំបន់ការពារធម្មជាតិ ឬមន្ត្រីមានសមត្ថកិច្ចនៃក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន អាចអនុញ្ញាតឱ្យមន្ត្រីនៃក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន ឬមន្ទីទទួលបន្ទុកបរិស្ថានខេត្ត សម្លាប់សត្វព្រៃទាំងឡាយណា កំពុងបង្កគ្រោះថ្នាក់ដល់ជីវិតមនុស្ស កំពុងមានរបួស ឬឆ្លងជំងឺមិនអាចព្យាបាលបាន ។

ការសម្រេចឱ្យសម្លាប់ និងវិធីសម្លាប់សត្វព្រៃ ត្រូវធ្វើឡើងស្របតាមលិខិតបទដ្ឋានគតិយុត្តស្តីសុខុមាលភាពសត្វ របស់ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន ។

## ផ្នែកទី៣
## ការប្តូរទីតាំង និងការចាប់សត្វព្រៃទាំងរស់

**មាត្រា៣៨២** ._ ការចាប់សត្វព្រៃទាំងរស់សម្រាប់គោលបំណងអភិរក្ស

ការចាប់សត្វព្រៃទាំងរស់ នៃក្រុមប្រភេទដូចមានចែងក្នុងមាត្រា៣៥៦ សម្រាប់គោលបំណងបង្កាត់ពូជអភិរក្ស ឬគ្រប់គ្រងការអភិរក្ស ត្រូវមានការអនុញ្ញាតពីក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន ។

នីតិវិធីនៃការដាក់ពាក្យស្នើសុំ ត្រូវស្របតាមលិខិតបទដ្ឋានគតិយុត្តស្តីពីការចាប់យក ការដឹកជញ្ជូន និងសុខុមាលភាពសត្វព្រៃ ។

**មាត្រា៣៨៣** ._ ការប្តូរទីតាំងសត្វព្រៃ

ការប្តូរទីតាំងសត្វព្រៃនៃក្រុមប្រភេទទី១ និងទី២ សម្រាប់គោលបំណងបង្កាត់ពូជអភិរក្ស គ្រប់គ្រងការអភិរក្ស ត្រូវមានការអនុញ្ញាតពីក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន ស្របតាមផែនការគ្រប់គ្រង និងស្តារសត្វ រុក្ខជាតិព្រៃឡើងវិញ ។

## ជំពូកទី៧
## ការគ្រប់គ្រង និងចាត់ចែងវត្ថុតាងសត្វ និងរុក្ខជាតិព្រៃ

**មាត្រា៣៨៤** ._ ការគ្រប់គ្រងវត្ថុតាងសត្វ រុក្ខជាតិព្រៃដែលរឹបអូសបាន

សត្វ រុក្ខជាតិព្រៃរស់ដែលរឹបអូសបាន មិនត្រូវរក្សាទុកជាភស្តុតាងនៅតុលាការសម្រាប់ដំណើរការនីតិវិធីតុលាការទេ ។ មានតែភស្តុតាងជាឯកសារ រួមមាន ភស្តុតាងជារូបភាព ឬរូបថតនៃសត្វរុក្ខជាតិព្រៃដែលរឹបអូសបានទេ ដែលត្រូវទទួលយកជាភស្តុតាង ដើម្បីប្រើប្រាស់ក្នុងនីតិវិធីតុលាការ ។ ប៉ុន្តែតុលាការអាចចុះពិនិត្យភស្តុតាងជាក់ស្តែងនៃសត្វ រុក្ខជាតិព្រៃដែលរឹបអូសបាននៅទីតាំងរក្សាទុក ។

សំណាកសត្វ រុក្ខជាតិព្រៃងាប់ អាចត្រូវរក្សាទុកជាភស្តុតាងនៅឯស្ថាប័នតុលាការសម្រាប់ដំណើរការនីតិវិធីដោយមានការអនុញ្ញាតពីក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន រហូតដល់ពេលនីតិវិធីតុលាការត្រូវបានបញ្ចប់ ។

ត្រូវហាមឃាត់ចំពោះការរក្សាសត្វ រុក្ខជាតិព្រៃរស់ទុកជាភស្តុតាង លើកលែងតែមានការអនុញ្ញាតពីក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន ដោយសហការជាមួយក្រសួង ស្ថាប័នមានសមត្ថកិច្ច ។

ក្នុងករណីត្រូវរក្សាទុកសត្វ រុក្ខជាតិព្រៃរស់ដែលរឹបអូសបានទុកជាភស្តុតាង នោះត្រូវធ្វើឡើងដោយសុវត្ថិភាព និងផាសុខភាពសម្រាប់សត្វ រុក្ខជាតិព្រៃដែលពាក់ព័ន្ធ ស្របតាមលិខិតបទដ្ឋានគតិយុត្តស្តីពីនីតិវិធីនៃការគ្រប់គ្រងសំណាកសត្វ រុក្ខជាតិព្រៃដែលរឹបអូសបាន ។

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន ត្រូវរៀបចំ និងធ្វើបច្ចុប្បន្នភាពជាទៀងទាត់នូវបញ្ជីសារពើភណ្ឌជាតិ នៃសត្វ និងរុក្ខជាតិព្រៃទាំងរស់ ទាំងងាប់ ដែលរឹបអូសបាន ។

**មាត្រា៣៨៥** ._ ប្រភេទវត្ថុតាងនៃបទល្មើសសត្វ រុក្ខជាតិព្រៃ

ប្រភេទវត្ថុតាងនៃបទល្មើសសត្វ រុក្ខជាតិព្រៃ មានដូចតទៅ ៖

១- សត្វ រុក្ខជាតិព្រៃដែលរស់ ឬងាប់ សំណាកសត្វ រុក្ខជាតិព្រៃ សត្វ ឬបំណែកនៃសត្វព្រៃដែលបរបាញ់បាន និងវត្ថុធាតុនានានៃសត្វ រុក្ខជាតិព្រៃ ។

២- ឧបករណ៍ និងមធ្យោបាយនានាដែលប្រើសម្រាប់ដឹកជញ្ជូនក្នុងបំណងប្រព្រឹត្តបទល្មើសដោយចេតនា មានជាអាទិ៍ សម្ភារៈដែលប្រើជាមធ្យោបាយដែលត្រូវបានហាមឃាត់សម្រាប់ការបរបាញ់ ។

៣- ឧបករណ៍ និងកំណត់ត្រានានាដែលបានប្រើក្នុងការធ្វើអាជីវកម្មសត្វ រុក្ខជាតិព្រៃ រួមមាន ទូរស័ព្ទ របាយការណ៍ហិរញ្ញវត្ថុ និងរបាយការណ៍ធានាគារ ។

៤-ទ្រព្យសម្បត្តិ បានមកពីដំណាក់កាលនានានៃការប្រព្រឹត្តបទល្មើសសត្វ រុក្ខជាតិព្រៃ ។

៥- ឯកសារ ឬសក្ខីកម្មរបស់សាក្សី ពាក់ព័ន្ធទៅនឹងសកម្មភាពខុសច្បាប់ ឬការប៉ុនប៉ងប្រព្រឹត្តបទល្មើសដោយចេតនាបែបណាមួយ ។

វត្ថុតាងនានាដែលរឹបអូសជាបណ្តោះអាសន្នខាងលើនេះ ត្រូវគ្រប់គ្រងស្របតាមបទប្បញ្ញត្តិនៃក្រមនេះ និងលិខិតបទដ្ឋានគតិយុត្តនានា ដែលបានកំណត់ដោយក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន ។

វត្ថុតាងដែលចែងនៅក្នុងចំណុចខាងលើនេះ ត្រូវសម្រេចរឹបអូសចុងក្រោយដោយសេចក្តីសម្រេចរបស់តុលាការ ។

**មាត្រា៣៨៦** ._ ការចាត់ចែងវត្ថុតាងដែលរឹបអូសបាន

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន មានសិទ្ធិចាត់ចែងវត្ថុតាងដែលរឹបអូសបាន ទាក់ទងនឹងធនធានធម្មជាតិ និងត្រូវបានសម្រេចចុងក្រោយដោយតុលាការឱ្យស្របតាមនីតិវិធីដែលបានកំណត់ដោយក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ ។

## ជំពូកទី៨
## ការគ្រប់គ្រងទីកន្លែងរក្សាសត្វព្រៃ ដែលនៅក្រៅ ទីជម្រកធម្មជាតិ
## ផ្នែកទោល
## បទប្បញ្ញត្តិទូទៅ

**មាត្រា៣៨៧**. _ ទីតាំងរក្សាសត្វ រុក្ខជាតិព្រៃ

ទីតាំងរក្សាទុកប្រភេទសត្វ រុក្ខជាតិព្រៃក្រៅទីជម្រកធម្មជាតិ រួមមាន ទីតាំងបង្កាត់ពូជអភិរក្ស មជ្ឈមណ្ឌលសង្គ្រោះសត្វព្រៃ គ្រឹះស្ថានឧទ្យានសួនសត្វ អគារសន្និធិរុក្ខជាតិស្ងួត សួនរុក្ខជាតិ សួនភូតគាមសាស្ត្រ វិទ្យាស្ថានកសិកម្ម និងសាកវប្បកម្ម ។

ការរៀបចំ និងដំណើរការប្រព្រឹត្តទៅនៃទីតាំងរក្សាសត្វ និងរុក្ខជាតិព្រៃ ត្រូវកំណត់ដោយលិខិតបទដ្ឋានគតិយុត្តរបស់ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន ។

**មាត្រា៣៨៨** ._ ការចុះបញ្ជីទីតាំងរក្សាសត្វ រុក្ខជាតិព្រៃ

ទីតាំងរក្សាសត្វ រុក្ខជាតិព្រៃ ត្រូវចុះបញ្ជីដើម្បីទទួលបានការទទួលស្គាល់ និងការអនុញ្ញាតពីក្រសួង ស្ថាប័នមានសត្ថកិច្ច ។

ម្ចាស់ទីតាំងរក្សាសត្វ និងរុក្ខជាតិព្រៃ ត្រូវដាក់ពាក់សុំចុះបញ្ជីដើម្បីទទួលការអនុញ្ញាតក្នុងរយៈពេល ៦ (ប្រាំមួយ) ខែ បន្ទាប់ពីក្រមនេះចូលជាធរមាន ។

នីតិវិធី និងលក្ខខណ្ឌតម្រូវនៃការចុះបញ្ជីទីតាំងរក្សាសត្វ រុក្ខជាតិព្រៃ ត្រូវកំណត់ដោយលិខិតបទដ្ឋានគតិយុត្តរបស់ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន ដោយសហការជាមួយក្រសួង ស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធ ។

**មាត្រា៣៨៩** ._ អធិការកិច្ច និងការអង្កេតតាមដានទីតាំងរក្សាទុកសត្វ រុក្ខជាតិព្រៃ

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន ត្រូវធ្វើអធិការកិច្ច និងអង្កេតតាមដានទីតាំងរក្សារុកប្រភេទសត្វ រុក្ខជាតិព្រៃទាំងនេះ។

នីតិវិធីនៃការធ្វើអធិការកិច្ច និងការអង្កេតតាមដានទីតាំងរក្សាទុកប្រភេទសត្វ រុក្ខជាតិព្រៃ ត្រូវកំណត់ដោយលិខិតបទដ្ឋានគតិយុត្តរបស់ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន ។

**មាត្រា៣៩០** ._ ការព្យួរ និងការលុបចោលលិខិតអនុញ្ញាតនៃទីតាំងរក្សាទុកសត្វ រុក្ខជាតិព្រៃ

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន ក្រសួង ស្ថាប័នមានសមត្ថកិច្ច ត្រូវព្យួរ ឬលុបចោលលិខិតអនុញ្ញាតសម្រាប់ទីតាំងរក្សាទុកសត្វ រុក្ខជាតិព្រៃ ក្នុងករណីដែលទីតាំងទាំងនោះមិនគោរពតាមលក្ខខណ្ឌនៃការអនុញ្ញាត ។

**មាត្រា៣៩១** ._ លិខិតអនុញ្ញាតរក្សាទុកសំណាកសត្វ រុក្ខជាតិព្រៃ

រាល់ទីតាំងរក្សាសត្វ និងរុក្ខជាតិព្រៃ ដែលរក្សាទុកសំណាកសត្វ រុក្ខជាតិព្រៃ នៃក្រុមប្រភេទទី១ ទី២ និងទី៣ ត្រូវមានលិខិតអនុញ្ញាតពីក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន។

**មាត្រា៣៩២** ._ ការបង្កាត់ពូជអភិរក្សសម្រាប់រុក្ខជាតិព្រៃ

ទីតាំងដែលធ្វើការបង្កាត់ពូជអភិរក្សនៃរុក្ខជាតិព្រៃ ត្រូវផ្តល់អាទិភាពលើការផ្សាំ និងការដាំដុះនូវរុក្ខជាតិព្រៃធម្មជាតិ ដែលមានប្រយោជន៍ផ្នែកឱសថសាស្ត្រ ។ ការផ្សាំ និងការដាំដុះរុក្ខជាតិនេះ ត្រូវធ្វើឡើងស្របតាមនីតិវិធី និងស្តង់ដារដែលបានទទួលស្គាល់ជាអន្តរជាតិ ។

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន ត្រូវរៀបចំលិខិតបទដ្ឋាគតិយុត្តស្តីពីស្តង់ដារជាតិ និងនីតិវិធីនៃការបង្កាត់ពូជរុក្ខជាតិព្រៃដែលមានប្រយោជន៍ផ្នែកឱសថសាស្ត្រនេះ ។

**មាត្រា៣៩៣**. _ ការបង្កាត់ពូជអភិរក្សសម្រាប់សត្វព្រៃ

ទីតាំងដែលធ្វើការបង្កាត់ពូជអភិរក្សសត្វព្រៃនៃក្រុមប្រភេទទី១ ឬទី២ ត្រូវរៀបចំកន្លែងរក្សាឱ្យបាននូវរបៀបរបបនៃការរស់នៅតាមបែបបធម្មជាតិ និងមានភាពចម្រុះផ្នែកហ្សេនេទិច តាមរយៈវិធានការដូចខាងក្រោម ៖

១- រៀបចំបញ្ជីកំណត់ហេតុសម្រាប់ប្រភេទសត្វនីមួយៗ និងកម្មវិធីបង្កាត់ពូជរបស់សត្វទាំងនោះ ។

២- ផ្តល់នូវទីបង្ខាំងដូចមានចែងនៅក្នុងលិខិតអនុញ្ញាតសម្រាប់ទីតាំងនីមួយៗ ។

៣- រក្សាបាននូវស្តង់ដារសុខុមាលភាពសត្វព្រៃដែលមានការទទួលស្គាល់ ស្របតាមលិខិតបទដ្ឋានគតិយុត្តស្តីពីសុខុមាលភាពសត្វព្រៃ ។

៤- បំពេញនូវសកម្មភាពផ្សេងទៀត ស្របតាមស្តង់ដារអន្តរជាតិ ។

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន ត្រូវរៀបចំលិខិតបទដ្ឋានគតិយុត្តស្តីពីស្តង់ដារ និងនីតិវិធីនៃការអភិរក្សសត្វព្រៃ ។

**មាត្រា៣៩៤**._ ការបញ្ចេញរុក្ខជាតិព្រៃចូលទៅក្នុងបរិស្ថានធម្មជាតិ

ប្រតិបត្តិករនៃគ្រឹះស្ថានឧទ្យានសួនសត្វ អគារសន្និធិរុក្ខជាតិស្ងួត សួនរុក្ខជាតិ សួនភូគតាមសាស្ត្រ វិទ្យាស្ថានកសិកម្ម និងសាកវប្បកម្ម និងទីតាំងដទៃទៀតដែលធ្វើការអភិរក្សរុក្ខជាតិព្រៃដែលមិនមានកំណើតនៅក្នុងព្រះរាជាណាចក្រកម្ពុជា មិនត្រូវអនុញ្ញាតឱ្យមានការបញ្ចេញរុក្ខជាតិព្រៃដែលរាតត្បាត ចូលទៅក្នុងបរិស្ថានធម្មជាតិបានឡើយ ។

ក្នុងករណីមានការបញ្ចេញរុក្ខជាតិព្រៃ ប្រតិបត្តិករត្រូវ ៖

១- ជូនដំណឹងទៅកាន់មន្ទីរទទួលបន្ទុកបរិស្ថានខេត្ត ក្នុងរយៈពេល២៤ម៉ោង ។

២- ខិតខំប្រមូល ឬដកយកមកវិញនូវប្រភេទរុក្ខជាតិរាតត្បាត និងសារធាតុដែលអាចបង្កឱ្យកើតឡើងវិញចេញពីបរិស្ថានធម្មជាតិ ។

នីតិវិធី និងលក្ខខណ្ឌនៃការបញ្ចេញរុក្ខជាតិព្រៃចូលទៅក្នុងបរិស្ថានធម្មជាតិ ត្រូវកំណត់ដោយលិខិតបទដ្ឋានគតិយុត្តរបស់ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន ។

**មាត្រា៣៩៥**._ ការដោះលែងសត្វព្រៃចូលទៅក្នុងបរិស្ថានធម្មជាតិ

ប្រតិបត្តិករនៃទីតាំងបង្កាត់ពូជអភិរក្ស មជ្ឈមណ្ឌលសង្គ្រោះសត្វព្រៃ គ្រឹះស្ថានឧទ្យានសួនសត្វ និងទីតាំងរក្សាទុកសត្វព្រៃ ដែលដោះលែងសត្វដែលបានកើតក្នុងទីរក្សាទុក ឬសត្វដែលបានរក្សាទុក ត្រូវកំណត់អត្តសញ្ញាណ រៀបចំទីតាំងដោះលែងឱ្យបានសមរម្យ ត្រួតពិនិត្យសុខភាពសត្វនៅពេលដោះលែង និងអង្កេតតាមដានក្រោយពេលដោះលែង ស្របតាមស្តង់ដារអន្តរជាតិស្តីពីចត្តាឡីស័ក និងការពិនិត្យសុខភាពដែលមានការទទួលស្គាល់ជាអន្តរជាតិ ។

នីតិវិធី និងលក្ខណ្ឌនៃការដោះលែងសត្វព្រៃចូលទៅក្នុងបរិស្ថានធម្មជាតិ ត្រូវកំណត់ដោយលិខិតបទដ្ឋានគតិយុត្តរបស់ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន ។

**មាត្រា៣៩៦** ._ ការហាមឃាត់ចំពោះការបង្ខាំងប្រភេទសត្វព្រៃ

ត្រូវហាមឃាត់ចំពោះរាល់ការរក្សាទុកសត្វព្រៃនៃក្រុមប្រភេទទី១ ទី២ និងទី៣ ក្នុងគោលបំណងចិញ្ចឹម សម្តែង ឱ្យធ្វើការ ក្រៅពីទីតាំងបង្កាត់ពូជអភិរក្ស មជ្ឈមណ្ឌលសង្គ្រោះសត្វព្រៃ ឬគ្រឹះស្ថានឧទ្យានសត្វព្រៃដែលមានលិខិតអនុញ្ញាត លើកលែងតែមានការការអនុញ្ញាតជាក់លាក់ពីក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន ។

**មាត្រា៣៩៧ .**_ ការធ្វើកំណត់ត្រាសម្រាប់សត្វព្រៃនៅក្នុងទីតាំងរក្សាទុក

ទីតាំងបង្កាត់ពូជអភិរក្ស មជ្ឈមណ្ឌលសង្គ្រោះសត្វព្រៃ និងគ្រឹះស្ថានឧទ្យានសត្វព្រៃ ត្រូវធ្វើកំណត់ត្រាពីកំណើត ការងាប់ និងការផ្ទេរសត្វព្រៃនៃក្រុមប្រភេទទី១ និងទី២ ។

**មាត្រា៣៩៨ .**_ ការបោះបង់ចោលសំណាកនៃប្រភេទសត្វព្រៃ

ការបោះបង់ចោលបំណែកសាច់ ឬវត្ថុតាំងលម្អដែលធ្វើពីសត្វព្រៃដែលងាប់ ត្រូវធ្វើឡើងស្របតាមលិខិតបទដ្ឋានគតិយុត្តដែលពាក់ព័ន្ធ ។

## ជំពូកទី៩
## ការគ្រប់គ្រងកសិដ្ឋានចិញ្ចឹមសត្វព្រៃ

**មាត្រា៣៩៩.** _ ការហាមឃាត់

ត្រូវហាមឃាត់ចំពោះ ៖

១- ការចិញ្ចឹម ការថែរក្សា ការបង្កាត់ពូជ ការធ្វើសន្និធិ ឬការរក្សាទុក សម្រាប់គោលបំណងពាណិជ្ជកម្មចំពោះសត្វព្រៃនៃក្រុមប្រភេទទី១ និងទី២ ។

២- ការបង្កើតកសិដ្ឋានចិញ្ចឹមសត្វព្រៃ ដើម្បីចិញ្ចឹម ថែរក្សា បង្កាត់ពូជ ធ្វើសន្និធិ ឬរក្សាទុកសត្វព្រៃណាមួយក្នុងបរិវេណដែលមានចម្ងាយ ២០គីឡូម៉ែត្រ ពីសមាសភាគនៃប្រព័ន្ធតំបន់ការពារធម្មជាតិ ។

៣- ការនាំយកសត្វព្រៃដែលចាប់បានពីព្រៃ ចូលទៅក្នុងកសិដ្ឋានចិញ្ចឹមសត្វព្រៃ ។ កសិដ្ឋានចិញ្ចឹមសត្វព្រៃត្រូវមានតែប្រភេទសត្វដែលយកមកពីកសិដ្ឋានចិញ្ចឹមសត្វព្រៃដទៃទៀតដែលមានលិខិតអនុញ្ញាតតែប៉ុណ្ណោះ ។

**មាត្រា៤០០ .**_ ការចេញលិខិតអនុញ្ញាតសម្រាប់កសិដ្ឋានចិញ្ចឹមសត្វព្រៃ

កសិដ្ឋានចិញ្ចឹមសត្វព្រៃសម្រាប់គោលបំណងពាណិជ្ជកម្ម ត្រូវមានលិខិតអនុញ្ញាតពីក្រសួងស្ថាប័នទទួលបន្ទុកបរិស្ថាន ។

នីតិវិធី និងលក្ខខណ្ឌតម្រូវនៃការចេញលិខិតអនុញ្ញាតសម្រាប់កសិដ្ឋានចិញ្ចឹមសត្វព្រៃ ត្រូវកំណត់ដោយលិខិតបទដ្ឋានគតិយុត្តរបស់ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន ។

**មាត្រា៤០១** ._ កាតព្វកិច្ចរបស់ម្ចាស់កសិដ្ឋានចិញ្ចឹមសត្វព្រៃ

ម្ចាស់កសិដ្ឋានចិញ្ចឹមសត្វព្រៃដែលមានលិខិតអនុញ្ញាត ត្រូវមានកាតព្វកិច្ចថែទាំងសត្វព្រៃក្នុងកសិដ្ឋានដូចខាងក្រោម៖

១- ការផ្ទេរសត្វព្រៃពីកសិដ្ឋានមួយទៅកសិដ្ឋានមួយ ត្រូវមានលិខិតអនុញ្ញាត ។

២- រៀបចំទីជម្រក ទីធ្លា អាហារ និងទឹកឱ្យបានគ្រប់គ្រាន់ ។

៣- រៀបចំទីបង្ខាំងទុកឱ្យមានអនាម័យ និងមិនចង្អៀតពេក ។

៤- រៀបចំការគ្រប់គ្រងសត្វ សុខុមាលភាពសត្វ សត្តឃាត ឱ្យស្របតាមស្តង់ដារអន្តរជាតិ ។

៥- ត្រូវទប់ស្កាត់សត្វព្រៃពីការរត់គេចពីទីតាំងរក្សាទុកទឹក ចូលទៅក្នុងព្រៃធម្មជាតិ។ ក្នុងករណីមានសត្វព្រៃរត់គេច ត្រូវជូនដំណឹងដល់មន្ទីរទទួលបន្ទុកបរិស្ថានខេត្តភ្លាម និងត្រូវស្វែងរក និងចាប់មកវិញ ។

៦- លក្ខខណ្ឌតម្រូវដទៃទៀត ដែលកំណត់ដោយលិខិតបទដ្ឋានគតិយុត្តរបស់ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន ។

**មាត្រា៤០២** ._ ការធ្វើអធិការកិច្ច ការព្យួរ និងការលុបចោល

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន ដោយសហការជាមួយក្រសួង ស្ថាប័នមានសមត្ថកិច្ច ត្រូវធ្វើអធិការកិច្ចជាទៀងទាត់លើកសិដ្ឋានចិញ្ចឹមសត្វព្រៃ ។

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងក្រសួង ស្ថាប័នមានសមត្ថកិច្ចដទៃទៀត ត្រូវព្យួរ ឬដកហូតអាជ្ញាប័ណ្ណសម្រាប់កសិដ្ឋានចិញ្ចឹមសត្វព្រៃណាដែលមិនគោរពតាមលក្ខខណ្ឌនៃការអនុញ្ញាត ឬការហាមឃាត់ដទៃទៀតដែលបានកំណត់ក្នុងលិខិតបទដ្ឋានគតិយុត្តរបស់ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន ។

នីតិវិធីនៃការធ្វើអធិការកិច្ច ការព្យួរ ឬការដកហូតអាជ្ញាប័ណ្ណសម្រាប់កសិដ្ឋានចិញ្ចឹមសត្វព្រៃ ត្រូវកំណត់ដោយលិខិតបទដ្ឋានគតិយុត្តរបស់ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន ។

**មាត្រា៤០៣** ._ ការធ្វើកំណត់ត្រាដោយកសិដ្ឋានចញ្ចឹមសត្វព្រៃ

ម្ចាស់កសិដ្ឋានចិញ្ចឹមសត្វព្រៃ ត្រូវធ្វើ និងរក្សាកំណត់ត្រាអំពីសត្វដែលបានចិញ្ចឹម និងកើតក្នុងកសិដ្ឋានតាមទម្រង់បែបបទដែលកំណត់ដោយក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន ។

នីតិវិធី និងបែបបទនៃការធ្វើកំណត់ត្រាអំពីសត្វព្រៃនៅក្នុងកសិដ្ឋានចិញ្ចឹមសត្វព្រៃ ត្រូវកំណត់ដោយលិខិតបទដ្ឋានគតិយុត្តរបស់ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន ។

**មាត្រា៤០៤** ._ ប្រតិបត្តិការពាណិជ្ជកម្មទាក់ទងនឹងសំណាក និងផលិតផលសត្វព្រៃចិញ្ចឹម

ត្រូវហាមឃាត់ចំពោះការទិញ ការលក់ ការធ្វើពាណិជ្ជកម្មលើផលិតផល ឬសំណាកសត្វព្រៃរស់ ទៅឱ្យបុគ្គលណាមួយផ្សេងក្រៅពីកសិដ្ឋានចិញ្ចឹមសត្វព្រៃដែលមានលិខិតអនុញ្ញាត ។

ប្រតិបត្តិការពាណិជ្ជកម្មដែលទាក់ទងនឹងសំណាក និងផលិតផលដែលបានមកពីកសិដ្ឋានចិញ្ចឹមសត្វព្រៃ ត្រូវមានកំណត់ត្រាដែលនឹងត្រូវធ្វើអធិការកិច្ចដោយក្រសួង ស្ថាប័នមានសមត្ថកិច្ច ។

**មាត្រា៤០៥** ._ ចត្តាឡីស័ក និងការអង្កេតតាមដានសុខភាពសត្វព្រៃ

ម្ចាស់កសិដ្ឋានចិញ្ចឹមសត្វព្រៃ ត្រូវអនុវត្តការធ្វើចត្តាឡីស័ក និងការអង្កេតតាមដានសុខភាពសត្វព្រៃក្នុងកសិដ្ឋាន ជាទៀងទាត់។

នីតិវិធីនៃការអង្កេតតាមដានសុខភាពសត្វ និងការធ្វើចត្តាឡីស័ក ត្រូវកំណត់ដោយលិខិតបទដ្ឋានគតិយុត្តរបស់ក្រសួង ស្ថាប័នមានសមត្ថកិច្ច ។

ក្រសួង ស្ថាប័នមានសមត្ថកិច្ច ត្រូវកំណត់អត្តសញ្ញាណជំងឺសត្វព្រៃដែលគួរឱ្យកត់សម្គាល់ និងធ្វើការផ្សព្វផ្សាយជាសាធារណៈ ។

**មាត្រា៤០៦** ._ ការសម្លាប់ដោយមនុស្សធម៌

សត្តឃាតចំពោះសត្វព្រៃចិញ្ចឹម ត្រូវធ្វើឡើងដោយមនុស្សធម៌។

ក្រសួង ស្ថាប័នមានសមត្ថកិច្ច ត្រូវរៀបចំលិខិតបទដ្ឋានគតិយុត្តស្តីពីការសម្លាប់សត្វព្រៃចិញ្ចឹម។

## ជំពូកទី១០
## ការគ្រប់គ្រងសំណាកសត្វ និងរុក្ខជាតិព្រៃដែលរឹបអូសបាន

**មាត្រា៤០៧** ._ នីតិវិធីនៃការគ្រប់គ្រងសំណាកសត្វព្រៃរស់ដែលរឹបអូសបាន

គ្រប់សំណាកប្រភេទសត្វព្រៃដែលរឹបអូសបាន ជាសត្វរស់ ហើយមានដើមកំណើតក្នុងស្រុកដែលមានក្នុងបញ្ជីក្រុមប្រភេទទី១ ទី២ និងទី៣ ត្រូវទទួលបានការថែទាំផ្នែកបសុព្យាបាល និងត្រូវបញ្ជូន ជាបន្ទាន់ទៅកាន់អាជ្ញាធរជំនាញពង្រឹងការអនុវត្តច្បាប់ប្រឆាំងនឹងការជួញដូរសត្វព្រៃ ដូចបាន

កំណត់ដោយអាជ្ញាធរគ្រប់គ្រង នៃព្រះរាជាណាចក្រកម្ពុជា ដែលបានបង្កើតឡើង ស្របតាមអនុសញ្ញាស្តីពីពាណិជ្ជកម្មអន្តរជាតិ លើប្រភេទសត្វ និងរុក្ខជាតិដែលកំពុងរងគ្រោះថ្នាក់ ដើម្បីដឹកជញ្ជូនសំណាករស់នោះទៅកាន់មជ្ឈមណ្ឌលសង្គ្រោះសត្វព្រៃ ឬទីតាំងដទៃទៀតដែល ទទួលបានលិខិតអនុញ្ញាតដែលមានសុពលភាព និងបានចេញស្របតាមមាតិកានេះ និងដើម្បី ដោះលែងសំណាករស់នោះទៅកាន់ទីជម្រកធម្មជាតិរបស់វា តាមការសមស្រប ។

**មាត្រា៤០៨** ._ នីតិវិធីនៃការគ្រប់គ្រងសំណាកសត្វព្រៃដែលរឹបអូសបាន

សំណាកសត្វព្រៃរស់ នៃក្រុមប្រភេទទី១ ទី២ និងទី៣ទាំងអស់ ដែលមាន ឬមិនមានដើមកំណើតក្នុងព្រះរាជាណាចក្រកម្ពុជា និងដែលរឹបអូសបាន ត្រូវទទួលការចាក់ថ្នាំការពារថៃទាំភ្លាម ហើយត្រូវបញ្ជូនទៅកាន់អាជ្ញាធរប្រឆាំងការជួញដូរសត្វព្រៃ ដែលត្រូវបានបង្កើតតាមអនុសញ្ញាស្តីពីពាណិជ្ជកម្មអន្តរជាតិលើប្រភេទសត្វ និងរុក្ខជាតិដែលកំពុងរងគ្រោះថ្នាក់ ។

អាជ្ញាធរខាងលើរនេះ ត្រូវបញ្ជូនសំណាកទាំងនោះ ទៅកាន់មជ្ឈមណ្ឌលសង្គ្រោះសត្វព្រៃ ឬទីតាំងដែលមានការអនុញ្ញាតផ្សេងទៀតស្របតាមមាតិកានេះ ឬបញ្ជូនទៅកាន់ទីជម្រកដែលសមស្រប ។

សំណាកសត្វព្រៃងាប់នៃក្រុមប្រភេទទី១ ទី២ និងទី៣ ទាំងអស់ ដែលរឹបអូសបានត្រូវបញ្ជូនទៅក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន ដើម្បីកំទេចចោល ឬរក្សាទុកស្របតាមលិខិតបទដ្ឋានគតិយុត្តរបស់ក្រសួងបរិស្ថាន ។

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន ត្រូវរៀបចំលិខិតបទដ្ឋានគតិយុត្តស្តីពីនីតិវិធីនៃការគ្រប់គ្រងបំផ្លាញចោល និងរក្សាទុកសំណាកសត្វព្រៃងាប់ដែលរឹបអូសបាន ស្របតាមអនុសញ្ញាស្តីពីពាណិជ្ជកម្មអន្តរជាតិលើប្រភេទសត្វ និងរុក្ខជាតិដែលកំពុងរងគ្រោះថ្នាក់ ។

**មាត្រា៤០៩** ._ នីតិវិធីនៃការគ្រប់គ្រងសំណាករុក្ខជាតិព្រៃដែលរឹបអូសបាន

សំណាករុក្ខជាតិព្រៃរស់ និងសារធាតុដែលបង្កកំណើតឡើងវិញនៃក្រុមប្រភេទទី១ ទី២ និងទី៣ ទាំងអស់ ដែលរឹបអូសបាន ត្រូវបញ្ជូនទៅក្នុងប្រភេទទីជម្រកសមស្របវិញ ឬត្រូវបញ្ជូនទៅកាន់ស្ថាប័នភូតគាមសាស្ត្រ ស្ថាប័នរុក្ខសាស្ត្រ ស្ថាប័នសាកវប្បកម្ម ស្ថាប័នកសិកម្ម ឬទីតាំងរក្សាទុកដទៃទៀត ឬស្ថាប័នស្រាវជ្រាវដែលមានលិខិតអនុញ្ញាតសម្រាប់ការអភិរក្សរុក្ខជាតិព្រៃ ដែលបានបង្កើតឡើងតាមអនុសញ្ញាស្តីពីពាណិជ្ជកម្មអន្តរជាតិលើប្រភេទសត្វ និងរុក្ខជាតិដែលកំពុងរងគ្រោះថ្នាក់ ។

សំណាករុក្ខជាតិព្រៃងាប់ និងសារធាតុមិនអាចបង្កកំណើតឡើងវិញបាន នៃក្រុមប្រភេទទី១ ទី២ និងទី៣ ត្រូវថែរក្សា រក្សាទុក ឬបំផ្លាញចោល ស្របតាមលិខិតបទដ្ឋានគតិយុត្តស្តីពីនីតិវិធីនៃការ

គ្រប់គ្រងសំណាករុក្ខជាតិព្រៃងាប់ដែលរឹបអូសបាន ដែលត្រូវរៀបចំដោយក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន។

**មាត្រា៤១០ ._** ការរៀបចំរបាយការណ៍ស្តីពីសំណាកប្រភេទសត្វ និងរុក្ខជាតិព្រៃដែលរឹបអូសបានក្នុងការធ្វើពាណិជ្ជកម្មអន្តរជាតិ

ក្រសួង ស្ថាប័នមានសមត្ថកិច្ចដែលរឹបអូសបាននូវសត្វ រុក្ខជាតិព្រៃ ដូចបានកំណត់ក្នុងឧបសម្ព័ន្ធនៃអនុសញ្ញាស្តីពីពាណិជ្ជកម្មអន្តរជាតិលើប្រភេទសត្វ និងរុក្ខជាតិដែលកំពុងរងគ្រោះថ្នាក់ ពីការនាំចូលពីបណ្តាប្រទេសដទៃ ត្រូវរាយការណ៍ពីការរឹបអូសនេះ ក្នុងរយៈពេល ៤៨ (សែសិបប្រាំបី) ម៉ោង ទៅកាន់អាជ្ញាធរគ្រប់គ្រង នៃអនុសញ្ញាស្តីពីពាណិជ្ជកម្មអន្តរជាតិលើប្រភេទសត្វ និងរុក្ខជាតិដែលកំពុងរងគ្រោះថ្នាក់ ។

## ជំពូកទី១១
## កិច្ចសហប្រតិបត្តិការអន្តរជាតិ

**មាត្រា៤១១ ._** សហប្រតិបត្តិការអន្តរជាតិក្នុងការបង្ក្រាបបទល្មើស

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងក្រសួង ស្ថាប័ន មានសមត្ថកិច្ច ត្រូវសហការ និងផ្តល់ព័ត៌មានទៅឱ្យអាជ្ញាធរ អនុវត្តច្បាប់នៃរដ្ឋផ្សេងទៀតដើម្បីទប់ស្កាត់ កំណត់អត្តសញ្ញាណ និងបង្ក្រាបបទល្មើសនៅក្រោមយុត្តាធិការនៃរដ្ឋនីមួយៗ ។

**មាត្រា៤១២ ._** សហប្រតិបត្តិការក្នុងនីតិវិធីស៊ើបអង្កេត

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងក្រសួង ស្ថាប័នមានសមត្ថកិច្ច ត្រូវសហការជាមួយអាជ្ញាធរអនុវត្តច្បាប់នៃរដ្ឋផ្សេងទៀត និងអង្គការអន្តរជាតិ ដូចខាងក្រោម ៖

១- ផ្តល់ភស្តុតាងជាឯកសារ សក្ខីកម្ម សាក្សី សារធាតុផ្សេងៗ និងការធ្វើបទបង្ហាញបកស្រាយ សម្រាប់ការវិភាគ និងការស៊ើបអង្កេត ។

២- ផ្តល់អ្នកជំនាញការ ផ្លាស់ប្តូរបុគ្គលិក និងបង្កើតមន្ត្រីទទួលបន្ទុកទំនាក់ទំនងការងារ ។ ការផ្តល់ជូននូវអ្នកជំនាញការ ការផ្តល់ការឯកភាព ឬការដោះដូរបុគ្គលិក និងការបិទផ្សាយអំពីមន្ត្រីទំនាក់ទំនង ។

៣- ស៊ើបអង្កេតរួមគ្នា ។

៤- ធ្វើការចោទប្រកាន់ ។

៥- ផ្តល់ជំនួយផ្សេងទៀតតាមការស្នើសុំសម្រាប់ករណីនីមួយៗ ។

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន អាចចរចា និងចុះកិច្ចព្រមព្រៀងជំនួយផ្នែកច្បាប់ទៅវិញទៅមក ជាមួយអាជ្ញាធរអនុវត្តច្បាប់នៃរដ្ឋផ្សេងទៀត និងអង្គការអន្តរជាតិ ។

## មាតិកាទី៥
## ការគ្រប់គ្រងតំបន់ឆ្នេរ
## ជំពូកទោល
## បទប្បញ្ញត្តិទូទៅ

**មាត្រា៤១៣** ._ វិសាលភាព

មាតិកានេះ អនុវត្តចំពោះតំបន់ឆ្នេរទាំងអស់នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

**មាត្រា៤១៤** ._ តួនាទី និងការទទួលខុសត្រូវរបស់គណៈកម្មការជាតិគ្រប់គ្រង និងអភិវឌ្ឍតំបន់ឆ្នេរ

គណៈកម្មការជាតិគ្រប់គ្រង និងអភិវឌ្ឍតំបន់ឆ្នេរ មានភារកិច្ចគ្រប់គ្រង ត្រួតពិនិត្យ និងចេញបទប្បញ្ញត្តិពាក់ព័ន្ធនឹងសកម្មភាព និងការអភិវឌ្ឍន៍ ដែលបង្កផលប៉ះពាល់ចំពោះតំបន់ឆ្នេរ រួមមានៈ

១- កំណត់តំបន់គ្រប់គ្រងចំពោះតំបន់ឆ្នេរ និងការអភិវឌ្ឍន៍នៅក្នុងតំបន់ឆ្នេរឱ្យស្របគ្នាជាមួយការកំណត់តំបន់គ្រប់គ្រងឆ្នេរ ។

២- កំណត់វិធានការនានាក្នុងការអភិរក្សបរិស្ថាន និងការអភិវឌ្ឍន៍ដោយចីរភាព ដើម្បីដាក់បញ្ចូលទៅក្នុងគោលនយោបាយ ផែនការសកម្មភាព ផែនការមេ កម្មវិធី និងគម្រោងដែលបង្កផលប៉ះពាល់ចំពោះការគ្រប់គ្រងតំបន់ឆ្នេរ ។

៣- កំណត់យុទ្ធសាស្ត្រនៃការកាត់បន្ថយ និងបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ ដើម្បីដាក់បញ្ចូលទៅក្នុងគោលនយោបាយ ផែនការសកម្មភាព ផែនការមេ កម្មវិធី និងគម្រោងដទៃទៀត ដែលបង្កផលប៉ះពាល់នៅក្នុងតំបន់ឆ្នេរ ។

៤- គ្រប់គ្រងធនធានធម្មជាតិ និងសកម្មភាពមនុស្សដែលមានលក្ខណៈចម្រុះនៅក្នុងតំបន់ឆ្នេរ ដើម្បីបញ្ចៀស ឬកាត់បន្ថយផលប៉ះពាល់ឱ្យដល់កម្រិតអប្បបរមានៅក្នុងតំបន់ឆ្នេរ ។

៥- គ្រប់គ្រងលើការបំពុលបរិស្ថានដែលមានប្រភពមកពីដី ដែលរួមមានសារធាតុបំពុលរឹង រាវ សារធាតុបំពុលតាមខ្យល់ ដែលអាចជ្រាបចូលទៅក្នុងដែនទឹកតំបន់ឆ្នេរ ។

៦- ការពារតំបន់ឆ្នេរមិនឱ្យមានការហូរច្រោះដី ព្យុះកន្ត្រាក់ និងផលប៉ះពាល់ស្រដៀងគ្នាដទៃទៀត ។

៧- ផ្តល់ឱកាសឱ្យមានការចូលរួមជាសាធារណៈ ស្របតាមបទប្បញ្ញត្តិស្តី នៃក្រមនេះ និង

៨- អនុវត្តតាមវិធានការចាំបាច់ដទៃទៀត ដើម្បីគ្រប់គ្រងប្រកបដោយប្រសិទ្ធភាព និងការអភិវឌ្ឍដោយចីរភាពនៃតំបន់ឆ្នេរ ។

**មាត្រា៤១៥** ._ ការគាំទ្រខាងផ្នែកបច្ចេកទេសរបស់ក្រសួង ស្ថាប័នទទួលបន្ទុកអភិវឌ្ឍន៍ដោយចីរភាព

ក្រសួង ស្ថាប័នទទួលបន្ទុកអភិវឌ្ឍន៍ដោយចីរភាព ត្រូវផ្តល់គាំទ្រខាងផ្នែកបច្ចេកទេសដល់គណៈកម្មការជាតិគ្រប់គ្រង និងអភិវឌ្ឍតំបន់ឆ្នេរ ដើម្បីអនុវត្តគោលនយោបាយក្នុងការការពារ និងលើកកម្ពស់ធនធានធម្មជាតិ និងបរិស្ថាន និងការអភិវឌ្ឍតំបន់ឆ្នេរដោយចីរភាព ប្រកបដោយប្រសិទ្ធផល និងប្រសិទ្ធភាព ។

**មាត្រា៤១៦**._ សកម្មភាពដែលត្រូវហាមឃាត់

ត្រូវហាមឃាត់ចំពោះសកម្មភាពនានា រួមមាន ការសាងសង់ហេដ្ឋារចនាសម្ព័ន្ធ ការធ្វើអាជីវកម្មរ៉ែខ្សាច់ ដែលបង្កឱ្យមានការបាត់បង់ ឬការខូចខាតនៅក្នុងតំបន់ឆ្នេរ ដូចខាងក្រោម ៖

១- ផ្កាថ្ម ។

២- ស្មៅសមុទ្រ ។

៣- ព្រៃកោងកាង ។

៤- ទីតាំងបង្កាត់ពូជមច្ឆាជាតិទឹកសាប និងទឹកសមុទ្រ និងធនធានជលផលដទៃទៀត ។

**មាត្រា៤១៧** ._ សកម្មភាពដែលអាចមានផលប៉ះពាល់អវិជ្ជមានចំពោះតំបន់ឆ្នេរ

រាល់ការផ្តល់ការឯកភាពចំពោះសកម្មភាពនានា ដែលអាចបង្កផលប៉ះពាល់ជាអវិជ្ជមានចំពោះតំបន់ឆ្នេរ ត្រូវធ្វើឡើងស្របគ្នាជាមួយនឹងវិធានការដែលកំណត់នៅក្នុងផែនការគ្រប់គ្រងបរិស្ថានដែលទទួលបានការឯកភាព ដើម្បីកាត់បន្ថយផលប៉ះពាល់ជាអវិជ្ជមានចំពោះតំបន់ឆ្នេរ ។

មុននឹងចេញលិខិតអនុញ្ញាត ឱ្យមានការអភិវឌ្ឍន៍នៅក្នុងតំបន់ឆ្នេរ គណៈកម្មការជាតិគ្រប់គ្រង និងអភិវឌ្ឍតំបន់ឆ្នេរ ត្រូវកំណត់ឱ្យបានថា ៖

១- សកម្មភាព ឬគម្រោងស្នើសុំឯកជន ឬសាធារណៈ ស្របគ្នាជាមួយនឹងផែនការប្រើប្រាស់ដី ដូចមានចែងនៅក្នុងនៃក្រមនេះ ។

២- សកម្មភាព ឬគម្រោងស្នើសុំឯកជន ឬសាធារណៈ បានដាក់បញ្ចូលនូវវិធានការក្នុងការបញ្ចៀស និងកាត់បន្ថយឱ្យដល់កម្រិតអប្បបរមានូវផលប៉ះពាល់ចំពោះតំបន់ឆ្នេរ ។

៣- ផលប៉ះពាល់ជាសក្តានុពលនៃការប្រែប្រួលអាកាសធាតុ ត្រូវបានព្យាករណ៍ទុក និងកាត់បន្ថយ ដែលរួមមាន ការហូរច្រោះនៅតំបន់ឆ្នេរ និងតំបន់គ្រោះថ្នាក់ដោយទឹកជំនន់សម្រាប់ដែនដីតំបន់ឆ្នេរ និងការគ្រប់គ្រងហានិភ័យគ្រោះមហន្តរាយ នីតិវិធីនៃការជម្លៀសប្រជាពលរដ្ឋ និងហេដ្ឋារចនាសម្ព័ន្ធដើម្បីការពារតំបន់ឆ្នេរពីការប្រែប្រួលអាកាសធាតុ ។

៤- ផលប៉ះពាល់ជាសក្តានុពលពីការបញ្ចេញសំណល់កករ និងសំណល់រាវ ចូលទៅក្នុងតំបន់ឆ្នេរ ត្រូវបានកាត់បន្ថយឱ្យដល់កម្រិតអប្បបរមា ឬបញ្ចៀស ដោយមានការគ្រប់គ្រងសំណល់ប្រកប ដោយប្រសិទ្ធផល ។

៥- ការងារចាក់បំពេញដើម្បីយកដីមកប្រើប្រាស់ ត្រូវបានកាត់បន្ថយឱ្យដល់កម្រិតអប្បបរមា និង

៦- លក្ខណៈវិនិច្ឆ័យដទៃទៀត ដែលបានកំណត់នៅក្នុងលិខិតបទដ្ឋានគតិយុត្តរបស់ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន ។

ត្រូវហាមឃាត់ជាដាច់ខាតចំពោះការផ្តល់ការឯកភាពលើសកម្មភាព និងការអភិវឌ្ឍន៍ទាំងឡាយណានៅក្នុងតំបន់ឆ្នេរ លើកលែងតែមានភស្តុតាងច្បាស់លាស់ដែលបញ្ជាក់ថាសំណើការអភិវឌ្ឍ ឬសកម្មភាពចំពោះគម្រោងស្នើសុំ បានពិចារណាអំពីផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុនៅក្នុងតំបន់ឆ្នេរដូចខាងក្រោម ៖

១- ផលប៉ះពាល់ដែលកើតមានដល់គម្រោង ។

២- ផលប៉ះពាល់ដែលបង្កឡើងដោយគម្រោង ឬការអភិវឌ្ឍន៍ដែលបានស្នើសុំ រួមមានព្រឹត្តិការណ៍ខ្យល់ព្យុះ ការជន់លិច ការបាក់ស្រុតឆ្នេរ និង

៣- កត្តាដទៃទៀត ។

**មាត្រា៤១៨** ._ ការរៀបចំលិខិតបទដ្ឋានគតិយុត្តស្តីពីការគ្រប់គ្រងតំបន់ឆ្នេរ

គណៈកម្មការជាតិគ្រប់គ្រង និងអភិវឌ្ឍតំបន់ឆ្នេរ ដោយសហការជាមួយក្រសួង ស្ថាប័នមានសមត្ថកិច្ច ត្រូវរៀបចំលិខិតបទដ្ឋានគតិយុត្តស្តីពីការគ្រប់គ្រងតំបន់ឆ្នេរ ដោយដាក់បញ្ចូលនូវចំណុចដូចខាងក្រោម ៖

១- ការរៀបចំផែនការប្រើប្រាស់ដី និងការកំណត់តំបន់គ្រប់គ្រងនៅក្នុងតំបន់ឆ្នេរ ។

២- វិធានការដើម្បីប្រយុទ្ធប្រឆាំងនឹងផលប៉ះពាល់ជាអវិជ្ជមាននៃការប្រែប្រួលអាកាសធាតុចំពោះតំបន់ឆ្នេរ ។

៣- វិធានការក្នុងត្រួតពិនិត្យការបំពុលទឹកពីប្រភពខាងលើចូលទៅក្នុងតំបន់ឆ្នេរ ។

៤- វិធានការក្នុងការការពារផ្កាថ្ម ស្មៅសមុទ្រ និងព្រៃកោងកាង និង

៥- ការចូលរួមជាសាធារណៈនៅក្នុងការគ្រប់គ្រងតំបន់ឆ្នេរ ។

## មាតិកាទី៦
## ការគ្រប់គ្រងធនធានទឹកដោយចីរភាព
## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ
## ផ្នែកទី១
## វិសាលភាព និងគោលការណ៍

**មាត្រា៤១៩** ._ វិសាលភាព

មាតិកានេះមានវិសាលភាពអនុវត្តចំពោះធនធានទឹកទាំងអស់ នៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា៤២០** ._ គោលការណ៍នៃការគ្រប់គ្រងធនធានទឹករួមគ្នា

ទឹក និងធនធានទឹក ត្រូវស្ថិតក្រោមការគ្រប់គ្រង និង អភិវឌ្ឍន៍ដោយផ្អែកលើគោលការណ៍ដូចខាងក្រោម ៖

១- សមធម៌សង្គម ៖ ធ្វើឱ្យមានសមភាពនៃការទទួលបានទឹកសម្រាប់អ្នកប្រើប្រាស់ទាំងអស់ ដោយយកចិត្តទុកដាក់ចំពោះ ក្រុមមនុស្សដែលមិនសូវបានទទួលការយកចិត្តទុកដាក់ និងដែលមិនមានតំណាងគ្រប់គ្រាន់ ក្នុងការទទួលបានទឹកក្នុងបរិមាណ និងគុណភាពគ្រប់គ្រាន់ ដើម្បីទ្រទ្រង់សុខុមាលភាព ។

២- ប្រសិទ្ធផលសេដ្ឋកិច្ច ៖ ផ្តល់ផលប្រយោជន៍ខ្ពស់បំផុតឱ្យទៅអ្នកប្រើប្រាស់ជាអតិបរមា សម្រាប់ធនធានហិរញ្ញវត្ថុ និងធនធានទឹកដែលបានប្រើប្រាស់ ។

៣- ចីរភាពអេកូឡូស៊ី ៖ តម្រូវឱ្យធ្វើការបែងចែងទឹកគ្រប់គ្រាន់ ដើម្បីធ្វើឱ្យមានចីរភាពនៃមុខងារតាមធម្មជាតិនៃពពួកសត្វ និងរុក្ខជាតិដែលទទួលការគំរាមកំហែង និងប្រព័ន្ធអេកូឡូស៊ី ។

**មាត្រា៤២១ ._** កត្តាដែលត្រូវពិចារណាសម្រាប់ការអនុវត្ត

នៅពេលអនុវត្តការគ្រប់គ្រងធនធានទឹកជាលក្ខណៈអន្តរវិស័យ ក្រសួង ស្ថាប័នទទួលបន្ទុកធនធានទឹក និងឧត្តុនិយម ត្រូវពិចារណាចំណុចដូចខាងក្រោម ៖

១- គ្រប់ទិដ្ឋភាពនៃធនធានទឹក ។

២- ទំនាក់ទំនងរវាងធនធានទឹក និងសមាសភាគដទៃទៀតនៃបរិស្ថានធម្មជាតិ រួមមាន ដីធ្លី ជលផល រុក្ខជាតិ សត្វ ជាអាទិ៍។

៣- លក្ខខណ្ឌតម្រូវសម្រាប់ការប្រើប្រាស់ទឹករបស់ប្រជាពលរដ្ឋ និងបរិស្ថានធម្មជាតិឱ្យមានប្រសិទ្ធភាព និងចីរភាព ។

**មាត្រា៤២២ ._** ការសហការរវាងក្រសួង ស្ថាប័នមានសមត្ថកិច្ច

ក្រសួង ស្ថាប័នមានសមត្ថកិច្ចទាំងអស់ ដែលទទួលខុសត្រូវលើការប្រើប្រាស់ទឹក ការអភិវឌ្ឍន៍ និងការគ្រប់គ្រងធនធានវារីជាតិដោយចីរភាពលើធនធានសត្វ និងរុក្ខជាតិក្នុងទឹកដែលមានជីវិត និងប្រព័ន្ធអេកូឡូស៊ីដែលពាក់ព័ន្ធ ត្រូវសហការអនុវត្តការគ្រប់គ្រងធនធានទឹកជាលក្ខណៈរួមគ្នា ។

**មាត្រា៤២៣ ._** ការរួមចំណែករបស់អ្នកពាក់ព័ន្ធ

ក្រសួង ស្ថាប័នមានសមត្ថកិច្ច ត្រូវសហការជាមួយនីតិបុគ្គលសាធារណៈ និងឯកជន ដើម្បីគ្រប់គ្រង វិនិយោគ ធ្វើអាជីវកម្ម អភិរក្ស និងអភិវឌ្ឍធនធានទឹក ។

## ផ្នែកទី២
## ម្ចាស់កម្មសិទ្ធិលើទឹក និងធនធានទឹក

**មាត្រា៤២៤ ._** កម្មសិទ្ធិលើធនធានទឹក

ទឹក និងធនធានទឹកទាំងអស់ ជាសម្បត្តិរដ្ឋ ។

**មាត្រា៤២៥ ._** ការបែងចែកទឹក

ការបង្វែរទឹកឆ្លងដែនចេញពីដែនដីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវមានការអនុញ្ញាត និងការឯកភាព ពីរាជរដ្ឋាភិបាល និងមានការអនុម័តយល់ព្រមដោយស្ថាប័ននីតិបញ្ញត្តិ ។

## ជំពូកទី២
## ការទទួលខុសត្រូវធនធានទឹក
### ផ្នែកទី១
### ការទទួលខុសត្រូវរបស់ក្រសួង ស្ថាប័នមានសមត្ថកិច្ច

**មាត្រា៤២៦** ._ ភារកិច្ច និងតួនាទីរបស់ក្រសួង ស្ថាប័នទទួលបន្ទុក

ក្រសួង ស្ថាប័នទទួលបន្ទុកធនធានទឹកត្រូវ ៖

១- គ្រប់គ្រង ដឹកនាំ និងត្រួតពិនិត្យការអនុវត្តបទប្បញ្ញត្តិពាក់ព័ន្ធនឹងធនធានទឹកនៃក្រមនេះ ។

២- ធ្វើការពិគ្រោះយោបល់ជាមួយក្រសួង ស្ថាប័នមានសមត្ថកិច្ច និងអ្នកពាក់ព័ន្ធដទៃទៀត ក្នុងការបំពេញមុខងារ ។

**មាត្រា៤២៧** ._ បញ្ជីសារពើភណ្ឌធនធានទឹកថ្នាក់ជាតិ

ក្រសួង ស្ថាប័នទទួលបន្ទុកធនធានទឹក ត្រូវរក្សាទុកនូវរាល់បញ្ជីសារពើភណ្ឌធនធានទឹកថ្នាក់ជាតិ នៃព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា៤២៨** ._ ទិន្នន័យធនធានទឹក

ទិន្នន័យស្ដីពីបរិមាណ និងគុណភាពទឹក និងព័ត៌មានផ្សេងទៀតពាក់ព័ន្ធនឹងទឹក ដែលប្រមូលបានដោយក្រសួង ស្ថាប័នមានសមត្ថកិច្ច ត្រូវបញ្ជូនមកក្រសួង ស្ថាប័នទទួលបន្ទុកធនធានទឹក ស្របតាមស្តង់ដារបច្ចេកទេស ដែលកំណត់ដោយក្រសួង ស្ថាប័នទទួលបន្ទុកធនធានទឹក ។

ទិន្នន័យពាក់ព័ន្ធនឹងធនធានទឹក ត្រូវដាក់បញ្ជូនទៅក្រសួង ស្ថាប័នមានសមត្ថកិច្ច ឬក្រសួង ស្ថាប័នទទួលបន្ទុកធនធានទឹក យ៉ាងហោចណាស់ ១ (មួយ)ឆ្នាំម្តង ។

**មាត្រា៤២៩** ._ ទិន្នន័យដែលអាចស្វែងរកបាន

ទិន្នន័យ និងព័ត៌មាន ដូចមានចែងក្នុងមាត្រា៤២៨ខាងលើនេះ ត្រូវផ្តល់ជូនបានដោយឥតគិតថ្លៃដល់ក្រសួង ស្ថាប័នមានសមត្ថកិច្ច និងអ្នកពាក់ព័ន្ធដែលមានចំណាប់អារម្មណ៍ ក្នុងទិសដៅបម្រើផលប្រយោជន៍សាធារណៈ លើកលែងតែព័ត៌មានសម្ងាត់ ។

ក្រសួង ស្ថាប័នទទួលបន្ទុកធនធានទឹក អាចតម្រូវឱ្យមានការបង់ថ្លៃ ចំពោះពាក្យស្នើសុំទាំងឡាយ ដែលធ្វើឡើងក្នុងគោលបំណងអាជីវកម្ម ។

**មាត្រា៤៣០** ._ ការរៀបចំលិខិតបទដ្ឋានគតិយុត្ត

ក្រសួង ស្ថាប័នទទួលបន្ទុកធនធានទឹក អាចរៀបចំលិខិតបទដ្ឋានគតិយុត្ត ដោយដាក់បញ្ចូល នូវចំណុច ដូចខាងក្រោម ៖

១- តំបន់ហាមឃាត់ការប្រើប្រាស់ទឹក ឬការសាងសង់ហេដ្ឋារចនាសម្ព័ន្ធ ។

២- ការរៀបចំបទប្បញ្ញត្តិពាក់ព័ន្ធនឹងហេដ្ឋារចនាសម្ព័ន្ធ សម្រាប់ការយកទឹក ឬ ប្រើប្រាស់ធនធានទឹក ។

៣- ការបង្កើត និងការគ្រប់គ្រងអាជ្ញាធរអាងទន្លេ ។

៤- បញ្ហាជាអាទិភាពសម្រាប់ដាក់បញ្ចូលទៅក្នុងផែនការធនធានទឹកអាងទន្លេ ។

៥- ការលើកទឹកចិត្តឱ្យមានការស្រាវជ្រាវ ឬ ការអភិវឌ្ឍន៍បច្ចេកវិទ្យាថ្មីៗ ដែលនឹងរួមចំណែកក្នុងការកាត់បន្ថយសំណល់ និងការកែលម្អគុណភាពទឹក និងបង្កើនប្រសិទ្ធផលនៃការប្រើប្រាស់ទឹក ។

៦- ការលើកទឹកចិត្ត និងមិនលើកទឹកចិត្ត ទាក់ទងនឹងយន្តការហិរញ្ញវត្ថុ រួមមាន ការប្រើប្រាស់ប្រាក់កម្រៃ និងតារាងថ្លៃតាមអត្រាថយចុះ ដើម្បីលើកទឹកចិត្តឱ្យមានការប្រើប្រាស់ទឹកដោយប្រសិទ្ធផល ។

៧- ការបង្កើត និង គ្រប់គ្រងសមាគមន៍កសិករប្រើប្រាស់ប្រើប្រាស់ទឹក ។

៨- ការប្រកាសស្តីពីតំបន់ប្រើប្រាស់ទឹក ដែលត្រូវការពារធម្មជាតិ ។

៩- ការកំណត់ និងគ្រប់គ្រងតំបន់ការពារគ្រោះទឹកជំនន់ ។

១០- ការលុប ឬផ្លាស់ប្តូរលំហូរទឹកតាមធម្មជាតិ ។

១១- ការរៀបចំបទប្បញ្ញត្តិស្តីពីការអភិវឌ្ឍទឹកក្រោមដី និងឧស្សាហកម្មអភិវឌ្ឍន៍ទឹកក្រោមដី រួមមាន៖

- គុណវុឌ្ឍិសម្រាប់អ្នកម៉ៅការជីកអណ្តូង និងអ្នកដំឡើងអណ្តូងខួង ។
- លក្ខខណ្ឌតម្រូវដែលបញ្ជាក់ថា ម៉ាស៊ីនខួងអណ្តូងបានធ្វើប្រតិបត្តិការ ស្របតាមវិញ្ញាបនបត្រ នៃអ្នកកាន់កាប់លិខិតអនុញ្ញាតខួងអណ្តូង ។
- យកសំណាក ធ្វើតេស្ត វិភាគ សិក្សា និងដាក់បញ្ចូលទិន្នន័យអណ្តូងខួង និងបញ្ជូនទិន្នន័យទាំងនេះទៅក្រសួង ស្ថាប័នទទួលបន្ទុកធនធានទឹក ។

- ការស្តាងអណ្តូងឡើងវិញ និងវិធីសាស្ត្រ និងលក្ខខណ្ឌតម្រូវ ដែលត្រូវអនុវត្ត ចំពោះប្រតិបត្តិការស្តារអណ្តូងឡើងវិញ ។

- សកម្មភាពជួសជុលអណ្តូង ។

- ការត្រួតពិនិត្យអណ្តូង ។

- វិធីសាស្ត្រនៃការខួង និងការជីកអណ្តូង និងការកំណត់ប្រភពទឹកក្រោមដី ។

- វិធានការ និងការប្រុងប្រយ័ត្នជាមុន ដែលត្រូវអនុវត្តមុនពេល និងក្នុងអំឡុង ពេលនៃការខួង ការជីក និងការកែលម្អអណ្តូង ។

- គោរពតាមការថែរក្សានានាសម្រាប់អណ្តូងដែលមិនដំណើរការ ។

- ជួសជុល និងថែទាំអណ្តូងមិនដំណើរការ ។

- ការថែទាំ និងធ្វើប្រតិបត្តិជួសជុលអណ្តូងជាប្រចាំ ។

១២- ការកំណត់បន្ទុកសេវា និងថ្លៃចំណាយនានា សម្រាប់ការគ្រប់គ្រងធនធានទឹក ស្របតាមបទប្បញ្ញត្តិនៃក្រមនេះ ។

## ផ្នែកទី២
## ការសម្របសម្រួលរបស់រាជរដ្ឋាភិបាល

**មាត្រា៤៣១** ._ គណៈកម្មាធិការជាតិគ្រប់គ្រង និងរៀបចំផែនការអាងទន្លេ

ក្រសួង ស្ថាប័នទទួលបន្ទុកធនធានទឹក ដោយសហការជាមួយក្រសួង ស្ថាប័នមានសមត្ថកិច្ច និងគណៈកម្មាធិការជាតិទន្លេមេគង្គ ត្រូវរៀបចំលិខិតបទដ្ឋានគតយុត្ត ដើម្បីបង្កើតគណៈកម្មាធិការ ជាតិគ្រប់គ្រង និងរៀបចំផែនការអាងទន្លេ ។

**មាត្រា៤៣២** ._ ភារៈកិច្ច និងតួនាទីគណៈកម្មាធិការជាតិគ្រប់គ្រង និងរៀបចំផែនការអាងទន្លេ

គណៈកម្មាធិការជាតិគ្រប់គ្រង និងរៀបចំផែនការអាងទន្លេ មានភារកិច្ច និងតួនាទីដូចខាង ក្រោម ៖

១- សម្របសម្រួល និងត្រួតពិនិត្យលើការរៀបចំផែនការយុទ្ធសាស្ត្រជាតិធនធានទឹក សម្រាប់គោលបំណងនៃការគ្រប់គ្រង ការពារ អភិរក្ស និងអភិវឌ្ឍន៍អាងទន្លេ ។

២- អង្កេតតាមដាន និងវាយតម្លៃលើការអនុវត្តផែនការយុទ្ធសាស្ត្រជាតិធនធានទឹក ។

៣- សម្រុះសម្រួល និងដោះស្រាយទំនាស់ក្នុងការគ្រប់គ្រង ការពារ អភិរក្ស និងអភិវឌ្ឍន៍អាងទន្លេ និង

៤- អនុវត្តកិច្ចការដទៃទៀតតាមការប្រគល់ជូនរបស់រាជរដ្ឋាភិបាល ។

**មាត្រា៤៣៣ .**_ សិទ្ធិ និងកាតព្វកិច្ចក្នុងការចូលរួមប្រើប្រាស់ អភិវឌ្ឍន៍ និងគ្រប់គ្រងទន្លេអន្តរជាតិ

ព្រះរាជាណាចក្រកម្ពុជា មានសិទ្ធិ និងកាតព្វកិច្ច ចាត់ចែងចំណែកសមស្រប និងដោយស្មើភាពក្នុងការប្រើប្រាស់ ការអភិវឌ្ឍន៍ និងការគ្រប់គ្រងទន្លេអន្តរជាតិ ក្នុងទឹកដីរបស់ខ្លួន ស្របតាមសិទ្ធិ និងកាតព្វកិច្ច ដែលមានចែងក្នុងកិច្ចព្រមព្រៀងអន្តរជាតិដែលព្រះរាជាណាចក្រកម្ពុជាជាភាគី ។

**មាត្រា៤៣៤ .**_ ការប្រើប្រាស់ដែលសមស្រប និងមានប្រសិទ្ធភាពបំផុត

ក្រសួង ស្ថាប័នទទួលបន្ទុកធនធានទឹក ត្រូវយកចិត្តទុកដាក់ឱ្យមានការប្រើប្រាស់ទឹកអាងទន្លេមេគង្គលើគ្រប់វិស័យ ស្របតាមគោលការណ៍គណៈកម្មាធិការជាតិទន្លេមេគង្គ ។

## ជំពូកទី៣
## ការរៀបចំផែនការធនធានទឹក
### ផ្នែកទី១
### ក្រសួង ស្ថាប័នទទួលបន្ទុក

**មាត្រា៤៣៥ .**_ ផែនការយុទ្ធសាស្ត្រធនធានទឹកថ្នាក់ជាតិ និងផែនការធនធានទឹកអាងទន្លេ

ក្រសួង ស្ថាប័នទទួលបន្ទុកធនធានទឹក ត្រូវរៀបចំសម្រាប់ការបែងចែក និងការគ្រប់គ្រងធនធានទឹកដោយចីរភាព ដើម្បីបំពេញតាមតម្រូវការទឹកក្នុងពេលអនាគត តាមរយៈការរៀបចំផែនការយុទ្ធសាស្ត្រធនធានទឹកថ្នាក់ជាតិ និងផែនការធនធានទឹកអាងទន្លេ ។

**មាត្រា៤៣៦ .**_ ការចូលរួមរបស់អ្នកពាក់ព័ន្ធ

នៅក្នុងការរៀបចំផែនការធនធានទឹកជាយុទ្ធសាស្ត្រថ្នាក់ជាតិ និងផែនការធនធានទឹកនៃអាងទន្លេ ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យធនធានទឹក ត្រូវសហការជាមួយគ្រប់ភាគីដែលពាក់ព័ន្ធដែលមានចំណាប់អារម្មណ៍ មានជាអាទិ៍ អាជ្ញាធរថ្នាក់ក្រោមជាតិ វិស័យឯកជន ក្រុមអ្នកទទួលប្រយោជន៍ និងនីតិបុគ្គលផ្សេងៗទៀត ។

ក្រសួង ស្ថាប័នទទួលបន្ទុកធនធានទឹក ត្រូវសហការជាមួយក្រសួង ស្ថាប័នមានសមត្ថកិច្ច រដ្ឋបាលថ្នាក់ក្រោមជាតិ អ្នកពាក់ព័ន្ធដែលមានចំណាប់អារម្មណ៍ ដើម្បីរៀបចំផែនការយុទ្ធសាស្ត្រធនធានទឹកថ្នាក់ជាតិ និងផែនការធនធានទឹកអាងទន្លេ ។

**មាត្រា៤៣៧** ._ ការធ្វើប្រតិភូកម្មអំណាច

ក្រសួង ស្ថាប័នទទួលបន្ទុកធនធានទឹក អាចធ្វើប្រតិភូកម្មអំណាចឱ្យអាជ្ញាធរអាងទន្លេ ដើម្បីរៀបចំផែនការយុទ្ធសាស្ត្រធនធានទឹកថ្នាក់ជាតិ និងផែនការធនធានទឹកអាងទន្លេ ។

**មាត្រា៤៣៨** ._ ការរៀបចំ និងអនុវត្តផែនការធនធានទឹកអាងទន្លេ

អាជ្ញាធរអាងទន្លេ ដែលទទួលបន្ទុកក្នុងការរៀបចំ និងអនុវត្តផែនការធនធានទឹកអាងទន្លេស្របតាមមាត្រា៤៣៥ នៃក្រមនេះ ត្រូវអនុវត្តតាមបទប្បញ្ញត្តិនានានៃមាតិកានេះ ។

**មាត្រា៤៣៩** ._ ព័ត៌មានសម្រាប់គោលបំណងនៃការរៀបចំផែនការ

ក្រសួង ស្ថាប័នទទួលបន្ទុកធនធានទឹក ត្រូវប្រមូលយក រក្សាទុក និងប្រើប្រាស់ព័ត៌មានសម្រាប់គោលបំណងនៃការរៀបចំផែនការ ដោយ ៖

១- ធ្វើការផ្ទៀងផ្ទាត់ជាប្រចាំ និងរក្សាទុកកំណត់ត្រា អំពីបរិមាណ និងគុណភាពទឹក ។

២- ប្រមូលព័ត៌មានអំពីតម្រូវការទឹក និងព័ត៌មានស្តីពីផលប៉ះពាល់នៃការគ្រប់គ្រងទឹកចំពោះប្រព័ន្ធអេកូឡូស៊ីធម្មជាតិ ធនធានជលផលទឹកសាបនិងសមុទ្រ និងប្រភេទសត្វនិងរុក្ខជាតិដែលរងការគំរាមកំហែង ពីក្រសួង ស្ថាប័នមានសមត្ថកិច្ច និងអ្នកពាក់ព័ន្ធ ។

៣- ប្រមូលព័ត៌មានអំពីតម្រូវការទឹកនាពេលអនាគត ។

៤- ធ្វើការកែលម្អជាប្រចាំចំពោះបណ្តាញជាតិសម្រាប់ការអង្កេតតាមដាន ដើម្បីប្រមូលព័ត៌មានពាក់ព័ន្ធ ។

**មាត្រា៤៤០** ._ ក្រុមប្រឹក្សាពិគ្រោះយោបល់បច្ចេកទេស

ក្រសួង ស្ថាប័នទទួលបន្ទុកធនធានទឹក ត្រូវបង្កើតក្រុមប្រឹក្សាពិគ្រោះយោបល់បច្ចេកទេស ។

សមាសភាពនៃក្រុមប្រឹក្សាពិគ្រោះយោបល់បច្ចេកទេស ត្រូវមានអ្នកជំនាញបច្ចេកទេស ដែលមានគុណវុឌ្ឍិគ្រប់គ្រាន់ ។ គុណវុឌ្ឍិនៃអ្នកជំនាញបច្ចេកទេស ត្រូវកំណត់ដោយក្រសួង ស្ថាប័នទទួលបន្ទុកធនធានទឹក ។

អ្នកជំនាញបច្ចេកទេស ត្រូវធ្វើការផ្តល់យោបល់លើ ៖

១- សេចក្តីព្រាងផែនការយុទ្ធសាស្ត្រថ្នាក់ជាតិធានទឹក និងសេចក្តីព្រាងផែនការធនធានទឹកអាងទន្លេ ។

២- វិសោធនកម្ម ឬបច្ចុប្បន្នភាព នៃផែនការយុទ្ធសាស្ត្រថ្នាក់ជាតិធានទឹក និងផែនការធនធានទឹកអាងទន្លេ ។

៣- ការផ្តល់សិទ្ធិអំណាចផ្សេងទៀត ស្របតាមបទប្បញ្ញត្តិនៃក្រមនេះ ។

## ផ្នែកទី២
## ផែនការយុទ្ធសាស្ត្រជាតិធនធានទឹក

**មាត្រា៤៤១** ._ គោលដៅនៃផែនការយុទ្ធសាស្ត្រជាតិធនធានទឹក

ក្រសួង ស្ថាប័នទទួលបន្ទុកធនធានទឹក ត្រូវរៀបចំផែនការយុទ្ធសាស្ត្រជាតិធនធានទឹក ដែលកំណត់អំពី ៖

១- សន្តិសុខនៃការផ្គត់ផ្គង់ទឹករយៈពេលវែង ។

២- ចីរភាពនៃធនធានទឹក ។

៣- កិច្ចការពារប្រព័ន្ធអេកូឡូស៊ី ដែលពឹងផ្អែកលើលំហូរទឹក និងបរិស្ថាន ។

៤- ការបែងចែក និងប្រើប្រាស់ធនធានទឹកដោយប្រសិទ្ធភាព និងយុត្តិធម៌ ដើម្បីទប់ស្កាត់គ្រោះមហន្តរាយ និងវិវាទ ។

**មាត្រា៤៤២** ._ លក្ខខណ្ឌតម្រូវនៃផែនការយុទ្ធសាស្ត្រជាតិធនធានទឹក

ផែនការយុទ្ធសាស្ត្រជាតិធនធានទឹក ត្រូវដាក់បញ្ចូលចំណុចដូចខាងក្រោម ៖

១- ការកំណត់អត្តសញ្ញាណប្រព័ន្ធអេកូឡូស៊ី និងប្រភេទសត្វ រុក្ខជាតិ ទទួលរងការគំរាមកំហែង ដែលពឹងផ្អែកលើលំហូរទឹក និងបរិស្ថាន ។

២- ការព្យាករណ៍ទុកលើតម្រូវការទឹករយៈពេលវែង ។

៣- កំណត់អត្តសញ្ញាណលើនិន្នាការអាកាសធាតុ និងធាតុអាកាសរយៈពេលវែង ។

៤- ការព្យាករណ៍ពីភាពអាចស្វែងរកបាន និងការប្រែប្រួលទឹកនាពេលអនាគត ។

៥- ជម្រើសដើម្បីបំពេញតម្រូវការទឹកនាពេលអនាគត ។

៦- ជម្រើសសម្រាប់ការគ្រប់គ្រងការបំពេញតម្រូវការទឹកនាពេលអនាគត ។

៧- ការកំណត់អាទិភាពនៃការប្រើប្រាស់ទឹក ។

៨- កំណត់ហេដ្ឋារចនាសម្ព័ន្ធរូបវន្តដែលមិនរាំងស្ទះដល់លំហូរបរិស្ថាន និងមានលំហូរផ្លូវទឹកគ្រប់គ្រាន់សម្រាប់ការធ្វើនាវាចរណ៍ ។

៩- យុទ្ធសាស្ត្រគ្រប់គ្រងគ្រោះរាំងស្ងួត ។

១០- យុទ្ធសាស្ត្រគ្រប់គ្រងគ្រោះទឹកជំនន់ ។ និង

១១- គោលបំណងនៃការអនុវត្តការគ្រប់គ្រងគុណភាពទឹក ។

## ផ្នែកទី៣
## ផែនការធនធានទឹកអាងទន្លេ

**មាត្រា៤៤៣** ._ គោលដៅនៃផែនការធនធានទឹកអាងទន្លេ

ក្រសួង ស្ថាប័នទទួលបន្ទុកធនធានទឹក ត្រូវរៀបចំផែនការធនធានទឹកអាងទន្លេដើម្បី ៖

១- កំណត់ភាពអាចស្វែងរកបានទឹកសម្រាប់គោលបំណងនីមួយៗ ។

២- ផ្តល់ក្របខ័ណ្ឌសម្រាប់ការគ្រប់គ្រង និងប្រើប្រាស់ទឹកដោយចីរភាព ។

៣- កំណត់អាទិភាព និងយន្តការសម្រាប់ដោះស្រាយតម្រូវការទឹកនាពេលអនាគត ។

៤- ផ្តល់ក្របខ័ណ្ឌសម្រាប់បង្កើតការបែងចែកទឹក ។

៥- ផ្តល់ក្របខ័ណ្ឌសម្រាប់ការបែងចែកទឹក ។

៦- ផ្តល់ក្របខ័ណ្ឌសម្រាប់ស្តារឡើងវិញតំបន់ដែលទទួលរងការហូតហែង ដែលកើតឡើងនៅក្នុងប្រព័ន្ធអេកូឡូស៊ីធម្មជាតិ ឬទន្លេ ដើម្បីកាត់បន្ថយការបាត់បង់ធនធានទឹក ។

**មាត្រា៤៤៤** ._ ទឹកក្រោមដី

ផែនការធនធានទឹកអាងទន្លេ ត្រូវកំណត់ក្របខ័ណ្ឌគ្រប់គ្រងលើការការទាញយកទឹកពីក្រោមដី នៅក្នុងករណីដែលក្រសួង ស្ថាប័នទទួលបន្ទុកធនធានទឹក យល់ឃើញថាមានហានិភ័យណាមួយកើតឡើង ដោយការទាញយកទឹក ឬការប្រើប្រាស់ទឹកក្រោមដី ក្នុងតំបន់ណាមួយ អាចបង្កផលប៉ះពាល់ចំពោះ ៖

១- ភាពអាចស្វែងរកបានទឹកសម្រាប់អ្នកប្រើប្រាស់បច្ចុប្បន្ន ។

២- តម្រូវការទឹកសម្រាប់ប្រព័ន្ធអេកូឡូស៊ីធម្មជាតិ ។

៣- គុណភាពទឹក ។

៤- ការសម្រេចបានតាមគោលបំណង ឬលទ្ធផលរំពឹងទុក ដែលបានកំណត់នៅក្នុងផែនការធនធានទឹកអាងទន្លេ ។

**មាត្រា៤៤៥** ._ ការប្រកាសផ្អាកការអភិវឌ្ឍន៍ជាបណ្តោះអាសន្ន

ក្នុងករណីក្រសួង ស្ថាប័នទទួលបន្ទុកធនធានទឹក ជូនដំណឹងអំពីការរៀបចំផែនការធនធានទឹកអាងទន្លេ ការផ្អាកជាបណ្តោះអាសន្នចំពោះការអភិវឌ្ឍន៍នៅក្នុងតំបន់ជម្រាលនៃអាងទន្លេនោះ ត្រូវមានសុពលភាពរហូតដល់ពេលដែល ៖

១- ផែនការធនធានទឹកទទួលការឯកភាព ។

២- ក្រសួង ស្ថាប័នទទួលបន្ទុកធនធានទឹក ជូនដំណឹងអំពីការលុបចោល ការរៀបចំផែនការធនធានទឹកអាងទន្លេវិញ ។

**មាត្រា៤៤៦** ._ វិធាននៃការផ្អាកការអភិវឌ្ឍន៍ជាបណ្តោះអាសន្ន

ក្នុងករណីដែលមានការផ្អាកការអភិវឌ្ឍន៍ជាបណ្តោះអាសន្ន ដូចមានចែងក្នុងមាត្រា៤៤៥ នៃក្រមនេះមានសុពលភាព នោះ ៖

១- មិនអនុញ្ញាតឱ្យមានការដាក់ពាក្យស្នើសុំអភិវឌ្ឍន៍ ឬធ្វើការពិចារណា ឬផ្តល់ការអនុញ្ញាតលើពាក្យស្នើសុំអភិវឌ្ឍន៍ឡើយ ទោះបីជាការដាក់ពាក្យស្នើសុំធ្វើឡើង មុនពេលការផ្អាកជាបណ្តោះអាសន្ននោះមានសុពលភាពក៏ដោយ ។ មិនអនុញ្ញាតឱ្យមានដំណើរការអភិវឌ្ឍន៍ឡើយ នៅក្នុងករណីដែលការអនុញ្ញាតនោះ អាចបង្កផលប៉ះពាល់ ដូចខាងក្រោម ៖

- កំណើនបរិមាណទឹក ដែលត្រូវយកមកប្រើប្រាស់
- ការផ្លាស់ប្តូរទីតាំង ដែលត្រូវយកទឹកមកប្រើប្រាស់
- កំណើនអត្រាទឹក ដែលត្រូវយកមកប្រើប្រាស់
- ការផ្លាស់ប្តូរចំពោះលក្ខខណ្ឌលំហូរទឹក ដែលត្រូវយកមកប្រើប្រាស់
- ការផ្លាស់ប្តូរចំពោះគោលដៅ នៃការយកទឹកមកប្រើប្រាស់ ។

២- ការងារថ្មីមិនត្រូវអនុញ្ញាតឱ្យចាប់ផ្តើមដំណើរការឡើយនៅក្នុងតំបន់ហាមឃាត់ជាបណ្តោះអាសន្ន ។

៣- ការងារដែលបានចាប់ផ្តើមដំណើរការរួចហើយ អាចអនុញ្ញាតឱ្យដំណើរការរហូតដល់បញ្ចប់ ប៉ុន្តែត្រូវមានការអនុញ្ញាតជាលាយលក្ខណ៍អក្សរពីក្រសួង ស្ថាប័នទទួលបន្ទុក

ធនធានទឹក និងត្រូវគោរពតាមកាលបរិច្ឆេទនៃការបញ្ចប់ និងលក្ខខណ្ឌផ្សេងទៀតដែលកំណត់ដោយក្រសួង ស្ថាប័នទទួលបន្ទុកធនធានទឹក ។

៤- ការងារបញ្ចប់រួចហើយ មិនត្រូវពង្រីកបន្ថែម ឬផ្លាស់ប្តូរឡើយ ។

**មាត្រា៤៤៧** ._ សុពលភាពនៃផែនការធនធានទឹកអាងទន្លេ

អាងទន្លេមួយ អាចមានផែនការធនធានទឹកអាងទន្លេតែមួយប៉ុណ្ណោះ លើកលែងមានការរៀបចំផែនការដាច់ដោយឡែក សម្រាប់ធនធានទឹកដីលើ និងទឹកក្រោមដី ។

**មាត្រា៤៤៨** ._ លក្ខខណ្ឌតម្រូវនៃផែនការធនធានទឹកអាងទន្លេ

សេចក្តីព្រាងផែនការធនធានទឹកអាងទន្លេ ត្រូវ ៖

១- កំណត់អំពីគោលបំណងនៃសេចក្តីព្រាងផែនការ ។

២- ដាក់បញ្ចូលផែនទីនៃតំបន់រៀបចំផែនការដែលបានស្នើឡើង ។

៣- ចែងអំពីធនធានទឹក និងគោលបំណងនៃការអនុវត្តសេចក្តីព្រាងផែនការចំពោះធនធានទឹកនោះ ។

៤- កំណត់អាទិភាពនៃអ្នកប្រើប្រាស់ធនធានទឹក និងធនធានទឹក សម្រាប់បំពេញតម្រូវការចាំបាច់របស់មនុស្ស និងប្រព័ន្ធអេកូឡូស៊ី មុននឹងបែងចែកទឹក និងធនធានទឹកទៅឱ្យអ្នកប្រើប្រាស់ក្នុងគោលដៅផ្សេងទៀត ។

៥- កំណត់លទ្ធផលរំពឹងទុក ដែលទាក់នឹងអេកូឡូស៊ី ប្រព័ន្ធអេកូឡូស៊ីដែលស្ថិតក្នុងសមាសភាគរបស់វា ដែលរួមមាន ទឹកក្រោមដី អាងបង្ហូរទឹក ល្អាងទឹកក្រោមដី និងអនុល្អាងទឹកក្រោមដី និងប្រភពទឹកផ្សេងៗ សម្រាប់ការគ្រប់គ្រងទឹកដោយចីរភាព ។

៦- ប្រើប្រាស់ព័ត៌មានល្អបំផុតដែលអាចស្វែងរកបាន និងកំណត់យុទ្ធសាស្ត្រដើម្បីសម្រេចបានលទ្ធផលរំពឹងទុក ។

៧- កំណត់យុទ្ធសាស្ត្រសម្រាប់ការរៀបចំការបែងចែកទឹក សម្រាប់តំបន់គម្រោងដែលបានស្នើឡើង ។

៨- កំណត់អំពីវិធានគ្រប់គ្រងបរិស្ថាន និងវិធានចែករំលែកទឹក ។

៩- កំណត់អត្តសញ្ញាណហេដ្ឋារចនាសម្ព័ន្ធទឹក ។

១០- កំណត់អត្តសញ្ញាណនៃកម្រិតផ្គត់ផ្គង់ទឹកពេញលេញសម្រាប់ទំនប់ទឹក រួមមានហេដ្ឋារចនាសម្ព័ន្ធដូចមានកំណត់នៅក្នុងចំណុចទី៩ ខាងលើ ។

១១- កំណត់លក្ខខណ្ឌតម្រូវនៃការអង្កេតតាមដានទឹក និងប្រព័ន្ធអេកូឡូស៊ីធម្មជាតិ និងការរៀបចំរបាយការណ៍ ដែលអាចដាក់បញ្ចូលនូវសូចនាករសុខភាពអាងទន្លេ ដើម្បីជួយក្នុងការវាយតម្លៃប្រសិទ្ធភាពនៃយុទ្ធសាស្ត្រគ្រប់គ្រង ដើម្បីសម្រេចបាននូវលទ្ធផលដែលបានរំពឹងទុក ដូចមានកំណត់នៅក្នុងចំណុចទី៥ខាងលើ ។

១២- កំណត់ពីលក្ខខណ្ឌតម្រូវនៃការរៀបចំរបាយការណ៍តាមពេលកំណត់ ។

១៣- ដាក់បញ្ចូលតារាងពេលវេលានៃយន្តការ សម្រាប់ការអនុវត្តសេចក្តីព្រាងផែនការ ។

១៤- ដាក់បញ្ចូលព័ត៌មានអំពីទឹកដែលមិនទាន់បានបែងចែក សម្រាប់គោលបំណងនៃការប្រើប្រាស់ក្នុងពេលអនាគត និងអាទិភាព និងដំណើរការសម្រាប់ការបែងចែក ឬបម្រុងទុក ។

១៥- រៀបចំដំណើរសម្រាប់ការផ្តល់ ការបម្រុងទុក ឬ ការគ្រប់គ្រងទឹក ដែលមិនទាន់បានបែងចែក ។

១៦- កំណត់លក្ខណៈវិនិច្ឆ័យសម្រាប់ការកែតម្រូវលើសេរភាព ក្នុងករណីចាំបាច់ ដើម្បីសម្រេចបានលទ្ធផលរំពឹងទុកនៃផែនការ និង

១៧- កំណត់លក្ខណៈវិនិច្ឆ័យសម្រាប់ដោះស្រាយភាពហួតហែង ដែលបានកើតឡើងនៅក្នុងប្រព័ន្ធអេកូឡូស៊ីធម្មជាតិ ។

**មាត្រា៤៤៩** ._ ផែនការទន្លេមេគង្គ

ផែនការធនធានទឹកអាងទន្លេ ដែលអនុវត្តចំពោះធនធានទឹកទន្លេមេគង្គ ត្រូវពិចារណាអំពី ៖

១- ចរន្តលំហូរទឹកឆ្លងដែនចូលមកកាន់ព្រះរាជាណាចក្រកម្ពុជា ។

២- លក្ខខណ្ឌតម្រូវផ្លូវច្បាប់ ឬស្មើភាពគ្នា សម្រាប់ចរន្តលំហូរទឹកឆ្លងដែនផ្នែកខាងក្រោមនៃព្រះរាជាណាចក្រកម្ពុជា ស្របតាមបទប្បញ្ញត្តិ នៃអនុសញ្ញាអង្គការសហប្រជាជាតិស្តីពីច្បាប់នៃការប្រើប្រាស់ផ្លូវទឹកអន្តរជាតិដែលមិនពាក់ព័ន្ធនឹងការធ្វើនាវាចរណ៍ ។

៣- បញ្ហាបរិស្ថានឆ្លងដែនដទៃៗទៀត និង

៤- អត្ថិភាព ប្រតិបត្តិការ និងលក្ខខណ្ឌតម្រូវ នៃកិច្ចព្រមព្រៀងអន្តររដ្ឋាភិបាលទាក់ទងនឹងទន្លេមេគង្គ ។

**មាត្រា៤៥០** ._ សេចក្តីព្រាងផែនការធនធានទឹកអាងទន្លេ

សេចក្តីព្រាងផែនការធនធានទឹកអាងទន្លេ ត្រូវផ្តល់នូវក្របខ័ណ្ឌសម្រាប់ការបង្កើតសិទ្ធិទទួលបានទឹក ដោយកំណត់នូវចំណុចដូចខាងក្រោម ៖

១- គោលដៅនៃលំហូរបរិស្ថាន ។

២- គោលបំណងសន្តិសុខនៃសិទ្ធិទទួលបានទឹក ។

៣- សូចនករនៃការអនុវត្តសម្រាប់គោលបំណងនៃលំហូរបរិស្ថាន និងគោលបំណងសន្តិសុខនៃសិទ្ធិទទួលបានទឹក ។

៤- អាទិភាពសម្រាប់ការផ្តល់សិទ្ធិទទួលបានទឹក ។

**មាត្រា៤៥១** ._ ការពិចារណាសម្រាប់សេចក្តីព្រាងផែនការធនធានទឹកអាងទន្លេ

ក្រសួង ស្ថាប័នទទួលបន្ទុកធនធានទឹក ត្រូវពិចារណាទៅលើចំណុចខាងក្រោម នៅពេលរៀបចំសេចក្តីព្រាងផែនការធនធានទឹកអាងទន្លេ ៖

១- បរិមាណ និងគុណភាពទឹក នៅក្នុងតំបន់ផែនការ ។

២- គោលបំណង និងអាទិភាព ថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដើម្បីលើកកម្ពស់ការអភិវឌ្ឍន៍ដោយចីរភាព ។

៣- ផែនការថ្នាក់តំបន់ សម្រាប់តំបន់នោះ ។

៤- រយៈពេល ប្រេកង់ ទំហំ និងការកំណត់ពេលនៃលំហូរទឹក ដែលមានសារៈសំខាន់ក្នុងការគាំទ្រប្រព័ន្ធអេកូឡូស៊ីធម្មជាតិ និងប្រភេទសត្វ រុក្ខជាតិ ដែលស្ថិតក្នុងស្ថានភាពគ្រោះថ្នាក់ និងការទទួលរងការគំរាមកំហែង ដូចបានវាយតម្លៃដោយប្រើព័ត៌មានវិទ្យាសាស្ត្រល្អបំផុតដែលអាចស្វែងរកបាន ។

៥- ការជន់លិច និងការស្រកទៅវិញដែលមានប្រយោជន៍ សម្រាប់គាំទ្រប្រព័ន្ធអេកូឡូស៊ីធម្មជាតិ និងប្រភេទសត្វ រុក្ខជាតិ ដែលស្ថិតក្នុងស្ថានភាពគ្រោះថ្នាក់ និងការទទួលរងការគំរាមកំហែង ។

៦- កម្រិតទឹកក្រោមដី និងដំណើរការហូរទឹកពីលើដីទៅក្រោមដី ដែលមានសារសំខាន់ក្នុងការគាំទ្រប្រព័ន្ធអេកូឡូស៊ីធម្មជាតិ និងប្រភេទសត្វ រុក្ខជាតិ ដែលស្ថិតក្នុងស្ថានភាពគ្រោះថ្នាក់ និងការទទួលរងការគំរាមកំហែង ។

៧- ការចូលរួមគ្រប់គ្រងទឹកនៃទីជម្រក ឬប្រព័ន្ធពាក់ព័ន្ធ ដែលរួមមាន ព្រៃឈើ និងដីសើម ដែលគាំទ្រដល់គោលបំណងនៃផែនការធនធានទឹកអាងទន្លេ ។

៨- សិទ្ធិដែលមានស្រាប់ក្នុងការទទួលបាន និងប្រើប្រាស់ទឹក ។

៩- តម្រូវការទឹកនាពេលអនាគតរបស់ព្រះរាជាណាចក្រកម្ពុជា ដែលរួមមាន តម្រូវការផ្នែកវប្បធម៌ សេដ្ឋកិច្ច បរិស្ថាន និងសង្គម ។

១០- គុណតម្លៃផ្នែកវប្បធម៌ សេដ្ឋកិច្ច បរិស្ថាន និងសង្គម ។

១១- ការវាយតម្លៃផ្នែកបច្ចេកទេសសម្រាប់សេចក្ដីព្រាងផែនការ ។

១២-ផលប៉ះពាល់នៃសេចក្ដីព្រាងផែនការទៅលើទឹក ដែលមិនបានកំណត់នៅក្នុងសេចក្ដីព្រាងផែនការ ។

១៣- ផលប៉ះពាល់នៃការយក ឬប្រើប្រាស់ទឹកដែលមិនមានកំណត់នៅក្នុងសេចក្ដីព្រាងផែនការ ទៅលើទឹកដែលមានកំណត់នៅក្នុងសេចក្ដីព្រាងផែនការ ។

១៣- យុទ្ធសាស្ត្រ និងគោលនយោបាយគ្រប់គ្រងធនធានដោយចីរភាព សម្រាប់អាងទន្លេ ឬអាងទឹកក្រោមដី និងតំបន់ឆ្នេរពាក់ព័ន្ធ ។

១៤- ការដាក់បញ្ជូនមតិយោបល់លើសំណើសេចក្ដីព្រាងផែនការទាំងអស់ ។

១៥- ផលប្រយោជន៍សាធារណៈ ។

**មាត្រា៤៥២** ._ ការជូនដំណឹងនៃសេចក្ដីព្រាងផែនការធនធានទឹកអាងទន្លេ

ក្រសួង ស្ថាប័នទទួលបន្ទុកធនធានទឹក ត្រូវជូនដំណឹងទៅក្រសួង ស្ថាប័នពាក់ព័ន្ធ និងសាធារណជន នៅពេលដែលសេចក្ដីព្រាងផែនការធនធានទឹកអាងទន្លេ ត្រូវបានរៀបចំរួច ដោយបញ្ជាក់អំពី ៖

១- ទីកន្លែងដែលអាចទទួលបានសំណៅនៃសេចក្ដីព្រាងផែនការ ។

២- ការដាក់បញ្ជូនមតិយោបល់ជាលាយលក្ខណ៍អក្សរលើសេចក្ដីព្រាងផែនការ របស់រូបវន្តបុគ្គល ឬនីតិបុគ្គលពាក់ព័ន្ធ ។

៣- កាលបរិច្ឆេទ នៃការដាក់បញ្ជូនមតិយោបល់លើសេចក្ដីព្រាងផែនការ ដែលត្រូវធ្វើឡើងយ៉ាងហោចណាស់ក្នុងរយៈពេល ៣០ (សាមសិប)ថ្ងៃ ក្រោយពីថ្ងៃជូនដំណឹងជាសាធារណៈ និងទីកន្លែង និងបុគ្គលដែលត្រូវទទួលការដាក់បញ្ជូនមតិយោបល់នោះ ។

**មាត្រា៤៥៣** ._ ការពិចារណាទៅលើមតិយោបល់សាធារណជន

មុននឹងបញ្ចប់ផែនការធនធានទឹកអាងទន្លេ ក្រសួង ស្ថាប័នទទួលបន្ទុកធនធានទឹក ត្រូវពិចារណាលើរាល់ការដាក់បញ្ជូនមតិយោបល់ទាំងអស់ ទាក់ទងនឹងសេចក្ដីព្រាងផែនការធនធានទឹកអាងទន្លេ ។

**មាត្រា៤៥៤** ._ ផែនការចុងក្រោយ

ផែនការធនធានទឹកអាងទន្លេចុងក្រោយ មិនមានអនុភាពអនុវត្តនោះទេ លុះត្រាតែទទួលបានការឯកភាពពីរាជរដ្ឋាភិបាល ។

**មាត្រា៤៥៥** ._ ផែនការដែលទទួលបានការឯកភាព

ផែនការធនធានទឹកអាងទន្លេដែលទទួលបានការឯកភាព ត្រូវអស់សុពលភាពក្រោយរយៈពេល ១០ (ដប់) ឆ្នាំ លើកលែងតែមុនរយៈពេលនេះ ផែនការនោះត្រូវបាន៖

១- និរាករណ៍ ឬ

២- ជំនួសដោយផែនការធនធានទឹកមួយផ្សេងទៀត ដែលបានចាប់ផ្តើមអនុវត្ត និងដែលកំណត់ថាជាផែនការជំនួស ។

**មាត្រា៤៥៦** ._ ការកែប្រែ និងការរៀបចំផែនការថ្មី

ក្រសួង ស្ថាប័ន ទទួលបន្ទុកវិស័យធនធានទឹក អាចធ្វើការកែប្រែ ឬរៀបចំផែនការធនធានទឹកអាងទន្លេថ្មីមួយដើម្បីជំនួសផែនការដែលមានស្រាប់ ដោយខ្លួនឯង ឬតាមរយៈការស្នើសុំពីអ្នកពាក់ព័ន្ធដទៃទៀត ។

**មាត្រា៤៥៧** ._ ការធ្វើយុត្តិកម្មសម្រាប់ការកែប្រែ ឬការរៀបចំផែនការថ្មី

ក្រសួង ស្ថាប័នទទួលបន្ទុកធនធានទឹក អាចកែប្រែ ឬរៀបចំផែនការធនធានទឹកអាងទន្លេថ្មីស្របតាមមាត្រា៤៥៦ នៃក្រមនេះ នៅក្នុងករណីដែល ៖

១- លទ្ធផលរំពឹងទុកនៃផែនការធនធានទឹកអាងទន្លេ មិនអាចសម្រេចបាន ឬ

២- គោលបំណងនៃផែនការធនធានទឹកអាងទន្លេ ឬយុទ្ធសាស្ត្រដើម្បីសម្រេចបាននូវលទ្ធផលរំពឹងទុកនៅក្នុងផែនការ លែងមានលក្ខណៈសមស្របសម្រាប់តំបន់ផែនការនោះទៀតហើយ ។

## ជំពូកទី៤
## ការចេញលិខិតអនុញ្ញាត
## ផ្នែកទី១
## បទប្បញ្ញត្តិទូទៅ

**មាត្រា៤៥៨** ._ សិទ្ធិប្រើប្រាស់ធនធានទឹក

បុគ្គលគ្រប់រូបមានសិទ្ធិយក និងប្រើប្រាស់ធនធានទឹក ដោយពុំចាំបាច់មានលិខិតអនុញ្ញាត ចំពោះចំណុចដូចខាងក្រោម ៖

១- តម្រូវការចាំបាច់របស់មនុស្សជាមូលដ្ឋាន រួមមាន ការហូបចុក បោកគក់ ការងូត អនាម័យ ការស្រោចស្រពសួនច្បារ និងដំណាំ ឬគោលបំណងជាលក្ខណៈគ្រួសារដទៃទៀត។

២- ការពន្លត់អគ្គីភ័យ និងគោលបំណងនៃការសង្គ្រោះបន្ទាន់ដទៃទៀត ។

**មាត្រា៤៥៩** ._ ការការពារសិទ្ធិស្របច្បាប់របស់បុគ្គលដទៃ

ការយក និងការប្រើប្រាស់ធនធានទឹក មិនត្រូវធ្វើឲ្យប៉ះពាល់ដល់សិទ្ធិស្របច្បាប់បុគ្គលដទៃនោះឡើយ ។

**មាត្រា៤៦០** ._ ម្ចាស់កម្មសិទ្ធិដី ឬអ្នកកាន់កាប់ដី

ម្ចាស់កម្មសិទ្ធិដី ឬអ្នកកាន់កាប់ដី មានសិទ្ធិប្រមូលយក និងប្រើប្រាស់ទឹកភ្លៀង និងទឹកដែលហូរទៅតាមធម្មជាតិកាត់លើដីកម្មសិទ្ធិ ដោយពុំចាំបាច់មានលិខិតអនុញ្ញាត។

ម្ចាស់កម្មសិទ្ធិដី ឬអ្នកកាន់កាប់ដីផ្នែកខាងក្រោមមានសិទ្ធិយក និងប្រើប្រាស់បាននូវបរិមាណទឹកដែលហូរពីដីខាងលើ ប៉ុន្តែបុគ្គលនោះពុំមានសិទ្ធិរាំងចរន្តទឹកហូរដោយការសាងសង់ផ្លូវ របង ទំនប់ រនាំង ឬត្រពាំង ដែលរារាំងដល់ចរន្តទឹកធម្មជាតិ ។

**មាត្រា៤៦១** ._ សកម្មភាពដែលតម្រូវឱ្យមានលិខិតអនុញ្ញាត

ត្រូវហាមឃាត់ចំពោះការធ្វើសកម្មភាពដូចខាងក្រោម លើកលែងតែមានលិខិតអនុញ្ញាត ៖

១- ការប្រើប្រាស់ទឹក ការបង្វែរទឹក និងការយកទឹក មិនស្របតាមគោលបំណងមាត្រា ៤៥៨ មាត្រា៤៥៩ និងមាត្រា៤៦០នៃក្រមនេះ ។

២- ការសាងសង់ ឬប្រតិបត្តិការ សម្រាប់ហេដ្ឋារចនាសម្ព័ន្ធដែលនាំឱ្យមានការប្រើប្រាស់ ការបង្វែរទឹក និងការយកទឹក មិនស្របតាមគោលបំណងមាត្រា៤៥៨ មាត្រា៤៥៩ និង មាត្រា៤៦០នៃក្រមនេះ ។

៣- ការទាញយកខ្សាច់ ដី ថ្ម ក្រួស រ៉ែ ប្រេងកាត និងឧស្ម័ន ពីបាត ច្រាំង ឬឆ្នេរសមុទ្រ ទន្លេ ស្ទឹង ព្រែក អូរ បឹងបួ ។

៩-ការលុប ការរៀបចំប្រព័ន្ធលំហូរទឹក ការជីកប្រឡាយ ការបង្វែរទឹកនៃទន្លេ ស្ទឹង ព្រែក អូរ បឹងបួ ប្រឡាយ អាងទឹក ប្រភពទឹកស្អាត និងអាងទឹកធម្មជាតិ ។

**មាត្រា៤៦២** ._ កម្រិតនៃការប្រើប្រាស់ ការបង្វែរទឹក និងការយកធនធានទឹក

ក្រសួង ស្ថាប័នទទួលបន្ទុកធនធានទឹក អាចរៀបចំលិខិតបទដ្ឋានគតិយុត្តដើម្បីកំណត់ពីកម្រិតនៃការប្រើប្រាស់ ការបង្វែរទឹក និងការយកធនធានទឹក សម្រាប់គោលបំណងណាមួយដោយពុំចាំបាច់មានលិខិតអនុញ្ញាត ស្របតាមមាត្រា៤៦១ នៃក្រមនេះ ។

**មាត្រា៤៦៣** ._ ការផ្តល់ការឯកភាពលើការស្នើសុំលិខិតអនុញ្ញាត

ការផ្តល់ការឯកភាពលើការស្នើសុំលិខិតអនុញ្ញាត ត្រូវគោរពតាមលក្ខខណ្ឌតម្រូវនានាដែលកំណត់ដោយក្រមនេះ ។

## ផ្នែកទី២
## លិខិតអនុញ្ញាតហេដ្ឋារចនាសម្ព័ន្ធ

**មាត្រា៤៦៤** ._ ការចេញលិខិតអនុញ្ញាតហេដ្ឋារចនាសម្ព័ន្ធ

ក្រសួង ស្ថាប័នទទួលបន្ទុកធនធានទឹក ត្រូវចេញលិខិតអនុញ្ញាតហេដ្ឋារចនាសម្ព័ន្ធ ស្របតាមផែនការធនធានទឹកអាងទន្លេ ។

**មាត្រា៤៦៥** ._ គោលបំណងនៃលិខិតអនុញ្ញាតហេដ្ឋារចនាសម្ព័ន្ធ

លិខិតអនុញ្ញាតហេដ្ឋារចនាសម្ព័ន្ធ ត្រូវផ្តល់សិទ្ធិឱ្យអ្នកកាន់នូវលិខិតអនុញ្ញាតនោះ ប្រើប្រាស់ទឹកទៅតាមកម្រិត និងបរិមាណមួយដែលចាំបាច់សម្រាប់ប្រតិបត្តិការហេដ្ឋារចនាសម្ព័ន្ធទឹក ។

**មាត្រា៤៦៦** ._ លក្ខខណ្ឌតម្រូវនៃលិខិតអនុញ្ញាតហេដ្ឋារចនាសម្ព័ន្ធ

ក្រសួង ស្ថាប័នទទួលបន្ទុកធនធានទឹក ត្រូវរៀបចំលិខិតបទដ្ឋានគតិយុត្តដើម្បីកំណត់ពីលក្ខខណ្ឌតម្រូវសម្រាប់ការស្នើសុំលិខិតអនុញ្ញាតហេដ្ឋារចនាសម្ព័ន្ធ ។

## ផ្នែកទី៣
## សិទ្ធិទទួលបានទឹក

**មាត្រា៤៦៧**._ បញ្ជីសិទ្ធទទួលបានទឹក

ក្រសួង ស្ថាប័នទទួលបន្ទុកធនធានទឹក ត្រូវរក្សាទុកនូវបញ្ជីសិទ្ធិទទួលបានទឹក ។

ព័ត៌មានដែលត្រូវដាក់បញ្ចូលទៅក្នុងសិទ្ធិទទួលបានទឹក ត្រូវកំណត់ដោយលិខិតបទដ្ឋានគតិយុត្តដោយឡែក ។

**មាត្រា៤៦៨**._ លក្ខខណ្ឌសម្រាប់សិទ្ធិទទួលបានទឹក

ការប្រើប្រាស់ទឹក ការបង្វែរទឹក និងការយកធនធានទឹក អាចធ្វើឡើងសិទ្ធិទទួលបានទឹកដែលកំណត់ដោយក្រសួង ស្ថាប័នទទួលបន្ទុកធនធានទឹក ។

**មាត្រា៤៦៩**._ សិទ្ធិស្របច្បាប់ក្នុងការទទួលបានទឹក

ម្ចាស់កម្មសិទ្ធិដី ឬអ្នកកាន់កាប់ដី អាចដាក់ពាក្យស្នើសុំសិទ្ធិទទួលបានទឹកទៅក្រសួង ស្ថាប័នទទួលបន្ទុកធនធានទឹក ដើម្បីយកទឹកមកប្រើប្រាស់ពី ៖

១-ប្រភពទឹកនានា បឹងបួ ឬប្រភពទឹកក្រោមដី ដែលស្ថិតនៅលើ ឬនៅជាប់ដីណាមួយ ។

២- អាងទឹកក្រោមដី ។

៣- លំហូរទឹកកាត់តាមដី ។

៤- ហេដ្ឋារចនាសម្ព័ន្ធ ដែលអនុវត្តតាមលិខិតអនុញ្ញាតហេដ្ឋារចនាសម្ព័ន្ធ អាចផ្គត់ផ្គង់ទឹកដល់ដីដែលពាក់ព័ន្ធបាន ។

**មាត្រា៤៧០**._ នីតិវិធី និងលក្ខខណ្ឌតម្រូវនៃការដាក់ពាក្យស្នើសុំសិទ្ធិទទួលបានទឹក

ក្រសួង ស្ថាប័នទទួលបន្ទុកធនធានទឹក ត្រូវរៀបចំលិខិតបទដ្ឋានគតិយុត្តដើម្បីកំណត់ពីនីតិវិធី និងលក្ខខណ្ឌតម្រូវក្នុងការដាក់ពាក្យស្នើសុំសិទ្ធិទទួលបានទឹក ។

**មាត្រា៤៧១**._ ការជូនដំណឹងជាសាធារណៈ

ក្នុងករណីដែលក្រសួង ស្ថាប័នទទួលបន្ទុកធនធានទឹកយល់ឃើញថា មានព័ត៌មានគ្រប់គ្រាន់សម្រាប់ផ្តល់ការឯកភាពលើពាក្យស្នើសុំសិទ្ធិទទួលបានទឹក ក្រសួង ស្ថាប័នទទួលបន្ទុកធនធានទឹកត្រូវជូនដំណឹងជាសាធារណៈអំពីពាក្យស្នើសុំនោះ ដោយបញ្ជាក់អំពី ៖

១- ព័ត៌មានលម្អិតនៃពាក្យស្នើសុំនោះ ។

២- ទីកន្លែងដែលត្រូវពិនិត្យលើពាក្យស្នើសុំនោះ ។

៣- កាលបរិច្ឆេទ នៃការដាក់ពាក្យស្នើសុំសិទ្ធិទទួលបានទឹកជាលាយលក្ខណ៍អក្សរដែលបានបញ្ជូនមកក្រសួង ស្ថាប័នទទួលបន្ទុកធនធានទឹក យ៉ាងហោចណាស់ ៣០ (សាមសិប) ថ្ងៃ បន្ទាប់ពីមានការជូនដំណឹងជាសាធារណៈ ។

**មាត្រា៤៧២** ._ នីតិវិធី និងលក្ខខណ្ឌតម្រូវសម្រាប់ការផ្តល់ការឯកភាព ឬបដិសេធ

នីតិវិធី និងលក្ខខណ្ឌតម្រូវសម្រាប់ការផ្តល់ការឯកភាព ឬបដិសេធ ចំពោះសិទ្ធិទទួលបានទឹកត្រូវកំណត់ដោយលិខិតបទដ្ឋានគតិយុត្តដោយឡែក ។

**មាត្រា៤៧៣** ._ អញ្ញត្តិកម្មសម្រាប់លំហូរបរិស្ថាន

លំហូរបរិស្ថាន ត្រូវអនុវត្តតាមបរិមាណជាអតិបរមានៃការបែងចែងទឹក ។

**មាត្រា៤៧៤** ._ ការប្រកាសអំពីសិទ្ធិទទួលបានទឹក

មុនការិយបរិច្ឆេទជលសាស្រ្ត នមួយៗ ក្រសួង ស្ថាប័នទទួលបន្ទុកធនធានទឹក ត្រូវប្រកាសអំពីសិទ្ធិទទួលបានទឹកសម្រាប់ឆ្នាំបន្ទាប់ ស្របតាមប្រភេទអាទិភាព និងវិធាននៃការបែងចែងទឹក ដែលកំណត់នៅក្នុងផែនធនធានទឹកអាងទន្លេ ។

**មាត្រា៤៧៥** ._ សិទ្ធិទទួលបានទឹក ដែលបានប្រកាសរួច

សិទ្ធិទទួលបានទឹក ដែលបានប្រកាសរួច ៖

១- ត្រូវបញ្ជាក់អំពីភាគរយនៃបរិមាណជាផ្លូវការអំពីសិទ្ធិទទួលបានទឹកដែលត្រូវអនុវត្តសម្រាប់ការិយបរិច្ឆេទជលសាស្រ្តនីមួយៗ ។

២-ត្រូវសម្រេចនៅមុនការិយបរិច្ឆេទជលសាស្រ្ត ដែលត្រូវប្រកាសពាក់ព័ន្ធនឹងសិទ្ធិទទួលបានទឹក ។

៣- ត្រូវកំណត់ស្របតាមបរិមាណទឹកដែលមានតាមរដូវកាល ចំពោះសិទ្ធិទទួលបានទឹក ។

៤- អាចកើនឡើងនូវបរិមាណទឹកក្នុងអំឡុងពេលនៃការិយបរិច្ឆេទជលសាស្ត្រ ។

៥- អាចខុសគ្នាទៅតាមតាមអនុតំបន់នៃអាងទន្លេ ។

៦- អាចធ្វើឡើងខុសគ្នាទៅតាមសិទ្ធិទទួលបានទឹកដូចបានកំណត់ក្នុងក្រុមអាទិភាព ។

៧- មិនសំដៅដល់ការចេញអាជ្ញាប័ណ្ណទឹក ឬលិខិតអនុញ្ញាត សម្រាប់ការផ្គត់ផ្គង់ទឹកតាមទីប្រជុំជន ឬទីក្រុង ។

**មាត្រា៤៧៦** ._ សិទ្ធិទទួលបានទឹកដែលកំណត់ក្នុងផែនការធនធានទឹកអាងទន្លេ

ផែនការធនធានទឹកអាងទន្ល ត្រូវកំណត់អំពីសិទ្ធិទទួលបានទឹក ៖

១- ការយកទឹកត្រូវអនុវត្តតាមផែនការធនធានទឹកអាងទន្លេ ។

២- ក្នុងករណីមានភាពមិនស្របគ្នារវាងផែនការធនធានទឹកអាងទន្លេ និងសិទ្ធិទទួលបានទឹក នោះផែនការធនធានទឹកអាទន្លេត្រូវមានមានឧត្តមានុភាព ។

៣- សិទ្ធិទទួលបានទឹក មិនអាចមានការកែប្រែណាមួយដែលនាំឱ្យកាត់បន្ថយ ឬមានផលប៉ះពាល់ជាអវិជ្ជមានទៅលើលក្ខខណ្ឌនៃការយកទឹកក្នុងអំឡុងពេលអនុវត្តផែនការឡើយ លើកលែងតែមានការយល់ព្រមលើសំណងការខូចខាត ដែលក្រសួង ស្ថាប័នទទួលបន្ទុកធនធានទឹកផ្តល់ឱ្យ ។

**មាត្រា៤៧៧** ._ ការកែសម្រួលទៅលើបរិមាណជាផ្លូវការ

បរិមាណជាផ្លូវការក្នុងការបែងចែងទឹក និងលក្ខខណ្ឌផ្សេងទៀត អាចត្រូវធ្វើការកែសម្រួលនៅចុងបញ្ចប់នៃផែនការធនធានទឹកអាងទន្លេ ដែលត្រូវអនុវត្ត ។

ការកែសម្រួលទៅលើបរិមាណជាផ្លូវការក្នុងការបែងចែងទឹក និងលក្ខខណ្ឌផ្សេងទៀតខាងលើនេះ មិនមានការសងសំណងការខូចខាតនោះទេ ។

**មាត្រា៤៧៨** ._ ការព្រមព្រៀងផ្គត់ផ្គង់ស្របតាមការអនុញ្ញាតសម្រាប់ហេដ្ឋារចនាសម្ព័ន្ធ

ក្នុងករណីដែលលិខិតអនុញ្ញាតណាមួយ អនុញ្ញាតឱ្យប្រើប្រាស់ធនធានទឹកដែលផ្គត់ផ្គង់លើហេដ្ឋារចនាសម្ព័ន្ធ ដែលកំពុងធ្វើប្រតិបត្តិការនៅក្រោមលិខិតអនុញ្ញាតហេដ្ឋារចនាសម្ព័ន្ធ អ្នកកាន់កាប់

លិខិតអនុញ្ញាតប្រើប្រាស់ធនធានទឹក និងអ្នកកាន់លិខិតអនុញ្ញាតហេដ្ឋារចនាសម្ព័ន្ធ ត្រូវចុះកិច្ចព្រមព្រៀងផ្គត់ផ្គង់ធនធានទឹកជាមួយគ្នា លើកលែងតែភាគីទាំងពីរជានីតិបុគ្គលតែមួយ ។

**មាត្រា៤៧៩** ._ កិច្ចព្រមព្រៀងស្តង់ដារផ្គត់ផ្គង់ទឹក

ក្រសួង ស្ថាប័នទទួលបន្ទុកធនធានទឹក ត្រូវរៀបចំកិច្ចព្រមព្រៀងស្តង់ដារផ្គត់ផ្គង់ទឹកមួយសម្រាប់ការស្តុកទុក និង/ឬការចែកចាយទឹកដល់អ្នកកាន់អាជ្ញាប័ណ្ណទឹក និងលិខិតអនុញ្ញាតហេដ្ឋារចនាសម្ព័ន្ធ ស្របតាមបទបញ្ញត្តិស្តីពីសិទ្ធិទទួលបានទឹក ។

កិច្ចព្រមព្រៀងស្តង់ដារផ្គត់ផ្គង់ទឹកអាចមានលក្ខណៈខុសគ្នាពីទីតាំងមួយទៅទីតាំងមួយ ។

**មាត្រា៤៨០** ._ ពាក្យសុំកិច្ចព្រមព្រៀងស្តង់ដារផ្គត់ផ្គង់ទឹក

កិច្ចព្រមព្រៀងស្តង់ដារផ្គត់ផ្គង់ទឹកសម្រាប់ទីតាំងចំពោះសិទ្ធិទទួលបានទឹកនោះ ត្រូវអនុវត្តចំពោះសិទ្ធិទទួលបានទឹក លើកលែងតែមានកិច្ចព្រមព្រៀងស្តង់ដារផ្គត់ផ្គង់ទឹកដែលបាន ៖

១-យល់ស្របរវាងអ្នកកាន់លិខិតអនុញ្ញាតហេដ្ឋារចនាសម្ព័ន្ធ និងអ្នកកាន់សិទ្ធិទទួលបានទឹក និង

២-ដាក់បញ្ជូនទៅកាន់ក្រសួង ស្ថាប័នទទួលបន្ទុកធនធានទឹក ។

## ផ្នែកទី៤
## ការការពារទន្លេ និងស្ទឹង

**មាត្រា៤៨១** ._ សកម្មភាពដែលទទួលបានការអនុញ្ញាត

បុគ្គលគ្រប់រូបអាចដាក់ពាក្យសុំលិខិតអនុញ្ញាតទៅកាន់ក្រសួង ស្ថាប័នទទួលបន្ទុកធនធានទឹក ដើម្បីធ្វើសកម្មភាពដូចខាងក្រោម៖

១- ការជីកផ្លូវទឹក បឹង ដីសើម តំបន់ទំនាប ទឹកផុសក្រោមដី ឬអាងទឹក និង

២-ចាក់បំពេញលុបផ្លូវទឹក បឹងធម្មជាតិ ដីសើម តំបន់ទំនាប ទឹកផុសក្រោមដី ឬអាងទឹក ។

**មាត្រា៤៨២** ._ នីតិវិធី និងលក្ខខណ្ឌតម្រូវសម្រាប់ការដាក់ពាក្យសុំលិខិតអនុញ្ញាត

ក្រសួង ស្ថាប័នទទួលបន្ទុកធនធានទឹក ត្រូវរៀបចំលិខិតបទដ្ឋានគតិយុត្តស្តីពីនីតិវិធី និងលក្ខខណ្ឌតម្រូវ សម្រាប់ការដាក់ពាក្យសុំលិខិតអនុញ្ញាត ។

**មាត្រា៤៨៣** ._ ការជូនដំណឹងជាសាធារណៈ

នៅពេលដែលក្រសួង ស្ថាប័នទទួលបន្ទុកធនធានទឹក យល់ថាមានព័ត៌មានគ្រប់គ្រាន់ ដើម្បីធ្វើសេចក្តីសម្រេចលើពាក្យស្នើសុំលិខិតអនុញ្ញាត ក្រសួង ស្ថាប័នទទួលបន្ទុកធនធានទឹកត្រូវជូនដំណឹងជាសាធារណៈ អំពីពាក្យស្នើសុំលិខិតអនុញ្ញាត ដូចខាងក្រោម ៖

១- ព័ត៌មានលម្អិតនៃពាក្យស្នើសុំលិខិតអនុញ្ញាតនោះ ។

២- ទីកន្លែងដែលត្រូវពិនិត្យលើពាក្យសុំលិខិតអនុញ្ញាតនោះ ។

៣- កាលបរិច្ឆេទ នៃការដាក់ពាក្យសុំលិខិតអនុញ្ញាតជាលាយលក្ខណ៍អក្សរ ដែលបានបញ្ជូនមកក្រសួង ស្ថាប័នទទួលបន្ទុកធនធានទឹក យ៉ាងហោចណាស់ក្នុងរយៈពេល ៣០ (សាមសិប) ថ្ងៃក្រោយពីថ្ងៃជូនដំណឹងជាសាធារណៈ ។

**មាត្រា៤៨៤** ._ នីតិវិធី និងការពិចារណាចំពោះការឯកភាព ឬបដិសេធ

នីតិវិធី និងលក្ខខណ្ឌនៃការផ្តល់ឯកភាព ឬការបដិសេធលើពាក្យសុំលិខិតអនុញ្ញាតត្រូវកំណត់ក្នុងលិខិតបទដ្ឋានគតិយុត្តដោយឡែក។

## ផ្នែកទី៥
## អ្នកអភិវឌ្ឍទឹកក្រោមដី

**មាត្រា៤៨៥** ._ ការដាក់ពាក្យសុំ

បុគ្គលគ្រប់រូបអាចដាក់ពាក្យស្នើសុំវិញ្ញាបនបត្រទៅកាន់ក្រសួង ស្ថាប័នទទួលបន្ទុកធនធានទឹក ដូចខាងក្រោម ៖

១- អ្នកខួងអណ្តូងខួង ។

២- អ្នកជីកអណ្តូងខួង ។

៣- អ្នកដំឡើងម៉ាស៊ីនបូមទឹកក្រោមដី ។

**មាត្រា៤៨៦** ._ នីតិវិធីសម្រាប់ការដាក់ពាក្យស្នើសុំ

ក្រសួង ស្ថាប័នទទួលបន្ទុកធនធានទឹក ត្រូវរៀបចំលិខិតបទដ្ឋានគតិយុត្តស្តីពីនីតិវិធីសម្រាប់ការដាក់ពាក្យស្នើសុំវិញ្ញាបនបត្រ ។

**មាត្រា៤៨៧** ._ នីតិវិធីសម្រាប់ការឯកភាព ឬបដិសេធ

នីតិវិធី និងលក្ខខណ្ឌសម្រាប់ការឯកភាព ឬបដិសេធលើពាក្យស្នើសុំវិញ្ញាបនបត្រ ត្រូវកំណត់ដោយលិខិតបទដ្ឋានគតិយុត្តដោយឡែក។

**មាត្រា៤៨៨** ._ លក្ខខណ្ឌនានានៃវិញ្ញាបនបត្រ

លក្ខខណ្ឌនានានៃវិញ្ញាបនបត្រត្រូវកំណត់ដោយលិខិតបទដ្ឋានគតិយុត្តដោយឡែក ។

**មាត្រា៤៨៩** ._ នីតិវិធីក្នុងការលុបចោលវិញ្ញាបនបត្រ

នីតិវិធីក្នុងការលុបចោលវិញ្ញាបនបត្រត្រូវកំណត់ដោយលិខិតបទដ្ឋានគតិយុត្តដោយឡែក ។

**មាត្រា៤៩០** ._ ភស្តុតាងនៃវិញ្ញាបនបត្រ

មន្ត្រីមានសមត្ថកិច្ច អាចតម្រូវឱ្យរូបវន្តបុគ្គលផ្តល់ភស្តុតាងជាវិញ្ញាបនបត្រ សម្រាប់ការធ្វើអធិការកិច្ច ក្នុងករណីដែលមន្ត្រីមានសមត្ថកិច្ចនោះ សង្ស័យថា មាន៖

១- ការខួង ការជីក ការធ្វើឱ្យជ្រៅ ការពង្រីក ឬការដាក់បំពង់ទប់ដីក្នុងប្រតិបត្តិការធ្វើអណ្តូងស្នប់ ។

២- ការដកចេញ ការដាក់ជំនួស ការប្តូរ ឬការជួសជុលបំពង់ទប់ដី និងបំពង់ហ្វីលក្នុងប្រតិបត្តិការធ្វើអណ្តូងស្នប់ ។

៣- បញ្ឈប់ដំណើរការនៃការធ្វើអណ្តូងខួង ។

៤- ការដំឡើង ការដាក់ជំនួស ការប្តូរ ឬការដកចេញម៉ូទ័របូមទឹកពីអណ្តូងស្នប់ ។

**មាត្រា៤៩១** ._ សកម្មភាពដែលត្រូវហាមឃាត់

ត្រូវហាមឃាត់ចំពោះ រាល់សកម្មភាពទាំងឡាយណាដែលធ្វើឡើងដោយពុំមានវិញ្ញាបនបត្រសម្រាប់មន្ត្រីអធិការកិច្ច ដើម្បីចុះធ្វើអធិការកិច្ច ។

**មាត្រា៤៩២** ._ លក្ខខណ្ឌតម្រូវក្នុងការរៀបចំរបាយការណ៍

បុគ្គលគ្រប់រូបដែលធ្វើការទាក់ទងនឹងអណ្តូងខួង សម្រាប់គោលបំណងមុខរបរ ឬអាជីវកម្ម ត្រូវរៀបចំរបាយការណ៍ ទៅក្រសួង ស្ថាប័នទទួលបន្ទុកធនធានទឹក ។

ព័ត៌មានលម្អិតសម្រាប់ដាក់បញ្ចូលក្នុងរបាយការណ៍ ត្រូវកំណត់ក្នុងលិខិតបទដ្ឋានគតិយុត្ត ដោយឡែក ។

**មាត្រា៤៩៣** ._ កំណត់ត្រាសកម្មភាព

អ្នកកាន់វិញ្ញាបនបត្រត្រូវរក្សាទុកព័ត៌មានអំពីសកម្មភាពដែលខ្លួនបានអនុវត្ត ស្របតាមបទប្បញ្ញត្តិនៃក្រមនេះ ។

អ្នកកាន់វិញ្ញាបនបត្រ ត្រូវផ្តល់ព័ត៌មានដូចមានចែងក្នុងកថាខណ្ឌខាងលើ ទៅកាន់ក្រសួង ស្ថាប័នទទួលបន្ទុកធនធានទឹក ក្នុងករណីមានការស្នើសុំ ។

## ផ្នែកទី៦
## ការដកហូតការអនុញ្ញាត

**មាត្រា៤៩៤** ._ លក្ខខណ្ឌសម្រាប់ការដកហូតការអនុញ្ញាត

ក្រសួង ស្ថាប័នទទួលបន្ទុកធនធានទឹក ត្រូវរៀបចំលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធស្តីពីលក្ខខណ្ឌ និងនីតិវិធីសម្រាប់ការដកហូតការអនុញ្ញាត ។

## ជំពូកទី៥
## ការតម្រូវឱ្យមានការអនុញ្ញាត

**មាត្រា៤៩៥** ._ ការអនុញ្ញាតចំពោះការផ្គត់ផ្គង់ និងប្រើប្រាស់ទឹក

បុគ្គលគ្រប់រូបមិនត្រូវអនុញ្ញាតឱ្យយក ផ្គត់ផ្គង់ ឬប្រើប្រាស់ទឹក លើកលែងតែទទួលបានការអនុញ្ញាត ស្របតាមបទប្បញ្ញត្តិនៃក្រមនេះ ។

**មាត្រា៤៩៦** ._ ការរំលោភបំពានទៅលើលិខិតអនុញ្ញាត

អ្នកកាន់លិខិតអនុញ្ញាត មិនត្រូវបំពានទៅលើលក្ខខណ្ឌដូចបានកំណត់នៅក្នុងលិខិតអនុញ្ញាតនោះទេ ។

**មាត្រា៤៩៧** ._ ការចេញចូលបរិវេណដីឯកជន របស់មន្ត្រីមានសមត្ថកិច្ច

ម្ចាស់កម្មសិទ្ធិដី ឬអ្នកកាន់កាប់ដីឯកជន មិនត្រូវបដិសេធមិនឱ្យមន្ត្រីដែលមានសមត្ថកិច្ចនៃក្រសួង ស្ថាប័នទទួលបន្ទុកធនធានទឹក ចេញចូលដីឯកជនរបស់ខ្លួនដើម្បីបំពេញភារកិច្ចក្នុងការធ្វើការសិក្សាផ្នែកបច្ចេកទេស ការវាយតម្លៃ ឬការអង្កេតតាមដាន លើកលែងតែ ៖

១- ក្រសួង ស្ថាប័នទទួលបន្ទុកធនធានទឹក មិនបានជូនដំណឹងជាលាយលក្ខណ៍អក្សរជាមុនដល់ម្ចាស់កម្មសិទ្ធិដី ឬអ្នកកាន់កាប់ដីឯកជន ឬ

២- មន្ត្រីមានសមត្ថកិច្ចមិនបានផ្តល់ភស្តុតាងអំពីអត្តសញ្ញាណ និងពុំមានលិខិតអនុញ្ញាតពីក្រសួង ស្ថាប័នទទួលបន្ទុកធនធានទឹក ។

## ជំពូកទី៦
## ការរៀបចំផែនការធនធានទឹកអាងទន្លេអន្តរកាល

**មាត្រា៤៩៨** ._ បញ្ជីសកម្មភាពអាទិភាពសម្រាប់ការរៀបចំផែនការធនធានទឹកអាងទន្លេ

ក្រសួង ស្ថាប័នទទួលបន្ទុកធនធានទឹក ត្រូវរៀបចំតារាងពេលវេលាសម្រាប់ការអនុវត្តលើការរៀបចំផែនការធនធានទឹកអាងទន្លេ ក្នុងរយៈពេល០១ (មួយ) ឆ្នាំក្រោយក្រមនេះចូលជាធរមាន ។

**មាត្រា៤៩៩** ._ ករណីលើកលែងចំពោះសិទ្ធិទទួលបានទឹក

បុគ្គលគ្រប់រូបមានសិទ្ធិប្រើប្រាស់ធនធានទឹក ដោយពុំចាំបាច់មានលិខិតអនុញ្ញាតចំពោះសកម្មភាពដូចខាងក្រោម៖

១- ការស្រោចស្រពដីនៃតំបន់ទាំងមូលដែលតិចជាង ១០ (ដប់)ហិកតា ។

២- ការផ្គត់ផ្គង់ទឹកស្អាត ដែលប្រើប្រាស់ទឹក តិចជាង ៥០ (សែសិប) ម៉ែត្រគូប ក្នុងមួយថ្ងៃ ឬ

៣- ថាមពលវារីអគ្គិសនីដើរដោយលំហូរទឹកទន្លេ ឬបច្ចេកទេសថាមពលវារីអគ្គិសនីដែលមិនតម្រូវឲ្យមានការបង្ខាំង ការបង្វែរ ឬការទាញយកទឹកមកប្រើ ។

**មាត្រា៥00** ._ ការអនុលោមតាមវិធានច្បាប់របស់នីតិបុគ្គល

នីតិបុគ្គលដែលធ្វើសកម្មភាព ដូចមានចែងក្នុងជំពូកទី៤ នៃមាតិកានេះ ដោយពុំមានការអនុញ្ញាតជាមុនពីក្រសួង ស្ថាប័នទទួលបន្ទុកធនធានទឹក ត្រូវអនុវត្តតាមបទប្បញ្ញត្តិដូចមានចែងក្នុងជំពូកទី៤ នៃមាតិកានេះ។

**មាត្រា៥០១ .**_ ការកំណត់អំពីច្រាំងទន្លេ ឬឆ្នេរសមុទ្រ

ក្រសួង ស្ថាប័នទទួលបន្ទុកធនធានទឹក ត្រូវរៀបចំលិខិតបទដ្ឋានគតិយុត្តដើម្បីកំណត់ពីចម្ងាយ និងលក្ខណៈរូបសាស្ត្រនៃច្រាំងទន្លេ និងឆ្នេរសមុទ្រ និងសមាសភាគនៃអាងទន្លេ ។

## គន្ថីទី៥
## ការអភិរក្ស និងការគ្រប់គ្រងបេតិកភណ្ឌវប្បធម៌ និងបេតិកភណ្ឌធម្មជាតិ
## មាតិកាទោល
## ការអភិរក្ស និងការគ្រប់គ្រងបេតិកភណ្ឌវប្បធម៌ និងបេតិកភណ្ឌធម្មជាតិ
## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**មាត្រា៥០២ .**_ វិសាលភាព

មាតិកានេះមានវិសាលភាពអនុវត្តចំពោះបេតិកភណ្ឌវប្បធម៌ និងបេតិកភណ្ឌធម្មជាតិ ក្នុងគោលដៅថែរក្សា ការពារ អភិរក្ស និងអភិវឌ្ឍ ឱ្យបានគង់វង្ស និងដោយចីរភាព។

**មាត្រា៥០៣ .**_ បេតិកភណ្ឌវប្បធម៌

បេតិកភណ្ឌវប្បធម៌សំដៅលើ សម្បត្តិវប្បធម៌រូបី និងអរូបី ដែលជាស្នាដៃរបស់មនុស្ស បង្ហាញពីទេពកោសល្យ ប្រាជ្ញាស្មារតី ឬគំនិតច្នៃប្រឌិត និងឆ្លុះបញ្ចាំងអំពីដំណាក់កាលវិវត្តន៍នៃអារ្យធម៌ ហើយដែលមានតម្លៃបុរេប្រវត្តិសាស្ត្រ ប្រវត្តិសាស្ត្រ ស្នាដៃស្ថាបត្យកម្ម បុរាណវិទ្យា ជាតិពន្ធុវិទ្យា អក្សរសាស្ត្រ សិល្បៈ សាសនា ឬវិទ្យាសាស្ត្រ ។

**មាត្រា៥០៤ .**_ សម្បត្តិវប្បធម៌រូបី និងអរូបី

សម្បត្តិវប្បធម៌រូបី ដូចមានចែងនៅក្នុងមាត្រា៥០៣ សំដៅលើចលនៈ និងអចលនសម្បត្តិ ដែលត្រូវបានបង្កើតឡើងនិងរកឃើញនៅក្នុងទឹក ក្នុងដី និងនៅលើដីនៃព្រះរាជាណាចក្រកម្ពុជា ទោះជាកម្មសិទ្ធិសាធារណៈក្តី ឬក៏ជាកម្មសិទ្ធិឯកជនក្តី កិច្ចការពារត្រូវបម្រើប្រយោជន៍សាធារណៈ។

សម្បត្តិវប្បធម៌អរូបី ជាស្នាដៃបង្កើតដោយមនុស្ស បានផ្ទេរបន្តពីជំនាន់មួយទៅជំនាន់មួយតាមរយៈការប្រតិបត្តិ ការបង្ហាញ ការសម្តែង ការនិយាយ ឬការគ្រាប់តៗគ្នា ដែលមិនអាចមើលឃើញ មិនអាចប៉ះពាល់បាន និងពិបាកយល់ដូចជា៖ ចំណេះដឹង បំណិន ភាសា សាសនា ជំនឿ ទំនៀមទំលាប់ប្រពៃណី ឧបករណ៍ សម្ភារៈ វត្ថុសិល្បៈជាដើម។

**មាត្រា៥០៥** ._ កិច្ចការពារបេតិកភណ្ឌវប្បធម៌

បេតិកភណ្ឌវប្បធម៌ ដែលត្រូវការពារ ដូចមានចែងក្នុងមាត្រា៥០៣ រួមមាន បេតិកភណ្ឌបុរេប្រវត្តិសាស្ត្រ មុនសម័យអង្គរ សម័យអង្គរ ក្រោយសម័យអង្គរ សម័យអាណាព្យាបាល និងសម័យទំនើប ត្រូវមានអាយុកាលចាប់ពី១០០(មួយរយ)ឆ្នាំឡើងទៅ ហើយស្ថិតនៅក្នុងប្រភេទណាមួយដូចខាងក្រោម៖

១- បុរាណស្ថាន ៖ ប្រាសាទបុរាណ ទីសក្ការៈបូជា វត្តអារាម សំណង់អាគារ ឬលំនៅស្ថានចាស់ៗ  ស្នាដៃគំនូរ ឬចម្លាក់នៅលើជញ្ជាំងភ្នំ លំនៅដ្ឋានល្អាងភ្នំ  ទីបញ្ចុះសពបុរាណ ទីក្រុងបុរាណ ទីប្រជុំជន ឬភូមិដ្ឋានបុរាណ ផ្លូវគមនាគមន៍ ប្រព័ន្ធផ្លូវទឹក ស្ពាន ស្រះ បារាយ ទំនប់ធារាសាស្ត្របុរាណ ។

២- វត្ថុបុរាណ ៖ រូបចម្លាក់ ផ្ទាំងចម្លាក់ ផ្ទាំងគំនូរវិចិត្រកម្ម ដែលគូរដោយដៃលើវត្ថុធាតុផ្សេងៗ រូបប្រថាប់ ផ្ទាំងសិលាចារឹកនៅដាច់តែឯង ឬជាប់លើថ្មដែលជាចំណែកនៃប្រាសាទ សំណេរលើវត្ថុធាតុផ្សេងៗ សាស្ត្រាស្លឹករិត  ក្បួន ក្រាំង គម្ពីរ សំណៅដើមនៃការផ្តុំ ឬតម្លើងជាវត្ថុសិល្បៈគ្រប់រូបភាពសម្ភារៈជាគ្រឿងរណ្តាប់បម្រើឱ្យពិធីសាសនា ឬគោរពបូជាផ្សេងៗ សម្ភារៈប្រើប្រាស់ក្នុងផ្ទះ សម្ភារៈកសិកម្ម ឧបករណ៍ភ្លេង ឧបករណ៍នេសាទ ឧបករណ៍ពេទ្យ គ្រឿងសាស្ត្រាវុធ គ្រឿងសង្ហារឹម គ្រឿងអលង្កា មធ្យោបាយធ្វើដំណើរ ឬដឹកជញ្ជូនតាមផ្លូវគោក និងតាមផ្លូវទឹក ។

៣- ស្នាដៃប្រវត្តិសាស្ត្រ ៖ សម្បត្តិវប្បធម៌ទាំងឡាយដែលឆ្លុះបញ្ចាំងអំពីប្រវត្តិសាស្ត្រ មានដូចជា ប្រវត្តិនៃបច្ចេកវិទ្យា ប្រវត្តិខាងយោធា ឬសង្គម ប្រវត្តិទាក់ទងនឹងអ្នកដឹកនាំ អ្នកប្រាជ្ញ សិល្បករជាតិ រួមទាំងប្រវត្តិទាក់ទងនឹងព្រឹត្តិការណ៍ជាតិសំខាន់ៗ ។

៤- ឯកសារកម្រ ៖ សៀវភៅ ប័ណ្ណសារផ្សេងៗជាខ្សែអាត់សំលែង ជារូបថត ឬជាខ្សែភាពយន្ត លិខិត កំណត់ត្រា ប្រកាស ក្រឹត្យច្បាប់ តែមប្រៃសណីយ៍ តែមសារពើពន្ធ ។

៥- ចំណេះជំនាញ ៖ វិជ្ជាពេទ្យបុរាណ វិធីផ្សំថ្នាំ វិធីព្យាបាលជម្ងឺ ចំណេះវិជ្ជាសំណង់ វិជ្ជាមន្តអាគមន៍ វិជ្ជាធ្វើសឹកសង្គ្រាម វិជ្ជាទាក់ដំរី ចំណេះដឹងខាងតារាសាស្ត្រ ខាងពិធីសាសនា ឬគោរពបូរជាផ្សេងៗ វិជ្ជាទស្សន៍ទាយ វិជ្ជាចារយន្ត ។

៦- សិល្បៈសម្តែង ៖ សិល្បៈទស្សនីយភាព តន្ត្រី ល្បែងប្រជាប្រិយ ពិធីបុណ្យ ។

**មាត្រា៥០៦** ._ បេតិកភណ្ឌធម្មជាតិ

បេតិកភណ្ឌធម្មជាតិសំដៅលើទម្រង់ធម្មជាតិនៃដែនដី ទាំងនៅដែនគោក និងដែនទឹក ដែលបង្កបង្កើតឡើងដោយកត្តារូបសាស្ត្រ ភូគព្ភសាស្ត្រ ជីវសាស្ត្រ ឬដោយមនុស្ស ដែលឆ្លុះបញ្ចាំងអំពីដំណាក់កាលវិវត្តន៍នៃធម្មជាតិ ឬអារ្យធម៌ និងមានតម្លៃប្រវត្តិសាស្ត្រ សិល្បៈ វិទ្យាសាស្ត្រ ឬសោភ័ណ។

កិច្ចការពារបេតិកភណ្ឌធម្មជាតិត្រូវបម្រើឱ្យប្រយោជន៍សាធារណៈ ។

**មាត្រា៥០៧** ._ ប្រភេទបេតិកភណ្ឌធម្មជាតិ

បេតិកភណ្ឌធម្មជាតិ ត្រូវចាត់ជាប្រភេទ ដូចខាងក្រោម៖

១- តំបន់បេតិកភណ្ឌធម្មជាតិ ។

២- ឧទ្យានបេតិកភណ្ឌធម្មជាតិ ។

៣- ឧទ្យានជាតិសមុទ្រ ។

៤- សួនប្រវត្តិសាស្ត្រ ។

បេតិកភណ្ឌធម្មជាតិដូចមានចែងខាងលើនេះ ត្រូវកំណត់ដោយលិខិតបទដ្ឋានគតិយុត្តដោយឡែកតាមសំណើរបស់ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន ។

**មាត្រា៥០៨** ._ តំបន់បេតិកភណ្ឌធម្មជាតិ

តំបន់បេតិកភណ្ឌធម្មជាតិសំដៅលើដែនដី ដែលបង្កើតឡើងដោយធម្មជាតិ ប្រមូលផ្ដុំទៅដោយអម្បូរសត្វ និងរុក្ខជាតិ ធនធានព្រៃឈើ ធនធានជីវៈចម្រុះ ប្រព័ន្ធអេកូឡូស៊ី ឬប្រភពទឹក ដែលមានសារៈប្រយោជន៍ខាងសត្តវិទ្យា បាសាណីភូតវិទ្យា ភូគគាមវិទ្យា ជីវៈវិទ្យា សោភ័ណ ឬជំនឿ។

តំបន់បេតិកភណ្ឌធម្មជាតិអាចរួមបញ្ចូលនូវធនធានវប្បធម៌ ទាំងរូបី និងអរូបី។

**មាត្រា៥០៩** ._ ឧទ្យានបេតិកភណ្ឌធម្មជាតិ

ឧទ្យានបេតិកភណ្ឌធម្មជាតិសំដៅលើដែនដី ដែលបង្កើតឡើងដោយធម្មជាតិ និងមនុស្ស ជាទីកន្លែងដែលប្រមូលផ្តុំទៅដោយព្រៃឈើ ធនធានជីវៈចម្រុះ អម្បូរសត្វនិងរុក្ខជាតិ និងធនធានវប្បធម៌ ដែលជាអត្តសញ្ញាណទឹកដី តំបន់ ឬទីប្រជុំជន និងមានតម្លៃខាងប្រវត្តិសាស្ត្រ វិទ្យាសាស្ត្រ សិល្បៈ សាសនា ឬសោភ័ណ។

**មាត្រា៥១០** ._ ឧទ្យានជាតិសមុទ្រ

ឧទ្យានជាតិសមុទ្រសំដៅលើដែនទឹក មានតំបន់ឆ្នេរ និងដែនកោះ ដែលប្រមូលផ្តុំទៅដោយព្រៃលិចទឹក ធនធានជីវៈចម្រុះ រុក្ខជាតិ និងសត្វសមុទ្រ ឬមច្ឆាជាតិ និងមានតម្លៃខាងប្រវត្តិសាស្ត្រ វិទ្យាសាស្ត្រ សោភ័ណ និងការកំសាន្ត។

**មាត្រា៥១១** ._ សួនប្រវត្តិសាស្ត្រ

សួនប្រវត្តិសាស្ត្រសំដៅលើទីកន្លែង ជាលំហរបៃតង ដែលរៀបចំឡើងដោយមនុស្សនៅតាមទីក្រុង ឬទីប្រជុំជន ឬនៅតាមលំនៅដ្ឋានសាធារណៈ ឬឯកជន បង្ហាញឱ្យឃើញអំពីស្នាដៃ ភាពប៉ិនប្រសព្វ និងគំនិតច្នៃប្រឌិត ដែលមានតម្លៃខាងប្រវត្តិសាស្ត្រ សិល្បៈ ឬសោភ័ណ និងមានសារៈប្រយោជន៍សម្រាប់ការលម្អ ការកំសាន្ត និងការសិក្សាស្រាវជ្រាវ។

**មាត្រា៥១២** ._ លក្ខណៈវិនិច្ឆ័យនៃបេតិកភណ្ឌធម្មជាតិ

លក្ខណៈវិនិច្ឆ័យនៃបេតិកភណ្ឌធម្មជាតិ មានដូចខាងក្រោម ៖

១- លក្ខណៈពិសេសពាក់ព័ន្ធនឹងប្រវត្តិសាស្ត្រ ដូចជា ប្រវត្តិនៃដើមកំណើត ដោយកត្តាភូពួសាស្ត្រ រូបសាស្ត្រ ឬជីវៈសាស្ត្រ ឬដោយអន្តរាគមន៍ពីមនុស្ស ឬសហាគមន៍មនុស្ស ។

២- ទីជម្រកនៃអម្បូរសត្វ និងរុក្ខជាតិ ដូចជាប្រភេទកម្រ ជិតផុតពូជ ឬកំពុងទទួលរងការគំរាមកំហែង ។

៣- ជម្រកសត្វនៃប្រភេទមួយ ឬច្រើន ដែលពង្រីកវិសាលភាពទៅតំបន់ផ្សេងៗ

៤- តំបន់ប្រភពទឹក ឬទឹកធ្លាក់ និងតំបន់ព្រៃឈើ ដែលរក្សាបាននូវប្រព័ន្ធអេកូឡូស៊ី និងបង្កើតទេសភាពប្លែកៗ សម្រាប់ការកំសាន្ត ។

៥- តំបន់ប្រើប្រាស់ក្នុងគោលដៅអភិរក្សជីវៈចម្រុះ អភិរក្សប្រភេទសត្វនិងរុក្ខជាតិកម្រ

៦- ជម្រកផ្កាថ្ម ឬរុក្ខជាតិសមុទ្រ ឬសំបុកពង-កូននៃមច្ឆាជាតិ ឬជម្រកនៃប្រភេទសត្វសមុទ្រ ដែលផ្តល់សារៈប្រយោជន៍ដល់ការសិក្សាស្រាវជ្រាវ ការអភិរក្ស និងការកំសាន្ត ។

៧- ដែនដីរៀបចំដោយមនុស្ស សម្រាប់ជាទីកន្លែងដាំដុះនូវពូជរុក្ខជាតិផ្សេងៗ ឬចិញ្ចឹមសត្វព្រៃដើម្បីបម្រើឱ្យការកំសាន្ត ឬការសិក្សាស្រាវជ្រាវ ។

៨- ដែនដី ឬទីកន្លែង ដែលបញ្ជាក់អំពីអត្តសញ្ញាណ ឬប្រវត្តិនៃនៃទីក្រុងឬទីប្រជុំជន ឬតំបន់ណាមួយ។

## ជំពូកទី២
## ការគ្រប់គ្រងបេតិកភណ្ឌវប្បធម៌
### ផ្នែកទី១
### ក្រសួង ស្ថាប័នមានសមត្ថកិច្ច

**មាត្រា៥១៣** ._ សមត្ថកិច្ចការងារគ្រប់គ្រងបេតិកភណ្ឌវប្បធម៌

ការងារគ្រប់គ្រងបេតិកភណ្ឌវប្បធម៌ ជាសមត្ថកិច្ចរបស់ក្រសួង ស្ថាប័នទទួលបន្ទុកបេតិកភណ្ឌវប្បធម៌ លើកលែងតែមានច្បាប់ ឬបទប្បញ្ញត្តិណាដែលចែងផ្ទុយពីក្រមនេះ។

**មាត្រា៥១៤** ._ តួនាទី និងភារកិច្ចរបស់ក្រសួង ស្ថាប័នទទួលបន្ទុកបេតិកភណ្ឌវប្បធម៌

ក្រសួង ស្ថាប័ន ទទួលបន្ទុកបេតិកភណ្ឌវប្បធម៌ ត្រូវអនុវត្តតួនាទី និងភារកិច្ចដូចខាងក្រោម៖

១- ថែរក្សា ការពារ និងអភិរក្សបេតិកភណ្ឌវប្បធម៌ឱ្យបានគង់វង្ស ស្របតាមក្រមនេះ និងច្បាប់ និងលិខិតបទដ្ឋានគិតយុត្តដោយឡែកផ្សេងទៀតដែលនៅជាធរមាន ។

២- អនុវត្តគោលនយោបាយ ដែលដាក់ចេញដោយក្រុមប្រឹក្សាជាន់ខ្ពស់ផ្នែកវប្បធម៌ជាតិ ក្នុងការការពារ ថែរក្សា និងលើកតម្លៃ បេតិកភណ្ឌវប្បធម៌ ។

**មាត្រា៥១៥** ._ ការលើកសំណើសុំបញ្ចូលទីតាំងតំបន់បេកិកភណ្ឌវប្បធម៌

ក្រសួង ស្ថាប័នទទួលបន្ទុកបេតិកភណ្ឌវប្បធម៌ ត្រូវលើកសំណើរទៅក្រុមប្រឹក្សាជាន់ខ្ពស់ផ្នែកវប្បធម៌ជាតិ អំពីបំណងស្នើសុំដាក់បញ្ចូលទីតាំងវប្បធម៌ណាជាតំបន់ការពារបេតិកភណ្ឌវប្បធម៌ ដូចមានចែងក្នុងមាត្រា៥៣៧ ។

**មាត្រា៥១៦** ._ ការរៀបចំផែនការគ្រប់គ្រងបេតិកភណ្ឌវប្បធម៌

ក្រសួង ស្ថាប័នទទួលបន្ទុកបេតិកភណ្ឌវប្បធម៌ ដោយសហការជាមួយក្រសួង/ស្ថាប័ន អាជ្ញាធរពាក់ព័ន្ធ សហគមន៍នានា ត្រូវរៀបចំផែនការគ្រប់គ្រងបេតិកភណ្ឌវប្បធម៌ សម្រាប់បុរាណស្ថាន ឬសម្បត្តិវប្បធម៌ណា ដែលបានចុះនៅក្នុងបញ្ជីបេតិកភណ្ឌវប្បធម៌ជាតិ តំបន់ការពារបេតិកភណ្ឌវប្បធម៌ ឬតំបន់បេតិកភណ្ឌទីក្រុង ស្របតាមបទប្បញ្ញត្តិស្តីពីការចូលរួមជាសាធារណៈ នៃក្រមនេះ ។

**មាត្រា៥១៧ ._** ការយកចិត្តទុកដាក់អំពីផលប៉ះពាល់នៃទីតាំងបេតិកភណ្ឌវប្បធម៌

ក្រសួង ស្ថាប័នទទួលបន្ទុកបេតិកភណ្ឌវប្បធម៌ ត្រូវយកចិត្តទុកដាក់អំពីផលប៉ះពាល់នៃទីតាំងបេតិកភណ្ឌវប្បធម៌ ចំពោះសហគមន៍មូលដ្ឋាន និងជនជាតិដើមភាគតិច ។

**មាត្រា៥១៨._** ការពិគ្រោះយោបល់ជាមួយអ្នកពាក់ព័ន្ធ

ក្រសួង ស្ថាប័នពាក់ព័ន្ធត្រូវធ្វើការពិគ្រោះយោបល់ជាមួយ សហគមន៍មូលដ្ឋាន និងជនជាតិដើមភាគតិច មុននឹងធ្វើសេចក្តីសម្រេចទាក់ទងនឹងបេតិកភណ្ឌវប្បធម៌ ដែលអាចប៉ះពាល់ដល់ពួកគាត់ ស្របតាមបទប្បញ្ញត្តិស្តីពីការចូលរួមជាសាធារណៈ នៃក្រមនេះ ។

## ផ្នែកទី២
## ក្រុមប្រឹក្សាជាន់ខ្ពស់ផ្នែកវប្បធម៌ជាតិ

**មាត្រា៥១៩ ._** តួនាទី និងភារកិច្ចរបស់ក្រុមប្រឹក្សាជាតិជាន់ខ្ពស់ផ្នែកវប្បធម៌ជាតិ

ក្រុមប្រឹក្សាជាន់ខ្ពស់ផ្នែកវប្បធម៌ជាតិ ត្រូវមានដំណើរការឡើងវិញ និងត្រូវមានតួនាទី និងភារកិច្ច ដូចខាងក្រោម៖

១- កំណត់អត្តសញ្ញាណ ការពារ ថែរក្សា ធ្វើកំណត់ត្រា និងលើកកម្ពស់កិច្ចការពារបេតិកភណ្ឌវប្បធម៌ សម្រាប់ជំនាន់បច្ចុប្បន្ន និងអនាគត នៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

២- បង្កើតគោលនយោបាយស្តីពីកិច្ចការពារ និងលើកស្ទួយបេតិកភណ្ឌវប្បធម៌ នៃព្រះរាជាណាចក្រកម្ពុជា ។

៣- បង្កើត និងរៀបចំផែនការយុទ្ធសាស្ត្រ និង ផែនការសកម្មភាព ដើម្បីការពារ លើកស្ទួយ និងគ្រប់គ្រងបេតិកភណ្ឌវប្បធម៌ ។

៤- ការពារទ្រព្យសម្បត្តិវប្បធម៌បុរេប្រវត្តិសាស្ត្រ និងប្រវត្តិសាស្ត្រ និងវត្ថុបុរាណនៃធម្មជាតិរូបសាស្ត្រ ។

៥- គ្រប់គ្រង និងត្រួតពិនិត្យតំបន់នានា នៅទីកន្លែងណាដែលវិមាន/បូជនីយដ្ឋាន ដែលបានចុះបញ្ជីរួចស្ថិតនៅ រួមជាមួយការប្រមូលផ្ដុំនៃវត្ថុសិល្បៈនានា ដែលមានការទាក់ទងទៅនឹងវិមាន ឬបូជនីយដ្ឋានទាំងនេះ ។

៦- ផ្ដល់ការអនុញ្ញាតសម្រាប់ការស្រាវជ្រាវផ្នែកបុរាណវត្ថុវិទ្យាទាំងអស់ ការងារអភិរក្ស និងសកម្មភាពដទៃទៀត ដែលទាក់ទងទៅនឹងទីតាំងបូជនីយដ្ឋាន និងទ្រព្យសម្បត្តិវប្បធម៌របស់ជាតិ ។

ក្រុមប្រឹក្សាជាន់ខ្ពស់ផ្នែកវប្បធម៌ជាតិ ត្រូវជួបប្រជុំជាទៀងរាល់៦(ប្រាំមួយ)ខែម្ដង ដើម្បីតាមដានការអនុវត្ត ប្រកបដោយប្រសិទ្ធភាពដើម្បីឆ្លើយតបទៅនឹងការពារបេតិកភណ្ឌវប្បធម៌ ។

**មាត្រា៥២០** ._ សមាជិកនៃក្រុមប្រឹក្សាជាន់ខ្ពស់ផ្នែកវប្បធម៌ជាតិ

ក្រុមប្រឹក្សាជាន់ខ្ពស់ផ្នែកវប្បធម៌ជាតិ ត្រូវមានសមាជិកដូចខាងក្រោម៖

១- តំណាងនាយករដ្ឋមន្ត្រី ជាប្រធាន ។

២- តំណាងរដ្ឋមន្ត្រីក្រសួង ស្ថាប័នទទួលបន្ទុកបេតិកភណ្ឌវប្បធម៌ ជាអនុប្រធាន ។

៣- តំណាងក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ជាសមាជិក ។

៤- តំណាងរដ្ឋមន្ត្រីក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន ជាសមាជិក ។

៥- តំណាងរដ្ឋមន្ត្រីក្រសួង ស្ថាប័នទទួលបន្ទុកឧស្សាហកម្ម និងសិប្បកម្មជាសមាជិក។

៦- តំណាងរដ្ឋមន្ត្រីក្រសួង ស្ថាប័នទទួលបន្ទុករៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ជាសមាជិក ។

៧- តំណាងពីរាជបណ្ឌិត្យសភាកម្ពុជា ជាសមាជិក ។

៨- តំណាងអាជ្ញាធរមានសមត្ថកិច្ចទទួលបន្ទុកតំបន់បេតិកភណ្ឌពិភពលោក ជាសមាជិក ។

៩- តំណាងសាលារាជធានី ខេត្ត ជាសមាជិក ។

១០- តំណាង២(ពីរ)រូប ពីអង្គការមិនមែនរដ្ឋាភិបាល ដែលមានការពាក់ព័ន្ធនឹងការការពារ និងការអភិរក្សបេតិកភណ្ឌ ជាសមាជិក ។

១១- អ្នកមានជំនាញផ្នែកបច្ចេកទេសចំនួន២(ពីរ) រូប ដែលមានគុណសម្បត្តិ និងជំនាញផ្នែកបេតិកភណ្ឌ ជាសមាជិក ។

១២- តំណាងក្រសួង ស្ថាប័ន ឬនីតិបុគ្គលដទៃទៀត ដែលមានការងារពាក់ព័ន្ធនឹងបេតិកភណ្ឌវប្បធម៌ ដែលក្រុមប្រឹក្សាជាន់ខ្ពស់ផ្នែកវប្បធម៌អាចជ្រើសរើសតាមការចាំបាច់ ។

**មាត្រា៥២១** ._ កិច្ចសហការរវាងក្រុមប្រឹក្សាជាន់ខ្ពស់ផ្នែកវប្បធម៌ជាតិ និងក្រសួង ស្ថាប័នពាក់ព័ន្ធ

ក្រុមប្រឹក្សាជាន់ខ្ពស់ផ្នែកវប្បធម៌ជាតិ ត្រូវសហការជាមួយក្រសួង ស្ថាប័នទទួលបន្ទុកបេតិកភណ្ឌវប្បធម៌ និង ក្រសួង ស្ថាប័នពាក់ព័ន្ធ និងនីតិបុគ្គលដទៃទៀត ក្នុងការៈ

១- អនុវត្តគោលនយោបាយក្នុងការលើកស្ទួយបេតិកភណ្ឌវប្បធម៌ ។

២- រៀបចំមធ្យោបាយ ដើម្បីអនុញ្ញាតឲ្យសាធារណជនអាចចូលទៅកាន់បេតិកភណ្ឌវប្បធម៌ ។

៣- តែងតាំងបុគ្គលិកត្រួតពិនិត្យ និងបុគ្គលិកដទៃទៀត ដើម្បីអនុវត្តការងារនេះ ។

៤- រៀបចំបណ្ដាញអ្នកទេសចរណ៍ ។

៥- លើកកម្ពស់តម្លៃវប្បធម៌ ដោយកៀងគរមូលនិធិដែលចាំបាច់ អប់រំដល់សាធារណជន បុគ្គលិកបណ្ដុះបណ្ដាល និងអនុវត្តការស្រាវជ្រាវអំពីបេតិកភណ្ឌរូបសាស្ត្រ វប្បធម៌ និងប្រវត្តិសាស្ត្រ ។

៦- ផ្ដល់ការធានាទាក់ទងនឹងការទទួលខុសត្រូវ និងកាតព្វកិច្ចផ្នែកគ្រប់គ្រង ដែលមានចែងនៅក្នុងអនុសញ្ញាស្ដីពីវប្បធម៌ និងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀត ដែលព្រះរាជាណាចក្រកម្ពុជាជាភាគីហត្ថលេខី ។

៧- ចាត់វិធានការចាំបាច់ ដើម្បីអនុវត្តគម្រោង និងសកម្មភាពដទៃទៀត ដែលទាក់ទងនឹងការការពារ ការថែរក្សា ការស្ដារឡើងវិញ និងការលើកស្ទួយបេតិកភណ្ឌជាតិ ។

៨- បង្កើតលិខិតបទដ្ឋានគតិយុត្ត ដើម្បីអនុវត្តកាតព្វកិច្ចរបស់ព្រះរាជាណាចក្រកម្ពុជាចំពោះការការពារបេតិកភណ្ឌវប្បធម៌ ។

## ជំពូកទី៣
## ការគ្រប់គ្រងបេតិកភណ្ឌធម្មជាតិ

**មាត្រា៥២២** ._ សមត្ថកិច្ចការងារគ្រប់គ្រងបេតិកភណ្ឌធម្មជាតិ

ការងារគ្រប់គ្រងបេតិកភណ្ឌធម្មជាតិ ជាសមត្ថកិច្ចរបស់ក្រសួង ស្ថាប័នទទួលបន្ទុក បរិស្ថាន លើកលែងតែមានច្បាប់ ឬបទប្បញ្ញត្តិណាដែលចែងផ្ទុយពីក្រមនេះ។

**មាត្រា៥២៣** ._ តួនាទី និងភារកិច្ចក្នុងការថែរក្សា ការពារ និងអភិរក្សបេតិកភណ្ឌធម្មជាតិ

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថានត្រូវអនុវត្តតួនាទី និងភារកិច្ចក្នុង ការថែរក្សា ការពារ និង អភិរក្សបេតិកភណ្ឌធម្មជាតិឱ្យបានគង់វង្ស ស្របតាមក្រមនេះ និងច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត ដោយឡែកដែលនៅជាធរមាន ។

**មាត្រា៥២៤** ._ ការរៀបចំបង្កើតបញ្ជីបេតិកភណ្ឌធម្មជាតិ

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន ត្រូវរៀបចំបង្កើតបញ្ជីបេតិកភណ្ឌធម្មជាតិ ដើម្បីកត់ត្រា បញ្ចូលនូវប្រភេទនៃបេតិកភណ្ឌធម្មជាតិ និងទិន្នន័យខាងវិទ្យាសាស្ត្រ ដែលបម្រើឱ្យការសិក្សា ស្រាវជ្រាវ និងអភិរក្ស។

**មាត្រា៥២៥** ._ ការរៀបចំផែនការគ្រប់គ្រងបេតិកភណ្ឌធម្មជាតិ

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន ដោយមានការចូលរួមពិគ្រោះយោបល់ពីសហគមន៍មូល ដ្ឋាន និងអ្នកពាក់ព័ន្ធនានា ត្រូវរៀបចំផែនការគ្រប់គ្រងបេតិកភណ្ឌធម្មជាតិ ស្របតាមច្បាប់ជាតិ និង អន្តរជាតិ ពាក់ព័ន្ធនឹងកិច្ចការពារ ថែរក្សា និងអភិរក្សធនធានធម្មជាតិ និងស្របតាមបទប្បញ្ញត្តិស្តីពីការ ចូលរួមជាសាធារណៈ នៃក្រមនេះ ។

**មាត្រា៥២៦** ._ ការយកចិត្តទុកដាក់អំពីផលប៉ះពាល់នៃទីតាំងបេតិកភណ្ឌធម្មជាតិ

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន ត្រូវយកចិត្តទុកដាក់អំពីផលប៉ះពាល់នៃទីតាំងបេតិកភណ្ឌ ធម្មជាតិទៅលើសហគមន៍មូលដ្ឋាន និងជនជាតិដើមភាគតិច ទៅលើជំនឿ មុខរបរ និងការគ្រប់គ្រង ដីធ្លី។

**មាត្រា៥២៧** ._ ការលើកទឹកចិត្តក្នុងការចូលរួមថែរក្សា ការពារ និងអភិរក្សបេតិកភណ្ឌធម្មជាតិ

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន ត្រូវលើកទឹកចិត្តដល់សហគមន៍មូលដ្ឋាន ឬជនជាតិដើម ភាគតិច ឱ្យចូលរួមក្នុងកិច្ចការថែរក្សា ការពារ និងអភិរក្សបេតិកភណ្ឌធម្មជាតិ ស្របតាមបទប្បញ្ញត្តិស្តី ពីការចូលរួមជាសាធារណៈ នៃក្រមនេះ ។

**មាត្រា៥២៨** ._ ការផ្តល់អាទិភាពក្នុងការអភិវឌ្ឍមុខរបររបស់សហគមន៍មូលដ្ឋាន ឬជនជាតិដើម ភាគតិច

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន ត្រូវផ្តល់អាទិភាពក្នុងការអភិវឌ្ឍមុខរបរ ដល់សហគមន៍មូលដ្ឋាន ឬជនជាតិដើម ភាគតិច ដែលស្ថិតក្នុង ឬក្បែរតំបន់បេតិកភណ្ឌធម្មជាតិ ។

**មាត្រា៥២៩** ._ ការដាក់បញ្ចូលបេតិកភណ្ឌវប្បធម៌និងសម្បត្តិវប្បធម៌ក្នុងសមាសភាគនៃប្រព័ន្ធតំបន់ការពារធម្មជាតិ

សមាសភាគនៃប្រព័ន្ធតំបន់ការពារធម្មជាតិ ត្រូវដាក់បញ្ចូលទីតាំងបេតិកភណ្ឌវប្បធម៌ និងសម្បត្តិវប្បធម៌ទាំងឡាយ ដែលមានក្នុងតំបន់នោះ។

## ជំពូកទី៤
## បញ្ជីបេតិកភណ្ឌវប្បធម៌ជាតិ

**មាត្រា៥៣០** ._ ការរៀបចំបញ្ជីបេតិកភណ្ឌវប្បធម៌ជាតិ

ក្រសួង ស្ថាប័នទទួលបន្ទុកបេតិកភណ្ឌវប្បធម៌ ត្រូវរៀបចំបញ្ជីបេតិកភណ្ឌវប្បធម៌ជាតិ ដែលមានលក្ខណៈវិទ្យាសាស្ត្រសម្រាប់ព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា៥៣១** ._ ការផ្ទៀងផ្ទាត់ឡើងវិញនូវបញ្ជីបេតិកភណ្ឌវប្បធម៌ជាតិ

បញ្ជីបេតិកភណ្ឌវប្បធម៌ជាតិ ត្រូវធ្វើការផ្ទៀងផ្ទាត់ឡើងវិញយ៉ាងហោចណាស់រាល់ ៥(ប្រាំ)ឆ្នាំម្តង ។

**មាត្រា៥៣២** ._ ការចុះបញ្ជីបេតិកភណ្ឌវប្បធម៌ជាតិ

ក្រសួង ស្ថាប័នទទួលបន្ទុកបេតិកភណ្ឌវប្បធម៌ជាតិ ត្រូវចុះបញ្ជីសម្បត្តិវប្បធម៌ ដូចមានចែងក្នុងមាត្រា៥០៥ ទៅក្នុងបញ្ជីបេតិកភណ្ឌវប្បធម៌ជាតិ ។

បញ្ជីបេតិកភណ្ឌវប្បធម៌ជាតិត្រូវបញ្ជាក់អំពីស្ថានភាពគ្រោះថ្នាក់នៃសម្បត្តិវប្បធម៌ណា ដែលតម្រូវឱ្យធ្វើការសង្គ្រោះបន្ទាន់។

បែបបទ និងនីតិវិធីនៃការរៀបចំ និងការចុះបញ្ជីបេតិកភណ្ឌវប្បធម៌ជាតិត្រូវអនុវត្តទៅតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តដែលនៅជាធរមាន។

**មាត្រា៥៣៣** ._ ការការពារស្របច្បាប់ចំពោះសម្បត្តិវប្បធម៌

សម្បត្តិវប្បធម៌ ដូចមានចែងក្នុងមាត្រា៥០៥ ដែលត្រូវបានចុះក្នុងបញ្ជីបេតិកភណ្ឌវប្បធម៌ជាតិ ត្រូវទទួលបាននូវការការពារ ស្របតាមក្រមនេះ និងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធដទៃទៀត ។

## ជំពូកទី៥
## ការធ្វើចំណាត់ថ្នាក់បេតិកភណ្ឌវប្បធម៌

**មាត្រា៥៣៤** ._ លក្ខណៈវិនិច្ឆ័យនៃការកំណត់ជាបេតិកភណ្ឌវប្បធម៌

លក្ខណៈវិនិច្ឆ័យនៃការកំណត់ជាបេតិកភណ្ឌវប្បធម៌ ត្រូវកំណត់ដោយលិខិតបទដ្ឋានគតិយុត្តរបស់ក្រសួង ស្ថាប័នទទួលបន្ទុកបេតិកភណ្ឌ ។

**មាត្រា៥៣៥** ._ បែបបទ និងនីតិវិធីនៃការធ្វើចំណាត់ថ្នាក់បេតិកភណ្ឌវប្បធម៌

បែបបទ និងនីតិវិធីនៃការធ្វើចំណាត់ថ្នាក់បេតិកភណ្ឌវប្បធម៌ ត្រូវអនុវត្តទៅតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត ដែលនៅជាធរមាន ។

## ជំពូកទី៦
## ការរៀបចំបង្កើតតំបន់ការពារបេតិកភណ្ឌវប្បធម៌

**មាត្រា៥៣៦** ._ ការបង្កើតតំបន់ការពារបេតិកភណ្ឌវប្បធម៌

ក្រសួង ស្ថាប័នទទួលបន្ទុកបេតិកភណ្ឌវប្បធម៌ ត្រូវរៀបចំបង្កើតឲ្យមានតំបន់ការពារបេតិកភណ្ឌវប្បធម៌ ដែលប្រមូលផ្ដុំទៅដោយ ប្រាសាទបុរាណ សំណង់ស្ថាបត្យកម្ម ផ្ទះសំបែង រចនាសម្ព័ន្ធភូមិដ្ឋាន ឬក្រុង ហេដ្ឋារចនាសម្ព័ន្ធឧស្សាហកម្ម ទីសក្ការៈបូជា ទីបញ្ចុះសព សំណល់វត្ថុបុរាណ ឬតំបន់ដទៃទៀត ដែលមានតម្លៃខាងបុរេប្រវត្តិសាស្ត្រ ប្រវត្តិសាស្ត្រ ស្ថាបត្យកម្ម បុរាណវិទ្យា ជាតិពន្ធុវិទ្យា នរវិទ្យា វិទ្យាសាស្ត្រ សិល្បៈ ឬសាសនា ។

**មាត្រា៥៣៧** ._ ការបែងចែកតំបន់ការពារបេតិកភណ្ឌវប្បធម៌

តំបន់ការពារបេតិកភណ្ឌវប្បធម៌ ត្រូវបែងចែកជាប្រភេទ ដូចខាងក្រោម ៖

១- រមណីយដ្ឋានវប្បធម៌ ។

២- តំបន់បុរាណស្ថាន ។

៣- តំបន់សក្ការៈសហាគម ។

៤- តំបន់បេតិកភណ្ឌទីក្រុង ។

តំបន់ការពារបេតិកភណ្ឌវប្បធម៌ ត្រូវកំណត់ដោយលិខិតបទដ្ឋានគតិយុត្តតាមសំណើរបស់ក្រសួងទទួលបន្ទុកបេតិកភណ្ឌវប្បធម៌ ។

**មាត្រា៥៣៨** ._ ការរៀបចំលក្ខណៈវិនិច្ឆ័យដើម្បីកំណត់ប្រភេទតំបន់ការពារបេតិកភណ្ឌវប្បធម៌

ការរៀបចំលក្ខណៈវិនិច្ឆ័យដើម្បីកំណត់ប្រភេទតំបន់ការពារបេតិកភណ្ឌវប្បធម៌ ត្រូវកំណត់ដោយលិខិតបទដ្ឋានគតិយុត្តរបស់ក្រសួង ស្ថាប័នទទួលបន្ទុកបេតិកភណ្ឌវប្បធម៌។

**មាត្រា៥៣៩** ._ ការស្នើសុំបង្កើតតំបន់ការពារបេតិកភណ្ឌវប្បធម៌

ការស្នើសុំបង្កើតតំបន់ការពារបេតិកភណ្ឌវប្បធម៌ ដូចមានចែងក្នុងមាត្រា៥៣៦ ត្រូវផ្អែកតាមគោលបំណងនៃការគ្រប់គ្រង លក្ខណៈវិនិច្ឆ័យ លទ្ធផលនៃការសិក្សាស្រាវជ្រាវ សិទ្ធិកាន់កាប់ដីធ្លី និងកត្តាពាក់ព័ន្ធដទៃទៀត ។

**មាត្រា៥៤០** ._ ឯកសារស្នើសុំបង្កើតតំបន់បេតិកភណ្ឌវប្បធម៌

ឯកសារស្នើសុំបង្កើតតំបន់បេតិកភណ្ឌវប្បធម៌ ត្រូវភ្ជាប់មកជាមួយនូវះ

១-ការអធិប្បាយអំពីសារៈសំខាន់ខាងបុរេប្រវត្តិសាស្ត្រ ប្រវត្តិសាស្ត្រ ស្ថាបត្យកម្ម បុរាណវិទ្យា ជាតិពន្ធុវិទ្យា វិទ្យាសាស្ត្រ សិល្បៈ ឬសាសនា និងភាពចាំបាច់ក្នុងការការពារនិងអភិរក្សតំបន់ដែលត្រូវស្នើសុំ ។

២-ការអធិប្បាយអំពីក្របខ័ណ្ឌច្បាប់ ឬលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការងារថែរក្សា ការពារ និងអភិរក្ស ។

៣-ផែនទីមានមាត្រដ្ឋានកំណត់ច្បាស់លាស់ ដែលបង្ហាញអំពីទីតាំងភូមិសាស្ត្រ ព្រំប្រទល់ ទំហំផ្ទៃដីនៃតំបន់ត្រូវស្នើសុំ ។

៤-របាយការណ៍អំពីលទ្ធផលនៃការពិគ្រោះយោបល់ជាមួយស្ថាប័ន ភាគីពាក់ព័ន្ធ និងតំណាងសហាគមន៍មូលដ្ឋាន ដែលមានទីតាំងនៅក្នុង ឬនៅក្បែរតំបន់ស្នើសុំ។

**មាត្រា៥៤១** ._ កិច្ចការពារតំបន់ការពារបេតិកភណ្ឌវប្បធម៌

តំបន់ការពារបេតិកភណ្ឌវប្បធម៌ ដែលត្រូវបានទទួលស្គាល់ ដូចមានចែងក្នុងមាត្រា៥៣៦ត្រូវទទួលបានកិច្ចការពារ ស្របតាមបទប្បញ្ញត្តិនៃក្រមនេះ និងលិខិតបទដ្ឋានគតិយុត្តដែលនៅជាធរមាន ។

## ជំពូកទី៧
## ការបង្កើតតំបន់បេតិកភណ្ឌទីក្រុង

**មាត្រា៥៤២**._ ការស្នើសុំបង្កើតតំបន់បេតិកភណ្ឌទីក្រុង

ក្រសួង ស្ថាប័នទទួលបន្ទុកបេតិកភណ្ឌវប្បធម៌ អាចលើកសំណើស្នើសុំទៅកាន់ក្រុមប្រឹក្សាជាន់ខ្ពស់ផ្នែកវប្បធម៌ជាតិ ដើម្បីបង្កើតតំបន់បេតិកភណ្ឌទីក្រុង ។

ការស្នើសុំបង្កើតតំបន់បេតិកភណ្ឌទីក្រុង ត្រូវផ្អែកតាមគោលបំណងនៃការគ្រប់គ្រង លក្ខណៈវិនិច្ឆ័យ និងលទ្ធផលនៃការសិក្សាស្រាវជ្រាវអំពីគុណតម្លៃនៃធនធានវប្បធម៌ ការរក្សាអត្តសញ្ញាណវប្បធម៌ ប្រពៃណី ទំនៀមទំលាប់ ការគោរពប្រណិប័តន៍ ការអភិរក្សស្នាដៃ និង/ឬគុណតម្លៃនៃការអភិវឌ្ឍទេសចរណ៍ ។

**មាត្រា៥៤៣**._ តំបន់បេតិកភណ្ឌទីក្រុង

តំបន់បេតិកភណ្ឌទីក្រុងសំដៅលើ បណ្តុំនៃសំណង់ស្ថាបត្យកម្មប្រវត្តិសាស្ត្រ និងហេដ្ឋារចនាសម្ព័ន្ធ រួមទាំងលំហបៃតង ដែលជាផ្នែកមួយ ឬទាំងស្រុងនៃទីប្រជុំជន ឬទីក្រុង ហើយដែលរក្សាបាននូវលក្ខណៈដើម និងបង្ហាញពីទេពកោសល្យ និងគំនិតច្នៃប្រឌិតក្នុងការរៀបចំតំបន់រស់នៅប្រកបដោយជាសុខភាព ។

**មាត្រា៥៤៤**._ ការពិភាក្សាអំពីសំណើសុំបង្កើតតំបន់បេតិកភណ្ឌទីក្រុង

ក្រសួង ស្ថាប័នទទួលបន្ទុកបេតិកភណ្ឌវប្បធម៌ ត្រូវជូនដំណឹងដល់ក្រសួង ស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធ និងធ្វើការពិភាក្សាអំពីសំណើសុំបង្កើតតំបន់បេតិកភណ្ឌទីក្រុង ។

ការបង្កើតតំបន់បេតិកភណ្ឌទីក្រុង ត្រូវកំណត់ដោយលិខិតបទដ្ឋានគតិយុត្ត តាមសំណើរបស់ក្រសួង ស្ថាប័នទទួលបន្ទុកបេតិកភណ្ឌវប្បធម៌ ។

**មាត្រា៥៤៥**._ ការរៀបចំផែនការតំបន់បេតិកភណ្ឌទីក្រុង

ក្រសួង ស្ថាប័នទទួលបន្ទុកបេតិកភណ្ឌវប្បធម៌ ត្រូវរៀបចំផែនការសម្រាប់តំបន់បេតិកភណ្ឌទីក្រុង និងចំណាត់ថ្នាក់នៃទីតាំងនោះ ស្របតាមបទប្បញ្ញត្តិនៃក្រមនេះ ។

**មាត្រា៥៤៦ ._** ការហាមឃាត់ចំពោះការកែប្រែ ឬការធ្វើឱ្យខូចខាតសោភ័ណភាពតំបន់បេតិកភណ្ឌបេតិភណ្ឌទីក្រុង

តំបន់ណាមួយ ឬតំបន់ទាំងមូលនៃទីប្រជុំជន ភូមិ ឬទីក្រុង ដែលត្រូវបានចាត់ថ្នាក់ជាតំបន់បេតិកភណ្ឌទីក្រុងមិនអាចកែប្រែ ផ្លាស់ប្តូររូបរាង ធ្វើឱ្យខូចខាតសោភ័ណភាព ឬទទួលរងនូវការបំផ្លិចបំផ្លាញដោយសកម្មភាពណាមួយឡើយ លុះត្រាតែមានលិខិតអនុញ្ញាតពីក្រសួង ស្ថាប័នទទួលបន្ទុកបេតិកភណ្ឌវប្បធម៌ ។

**មាត្រា៥៤៧ ._** ការហាមឃាត់ចំពោះការកែប្រែ ឬការធ្វើឱ្យខូចខាតសោភ័ណភាពចំពោះសំណង់នៃតំបន់បេតិកភណ្ឌទីក្រុង

សំណង់សាធារណៈ ឯកជន សាសនា ហេដ្ឋារចនាសម្ព័ន្ធនិងលំហបៃតងនៃតំបន់បេតិកភណ្ឌទីក្រុងមិនត្រូវបានកែប្រែរូបរាង ផ្លាស់ប្តូររចនាបទ ឬក៏ធ្វើឱ្យខូចសោភ័ណភាពត្រង់កន្លែងណាមួយឡើយ លុះត្រាតែមានច្បាប់អនុញ្ញាត ពីក្រសួង ស្ថាប័នទទួលបន្ទុកបេតិកភណ្ឌវប្បធម៌។

**មាត្រា៥៤៨ ._** ការស្នើសុំការអនុញ្ញាតដើម្បីជួសជុល កែប្រែរូបរាង និងកំទេចចោលសំណង់ក្នុងតំបន់បេតិកភណ្ឌទីក្រុង

ម្ចាស់កម្មសិទ្ធិនៃអចលនទ្រព្យ សំណង់ទូទៅ ឬលំនៅដ្ឋាន ដែលស្ថិតក្នុងតំបន់បេតិកភណ្ឌទីក្រុង ត្រូវសុំការអនុញ្ញាតមកក្រសួង ស្ថាប័នទទួលបន្ទុកបេតិកភណ្ឌវប្បធម៌ មុននឹងធ្វើការជួសជុល កែប្រែរូបរាង ឬកំទេចចោលសំណង់ទាំងនោះ។

**មាត្រា៥៤៩ ._** ការវាយតម្លៃបេតិកភណ្ឌវប្បធម៌

ក្រសួង ស្ថាប័នទទួលបន្ទុកបេតិកភណ្ឌវប្បធម៌ ត្រូវវាយតម្លៃបេតិកភណ្ឌវប្បធម៌ មុនសម្រេចឯកភាពឲ្យមានការសាងសង់ ជួសជុល ឬការកំទេចចោល ឬធ្វើការអភិវឌ្ឍឡើងវិញនៅក្នុងតំបន់បេតិកភណ្ឌទីក្រុងនោះ ។

## ជំពូកទី៨
## កិច្ចការពារបេតិកភណ្ឌវប្បធម៌ជាតិ
## ផ្នែកទោល
## ការប្រទះឃើញដោយចៃដន្យនូវសម្បត្តិវប្បធម៌

**មាត្រា៥៥០** ._ កាតព្វកិច្ចទូទៅចំពោះការរាយការណ៍

បុគ្គលគ្រប់រូប ដែលបានដឹង ឬប្រទះឃើញដោយចៃដន្យនូវ សំណាង់ប្រាសាទបាក់បែក គ្រឹះប្រាសាទ ស្លាកស្នាមដែលបញ្ជាក់អំពីទីតាំងបុរាណស្ថាន វត្ថុបុរាណ ឬតំបន់បេតិកភណ្ឌវប្បធម៌ ត្រូវមានកាតព្វកិច្ចរាយការណ៍ជាបន្ទាន់ជូនអាជ្ញាធរដែនដី និងក្រសួង ស្ថាប័នមានសមត្ថកិច្ច ។

**មាត្រា៥៥១** ._ កាតព្វកិច្ចរាយការណ៍អំពីការប្រទះឃើញដោយចៃដន្យក្នុងការធ្វើប្រតិបត្តការសាងសង់

រូបវន្តបុគ្គល ឬនីតិបុគ្គល ដែលប្រទះឃើញដោយចៃដន្យនូវវត្ថុបុរាណ ឬសម្បត្តិវប្បធម៌ ឬតំបន់បេតិកភណ្ឌវប្បធម៌ នៅក្នុងកំឡុងពេលប្រតិបត្តការសាងសង់ ឬជីកគាស់កកាយស្ថារហេដ្ឋារចនាសម្ព័ន្ធផ្សេងៗ ដូចមានចែងក្នុងមាត្រា៥០៥នៃក្រមនេះ ត្រូវបញ្ឈប់ការងារសាងសង់ជាបណ្តោះអាសន្ន និងត្រូវរាយការណ៍ទៅកាន់អាជ្ញាធរមូលដ្ឋាន។

**មាត្រា៥៥២** ._ ការកំណត់ជាបឋមនៃសម្បត្តិវប្បធម៌ ឬវត្ថុបុរាណ

ក្រសួង ស្ថាប័នទទួលបន្ទុកបេតិកភណ្ឌវប្បធម៌ ត្រូវធ្វើការកំណត់ជាបឋមអំពីសារៈសំខាន់នៃសម្បត្តិវប្បធម៌ ឬវត្ថុបុរាណ នៅក្នុងរយៈពេល១៤ (ដប់បួន) ថ្ងៃ ក្រោយពេលទទួលបានការជូនដំណឹង ឬរបាយការណ៍ ។

រយៈពេលនេះ អាចពន្យាបានតែម្តងប៉ុណ្ណោះ ដោយមានរយៈពេល១៤(ដប់បួន)ថ្ងៃបន្ថែម ។ ក្រសួង ស្ថាប័នទទួលបន្ទុកបេតិកភណ្ឌវប្បធម៌ ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរដល់រូបវន្តបុគ្គល ឬនីតិបុគ្គល អំពីការពន្យាពេលនេះ ។

**មាត្រា៥៥៣** ._ សេចក្តីសម្រេចផ្អាកជាបណ្តោះអាសន្ន

ក្រសួង ស្ថាប័នទទួលបន្ទុកបេតិកភណ្ឌវប្បធម៌ ត្រូវចេញសេចក្តីសម្រេចផ្អាកជាបណ្តោះអាសន្នចំពោះទីតាំងទាំងឡាយណាដែលមានការប្រទះឃើញសម្បត្តិវប្បធម៌ ឬវត្ថុបុរាណ ។ សេចក្តី

សម្រេចផ្អាកបណ្តោះអាសន្ននេះ មានសុពលភាពរយៈពេល៣០ (សាមសិប) ថ្ងៃ បន្ទាប់ពីបានធ្វើការកំណត់ជាបឋម ដូចមានចែងក្នុងមាត្រា៥៥២នៃក្រមនេះ ។

ក្នុងករណីក្រសួង ស្ថាប័នទទួលបន្ទុកបេតិកភណ្ឌវប្បធម៌ពុំបានចេញសេចក្តីសម្រេចថ្មី ក្រោយរយៈពេល ៣០ (សាមសិប) ថ្ងៃបន្តទៀតនោះទេ រូបវន្តបុគ្គល ឬនីតិបុគ្គល អាចបន្តសកម្មភាពការងាររបស់ខ្លួនបានជាប្រក្រតី ។

## ជំពូកទី៩
## ការធ្វើកំណាយ

**មាត្រា៥៥៤** ._ ការហាមឃាត់ចំពោះការជីករុករក ឬស្រាវជ្រាវស្វែងរកសម្បត្តិវប្បធម៌

គ្មានជនណាម្នាក់មានសិទ្ធិជីករុករក ឬស្រាវជ្រាវ នៅលើដីកម្មសិទ្ធិរបស់ខ្លួន ឬរបស់អ្នកដទៃ ឬដីសាធារណៈ ក្នុងបំណងស្វែងរកវត្ថុផ្សេងៗ ឬស្លាកស្នាមភស្តុតាង ដែលមានសារៈសំខាន់ខាងបុរេប្រវត្តិសាស្ត្រ ប្រវត្តិសាស្ត្រ បុរាណវិទ្យា ជាតិពន្ធុវិទ្យា សិល្បៈ ឬវិទ្យាសាស្ត្រផ្សេងៗ ដោយគ្មានការអនុញ្ញាតជាមុនពីក្រសួងទទួលបន្ទុកបេតិកភណ្ឌវប្បធម៌ឡើយ។

**មាត្រា៥៥៥** ._ ការជីករុករក ឬស្រាវជ្រាវរបស់ស្ថាប័នវិទ្យាសាស្ត្រ ឬអ្នកសិក្សាស្រាវជ្រាវ

ស្ថាប័នវិទ្យាសាស្ត្រ ឬអ្នកសិក្សាស្រាវជ្រាវ ដែលមានបំណងជីករុករក ឬស្រាវជ្រាវនៅក្នុងដី ឬក្នុងទឹក ក្នុងបំណងសិក្សាស្រាវជ្រាវផ្នែកបុរេប្រវត្តិសាស្ត្រ ប្រវត្តិសាស្ត្រ បុរាណវិទ្យា ជាតិពន្ធុវិទ្យា ឬសិល្បៈ ត្រូវដាក់សំណើសុំដើម្បីទទួលការអនុញ្ញាតទៅក្រសួង ស្ថាប័នទទួលបន្ទុកបេតិកភណ្ឌវប្បធម៌ ។

**មាត្រា៥៥៦** ._ ការចូលរួមជីករុករក ឬស្រាវជ្រាវរបស់មន្ត្រីជំនាញជាមួយស្ថាប័នវិទ្យាសាស្ត្រ ឬអ្នកសិក្សាស្រាវជ្រាវ

រាល់ការជីករុករក ឬស្រាវជ្រាវ ដោយស្ថាប័នវិទ្យាសាស្ត្រ ឬអ្នកសិក្សាស្រាវជ្រាវ ដែលទទួលបានច្បាប់អនុញ្ញាត ដូចមានចែងក្នុងមាត្រា៥៥៥ ត្រូវមានការចូលរួមពីមន្ត្រីជំនាញនៃ ក្រសួង ស្ថាប័នទទួលបន្ទុកបេតិកភណ្ឌវប្បធម៌ ។

**មាត្រា៥៥៧** ._ ការចាត់ទុកសម្បត្តិវប្បធម៌ជាសម្បត្តិរដ្ឋ

សម្បត្តិវប្បធម៌ ដែលបានរកឃើញក្នុងពេលជីករុករក ឬស្រាវជ្រាវ ត្រូវចាត់ទុកជាសម្បត្តិរដ្ឋ។

**មាត្រា៥៥៨** ._ ការបញ្ឈប់ជាបណ្តោះអាសន្ន ឬដកហូតលិខិតអនុញ្ញាតចំពោះការមិនគោរព
កាតព្វកិច្ច

ក្រសួង ស្ថាប័នទទួលបន្ទុកបេតិកភណ្ឌវប្បធម៌មានសិទ្ធិបញ្ឈប់ជាបណ្តោះអាសន្ន ឬដកហូតលិខិតអនុញ្ញាត ក្នុងករណីពិនិត្យឃើញថា ស្ថាប័នវិទ្យាសាស្ត្រ ឬអ្នកសិក្សាស្រាវជ្រាវនោះមិនគោរពតាមកាតព្វកិច្ច ដូចមានចែងនៅក្នុងច្បាប់ និងបទប្បញ្ញត្តិពាក់ព័ន្ធស្តីពីការជីករុករកវត្ថុបុរាណ ដែលនៅជាធរមាន។

**មាត្រា៥៥៩** ._ ការស្នើសុំលិខិតអនុញ្ញាតដើម្បីសិក្សាស្រាវជ្រាវ

ស្ថាប័នវិទ្យាសាស្ត្រ ឬអ្នកសិក្សាស្រាវជ្រាវ ដែលមានបំណងស្រាវជ្រាវ ឬជីករុករកនៅក្នុងដី ឬក្នុងទឹក ក្នុងបំណងសិក្សាស្រាវជ្រាវផ្នែកសត្តវិទ្យា បាសាណីភូតវិទ្យា ភូតគាមវិទ្យា ជីវៈវិទ្យា ឬវិទ្យាសាស្ត្រពាក់ព័ន្ធដទៃទៀត ត្រូវដាក់សំណើសុំ ដើម្បីទទួលការអនុញ្ញាតទៅក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន ។

**មាត្រា៥៦០** ._ ការចូលរួមស្រាវជ្រាវពីមន្ត្រីជំនាញជាមួយស្ថាប័នវិទ្យាសាស្ត្រ ឬអ្នកសិក្សាស្រាវជ្រាវ

ការស្រាវជ្រាវ ឬជីករុករកដោយស្ថាប័នវិទ្យាសាស្ត្រ ឬអ្នកសិក្សាស្រាវជ្រាវ ដែលទទួលបានច្បាប់អនុញ្ញាត ដូចមានចែងក្នុងមាត្រា៥៥៩ ត្រូវមានការចូលរួមពីមន្ត្រីជំនាញ របស់ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន ។

**មាត្រា៥៦១** ._ បន្ទុកនៃការចំណាយលើការធ្វើកំណាយ

ការចំណាយលើការធ្វើកំណាយ ជាបន្ទុករបស់អ្នកស្នើសុំ។

## ជំពូកទី១០
## កំណាយបន្ទារ

**មាត្រា៥៦២** ._ ការស្នើសុំក្រុមឯកទេសបុរាណវិទ្យាពីក្រសួង ស្ថាប័នមានសមត្ថកិច្ច

នីតិបុគ្គល ឬរូបវន្តបុគ្គលដែលមានបំណងជីកកកាយ ឈូសឆាយ ពង្រាប ចាក់ដីបំពេញ ឬសាងសង់សំណង់ផ្សេងៗ ក្នុងតំបន់ដែលក្រសួង ស្ថាប័នទទួលបន្ទុកបេតិកភណ្ឌវប្បធម៌មិនបានប្រកាសថាជាស្ថានីយបុរាណ ឬជាកន្លែងដែលសង្ស័យថាមានវត្ថុបុរាណ ត្រូវស្នើសុំក្រុមឯកទេសបុរាណវិទ្យា ពីក្រសួង ស្ថាប័នទទួលបន្ទុកបេតិកភណ្ឌវប្បធម៌ ដើម្បីពិនិត្យ ស្រាវជ្រាវ និងរិះរកវិធីបញ្ចៀសផលប៉ះពាល់ជាអវិជ្ជមានដល់ស្ថានីយបុរាណ ឬជាកន្លែងដែលសង្ស័យថាជាស្ថានីយបុរាណ ក្នុងករណីមិនអាចបញ្ចៀសបានទេ ត្រូវធ្វើកំណាយបង្ការ ។

**មាត្រា៥៦៣** ._ ការហាមឃាត់ដាច់ខាតចំពោះការធ្វើឱ្យខូចខាតដល់សម្បត្តិវប្បធម៌

ត្រូវហាមឃាត់ដាច់ខាតចំពោះសកម្មភាពដែលបង្កឱ្យមានការខូចខាត ការបំផ្លិចបំផ្លាញ ឬធ្វើឲ្យគ្រោះថ្នាក់ដល់សម្បត្តិវប្បធម៌ ដូចមានចែងក្នុងមាត្រា៥០៥ លើកលែងតែមានការអនុញ្ញាត ស្របតាមក្រមនេះ និងច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាន ។

**មាត្រា៥៦៤** ._ ការហាមឃាត់ចំពោះការផ្តល់លិខិតអនុញ្ញាតសាងសង់

ក្រសួង ស្ថាប័នមានសមត្ថកិច្ចមិនត្រូវផ្តល់ការអនុញ្ញាត លើគម្រោងសាងសង់ ដូចមានចែងក្នុងមាត្រា៥៦២ លុះត្រាតែម្ចាស់គម្រោងអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ ឬសាងសង់នោះបានអនុវត្តការធ្វើកំណាយបង្ការជាមុនសិន ។

**មាត្រា៥៦៥** ._ កិច្ចសហការក្នុងការធ្វើកំណាយបង្ការ

កំណាយបង្ការត្រូវអនុវត្តដោយក្រសួង ស្ថាប័នទទួលបន្ទុកបេតិកភណ្ឌវប្បធម៌ ឬសហការជាមួយស្ថាប័នស្រាវជ្រាវវិទ្យាសាស្ត្របុរាណវិទ្យា ។

**មាត្រា៥៦៦** ._ ការស្នើសុំលិខិតអនុញ្ញាតសាងសង់ហេដ្ឋារចនាសម្ព័ន្ធ ឬសំណង់ផ្សេងៗ

លិខិតសុំការអនុញ្ញាតសាងសង់ហេដ្ឋារចនាសម្ព័ន្ធ ឬសំណង់ផ្សេងៗ ត្រូវមានភ្ជាប់ជាមួយនូវរបាយការណ៍វាយតម្លៃ របស់ក្រសួង ស្ថាប័នទទួលបន្ទុកបេតិកភណ្ឌវប្បធម៌។

**មាត្រា៥៦៧** ._ បន្ទុកចំណាយលើការងារធ្វើកំណាយបង្ការ

ម្ចាស់គម្រោងអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធ ឬគម្រោងសាងសង់ផ្សេងៗ ដែលធ្វើប្រតិបត្តិការនៅក្នុងតំបន់ដែលក្រសួងវប្បធម៌ បានប្រកាសថា ជាស្ថានីយបុរាណ ឬជាកន្លែងដែលសង្ស័យថាមានវត្ថុបុរាណ ត្រូវទទួលបន្ទុកលើការចំណាយសម្រាប់ការងារធ្វើកំណាយបង្ការ ។

**មាត្រា៥៦៨** ._ ការហាមឃាត់ចំពោះការយកចេញ ឬបំផ្លាញបេតិកភណ្ឌ

ត្រូវហាមឃាត់ចំពោះការយកចេញ ឬបំផ្លិចបំផ្លាញនូវសម្បត្តិវប្បធម៌ ឬវត្ថុបុរាណណាមួយ ដែលមាននៅក្នុងទីតាំងដីកម្មសិទ្ធិឯកជន លើកលែងតែមានការអនុញ្ញាតពីក្រសួងទទួលបន្ទុកបេតិកភណ្ឌវប្បធម៌ ។

**មាត្រា៥៦៩** ._ កាតព្វកិច្ចធ្វើកំណត់ត្រា

រូបវន្តបុគ្គល នីតិបុគ្គលត្រូវមានកាតព្វកិច្ច ក្នុងការធ្វើកំណត់ត្រា និងថតរូបសម្បត្តិវប្បធម៌ ឬ វត្ថុបុរាណ រួចបញ្ជូនទៅអាជ្ញាធរ ឬស្ថាប័នមានសមត្ថកិច្ច។

**មាត្រា៥៧០** ._ ការហាមឃាត់ពាក់ព័ន្ធទៅនឹងការមិនបានអនុលោមតាម

ការខកខានមិនបានរាយការណ៍អំពីការប្រទះឃើញដោយចៃដន្យ ឬការបំផ្លិចបំផ្លាញសម្បត្តិវប្បធម៌ ឬ វត្ថុបុរាណណាមួយ មុនពេលធ្វើការកំណត់អំពីតម្លៃបេតិកភណ្ឌនោះ ត្រូវទទួលរងនូវការលុបចោលលិខិតអនុញ្ញាត ។

## ជំពូកទី១១
## កិច្ចការពារបេតិកភណ្ឌវប្បធម៌ក្រោមទឹក

**មាត្រា៥៧១** ._ បេតិកភណ្ឌវប្បធម៌ក្រោមទឹក

បេតិកភណ្ឌវប្បធម៌ក្រោមទឹក សំដៅលើសម្បត្តិវប្បធម៌ ដូចមានចែងក្នុងមាត្រា៥០៤ ដែលលិចចូលទៅក្នុងទឹកដោយផ្នែក ឬទាំងស្រុង មួយរយៈកាល ឬជានិរន្តរ៍ អស់រយៈពេលយ៉ាងហោចណាស់ស្ថិតក្នុងបុរេប្រវត្តិសាស្ត្រ សម័យមុនអង្គរ សម័យអង្គរ សម័យក្រោយអង្គរ សម័យអាណាព្យាបាលបារាំង និងសម័យទំនើប រួមមាន ៖

១- ទីតាំង រចនាសម្ព័ន្ធ អគារ វត្ថុបុរាណ ឬសំណល់អដ្ឋិធាតុរបស់មនុស្ស និងសំណល់សត្វ ។

២- សំពៅ ទូក នាវា យន្តហោះ យានយន្តដទៃទៀត ឬបំណែករបស់វា និងវត្ថុផ្សេងទៀត ។

៣- វត្ថុនានាដែលមានតម្លៃផ្នែកបុរេប្រវត្តិសាស្ត្រ ប្រវត្តិសាស្ត្រ ឬសិល្បៈ។

**មាត្រា៥៧២** ._ ការកំណត់ទីតាំងសម្បត្តិបេតិកភណ្ឌក្រោមទឹក

ក្រសួង ស្ថាប័នទទួលបន្ទុកបេតិកភណ្ឌវប្បធម៌ ត្រូវកំណត់ទីតាំងសម្បត្តិវប្បធម៌ក្រោមទឹកទាំងនោះ ទៅក្នុងបញ្ជីបេតិកភណ្ឌវប្បធម៌ជាតិ ។

**មាត្រា៥៧៣** ._ កាតព្វកិច្ចរាយការណ៍

រូបវន្តបុគ្គល និងនីតិបុគ្គល ត្រូវមានកាតព្វកិច្ចរាយការណ៍ជូនក្រសួង ស្ថាប័នទទួលបន្ទុកបេតិកភណ្ឌវប្បធម៌ អំពីវត្ថុក្រោមទឹកណាមួយ ដែលកំណត់អត្តសញ្ញាណជាសម្បត្តិវប្បធម៌ ដែលត្រូវបានប្រទះឃើញ ដើម្បីធ្វើការកំណត់ដាក់បញ្ចូលទៅក្នុងបញ្ជីបេតិកភណ្ឌវប្បធម៌ជាតិ ។

**មាត្រា៥៧៤** ._ ការហាមឃាត់ចំពោះការធ្វើឲ្យខូចខាត ការស្រង់ ឬ ការរំខាន

រាល់សកម្មភាពដែលបង្កការខូចខាត ការបំផ្លិចបំផ្លាញ ការស្រង់ ឬការរំខាន ចំពោះបេតិកភណ្ឌវប្បធម៌ក្រោមទឹក ត្រូវហាមឃាត់ ។

**មាត្រា៥៧៥** ._ ការការពារ ការវាយតម្លៃផ្នែកវិទ្យាសាស្ត្រ និងការរុករកបេតិកភណ្ឌវប្បធម៌ក្រោមទឹក

ក្រសួង ស្ថាប័នទទួលបន្ទុកបេតិកភណ្ឌវប្បធម៌ ត្រូវរៀបចំលិខិតបទដ្ឋានគតិយុត្ត ដើម្បីអនុញ្ញាតឲ្យមានការការពារ ការវាយតម្លៃផ្នែកវិទ្យាសាស្ត្រ និងការរុករកបេតិកភណ្ឌវប្បធម៌ក្រោមទឹក ។

**មាត្រា៥៧៦** ._ ការចេញលិខិតអនុញ្ញាតចំពោះសកម្មភាពដែលបង្កផលប៉ះពាល់ចំពោះបេតិកភណ្ឌវប្បធម៌ក្រោមទឹក

ក្រសួង ស្ថាប័នទទួលបន្ទុកបេតិកភណ្ឌវប្បធម៌ អាចចេញលិខិតអនុញ្ញាត ចំពោះសកម្មភាពដែលបង្កផលប៉ះពាល់ចំពោះបេតិកភណ្ឌវប្បធម៌ក្រោមទឹក ស្របតាមក្រមនេះ និងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន ។

## ផ្នែកទី៣
## លិខិតអនុញ្ញាតសម្រាប់គម្រោងអភិវឌ្ឍដែលបង្កផលប៉ះពាល់ដល់បេតិកភណ្ឌវប្បធម៌

**មាត្រា៥៧៧** ._ គម្រោង និងសកម្មភាពដែលតម្រូវឲ្យមានលិខិតអនុញ្ញាត

រាល់គម្រោង ឬសកម្មភាពទាំងឡាយណា ដែលអាចបង្កផលប៉ះពាល់ដល់បេតិកភណ្ឌវប្បធម៌ ដែលបានចុះក្នុងបញ្ជី ឬមិនទាន់បានចុះនៅក្នុងបញ្ជីបេតិកភណ្ឌវប្បធម៌ជាតិ និងទីតាំងដែលសង្ស័យថាមានបេតិកភណ្ឌវប្បធម៌ ត្រូវទទួលលិខិតអនុញ្ញាតជាមុនសិនពីក្រសួង ស្ថាប័នទទួលបន្ទុកបេតិកភណ្ឌវប្បធម៌ មុននឹងចាប់ផ្តើមអនុវត្តការងាររបស់ខ្លួន ។

**មាត្រា៥៧៨** ._ ការហាមឃាត់ចំពោះការធ្វើឲ្យខូចខាត ឬការបំផ្លិចបំផ្លាញ

ត្រូវហាមឃាត់ចំពោះសកម្មភាពដែលបង្កឱ្យមានការខូចខាត ឬការបំផ្លិចបំផ្លាញសម្បត្តិវប្បធម៌ ឬវត្ថុបុរាណ ដែលមានចុះនៅក្នុងបញ្ជីបេតិកភណ្ឌវប្បធម៌ជាតិ លើកលែងតែមានការអនុញ្ញាត ពីក្រសួង ស្ថាប័នទទួលបន្ទុកបេតិកភណ្ឌវប្បធម៌ ។

## ជំពូកទី១២
## ការដោះស្រាយវិវាទ និងបទបញ្ជាបន្ទាន់

**មាត្រា៥៧៩** ._ នីតិវិធីដោះស្រាយវិវាទ

នៅក្នុងករណីមានវិវាទកើតឡើង គូភាគីត្រូវអនុវត្តតាមនីតិវិធី ដូចមានចែងនៅក្នុងគន្ថីទី៩ នៃក្រមនេះ ។

**មាត្រា៥៨០** ._ ការធ្វើជាតំណាងក្នុងការដោះស្រាយវិវាទ

ក្រសួង ស្ថាប័នទទួលបន្ទុកបេតិកភណ្ឌវប្បធម៌ ត្រូវធ្វើជាតំណាងនៅក្នុងនីតិវិធីដោះស្រាយវិវាទ ដែលមានផលប៉ះពាល់លើតម្លៃបេតិកភណ្ឌវប្បធម៌ ។

**មាត្រា៥៨១** ._ ការចេញបទបញ្ជាបន្ទាន់ក្នុងការផ្អាកសកម្មភាពគំរាមកំហែង ឬគ្រោះថ្នាក់ដល់វត្ថុបេតិកភណ្ឌ

ក្រសួង ស្ថាប័នទទួលបន្ទុកបេតិកភណ្ឌវប្បធម៌ អាចចេញបទបញ្ជាបន្ទាន់ដើម្បីផ្អាកការងារ ការសាងសង់ ឬការឈូសឆាយ ក្នុងករណីដែលទីតាំង ឬសម្បត្តិវប្បធម៌កំពុងទទួលរងគ្រោះថ្នាក់ ឬបំផ្លិចបំផ្លាញ ទោះបីជាទីតាំងឬសម្បត្តិវប្បធម៌នោះ បានឬមិនទាន់បានចុះនៅក្នុងបញ្ជីបេតិកភណ្ឌជាតិក៏ដោយ ។

អំឡុងពេលការផ្អាកសកម្មភាពការងារនេះ ត្រូវតាមអនុវត្តតាមបទប្បញ្ញត្តិដូចមានចែងក្នុងមាត្រា៥៥២ នៃក្រមនេះ ។

## ជំពូកទី១៣
## ការលើកកម្ពស់ និងការការពារបេតិកភណ្ឌវប្បធម៌អរូបិយ

**មាត្រា៥៨២** ._ កិច្ចការពារ និងលើកកម្ពស់បេតិកភណ្ឌវប្បធម៌អរូបី

បេតិកភណ្ឌវប្បធម៌អរូបី ដូចមានចែងក្នុងមាត្រា៥០៥ ត្រូវទទួលបាននូវកិច្ចការពារ និងលើកកម្ពស់ ស្របតាមបទប្បញ្ញត្តិដូចមានចែងក្នុងក្រមនេះ និងច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត ដែលនៅជាធរមាន ។

**មាត្រា៥៨៣** ._ វិធានការការពារ និងលើកកម្ពស់បេតិកភណ្ឌអរូបី

ក្រសួង ស្ថាប័នទទួលបន្ទុកបេតិកភណ្ឌវប្បធម៌ ត្រូវរៀបចំលិខិតបទដ្ឋានគតិយុត្ត ដើម្បីការពារ និងលើកកម្ពស់បេតិកភណ្ឌវប្បធម៌អរូបី ។

**មាត្រា៥៨៤** ._ ការចូលរួមផ្តល់យោបល់ជាសាធារណៈ

ក្រសួង ស្ថាប័នទទួលបន្ទុកបេតិកភណ្ឌវប្បធម៌ ត្រូវដាក់លិខិតបទដ្ឋានគតិយុត្ត ដូចមានចែងក្នុងមាត្រា៥៨២ខាងលើនេះ ឲ្យសាធារណជនអាចស្វែងរកបាន ដើម្បីផ្តល់យោបល់ មុនពេលមានការឯកភាពពីក្រុមប្រឹក្សាជាន់ខ្ពស់ផ្នែកវប្បធម៌ជាតិ ។

**មាត្រា៥៨៥** ._ ការលើកតម្លៃបេតិកភណ្ឌវប្បធម៌អរូបី

ក្រសួង ស្ថាប័នទទួលបន្ទុកបេតិកភណ្ឌវប្បធម៌ត្រូវជម្រុញ និងលើកតម្លៃបេតិកភណ្ឌវប្បធម៌អរូបី តាមរយៈការអភិរក្សទំនៀមទំលាប់ កិច្ចប្រតិបត្តិជំនឿផ្សេងៗ ដែលមាននៅទីតាំងស្រាប់ ការ

បង្កើតព្រឹត្តិការណ៍សំខាន់ៗដូចជា មហោស្រព ការសម្តែង ឬការតាំងពិព័ណ៌ជាអាទិ៍ ដែលមានលក្ខណៈថ្នាក់ជាតិ ថ្នាក់តំបន់ និងអន្តរជាតិ ។

**មាត្រា៥៨៦** ._ ការបណ្តុះបណ្តាលបន្តនូវទម្រង់វប្បធម៌អរូបី

ក្រសួង ស្ថាប័នទទួលបន្ទុកបេតិកភណ្ឌវប្បធម៌ត្រូវលើកទឹកចិត្តឱ្យមានការបណ្តុះបណ្តាល បន្តនូវទម្រង់វប្បធម៌អរូបីដែលជិតបាត់បង់ និងត្រូវបានចុះក្នុងបញ្ជីបេតិកភណ្ឌវប្បធម៌ជាតិ និងបញ្ជីបេតិកភណ្ឌវប្បធម៌អរូបីរបស់មនុស្សជាតិ ។

**មាត្រា៥៨៧** ._ ការឧបត្ថម្ភដល់ការសិក្សាស្រាវជ្រាវ និងបោះពុម្ពផ្សព្វផ្សាយទម្រង់វប្បធម៌អរូបី

ក្រសួង ស្ថាប័នទទួលបន្ទុកបេតិកភណ្ឌវប្បធម៌ត្រូវជម្រុញឱ្យមាន និងឧបត្ថម្ភដល់ការសិក្សាស្រាវជ្រាវ និងបោះពុម្ពផ្សព្វផ្សាយនូវទម្រង់វប្បធម៌អរូបី ដែលបានបាត់បង់ ។

## ជំពូកទី១៤
## ការអប់រំ និងការយល់ដឹង

**មាត្រា៥៨៨** ._ ការអប់រំ និងការយល់ដឹងជាសាធារណៈ

ក្រសួង ស្ថាប័នទទួលបន្ទុកបេតិកភណ្ឌវប្បធម៌ ដោយសហការជាមួយក្រសួង ស្ថាប័នមានសមត្ថកិច្ច អង្គការមិនមែនរដ្ឋាភិបាល និងវិស័យឯកជន ត្រូវរៀបចំកម្មវិធីអប់រំ និងការយល់ដឹងជាសាធារណៈ សម្រាប់ការអភិរក្ស ការអភិវឌ្ឍបេតិកភណ្ឌវប្បធម៌រូបី និងអរូបី ។

**មាត្រា៥៨៩** ._ ថ្លៃសេវា និងបន្ទុកផ្សេងៗ

ផែនការគ្រប់គ្រងតំបន់បេតិកភណ្ឌវប្បធម៌ អាចដាក់បញ្ចូលនូវបទប្បញ្ញត្តិដែលចែងអំពីការបង់កម្រៃសេវា និងបន្ទុកផ្សេងៗ ដែលត្រូវយកមកប្រើប្រាស់សម្រាប់ការលើកកម្ពស់ និងកិច្ចការពារបេតិកភណ្ឌវប្បធម៌ ។

**មាត្រា៥៩០** ._ ការរៀបចំក្របខណ្ឌច្បាប់គ្រប់គ្រង និងការផ្តល់អាជ្ញាប័ណ្ណ

ក្រសួង ស្ថាប័នទទួលបន្ទុកបេតិកភណ្ឌវប្បធម៌ ត្រូវរៀបចំច្បាប់ និងលិខិតបទដ្ឋានគតិយុត្តស្តីពីការផ្តល់អាជ្ញាប័ណ្ណ និងការគ្រប់គ្រងសារមន្ទីរ និង/ឬ ស្ថាប័ន ឬអង្គការវប្បធម៌ ស្របតាមបទដ្ឋានជាតិ និងអន្តរជាតិ ។

## ជំពូកទី១៥
## បទប្បញ្ញត្តិប្រឆាំងនឹងការជួញដូរសម្បត្តិវប្បធម៌

**មាត្រា៥៩១** ._ ការហាមឃាត់ចំពោះការនាំចេញសម្បត្តិវប្បធម៌

ត្រូវបានហាមឃាត់ដាច់ខាតនូវការនាំចេញសម្បត្តិវប្បធម៌ ដូចមានចែងក្នុងមាត្រា៥០៥ លើកលែងតែមានការអនុញ្ញាតពីក្រសួង ស្ថាប័នទទួលបន្ទុកបេតិកភណ្ឌវប្បធម៌ ។

បែបបទ និងនីតិវិធីនៃការអនុញ្ញាតនាំចេញសម្បត្តិវប្បធម៌ ត្រូវអនុវត្តតាមច្បាប់ និងបទប្បញ្ញត្តិដែលនៅជាធរមាន។

**មាត្រា៥៩២** ._ កិច្ចសហការ និងការចាត់វិធានការប្រឆាំងការជួញដូរ និងការធ្វើចរាចរសម្បត្តិវប្បធម៌

ក្រសួង ស្ថាប័នទទួលបន្ទុកបេតិកភណ្ឌវប្បធម៌ ដោយសហការជាមួយក្រសួង ស្ថាប័នមានសមត្ថកិច្ច ត្រូវចាត់វិធានការប្រឆាំងការជួញដូរ និងការធ្វើចរាចរសម្បត្តិវប្បធម៌។

**មាត្រា៥៩៣** ._ កិច្ចសហការអន្តរជាតិ

ក្រសួង ស្ថាប័នទទួលបន្ទុកបេតិកភណ្ឌវប្បធម៌ ដោយសហការជាមួយក្រសួង ស្ថាប័នមានសមត្ថកិច្ច អង្គការមិនមែនរដ្ឋាភិបាល និងអង្គការប្រឆាំងការជួញដូរវត្ថុបុរាណ ត្រូវធ្វើការសិក្សាស្រាវជ្រាវ និងបោះពុម្ពផ្សព្វផ្សាយនូវសម្បត្តិវប្បធម៌ ដែលបាននាំចេញដោយខុសច្បាប់។

**មាត្រា៥៩៤** ._ វិធានសម្រាប់ការនាំយកមកវិញ

ក្រសួង ស្ថាប័នទទួលបន្ទុកបេតិកភណ្ឌវប្បធម៌ ដោយសហការជាមួយក្រសួង ស្ថាប័នមានសមត្ថកិច្ច អង្គការអន្តរជាតិ និងអង្គការមិនមែនរដ្ឋាភិបាល ត្រូវរៀបចំលិខិតបទដ្ឋានគតិយុត្តស្តីពីការនាំមកវិញនូវសម្បត្តិវប្បធម៌ ដែលត្រូវបានយកចេញពីព្រះរាជាណាចក្រកម្ពុជាដោយខុសច្បាប់ ។

**មាត្រា៥៩៥** ._ ការចរចា ឬប្តឹងទាមទារឱ្យមានការបញ្ជូនត្រឡប់មកវិញនូវសម្បត្តិវប្បធម៌

ក្រសួង ស្ថាប័នទទួលបន្ទុកបេតិកភណ្ឌវប្បធម៌ ត្រូវចាត់វិធានការ និងនីតិវិធីក្នុងការចរចាឬប្តឹងទាមទារឱ្យមានការបញ្ជូនត្រឡប់មកវិញនូវសម្បត្តិវប្បធម៌ ដែលត្រូវបាននាំចេញដោយខុសច្បាប់ស្របតាមច្បាប់ជាតិ និងអន្តរជាតិ ។

## គន្ថីទី៦
## ការគ្រប់គ្រងសំណល់ និងការបំពុលបរិស្ថាន
## មាតិកាទី១
## កាតព្វកិច្ចទូទៅចំពោះការត្រួតពិនិត្យការបំពុលបរិស្ថាន
## ជំពូកទី១
## ការហាមឃាត់ការបំពុលបរិស្ថាន

**មាត្រា៥៩៦** ._ កាតព្វកិច្ចទូទៅចំពោះការបំពុលខ្យល់ ទឹក និងដី

បុគ្គលគ្រប់រូបមិនត្រូវធ្វើសកម្មភាពណាមួយ ដែលនាំឱ្យមានការបំពុលខ្យល់ ទឹក និងដីឡើយ។

**មាត្រា៥៩៧** ._ ការហាមឃាត់ចំពោះសំណល់

បុគ្គលគ្រប់រូប មិនត្រូវផលិត វេចខ្ចប់ នាំចូល នាំចេញ ដឹកជញ្ជូន ចែកចាយ ទិញ លក់ កាន់កាប់ ប្រើប្រាស់ គ្រប់គ្រង ស្តុកទុក ធ្វើប្រព្រឹត្តកម្ម ចម្រាញ់ កែច្នៃឡើងវិញ បញ្ចេញចោល ឬ បោះបង់ចោលសំណល់ណាមួយឡើយ លើកលែងតែទទួលបានការអនុញ្ញាត ស្របតាមបទប្បញ្ញត្តិនៃក្រមនេះច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ។

**មាត្រា៥៩៨** ._ ការហាមឃាត់ការបំពុលដោយសំឡេង ឬរំញ័រ

បុគ្គលគ្រប់រូប មិនត្រូវធ្វើសកម្មភាពណាមួយ ដែលបង្កឱ្យមានការបំពុលដោយសំឡេង ឬរំញ័រដែលលើសពីស្តង់ដារបរិស្ថានដែលបានអនុញ្ញាត ស្របតាមបទប្បញ្ញត្តិនៃក្រមនេះ និងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ ។

## ជំពូកទី ២
## លិខិតអនុញ្ញាត

**មាត្រា៥៩៩ .**_ កាតព្វកិច្ចអនុវត្តតាមលក្ខខណ្ឌនៃលិខិតអនុញ្ញាត

បុគ្គលគ្រប់រូបដែលទទួលបានលិខិតអនុញ្ញាតពីក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន ត្រូវគោរព តាមលក្ខខណ្ឌនានានៃលិខិតអនុញ្ញាតនោះ ។

**មាត្រា៦០០ .**_ ការអនុវត្តស្តង់ដារបរិស្ថាន

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន ត្រូវប្រើប្រាស់ស្តង់ដារបរិស្ថានដើម្បីកំណត់លក្ខខណ្ឌនៃ លិខិតអនុញ្ញាត ស្របតាមបទប្បញ្ញត្តិនៃក្រមនេះ ។

## មាតិកាទី ២
## ស្តង់ដារបរិស្ថាន
## ជំពូកទី ១
## បទប្បញ្ញត្តិទូទៅ

**មាត្រា៦០១ .**_ វិសាលភាព

មាតិកានេះមានវិសាលភាពអនុវត្តចំពោះស្តង់ដារបរិស្ថានដូចខាងក្រោម៖

១- សារធាតុ និងផលិតផលគ្រោះថ្នាក់ ។

២- ការគ្រប់គ្រងសំណល់ ។

៣- ការបំភាយខ្យល់ និងគុណភាពខ្យល់បរិយាកាស ។

៤- គុណភាពទឹកសាធារណៈ ។

៥- ទឹកកខ្វក់ ។

៦- គុណភាពដី និងការបំពុលដី ។

៧- ការបញ្ចេញសំឡេង និងរំញ័រ ។

៨- ផលិតកម្ម និងការប្រើប្រាស់ដោយចីរភាព ។

៩- ប្រសិទ្ធផលថាមពល ។

១០- ការបញ្ចេញ និងគោលដៅគុណភាពបរិស្ថានផ្សេងៗ ដែលកំណត់ដោយក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន ។

**មាត្រា៦០២ .**_ ការរៀបចំស្តង់ដារបរិស្ថាន

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន ត្រូវទទួលបន្ទុកក្នុងការរៀបចំស្តង់ដារបរិស្ថាន ។

**មាត្រា៦០៣** ._ ស្តង់ដារបរិស្ថាន

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន ត្រូវរៀបចំលិខិតបទដ្ឋានគតិយុត្តស្តីពីស្តង់ដារបរិស្ថាន ។

**មាត្រា៦០៤** ._ លក្ខខណ្ឌតម្រូវសម្រាប់រៀបចំស្តង់ដារបរិស្ថាន

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន ត្រូវរៀបចំលិខិតបទដ្ឋានគតិយុត្តស្តីពីស្តង់ដារបរិស្ថាន ដោយយកចិត្តទុកដាក់លើចំណុច ដូចខាងក្រោម៖

១- គោលការណ៍នានាដូចមានចែងនៅក្នុងគន្ថីទី១ នៃក្រមនេះ ។

២- ផលប៉ះពាល់ជាសក្តានុពលចំពោះសុខភាពសាធារណៈ ។

៣- ផលប៉ះពាល់ជាសក្តានុពលចំពោះជនងាយរងគ្រោះ ។

៤- ការខូចខាតជាសក្តានុពលចំពោះបរិស្ថាន ។

៥- ព័ត៌មានផ្នែកវិទ្យាសាស្ត្រប្រសើរបំផុត ដែលអាចស្វែងរកបាន ។

៦- ស្តង់ដារនៃសមាគមន៍ប្រជាជាតិអាស៊ីអាគ្នេយ៍ ។

៧ -ស្តង់ដារអន្តរជាតិ ។

៨- បច្ចេកទេសប្រសើរបំផុតដែលអាចស្វែងរកបាន ។

៩- ទម្លាប់នៃការអនុវត្តល្អៗផ្នែកឧស្សាហកម្ម។

## ជំពូកទី ២
## ការអនុវត្តស្តង់ដារបរិស្ថាន

**មាត្រា៦០៥** ._ វិសាលភាពអនុវត្តស្តង់ដារបរិស្ថាន

ស្តង់ដារបរិស្ថាន រួមមានស្តង់ដារគុណភាពបរិស្ថាន ការបញ្ចេញ និងការអនុវត្តការគ្រប់គ្រងសំណល់ ត្រូវអនុវត្តចំពោះរាល់សកម្មភាពទាំងអស់ និងលិខិតអនុញ្ញាតទាំងឡាយណា ដែលបានចេញ ស្របតាមក្រមនេះ និងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀត ។

**មាត្រា៦០៦** ._ លិខិតអនុញ្ញាត

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន ឬក្រសួង ស្ថាប័នមានសមត្ថកិច្ច មិនត្រូវចេញនូវលិខិតអនុញ្ញាត ដែលមិនស្របទៅនឹងស្តង់ដារបរិស្ថាន ។

**មាត្រា៦០៧** ._ ការមិនអនុលោមតាមច្បាប់

រាល់លិខិតអនុញ្ញាតទាំងឡាយណា ដែលមិនអនុលោមតាមស្តង់ដារបរិស្ថានត្រូវចាត់ទុកជាមោឃៈ ។

## ជំពូកទី ៣
## ស្តង់ដារបរិស្ថានដែលនៅជាធរមាន

**មាត្រា៦០៨** ._ ការអនុវត្តស្តង់ដារបរិស្ថានដែលនៅជាធរមាន

ស្តង់ដារបរិស្ថាន ដែលនៅជាធរមាន ត្រូវបន្តសុពលភាពអនុវត្ត រហូតដល់ពេលមានស្តង់ដារបរិស្ថានថ្មី ដែលរៀបចំឡើងស្របតាមក្រមនេះមកជំនួស ។

ក្នុងករណីដែលពុំទាន់មានស្តង់ដារបរិស្ថានជាក់លាក់ ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន អាចជ្រើសរើសស្តង់ដារអន្តរជាតិ ស្តង់ដារនៃសមាគមន៍ប្រជាជាតិអាស៊ីអាគ្នេយ៍ ឬទម្លាប់អនុវត្តដ៏ល្អបំផុតផ្នែកឧស្សាហកម្មមកអនុវត្តជាស្តង់ដារក្នុងអំឡុងពេលអន្តរកាលបាន ។

**មាត្រា៦០៩** ._ ការរៀបចំសេចក្តីព្រាងស្តង់ដារបរិស្ថាន

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន ដោយពិគ្រោះយោបល់ជាមួយក្រសួង ស្ថាប័នមានសមត្ថកិច្ច ត្រូវរៀបចំសេចក្តីព្រាងស្តង់ដារបរិស្ថាន ។

**មាត្រា៦១០** ._ ការចូលរួមជាសាធារណៈ

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន ត្រូវផ្តល់ឱកាសឱ្យសាធារណជនចូលរួមផ្តល់យោបល់ លើសេចក្តីព្រាងស្តង់ដារបរិស្ថាន ។

**មាត្រា៦១១** ._ ការកែសម្រួលសេចក្តីព្រាងស្តង់ដារបរិស្ថាន

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន ត្រូវពិចារណាលើមតិយោបល់ លើសេចក្តីព្រាងស្តង់ដារបរិស្ថាន និងត្រូវកែសម្រួលសេចក្តីព្រាងស្តង់ដារបរិស្ថាននេះដោយផ្អែកលើមតិយោបល់ទាំងនោះ និងត្រូវពន្យល់មូលហេតុ ក្នុងករណីមានការបដិសេធចំពោះមតិយោបល់ទាំងនេះ ។

**មាត្រា៦១២** ._ ការធ្វើបច្ចុប្បន្នភាពស្តង់ដារបរិស្ថាន

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន ត្រូវធ្វើបច្ចុប្បន្នភាពជាប្រចាំ និងកែសម្រួលស្តង់ដារបរិស្ថាន ដោយផ្អែកតាមភាពរីកចម្រើនផ្នែកវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា និងកត្តាបរិស្ថាន និងសង្គម ។

**មាត្រា៦១៣** ._ ការស្នើសុំកែសម្រួលស្តង់ដារបរិស្ថាន

បុគ្គលគ្រប់រូបមានសិទ្ធិដាក់សំណើសុំកែសម្រួលស្តង់ដារបរិស្ថាន ដោយផ្អែកលើព័ត៌មានថ្មីៗ ទៅកាន់ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន ។

**មាត្រា៦១៤** ._ នីតិវិធីនៃការរៀបចំស្តង់ដារបរិស្ថាន

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន ត្រូវរៀបចំលិខិតបទដ្ឋានគតិយុត្ត ស្តីពីនីតិវិធីសម្រាប់រៀបចំស្តង់ដារបរិស្ថាន ។

**មាត្រា៦១៥** ._ ការដាក់ឱ្យសាធារណជនអាចស្វែងរកបានស្តង់ដារបរិស្ថាន

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន ត្រូវដាក់ឱ្យសាធារណជនអាចស្វែងរកបាននូវស្តង់ដារគុណភាពបរិស្ថានស្របតាមបទប្បញ្ញត្តិ នៃក្រមនេះ ។

## មាតិកាទី ៣
## ការគ្រប់គ្រងសារធាតុគ្រោះថ្នាក់
### ជំពូកទី ១
### បទប្បញ្ញត្តិទូទៅ

**មាត្រា៦១៦** ._ វិសាលភាព

មាតិកានេះមានវិសាលភាពអនុវត្តចំពោះផលិតផល និងសារធាតុគ្រោះថ្នាក់បុគ្គលគ្រប់រូប ដែលផលិត ដឹកជញ្ជូន ទិញ លក់ ប្រើប្រាស់ រក្សាទុក បញ្ចេញ ឬបោះបង់ចោលផលិតផល និងសារ

ធាតុគ្រោះថ្នាក់ និងវត្ថុធាតុដែលពាក់ព័ន្ធក្នុងវដ្តជីវិតនៃវត្ថុធាតុទាំងនេះនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

មាតិកានេះ មិនមានវិសាលភាពអនុវត្តចំពោះសារធាតុវិទ្យុសកម្ម ឱសថ សម្ភារៈកែសម្ផស្ស ផលិតផលអាហារ ឬអាហារបន្ទាប់បន្សំ ដែលត្រូវស្ថិតនៅក្រោមច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត ដោយឡែកឡើយ ។

**មាត្រា៦១៧** ._ តួនាទី និងភារៈកិច្ចរបស់ក្រសួង ស្ថាប័នមានសមត្ថកិច្ច

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន ដោយមានការចូលរួមសហការពីក្រសួង ស្ថាប័នមានសមត្ថកិច្ច ត្រូវទទួលខុសត្រូវចំពោះការគ្រប់គ្រងផលិតផល និងសារធាតុគ្រោះថ្នាក់។

**មាត្រា៦១៨** ._ ការរៀបចំយន្តការគ្រប់គ្រង និងត្រួតពិនិត្យ

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន ដោយសហការជាមួយក្រសួង ស្ថាប័នមានសមត្ថកិច្ច ត្រូវរៀបចំលិខិតបទដ្ឋានគតិយុត្តសម្រាប់ធ្វើការគ្រប់គ្រង និងត្រួតពិនិត្យសារធាតុគ្រោះថ្នាក់។

**មាត្រា៦១៩** ._ លក្ខណៈវិនិច្ឆ័យសម្រាប់កំណត់ប្រភេទ និងចំណាត់ថ្នាក់សារធាតុគ្រោះថ្នាក់

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន ត្រូវរៀបចំលិខិតបទដ្ឋានគតិយុត្តស្តីពីលក្ខណៈវិនិច្ឆ័យសម្រាប់កំណត់ប្រភេទ និងចំណាត់ថ្នាក់សារធាតុគ្រោះថ្នាក់ ។

លក្ខណៈវិនិច្ឆ័យនេះ ត្រូវផ្អែកលើលិខិតូបករណ៍អន្តរជាតិដែលព្រះរាជាណាចក្រកម្ពុជាជាភាគីហត្ថលេខី និងទម្លាប់អនុវត្តល្អបំផុត និងព័ត៌មានវិទ្យាសាស្ត្រល្អបំផុត ដែលអាចស្វែងរកបាន ។

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន ត្រូវធ្វើការត្រួតពិនិត្យឡើងវិញ និងធ្វើបច្ចុប្បន្នភាពជាប្រចាំលើលិខិតបទដ្ឋានគតិយុត្ត ដូចមានចែងក្នុងកថាខណ្ឌខាងលើនេះ ។

**មាត្រា៦២០** ._ ការទទួលខុសត្រូវលើការខូចខាត

បុគ្គលគ្រប់រូប ដែលផលិត ឬប្រើប្រាស់សារធាតុគ្រោះថ្នាក់សម្រាប់ការផលិតទំនិញ និងផលិតផល ត្រូវទទួលខុសត្រូវលើការខូចខាតចំពោះសុខភាពមនុស្ស ទ្រព្យសម្បត្តិ និងបរិស្ថាន ។

## ជំពូកទី ២
## ការហាមឃាត់សារធាតុគ្រោះថ្នាក់

**មាត្រា៦២១ .**_ ការហាមឃាត់ចំពោះសារធាតុហាមឃាត់ ឬដាក់ម៉ាកនាំឱ្យមានការភាន់ច្រឡំ

បុគ្គលគ្រប់រូបមិនត្រូវធ្វើសកម្មភាព ដូចខាងក្រោម ៖

១- ការផលិត ការវេចខ្ចប់ ការនាំចូល ការនាំចេញ ការដឹកជញ្ជូន ការចែកចាយ ការទិញ ការលក់ ការកាន់កាប់ ការប្រើប្រាស់ ការគ្រប់គ្រង ការស្តុកទុក ការធ្វើប្រព្រឹត្តកម្ម ការចម្រាញ់ ការកែច្នៃ ការបញ្ចេញ ឬការបោះបង់ចោល សារធាតុគ្រោះថ្នាក់ដែលបានដាក់ម៉ាកនាំឱ្យមានការភាន់ច្រឡំ ឬសារធាតុគ្រោះថ្នាក់ហាមឃាត់ ។

២- ការកែប្រែ ការបំផ្លាញចោល ឬការដកចេញនូវស្លាកសញ្ញា ឬផ្នែកណាមួយនៃស្លាកសញ្ញាសារធាតុគ្រោះថ្នាក់ណាមួយ នៅពេលលក់សារធាតុគ្រោះថ្នាក់នេះ ។

**មាត្រា៦២២ .**_ ការហាមឃាត់ចំពោះសារធាតុបំពុលសរីរាង្គមិនងាយបំបែកធាតុ

បុគ្គលគ្រប់រូបមិនត្រូវផលិត វេចខ្ចប់ នាំចូល នាំចេញ ដឹកជញ្ជូន ចែកចាយ ទិញ លក់ កាន់កាប់ ប្រើប្រាស់ ឬគ្រប់គ្រង ស្តុកទុក ធ្វើប្រព្រឹត្តកម្ម ចម្រាញ់ កែច្នៃ បញ្ចេញចោល បោះបង់ចោល សារធាតុបំពុលសរីរាង្គមិនងាយបំបែកធាតុ ដែលបានហាមឃាត់ដោយអនុសញ្ញាស្តុកខូម ។

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន ត្រូវរៀបចំលិខិតបទដ្ឋានគតិយុត្តស្តីពីបញ្ជីសារធាតុបំពុលសរីរាង្គមិនងាយបំបែកធាតុ ដែលបានហាមឃាត់  ដូចមានចែងក្នុងកថាខណ្ឌខាងលើ។

បញ្ជីសារធាតុបំពុលសរីរាង្គមិនងាយបំបែកធាតុដែលបានហាមឃាត់ ត្រូវដាក់ឱ្យសាធារណជនអាចស្វែងរកបាន ។

**មាត្រា៦២៣ .**_ ការហាមឃាត់សំណនៅក្នុងថ្នាំលាប និងផលិតផលសម្រាប់កុមារ

ថ្នាំលាបទាំងឡាយដែលមានសារធាតុសំណ ឬសមាសធាតុសំណ ដែលមានបរិមាណលើសពី៩០ភាគនៃមួយលានឯកតា នៃបរិមាណដែលជាកំហាប់សំណ ឬថ្នាំលាប ឬទម្ងន់នៃហ្វីលថ្នាំលាបដែលស្ងួត ត្រូវចាត់ទុកជាផលិតផលហាមឃាត់ ។

ផលិតផលសម្រាប់កុមារ ដែលលាបថ្នាំមានសារធាតុសំណ  ដែលមានបរិមាណលើសពី៩០ភាគនៃមួយលានឯកតា នៃបរិមាណដែលជាកំហាប់សំណ ឬថ្នាំលាប ឬទម្ងន់នៃហ្វីលថ្នាំលាបដែលស្ងួត ត្រូវចាត់ទុកជាផលិតផលហាមឃាត់ ។

**មាត្រា៦២៤** ._ កាលបរិច្ឆេទនៃសុពលភាពអនុវត្តចំពោះការហាមឃាត់លើថ្នាំលាបដែលមានសារធាតុសំណ

ការហាមឃាត់ចំពោះថ្នាំលាប និងផលិតផលដែលមានសារធាតុធាតុសំណដែលបានហាមឃាត់ ដូចមានចែងក្នុងមាត្រា៦២៣ នៃក្រមនេះ ត្រូវមានសុពលភាពអនុវត្តដូចខាងក្រោម៖

១- ក្នុងរយៈពេល៣(បី)ឆ្នាំក្រោយពីការចូលជាធរមាននៃក្រមនេះ សម្រាប់ការផលិត ការនាំចូល ការនាំចេញ ការលក់ផលិតផលកុមារ ដែលមានថ្នាំលាបមានសារធាតុសំណក្នុងបរិមាណលើសពី៩០ភាគនៃមួយលានឯកតានៃបរិមាណដែលជាកំហាប់សំណ ឬថ្នាំលាប ឬទម្ងន់នៃហ្វីលថ្នាំលាបដែលស្ងួត ។

២- ក្នុងរយៈពេល៣(បី)ឆ្នាំក្រោយពីការចូលជាធរមាននៃក្រមនេះ សម្រាប់ការផលិត ការនាំចូល ការនាំចេញថ្នាំលាប ដែលមានពណ៌ ឬសារធាតុធ្វើឱ្យឆាប់ស្ងួត ឬការប្រើប្រាស់ក្នុងគោលបំណងណាមួយ ដែលក្នុងនោះមានសារធាតុសំណក្នុងបរិមាណលើសពី៩០ភាគនៃមួយលានឯកតានៃបរិមាណដែលជាកំហាប់សំណ ឬថ្នាំលាប ឬនៃទម្ងន់នៃហ្វីលថ្នាំលាបស្ងួត សម្រាប់ការអនុវត្តក្នុងវិស័យស្ថាបត្យកម្ម ការតុបតែង និងគេហដ្ឋាន ។

៣- ក្នុងរយៈពេល ៦ (ប្រាំមួយ) ឆ្នាំ ក្រោយពេលក្រមនេះចូលជាធរមាន សម្រាប់ការផលិត ការនាំចូល ការនាំចេញ ថ្នាំលាបដែលមានពណ៌ឬសារធាតុធ្វើឱ្យឆាប់ស្ងួត ឬការប្រើប្រាស់ក្នុងគោលបំណងណាមួយ ដែលក្នុងនោះមានសារធាតុសំណក្នុងបរិមាណលើសពី៩០ភាគនៃមួយលានឯកតានៃបរិមាណដែលជាកំហាប់សំណ ឬថ្នាំលាប ឬនៃទម្ងន់នៃហ្វីលថ្នាំលាបស្ងួត សម្រាប់ការអនុវត្តក្នុងវិស័យឧស្សាហកម្ម ។

**មាត្រា៦២៥** ._ នីតិវិធីសម្រាប់ការអង្កេតតាមដាន និងការពង្រឹងការអនុវត្តចំពោះការហាមឃាត់ទៅលើថ្នាំលាបដែលមានសារធាតុសំណ

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន ត្រូវរៀបចំលិខិតបទដ្ឋានគតិយុត្តស្តីពីការអង្កេតតាមដាន និងការពង្រឹងការអនុវត្តចំពោះការហាមឃាត់ទៅលើថ្នាំលាប និងផលិតផលកុមារដែលមានសារធាតុសំណ ។

**មាត្រា៦២៦** ._ ការរឹបអូសសារធាតុហាមឃាត់ ឬដាក់ម៉ាកនាំឱ្យមានការភាន់ច្រឡំ

ត្រូវធ្វើការរឹបអូស រាល់ផលិតផល ឬសារធាតុគ្រោះថ្នាក់ដែលហាមឃាត់ ឬដាក់ម៉ាកនាំឱ្យមានការភាន់ច្រឡំ ។

**មាត្រា៦២៧**._ ការហាមឃាត់ចំពោះសារធាតុដែលមិនបានចុះបញ្ជី

បុគ្គលគ្រប់រូប មិនត្រូវផលិត វេចខ្ចប់ នាំចូល នាំចេញ ដឹកជញ្ជូន ចែកចាយ ទិញ លក់ កាន់កាប់ ប្រើប្រាស់ គ្រប់គ្រង ស្តុកទុក ធ្វើប្រព្រឹត្តកម្ម ចម្រាញ់ កែច្នៃ បញ្ចេញចោល បោះបង់ចោល ផលិតផល ឬសារធាតុគ្រោះថ្នាក់ដែលមិនទាន់បានចុះបញ្ជី ។

**មាត្រា៦២៨**._ ការហាមឃាត់ចំពោះការវេចខ្ចប់ដែលមិនត្រឹមត្រូវ

បុគ្គលគ្រប់រូប មិនត្រូវផលិត វេចខ្ចប់ នាំចូល នាំចេញ ដឹកជញ្ជូន ចែកចាយ ទិញ លក់ កាន់កាប់ ប្រើប្រាស់ គ្រប់គ្រង ស្តុកទុក ធ្វើប្រព្រឹត្តកម្ម ចម្រាញ់ កែច្នៃ បញ្ចេញចោល បោះបង់ចោល ផលិតផល ឬ សារធាតុគ្រោះថ្នាក់ ដែលមិនបានវេចខ្ចប់ ស្របតាមបទប្បញ្ញត្តិ និងលក្ខខណ្ឌនៃការវេចខ្ចប់ដែលនៅជាធរមានឡើយ ។

**មាត្រា៦២៩**._ ការហាមឃាត់ចំពោះការវេចខ្ចប់ និងការផ្សាយពាណិជ្ជកម្មមិនពិត ឬនាំឱ្យមានការភាន់ច្រឡំ

បុគ្គលគ្រប់រូប មិនត្រូវវេចខ្ចប់ ឬផ្សាយពាណិជ្ជកម្មអំពីផលិតផល ឬសារធាតុគ្រោះថ្នាក់ នៅក្នុងលក្ខណៈដែលមិនពិត ឬធ្វើឱ្យមានការភាន់ច្រឡំ ឬអាចនាំឱ្យមានការចាប់អារម្មណ៍ដែលមិនត្រឹមត្រូវទាក់ទងនឹងលក្ខណៈរូបរាង តម្លៃ បរិមាណ សមាសភាគ សុវត្ថិភាព ឬការចុះបញ្ជីឡើយ ។

**មាត្រា៦៣០**._ ការហាមឃាត់ចំពោះការប្រើប្រាស់សារធាតុដែលបង្កឱ្យមានរបួសស្នាម

បុគ្គលគ្រប់រូប មិនត្រូវប្រើប្រាស់សារធាតុរួមមាន អាស៊ីត សាំង ឬសារធាតុគីមីពុល ដែលអាចបង្កឱ្យមានច្រេះស៊ី ការរលាក អុកស៊ីតកម្ម ឬរបួសស្នាម ដែលមានផលប៉ះពាល់ដល់សុខភាព និងជីវិតមនុស្សឡើយ លើកលែងតែមានការអនុញ្ញាតស្របតាមបទប្បញ្ញត្តិនៃក្រមនេះ ។

## ជំពូកទី ៣
## ការចុះបញ្ជី និងការបង្ហាញព័ត៌មានអំពីសារធាតុគ្រោះថ្នាក់

**មាត្រា៦៣១** ._ នីតិវិធី និងលក្ខខណ្ឌនៃការចុះបញ្ជីផលិតផល និងសារធាតុគ្រោះថ្នាក់

បុគ្គលគ្រប់រូប ត្រូវធ្វើការចុះបញ្ជី ផលិតផល និងសារធាតុគ្រោះថ្នាក់ ដែលប្រើប្រាស់ក្នុងគោលបំណង ចែកចាយ លក់ ឬប្រើប្រាស់នៅក្នុងព្រះរាជាណាចក្រកម្ពុជា ស្របតាមក្រមនេះ និងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន ។

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន ដោយសហការជាមួយក្រសួង ស្ថាប័នមានសមត្ថកិច្ច ត្រូវរៀបចំលិខិតបទដ្ឋានគតិយុត្តស្តីពីនីតិវិធីនៃការចុះបញ្ជីផលិតផល និងសារធាតុគ្រោះថ្នាក់ ។

**មាត្រា៦៣២** ._ លក្ខខណ្ឌតម្រូវនៃការដាក់ពាក្យស្នើសុំ

ការដាក់ពាក្យស្នើសុំចុះបញ្ជី ត្រូវដាក់ជូនក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន ដោយមានភ្ជាប់ជាមួយនូវព័ត៌មានដូចខាងក្រោម៖

១- អ្នកផលិត ។

២- ពាណិជ្ជនាមទូទៅនៃសារធាតុគីមី ។

៣- ចំណាត់ថ្នាក់នៃកម្រិតបង្កគ្រោះថ្នាក់ ។

៤- ចំនួន ។

៥- គោលបំណងនៃការនាំចូល ឬប្រើប្រាស់ ។

៦- ឯកសារព័ត៌មានអំពីសុវត្ថិភាព ។

៧- ព័ត៌មានអំពីកម្រិតបង្កគ្រោះថ្នាក់ ។

៨- ហានិភ័យជាសក្តានុពលចំពោះសុខភាពមនុស្ស និង

៩- អាសយដ្ឋានសម្រាប់ធ្វើការចែកចាយ ។

**មាត្រា៦៣៣** ._ ការត្រួតពិនិត្យលើពាក្យស្នើសុំ និងការឯកភាពលើការចុះបញ្ជី

ព័ត៌មានអំពីសារធាតុគ្រោះថ្នាក់ ត្រូវទទួលការត្រួតពិនិត្យ និងការឯកភាពជាមុនពីក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន មុននឹងបញ្ជូនទៅឱ្យក្រសួង ស្ថាប័នមានសមត្ថកិច្ច ដើម្បីធ្វើសេចក្តីសម្រេច ។

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន អាចធ្វើការពិសោធន៍ និងផ្តល់ការពិគ្រោះយោបល់បន្ថែម ដើម្បីផ្ទៀងផ្ទាត់ពីភាពត្រឹមត្រូវនៃព័ត៌មានទាំងនេះ ។ ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន ត្រូវឯកភាពលើការចុះបញ្ជី ក្នុងករណីដែលព័ត៌មានស្តីពីសារធាតុគ្រោះថ្នាក់បង្ហាញថា មិនបង្កឱ្យមានគ្រោះថ្នាក់ដល់សុខភាពមនុស្ស ឬបរិស្ថាន ។

អ្នកស្នើសុំការចុះបញ្ជី ត្រូវទទួលបន្ទុកក្នុងការបង្ហាញភស្តុតាងនៃការបំពេញតាមស្តង់ដារ នៃការចុះបញ្ជី ។

**មាត្រា៦៣៤**._ កាតព្វកិច្ចផ្តល់ព័ត៌មាន

ក្រសួង ស្ថាប័នមានសមត្ថកិច្ច ត្រូវផ្តល់ព័ត៌មានស្តីពីផលិតផល និងសារធាតុគ្រោះថ្នាក់ទៅឱ្យក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន សម្រាប់គោលបំណងនៃការរៀបចំបញ្ជីសារពើភ័ណ្ឌ ការអង្កេតតាមដាន ការវាយតម្លៃពីហានិភ័យ និងការធ្វើអធិការកិច្ច ។

ក្នុងករណីអ្នកផលិត ឬអ្នកនាំចូលនៃសារធាតុគ្រោះថ្នាក់ មានព័ត៌មានបន្ថែមពាក់ព័ន្ធទៅនឹងផលប៉ះពាល់អវិជ្ជមានគួរឱ្យកត់សម្គាល់នៃសារធាតុគ្រោះថ្នាក់នោះ អ្នកផលិត ឬអ្នកនាំចូល ត្រូវផ្តល់ព័ត៌មានមកកាន់ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថានជាបន្ទាន់។

**មាត្រា៦៣៥**._ ផែនការសកម្មភាពសម្រាប់ការទប់ស្កាត់ ការឆ្លើយតបជាបន្ទាន់ ការកាត់បន្ថយ និងការអង្កេតតាមដាននិងការគ្រប់គ្រងហានិភ័យ

បន្ទាប់ពីមានការចុះបញ្ជីជាផ្លូវការរួចហើយ អ្នកស្នើសុំចុះបញ្ជីសារធាតុគ្រោះថ្នាក់ ត្រូវរៀបចំផែនការសកម្មភាពសម្រាប់ការទប់ស្កាត់ ការឆ្លើយតបជាបន្ទាន់ ការកាត់បន្ថយ ការអង្កេតតាមដាន និងការគ្រប់គ្រងហានិភ័យ នៃសារធាតុគ្រោះថ្នាក់ ។

អ្នកស្នើសុំចុះបញ្ជីសារធាតុគ្រោះថ្នាក់ ត្រូវទទួលខុសត្រូវក្នុងការផ្តល់ព័ត៌មានឱ្យបានត្រឹមត្រូវស្តីពីសារធាតុគ្រោះថ្នាក់ ទៅឱ្យក្រសួង ស្ថាប័នមានសមត្ថកិច្ច ក្នុងករណីមានការស្នើសុំ ។

**មាត្រា៦៣៦**._ ការលុបចោលការចុះបញ្ជី

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន ត្រូវលុបចោលការចុះបញ្ជីសារធាតុគ្រោះថ្នាក់ ឬការប្រើប្រាស់ជាក់លាក់ណាមួយនៃសារធាតុគ្រោះថ្នាក់ ក្នុងករណីដែលបានកំណត់ថា សារធាតុគ្រោះថ្នាក់ ឬការប្រើប្រាស់សារធាតុគ្រោះថ្នាក់នោះ បង្កឱ្យមានហានិភ័យនៃផលប៉ះពាល់ធ្ងន់ធ្ងរចំពោះសុខភាពមនុស្ស ឬបរិស្ថាន ។

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន ត្រូវព្យួរការចុះបញ្ជីសារធាតុគ្រោះថ្នាក់ ឬការប្រើប្រាស់ជាក់លាក់ណាមួយនៃសារធាតុគ្រោះថ្នាក់ ក្នុងករណីបានកំណត់ថា សារធាតុគ្រោះថ្នាក់ ឬការប្រើប្រាស់សារធាតុគ្រោះថ្នាក់នោះ អាចបង្កឱ្យកើតមានហានិភ័យនៃផលប៉ះពាល់ធ្ងន់ធ្ងរចំពោះ សុខភាព

មនុស្ស ឬបរិស្ថាន ។

## ជំពូកទី ៤
## ការដាក់ស្លាកសញ្ញាសារធាតុគ្រោះថ្នាក់

**មាត្រា៦៣៧** ._ បទប្បញ្ញត្តិចំពោះការដាក់ស្លាកសញ្ញាសារធាតុគ្រោះថ្នាក់

បុគ្គលគ្រប់រូបដែលចូលរួមក្នុងការផលិត ការវេចខ្ចប់ ការនាំចូល ការនាំចេញ ការដឹកជញ្ជូន ការចែកចាយ ឬការលក់ផលិតផលឬសារធាតុគ្រោះថ្នាក់ ត្រូវដាក់ស្លាកសញ្ញាឱ្យបានត្រឹមត្រូវលើផលិតផលឬសារធាតុគ្រោះថ្នាក់ទាំងនោះ ស្របតាមលិខិតបទដ្ឋានគតិយុត្តស្ដីពីការដាក់ស្លាកសញ្ញាលើផលិតផល ។

**មាត្រា៦៣៨** ._ លក្ខណៈវិនិច្ឆ័យនៃភាពអាចបង្កគ្រោះថ្នាក់

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន ត្រូវរៀបចំលិខិតបទដ្ឋានគតិយុត្ត ស្ដីពីការដាក់ស្លាកសញ្ញាលើផលិតផលគ្រោះថ្នាក់ ។លក្ខណៈវិនិច្ឆ័យនៃភាពអាចបង្កគ្រោះថ្នាក់ ត្រូវផ្អែកលើបទដ្ឋានបច្ចេកទេសអន្តរជាតិស្ដីពីប្រព័ន្ធស៊ីចង្វាក់ជាសាកលអំពីការចាត់ថ្នាក់ និងដាក់ស្លាកសញ្ញាសារធាតុគីមី ។

**មាត្រា៦៣៩** ._ កាតព្វកិច្ចផ្ដល់ព័ត៌មាន

បុគ្គលគ្រប់រូប ដែលពាក់ព័ន្ធនឹងផលិតកម្ម ការវេចខ្ចប់ ការនាំចេញ ការនាំចូល ការដឹកជញ្ជូន ការចែកចាយ ឬការលក់ផលិតផល ឬសារធាតុគ្រោះថ្នាក់ ត្រូវដាក់ឱ្យសាធារណៈជនអាចស្វែងរកបាននូវព័ត៌មានស្ដីពីសុវត្ថិភាព ការកាត់បន្ថយ និងការទប់ស្កាត់ភាពបង្កគ្រោះថ្នាក់ និងហានិភ័យនៃផលប៉ះពាល់ចំពោះសុខភាព នៃផលិតផល និងសារធាតុគ្រោះថ្នាក់ ដែលត្រូវយកមកធ្វើការចែកចាយ ឬលក់នៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

## ជំពូកទី ៥
## ការដឹកជញ្ជូន ការប្រើប្រាស់ និងការបោះបង់ចោលសារធាតុគ្រោះថ្នាក់

**មាត្រា៦៤០** ._ ការដឹកជញ្ជូន

បុគ្គលគ្រប់រូប ដែលដឹកជញ្ជូនសារធាតុគ្រោះថ្នាក់ ត្រូវអនុវត្តតាមបទប្បញ្ញត្តិស្តីពីការដឹកជញ្ជូនសារធាតុ ឬផលិតផលគ្រោះថ្នាក់ដូចបានកំណត់តាមមាតិកានេះ ។

ប្រតិបត្តិករ និងម្ចាស់មធ្យោបាយដឹកជញ្ជូន ត្រូវរៀបចំផែនការសុវត្ថិភាព និងសុខភាព បុគ្គលិក និងផែនការឆ្លើយតប ដើម្បី ៖

១- កំណត់ និងចាត់វិធានការចាំបាច់ ដើម្បីកាត់បន្ថយដល់កម្រិតអប្បបរមានូវគ្រោះថ្នាក់ដែលអាចកើតឡើង និងដោះស្រាយផលវិបាកនានា រួមមានការបណ្តុះបណ្តាលបុគ្គលិកផ្នែកដឹកជញ្ជូនអំពីវិធានការសុវត្ថិភាព និងផែនការឆ្លើយតបទាំងនោះ ។

២- កំណត់ និងជូនដំណឹង ដល់ក្រសួង ស្ថាប័នមានសមត្ថកិច្ចដែលនៅជិតបំផុត ក្នុងករណីមានគ្រោះថ្នាក់កើតឡើងក្នុងពេលដឹកជញ្ជូន តាមផ្លូវគោក ផ្លូវទឹក និងផ្លូវអាកាស ។

ប្រតិបត្តិករ ឬម្ចាស់មធ្យោបាយដឹកជញ្ជូន ត្រូវធានាថា៖ យានយន្តដែលប្រើប្រាស់ក្នុងការដឹកជញ្ជូនផលិតផល ឬសារធាតុគ្រោះថ្នាក់ ត្រូវ៖

១- មានសុវត្ថិភាពសម្រាប់ការដឹកជញ្ជូនសារធាតុគ្រោះថ្នាក់ទាំងនោះប្រកបដោយសុវត្ថិភាព និង

២- មានដាក់សញ្ញាសម្គាល់ ដែលមានរូបភាព ឬរូបសញ្ញាបង្ហាញពីភាពអាចបង្កគ្រោះថ្នាក់ឱ្យបានត្រឹមត្រូវ ។

**មាត្រា៦៤១** ._ ការរៀបចំលិខិតបទដ្ឋានគតិយុត្តស្តីពីការដឹកជញ្ជូន

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន ដោយសហការជាមួយក្រសួង ស្ថាប័នទទួលបន្ទុកដឹកជញ្ជូន និងក្រសួង ស្ថាប័នមានសមត្ថកិច្ចដទៃទៀត ត្រូវរៀបចំលិខិតបទដ្ឋានគតិយុត្តស្តីពីការដឹកជញ្ជូនផលិតផល ឬសារធាតុគ្រោះថ្នាក់ ។

**មាត្រា៦៤២** ._ សិទ្ធិប្រើប្រាស់សារធាតុគ្រោះថ្នាក់

បុគ្គលគ្រប់រូប មានសិទ្ធិប្រើប្រាស់សារធាតុគ្រោះថ្នាក់ ស្របតាមលក្ខខណ្ឌដូចមានចែងក្នុងក្រមនេះ និងលិខិតបទដ្ឋានគតិយុត្តស្តីពីសុវត្ថិភាពនៃសារធាតុគ្រោះថ្នាក់ ។

**មាត្រា៦៤៣** ._ ការហាមឃាត់ចំពោះការប្រើប្រាស់សារធាតុគ្រោះថ្នាក់

បុគ្គលគ្រប់រូប មិនត្រូវប្រើប្រាស់សារធាតុគ្រោះថ្នាក់ ដែលអាចបង្កផលប៉ះពាល់សុខភាពមនុស្ស នៅក្នុងផលិតផលចំណីអាហារ គ្រឿងកែសម្ផស្ស និងផលិតកុមារឡើយ ។

**មាត្រា៦៤៤** ._ ការប្រើប្រាស់សារធាតុគ្រោះថ្នាក់ក្នុងការស្រាវជ្រាវផ្នែកវិទ្យាសាស្ត្រ

បុគ្គលគ្រប់រូប ដែលប្រើប្រាស់សារធាតុគ្រោះថ្នាក់ ក្នុងគោលបំណងធ្វើការស្រាវជ្រាវផ្នែកវិទ្យាសាស្ត្រ ត្រូវ៖

១- ប្រើប្រាស់សារធាតុគ្រោះថ្នាក់ ឱ្យស្របតាមបទប្បញ្ញត្តិនៃក្រមនេះ និងច្បាប់និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ ។

២- បំពាក់ឧបករណ៍គ្រប់គ្រាន់សម្រាប់មន្ទីរពិសោធន៍ដើម្បីទុកដាក់ និងប្រើប្រាស់ឱ្យមានសុវត្ថិភាពនូវសារធាតុគ្រោះថ្នាក់ និងត្រូវមានឧបករណ៍ការពារខ្លួនសម្រាប់បុគ្គលិក ។

៣- ដាក់ស្លាកសញ្ញាគ្រោះថ្នាក់ឱ្យបានត្រឹមត្រូវលើសារធាតុគ្រោះថ្នាក់ ស្របតាមលិខិតបទដ្ឋានគតិយុត្តស្តីពីការដាក់ស្លាកសញ្ញាលើផលិតផលគ្រោះថ្នាក់ ។

៤- រៀបចំមន្ទីរពិសោធន៍ឱ្យមានប្រព័ន្ធទុកដាក់ឯកសារនិងកត់ត្រាសារធាតុគ្រោះថ្នាក់ដែលប្រើប្រាស់ឱ្យបានសមស្រប ។

៥- បោះបង់ចោលសារធាតុ ឬសំណល់គ្រោះថ្នាក់ ស្របតាមបទប្បញ្ញត្តិស្តីពីការគ្រប់គ្រងសំណល់ នៃក្រមនេះ ។

៦- រៀបចំយន្តការដែលមានប្រសិទ្ធភាព ដើម្បីកំណត់ និងកាត់បន្ថយឱ្យដល់កម្រិតអប្បបរមានូវគ្រោះថ្នាក់ដែលអាចកើតមានឡើង ដោយសារការប្រើប្រាស់ និងការបោះបង់ចោលសំណល់ ឬសារធាតុគ្រោះថ្នាក់ ។

**មាត្រា៦៤៥** ._ ការបោះបង់ចោលសារធាតុគ្រោះថ្នាក់

បុគ្គលគ្រប់រូប មិនត្រូវដុត ឬបោះបង់ចោលសំណល់ ឬសារធាតុគ្រោះថ្នាក់ ចូលទៅក្នុងបរិស្ថាន ដោយគ្មានការអនុញ្ញាតពីក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន ។

ការបោះបង់ចោលផ្នែកណាមួយនៃសារធាតុគ្រោះថ្នាក់ ឬបញ្ចប់នៃសារធាតុទាំងនេះ ត្រូវធ្វើឡើងស្របតាមបទប្បញ្ញត្តិស្តីពីការគ្រប់គ្រងសំណល់នៃក្រមនេះ ។

## ជំពូកទី ៦
## សុវត្ថិភាពនៃសារធាតុគ្រោះថ្នាក់ ការទប់ស្កាត់គ្រោះថ្នាក់ ការត្រៀមលក្ខណៈ និងការឆ្លើយតបជាបន្ទាន់

**មាត្រា៦៤៦** ._ សមត្ថភាពផ្នែកបច្ចេកទេស

អ្នកផលិត ផលិតផលសារធាតុគ្រោះថ្នាក់ ត្រូវបណ្តុះបណ្តាលបុគ្គលិករបស់ខ្លួនឱ្យមានសមត្ថភាពផ្នែកបច្ចេកទេសសម្រាប់ការប្រើប្រាស់នីតិវិធី និងឧបករណ៍ការពារបរិស្ថាន និងសង្គម រួមមាន៖

១- រោងជាង ឃ្លាំងទុកដាក់ និងឧបករណ៍បច្ចេកទេស ។

២- ឧបករណ៍ និងសម្ភារៈសុវត្ថិភាពទូទៅ និងឧបករណ៍ និងសម្ភារៈដាក់លាក់សម្រាប់ទប់ស្កាត់ និងប្រយុទ្ធប្រឆាំងអគ្គីភ័យ ការផ្ទុះ ការបែកផ្កាភ្លើង ការលេចសារធាតុគ្រោះថ្នាក់ ឬការរាលដាល និងគ្រោះថ្នាក់ដទៃទៀត ដោយសារសារធាតុគ្រោះថ្នាក់ ។

៣- ឧបករណ៍ និងសម្ភារៈការពារការងារ ។

៤- ឧបករណ៍ និងសម្ភារៈការពារបរិស្ថាន ។

៥- ប្រព័ន្ធប្រព្រឹត្តកម្ម និងបញ្ចេញសំណល់ ។

៦- ការរៀបចំផែនការទប់ស្កាត់ និងឆ្លើយតបជាបន្ទាន់ ទាក់ទងនឹងការផ្តល់ព័ត៌មានអំពីភាពអាចបង្កគ្រោះថ្នាក់ ។

**មាត្រា៦៤៧** ._ សមត្ថភាពនៃបុគ្គលិកជំនាញ

បុគ្គលគ្រប់រូប ដែលចូលរួមក្នុងការផលិតផលិតផល ឬសារធាតុគ្រោះថ្នាក់ ត្រូវមានបុគ្គលិកជំនាញការដែលមានសមត្ថភាពគ្រប់គ្រាន់ក្នុងការអនុវត្តសកម្មភាពការងារ ទាក់ទងទៅនឹងទំហំ ប្រភេទ និងកម្រិត នៃសារធាតុគ្រោះថ្នាក់ និងមានចំណេះដឹងអំពីបច្ចេកវិទ្យា និង ផែនការនិងវិធានការសុវត្ថិភាពនៃសារធាតុគ្រោះថ្នាក់ ។

**មាត្រា៦៤៨** ._ លក្ខខណ្ឌតម្រូវនៃការចុះបញ្ជី និងលិខិតអនុញ្ញាត

បុគ្គលគ្រប់រូប ដែលចូលរួមក្នុងការផលិតផលិតផល ឬសារធាតុគ្រោះថ្នាក់ ត្រូវមានការចុះបញ្ជីអំពីសារធាតុគ្រោះថ្នាក់ និងទទួលបានលិខិតអនុញ្ញាតត្រឹមត្រូវពីក្រសួង ស្ថាប័នមានសមត្ថកិច្ច ។

**មាត្រា៦៤៩** ._ លក្ខខណ្ឌតម្រូវនៃការរៀបចំរបាយការណ៍ប្រចាំឆ្នាំ

បុគ្គលគ្រប់រូបដែលចូលរួមក្នុងការផលិតផលិតផលឬសារធាតុគ្រោះថ្នាក់ ត្រូវផ្តល់ជូនក្រសួង ស្ថាប័នមានសមត្ថកិច្ច និងក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាននូវរបាយការប្រចាំឆ្នាំស្តីពីដំណើរការផលិតកម្ម ចំនួននៃធាតុផ្សំគ្រោះថ្នាក់ គោលបំណងនៃការប្រើប្រាស់ ទីតាំងចែកចាយ ប្រព័ន្ធប្រព្រឹត្តកម្ម និងបញ្ចេញសំណល់ វិធានការ និងផែនការសុវត្ថិភាព ។

ក្រសួង ស្ថាប័នមានសមត្ថកិច្ច ដោយសហការជាមួយក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន ត្រូវរៀបចំទម្រង់បែបបទ នៃការរៀបចំរបាយការណ៍ប្រចាំឆ្នាំ ។

**មាត្រា៦៥០** ._ លក្ខខណ្ឌតម្រូវផ្នែកសុវត្ថិភាព

អ្នកផលិតដែលចូលរួមក្នុងការផលិតសារធាតុ ឬផលិតផលគ្រោះថ្នាក់ ត្រូវ ៖

១- បំពេញឱ្យបានតឹងរ៉ឹងតាមព័ត៌មានបច្ចេកទេស ការដាក់ស្លាកសញ្ញា និងការណែនាំអំពីសុវត្ថិភាពសម្រាប់សារធាតុគ្រោះថ្នាក់ ។

២- មានវិធានការទប់ស្កាត់ និងការឆ្លើយតបជាបន្ទាន់ រួមមាន ការសង្គ្រោះបឋម ផែនការជម្លៀស ឧបករណ៍ពន្លត់អគ្គីភ័យ និងឧបករណ៍ការពារខ្លួនសម្រាប់បុគ្គលិក ។

៣- រៀបចំវគ្គបណ្តុះបណ្តាលស្តីពីការប្រើប្រាស់ និងការទុកដាក់ ឬឱ្យមានសុវត្ថិភាពនូវសារធាតុគ្រោះថ្នាក់ ។

៤- រៀបចំផែនការឆ្លើយតបជាបន្ទាន់ពាក់ព័ន្ធនឹងសារធាតុគ្រោះថ្នាក់ ។

**មាត្រា៦៥១** ._ ការជូនដំណឹងអំពីគ្រោះថ្នាក់

បុគ្គលគ្រប់រូប ត្រូវបញ្ឈប់សកម្មភាពដែលទាក់ទងនឹងគ្រោះថ្នាក់ ហើយរាយការណ៍ជាបន្ទាន់ទៅកាន់អាជ្ញាធរមានសមត្ថកិច្ច ឬក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន ក្នុងករណីមានគ្រោះថ្នាក់ដែលបង្កឡើងដោយសារធាតុគ្រោះថ្នាក់ ។ បុគ្គលគ្រប់រូបត្រូវចាត់វិធានការឱ្យបានត្រឹមត្រូវ ស្របតាមផែនការទប់ស្កាត់ និងឆ្លើយតបជាបន្ទាន់ ដើម្បីកាត់បន្ថយផលប៉ះពាល់ចំពោះសុខភាពមនុស្ស និងបរិស្ថាន ។

បុគ្គលគ្រប់រូបដែលពាក់ព័ន្ធដោយផ្ទាល់ទៅនឹងគ្រោះថ្នាក់ ត្រូវ៖

១- ជូនដំណឹងជាបន្ទាន់ទៅដល់សាធារណជនក្នុងតំបន់ អំពីហានិភ័យដល់សុខភាព ទ្រព្យសម្បត្តិ ឬបរិស្ថាន ។

២- ណែនាំសាធារណជនអំពីវិធានការកាត់បន្ថយហានិភ័យទាំងនោះ ។

# មាតិកាទី ៤
# ការគ្រប់គ្រងសំណល់
## ជំពូកទី ១
## បទប្បញ្ញត្តិទូទៅ

**មាត្រា៦៥២** ._ វិសាលភាព

មាតិកានេះ មានវិសាលភាពអនុវត្តចំពោះរាល់សកម្មភាពដែលពាក់ព័ន្ធនឹងការកាន់កាប់ ការដឹកជញ្ជូន ការគ្រប់គ្រង ការស្តុកទុក ការធ្វើប្រព្រឹត្តកម្ម ការបោះបង់ចោល ការចម្រាញ់ ឬការកែច្នៃសំណល់គ្រោះថ្នាក់ និងសំណល់រឹង នៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា៦៥៣** ._ តួនាទី និងភារកិច្ចរបស់ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន ដោយសហការជាមួយក្រសួង ស្ថាប័នមានសមត្ថកិច្ច ត្រូវទទួលខុសត្រូវក្នុងការគ្រប់គ្រងសំណល់គ្រោះថ្នាក់ និងសំណល់រឹង ស្របតាមក្រមនេះ និងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ ។

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន មានតួនាទី និងភារកិច្ច ដូចខាងក្រោមៈ

១- រៀបចំគោលនយោបាយ ផែនការយុទ្ធសាស្ត្រជាតិ និងលិខិតបទដ្ឋានគតិយុត្ត ពាក់ព័ន្ធទៅនឹងការគ្រប់គ្រងសំណល់គ្រោះថ្នាក់ និងសំណល់រឹង ដោយសហការជាមួយក្រសួង ស្ថាប័នមានសមត្ថកិច្ច និងអ្នកពាក់ព័ន្ធ ។

២- ផ្តល់ការណែនាំផ្នែកបច្ចេកទេស និងការអភិវឌ្ឍសមត្ថភាពដល់ក្រសួង ស្ថាប័នមានសមត្ថកិច្ច ដែលទទួលបន្ទុកក្នុងការគ្រប់គ្រងសំណល់គ្រោះថ្នាក់ និងសំណល់រឹង ។

៣- បញ្ជាក់ និងប្រគល់សិទ្ធិអំណាចដល់ក្រសួង ស្ថាប័នមានសមត្ថកិច្ច ដែលទទួលបន្ទុកគ្រប់គ្រងសំណល់គ្រោះថ្នាក់ និងសំណល់រឹង ។

៤- សម្របសម្រួលជាមួយអ្នកពាក់ព័ន្ធ និងក្រសួង ស្ថាប័នមានសមត្ថកិច្ចដើម្បីកៀរគរធនធានហិរញ្ញវត្ថុ មធ្យោបាយ និងសម្ភារៈ សម្រាប់គាំទ្រដល់ក្រសួង ស្ថាប័នមានសមត្ថកិច្ច ក្នុងការគ្រប់គ្រងសំណល់គ្រោះថ្នាក់ និងសំណល់រឹង ។

៥- គាំទ្រ និងសហការជាមួយក្រសួង ស្ថាប័នមានសមត្ថកិច្ច ដើម្បី ៖

- លើកកម្ពស់ការអប់រំ និងការយល់ដឹងអំពីការគ្រប់គ្រងសំណល់គ្រោះថ្នាក់ និងសំណល់រឹងដោយមានសុវត្ថិភាពនិងមិនប៉ះពាល់បរិស្ថាន ។

- លើកកម្ពស់កម្មវិធីកាត់បន្ថយការបង្កើត ការប្រើប្រាស់ឡើងវិញ និងការកែច្នៃសំណល់ និង

- លើកកម្ពស់ការប្រើប្រាស់ផលិតផលដែលបានកែច្នៃពីសំណល់ ។

៦- អង្កេតតាមដាន ធ្វើអធិការកិច្ច និងវាយតម្លៃលើការអនុវត្តការងាររបស់ក្រសួង ស្ថាប័នមានសមត្ថកិច្ច ដែលទទួលបន្ទុកលើការគ្រប់គ្រងសំណល់គ្រោះថ្នាក់ និងសំណល់រឹង ។

**មាត្រា៦៥៤ .**_ តួនាទី និងភារកិច្ចរបស់ក្រសួង ស្ថាប័នមានសមត្ថកិច្ច

រាជរដ្ឋាភិបាលកម្ពុជា ត្រូវរៀបចំលិខិតបទដ្ឋានគតិយុត្ត ដើម្បីកំណត់ពីតួនាទី និងភារកិច្ចរបស់ក្រសួង ស្ថាប័នមានសមត្ថកិច្ច និងរដ្ឋបាលថ្នាក់ក្រោមជាតិ ក្នុងការគ្រប់គ្រងសំណល់គ្រោះថ្នាក់ និងសំណល់រឹង ។

**មាត្រា៦៥៥ .**_ ការទទួលខុសត្រូវចំពោះការខូចខាត

បុគ្គលគ្រប់រូប ដែលបង្កើតសំណល់គ្រោះថ្នាក់ និងសំណល់រឹង ត្រូវទទួលខុសត្រូវចំពោះការខូចខាតដល់សុខភាពមនុស្ស ទ្រព្យសម្បត្តិ ឬបរិស្ថាន ។

## ជំពូកទី ២
## ការធ្វើចំណាត់ថ្នាក់សំណល់

**មាត្រា៦៥៦ .**_ ការរៀបចំលិខិតបទដ្ឋានគតិយុត្តស្តីពីការធ្វើចំណាត់ថ្នាក់សំណល់

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន ត្រូវរៀបចំលិខិតបទដ្ឋានគតិយុត្តស្តីពីការធ្វើចំណាត់ថ្នាក់សំណល់គ្រោះថ្នាក់ និងសំណល់រឹង ក្នុងរយៈពេល ១៨ (ដប់ប្រាំបី) ខែ ក្រោយពេលក្រមនេះចូលជាធរមាន ។

**មាត្រា៦៥៧ .**_ ការត្រួតពិនិត្យឡើងវិញ និងការធ្វើបច្ចុប្បន្នភាពចំណាត់ថ្នាក់សំណល់

លិខិតបទដ្ឋានគតិយុត្តស្តីពីការធ្វើចំណាត់ថ្នាក់សំណល់គ្រោះថ្នាក់ និងសំណល់រឹងនោះ ត្រូវត្រួតពិនិត្យឡើងវិញ និងធ្វើបច្ចុប្បន្នភាពរៀងរាល់៥ (ប្រាំ) ឆ្នាំម្តង ។

## ជំពូកទី៣
## ការគ្រប់គ្រងសំណល់រឹង

**មាត្រា៦៥៨** ._ ផែនការយុទ្ធសាស្ត្រជាតិស្តីពីការគ្រប់គ្រងសំណល់រឹង

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន ដោយសហការជាមួយក្រសួង ស្ថាប័នពាក់មានសមត្ថកិច្ច ត្រូវរៀបចំផែនការយុទ្ធសាស្ត្រជាតិស្តីពីការគ្រប់គ្រងសំណល់រឹង ដែលផ្តោតទៅលើការកាត់បន្ថយ ការប្រើប្រាស់ឡើងវិញ និងការកែច្នៃសំណល់រឹង ស្របទៅតាមបទប្បញ្ញត្តិនៃក្រមនេះ ។

**មាត្រា៦៥៩** ._ ការអនុវត្តផែនការយុទ្ធសាស្ត្រជាតិស្តីពីការគ្រប់គ្រងសំណល់រឹង

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន ត្រូវរៀបចំលិខិតបទដ្ឋានគតិយុត្ត ដើម្បីអនុវត្តផែនការយុទ្ធសាស្ត្រជាតិស្តីពីការគ្រប់គ្រងសំណល់រឹង ។

**មាត្រា៦៦០** ._ ការរៀបចំផែនការជាក់លាក់តាមវិស័យ

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន ដោយសហការជាមួយក្រសួង ស្ថាប័នមានសមត្ថកិច្ច ត្រូវរៀបចំផែនការជាក់លាក់តាមវិស័យនីមួយៗសម្រាប់គ្រប់គ្រងប្រភេទសំណល់រឹងនីមួយៗ ស្របតាមផែនការយុទ្ធសាស្ត្រជាតិស្តីពីការគ្រប់គ្រងសំណល់រឹង ។

ផែនការជាក់លាក់តាមវិស័យនីមួយៗ សម្រាប់ប្រភេទសំណល់រឹង ត្រូវដាក់បញ្ចូលគោលដៅសម្រាប់ការកាត់បន្ថយកំណើននៃបរិមាណសំណល់រឹង និងវិធានការកាត់បន្ថយ ការប្រើប្រាស់ឡើងវិញ និងការកែច្នៃសំណល់រឹង ។

**មាត្រា៦៦១** ._ ការអនុវត្តផែនការជាក់លាក់តាមវិស័យ

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន ត្រូវរៀបចំលិខិតបទដ្ឋានគតិយុត្ត ដើម្បីអនុវត្តផែនការគ្រប់គ្រងសំណល់រឹងជាក់លាក់តាមវិស័យនីមួយៗ ។

**មាត្រា៦៦២** ._ ការត្រួតពិនិត្យឡើងវិញ និងការធ្វើបច្ចុប្បន្នភាពផែនការគ្រប់គ្រងសំណល់រឹង

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន ដោយសហការជាមួយក្រសួង ស្ថាប័នមានសមត្ថកិច្ច ត្រូវត្រួតពិនិត្យឡើងវិញ និងធ្វើបច្ចុប្បន្នភាពផែនការគ្រប់គ្រងសំណល់រឹងយ៉ាងហោចណាស់រៀងរាល់១០ (ដប់) ឆ្នាំម្តង ។

## **ជំពូកទី៤**
## **ការគ្រប់គ្រងសំណល់គ្រោះថ្នាក់**

**មាត្រា៦៦៣**._ ការគ្រប់គ្រង និងការត្រួតពិនិត្យសំណល់គ្រោះថ្នាក់

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន ត្រូវរៀបចំលិខិតបទដ្ឋានគតិយុត្ត ស្តីពីការគ្រប់គ្រងសំណល់គ្រោះថ្នាក់ ។

**មាត្រា៦៦៤**._ កាតព្វកិច្ចក្នុងការស្តុកទុក ការគ្រប់គ្រង និងការបោះបង់ចោលសំណល់គ្រោះថ្នាក់

ម្ចាស់បង្កើតសំណល់គ្រោះថ្នាក់ ត្រូវស្តុកទុក គ្រប់គ្រង ធ្វើប្រព្រឹត្តកម្ម និងការបោះបង់ចោលសំណល់គ្រោះថ្នាក់ ស្របតាមបទប្បញ្ញត្តិនៃក្រមនេះ និងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ ។

ម្ចាស់បង្កើតសំណល់ ត្រូវទទួលខុសត្រូវលើការចំណាយលើការប្រមូល និងការបោះបង់ចោលសំណល់គ្រោះថ្នាក់ ។

## **មាតិកាទី៥**
## **ការត្រួតពិនិត្យការបំពុលទឹក**
## **ជំពូកទី១**
## **បទប្បញ្ញត្តិទូទៅ**

**មាត្រា៦៦៥**._ វិសាលភាព

មាតិកានេះ មានវិសាលភាពអនុវត្តចំពោះសកម្មភាព និងការគ្រប់គ្រងការបំពុលទឹកពីប្រភពជាក់លាក់ និងមិនជាក់លាក់នៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា៦៦៦**._ ការគ្រប់គ្រងការបំពុលទឹកពីប្រភពជាក់លាក់ និងមិនជាក់លាក់

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន ត្រូវទទួលបន្ទុកក្នុងការគ្រប់គ្រងការបំពុលទឹកពីប្រភពជាក់លាក់ និងមិនជាក់លាក់ ។

**មាត្រា៦៦៧**._ ការទទួលខុសត្រូវចំពោះការខូចខាត

បុគ្គលគ្រប់រូប ដែលបញ្ចេញសារធាតុបំពុលពីប្រភពជាក់លាក់ ចូលទៅក្នុងធនធានទឹកលើដី ឬក្រោមដី ឬធ្វើសកម្មភាពប្រើប្រាស់ដី ដែលបង្កឱ្យមានការបំពុលទឹកពីប្រភពមិនជាក់លាក់ ត្រូវទទួលខុសត្រូវចំពោះការខូចខាតដល់សុខភាពមនុស្ស ទ្រព្យសម្បត្តិ ឬបរិស្ថាន ។

## ជំពូកទី២
## អង្កេតតាមដាន និងការត្រួតពិនិត្យប្រភពបំពុលទឹកជាក់លាក់

**មាត្រា៦៦៨** ._ ការហាមឃាត់ការបញ្ចេញសារធាតុបំពុលពីប្រភពបំពុលទឹកជាក់លាក់

ត្រូវបានហាមឃាត់ ចំពោះការបញ្ចេញសារធាតុបំពុលពីប្រភពជាក់លាក់ ចូលទៅក្នុងទឹកលើដី ឬក្រោមដី លើកលែងតែមានការអនុញ្ញាតស្របតាមបទប្បញ្ញត្តិនៃក្រមនេះ និងច្បាប់និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ។

**មាត្រា៦៦៩** ._ ការទទួលខុសត្រូវចំពោះការធ្វើប្រព្រឹត្តកម្ម និងការបញ្ចេញចោលសារធាតុបំពុល

ម្ចាស់ឬប្រតិបត្តិករនៃប្រភពបំពុលជាក់លាក់ ត្រូវទទួលខុសត្រូវចំពោះការធ្វើប្រព្រឹត្តកម្ម និងការបញ្ចេញចោលសារធាតុបំពុល មុនពេលបញ្ចេញសារធាតុបំពុលចូលទៅក្នុងបរិស្ថាន ។

**មាត្រា៦៧០** ._ លិខិតអនុញ្ញាតក្នុងការបញ្ចេញចោល

ការបញ្ចេញចោលសារធាតុបំពុលពីប្រភពជាក់លាក់ចូលទៅក្នុងទឹកលើដី ឬក្រោមដី ត្រូវទទួលការអនុញ្ញាត ពីក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន ។

លិខិតអនុញ្ញាត ដែលចេញដោយក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន ៖

ក- ត្រូវមានកំណត់ស្តង់ដារបញ្ចេញចោល និង/ឬ លក្ខខណ្ឌតម្រូវក្នុងការត្រួតពិនិត្យស្របតាមបទប្បញ្ញត្តិស្តីពីស្តង់ដារបរិស្ថាននៃក្រមនេះ និងច្បាប់និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ ។

ខ- អាចកំណត់ និង/ឬ លក្ខខណ្ឌតម្រូវបន្ថែមសម្រាប់ការត្រួតពិនិត្យ បញ្ចេញចោលសារធាតុបំពុលពីប្រភពជាក់លាក់ ដើម្បីការពារគុណភាពទឹកលើដី ឬក្រោមដីដែលទទួលសារធាតុបំពុល ឬ ប្រព័ន្ធអេកូឡូស៊ី និងដែនទឹកនៅតាមខ្សែទឹកខាងក្រោម ដែលអាចទទួលរងផលប៉ះពាល់ពីការបញ្ចេញចោល ។

គ- ត្រូវកំណត់លក្ខខណ្ឌតម្រូវ សម្រាប់ការអង្កេតតាមដាន និងការរៀបចំរបាយការណ៍ ដែលរួមមាន៖

១- ការអង្កេតតាមដានបរិមាណ គុណភាព ពេលវេលា និងរយៈពេល នៃការបញ្ចេញចោល ។

២- ការអង្កេតតាមដានគុណភាពទឹកដែលទទួលសារធាតុបំពុល និងដែនទឹកនៅតាមខ្សែទឹកខាងក្រោម ដែលទទួលរងផលប៉ះពាល់ពីការបញ្ចេញចោល។

៣- ការរក្សាទុកកំណត់ត្រា និងការរៀបចំរបាយការណ៍ស្តីពីព័ត៌មាននៃការអង្កេតតាមដានជូនក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន ។

៤- សូចនករសម្រាប់គោលបំណងនៃការអង្កេតតាមដាន ។

ឃ- ត្រូវមានសុពលភាពក្នុងរយៈពេល១ (មួយ)ឆ្នាំ លើកលែងតែមានការកំណត់ផ្សេងពីនេះ ។

ង- អាចកែសម្រួល ឬលុបចោល គ្រប់ពេលដោយគ្រាន់តែធ្វើការជូនដំណឹងជាលាយលក្ខណ៍អក្សរ ដោយបញ្ជាក់ពីមូលហេតុទៅកាន់ម្ចាស់ និងប្រតិបត្តិករនៃប្រភពជាក់លាក់ ។

**មាត្រា៦៧១** ._ លក្ខខណ្ឌបន្ថែម

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន ដោយសហការជាមួយក្រសួង ស្ថាប័នមានសមត្ថកិច្ច អាចរៀបចំ ៖

១- នីតិវិធីសម្រាប់ការដាក់ពាក្យស្នើសុំ និងការស្នើសុំបន្តសុពលភាពនៃលិខិតអនុញ្ញាត ។

២- កម្រិតស្តង់ដារ និងលក្ខខណ្ឌតម្រូវ សម្រាប់ត្រួតពិនិត្យការបញ្ចេញចោល ដោយប្រើប្រាស់កម្រិតកំហាប់ និង/ឬ កម្រិតនៃការផ្ទុកសារធាតុបំពុលចេញពីប្រភពជាក់លាក់ ដោយផ្អែកលើបច្ចេកវិទ្យាដ៏ប្រសើរបំផុតដែលអាចស្វែងរកបាន និងទម្លាប់អនុវត្តដ៏ប្រសើរបំផុតនៃការគ្រប់គ្រងបរិស្ថានដែលចំណាយថវិកាតិច ។

**មាត្រា៦៧២** ._ លក្ខណៈវិនិច្ឆ័យសម្រាប់ការផ្តល់វិញ្ញាបនបត្រសម្រាប់ប្រតិបត្តិករប្រភពបំពុលជាក់លាក់

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន ត្រូវរៀបចំលិខិតបទដ្ឋានគតិយុត្ត ស្ដីពីលក្ខណៈវិនិច្ឆ័យ និងកម្រិតនៃការចេញវិញ្ញាបនបត្រ សម្រាប់ប្រតិបត្តិករនៃប្រភពបំពុលជាក់លាក់ ដែលត្រូវដាក់បញ្ចូលនូវលក្ខខណ្ឌតម្រូវសម្រាប់ការអប់រំ ការបណ្ដុះបណ្ដាល បទពិសោធន៍ និងភាពស្ទាត់ជំនាញ ។

**មាត្រា៦៧៣** ._ ការអង្កេតតាមដានការអនុវត្តលក្ខខណ្ឌនៃលិខិតអនុញ្ញាត

ម្ចាស់ ឬប្រតិបត្តិករនៃប្រភពបំពុលជាក់លាក់ ដែលទទួលបានលិខិតអនុញ្ញាតពីក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន ត្រូវធ្វើការអង្កេតតាមដានការអនុវត្តលក្ខខណ្ឌនានាដែលបានកំណត់នៅក្នុងលិខិតអនុញ្ញាតនោះ ។

**មាត្រា៦៧៤** ._ វិញ្ញាបនបត្របញ្ជាក់ពីការវិភាគលើសំណាក និងការអង្កេតតាមដាន

ម្ចាស់ ឬ ប្រតិបត្តិករនៃប្រភពបំពុលជាក់លាក់ ដែលបានទទួលលិខិតអនុញ្ញាតពីក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន ត្រូវបញ្ជាក់ថាការជ្រើសរើសសំណាកយកមកវិភាគ និងការអង្កេតតាមដាន ត្រូវធ្វើឡើង ស្របតាមលក្ខខណ្ឌតម្រូវដូចមានកំណត់នៅក្នុងលិខិតអនុញ្ញាត និងលក្ខខណ្ឌផ្សេងទៀត ដែលកំណត់ដោយក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន ។

**មាត្រា៦៧៥** ._ លក្ខខណ្ឌតម្រូវក្នុងការជូនដំណឹង

ម្ចាស់ ឬ ប្រតិបត្តិករនៃប្រភពបំពុលជាក់លាក់ ដែលបានទទួលលិខិតអនុញ្ញាតពីក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន ត្រូវជូនដំណឹងជាបន្ទាន់ទៅក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន ក្នុងករណីដូចខាងក្រោម៖

១- មានការរំលោភបំពានទៅលើលក្ខខណ្ឌនៃលិខិតអនុញ្ញាត ។

២- មានបញ្ហាជាមួយឧបករណ៍វិភាគសំណាក ឬលទ្ធផលនៃការវិភាគសំណាក ។

៣- មានដំណើរការមិនប្រក្រតីនៃឧបករណ៍ត្រួតពិនិត្យការបំពុល ។

**មាត្រា៦៧៦** ._ បទបញ្ជាឱ្យធ្វើការអង្កេតតាមដាន

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន អាចធ្វើការអង្កេតតាមដាន ឬ ចេញបទបញ្ជាឱ្យប្រតិបត្តិករនៃប្រភពបំពុលជាក់លាក់ធ្វើការអង្កេតតាមដានការបញ្ចេញចោលសារធាតុបំពុលពីប្រភពជាក់លាក់ចូលទៅក្នុងទឹកលើដី ឬក្រោមដី ។

**មាត្រា៦៧៧** ._ ការអង្កេតតាមដានទឹកលើដី និងទឹកក្រោមដី

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន អាចធ្វើការអង្កេតតាមដានគុណភាពទឹកលើដី ឬក្រោមដី ។

**មាត្រា៦៧៨** ._ សំណាកសម្រាប់ការអង្កេតតាមដាន

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន អាចទទួល និងពិចារណាទៅលើសំណាកនៃការអង្កេតតាមដាន នៃប្រភពទឹកលើដី ឬក្រោមដី ដែលបុគ្គលណាមួយបានផ្តល់ឱ្យ ។

**មាត្រា៦៧៩** ._ ការវិភាគសំណាកនៃការអង្កេតតាមដាន

សំណាកនៃការអង្កេតតាមដានទាំងអស់ ត្រូវវិភាគដោយមន្ទីរពិសោធន៍របស់ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន ឬមន្ទីរពិសោធន៍ផ្សេងទៀត ដែលមានការទទួលស្គាល់ពីក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន ។

## ជំពូកទី៣
## ការត្រួតពិនិត្យប្រភពបំពុលទឹកមិនជាក់លាក់

**មាត្រា៦៨០** ._ ការទទួលខុសត្រូវចំពោះទម្លាប់នៃការគ្រប់គ្រងដ៏ប្រសើរបំផុត

ម្ចាស់ ឬ ប្រតិបត្តិករនៃសកម្មភាពប្រើប្រាស់ដី ដែលបង្កឱ្យមានការបំពុលពីប្រភពមិនជាក់លាក់ ត្រូវអនុវត្តទម្លាប់នៃការគ្រប់គ្រងដ៏ប្រសើរបំផុត ។

**មាត្រា៦៨១** ._ ប្រភេទនៃប្រភពបំពុលមិនជាក់លាក់ និងទម្លាប់នៃការគ្រប់គ្រងដ៏ប្រសើរបំផុត

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន ត្រូវរៀបចំលិខិតបទដ្ឋានគតិយុត្ត ស្តីពីប្រភេទនៃប្រភពបំពុលមិនជាក់លាក់ និងទម្លាប់នៃការគ្រប់គ្រងដ៏ប្រសើរបំផុត ដើម្បីកាត់បន្ថយការបំពុលទឹកសម្រាប់ប្រភេទនីមួយៗ ។

## ជំពូកទី៤
## ការប្រើប្រាស់ឡើងវិញនូវទឹកកខ្វក់ និងសំណល់

**មាត្រា៦៨២ ._** សំណល់ភក់ និងជីវសំណល់រឹង

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន ត្រូវរៀបចំលិខិតបទដ្ឋានគតិយុត្តស្ដីពីសំណល់ភក់ ឬជីវៈសំណល់រឹង រួមមាន៖

១- គោលការណ៍ណែនាំ ដើម្បីលើកទឹកចិត្តចំពោះការប្រើប្រាស់សំណល់ភក់ ឬជីវៈសំណល់រឹង ។

២- គោលការណ៍ណែនាំសម្រាប់ការប្រើប្រាស់សំណល់ភក់ ឬជីវៈសំណល់រឹងដោយការទទួលខុសត្រូវ និងដោយសុវត្ថិភាព ។

៣- វិធីសាស្ត្រក្នុងការប្រើប្រាស់សំណល់ភក់ និងជីវសំណល់រឹង ។

៤- គ្រឿងលើកទឹកចិត្តចំពោះការប្រើប្រាស់សំណល់ភក់ និងជីវៈសំណល់រឹង ដែលអនុវត្តក្នុងវិស័យកសិកម្ម ។

៥- គ្រឿងលើកទឹកចិត្តចំពោះការប្រើប្រាស់សំណល់ភក់ និងជីវៈសំណល់រឹងក្នុងការផលិតថាមពល និង

៦- ស្តង់ដារអប្បបរមាសម្រាប់កម្រិតនៃការធ្វើប្រព្រឹត្តកម្មទឹកកខ្វក់ ស្របតាមបទប្បញ្ញត្តិស្ដីពីស្តង់ដារបរិស្ថាននៃក្រមនេះ ។

**មាត្រា៦៨៣ ._** ការប្រើប្រាស់ទឹកឡើងវិញ

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន ត្រូវរៀបចំលិខិតបទដ្ឋានគតិយុត្តស្ដីពីការការប្រើប្រាស់ទឹកឡើងវិញ រួមមាន៖

១- គោលការណ៍ណែនាំដើម្បីលើកទឹកចិត្តចំពោះការប្រើប្រាស់ឡើងវិញនូវទឹកកខ្វក់ដែលបានធ្វើប្រព្រឹត្តកម្មរួច ។

២- គោលការណ៍ណែនាំសម្រាប់ការប្រើប្រាស់ឡើងវិញនូវទឹកកខ្វក់ដែលបានធ្វើប្រព្រឹត្តកម្មរួច ដោយការទទួលខុសត្រូវ និងដោយសុវត្ថិភាព ។

៣- កាតព្វកិច្ចរបស់ប្រតិបត្តិករនៃបរិក្ខារប្រព្រឹត្តកម្មទឹកកខ្វក់ ។

៤- កាតព្វកិច្ចរបស់ប្រតិបត្តិករនៃប្រព័ន្ធចែកចាយទឹក ។

៥- ការអនុវត្តចំពោះការប្រើប្រាស់ទឹកកខ្វក់ឡើងវិញ។

៦- ស្តង់ដារអប្បបរមាសម្រាប់កម្រិតនៃការធ្វើប្រព្រឹត្តកម្មទឹកកខ្វក់ វិធីសាស្ត្រ និងការចែកចាយសម្រាប់ការអនុវត្តការប្រើប្រាស់ទឹកកខ្វក់ឡើងវិញ ស្របតាមបទប្បញ្ញត្តិស្ដីពីស្តង់ដារបរិស្ថាន នៃក្រមនេះ ។

៧- គ្រឿងលើកទឹកចិត្តចំពោះការប្រើប្រាស់ទឹកកខ្វក់ឡើងវិញ។

## ជំពូកទី៥
## ការត្រួតពិនិត្យការបំពុលសមុទ្រ

**មាត្រា៦៨៤** ._ ការរៀបចំលិខិតបទដ្ឋានគតិយុត្តស្តីពីការត្រួតពិនិត្យការបំពុលសមុទ្រ

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន ត្រូវរៀបចំលិខិតបទដ្ឋានគតិយុត្តស្តីពីការត្រួតពិនិត្យការបំពុលសមុទ្រ នៅក្នុងដែនសមុទ្រនៃព្រះរាជាណាចក្រកម្ពុជា ដែលត្រូវដាក់បញ្ចូលនូវលក្ខខណ្ឌតម្រូវនៃការអង្កេតតាមដាន ការវាយតម្លៃ និងការរៀបចំរបាយការណ៍ ស្របតាមលិខិតូបករណ៍អន្តរជាតិទាក់ទងនឹងការត្រួតពិនិត្យការបំពុលសមុទ្រ ដែលព្រះរាជាណាចក្រកម្ពុជាជាភាគីហត្ថលេខី ។

**មាត្រា៦៨៥** ._ ការបំពុលពីនាវា

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន ដោយសហការជាមួយក្រសួង ស្ថាប័នមានសមត្ថកិច្ច ត្រូវរៀបចំលិខិតបទដ្ឋានគតិយុត្តបន្ថែមស្តីពីការទប់ស្កាត់ និងការកាត់បន្ថយឱ្យដល់កម្រិតអប្បបរមានូវការបំពុលពីនាវា ដែលកើតចេញពីប្រតិបត្តិការប្រចាំថ្ងៃ និងឧបទ្ទវហេតុ។

## មាតិកាទី៦
## ការត្រួតពិនិត្យការបំពុលខ្យល់
## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**មាត្រា៦៨៦** ._ វិសាលភាព

មាតិកានេះមានវិសាលភាពអនុវត្តចំពោះគ្រប់ប្រភពបំពុលខ្យល់ចល័ត និងអចល័ត នៅក្នុងព្រះរាជាណាចក្រកម្ពុជា លើកលែងតែប្រភពបំពុលតិចតួច ដូចមានចែងក្នុងលិខិតបទដ្ឋានគតិយុត្តស្តីពីស្តង់ដារគុណភាពខ្យល់នៃក្រមនេះ ។

**មាត្រា៦៨៧** ._ ការគ្រប់គ្រងការបំពុលខ្យល់

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន ត្រូវទទួលបន្ទុកលើការគ្រប់គ្រងការបំពុលខ្យល់ ។

**មាត្រា៦៨៨ .**_ការទទួលខុសត្រូវលើការខូចខាត

បុគ្គលគ្រប់រូប ដែលបង្កឱ្យមានការបំពុលខ្យល់ពីប្រភពចល័ត ឬអចល័ត ត្រូវទទួលខុសត្រូវលើការខូចខាតចំពោះសុខភាពមនុស្ស ទ្រព្យសម្បត្តិ ឬបរិស្ថាន ។

**មាត្រា៦៨៩ .**_ ស្តង់ដារគុណភាពខ្យល់

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន ត្រូវរៀបចំលិខិតបទដ្ឋានគតិយុត្តស្តីពីស្តង់ដារគុណភាពខ្យល់ ឱ្យស្របតាមបទប្បញ្ញត្តិស្តីពីស្តង់ដារបរិស្ថាននៃក្រមនេះ នៅក្នុងរយៈពេល១ (មួយ) ឆ្នាំ ក្រោយពេលក្រមនេះចូលជាធរមាន ។

លិខិតបទដ្ឋានគតិយុត្តស្តីពីស្តង់ដារគុណភាពខ្យល់ ត្រូវដាក់បញ្ចូល ៖

១- ស្តង់ដារគុណភាពខ្យល់បរិយាកាស ដោយផ្អែកលើព័ត៌មានផ្នែកវិទ្យាសាស្ត្រដ៏ប្រសើរបំផុតដែលអាចស្វែងរកបាន ។

២- ស្តង់ដារបញ្ចេញសារធាតុបំពុលខ្យល់ ។

៣- បញ្ជីនៃប្រភពបំពុលតិចតួច ដែលទទួលបានការលើកលែង ។

៤- បទប្បញ្ញត្តិសម្រាប់ការកាត់បន្ថយការបំពុលខ្យល់ក្នុងអគារ ។

**មាត្រា៦៩០ .**_ ការត្រួតពិនិត្យឡើងវិញ និងការធ្វើបច្ចុប្បន្នភាពលើស្តង់ដារគុណភាពខ្យល់

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថានត្រូវពិនិត្យឡើងវិញ និងធ្វើបច្ចុប្បន្នភាពនូវលិខិតបទដ្ឋានគតិយុត្តស្តីពីស្តង់ដារគុណភាពខ្យល់ រៀងរាល់១០(ដប់)ឆ្នាំម្តង និងត្រូវដាក់ឱ្យសាធារណជនអាចស្វែងរកបាន ដើម្បីចូលរួមផ្តល់មតិយោបល់ ។

**មាត្រា៦៩១ .**_ ការអភិវឌ្ឍបច្ចេកវិទ្យាកាត់បន្ថយ និងទប់ស្កាត់ការបំពុលខ្យល់

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន ត្រូវលើកកម្ពស់ និងគាំទ្រដល់កិច្ចការស្រាវជ្រាវ និងអភិវឌ្ឍបច្ចេកវិទ្យា ដើម្បីប្រើប្រាស់ក្នុងការកាត់បន្ថយ និងទប់ស្កាត់ការបំពុលខ្យល់ពីប្រភពចល័ត និងអចល័ត ។

## ជំពូកទី២
## ការបំពុលខ្យល់ពីប្រភពចល័ត

**មាត្រា៦៩២**._ ស្តង់ដារបញ្ចេញសារធាតុបំពុលខ្យល់ពីប្រភពចល័ត

ត្រូវហាមឃាត់ចំពោះការបញ្ចេញសារធាតុបំពុលខ្យល់ ចេញពីប្រភពចល័តចូលទៅក្នុងបរិយាកាស លើកលែងតែមានការអនុញ្ញាតស្របតាមបទប្បញ្ញត្តិនៃក្រមនេះ ។

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន ត្រូវរៀបចំស្តង់ដារសម្រាប់កម្រិតសារធាតុបំពុលខ្យល់អតិបរមា ដែលអនុញ្ញាតឱ្យបញ្ចេញដោយប្រភពចល័ត ។

**មាត្រា៦៩៣**._ ការដាក់កម្រិតចំពោះការនាំចូល ការប្រើប្រាស់ និងការផលិតលើសពីស្តង់ដារកំណត់

ត្រូវហាមឃាត់ ចំពោះការផលិត ឬការប្រើប្រាស់យានយន្ត និងគ្រឿងចក្រ ដែលបញ្ចេញសារធាតុបំពុលខ្យល់លើសពីស្តង់ដារកំណត់ ។

ក្រសួង ស្ថាប័នទទួលបន្ទុកគយ ត្រូវហាមឃាត់ការនាំចូលយានយន្ត និងគ្រឿងចក្រដែលបញ្ចេញសារធាតុបំពុលខ្យល់លើសពីស្តង់ដារកំណត់ ឬអាចនាំចូលយានយន្ត និងគ្រឿងចក្រទាំងនេះបាន ប៉ុន្តែត្រូវជួសជុល និងកែលម្អឱ្យស្របតាមស្តង់ដារបញ្ចេញការបំពុលខ្យល់ពីប្រភពចល័ត មុននឹងធ្វើការប្រើប្រាស់ ។

**មាត្រា៦៩៤**._ លិខិតបទដ្ឋានគតិយុត្តស្តីពីឥន្ធនៈ និងសារធាតុបន្ថែមនៅក្នុងឥន្ធនៈ

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន ត្រូវរៀបចំលិខិតបទដ្ឋានគតិយុត្តស្តីពីឥន្ធនៈ ឬ សារធាតុបន្ថែមនៅក្នុងឥន្ធនៈ ដើម្បីបំពេញបន្ថែមលើលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ ។ លិខិតបទដ្ឋានគតិយុត្តនេះ ត្រូវដាក់បញ្ចូលចំណុចដូចខាងក្រោម៖

១- លក្ខខណ្ឌតម្រូវសម្រាប់ការចុះបញ្ជីឥន្ធនៈ ឬសារធាតុបន្ថែមនៅក្នុងឥន្ធនៈ ដើម្បីកំណត់ពីកម្រិតនៃការបញ្ចេញសារធាតុបំពុលខ្យល់ដែលមិនបង្កគ្រោះថ្នាក់ដល់បរិស្ថាន ។

២- ឥន្ធនៈ ឬសារធាតុបន្ថែមនៅក្នុងឥន្ធនៈ ដែលប្រើប្រាស់នៅក្នុងប្រភពបំពុលចល័តមិននៅលើផ្លូវ ដែលត្រូវហាមឃាត់មិនឱ្យលក់ ដោយផ្អែកលើព័ត៌មានវិទ្យាសាស្ត្រដ៏ប្រសើរបំផុតដែលអាចស្វែងរកបាន ។

៣- លក្ខខណ្ឌលើកលែងចំពោះការហាមឃាត់ការប្រើប្រាស់ជាបណ្តោះអាសន្ននូវឥន្ធនៈ ឬសារធាតុបន្ថែមក្នុងឥន្ធនៈ ក្នុងករណីមាន គ្រោះមហន្តរាយធម្មជាតិ ការខូចខាតបំពង់ឧស្ម័ន ឬឧបករណ៍ចម្រាញ់ ឬព្រឹត្តិការណ៍ផ្សេងទៀត ដែលមិនអាចព្យាករណ៍ ឬទប់ស្កាត់បាន ។

៤- កំហាប់អតិបរមា ដែលឥន្ធនៈ ឬសារធាតុបន្ថែមនៅក្នុងឥន្ធនៈ ប្រើប្រាស់នៅក្នុងប្រភពចល័តមិននៅលើផ្លូវ និងនៅក្នុងគ្រឿងម៉ាស៊ីនយាន្តយន្ត ដែលទទួលបានការអនុញ្ញាតឱ្យលក់ពីក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន ។

៥- កំហាប់អតិបរមា ឬ អត្រានៃការបញ្ចេញនីត្រូសែនអុកស៊ីត សមាសភាគសរីរាង្គហើរ និងសារធាតុបំពុលខ្យល់ដទៃទៀត ដែលបញ្ចេញដោយប្រភពចល័ត ឬគ្រឿងម៉ាស៊ីនយានយន្ត ។

៦- លក្ខខណ្ឌតម្រូវចំពោះចំណុះស្តាន់ដ័រអតិបរមាសម្រាប់ឥន្ធនៈម៉ាស៊ូត ។

**មាត្រា៦៩៥** ._ កម្មវិធីទិញយកយានយន្តមកវិញ

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន ត្រូវរៀបចំលិខិតបទដ្ឋានគតិយុត្តស្តីពីកម្មវិធីលើកកម្ពស់ខ្យល់ស្អាត តាមរយៈការទិញយានយន្តចាស់ៗពីប្រជាពលរដ្ឋ ។ កម្មវិធីនេះ ត្រូវផ្តល់ការលើកទឹកចិត្តជាសាច់ប្រាក់ ដើម្បីឱ្យឈប់ប្រើប្រាស់យានយន្តចាស់ៗដែលបំពុលខ្យល់ ។

ការលើកទឹកចិត្តជាសាច់ប្រាក់ មិនត្រូវផ្អែកលើតម្លៃទីផ្សារនៃយានយន្តឡើយ ប៉ុន្តែត្រូវផ្អែក លើយានយន្តដែលកំពុងដំណើរការ ឬអាចបើកបរបាន ចំនួនគីឡូម៉ែត្រដែលយានយន្តនោះបានកត់ត្រា និងការខូចខាតជាចម្បងណាមួយចំពោះយានយន្តនោះ ។

## ជំពូកទី៣
## ការបំពុលខ្យល់ពីប្រភពអចល័ត

**មាត្រា៦៩៦** ._ ការហាមឃាត់ចំពោះការបញ្ចេញសារធាតុបំពុលខ្យល់ពីប្រភពអចល័ត

ការបញ្ចេញសារធាតុបំពុលខ្យល់អចល័តចូលទៅក្នុងបរិយាកាស ត្រូវបានហាមឃាត់ លើកលែងតែទទួលបានការអនុញ្ញាតពីក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន ។

**មាត្រា៦៩៧** ._ ការទទួលខុសត្រូវរបស់ម្ចាស់ និងប្រតិបត្តិករចំពោះការបញ្ចេញសារធាតុបំពុលខ្យល់

ម្ចាស់ ឬប្រតិបត្តិករ ត្រូវទទួលខុសត្រូវចំពោះសារធាតុបំពុលខ្យល់ទាំងអស់ ដែលបញ្ចេញ ចូលទៅក្នុងបរិយាកាស និងអនុវត្តតាមស្តង់ដារបញ្ចេញសារធាតុបំពុលខ្យល់ ដែលកំណត់ដោយក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន ។

**មាត្រា៦៩៨** ._ ស្តង់ដារបញ្ចេញសារធាតុបំពុលខ្យល់ទូទៅ

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន ត្រូវរៀបចំលិខិតបទដ្ឋានគតិយុត្តស្តីពីស្តង់ដារស្តង់ដារបញ្ចេញការបំពុលខ្យល់ទូទៅ ដោយផ្អែកលើបច្ចេកវិទ្យាដ៏ប្រើសើរបំផុតដែលអាចស្វែងរកបាន ដែលចំណាយថវិកាតិច សម្រាប់ប្រភេទនានានៃប្រភពសារធាតុបំពុលខ្យល់អចល័ត ។

**មាត្រា៦៩៩** ._ ស្តង់ដារសម្រាប់លិខិតអនុញ្ញាតចំពោះប្រភពថ្មី ឬដែលមានស្រាប់

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន ត្រូវកំណត់ស្តង់ដារបញ្ចេញការបំពុលខ្យល់ពីប្រភពអចល័តនៅក្នុងលិខិតអនុញ្ញាត សម្រាប់អ្នកដាក់ពាក្យស្នើសុំ ដូចខាងក្រោម ៖

១- ចំពោះប្រភពអចល័តថ្មី ឬដែលមានស្រាប់ ដែលមានស្តង់ដារទូទៅរួចហើយ ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន ត្រូវបញ្ចូលស្តង់ដារជាក់លាក់មួយនៅក្នុងលិខិតអនុញ្ញាត យ៉ាងហោចណាស់ ឱ្យមានលក្ខណៈតឹងរ៉ឹងដូចស្តង់ដារទូទៅ លើកលែងតែក្នុងករណីដូចមានចែងក្នុងមាត្រា៧០០ នៃក្រមនេះ ។

២- ចំពោះប្រភពអចល័តថ្មី ឬដែលមានស្រាប់ ដែលពុំទាន់មានស្តង់ដារទូទៅទេ ប៉ុន្តែក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន បានចេញលិខិតអនុញ្ញាតរួចហើយសម្រាប់ប្រភពអចល័តថ្មីក្នុងប្រភេទដូចគ្នា ដែលមានស្តង់ដារមួយ ដោយផ្អែកលើបច្ចេកវិទ្យាប្រសើរបំផុត ដែលអាចស្វែងរកបាន និងចំណាយថវិកាតិច ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន ត្រូវបញ្ចូលស្តង់ដារជាក់លាក់មួយ នៅក្នុងលិខិតអនុញ្ញាត យ៉ាងហោចណាស់ ឱ្យមានលក្ខណៈតឹងរ៉ឹងដូចស្តង់ដារដែលបានកំណត់នៅក្នុងលិខិតអនុញ្ញាតលើកមុនដែរ ។

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន អាចប្រើប្រាស់ស្តង់ដារ មួយដែលតឹងរ៉ឹងជាងស្តង់ដារទូទៅនៅក្នុងលិខិតអនុញ្ញាត នៅក្នុងករណីដែលក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន បានកំណត់ថា ស្តង់ដារតឹងរ៉ឹងជាងមុននេះ មានភាពចាំបាច់ ដើម្បីសម្រេចបាននូវស្តង់ដារគុណភាពខ្យល់បរិយាកាស ដោយផ្អែកលើព័ត៌មានផ្នែកវិទ្យាសាស្ត្រប្រសើរបំផុតដែលអាចស្វែងរកបាន។

**មាត្រា៧០០** ._ ការលើកលែងចំពោះប្រភពដែលមានស្រាប់

ម្ចាស់ ឬ ប្រតិបត្តិករ នៃប្រភពបំពុលខ្យល់អចល័តដែលមានស្រាប់ អាចដាក់ពាក្យសុំការលើកលែងពីស្តង់ដារទូទៅ ឬស្តង់ដារដែលបានកំណត់ពីមុននៅក្នុងលិខិតអនុញ្ញាត ដោយផ្អែកលើបច្ចេកវិទ្យាដ៏ប្រសើរបំផុតដែលអាចស្វែងរកបាន ដែលចំណាយថវិកាតិច ។

ម្ចាស់ ឬ ប្រតិបត្តិករ ត្រូវបញ្ជាក់ពីហេតុផលសមរម្យក្នុងការប្រើប្រាស់ស្តង់ដារទាបជាងស្តង់ដារ ដូចមានចែងក្នុងកថាខណ្ឌខាងលើ ដោយហេតុថាបច្ចេកវិទ្យាប្រសើរបំផុតដែលចំណាយថវិកាតិចនោះ មិនអាចស្វែងរកបាន ឬត្រូវចំណាយថវិកាខ្ពស់ពេកសម្រាប់ប្រភពបំពុលដែលមានស្រាប់ជាក់លាក់នោះ ។

ក្នុងករណីក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន សម្រេចឱ្យប្រើប្រាស់ស្តង់ដារដែលទាបជាងមុននេះ ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន ត្រូវកំណត់ស្តង់ដារលើកលែង ដោយផ្អែកលើបច្ចេកវិទ្យាប្រសើរបំផុតដែលអាចស្វែងរកបាន ដែលចំណាយថវិកាតិច សម្រាប់ប្រភពដែលមានស្រាប់ជាក់លាក់នោះ ។

## ជំពូកទី៤
## លិខិតអនុញ្ញាតក្នុងការបញ្ចេញសារធាតុបំពុលខ្យល់ពីប្រភពអចល័ត

**មាត្រា៧០១** ._ ការដាក់ពាក្យសុំលិខិតអនុញ្ញាត

ម្ចាស់ ឬ ប្រតិបត្តិករនៃប្រភពបំពុលអចល័ត ត្រូវដាក់ពាក្យ ស្នើសុំលិខិតអនុញ្ញាតទៅក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន ដើម្បីបញ្ចេញសារធាតុបំពុលខ្យល់ទៅក្នុងបរិយាកាស ។ ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន ត្រូវផ្ញើសំណៅថតចម្លងមួយច្បាប់នៃពាក្យស្នើសុំនេះ ទៅក្រសួង ស្ថាប័នមានសមត្ថកិច្ច ។

បន្ទាប់ពីទទួលបានពាក្យស្នើសុំ ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន ត្រូវចេញលិខិតអនុញ្ញាតស្របតាមបទប្បញ្ញត្តិនៃក្រមនេះ ។ ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន ត្រូវផ្ញើសំណៅមួយច្បាប់នៃលិខិតអនុញ្ញាតទៅក្រសួង ស្ថាប័នមានសមត្ថកិច្ច ។

**មាត្រា៧០២** ._ នីតិវិធីក្នុងការដាក់ពាក្យស្នើសុំលិខិតអនុញ្ញាត

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន ត្រូវរៀបចំលិខិតបទដ្ឋានគតិយុត្តស្តីពីនីតិវិធីក្នុងការដាក់ពាក្យស្នើសុំ និងការដាក់ពាក្យស្នើសុំឡើងវិញ សម្រាប់លិខិតអនុញ្ញាតនៃប្រភពអចល័ត ។

ដំណើរការនៃការរៀបចំលិខិតបទដ្ឋានគតិយុត្ត ដូចមានចែងក្នុងកថាខណ្ឌខាងលើនេះ ត្រូវអនុញ្ញាតឱ្យមានការចូលរួមជាសាធារណៈ ស្របតាមបទប្បញ្ញត្តិនៃក្រមនេះ ។

**មាត្រា៧០៣** ._ លក្ខខណ្ឌតម្រូវនៃលិខិតអនុញ្ញាត

លិខិតអនុញ្ញាតសម្រាប់ការបញ្ចេញសារធាតុបំពុលខ្យល់ពីប្រភពអចល័ត ត្រូវដាក់បញ្ចូលចំណុច ដូចខាងក្រោម៖

១- ស្តង់ដារបញ្ចេញសារធាតុបំពុលខ្យល់ ដើម្បីសម្រេចបាននូវស្តង់ដារគុណភាពខ្យល់បរិកាស និងត្រូវផ្អែកលើបច្ចេកវិទ្យាប្រសើរបំផុតដែលអាចស្វែងរកបាន ដែលចំណាយថវិកាតិច ។

២- លក្ខខណ្ឌតម្រូវនានាសម្រាប់ការដំឡើង និងប្រតិបត្តិការនៃប្រព័ន្ធ ឬយន្តការ អង្កេតតាមដានការបញ្ចេញសារធាតុបំពុលខ្យល់ ។

៣- លក្ខខណ្ឌតម្រូវសម្រាប់ការរៀបចំរបាយការណ៍ស្តីពីលទ្ធផលនៃការអង្កេត តាមដានទៅក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន យ៉ាងហោចណាស់ រៀងរាល់៦(ប្រាំមួយ)ខែម្តង ។ របាយការណ៍ស្តីពីការអង្កេតតាមដាន ត្រូវកំណត់អំពីកម្រិតនៃការបំពុលខ្យល់លើសកម្រិតស្តង់ដារដែលបានកំណត់នៅក្នុងលិខិតអនុញ្ញាត។

៤- លក្ខខណ្ឌតម្រូវសម្រាប់ការរក្សាទុកនូវកំណត់ត្រានៃលទ្ធផលនៃការអង្កេតតាមដានការបញ្ចេញសារធាតុបំពុលខ្យល់ និងរបាយការណ៍ស្តីពីការអង្កេតតាមដានណាមួយដែលបានដាក់ជូនក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន ។ របាយការណ៍ និងព័ត៌មានដែលប្រើប្រាស់សម្រាប់រៀបចំរបាយការណ៍ទាំងនោះ ត្រូវរក្សាទុកក្នុងរយៈពេលយ៉ាងតិចបំផុត៥(ប្រាំ) ឆ្នាំ គិតចាប់ពីថ្ងៃដែលបានទទួលលទ្ធផលនៃការអង្កេតតាមដាន និងថ្ងៃដែលរបាយការណ៍ស្តីពីការអង្កេតតាមដាននោះ បានដាក់ជូនក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន ។

**មាត្រា៧០៤** ._ ប្រភពបំពុលខ្យល់ថ្មី និងដែលមានស្រាប់

លក្ខខណ្ឌតម្រូវដើម្បីទទួលបានលិខិតអនុញ្ញាត ក្នុងការបញ្ចេញសារធាតុបំពុលខ្យល់ ត្រូវអនុវត្តចំពោះទាំងប្រភពបំពុលខ្យល់អចល័តថ្មី និងដែលមានស្រាប់ ។

**មាត្រា៧០៥** ._ រយៈពេលនៃការដាក់ពាក្យសុំលិខិតអនុញ្ញាត

ការដាក់ពាក្យស្នើសុំលិខិតអនុញ្ញាត សម្រាប់ការបំពុលខ្យល់ពី ប្រភពបំពុលខ្យល់អចល័តថ្មី ឬដែលមានស្រាប់ មានរយៈពេលដូចខាងក្រោម ៖

១- រយៈពេល៩០ (កៅសិប) ថ្ងៃ មុនពេលចាប់ផ្តើមប្រតិបត្តិការគម្រោង ចំពោះគម្រោងនៅរាជធានីភ្នំពេញ ឬ

២- រយៈពេល១២០(មួយរយម្ភៃ)ថ្ងៃ មុនពេលចាប់ផ្តើមប្រតិបត្តិការគម្រោង ចំពោះគម្រោងនៅតាមបណ្តាខេត្ត ។

ក្នុងករណីដែលម្ចាស់ ឬ ប្រតិបត្តិករនៃប្រភពបំពុលខ្យល់អចល័តបានដាក់ពាក្យស្នើសុំលិខិតអនុញ្ញាត ក្នុងរយៈពេលដូចបានកំណត់ខាងលើនេះ ហើយក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថានមិនបានចេញលិខិតអនុញ្ញាត ឬ បដិសេធ មុនពេលការចាប់ផ្តើមប្រតិបត្តិការគម្រោងអភិវឌ្ឍ ម្ចាស់ ឬ ប្រតិបត្តិករនៃប្រភពបំពុលខ្យល់អចល័តនោះ អាចបន្តប្រតិបត្តិការគម្រោងបាន ដោយទទួលខុសត្រូវចំពោះហានិភ័យដោយខ្លួនឯង ។

ក្នុងករណីដែលម្ចាស់ ឬ ប្រតិបត្តិករនៃប្រភពបំពុលខ្យល់អចល័តនៅតែបន្តប្រតិបត្តិការគម្រោងរបស់ខ្លួនរហូតដល់ពេលដែលក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន ចេញនូវលិខិតអនុញ្ញាត ម្ចាស់ ឬ ប្រតិបត្តិករនោះ ត្រូវដំឡើង ឬអនុវត្តបច្ចេកវិទ្យា ឬវិធានការចាំបាច់នានា ដើម្បីបំពេញតាមស្តង់ដារនៃការបញ្ចេញសារធាតុបំពុលខ្យល់ ដែលមានមុនពេលចាប់ផ្តើមប្រតិបត្តិការគម្រោង ។

ក្នុងករណីដែលក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន បដិសេធក្នុងការផ្តល់លិខិតអនុញ្ញាត ម្ចាស់ ឬប្រតិបត្តិករនៃប្រភពបំពុលខ្យល់អចល័ត មិនត្រូវប្រតិបត្តិការគម្រោងនោះឡើយ ។

**មាត្រា៧០៦** ._ រយៈពេលសុពលភាពនៃលិខិតអនុញ្ញាត

លិខិតអនុញ្ញាតចំពោះប្រភពបំពុលខ្យល់អចល័ត មានសុពលភាពរយៈពេល៥ (ប្រាំ) ឆ្នាំ គិតចាប់ពីកាលបរិច្ឆេទនៃការចេញលិខិតអនុញ្ញាត ។

ម្ចាស់ ឬ ប្រតិបត្តិករនៃប្រភពបំពុលខ្យល់អចល័ត ត្រូវដាក់ពាក្យស្នើសុំបន្តសុពលភាពនៃលិខិតអនុញ្ញាតនោះសាជាថ្មី ក្នុងរយៈពេលយ៉ាងតិច៦(ប្រាំមួយ)ខែ មុនពេលលិខិតអនុញ្ញាតនោះអស់សុពលភាព ។

**មាត្រា៧០៧** ._ សិទ្ធិអំណាចក្នុងការកែសម្រួល និងលុបចោលលិខិតអនុញ្ញាត

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន អាចកែសម្រួល ឬ លុបចោលលិខិតអនុញ្ញាត សម្រាប់ប្រភពបំពុលអចល័តណាមួយបានគ្រប់ពេលវេលា ។

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន ត្រូវផ្តល់ហេតុផលជាលាយលក្ខណ៍អក្សរ ទៅឱ្យម្ចាស់ ឬ ប្រតិបត្តិករនៃប្រភពបំពុលខ្យល់អចល័ត ក្នុងករណីសម្រេចធ្វើការកែសម្រួល ឬ លុបចោលលិខិតអនុញ្ញាត ។

## ជំពូកទី៥
## ការគ្រប់គ្រង និងការត្រួតពិនិត្យ គុណភាពបរិយាកាស

**មាត្រា៧០៨ .**_ ការអង្កេតតាមដានគុណភាពខ្យល់បរិយាកាសសម្រាប់ប្រភពបំពុលខ្យល់អចល័ត

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន ត្រូវទទួលខុសត្រូវក្នុងការអង្កេតតាមដាន គុណភាពខ្យល់បរិយាកាស ដោយសហការជាមួយ ម្ចាស់ និង/ឬ ប្រតិបត្តិករនៃប្រភពបំពុលខ្យល់អចល័ត ។

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន ត្រូវរៀបចំលិខិតបទដ្ឋានគតិយុត្តស្តីពីនីតិវិធីសម្រាប់ការអង្កេតតាមដានគុណភាពខ្យល់បរិយាកាស ។

ម្ចាស់ ឬប្រតិបត្តិករនៃប្រភពបំពុលខ្យល់អចល័ត ដែលទទួលបានលិខិតអនុញ្ញាតពីក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន ត្រូវទទួលខុសត្រូវក្នុងការអនុវត្តតាមលក្ខខណ្ឌតម្រូវនៃលិខិតអនុញ្ញាត ។

**មាត្រា៧០៩ .**_ របាយការណ៍អង្កេតតាមដានប្រភពបំពុលខ្យល់អចល័ត

ម្ចាស់ ឬប្រតិបត្តិករនៃប្រភពបំពុលខ្យល់អចល័ត ដែលទទួលបានលិខិតអនុញ្ញាតពីក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន ត្រូវបញ្ជាក់នៅក្នុងរបាយការណ៍ស្តីពីការអង្កេតតាមដាន អំពីសំណាក និងការអនុវត្តការអង្កេតតាមដាន ស្របតាមលក្ខខណ្ឌតម្រូវនៃលិខិតអនុញ្ញាត និងលក្ខខណ្ឌដទៃទៀតដែលកំណត់ដោយក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន ។

**មាត្រា៧១០ .**_ កាតព្វកិច្ចក្នុងការរៀបចំរបាយការណ៍នៃប្រភពបំពុលខ្យល់អចល័តចំពោះលក្ខខណ្ឌតម្រូវក្នុងលិខិតអនុញ្ញាត

ម្ចាស់ ឬប្រតិបត្តិករនៃប្រភពបំពុលខ្យល់អចល័ត ដែលទទួលបានលិខិតអនុញ្ញាតពី ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន ត្រូវកំណត់អត្តសញ្ញាណឱ្យបានច្បាស់លាស់ នៅក្នុងរបាយការណ៍នៃការអង្កេតតាមដាន អំពីការបញ្ចេញសារធាតុបំពុលខ្យល់លើសពីកម្រិតដែលមានកំណត់នៅក្នុងលិខិតអនុញ្ញាត ។

ម្ចាស់ ឬប្រតិបត្តិករនៃប្រភពបំពុលខ្យល់អចល័ត ដែលទទួលបានអនុញ្ញាតពីក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន ត្រូវជូនដំណឹងដល់ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន ក្នុងករណីមានបញ្ហាជាមួយការធ្វើសំណាក ឬ ឧបករណ៍ត្រួតពិនិត្យការបំពុលមិនដំណើរការក្នុងរយៈពេលយ៉ាងយូរបំផុត ២៤(ម្ភៃបួន) ម៉ោង គិតចាប់ពីពេលដែលបានដឹងអំពីបញ្ហានេះ ។

ការរៀបចំបាយការណ៍នេះត្រូវធ្វើឡើង ក្នុងករណីដែលមានបញ្ហាទាក់ទងនឹងសំណាក និង ឧបករណ៍ត្រួតពិនិត្យការបំពុលមិនដំណើរការ ទោះបីបញ្ហានេះមិនបណ្តាលឱ្យមានការបញ្ចេញការបំពុលខ្យល់លើសស្តង់ដារកំណត់ក៏ដោយ ។

**មាត្រា៧១១** ._ កាតព្វកិច្ចក្នុងការរៀបចំរបាយការណ៍នៃប្រភពបំពុលខ្យល់អចល័តចំពោះការគំរាមកំហែងដល់បរិស្ថាន

ម្ចាស់ ឬប្រតិបត្តិករនៃប្រភពអចល័ត ដែលទទួលបានលិខិតអនុញ្ញាតពី ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន ត្រូវរាយការណ៍ អំពីការបំពានលើលិខិតអនុញ្ញាត ដែលអាចបង្កគ្រោះថ្នាក់ដល់បរិស្ថាន ទៅកាន់ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន ក្នុងរយៈពេលយ៉ាងយូរបំផុត២៤ (ម្ភៃបួន) ម៉ោង គិតចាប់ពីពេលដែលបានដឹងអំពីការបំពាននោះ ។

ការរាយការណ៍នេះ ត្រូវដាក់បញ្ចូល លក្ខណៈ និងភាពធ្ងន់ធ្ងរនៃការបំពាន ការគំរាមកំហែង ដែលអាចកើតឡើងចំពោះបរិស្ថាន និងវិធានការ កាត់បន្ថយផលប៉ះពាល់ដល់កម្រិតអប្បបរមានូវផលប៉ះពាល់ដែលបានបង្កឡើង ។

ម្ចាស់ ឬប្រតិបត្តិករនៃប្រភពបំពុលខ្យល់អចល័ត ដែលទទួលបានលិខិតអនុញ្ញាតពី ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន ត្រូវដាក់បញ្ជូនរបាយការណ៍ជាលាយលក្ខណ៍អក្សរ ទៅកាន់ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន ក្នុងរយៈពេលយ៉ាងយូរបំផុត៣(បី)ថ្ងៃ គិតចាប់ពីពេលដែលបានដឹងអំពីការបំពាននោះ ។

**មាត្រា៧១២** ._ ការអង្កេតតាមដានការបញ្ចេញសារធាតុបំពុលខ្យល់ពីប្រភពចល័ត

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន ដោយសហការជាមួយក្រសួង ស្ថាប័នមានសមត្ថកិច្ច ត្រូវទទួលខុសត្រូវការអង្កេតតាមដានការបញ្ចេញសារធាតុបំពុលខ្យល់ពីប្រភពចល័ត ។

ក្រសួង ស្ថាប័នទទួលបន្ទុបរិស្ថាន ដោយសហការជាមួយក្រសួង ស្ថាប័នមានសមត្ថកិច្ច ត្រូវរៀបចំលិខិតបទដ្ឋានគតិយុត្តិស្តីពីនីតិវិធីនៃការអង្កេតតាមដានការបញ្ចេញសារធាតុបំពុលខ្យល់ពីប្រភពចល័ត ។

**មាត្រា៧១៣** ._ វិធីសាស្ត្រសម្រាប់ការអង្កេតតាមដានការបំពុលខ្យល់ពីប្រភពចល័ត និងអចល័ត

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន ត្រូវរៀបចំលិខិតបទដ្ឋានគតិយុត្តស្តីពីវិធីសាស្ត្រសម្រាប់ការអង្កេតតាមដានការបំពុលខ្យល់ពីប្រភពចល័ត និងអចល័ត ។

**មាត្រា៧១៤**._ ការធ្វើតេស្តលើសំណាកនៃការបញ្ចេញសារធាតុបំពុលខ្យល់ពីប្រភពអចល័ត

ម្ចាស់ ឬប្រតិបត្តិករនៃប្រភពបំពុលខ្យល់អចល័ត ដែលទទួលបានលិខិតអនុញ្ញាតពីក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន ត្រូវអនុវត្តការធ្វើតេស្តលើសំណាក នៃការបញ្ចេញសារធាតុបំពុលខ្យល់ពីគ្រប់ចំណុចនៃការបញ្ចេញទាំងអស់ នៅក្នុងរយៈពេល១ (មួយ) ខែ បន្ទាប់ពីការចាប់ផ្តើមប្រតិបត្តិការនៃប្រភពបំពុលខ្យល់អចល័ត ដើម្បីផ្ទៀងផ្ទាត់ប្រតិបត្តិការឱ្យបានត្រឹមត្រូវនូវបច្ចេកវិទ្យា ឬយន្តការនៃការត្រួតពិនិត្យការបំពុលខ្យល់ ។

ម្ចាស់ ឬប្រតិបត្តិករនៃប្រភពបំពុលខ្យល់អចល័ត ត្រូវបញ្ជូនលទ្ធផលនៃការធ្វើតេស្តសំណាកនេះទៅក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន ។

**មាត្រា៧១៥**._ សំណាកនៃការអង្កេតតាមដានប្រភពបំពុលខ្យល់អចល័ត

សំណាកនៃការអង្កេតតាមដានណាមួយ ដែលបានផ្តល់ជូនក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន មិនត្រូវចាត់ទុកថាមានសុពលភាព ឬជឿជាក់បានឡើយ លើកលែងតែ មន្ទីរពិសោធន៍របស់ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន ឬ មន្ទីរពិសោធន៍ដទៃទៀត ដែលបានទទួលស្គាល់ពីក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន បានធ្វើការវិភាគ និងបញ្ជាក់លើសំណាកទាំងនោះ ។

**មាត្រា៧១៦**._ ថ្លៃចំណាយលើការវិភាគលើសំណាក

ម្ចាស់ ឬ ប្រតិបត្តិករនៃប្រភពបំពុលខ្យល់អចល័ត ត្រូវទទួលបន្ទុកលើការចំណាយលើការវិភាគសំណាក ។

**មាត្រា៧១៧**._ ការខកខានមិនបានបំពេញតាមស្តង់ដារប្រភពបំពុលខ្យល់អចល័ត

ក្នុងករណីក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថានរកឃើញថា មានការបញ្ចេញការបំពុលខ្យល់ពីប្រភពអចល័ត មិនបានបំពេញតាមស្តង់ដារដូចមានចែងក្នុងលិខិតបទដ្ឋានគិតយុត្តស្តីពីស្តង់ដារគុណភាពខ្យល់ ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថានត្រូវ៖

១- ចេញបទបញ្ជាជាលាយលក្ខណ៍អក្សរ ឱ្យម្ចាស់ ឬ ប្រតិបត្តិករ នៃប្រភពបំពុលខ្យល់អចល័ត ធ្វើការកែតម្រូវសកម្មភាពដែលបំពាននោះ នៅក្នុងរយៈពេលមួយសមរម្យ មិនឱ្យលើសពី៣០(សាមសិប)ថ្ងៃ និង/ឬ

២- ចេញបទបញ្ជាជាលាយលក្ខណ៍អក្សរ ឱ្យម្ចាស់ ឬប្រតិបត្តិករនៃប្រភពបំពុលខ្យល់អចល័ត បញ្ឈប់សកម្មភាពជាបណ្ដោះអាសន្ន រហូតដល់ពេលមានការកែតម្រូវចំពោះការបំពាន ក្នុងករណីដែលសកម្មភាពបំពាននោះអាចបង្កឱ្យមានការខូចខាតដល់បរិស្ថាន ។

**មាត្រា៧១៨ ._** ការគ្រប់គ្រង និងភាពអាចស្វែងរកបានទិន្នន័យគុណភាពខ្យល់

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន ត្រូវរក្សាទុកទិន្នន័យដែលពាក់ព័ន្ធទៅនឹងលទ្ធផលនៃការពិសោធន៍គុណភាពខ្យល់ ដើម្បីប្រើប្រាស់ក្នុងការវាយតម្លៃស្ថានភាពគុណភាពខ្យល់ ។

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន ត្រូវដាក់ឱ្យសាធារណៈជនអាចស្វែងរកបាននូវព័ត៌មានទាំងអស់ទាក់ទងនឹងស្ថានភាពនៃគុណភាពខ្យល់ ។

**មាត្រា៧១៩ ._** ការជូនដំណឹងជាសាធារណៈអំពីការគំរាមកំហែងដល់បរិស្ថាន

ក្នុងករណី ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន រកឃើញថា មានតំបន់ណាមួយទទួលរងផលប៉ះពាល់ដោយការបំពុលខ្យល់ ដែលអាចគំរាមកំហែងដល់បរិស្ថាន នោះក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន ត្រូវជូនដំណឹងដល់សាធារណជនអំពីគ្រោះថ្នាក់ទាំងនោះ សិក្សាអំពីប្រភពនៃការបំពុលខ្យល់នេះ និងចាត់វិធានការទប់ស្កាត់ការបំពុលខ្យល់ និងស្ដារគុណភាពខ្យល់ឡើងវិញ ។

## ជំពូកទី៦
## ការផ្ដល់វិញ្ញាបនបត្រឱ្យប្រតិបត្តិករ

**មាត្រា៧២០ ._** លក្ខណៈវិនិច្ឆ័យ និងការបញ្ជាក់

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន អាចរៀបចំលក្ខណៈវិនិច្ឆ័យ និង/ឬវិញ្ញាបនបត្រដែលត្រូវផ្ដល់ឱ្យម្ចាស់ ឬប្រតិបត្តិករនៃប្រភពបំពុលខ្យល់ ។

លក្ខណៈវិនិច្ឆ័យ និងវិញ្ញាបនបត្រ អាចដាក់បញ្ចូលនូវលក្ខខណ្ឌតម្រូវសម្រាប់ការអប់រំ ការបណ្ដុះបណ្ដាល បទពិសោធន៍ និងភាពស្ទាត់ជំនាញ ។

## ជំពូកទី៧
## ការបំពុលខ្យល់ឆ្លងដែន

**មាត្រា៧២១** ._ ការបំពុលខ្យល់ឆ្លងដែន

ក្នុងករណីដែលក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន មានហេតុផលជឿជាក់ថា ការបំពុលខ្យល់ដែលបានបញ្ចេញពីប្រទេសណាមួយបង្កឱ្យមានគ្រោះថ្នាក់ដល់បរិស្ថាន នៅក្នុងព្រះរាជាណាចក្រកម្ពុជា បន្ទាប់ពីទទួលបានរបាយការណ៍ ការស្ទាបស្ទង់ ឬសិក្សា ពីស្ថាប័នអន្តរជាតិដែលមានការទទួលស្គាល់ ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន ត្រូវសហការជាមួយក្រសួង ស្ថាប័នមានសមត្ថកិច្ច ដើម្បីអនុវត្តដំណើរការការទូត ដើម្បីជូនដំណឹង និងពិគ្រោះយោបល់ជាមួយប្រទេសដែលជាប្រភពនៃការបំពុលខ្យល់នោះ ដើម្បីស្វែងរកមធ្យោបាយក្នុងការកាត់បន្ថយផលប៉ះពាល់នៃសារធាតុបំពុលខ្យល់ទាំងនោះ ។

**មាត្រា៧២២** ._ ការបំពុលខ្យល់ដែលមានប្រភពនៅក្នុងព្រះរាជាណាចក្រកម្ពុជា

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន ត្រូវសហការជាមួយប្រទេសដែលទទួលរងការបំពុលខ្យល់ដែលមានប្រភពមកពីព្រះរាជាណាចក្រកម្ពុជា ដោយផ្អែកលើព័ត៌មានវិទ្យាសាស្ត្រប្រសើរបំផុតដែលអាចស្វែងរកបាន ដើម្បីស្វែងរកមធ្យោបាយក្នុងការកាត់បន្ថយផលប៉ះពាល់នៃសារធាតុបំពុលខ្យល់ទាំងនោះ ដែលបានបង្កគ្រោះថ្នាក់ដល់បរិស្ថាននៅក្នុងប្រទេសនោះ ។

**មាត្រា៧២៣** ._ សិទ្ធិក្នុងការធ្វើបដិការ

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន ត្រូវផ្តល់សិទ្ធក្នុងការធ្វើបដិការទាក់ទងនឹងការបំពុលខ្យល់ដែលមានប្រភពនៅក្នុងព្រះរាជាណាចក្រកម្ពុជា និងបានបង្កផលប៉ះពាល់ដល់ប្រទេសដទៃទៀត ដូចគ្នានឹងសិទ្ធិដែលប្រទេសនោះ ផ្តល់មកឱ្យព្រះរាជាណាចក្រកម្ពុជាដែរ ។

## ជំពូកទី៨
## សារធាតុបំផ្លាញស្រទាប់អូហ្សូន

**មាត្រា៧២៤** ._ ស្ថាប័នទទួលខុសត្រូវ

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន ត្រូវរៀបចំលិខិតបទដ្ឋានគតិយុត្ត ដើម្បីត្រួតពិនិត្យការប្រើប្រាស់សារធាតុបំផ្លាញស្រទាប់អូហ្សូន ។

**មាត្រា៧២៥** ._ ការត្រួតពិនិត្យឡើងវិញ និងការធ្វើបច្ចុប្បន្នភាពលើលិខិតបទដ្ឋានគតិយុត្ត

លិខិតបទដ្ឋានគតិយុត្តស្តីពីការត្រួតពិនិត្យការប្រើប្រាស់សារធាតុបំផ្លាញស្រទាប់អូហ្សូន ត្រូវត្រួតពិនិត្យឡើងវិញ និងធ្វើបច្ចុប្បន្នភាព រៀងរាល់៣ (បី) ឆ្នាំម្តង ។

# មាតិកាទី៧
# ការត្រួតពិនិត្យសំឡេង និងរំញ័រ
## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**មាត្រា៧២៦** ._ វិសាលភាព

មាតិកានេះមានវិសាលភាពអនុវត្តចំពោះការបញ្ចេញសំឡេង និងរំញ័រទាំងអស់ នៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា៧២៧** ._ ក្រសួង ស្ថាប័នទទួលខុសត្រូវ

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន ត្រូវទទួលខុសត្រូវលើការគ្រប់គ្រងការបញ្ចេញសំឡេង និងរំញ័រ ។

**មាត្រា៧២៨** ._ ការទទួលខុសត្រូវចំពោះការខូចខាត

បុគ្គលគ្រប់រូប ដែលបង្កឱ្យមានការបញ្ចេញសំឡេង ឬរំញ័រ ត្រូវទទួលខុសត្រូវចំពោះការខូចខាតចំពោះសុខភាពមនុស្ស ទ្រព្យសម្បត្តិ និងបរិស្ថាន ។

## ជំពូកទី២
## ការគ្រប់គ្រងសំឡេង និងរំញ័រ

**មាត្រា៧២៩** ._ ការរៀបចំស្តង់ដារកម្រិតលើការបញ្ចេញសំឡេង និងរំញ័រ

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន ត្រូវរៀបចំលិខិតបទដ្ឋានគតិយុត្តស្តីពីស្តង់ដារកម្រិតលើការបញ្ចេញសំឡេង និងរំញ័រ ស្របតាមបទប្បញ្ញត្តិស្តីពីស្តង់ដារបរិស្ថាន នៃក្រមនេះ ។

ស្តង់ដារកម្រិតលើការបញ្ចេញសំឡេង និងរំញ័រ ត្រូវចាត់ថ្នាក់ការបញ្ចេញស្របតាមប្រភេទនៃប្រភពចល័ត និងអចល័ត រួមមាន រោងចក្រ គ្រឿងចក្រ បរិក្ខាសាងសង់ បរិក្ខារ៉ៃ គ្រឿងម៉ាស៊ីន និងយានយន្ត ឬនាវាផ្សេងទៀត ។

ស្តង់ដារកម្រិតលើការបញ្ចេញសំឡេង និងរំញ័រ អាចដាក់បញ្ចូលស្តង់ដារតឹងរ៉ឹងចំពោះកន្លែងធ្វើការ ឬតំបន់សាធារណៈដែលងាយទទួលរងផលប៉ះពាល់ដោយសំឡេង និងរំញ័រ រួមមានលំនៅដ្ឋាន សាលារៀន បណ្ណាល័យ មន្ទីរពេទ្យ សណ្ឋាគារ វត្តអារាម និងទីកន្លែងសាសនាផ្សេងទៀត ។

**មាត្រា៧៣០** ._ ការគោរពតាមស្តង់ដារ

បុគ្គលគ្រប់រូប ដែលបង្កឱ្យមានការបញ្ចេញសំឡេង និងរំញ័រ ត្រូវគោរពតាមស្តង់ដារបញ្ចេញសំឡេង និងរំញ័រ ដូចមានចែងក្នុងក្រមនេះ ។

**មាត្រា៧៣១** ._ លក្ខខណ្ឌតម្រូវក្នុងការអង្កេតតាមដាន

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន ត្រូវរៀបចំលិខិតបទដ្ឋានគតិយុត្តស្តីពី លក្ខខណ្ឌតម្រូវក្នុងការអង្កេតតាមដាន ដើម្បីគោរពតាមស្តង់ដារបញ្ចេញសំឡេង និងរំញ័រ ដូចមានចែងក្នុងក្រមនេះ ។

លក្ខខណ្ឌតម្រូវក្នុងការអង្កេតតាមដាន ត្រូវអនុវត្ត និងដាក់បញ្ចូលទៅក្នុងលិខិតអនុញ្ញាតរួមមាន លិខិតអនុញ្ញាតសាងសង់ដែលចេញដោយក្រសួង ស្ថាប័នមានសមត្ថកិច្ច សម្រាប់សកម្មភាព ឬគម្រោងដែលបង្កឱ្យមានផលប៉ះពាល់ដោយសំឡេង ឬរំញ័រ ។

## មាតិកាទី៨
## ការស្តារឡើងវិញនូវទីតាំងដែលទទួលរងការបំពុល
## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**មាត្រា៧៣២** ._ វិសាលភាព

មាតិកានេះ មានវិសាលភាពអនុវត្តចំពោះរាល់សកម្មភាព និងការគ្រប់គ្រងលើការស្តារឡើងវិញនូវផលប៉ះពាល់បរិស្ថានធ្ងន់ធ្ងរនៅទីតាំងបំពុលទាំងអស់នៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា៧៣៣** ._ ក្រសួង ស្ថាប័នទទួលបន្ទុក

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន ដោយសហការជាមួយក្រសួង ស្ថាប័នមានសមត្ថកិច្ច ត្រូវទទួលបន្ទុកក្នុងការគ្រប់គ្រងការស្តារឡើងវិញទីតាំងបំពុលទាំងអស់។

**មាត្រា៧៣៤**._ ការរៀបចំលិខិតបទដ្ឋានគតិយុត្តស្តីពីប្រភេទនៃទីតាំងបំពុល និងនីតិវិធីនៃការស្តារឡើងវិញ

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន ដោយសហកាជាមួយក្រសួង ស្ថាប័នមានសមត្ថកិច្ចផ្សេងទៀត ត្រូវរៀបចំលិខិតបទដ្ឋានគតិយុត្តស្តីពីប្រភេទនៃទីតាំងបំពុល និងនីតិវិធីនៃការស្តារឡើងវិញនូវទីតាំងបំពុល ស្របតាមបទប្បញ្ញត្តិនៃក្រមនេះ ។

លិខិតបទដ្ឋានគតិយុត្តស្តីពីប្រភេទនៃទីតាំងបំពុល និងនីតិវិធីនៃការស្តារឡើងវិញនូវទីតាំងបំពុល ត្រូវដាក់បញ្ចូល ៖

១- ការកំណត់អត្តសញ្ញាណទីតាំងបំពុល ។

២- ការសិក្សា និងការវាយតម្លៃហានិភ័យ ។

៣- លក្ខខណ្ឌតម្រូវនៃការស្តារឡើងវិញ ។

៤- នីតិវិធីសម្រាប់កំណត់ការទទួលខុសត្រូវ សម្រាប់ការស្តារទីតាំងបំពុលឡើងវិញ ។

៥- លក្ខណៈវិនិច្ឆ័យនៃទីតាំងបំពុល និងនីតិវធីសម្រាប់កំណត់អត្តសញ្ញាណទីតាំងបំពុល ។

៦- នីតិវិធីសម្រាប់ការសិក្សាទីតាំងបំពុល និងការវាយតម្លៃហានិភ័យ។

៧- នីតិវិធីស្តីពីការកំណត់លក្ខខណ្ឌតម្រូវសម្រាប់កិច្ចព្រមព្រៀងស្តារឡើងវិញចំពោះទីតាំងបំពុល ។

៨- នីតិវិធីសម្រាប់កំណត់លក្ខខណ្ឌតម្រូវក្នុងការផ្តល់មូលនិធិក្នុងការអនុវត្តការស្តារឡើងវិញទីតាំងបំពុល ។

៩- លក្ខខណ្ឌតម្រូវនៃគុណវុឌ្ឍិនៃទីប្រឹក្សាពិគ្រោះយោបល់ស្តារឡើងវិញទីតាំងបំពុល ។

១០- នីតិវិធីសម្រាប់ការអង្កេតតាមដានលើការស្តារឡើងវិញទីតាំងបំពុល ។

១១- នីតិវិធីសម្រាប់ការផ្តល់ការឯកភាពលើការបញ្ចប់ការស្តារឡើងវិញទីតាំងបំពុល ។

**មាត្រា៧៣៥**._ ការទទួលខុសត្រូវចំពោះការស្តារ ទីតាំងបំពុលឡើងវិញ

ការកំណត់អត្តសញ្ញាណបុគ្គលដែលទទួលខុសត្រូវចំពោះការស្តារឡើងវិញនូវទីតាំងបំពុលត្រូវស្របតាមបទប្បញ្ញត្តិស្តីពីសំណងការខូចខាត និងការស្តារឡើងវិញចំពោះការខូចខាតបរិស្ថាន នៃក្រមនេះ ។

**មាត្រា៧៣៦** ._ ព័ត៌មានស្តីពីទីតាំងបំពុល

រាល់ព័ត៌មានទាំងអស់ស្តីពីទីតាំងបំពុល ត្រូវដាក់ឱ្យសាធារណៈជនអាចស្វែងរកបាន ។

**មាត្រា៧៣៧** ._ ការចុះបញ្ជីទីតាំងបំពុល

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន ត្រូវរៀបចំបញ្ជីនៃទីតាំងបំពុល ដែលត្រូវដាក់បញ្ចូលនូវទីតាំងបំពុលទាំងអស់ និងលិខិតបញ្ជាក់ស្តីពីការបញ្ចប់ការស្តារឡើងវិញ ។

បញ្ជីនៃទីតាំងបំពុល និងលិខិតបញ្ជាក់ស្តីពីការបញ្ចប់ការស្តារឡើងវិញ ត្រូវដាក់ឱ្យសាធារណជនអាចស្វែងរកបាន ស្របតាមបទប្បញ្ញត្តិនៃក្រមនេះ ។

**មាត្រា៧៣៨** ._ ឯកសារយោងផ្នែកវិទ្យាសាស្ត្រ និងបច្ចេកទេសសម្រាប់ការស្តារទីតាំងបំពុលឡើងវិញ

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន ត្រូវរៀបចំលិខិតបទដ្ឋានគតិយុត្តិស្តីពីឯកសារយោងផ្នែកបច្ចេកទេស និងវិទ្យាសាស្ត្រ ដែលអាចប្រើប្រាស់ សម្រាប់ការរៀបចំការស្តារឡើងវិញនូវផលប៉ះពាល់បរិស្ថាននៅទីតាំងបំពុល ។

## ជំពូកទី២
## ការកំណត់អត្តសញ្ញាណ និងការសិក្សាទីតាំងបំពុល

**មាត្រា៧៣៩** ._ កាតព្វកិច្ចជូនដំណឹងរបស់អ្នកទទួលខុសត្រូវចំពោះទីតាំងបំពុល

រូបវន្តបុគ្គល ឬអ្នកដែលបានដឹងអំពីទីតាំងបំពុល ឬអ្នកដែលទទួលខុសត្រូវទីតាំងបំពុល ត្រូវរាយការណ៍ជាបន្ទាន់អំពីទីតាំងបំពុលទៅក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន ឬក្រសួង ស្ថាប័នមានសមត្ថកិច្ច។

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន ត្រូវជូនដំណឹងទៅ ក្រសួង ស្ថាប័នមានសមត្ថកិច្ច ក្នុងរយៈពេល៧ (ប្រាំពីរ) ថ្ងៃបន្ទាប់ពីទទួលបានព័ត៌មានអំពីទីតាំងបំពុល ។

**មាត្រា៧៤០ ._** ការសិក្សាទីតាំងបំពុល

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន ដោយមានការសហការជាមួយក្រសួង ស្ថាប័ន មានសមត្ថកិច្ច ត្រូវសិក្សាទីតាំងបំពុល និងធ្វើការវាយតម្លៃហានិភ័យ ដើម្បីការពារសុវត្ថិភាពទីតាំងបំពុល កាត់បន្ថយហានិភ័យដែលកើតឡើងភ្លាមៗ និងវាយតម្លៃផលប៉ះពាល់បរិស្ថាន កំណត់ទំហំនៃការបំពុលសម្រាប់ការស្តារឡើងវិញដែលអាចទទួលយកបាន និងជ្រើសរើសជម្រើសស្តារឡើងវិញដែលសមស្របបំផុត ។

## ជំពូកទី៣
## ការស្តារឡើងវិញ និងការអង្កេតតាមដាន

**មាត្រា៧៤១ ._** លក្ខខណ្ឌតម្រូវសម្រាប់ការស្តារឡើងវិញទីតាំងបំពុល

ការស្តារឡើងវិញនូវផលប៉ះពាលបរិស្ថាននៅទីតាំងបំពុល ត្រូវបំពេញតាមលក្ខខណ្ឌតម្រូវទីតាំងបំពុលដូចខាងក្រោម៖

១- កាតព្វកិច្ចទូទៅសម្រាប់ត្រួតពិនិត្យការបំពុល ដូចមានចែងក្នុងក្រមនេះ ។

២- ស្តង់ដារបរិស្ថាន ដូចមានចែងក្នុងក្រមនេះ ។

៣- កម្រិតនៃហានិភ័យដែលបានរៀបចំឡើងនៅក្នុងការវាយតម្លៃហានិភ័យ ។

**មាត្រា៧៤២ ._** កិច្ចព្រមព្រៀងក្នុងការស្តារឡើងវិញ

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន អាចតម្រូវឱ្យបុគ្គលគ្រប់រូបចុះកិច្ចព្រមព្រៀងស្តារឡើងវិញដោយមានលក្ខខណ្ឌតម្រូវជាក់លាក់សម្រាប់ការស្តារទីតាំងបំពុលឡើងវិញ ស្របតាមបទប្បញ្ញត្តិស្តីពីសំណាងការខូចខាត និងការស្តារឡើងវិញចំពោះការខូចខាតបរិស្ថាន នៃក្រមនេះ ។

**មាត្រា៧៤៣._** ការផ្តល់មូលនិធិសម្រាប់ការស្តារឡើងវិញទីតាំងបំពុល

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន ត្រូវកំណត់លក្ខខណ្ឌតម្រូវសម្រាប់ការផ្តល់មូលនិធិ ក្នុងការអនុវត្តការស្តារឡើងវិញនូវទីតាំងបំពុល ស្របតាមបទប្បញ្ញត្តិស្តីពីសំណាងការខូចខាត និងការស្តារឡើងវិញចំពោះការខូចខាតបរិស្ថាន នៃក្រមនេះ ។

**មាត្រា៧៤៤ ._** លក្ខខណ្ឌតម្រូវសម្រាប់ទីប្រឹក្សាពិគ្រោះយោបល់ទីតាំងបំពុល

ក្រសួង ស្ថាប័នទទួលបរិស្ថាន អាចរៀបចំគុណវុឌ្ឍិជាក់លាក់សម្រាប់ទីប្រឹក្សាពិគ្រោះយោបល់ស្តារឡើងវិញទីតាំងបំពុល ។

**មាត្រា៧៤៥** ._ ការអង្កេតតាមដានការស្តារឡើងវិញ

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន ដោយសហការជាមួយក្រសួង ស្ថាប័នមានសមត្ថកិច្ច ត្រូវធ្វើការអង្កេតតាមដានលើការស្តារឡើងវិញទីតាំងបំពុល ។

**មាត្រា៧៤៦** ._ ការឯកភាពលើការស្តារឡើងវិញ

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន ត្រូវផ្តល់ការឯកភាពលើការបញ្ចប់ការស្តារឡើងវិញទីតាំងបំពុល ស្របតាមលក្ខខណ្ឌតម្រូវសម្រាប់ស្តារទីតាំងបំពុលដូចមានចែងក្នុងក្រមនេះ ។

នីតិវិធីសម្រាប់ផ្តល់ការឯកភាពលើបញ្ចប់ការស្តារឡើងវិញទីតាំងបំពុល ត្រូវស្របតាមបទបប្បញ្ញត្តិស្តីពីសំណងការខូចខាត និងការស្តារឡើងវិញចំពោះការខូចខាតបរិស្ថាននៃក្រមនេះ ។

## មាតិកាទី៩
## ប្រព័ន្ធថ្នាក់ជាតិស្តីពីសារធាតុបំពុលដែលសាយភាយ និងផ្លាស់ទី
### ជំពូកទី១
### បទប្បញ្ញត្តិទូទៅ

**មាត្រា៧៤៧** ._ វិសាលភាព

មាតិកានេះ មានវិសាលភាពអនុវត្តចំពោះរាល់សារធាតុគីមី និងសារធាតុបំពុល ដែលបានបញ្ចេញទៅក្នុងខ្យល់ ទឹក និងដី ឬដែលបានដឹកជញ្ជូន ឬផ្លាស់ចេញពីទីតាំងណាមួយទៅទីតាំងណាមួយទៀត នៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា៧៤៨** ._ ក្រសួង ស្ថាប័នទទួលបន្ទុក

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន ត្រូវរៀបចំ និងទទួលខុសត្រូវក្នុងការគ្រប់គ្រងប្រព័ន្ធទិន្នន័យជាតិស្តីពីការសាយភាយ និងការបំលាស់ទីសារធាតុបំពុល សម្រាប់ព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា៧៤៩** ._ បញ្ជីឧស្សាហកម្ម

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន ដោយសហការជាមួយក្រសួង ស្ថាប័នទទួលបន្ទុករ៉ែ ត្រូវរៀបចំលិខិតបទដ្ឋានគតិយុត្តស្តីពីបញ្ជីឧស្សាហកម្មនៃប្រព័ន្ធទិន្នន័យជាតិស្តីពីការសាយភាយ និងការបំលាស់ទីសារធាតុបំពុល ដោយផ្អែកលើ៖

១- ចំណាត់ថ្នាក់ស្តង់ដារឧស្សាហកម្ម អន្តរជាតិនៃសកម្មភាពសេដ្ឋកិច្ចទាំងអស់ និង

២- សំណើសម្រាប់បញ្ជីស៊ីចង្វាក់គ្នានៃវិស័យដែលត្រូវរៀបចំរបាយការណ៍ នៃបញ្ជីប្រព័ន្ធជា សកលស្តីពីសារធាតុបំពុលដែលសាយភាយ និងផ្លាស់ទី របស់អង្គការសម្រាប់កិច្ចសហប្រតិបត្តិការ និងការអភិវឌ្ឍសេដ្ឋកិច្ច ។

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន ត្រូវធ្វើបច្ចុប្បន្នភាពលើបញ្ជីនៃឧស្សាហកម្មនៃប្រព័ន្ធទិន្នន័យជាតិស្តីពីការសាយភាយ និងការបំលាស់ទីសារធាតុបំពុលនេះ តាមការចាំបាច់ ។

**មាត្រា៧៥០** ._ បញ្ជីនៃសារធាតុបំពុលបរិស្ថាន

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន ត្រូវរៀបចំលិខិតបទដ្ឋានគតិយុត្តស្តីពីបញ្ជីនៃសារធាតុបំពុលបរិស្ថាននៃប្រព័ន្ធទិន្នន័យជាតិស្តីពីការសាយភាយ និងការបំលាស់ទីសារធាតុបំពុល ដោយផ្អែកលើសំណើសម្រាប់បញ្ជីស៊ីចង្វាក់គ្នានៃវិស័យដែលត្រូវរៀបចំរបាយការណ៍ នៃបញ្ជីប្រព័ន្ធជាសកលស្តីពីសារធាតុបំពុលដែលសាយភាយ និងផ្លាស់ទី របស់អង្គការសម្រាប់កិច្ចសហប្រតិបត្តិការ និងការអភិវឌ្ឍសេដ្ឋកិច្ច ។

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន ត្រូវធ្វើបច្ចុប្បន្នភាពលើបញ្ជី នៃសារធាតុបំពុលបរិស្ថាននៃប្រព័ន្ធទិន្នន័យជាតិស្តីពីការសាយភាយ និងការបំលាស់ទីសារធាតុបំពុល តាមការចាំបាច់ ។

## ជំពូកទី២
## ការគ្រប់គ្រងប្រព័ន្ធទិន្នន័យជាតិស្តីពីការសាយភាយ និងការបំលាស់ទីសារធាតុបំពុល

**មាត្រា៧៥១** ._ ទម្រង់បែបបទនៃការស្នើសុំបញ្ចេញសារធាតុបំពុលបរិស្ថាន

ម្ចាស់ ឬប្រតិបត្តិករ ដែល បានផលិត វេចខ្ចប់ នាំចូល នាំចេញ ដឹកជញ្ជូន ចែកចាយ ទិញ លក់ កាន់កាប់ ប្រើប្រាស់ គ្រប់គ្រង ស្តុកទុក ធ្វើប្រព្រឹត្តកម្ម ចម្រាញ់ កែច្នៃ បញ្ចេញ ឬ បោះបង់ចោលសារធាតុបំពុលបរិស្ថានលើសពីបរិមាណដែលបានកំណត់នៅក្នុងលិខិតបទដ្ឋានគតិយុត្តស្តីពីបញ្ជីនៃសារធាតុបំពុលបរិស្ថាននៃប្រព័ន្ធទិន្នន័យជាតិស្តីពីការសាយភាយ និងការបំលាស់ទីសារធាតុបំពុល ត្រូវបំពេញទម្រង់បែបបទស្នើសុំបញ្ចេញសារធាតុបំពុលបរិស្ថានសម្រាប់សារធាតុបំពុលបរិស្ថាននីមួយៗ

ដូចមានកំណត់នៅក្នុងបញ្ជីនៃសារធាតុបំពុលបរិស្ថាននៃប្រព័ន្ធទិន្នន័យជាតិស្តីពីការសាយភាយ និងការបំលាស់ទីសារធាតុបំពុលនោះ ។

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន ត្រូវរៀបចំលិខិតបទដ្ឋានគតិយុត្តស្តីពីនីតិវិធីនៃទម្រង់បែបបទនៃការស្នើសុំបញ្ចេញសារធាតុបំពុលបរិស្ថាន ។

**មាត្រា៧៥២** ._ បញ្ជីនៃសារធាតុបំពុលបរិស្ថាននៃប្រព័ន្ធទិន្នន័យជាតិស្តីពីការសាយភាយ និងការបំលាស់ទីសារធាតុបំពុល

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន ត្រូវរក្សាទុកបញ្ជីនៃសារធាតុបំពុលបរិស្ថាននៃប្រព័ន្ធទិន្នន័យជាតិស្តីពីការសាយភាយ និងការបំលាស់ទីសារធាតុបំពុល ដោយផ្អែកលើព័ត៌មានដែលបានបញ្ជូនមកកាន់ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន ស្របតាមមាត្រា៧៥១ នៃក្រមនេះ ។

## គន្ថីទី៧
## ការអប់រំ ស្រាវជ្រាវ និងយល់ដឹងពីបរិស្ថាន
## មាតិកាទោល
## ការអប់រំ ស្រាវជ្រាវ និងយល់ដឹងពីបរិស្ថាន
## ជំពូកទី១
## គោលនយោបាយ និងយុទ្ធសាស្ត្រអប់រំបរិស្ថាន

**មាត្រាថ្មី៧៥៣** ._វិសាលភាព

គន្ថីនេះមានវិសាលភាពអនុវត្តចំពោះគ្រឹះស្ថានស្រាវជ្រាវបែបសិក្សា អប់រំ បណ្តុះបណ្តាល ក្រសួង ស្ថាប័ន អង្គការសង្គមស៊ីវិល ដែលមានការពាក់ព័ន្ធក្នុងការផ្តល់ការអប់រំ បណ្តុះបណ្តាល ដើម្បីលើកកំពស់ការយល់ដឹងអំពីបរិស្ថាន ។

**មាត្រា៧៥៤**._ គោលនយោបាយអប់រំបរិស្ថាន

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន ត្រូវរៀបចំគោលនយោបាយអប់រំបរិស្ថានថ្នាក់ជាតិសម្រាប់បញ្ជ្រាបទៅក្នុងផែនការយុទ្ធសាស្ត្រ និងផែនការសកម្មភាពអភិវឌ្ឍន៍តាមវិស័យ ដើម្បីគាំទ្រដល់ការអភិវឌ្ឍដោយចីរភាព។

គោលនយោបាយអប់រំបរិស្ថានត្រូវពិនិត្យ និងកែសម្រួលឡើងវិញ យ៉ាងហោចណាស់ រៀងរាល់៥ឆ្នាំម្តង ។

**មាត្រា៧៥៥** ._ ផែនការយុទ្ធសាស្ត្រ និងផែនការសកម្មភាពថ្នាក់ជាតិ

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន ត្រូវរៀបចំផែនការយុទ្ធសាស្ត្រ និងផែនការសកម្មភាពអប់រំបរិស្ថាន ដោយកំណត់ក្របខណ្ឌអប់រំបរិស្ថាន និងការអភិវឌ្ឍដោយចីរភាព ដើម្បីផ្តល់ចំណេះដឹង និងជំនាញបរិស្ថាន ដល់ក្រសួង ស្ថាប័នមានសមត្ថកិច្ច ក្នុងការដាក់បញ្ចូលទៅក្នុងផែនការអភិវឌ្ឍតាមវិស័យនានា ។

**មាត្រា៧៥៦** ._ផែនការសកម្មភាពអប់រំបរិស្ថានតាមវិស័យ និងនៅថ្នាក់ក្រោមជាតិ

ក្រសួង ស្ថាប័នពាក់ព័ន្ធ និងរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវរៀបចំផែនការសកម្មភាពអប់រំបរិស្ថានឱ្យស្របតាមវិស័យជំនាញ និងស្ថានភាពបរិស្ថានក្នុងដែនសមត្ថកិច្ចរបស់ខ្លួន និងត្រូវរាយការណ៍ជូនក្រសួងស្ថាប័នទទួលបន្ទុកបរិស្ថាន ដើម្បីតម្កល់ទុកជាឯកសារ។

ក្រសួង ស្ថាប័នពាក់ព័ន្ធ និងរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវរៀបចំរបាយការណ៍ប្រចាំឆ្នាំស្តីពីការប្រតិបត្តិការងារអប់រំបរិស្ថានតាមវិស័យជំនាញ ជូនក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថានសម្រាប់តម្កល់ទុកជាឯកសារ ។

**មាត្រា៧៥៧**._ ផែនការសកម្មភាពអប់រំបរិស្ថាន

ក្រសួង ស្ថាប័នទទួលបន្ទុកអប់រំ ដោយសហការជាមួយ ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និង ក្រសួង ស្ថាប័នមានសមត្ថកិច្ច ត្រូវរៀបចំផែនការសកម្មភាពអប់រំបរិស្ថាន នៅក្នុងរយៈពេល ១៨ (ដប់ប្រាំបី) ខែ បន្ទាប់ពីក្រមនេះចូលជាធរមាន ។

ផែនការសកម្មភាពអប់រំបរិស្ថាន ត្រូវធ្វើបច្ចុប្បន្នភាព យ៉ាងហោចណាស់ ៥ (ប្រាំ) ឆ្នាំ ម្តង ។

**មាត្រាថ្មី៧៥៨** ._គណកម្មាធិការអន្តរក្រសួងដឹកនាំការងារអប់រំបរិស្ថាន និងការទទួលខុសត្រូវ

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន ត្រូវរៀបចំគណកម្មាធិការអន្តរក្រសួងដឹកនាំការងារអប់រំបរិស្ថាន ដែលមានភារកិច្ច និងតួនាទី ដូចខាងក្រោម៖

១- រៀបចំ និងគាំទ្រនូវកម្មវិធី និងកិច្ចប្រឹងប្រែងនានា ដោយធ្វើការសម្របសម្រួលជាមួយក្រសួងស្ថាប័នពាក់ព័ន្ធ ដើម្បីលើកកម្ពស់ការយល់ដឹងពីបរិស្ថានធម្មជាតិ ។

២- គាំទ្រដល់ការរៀបចំនិងផ្សព្វផ្សាយនូវគំរូកម្មវិធីសិក្សា ឯកសារអប់រំបរិស្ថាន និងកម្មវិធីបណ្តុះបណ្តាលនានាសម្រាប់ថ្នាក់មតេយ្យសិក្សា បឋមសិក្សា មធ្យមសិក្សា ឧត្តមសិក្សា និងក្រុមដែលមានចំណាប់អារម្មណ៍ផ្សេងទៀត រួមមានអ្នកធ្វើសេចក្តីសម្រេច និងអ្នករៀបចំគោលនយោបាយ ជាអាទិ៍ ។

៣- សម្របសម្រួល និងត្រួតពិនិត្យលើការផ្តល់កម្មសិក្សា និងកម្មវិធីអាហារូបករណ៍ ។

៤- សម្របសម្រួល និងត្រួតពិនិត្យលើការផ្តល់រង្វាន់លើកទឹកចិត្តស្តីពីសកម្មភាពសាលាមេត្រី បរិស្ថាន និងសកម្មភាពមេត្រីបរិស្ថាននៅតាមគ្រឹះស្ថានសិក្សាសាធារណៈ និងឯកជន ។

៥- សម្របសម្រួល និងតម្រង់ទិសការងារអប់រំបរិស្ថាន ។

៦- សម្របសម្រួល កៀគរ និងគ្រប់គ្រងមូលនិធិអប់រំបរិស្ថាន សម្រាប់គាំទ្រដល់គោលបំណងនៃការងារអប់រំបរិស្ថាន ។

## ជំពូកទី២
## ការអប់រំ និងបណ្តុះបណ្តាលបរិស្ថាន

**មាត្រា៧៥៩** ._ កម្មវិធីអប់រំ និងបណ្តុះបណ្តាលបរិស្ថាន

ក្រសួង ស្ថាប័នមានសមត្ថកិច្ច ត្រូវរៀបចំកម្មវិធីអប់រំ និងបណ្តុះបណ្តាលបរិស្ថាន ដោយបញ្ចូលនូវចំណេះដឹងបរិស្ថាន និងជំនាញពាក់ព័ន្ធ នឹងការអភិវឌ្ឍដោយចីរភាព ទៅក្នុងកម្មវិធីសិក្សាគោល ឬកម្មវិធីសិក្សាជំនាញវិជ្ជាជីវៈ នៅតាមអង្គភាពសាមីរបស់ខ្លួន។

**មាត្រា៧៦០** ._ ការបណ្តុះបណ្តាលទូទៅ

ក្រសួង ស្ថាប័នមានសមត្ថកិច្ច ត្រូវរៀបចំយន្តការ និងផែនការការងារ ដើម្បីដាក់បញ្ចូលខ្លឹមសារ វិធីសាស្ត្រ និងសម្ភារៈដែលទាក់ទងនឹងចំណេះដឹង និងជំនាញស្តីពីការអភិវឌ្ឍដោយចីរភាពទៅក្នុងការអប់រំ និងការបណ្តុះបណ្តាលបរិស្ថានដល់អង្គភាពចំណុះរបស់ខ្លួន ។

**មាត្រា៧៦១** ._ ការបណ្តុះបណ្តាលមន្ត្រី

ក្រសួង ស្ថាប័នមានសមត្ថកិច្ច ត្រូវរៀបចំផែនការ និងកម្មវិធីបណ្តុះបណ្តាលបរិស្ថានជាក់លាក់ពាក់ព័ន្ធនឹងកិច្ចគាំពារបរិស្ថាន ការអភិរក្សជីវៈចម្រុះ ការប្រើប្រាស់ធនធានធម្មជាតិដោយចីរភាព និងការអភិវឌ្ឍដោយចីរភាពសម្រាប់មន្ត្រីក្រោមឱវាទរបស់ខ្លួន ។

**មាត្រា៧៦២** ._ ការរៀបចំសម្ភារបណ្តុះបណ្តាល

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន ដោយសហការជាមួយក្រសួង ស្ថាប័នមានសមត្ថកិច្ច ត្រូវរៀបចំសម្ភារបណ្តុះបណ្តាល និងកម្មវិធីសិក្សាស្តីពីកិច្ចគាំពារបរិស្ថាន ការអភិរក្សជីវៈចម្រុះ ការប្រើប្រាស់ធនធានធម្មជាតិដោយចីរភាព និងការអភិវឌ្ឍដោយចីរភាព ។

**មាត្រា៧៦៣** ._ ការកំណត់ទំហំនៃតម្រូវការ

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន ដោយសហការជាមួយក្រសួង ស្ថាប័នមានសមត្ថកិច្ច ត្រូវកំណត់ទំហំនៃតម្រូវការ ដើម្បីផ្តល់ឱកាសចំពោះការអប់រំ និងការបណ្តុះបណ្តាលស្តីពីកិច្ចគាំពារបរិស្ថាន ការអភិរក្សជីវៈចម្រុះ ការប្រើប្រាស់ធនធាន ធម្មជាតិដោយចីរភាព និងការអភិវឌ្ឍដោយចីរភាពដល់សហគមន៍មូលដ្ឋាន សង្គមស៊ីវិល និងវិស័យឯកជន ។

អ្នកគ្រប់គ្រង អ្នកចាត់ការទូទៅ អ្នកតំណាងសហគ្រាសផលិត និងសេវាកម្មគ្រប់ប្រភេទ ត្រូវចូលរួមវគ្គបណ្តុះបណ្តាលជំនាញគ្រប់គ្រងបរិស្ថានឱ្យបានយ៉ាងតិចមួយដង ឬឱ្យបានរយៈពេលយ៉ាងតិចប្រាំបីម៉ោង ដោយមានការចេញវិញ្ញាបនបត្របញ្ជាក់ការសិក្សា ។

## ជំពូកទី៣
## បណ្ឌិតសភាជាតិអប់រំ និងស្រាវជ្រាវបរិស្ថាន និងធនធានធម្មជាតិ

**មាត្រា៧៦៤** ._ បណ្ឌិតសភាជាតិអប់រំនិងស្រាវជ្រាវបរិស្ថាន និងធនធានធម្មជាតិ

ត្រូវបង្កើតបណ្ឌិតសភាជាតិអប់រំនិងស្រាវជ្រាវបរិស្ថាន និងធនធានធម្មជាតិ ក្នុងរយៈពេល ១៨ (ដប់ប្រាំបី) ខែ ក្រោយពេលក្រមនេះចូលជាធរមាន ។

**មាត្រា៧៦៥** ._ ការបណ្តុះបណ្តាល និងការអភិវឌ្ឍសមត្ថភាពដល់មន្ត្រីរាជការ និងអ្នកពាក់ព័ន្ធ

បណ្ឌិតសភាជាតិអប់រំ និងស្រាវជ្រាវបរិស្ថាន ត្រូវផ្តល់ការអប់រំ ការសិក្សាស្រាវជ្រាវ ការបណ្តុះបណ្តាល និងការអភិវឌ្ឍសមត្ថភាពវិជ្ជាជីវៈ ពាក់ព័ន្ធនឹងជំនាញគ្រប់គ្រងបរិស្ថាន និងកិច្ចគាំពារបរិស្ថាន

ការអភិរក្សជីវៈចម្រុះ ការប្រើប្រាស់ធនធានធម្មជាតិដោយចីរភាព និងការអភិវឌ្ឍដោយចីរភាព ដល់មន្ត្រីរាជការ ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន ក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ ។

បណ្ឌិតសភាជាតិ អប់រំ និងស្រាវជ្រាវបរិស្ថាន ត្រូវផ្តល់ការបណ្តុះបណ្តាលចំណេះដឹងបរិស្ថានដល់បុគ្គលិក កម្មកររោងចក្រ សហគ្រាស និងក្រុមវិជ្ជាជីវៈផ្សេងៗទៀត ។ ម្ចាស់ ឬអ្នកទទួលខុសត្រូវគ្រប់គ្រងសហគ្រាស សិប្បកម្ម ផលិតកម្ម និងឧស្សាហកម្ម ត្រូវទទួលការបណ្តុះបណ្តាលជំនាញគ្រប់គ្រងបរិស្ថានអប្បបរមា យ៉ាងហោចណាស់ ១៥ម៉ោងសិក្សា ។

**មាត្រា៧៦៦** ._ ការផ្តល់វិញ្ញាបនបត្រ

បណ្ឌិតសភាជាតិ អប់រំនិងស្រាវជ្រាវបរិស្ថាន ត្រូវផ្តល់នូវកម្មវិធីបណ្តុះបណ្តាលកម្រិតវិញ្ញាបនបត្រវិជ្ជាជីវៈ ពាក់ព័ន្ធនឹងជំនាញគ្រប់គ្រងបរិស្ថាន កិច្ចគាំពារបរិស្ថាន ការអភិរក្សជីវៈចម្រុះ ការប្រើប្រាស់ធនធានធម្មជាតិដោយចីរភាព និងការអភិវឌ្ឍដោយចីរភាព ជូនមន្ត្រីរាជការថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ នាយកប្រចាំតំបន់ ឆ្មាំ មន្ត្រីរបៀងអភិរក្សជីវៈចម្រុះនិងតំបន់ការពារធម្មជាតិ គណៈកម្មាធិការគ្រប់គ្រងរួមគ្នា និងសមាជិកសហគមន៍ និងសាធារណជន ព្រមទាំងផ្តល់ជូនវិញ្ញាបនបត្រដល់អ្នកដែលបានបញ្ចប់ការបណ្តុះបណ្តាលនេះ ។

បណ្ឌិតសភាជាតិអប់រំ និងស្រាវជ្រាវបរិស្ថាន ត្រូវផ្តល់វិញ្ញាបនបត្របញ្ជាក់ការសិក្សាដល់ ម្ចាស់ ឬអ្នកទទួលខុសត្រូវគ្រប់គ្រងសហគ្រាស សិប្បកម្ម ផលិតកម្ម និងឧស្សាហកម្ម បុគ្គលិក កម្មកររោងចក្រ សហគ្រាស និងក្រុមវិជ្ជាជីវៈផ្សេងៗទៀត ស្របតាមមាត្រានេះ ។

**មាត្រា៧៦៧** ._ ការបណ្តុះបណ្តាលសម្រាប់ដោះស្រាយបណ្តឹងបរិស្ថាន

បណ្ឌិតសភាជាតិអប់រំ និងស្រាវជ្រាវបរិស្ថាន ត្រូវផ្តល់ការបណ្តុះបណ្តាលជំនាញគ្រប់គ្រង និងដោះស្រាយវិវាទបរិស្ថាន ទៅកាន់គណៈកម្មាធិការសន្ធានការីបរិស្ថាន និងធនធានធម្មជាតិថ្នាក់ឃុំ សង្កាត់ និងគណៈកម្មាធិការជាតិដោះស្រាយវិវាទបរិស្ថាន និងធនធានធម្មជាតិ ដូចមានចែងក្នុងគន្ថីទី ៩ នៃក្រមនេះ ។

**មាត្រា៧៦៨** ._ ការបង្កើតកម្មវិធីដទៃទៀតពាក់ព័ន្ធនឹងការអប់រំ ការស្រាវជ្រាវ និងការបណ្តុះបណ្តាលបរិស្ថាន

បណ្ឌិតសភាជាតិអប់រំនិងស្រាវជ្រាវបរិស្ថាន ត្រូវបង្កើតកម្មវិធីដទៃទៀត ពាក់ព័ន្ធនឹងការស្រាវជ្រាវគោលនយោបាយ វិទ្យាសាស្ត្រនិងបច្ចេកវិទ្យា ការអប់រំ និងការបណ្តុះបណ្តាលបរិស្ថាន ក្នុងករណីចាំបាច់ ។

## ជំពូកទី៤
## ការអប់រំបរិស្ថានក្នុងប្រព័ន្ធអប់រំ

**មាត្រា៦៦៩ .**_ លក្ខខណ្ឌតម្រូវសម្រាប់ចំណេះដឹង និងចីរភាពបរិស្ថាន

ក្រសួង ស្ថាប័នមានសមត្ថកិច្ច ដោយសហការជាមួយក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន ត្រូវរៀបចំលិខិតបទដ្ឋានគតិយុត្តស្តីពីនីតិវិធីដើម្បីដាក់បញ្ចូល លក្ខខណ្ឌតម្រូវសម្រាប់ចំណេះដឹង និងចីរភាពបរិស្ថាន ទៅក្នុងលក្ខណៈវិនិច្ឆ័យដែលមានគុណវុឌ្ឍិគ្រប់គ្រាន់ ដែលរួមមាន ការផ្តល់វិញ្ញាបនបត្រ និងការចេញវិញ្ញាបនបត្របញ្ជាក់ឡើងវិញសម្រាប់អ្នកមានជំនាញវិជ្ជាជីវៈ ក្នុងករណីចាំបាច់ ។

**មាត្រា៧៧០ .**_ សមាហរណកម្មចំណេះដឹងបរិស្ថានទៅក្នុងកម្មវិធីសិក្សាគ្រប់កម្រិត

ក្រសួង ស្ថាប័នទទួលបន្ទុកអប់រំ ដោយសហការជាមួយក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន ត្រូវ រៀបចំលិខិតបទដ្ឋានគតិយុត្តស្តីពីការដាក់បញ្ចូលបទបញ្ញត្តិស្តីពី កិច្ចគាំពារបរិស្ថាន ការអភិរក្សជីវៈចម្រុះ ការប្រើប្រាស់ធនធានធម្មជាតិដោយចីរភាព និងការអភិវឌ្ឍដោយចីរភាព ចូលទៅក្នុងកម្មវិធីសិក្សា អប់រំ និងបណ្តុះបណ្តាលសម្រាប់អ្នកសិក្សានៅគ្រប់កម្រិតសិក្សា ដែលរួមមាន ការអប់រំចំណេះទូទៅ ការអប់រំឧត្តមសិក្សា ការអប់រំក្រោយឧត្តមសិក្សា និងការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ ។

**មាត្រា៧៧១ .**_ អាទិភាពនៃការអភិវឌ្ឍ និងភាពរីកចម្រើនផ្នែកស្រាវជ្រាវវិទ្យាសាស្ត្រ និងបច្ចេកវិទ្យាបៃតង

ក្រសួង ស្ថាប័នទទួលបន្ទុកអប់រំ ដោយសហការជាមួយក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន ត្រូវរៀបចំលិខិតបទដ្ឋានគតិយុត្ត ស្តីពីការអប់រំ និងការបណ្តុះបណ្តាលពាក់ព័ន្ធនឹងកិច្ចគាំពារបរិស្ថាន ការអភិរក្សជីវៈចម្រុះ ការប្រើប្រាស់ធនធានធម្មជាតិដោយចីរភាព និងការអភិវឌ្ឍដោយចីរភាពដើម្បីឆ្លុះបញ្ចាំងពីអាទិភាពនៃការអភិវឌ្ឍ និងភាពរីកចម្រើនផ្នែកស្រាវជ្រាវវិទ្យាសាស្ត្រ និងបច្ចេកវិទ្យាបៃតង ។

**មាត្រា៧៧២ .**_ សម្ភារសិក្សាឧបទេស

ក្រសួង ស្ថាប័នទទួលបន្ទុកអប់រំ ដោយសហការជាមួយក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន ត្រូវរៀបចំ និង ធ្វើបច្ចុប្បន្នភាពសម្ភារសិក្សាឧបទេសដែលបានបោះពុម្ពផ្សាយ ដែលរួមមាន ឯកសារសិក្សារៀនសូត្រផ្នែកគរុកោសល្យ ផ្នែកអប់រំ និងវិធីសាស្ត្រ សៀវភៅសិក្សាគោល និងឯកសារពាក់ព័ន្ធដទៃទៀត ដែលគាំទ្រដល់ដំណើការបង្រៀន និងសិក្សា ពាក់ព័ន្ធនឹងកិច្ចគាំពារបរិស្ថាន ការអភិរក្សជីវៈចម្រុះ ការប្រើប្រាស់ធនធានធម្មជាតិចីរភាព និងការអភិវឌ្ឍដោយចីរភាព ។

**មាត្រា៧៧៣** ._ ប្រព័ន្ធគ្រប់គ្រងបរិស្ថាន

ក្រសួង ស្ថាប័នទទួលបន្ទុកអប់រំ ដោយសហការជាមួយក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន ត្រូវរៀបចំលិខិតបទដ្ឋានគតិយុត្តស្ដីពីនីតិវិធីដើម្បីគាំទ្រដល់ការបង្កើតប្រព័ន្ធគ្រប់គ្រងបរិស្ថាននៅតាមសាលារៀន គ្រឹះស្ថានឧត្ដមសិក្សា និងគ្រឹះស្ថានសិក្សាដទៃទៀត ។

**មាត្រា៧៧៤** ._ លក្ខណៈវិនិច្ឆ័យដែលមានគុណវុឌ្ឍិគ្រប់គ្រាន់

ក្រសួង ស្ថាប័នទទួលបន្ទុកអប់រំ ត្រូវរៀបចំលក្ខណៈវិនិច្ឆ័យដែលមានគុណវុឌ្ឍិគ្រប់គ្រាន់ទាក់ទងនឹងការអប់រំ និងការបណ្ដុះបណ្ដាលចំណេះដឹងពាក់ព័ន្ធនឹងកិច្ចគាំពារបរិស្ថាន ការអភិរក្សជីវៈចម្រុះ ការប្រើប្រាស់ធនធានធម្មជាតិដោយចីរភាព និងការអភិវឌ្ឍដោយចីរភាព សម្រាប់អ្នកសិក្សានៅគ្រប់កម្រិតភូមិសិក្សា ។

**មាត្រា៧៧៥** ._ សមត្ថភាពជំនាញ វិធីសាស្ត្រ និងវិធាន

ក្រសួង ស្ថាប័នទទួលបន្ទុកអប់រំ ដោយសហការជាមួយក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និង ក្រសួង ស្ថាប័នពាក់ព័ន្ធដទៃទៀត ត្រូវរៀបចំ និងគាំទ្របណ្ដាញជាតិស្ដីពីសមត្ថភាពជំនាញ វិធីសាស្ត្រ និងវិធាន នៃកិច្ចគាំពារបរិស្ថាន ការអភិរក្សជីវៈចម្រុះ ការប្រើប្រាស់ធនធានធម្មជាតិដោយចីរភាព និងការអភិវឌ្ឍដោយចីរភាព ។

## ជំពូកទី៥
## ការលើកកម្ពស់ការយល់ដឹងពីបរិស្ថាន

**មាត្រា៧៧៦** ._ ការយល់ដឹងអំពីបរិស្ថានរបស់ភាគីពាក់ព័ន្ធ

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន ត្រូវរៀបចំលិខិតបទដ្ឋានគតិយុត្តដែលផ្តល់ឱកាសឱ្យអ្នកពាក់ព័ន្ធចូលរួមក្នុងការរៀបចំគោលនយោបាយ និងគម្រោងនានា និងដំណើការធ្វើសេចក្តីសម្រេចពាក់ព័ន្ធនឹងផលប៉ះពាល់អវិជ្ជមាន ទាក់ទងទៅនឹងដំណើរការនៃកិច្ចគាំពារបរិស្ថាន ការអភិរក្សជីវៈចម្រុះ ការប្រើប្រាស់ធនធានធម្មជាតិដោយចីរភាព និងការអភិវឌ្ឍដោយចីរភាព ។

**មាត្រាថ្មី៧៧៧** ._ ផែនការសកម្មភាពអប់រំបរិស្ថាន

ក្រសួង ស្ថាប័នទទួលបន្ទុកអប់រំ ដោយសហការជាមួយក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងក្រសួង ស្ថាប័នមានសមត្ថកិច្ច ត្រូវរៀបចំផែនការសកម្មភាពអប់រំបរិស្ថាន ក្នុងរយៈពេល១៨(ដប់ប្រាំបី)ខែ ក្រោយពេលក្រមនេះចូលជាធរមាន ។

ផែនការសកម្មភាពអប់រំបរិស្ថាន ត្រូវធ្វើបច្ចុប្បន្នភាព យ៉ាងហោចណាស់ រៀងរាល់ ៥(ប្រាំ) ឆ្នាំម្តង ។

**មាត្រា៧៧៨** ._ យុទ្ធនាការយល់ដឹងបរិស្ថានជាសាធារណៈ

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន ដោយសហការជាមួយក្រសួង ស្ថាប័នមានសមត្ថកិច្ចត្រូវរៀបចំ យុទ្ធនាការយល់ដឹងបរិស្ថានជាសាធារណៈ ដើម្បីលើកកម្ពស់កិច្ចគាំពារបរិស្ថាន ការអភិរក្សជីវៈចម្រុះ ការប្រើប្រាស់ធនធានធម្មជាតិដោយចីរភាព និងការអភិវឌ្ឍដោយចីរភាព ។

**មាត្រា៧៧៩** ._ ការអប់រំបរិស្ថានក្រៅប្រព័ន្ធ

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន ដោយសហការជាមួយក្រសួង ស្ថាប័នមានសមត្ថកិច្ច ត្រូវរៀបចំកម្មវិធីអប់រំផ្សព្វផ្សាយចំណេះដឹងបរិស្ថាន តាមគ្រប់មធ្យោបាយ និងរូបភាពដល់ប្រជាពលរដ្ឋ សមាគមន៍ សហជីព និងក្រុមគោលដៅផ្សេងៗទៀតដែលកំពុងប្រតិបត្តិការងារនៅព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា៧៨០** ._ ការអប់រំបរិស្ថានឥតប្រព័ន្ធ

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន ដោយសហការជាមួយក្រសួងស្ថាប័នទទួលបន្ទុកការងារធម្មការ និងកិច្ចសាសនា ត្រូវរៀបចំ និងអនុវត្តកម្មវិធីអប់រំ ដើម្បីលើកកម្ពស់ការយល់ដឹងពីបរិស្ថាន ដោយបញ្ចូលបទប្បញ្ញត្តិបរិស្ថានទៅក្នុងពិធីកម្មសាសនា និងព្រឹត្តការណ៍សាសនា ។

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន ដោយសហការជាមួយក្រសួង ស្ថាប័នទទួលបន្ទុកការងារវប្បធម៌ ត្រូវរៀបចំ និងអនុវត្តកម្មវិធីអប់រំ ដើម្បីលើកកម្ពស់ការយល់ដឹងពីបរិស្ថាន ដោយដាក់បញ្ចូលបទប្បញ្ញត្តិបរិស្ថានទៅក្នុងភាពយន្ត តន្ត្រីចំរៀង និងទម្រង់នានានៃសិល្បៈបុរាណ និងសម័យ ។

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន ដោយសហការជាមួយក្រសួង ស្ថាប័នទទួលបន្ទុកការងារព័ត៌មាន និងឃោសនាការ ត្រូវរៀបចំ និងអនុវត្តកម្មវិធីអប់រំ ដើម្បីលើកកម្ពស់ការយល់ដឹងពីបរិស្ថានតាមគ្រប់មធ្យោបាយ និងរូបភាព ដោយដាក់បញ្ចូលបទប្បញ្ញត្តិបរិស្ថានទៅក្នុងការផ្សព្វផ្សាយតាមរលកធាតុអាកាស និងឯកសារបោះពុម្ពផ្សាយ  យ៉ាងតិច៥(ប្រាំ)ភាគរយនៃកម្មវិធីផ្សាយរបស់អង្គភាព ឬស្ថានីយ៍នីមួយៗ ។

**មាត្រា៧៨១** ._ សកម្មភាពបរិស្ថានប្រចាំឆ្នាំ

រដ្ឋបាលថ្នាក់ក្រោមជាតិ  គ្រឹះស្ថានសិក្សា សហគ្រាសផលិត និងសេវាកម្មនានា ត្រូវរៀបចំសកម្មភាពអប់រំផ្សព្វផ្សាយបរិស្ថាន និងសកម្មភាពបរិស្ថាននានា តាមគ្រប់មធ្យោបាយ និងរូបភាព ឱ្យស្របតាមប្រតិទិនបរិស្ថានប្រចាំឆ្នាំ ។

**មាត្រា៧៨២** ._ មជ្ឈមណ្ឌលធនធានបរិស្ថាន

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន ត្រូវរៀបចំឱ្យមានមជ្ឈមណ្ឌលធនធានបរិស្ថានថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ក្នុងទម្រង់ជាបណ្ណាល័យ សាលពិព័រណ៍ ឧទ្យាន សាលសោតទស្សន៍ ឬសាលពហុមុខងារ សម្រាប់ប្រើប្រាស់ជាប្រយោជន៍ដល់ការសិក្សា ការស្រាវជ្រាវ ការស្វែងយល់ និងការផ្សព្វផ្សាយ ចំណេះដឹង និងព័ត៌មានបរិស្ថានដល់សាធារណជន ។

## ជំពូកទី៦
## ការស្រាវជ្រាវ និងនវានុវត្តន៍

**មាត្រា៧៨៣** ._ ការរៀបចំកម្មវិធីបណ្តុះបណ្តាលគ្រូបង្រៀន និងគរុសិស្ស

ក្រសួង ស្ថាប័នទទួលបន្ទុកអប់រំ ត្រូវរៀបចំកម្មវិធីបណ្តុះបណ្តាលគ្រូបង្រៀន និងគរុសិស្ស ដោយផ្អែកលើបសិដ្ឋកម្មផ្នែកវិទ្យាសាស្ត្រ និងបច្ចេកវិទ្យានៃចំណេះដឹងដែលទាក់ទងនឹងកិច្ចគាំពារបរិស្ថាន ការអភិរក្សជីវៈចម្រុះ ការប្រើប្រាស់ធនធានធម្មជាតិដោយចីរភាព និងការអភិវឌ្ឍដោយចីរភាព ។

**មាត្រា៧៨៤**._ កម្មវិធីអប់រំ និងស្រាវជ្រាវ

ក្រសួង ស្ថាប័នទទួលបន្ទុកអប់រំ ដោយសហការជាមួយក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងក្រសួង ស្ថាប័នមានសមត្ថកិច្ច ត្រូវគាំទ្រចំពោះការរៀបចំ និងការអនុវត្តកម្មវិធីអប់រំ និងស្រាវជ្រាវចម្រុះ ដើម្បីស្វែងរកដំណោះស្រាយ សម្រាប់កិច្ចគាំពារបរិស្ថាន ការអភិរក្សជីវៈចម្រុះ ការប្រើប្រាស់ធនធានធម្មជាតិដោយចីរភាព និងការអភិវឌ្ឍដោយចីរភាព ។

**មាត្រា៧៨៥**._ ការធ្វើបច្ចុប្បន្នភាពឯកសារសម្ភារឧបទេសអប់រំ និងបណ្ដុះបណ្ដាល

ក្រសួង ស្ថាប័នទទួលបន្ទុកអប់រំ ត្រូវធ្វើបច្ចុប្បន្នភាពជាប្រចាំ ទៅលើសម្ភារឧបទេសសម្រាប់ការអប់រំ និងបណ្ដុះបណ្ដាល ដោយផ្អែកទៅលើចំណេះដឹងផ្នែកវិទ្យាសាស្ត្រថ្មីបំផុត ។

**មាត្រា៧៨៦**._ ធនធាន និងការគាំទ្រសម្រាប់ការសិក្សា ការស្រាវជ្រាវ និងទស្សនកិច្ចសិក្សា

ក្រសួង ស្ថាប័នទទួលបន្ទុកអប់រំ ត្រូវគាំទ្ររាល់ការសិក្សា និងការស្រាវជ្រាវ តាមរយៈការផ្ដល់ធនធានសម្រាប់ការស្រាវជ្រាវ និងឱកាសសម្រាប់ការសិក្សា និងការធ្វើទស្សនកិច្ចសិក្សា ។

**មាត្រា៧៨៧**._ ការអភិវឌ្ឍចំណេះដឹងស្ដីពីគោលដៅអភិវឌ្ឍដោយចីរភាព

ក្រសួង ស្ថាប័នទទួលបន្ទុកអប់រំ ដោយសហការជាមួយក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន ត្រូវរៀបចំគោលនយោបាយ និងផែនការ ដើម្បីធ្វើឱ្យមានសង្គតិភាពរវាងចំណេះដឹងអំពីកិច្ចគាំពារបរិស្ថាន និងការប្រើប្រាស់ធនធានចីរភាពជាមួយនឹងការអភិវឌ្ឍចំណេះដឹង និងជំនាញតាមវិស័យដទៃទៀតដែលពាក់ព័ន្ធទៅនឹងគោលដៅអភិវឌ្ឍដោយចីរភាពរបស់ព្រះរាជាណាចក្រកម្ពុជា តាមរយៈ ៖

១- កិច្ចសហការជាមួយអ្នកមានចំណេះដឹងជាលក្ខណៈប្រពៃណី ។

២- ការគាំទ្រចំពោះកិច្ចសហការជាអន្តរវិស័យ ការជំរុញឱ្យមានអន្តរកម្មរវាង វិទ្យាសាស្ត្រ ការអភិវឌ្ឍផ្នែកបច្ចេកវិទ្យា និងធុរកិច្ច និងការគាំទ្រចំពោះការអភិវឌ្ឍវិស័យបច្ចេកវិទ្យាសមស្របនានា ដែលមានផលប៉ះពាល់ជាអវិជ្ជមានតិចតួចចំពោះបរិស្ថាន ។

៣- ការគាំទ្រចំពោះការអប់រំទៅវិញទៅមករវាងការស្រាវជ្រាវ និងនវានុវត្តន៍ និង

៤- ការបង្កើតកម្មវិធីស្រាវជ្រាវដែលមានគោលដៅក្នុងការកំណត់អំពីដំណោះស្រាយនវានុវត្តន៍ សម្រាប់កិច្ចគាំពារបរិស្ថាន ការអភិរក្សជីវៈចម្រុះ ការប្រើប្រាស់ធនធានធម្មជាតិដោយចីរភាព និងការអភិវឌ្ឍដោយចីរភាព ។

## ជំពូកទី៧
## ការលើកទឹកចិត្តសកម្មភាពអប់រំបរិស្ថាន

**មាត្រា៧៨៨** ._ កម្មវិធីសាលាមេត្រីបរិស្ថាន

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន ដោយសហការជាមួយក្រសួង ស្ថាប័នទទួលបន្ទុកអប់រំ និងក្រសួង ស្ថាប័នមានសមត្ថកិច្ច ដែលមានគ្រឹះស្ថានសិក្សាក្រោមចំណុះ ត្រូវជំរុញការអនុវត្តកម្មវិធីសាលាមេត្រីបរិស្ថាន និងកម្មវិធីសកម្មភាពមេត្រីបរិស្ថានផ្សេងទៀត នៅតាមគ្រឹះស្ថានសិក្សាក្រោមចំណុះរបស់ខ្លួន ។

**មាត្រា៧៨៩** ._ ការផ្តល់រង្វាន់លើកទឹកចិត្តដល់សកម្មភាពមេត្រីបរិស្ថាននៅគ្រឹះស្ថានសិក្សា

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន ដោយសហការជាមួយក្រសួង ស្ថាប័នទទួលបន្ទុកអប់រំ និងក្រសួង ស្ថាប័នមានសមត្ថកិច្ច ដែលមានគ្រឹះស្ថានសិក្សាក្រោមចំណុះ ត្រូវរៀបចំទម្រង់នៃប្រភេទរង្វាន់លើកទឹកចិត្ត និងផ្តល់រង្វាន់លើកទឹកចិត្តកម្រិតថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ ដល់គ្រឹះស្ថានសិក្សាគ្រប់ភូមិសិក្សា ដែលមានស្នាដៃឆ្នើមក្នុងការអនុវត្តកម្មវិធីអប់រំបរិស្ថាន និងទម្រង់នានានៃសកម្មភាពមេត្រីបរិស្ថាន ។

**មាត្រា៧៩០** ._ សកម្មភាពចូលរួមការងារអប់រំ និងលើកកម្ពស់ការយល់ដឹងពីបរិស្ថាន

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន ដោយសហការជាមួយក្រសួង ស្ថាប័នមានសមត្ថកិច្ច ដែលមានគ្រឹះស្ថានសិក្សាក្រោមចំណុះ ត្រូវរៀបចំ និងផ្តល់រង្វាន់យុវជនបរិស្ថាន ដល់សិស្សានុសិស្សឆ្នើម ចាប់ពីថ្នាក់មតេយ្យសិក្សាដល់ថ្នាក់ទី១២ ដែលបានចូលរួមក្នុងសកម្មភាពលើកកម្ពស់ការយល់ដឹងបរិស្ថានក្នុងតំបន់របស់ខ្លួន ។

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និង ក្រសួង ស្ថាប័នមានសមត្ថកិច្ច ដែលមានគ្រឹះស្ថានសិក្សាក្រោមចំណុះ ត្រូវរៀបចំ និងផ្តល់រង្វាន់ដល់គ្រូបង្រៀនគ្រប់ភូមិសិក្សាចាប់ពីថ្នាក់មតេយ្យសិក្សាដល់ថ្នាក់មធ្យមសិក្សា ដែលមានស្នាដៃឆ្នើមក្នុងការបង្រៀន និងដឹកនាំសិស្សានុសិស្សធ្វើសកម្មភាពសិក្សាស្រាវជ្រាវបរិស្ថាន ឬសកម្មភាពការងារបរិស្ថាននៅតាមសាលារៀន និងសហគមន៍ជុំវិញសាលារៀន ។

## ជំពូកទី៨
## មូលនិធិអប់រំ និងស្រាវជ្រាវបរិស្ថាន

**មាត្រា៧៩១ ._** ការបង្កើតមូលនិធិអប់រំនិងស្រាវជ្រាវបរិស្ថាន

ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន ត្រូវរៀបចំបង្កើតមូលនិធិអប់រំនិងស្រាវជ្រាវបរិស្ថាន ដើម្បីបម្រើដល់ការងារអប់រំនិងបណ្តុះបណ្តាលបរិស្ថាន ឱ្យឆ្លើយតបទៅនឹងតម្រូវការនៃកិច្ចគាំពារបរិស្ថាន ទាំងនៅក្នុងព្រះរាជាណាចក្រកម្ពុជា និងក្នុងពិភពលោក ព្រមទាំងដើម្បីជួយសម្រួលដល់កិច្ចសហការ ការសម្របសម្រួល និងការចែករំលែកធនធានពីវិស័យសាធារណៈ និងឯកជន។

មូលនិធិអប់រំ និងស្រាវជ្រាវបរិស្ថាន ត្រូវជួយដល់ការបង្កើតប្រព័ន្ធអប់រំបរិស្ថានជឿនលឿនមួយ និងជួយជំរុញដល់ការបង្កើតភាពជាដៃគូរវាងក្រសួង ស្ថាប័នថ្នាក់ជាតិ រដ្ឋបាលថ្នាក់ក្រោមជាតិ វិស័យធុរកិច្ច វិស័យឧស្សាហកម្ម គ្រឹះស្ថានឧត្តមសិក្សា ក្រុមបរិស្ថានសហគមន៍មូលដ្ឋាន និងអង្គការអន្តរជាតិ ។

មូលនិធិអប់រំ និងស្រាវជ្រាវបរិស្ថាន ជាអង្គភាពទទួលជំនួយសប្បុរស និងមិនយកប្រាក់ចំណេញ ដែលចំណូលទាំងអស់សម្រាប់មូលនិធិនេះមិនត្រូវជាប់ពន្ធឡើយ។

**មាត្រា៧៩២ ._** គោលបំណងរបស់មូលនិធិអប់រំនិងស្រាវជ្រាវបរិស្ថាន

មូលនិធិអប់រំនិងស្រាវជ្រាវបរិស្ថាន ត្រូវបង្កើតឡើងក្នុងគោលបំណង៖

១- ទទួលយករាល់អំណោយទាំងអស់ពីវិស័យសាធារណៈ និងឯកជន ដើម្បីយកមកបម្រើដល់សកម្មភាពនិងសេវាកម្មការងារអប់រំបណ្តុះបណ្តាល និងស្រាវជ្រាវបរិស្ថាន ។

២- អនុវត្តរាល់សកម្មភាពអប់រំបរិស្ថាននានាដែលនឹងជួយដល់ការបណ្តុះស្មារតីភ្ញាក់រលឹកនិងការទទួលខុសត្រូវរបស់សាធារណជនលើបរិស្ថាន ក៏ដូចជាការបណ្តុះមនុស្សបរិស្ថានដ៏ល្អមួយ និងការបង្កើតប្រព័ន្ធអប់រំបរិស្ថានជឿនលឿនមួយ ។

៣- ចូលរួមជាមួយស្ថាប័នអន្តរជាតិ និងរូបវន្តបុគ្គលនានាក្នុងការសម្របសម្រួលនិងអនុវត្តសកម្មភាពដែលនឹងផ្តល់កាលានុវត្តន៍ភាពសម្រាប់ការអប់រំ បណ្តុះបណ្តាល និងស្រាវជ្រាវបរិស្ថាន ដើម្បីដោះស្រាយបញ្ហាបរិស្ថាន។

**មាត្រា៧៩៣ ._** ប្រភពចំណូលរបស់មូលនិធិអប់រំ និងស្រាវជ្រាវបរិស្ថាន

ប្រភពចំណូលរបស់មូលនិធិអប់រំ និងស្រាវជ្រាវបរិស្ថានមានដូចតទៅ៖

១- ចំណូលពីមូលនិធិបរិស្ថាន និងសង្គមដែលទទួលបាន ត្រូវចែករំលែកយ៉ាងតិច១០ (ដប់) ភាគរយ បញ្ចូលទៅក្នុងមូលនិធិអប់រំ និងស្រាវជ្រាវបរិស្ថាន ។

២- ចំណូលពីការផាកពិន័យបទល្មើសបរិស្ថាន ដែលទទួលបាន ត្រូវចែករំលែកយ៉ាងតិច១០ (ដប់) ភាគរយ បញ្ចូលទៅក្នុងមូលនិធិអប់រំ និងស្រាវជ្រាវបរិស្ថាន ។

៣- ចំណូលពីការប្រាក់របស់មូលនិធិអប់រំ និងស្រាវជ្រាវបរិស្ថានផ្ទាល់ ។

៤- អំណោយពីប្រជាពលរដ្ឋ សហគ្រាសឧស្សាហកម្ម សេវាកម្ម វិស័យឯកជន ឬពីសមាគមន៍និងក្រុមនានា ។

៥- អំណោយផ្សេងៗទៀតពីដៃគូអភិវឌ្ឍន៍ ដៃគូសហការ ។

**មាត្រា៧៩៤** ._ លក្ខខណ្ឌទទួលអំណោយ

រាល់ប្រភេទអំណោយជាថវិកា ឧបករណ៍បរិក្ខារ ឬមរតក អាចទទួលយកបានដោយ មូលនិធិអប់រំនិងស្រាវជ្រាវបរិស្ថាន ប្រសិនបើអំណោយទាំងនេះមិនមានជាប់លក្ខខណ្ឌ ភាពប្រទាំងប្រទើស ឬភ្ជាប់នូវកម្មវត្ថុ សម្រាប់ជាប្រយោជន៍របស់បុគ្គលណាមួយនាពេលបច្ចុប្បន្ននិងទៅអនាគត ប៉ុន្តែជាប្រយោជន៍សម្រាប់ មូលនិធិអប់រំនិងស្រាវជ្រាវបរិស្ថាន ។

**មាត្រា៧៩៥** ._ ការប្រើប្រាស់មូលនិធិអប់រំ និងស្រាវជ្រាវបរិស្ថាន

មូលនិធិអប់រំ និងស្រាវជ្រាវបរិស្ថាន គួរត្រូវបានប្រើប្រាស់ដើម្បីបម្រើឱ្យសកម្មភាពការងារមួយចំនួនដូចខាងក្រោម ៖

១- រៀបចំសិក្ខាសាលា ឬការបណ្តុះបណ្តាលបរិស្ថាន ។

២- អនុវត្តកម្មវិធីយុទ្ធនាការ និងព្រឹត្តការណ៍បរិស្ថាន ។

៣- ចងក្រងឯកសារអប់រំបរិស្ថាន ឯកសារបង្រៀនពីបរិស្ថាន ខិត្តប័ណ្ណផ្សព្វផ្សាយ កូនសៀវភៅ ។

៤- អនុវត្តលើការសិក្សាស្រាវជ្រាវ និងអភិវឌ្ឍន៍លើការងារអប់រំបរិស្ថាន ។

៥- ឧបត្ថម្ភធនទៅលើមធ្យោបាយអប់រំបរិស្ថាន ឬទីកន្លែងដែលរៀបចំព្រឹត្តការណ៍អប់រំបរិស្ថាន ។

៦- ឧបត្ថម្ភធនដល់អង្គភាព ឬភ្នាក់ងារអប់រំបរិស្ថានដែលបានជួលអ្នកអប់រំបរិស្ថានទៅបណ្តុះបណ្តាល ឬរៀបចំសិក្ខាសាលាបរិស្ថាន ។

៧- ឧបត្ថម្ភធនដល់កម្មវិធីអប់រំបរិស្ថាន ។

៨- ប្រើប្រាស់សម្រាប់បណ្តុះបណ្តាលដល់អ្នកអប់រំបរិស្ថាន ។

៩- សកម្មភាពផ្សេងទៀតដែលពាក់ព័ន្ធនឹងការលើកកម្ពស់ការអប់រំបរិស្ថាន ។

## ជំពូកទី៩
## ក្របខ័ណ្ឌប្រតិបត្តិការ និងសេចក្តីអនុញ្ញាត

**មាត្រា៧៩៦**._ ការគាំទ្រផ្នែកលិខិតបទដ្ឋានគតិយុត្ត ផ្នែកហិរញ្ញវត្ថុ និងផ្នែកអង្គការចាត់តាំង

ក្រសួង ស្ថាប័នមានសមត្ថកិច្ច ត្រូវរៀបចំបង្កើតលិខិតបទដ្ឋានគតិយុត្ត ដើម្បីកំណត់បរិធានច្បាប់ ហិរញ្ញវត្ថុ ការរៀបចំបង្កើតអង្គការចាត់តាំងសម្រាប់ការងារអប់រំ និងស្រាវជ្រាវផ្នែកបរិស្ថាន ។

លិខិតបទដ្ឋានគតិយុត្តទាំងនេះ ត្រូវដាក់បញ្ចូល ៖

១- ការកំណត់វិស័យអាទិភាព ជាក់លាក់ ដោយធ្វើការសហការជាមួយអ្នកពាក់ព័ន្ធ ។

២- ការបង្កើតយន្តការសម្របសម្រួលការអប់រំ និងការបណ្តុះបណ្តាល ស្តីពីកិច្ចការពារបរិស្ថាន ការអភិរក្សជីវៈចម្រុះ ការប្រើប្រាស់ធនធានធម្មជាតិដោយចីរភាព និងការអភិវឌ្ឍដោយចីរភាព រវាងក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ និងគ្រឹះស្ថានអប់រំ ចាប់ពីថ្នាក់បឋមសិក្សា រហូតដល់ថ្នាក់ក្រោយឧត្តមសិក្សា ។

៣- ការប្រើប្រាស់បរិធានផ្នែកសេដ្ឋកិច្ច និងអង្គការចាត់តាំង ដើម្បីលើកកម្ពស់ការដោះដូរការអប់រំ និងវិទ្យាសាស្ត្រជាអន្តរជាតិ និងកម្មវិធីអន្តរជាតិនានា សម្រាប់ការស្រាវជ្រាវ និងការអភិវឌ្ឍផ្នែកបច្ចេកវិទ្យាបរិស្ថាន និង

៤- ការបង្កើតធនធានព័ត៌មាន ដើម្បីគាំទ្រលើការអប់រំបរិស្ថាន ។

**មាត្រា៧៩៧** ._ សេចក្តីអនុញ្ញាត

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន ត្រូវទទួលបន្ទុកគ្រប់គ្រង ចាត់ចែង និងសម្របសម្រួលលើការអនុញ្ញាតឱ្យប្រើប្រាស់កញ្ចប់ថវិកាមូលនិធិអប់រំបរិស្ថាន ដើម្បីគាំទ្រដល់ការងារអប់រំ បណ្តុះបណ្តាល និងស្រាវជ្រាវបរិស្ថាន ដូចមានចែងក្នុងមាត្រាថ្មី៧៩៥ ស្តីពីការប្រើប្រាស់មូលនិធិអប់រំ និងស្រាវជ្រាវបរិស្ថាន នៃក្រមនេះ ។

## គន្ថីទី៨
## វិធានការសេដ្ឋកិច្ច គណនី ប្រាក់កម្រៃ និងមូលនិធិផ្នែកបរិស្ថាន

## មាតិកាទី១
## វិធានការសេដ្ឋកិច្ច និងគណនី
## ជំពូកទី១
## វិធានការសេដ្ឋកិច្ច

**មាត្រា៧៩៨**._ ការវាយតម្លៃលើឱកាស និងយន្តការដើម្បីលើកទឹកចិត្តឱ្យមានការវិនិយោគផ្នែកបរិស្ថាន និងធនធានធម្មជាតិ

ក្រសួង ស្ថាប័នទទួលបន្ទុកសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវដឹកនាំក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងក្រសួង ស្ថាប័នមានសមត្ថកិច្ចដទៃទៀត ដើម្បីធ្វើការវាយតម្លៃជាប្រចាំទៅលើឱកាស និងយន្តការលើកទឹកចិត្តឱ្យមានការវិនិយោគ ក្នុងកិច្ចការពារបរិស្ថាន និងការអភិរក្ស ការគ្រប់គ្រង និងការស្តារឡើងវិញនូវធនធានធម្មជាតិ ។

**មាត្រា៧៩៩** ._ វិធានការសេដ្ឋកិច្ចដើម្បីគាំទ្រគោលនយោបាយបរិស្ថាន

ក្រសួង ស្ថាប័នទទួលបន្ទុកសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដោយមានជំនួយពីក្រសួង ស្ថាប័ន ទទួលបន្ទុកបរិស្ថាន និងក្រសួង ស្ថាប័នមានសមត្ថកិច្ចដទៃទៀត ត្រូវរៀបចំលិខិតបទដ្ឋានគតិយុត្ត ស្តីពីវិធានការសេដ្ឋកិច្ច ក្នុងការគាំទ្រដល់ការអភិវឌ្ឍដោយចីរភាព កិច្ចការពារបរិស្ថាន និង ការអភិរក្ស ការគ្រប់គ្រង និងស្តារឡើងវិញនូវធនធានធម្មជាតិ និងបេតិកភណ្ឌវប្បធម៌ ស្របតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពិសេសដោយឡែកពាក់ព័ន្ធនឹងពន្ធ និងលទ្ធកម្ម ។

ការរៀបចំលិខិតបទដ្ឋានគតិយុត្ត ដូចមានចែងក្នុងកថាខណ្ឌខាងលើនេះ ត្រូវស្របតាមបទដ្ឋានទាំងឡាយដែលទទួលស្គាល់ជាអន្តរជាតិ និងត្រូវរៀបចំឱ្យមានវិធានការសេដ្ឋកិច្ច ពាក់ព័ន្ធនឹង ៖

១- ការដាក់បញ្ចូលស្តង់ដារពាក់ព័ន្ធ ការអនុវត្តការងារបរិស្ថាន និងសង្គម និងការគ្រប់គ្រងហានិភ័យ ទៅក្នុងការធ្វើសេចក្តីសម្រេចរបស់នីតិបុគ្គលពីវិស័យធុរកិច្ច និងហិរញ្ញវត្ថុ ។

២- ការវិនិយោគលើវិស័យឯកជន ពាក់ព័ន្ធនឹងបរិស្ថាន ។

៣- ការកាត់បន្ថយការកាប់បំផ្លាញព្រៃឈើ និងការលើកកម្ពស់ការអភិរក្សជីវៈចម្រុះ និងធនធានធម្មជាតិ ។

៤- ការផលិតធ្យូង និងអុសដោយចីរភាព ។

៥- រុក្ខាប្រមាញ់ និងជលផលដោយចីរភាព ។

៦- ការអភិរក្សទឹកសាប រួមមានការលើកកម្ពស់ការប្រើប្រាស់ធនធានទឹកប្រកបដោយ ប្រសិទ្ធផល និងការស្រាវជ្រាវដើម្បីបង្កើនគុណភាពទឹក និងកាត់បន្ថយសំណល់រាវ ។

៧- ការគ្រប់គ្រងធនធានធម្មជាតិនៅតាមសហគមន៍ រួមមានការលើកលែងអាករ លើតម្លៃបន្ថែម និងពន្ធដទៃទៀតលើប្រាក់ចំណូល ប្រាក់កម្រៃ ឬប្រាក់រួមវិភាគទានផ្សេងៗ ដែលទទួលបានពីការអនុវត្តការគ្រប់គ្រងរួមគ្នា ។

៨- ការអភិវឌ្ឍ និងការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធថាមពលដោយចីរភាព រួមមានអគ្គិសនីខ្នាតតូច ។

៩- ការលើកកម្ពស់ប្រព័ន្ធថាមពលពន្លឺព្រះអាទិត្យតាមផ្ទះ រួមមានបន្ទះស្រូបពន្លឺ ព្រះអាទិត្យ អាគុយនិងថ្មពិលប្រើប្រាស់ពន្លឺព្រះអាទិត្យ និងគ្រឿងដំឡើងដទៃទៀត ។

១០- ការប្រើប្រាស់ធនធានធម្មជាតិប្រកបដោយប្រសិទ្ធផលដោយឧស្សាហកម្ម រួមមានការប្រើប្រាស់ថាមពលស្អាត ប្រភេទនៃផលិតកម្មដែលមានប្រសិទ្ធផលធនធាន និងមានការបញ្ចេញកាបូនតិច និងការកាត់បន្ថយការបំពុលពីប្រភពឧស្សាហកម្ម និងកសិកម្ម ។

១១- ការប្រើប្រាស់បច្ចេកវិទ្យាបរិស្ថានប្រសើរបំផុតដែលអាចស្វែងរកបាន និងដែលបានផ្ទៀងផ្ទាត់រួច ។

១២- ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ និងសេវាកម្មនានា ក្នុងគោលបំណងការពារបរិស្ថាន ។

១៣- ការបែងចែកដោយសមធម៌ នូវប្រាក់ចំណូលបានមកពីយន្តការទូទាត់ការបញ្ចេញកាបូនដែលកំណត់ដោយក្រសួង ស្ថាប័នទទួលបន្ទុកអភិវឌ្ឍន៍ដោយចីរភាព ។

១៤- ការបង់ថ្លៃលើការផលិត ឬការថែទាំសេវាកម្មធនធានធម្មជាតិ និងប្រព័ន្ធអេកូឡូស៊ី ទៅកាន់រូបវន្តបុគ្គល និងសហគមន៍ ដោយសហការជាមួយរដ្ឋបាលថ្នាក់ក្រោមជាតិ ។

១៥- ការលើកកម្ពស់ការនាំចូល និងការទិញយានយន្តមេត្រីបរិស្ថាន និងទប់ស្កាត់ ការនាំចូលយានយន្តដែលមានផលប៉ះពាល់ខ្ពស់ដល់បរិស្ថាន ។

១៦- ការលើកកម្ពស់ការប្រើប្រាស់ថាមពលដោយចីរភាព រួមមានការគាំទ្រដល់ ការប្រើប្រាស់ក្នុងធុរកិច្ចនូវប្រភពថាមពលដោយចីរភាព ធុរកិច្ចដែលធ្វើពាណិជ្ជកម្ម ដំឡើង ឬផ្គត់ផ្គង់ផ្នែកបច្ចេកទេស ឬថែទាំឧបករណ៍ថាមពលដោយចីរភាព ធុរកិច្ចដែលនាំចូល ផលិត ចែកចាយ ឬលក់ឧបករណ៍ដែលផលិតថាមពលដោយចីរភាព ឬបង្កើន ប្រសិទ្ធផល ថាមពលដែលមានលក្ខណៈសម្បត្តិត្រឹមត្រូវ ស្របតាមបទប្បញ្ញត្តិពាក់ព័ន្ធនឹងសុខភាព សុវត្ថិភាព និង

បរិស្ថាន និងការនាំចូលឧបករណ៍សម្រាប់ផលិតថាមពលដោយចីរភាព ឬបង្កើនប្រសិទ្ធផលថាមពល ។

១៧- ការអភិរក្ស និងការការពារបេតិកភណ្ឌវប្បធម៌ ។

១៨- ការអភិរក្សថាមពល តាមរយៈការបង្កើនចំហេះ និងប្រសិទ្ធផលនៃការប្រើប្រាស់អគ្គិសនី ការទប់ស្កាត់ការបាត់បង់ថាមពល ការកែច្នៃសំណល់ថាមពល ការជំនួសមកវិញនូវថាមពលកកើតឡើងវិញ និងមធ្យោបាយនានានៃការអភិរក្សថាមពល ដែលបាន កំណត់ដោយក្រសួង ស្ថាប័នមានសមត្ថកិច្ច ។

១៩- វិធានការសេដ្ឋកិច្ចពាក់ព័ន្ធដទៃទៀត ដែលកំណត់ដោយក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន ដើម្បីសម្រេចបានគោលបំណងនៃក្រមនេះ ។

**មាត្រា៨០០ ._** សំណើសម្រាប់ក្រុមហ៊ុនសហកម្មសិទ្ធិឯកជន និងសាធារណៈ

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថានផ្ទាល់ ឬដោយសហការជាមួយក្រសួង ស្ថាប័នមានសមត្ថកិច្ច អាចចេញលិខិតស្នើសុំចំពោះសំណើសម្រាប់ក្រុមហ៊ុនសហកម្មសិទ្ធិ ឯកជន និងសាធារណៈដើម្បីរៀបចំហេដ្ឋារចនាសម្ព័ន្ធគាំទ្រផ្នែកបរិស្ថាន និងការអភិវឌ្ឍដោយចីភាព ស្របតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងក្រុមហ៊ុនសហកម្មសិទ្ធិឯកជន និងសាធារណៈ ។

ក្រសួង ស្ថាប័ន ទទួលបន្ទុកបរិស្ថាន អាចតម្រូវឱ្យអ្នកដាក់សំណើសុំ ដូចមានចែងក្នុងកថាខណ្ឌខាងលើនេះ ដាក់បញ្ចូលភស្តុតាងស្ដីពីធនធាន និងស្ថានភាពហិរញ្ញវត្ថុ ការសិក្សាទីផ្សារ ការប្រើប្រាស់ផែនការកំណត់ប្រភពដោយចីរភាព ការបង្ហាញពីការចូលវិភាគទានរបស់គម្រោង ចំពោះការអភិវឌ្ឍដោយចីរភាពដែលស៊ាំនឹងការបញ្ចេញកាបូនតិច និងសមត្ថភាពក្នុងការផ្ដល់ការគាំទ្រផ្នែកបច្ចេកទេសដែលកំពុងតែដំណើរការ ។

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន ត្រូវអនុវត្តតាមដំណើរការនៃលទ្ធកម្ម ដូចបានកំណត់នៅក្នុងគោលការណ៍ណែនាំនៃគោលនយោបាយពាក់ព័ន្ធនានា ស្ដីពីក្រុមហ៊ុនសហកម្មសិទ្ធិឯកជន និងសាធារណៈ ។

ក្រសួង ស្ថាប័នទទួលបន្ទុកសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវរៀបចំលិខិតបទដ្ឋានគតិយុត្ត ដើម្បីកំណត់ឱ្យមានការដាក់បញ្ចូលអ្នកតំណាងសហគមន៍មូលដ្ឋានមួយរូប ដែលរស់នៅក្នុងតំបន់ដែលរងផលប៉ះពាល់ខ្លាំងបំផុតដោយហេដ្ឋារចនាសម្ព័ន្ធ និងសេវាកម្មពាក់ព័ន្ធនានា ទៅក្នុងគណៈកម្មការលទ្ធកម្ម នៅពេលអនុវត្តការងារដេញថ្លៃលទ្ធកម្ម ស្របតាមបទប្បញ្ញត្តិស្ដីពីការចូលរួមជាសាធារណៈ និងសិទ្ធិទទួលបានព័ត៌មាននៃក្រមនេះ។

**មាត្រា៨០១ .**_ ធនាគារអភិរក្ស ឬធនាគារកាត់បន្ថយផលប៉ះពាល់បរិស្ថាន និងធនធានធម្មជាតិ

ធនាគារជាតិនៃកម្ពុជា និងក្រសួង ស្ថាប័នទទួលបន្ទុកសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដោយមាន ជំនួយពីក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន អាចបង្កើតធនាគារអភិរក្ស ឬធនាគារកាត់បន្ថយផលប៉ះពាល់បរិស្ថាន និងធនធានធម្មជាតិ។

ព្រះរាជាណាចក្រកម្ពុជា តាមរយៈក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន អាចចុះកិច្ចព្រមព្រៀងរកស៊ីរួមគ្នា ស្របតាមច្បាប់ និងលិខិតទដ្ឋានគតិយុត្តពាក់ព័ន្ធ ។

ធនាគារអភិរក្ស ឬធនាគារ កាត់បន្ថយផលប៉ះពាល់បរិស្ថាន និងធនធានធម្មជាតិ ត្រូវមានសមាសភាគីគ្រប់គ្រងរួមគ្នា ។

## ជំពូកទី២
## គណនី

**មាត្រា៨០២ .**_ ការបង់ថ្លៃលើសេវាកម្មប្រព័ន្ធអេកូឡូស៊ី

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន ត្រូវរៀបចំយន្តការសម្រាប់ការកំណត់បង់ថ្លៃ លើសេវាកម្មប្រព័ន្ធអេកូឡូស៊ី ទៅឱ្យរូបវន្តបុគ្គល សហគមន៍ ឬនីតិបុគ្គល ដែលបានចូលរួមចំណែកក្នុងការត្រួតពិនិត្យ ការពារ ឬគ្រប់គ្រងសេវាកម្មប្រព័ន្ធអេកូឡូស៊ី ដោយផ្អែកលើទិន្នន័យ និងស្ថិតិប្រសើរបំផុតដែលអាចស្វែងរកបាន ពាក់ព័ន្ធនឹងស្ថានភាព និងតម្លៃនៃសេវាកម្ម ប្រព័ន្ធអេកូឡូស៊ី ដែលបានវាយតម្លៃរួចរាល់ ។

ការកំណត់យន្តការបង់ថ្លៃសេវាកម្មប្រព័ន្ធអេកូឡូស៊ី ត្រូវផ្អែកលើមូលដ្ឋានសមធម៌ និងសិទ្ធិរបស់សហគមន៍មូលដ្ឋាន។

**មាត្រា៨០៣ .**_ កិច្ចសហប្រតិបត្តិការរបស់ក្រសួង ស្ថាប័នមានសមត្ថកិច្ច

ក្រសួង ស្ថាប័នមានសមត្ថកិច្ចទទួលបន្ទុកការបង់ថ្លៃសេវាកម្មប្រព័ន្ធអេកូឡូស៊ី ត្រូវគាំទ្រ និងសហការជាមួយក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន ដើម្បីរៀបចំ អនុវត្ត និងគ្រប់គ្រងយន្តការ ដូចមានចែងក្នុងមាត្រា៨០២ នៃក្រមនេះ ។

**មាត្រា៨០៤ .**_ ការទទួលបានរបាយការណ៍ជាសាធារណៈ

ក្រសួង ស្ថាប័នមានសមត្ថកិច្ច ត្រូវផ្សព្វផ្សាយជាប្រចាំ និងដាក់ឱ្យសាធារណជនអាចស្វែង រកបាននូវរបាយការណ៍ដែលបង្ហាញពីទិន្នន័យ និងស្ថិតិ ដែលបានរៀបចំ ពាក់ព័ន្ធនឹងស្ថានភាព និងតម្លៃនៃបរិស្ថាន និងធនធានធម្មជាតិ របស់ព្រះរាជាណាចក្រកម្ពុជា ។

## មាតិកាទី២
## ប្រាក់កម្រៃ មូលនិធិ និងការគ្រប់គ្រងមូលនិធិបរិស្ថាន
### ជំពូកទី១
### ប្រាក់កម្រៃ សួយសារ និងបុព្វលាភបរិស្ថាន

**មាត្រា៨០៥** ._ ការទទួលខុសត្រូវក្នុងការបង់ប្រាក់កម្រៃ សួយសារ និងបុព្វលាភបរិស្ថាន

បុគ្គលគ្រប់រូប ត្រូវទទួលបន្ទុកក្នុងការបង់ប្រាក់កម្រៃ សួយសារ និងបុព្វលាភបរិស្ថាន និងថ្លៃផ្សេងទៀត ស្របតាមលិខិតបទដ្ឋានគតិយុត្តអន្តរក្រសួង រវាងក្រសួង ស្ថាប័នទទួលបន្ទុកសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន ។

**មាត្រា៨០៦** ._ ការរៀបចំប្រាក់កម្រៃ សួយសារ និងបុព្វលាភបរិស្ថាន

ក្រសួង ស្ថាប័នទទួលបន្ទុកសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដោយមានជំនួយពីក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន ត្រូវរៀបចំលិខិតបទដ្ឋានគតិយុត្តដើម្បីកំណត់ពីចំនួនទឹកប្រាក់ និងនីតិវិធី ការគ្រប់គ្រង និង ការលើកលែងការបង់ប្រាក់កម្រៃ សួយសារ និងបុព្វលាភបរិស្ថានណាមួយ ដែលពាក់ព័ន្ធនឹងក្រមនេះ រួមមាន ៖

១- ការវាយតម្លៃ និងអង្កេតតាមដានបរិស្ថាន ។

២- យន្តការគ្រប់គ្រង និងចីរភាពបរិស្ថាន ។

៣- ការគ្រប់គ្រងធនធានធម្មជាតិប្រកបដោយចីរភាព ។

៤- ការអភិរក្ស និងគ្រប់គ្រងបេតិកភណ្ឌវប្បធម៌ ។

៥- ការគ្រប់គ្រងសំណល់ និងការបំពុល ។

៦- ការអប់រំ និងការយល់ដឹងពីបរិស្ថាន ។

៧- ការដោះស្រាយវិវាទបរិស្ថាន និងធនធានធម្មជាតិ និង

៨- វិស័យដទៃទៀតពាក់ព័ន្ធណាមួយ ដែលកំណត់ដោយក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន ។

**មាត្រា៨០៧ ._** ការទទួលខុសត្រូវសម្រាប់ប្រាក់កម្រៃផ្សេងទៀត

បុគ្គលគ្រប់រូប ត្រូវបន្តទទួលបន្ទុកក្នុងការបង់ប្រាក់កម្រៃ សួយសារ និងបុព្វលាភទាំងឡាយ ស្របតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធផ្សេងទៀត ។

**មាត្រា៨០៨ ._** ការធានាផ្នែកហិរញ្ញវត្ថុសម្រាប់ការបង់ប្រាក់កម្រៃ សួយសារ និងបុព្វលាភ

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងក្រសួង ស្ថាប័នមានសមត្ថកិច្ចដទៃទៀត អាចតម្រូវ ឱ្យបុគ្គលគ្រប់រូប ដែលទទួលបន្ទុកបង់ប្រាក់កម្រៃ សួយសារ និងបុព្វលាភ និងថ្លៃផ្សេងទៀត ផ្តល់ការធានាធនធានហិរញ្ញវត្ថុគ្រប់គ្រាន់សម្រាប់ការបង់ថ្លៃទាំងនេះ នៅមុនពេលការចេញលិខិតអនុញ្ញាត ឬលិខិតឯកភាព ។

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងក្រសួង ស្ថាប័នមានសមត្ថកិច្ចដទៃទៀត និងក្រសួង ស្ថាប័នទទួលបន្ទុកសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវរៀបចំលិខិតបទដ្ឋានគតិយុត្តស្តីពីលក្ខណៈវិនិច្ឆ័យ និងនីតិវិធីសម្រាប់ការធានាចំពោះការបង់ប្រាក់កម្រៃ សួយសារ និងបុព្វលាភ ។

## ជំពូកទី២
## ការបន្តមូលនិធិបរិស្ថានដែលមានស្រាប់ និងការគ្រប់គ្រងមូលនិធិ
### ផ្នែកទី១
### ការបន្តមូលនិធិបរិស្ថានដែលមានស្រាប់

**មាត្រា៨០៩ ._** ការបង់មូលនិធិទាយជ្ជទានបរិស្ថាន

បុគ្គលគ្រប់រូប ត្រូវបន្តបង់មូលនិធិទាយជ្ជទានបរិស្ថាន ស្របតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ ។ ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន ត្រូវធ្វើការគ្រប់គ្រងមូលនិធិនេះ ស្របតាមបទប្បញ្ញត្តិស្តីពីការចូលរួមជាសាធារណៈ និងសិទ្ធិទទួលបានព័ត៌មានបរិស្ថាន នៃក្រមនេះ ។

**មាត្រា៨១០ ._** ការបន្តមូលនិធិតំបន់ការពារ

បុគ្គលគ្រប់រូបត្រូវបន្តមូលនិធិតំបន់ការពារស្របតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ។ ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន ត្រូវធ្វើការគ្រប់គ្រងមូលនិធិនេះ ស្របតាមបទប្បញ្ញត្តិស្តីពីការចូលរួមជាសាធារណៈ និង សិទ្ធិទទួលបានព័ត៌មានបរិស្ថាន នៃក្រមនេះ ។

**មាត្រា៨១១ ._** ការបន្តមូលនិធិបរិស្ថាន និងសង្គម

បុគ្គលគ្រប់រូប ត្រូវបង់មូលនិធិបរិស្ថាន និងសង្គម ស្របតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត ពាក់ព័ន្ធ ។ ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន ត្រូវធ្វើការគ្រប់គ្រងមូលនិធិនេះ ស្របតាមបទប្បញ្ញត្តិ ស្តីពីការចូលរួមជាសាធារណៈនិង សិទ្ធិទទួលបានព័ត៌មានបរិស្ថាន នៃក្រមនេះ ។

## ផ្នែកទី២
## មូលនិធិបរិស្ថាន និងសង្គម

**មាត្រា៨១២ ._** ប្រភពចំណូលសម្រាប់មូលនិធិបរិស្ថាន និងសង្គម

ប្រភពចំណូលនៃមូលនិធិបរិស្ថាន និងសង្គមបានមកពីប្រភពដូចខាងក្រោម៖

១- ប្រាក់ដែលបានមកពីការដោះស្រាយបណ្តឹងស្របតាមបទប្បញ្ញត្តិនៃក្រមនេះ ។

២- ប្រាក់ដែលទទួលបានពីការអនុវត្តការស្តារបរិស្ថានឡើងវិញ ។

៣- ប្រាក់ដែលទទួលបានពីសំណងការខូចខាតបរិស្ថាន ។

៤- ប្រាក់ដែលទទួលបាន តាមរយៈហិរញ្ញប្បទានជាតិ និងអន្តរជាតិ និង

៥- ប្រាក់ដែលទទួលបានតាមរយៈអំណោយសប្បុរសធម៌ពីអង្គការ និង សប្បុរសជន នានា ។

**មាត្រា៨១៣ ._** គណៈកម្មការមូលនិធិបរិស្ថាន និងសង្គម

មូលនិធិបរិស្ថាន និងសង្គម ត្រូវគ្រប់គ្រងដោយគណៈកម្មការមូលនិធិបរិស្ថាន និងសង្គម ដែល បង្កើតឡើងដោយក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន ។

គណៈកម្មការមូលនិធិបរិស្ថាន និងសង្គម ត្រូវរៀបចំយុទ្ធសាស្ត្រមួយ ដើម្បីគ្រប់គ្រងមូលនិធិ រយៈពេលវែង។ យុទ្ធសាស្ត្រនេះ ត្រូវដាក់បញ្ចូលការពិចារណាលើវិធីសាស្ត្រលទ្ធកម្ម ការគ្រប់គ្រង មូលនិធិ ដែលរួមមាន មូលធនកម្ម និងការវិនិយោគ និងវិធានការផ្នែករដ្ឋបាល និង ផ្លូវច្បាប់ និងគោល នយោបាយពាក់ព័ន្ធដទៃទៀត ។

ភារកិច្ច និងតួនាទី របស់គណៈកម្មការមូលនិធិបរិស្ថាន និងសង្គម ត្រូវកំណត់ដោយលិខិត បទដ្ឋានគតិយុត្ត របស់ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន ។

ការចំណាយពាក់ព័ន្ធនឹង ការបំពេញភារកិច្ច និងតួនាទីរបស់គណៈកម្មការមូលនិធិបរិស្ថាន និងសង្គម ត្រូវកំណត់ដោយលិខិតបទដ្ឋានគតិយុត្តអន្តរក្រសួងរវាង ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងក្រសួង ស្ថាប័នទទួលបន្ទុកសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

## ជំពូកទី៣
## ការបង្កើត និងការគ្រប់គ្រងមូលនិធិបរិស្ថាន
### ផ្នែកទី១
### មូលនិធិបរធនបាលកិច្ច

**មាត្រា៨១៤ ._** ការគ្រប់គ្រងមូលនិធិបរធនបាលកិច្ចបរិស្ថាន

មូលនិធិបរធនបាលកិច្ចបរិស្ថាន ត្រូវបានផ្ទេរពីបរធនបាលទាយកទៅកាន់បរធនបាល ដើម្បីធ្វើការគ្រប់គ្រងសម្រាប់ជាផលប្រយោជន៍ដល់អត្ថគាហកៈ ស្របតាមការកំណត់របស់បរធនបាលទាយក ។ មូលនិធិបរធនបាលកិច្ចបរិស្ថាន មានជាអាទិ៍ មូលនិធិបរធនបាលកិច្ច សម្រាប់ការអភិរក្សសត្វព្រៃ អាកាសធាតុ និងព្រៃឈើ នីតិសម្បទា ការស្តារឡើងវិញ ការគ្រប់គ្រងរួមគ្នា និងទម្រង់ផ្សេងទៀតនៃការបែងចែងផលប្រយោជន៍ផ្នែកបរិស្ថាន សង្គម និងសេដ្ឋកិច្ច ។

**មាត្រា៨១៥ ._** ការបង្កើត ការលុបចោល និងគោលបំណងនៃមូលនិធិបរធនបាលកិច្ចបរិស្ថាន

បរធនបាលទាយក អាចធ្វើដោយខ្លួនឯង ឬដោយសហការជាមួយសមាគមន៍ក្នុងស្រុក ឬសមាគមន៍បរទេស ដើម្បីបង្កើត ឬធ្វើប្រតិបត្តិការមូលនិធិបរធនបាលកិច្ច។

មូលនិធិបរធនបាលកិច្ច អាចលុបចោលបាន ស្របតាមលក្ខខណ្ឌដែលបានកំណត់ ។

មូលនិធិបរធនបាលកិច្ចបរិស្ថាន ត្រូវប្រើប្រាស់សម្រាប់សកម្មភាពដែលបានកំណត់ជាអាទិភាពនៅក្នុងផែនការថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ស្តីពីកិច្ចការពារបរិស្ថាន ការគ្រប់គ្រងរួមគ្នា ចីរភាព និងការអភិរក្ស និងក្នុងគោលបំណង ៖

១- ការពារ អភិរក្ស និងស្តារឡើងវិញនូវបរិស្ថាន និងធនធានធម្មជាតិ ។

២- ការពារបេតិកភណ្ឌវប្បធម៌ ឬជីវៈចម្រុះ ។

៣- លើកកម្ពស់ការគ្រប់គ្រងធនធានធម្មជាតិ និងសេវាកម្មប្រព័ន្ធអេកូឡូស៊ីដោយចីរភាព ។

៤- លើកកម្ពស់ការស្រាវជ្រាវ និងការអប់រំបរិស្ថាន ។

៥- អភិវឌ្ឍសមត្ថភាព ឬពង្រឹងស្ថាប័ន ។

៦- គាំទ្រទៅលើសហគមន៍ដែលរងផលប៉ះពាល់ដោយផ្ទាល់ពីការអភិវឌ្ឍ ឬ

៧- ក្នុងគោលបំណងដើម្បីប្រយោជន៍សាធារណៈ និងសម្រាប់ផលប្រយោជន៍បរិស្ថានណាមួយ ដែលកំណត់ដោយរដ្ឋមន្ត្រីនៃក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន ។

មូលនិធិបរធនបាលកិច្ចបរិស្ថាន ត្រូវបានបង្កើតឡើងស្របតាមនីតិវិធី និងទម្រង់ ដែលកំណត់ដោយក្រសួង ស្ថាប័នទទួលបន្ទុកសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងត្រូវចុះបញ្ជីនៅក្រសួង ស្ថាប័នទទួលបន្ទុកសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។ បរធនបាលទាយកដែលមានបំណងបង្កើត ឬធ្វើប្រតិបត្តិការមូលនិធិបរធនបាលកិច្ចបរិស្ថាន ត្រូវរៀបចំលិខិតបរធនបាលកិច្ច និងចុះបញ្ជី នៅក្រសួង ស្ថាប័នទទួលបន្ទុកសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្របតាមលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធស្ដីពីបរធនបាលកិច្ច ។

**មាត្រា៨១៦** ._ លិខិតបទដ្ឋានគតិយុត្តស្ដីពីការគ្រប់គ្រង និងការត្រួតពិនិត្យមូលនិធិបរធនបាលកិច្ចបរិស្ថាន

ក្រសួង ស្ថាប័នទទួលបន្ទុកសេដ្ឋកិច្ច និងហិរញ្ញវត្ថុដោយសម្របសម្រួលជាមួយក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន ត្រូវរៀបចំលិខិតបទដ្ឋានគតិយុត្តស្ដីពីវិធាន និងនីតិវិធីសម្រាប់ការបង្កើត គ្រប់គ្រង និងត្រួតពិនិត្យមូលនិធិបរធនបាលកិច្ចបរិស្ថាន និងគណនីមូលនិធិនេះ ។

**មាត្រា៨១៧** ._ ការចុះបញ្ជីនៃបរធនបាលកិច្ចបរិស្ថាន

បរធនបាលកិច្ចបរិស្ថានមានសុពលភាព លុះត្រាតែបានចុះបញ្ជីនៅក្រសួង ស្ថាប័នទទួលបន្ទុកសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។ ក្រសួង ស្ថាប័នទទួលបន្ទុកសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវធ្វើសេចក្ដីសម្រេចលើពាក្យស្នើសុំចុះបញ្ជីនេះ ក្នុងរយៈពេល ៩០ (កៅសិប) ថ្ងៃ បន្ទាប់ពីទទួលបានពាក្យស្នើសុំ ។

ក្នុងករណីដែលក្រសួង ស្ថាប័នទទួលបន្ទុកសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បដិសេធចំពោះពាក្យស្នើសុំចុះបញ្ជី ដូចមានចែងក្នុងកថាខណ្ឌខាងលើនេះ ក្រសួង ស្ថាប័នទទួលបន្ទុកសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវផ្ដល់ជាការពន្យល់ជាលាយលក្ខណ៍អក្សរទៅម្ចាស់សំណើ ក្នុងរយៈពេល ៣០ (សាមសិប) ថ្ងៃ បន្ទាប់ពីកាលបរិច្ឆេទនៃការទទួលបានពាក្យស្នើសុំ ។

**មាត្រា៨១៨** ._ ទ្រព្យសម្បត្តិបរធនបាលកិច្ចបរិស្ថាន

ទ្រព្យសម្បត្តិបរធនបាលកិច្ចបរិស្ថាន អាចបង្កើតមកពី៖

១- ថវិកាជាតិ ។

២- ជំនួយអភិវឌ្ឍន៍ជាផ្លូវការ ដែលបានផ្តល់ឱ្យដោយអង្គការជាតិ និងអន្តរជាតិ ។

៣- ការបង់ថ្លៃសេវាកម្មប្រព័ន្ធអេកូឡូស៊ី ។

៤- សេវាកម្មគ្រប់គ្រងធនធានធម្មជាតិ និង

៥- អំណោយផ្ទាល់ពីវិស័យឯកជន និងសប្បុរសជនដទៃទៀត ។

ប្រយោជន៍ទាំងអស់ដែលកើតចេញពីបរធនបាលកិច្ចបរិស្ថាន ត្រូវបង់ចូល និងត្រូវបង្កើតជាផ្នែកនៃមូលនិធិបរធនបាលកិច្ចបរិស្ថាន ។

**មាត្រា៨១៩ ._** សិទ្ធិ និងកាតព្វកិច្ចរបស់បរធនបាលទាយក

បរធនបាលទាយក មានសិទ្ធិជាអាទិ៍ ដូចខាងក្រោម៖

១- ទទួលព័ត៌មានពាក់ព័ន្ធនឹងការគ្រប់គ្រងបរធនបាលកិច្ច ដែលមានជាអាទិ៍ របាយការណ៍ហិរញ្ញវត្ថុ របាយការណ៍សវនកម្ម និងឯកសារពាក់ព័ន្ធផ្សេងទៀត និង

២- តែងតាំង និងបញ្ឈប់បរធនបាល ស្របតាមលក្ខខណ្ឌដែលបានកំណត់ក្នុងលិខិតបរធនបាលកិច្ច ។

បរធនបាលទាយក មានកាតព្វកិច្ចជាអាទិ៍ ដូចខាងក្រោម៖

១- ផ្ទេរបរធន ទៅឱ្យបរធនបាល ។

២- ជូនដំណឹងជាលាយលក្ខណ៍អក្សរទៅកាន់ក្រសួង ស្ថាប័នទទួលបន្ទុកសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ចំពោះការកែប្រែបរធនបាលកិច្ច បរធនបាល អ្នកផ្តល់វិភាគទានបរធនបាលកិច្ច ឬលក្ខខណ្ឌនៃលិខិតបរធនបាលកិច្ច និង

៣- អនុវត្តតាមលក្ខខណ្ឌដែលបានកំណត់ក្នុងលិខិតបរធនបាលកិច្ច ។

ក្នុងករណីដែលបរធនបាលទាយកពុំមានលទ្ធភាព ឬសមត្ថភាពជាស្ថាពរក្នុងការអនុវត្តកាតព្វកិច្ចរបស់ខ្លួន ក្រសួង ស្ថាប័នទទួលបន្ទុកសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អាចបំពេញមុខងារ ជាបរធនបាលទាយកជំនួស ។

**មាត្រា៨២០ ._** សិទ្ធិរបស់អត្ថគាហក:

អត្ថគាហក: មានសិទ្ធិជាអាទិ៍ ដូចខាងក្រោម៖

១- ទទួលអត្ថប្រយោជន៍ដូចមានចែងក្នុងលិខិតបរធនបាលកិច្ច ។

២- ទាមទារឱ្យបរធនបាលបំពេញកាតព្វកិច្ចដែលបានកំណត់ក្នុងលិខិតបរធនបាលកិច្ច ។

៣- ទទួលព័ត៌មានពាក់ព័ន្ធនឹងការគ្រប់គ្រង និងចាត់ចែងនៃបរធនបាលកិច្ច និង

៩- សិទ្ធិផ្សេងៗទៀត ដែលមានចែងក្នុងលិខិតបរធនបាលកិច្ច ។

ក្នុងករណីដែលគ្មានរបៀប ឬវិធីទទួលផល ដូចមានចែងក្នុងកថាខណ្ឌខាងលើ ត្រូវសន្មតថា អត្ថគាហកៈទាំងនេះ ទទួលផលស្មើៗគ្នា ។

**មាត្រា៨២១** ._ សិទ្ធិ និងកាតព្វកិច្ចរបស់បរធនបាល

បរធនបាល មានសិទ្ធិជាអាទិ៍ ដូចខាងក្រោម៖

១- ទទួលលាភការ ឬកម្រៃនានាក្នុងការគ្រប់គ្រងបរធនបាលកិច្ច ដែលអាចប្រែប្រួលទៅតាមបទពិសោធន៍ការងារ និងគុណវឌ្ឍិវិជ្ជាជីវៈរបស់ខ្លួន ។

២- ស្វែងរកមូលនិធិ និងឱកាសវិនិយោគបន្ថែមដើម្បីជាប្រយោជន៍របស់បរធនបាល។

៣- តំណាងឱ្យបរធនបាលទាយក ឬអត្ថគាហកៈនៅចំពោះមុខច្បាប់ ឬអាជ្ញាធរ មានសមត្ថកិច្ច ។

៤- គោរពតាមលក្ខខណ្ឌដែលកំណត់ដោយលិខិតបរធនបាលកិច្ច ឬបទប្បញ្ញត្តិ ជាធរមាន ។

៥- គ្រប់គ្រង និងចាត់ចែងបរធនតាមគោលបំណង និងលក្ខខណ្ឌនៃលិខិតបរធន បាលកិច្ច និងដើម្បីជាប្រយោជន៍របស់អត្ថគាហកៈ និង

៦- ចំណាយក្នុងសកម្មភាពសង្គម ស្របតាមគោលបំណង និងលក្ខខណ្ឌនៃលិខិតបរធនបាលកិច្ច ។

បរធនបាល មានកាតព្វកិច្ចជាអាទិ៍ ដូចខាងក្រោម៖

១- ត្រូវដាក់ពាក្យចុះបញ្ជីបរធន តាមបែបបទ និងនីតិវិធីរបស់ក្រសួង ស្ថាប័នទទួលបន្ទុកសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

២- ត្រូវរាយការណ៍ និងផ្តល់ព័ត៌មានពាក់ព័ន្ធនឹងការគ្រប់គ្រងបរធនបាលកិច្ច ឱ្យបរធនបាលទាយក អត្ថគាហកៈ និងបញ្ញត្តិករពាក់ព័ន្ធ ។

៣- រក្សាកំណត់ហេតុនៃកិច្ចប្រជុំ សម្រាប់ការគ្រប់គ្រងគណនីប្រចាំឆ្នាំ ។

៤- ឆ្លើយតបទៅនឹងបញ្ញត្តិករពាក់ព័ន្ធ ។

៥- បង់ពន្ធគ្រប់ប្រភេទដែលទាក់ទងនឹងទ្រព្យសម្បត្តិបរធនបាលកិច្ច លុះត្រាតែ មានការលើកលែងពន្ធដែលកំណត់ដោយច្បាប់ ។

៦- ផ្តល់ផលប្រយោជន៍ដែលបានកំណត់ក្នុងលិខិតបរធនបាលកិច្ចឱ្យអត្ថគាហកៈ។

៧- ចាត់វិធានការសមស្របក្នុងករណីរំលោភបំពានលើបរធន និង

៨- ចុះកិច្ចសន្យាធានារ៉ាប់រងលើការទទួលខុសត្រូវ ក្នុងមុខងារជាបរធនបាល ។

បរធនបាលមិនអាចផ្ទេរមុខងាររបស់ខ្លួន ឱ្យទៅបុគ្គលផ្សេងទៀតបានឡើយ លើកលែងតែក្នុងកាលៈទេសៈដែលបរធនបាលនោះ ទទួលមរណភាព អសមត្ថភាព ឬខកខានក្នុងការបំពេញ មុខងាររបស់ខ្លួនជាបរធនបាល ស្របតាមលិខិតបរធនបាលកិច្ច ។

**មាត្រា៨២២** ._ ការទទួលខុសត្រូវរបស់បរធនបាល

បរធនបាល ត្រូវទទួលខុសត្រូវ ចំពោះសកម្មភាពដូចខាងក្រោម៖

១- ការធ្វើឱ្យបាត់បង់ និងថយចុះនៃបរធនដោយគ្មានមូលហេតុត្រឹមត្រូវ ។

២- ការប្រើប្រាស់បរធន ខុសពីបំណងបរធនបាលកិច្ចហិរញ្ញវត្ថុ ។

៣-កំហុសដែលបានប្រព្រឹត្តដោយចេតនា ឬអចេតនា ក្នុងការបំពេញការងាររបស់ខ្លួន ។

៤- ការចំណាយណាមួយ ផ្ទុយពីបំណងបរធនបាលកិច្ចហរិញ្ញវត្ថុ ។

៥- បែងចែងឱ្យបានច្បាស់លាស់រវាងទ្រព្យសម្បត្តិផ្ទាល់ខ្លួន និងទ្រព្យសម្បត្តិបរធនបាលកិច្ច ។

៦-ចាត់វិធានការសមស្របដើម្បីការពារទ្រព្យសម្បត្តិបរធនបាលកិច្ច និងអត្ថគាហកៈ ដោយមានមូលហេតុ ផ្អែកលើចំណេះដឹង ជំនាញ និងវិជ្ជាជីវៈ ។

៧- បំពេញតួនាទីដោយយកចិត្តទុកដាក់ និងប្រុងប្រយ័ត្ន រក្សាភាពស្មោះត្រង់ និងសុចរិត និងដោយការថែរក្សា និងការប្រុងប្រយ័ត្នដូចការងាររបស់ខ្លួនផ្ទាល់ដែរ ។

៨- ចៀសវាងទំនាស់ផលប្រយោជន៍ដោយផ្ទាល់ និងប្រយោល ដែលនាំឱ្យប៉ះពាល់ ឬខូចខាតដល់ប្រយោជន៍របស់អត្ថគាហកៈ ។

៩- មិនអាចទទួលយកផលប្រយោជន៍ពីតតិយជនបានឡើយ ក្នុងករណីមាន ទំនាស់ផលប្រយោជន៍ ។

**មាត្រា៨២៣** ._ ទំនាស់ផលប្រយោជន៍ចំពោះមូលនិធិបរធនបាលកិច្ចបរិស្ថាន

ក្នុងអំឡុងពេលបំពេញភារកិច្ចរបស់ខ្លួន បរធនបាលត្រូវរាយការណ៍អំពីទំនាស់ផលប្រយោជន៍ទៅកាន់ក្រសួង ស្ថាប័នទទួលបន្ទុកសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

ក្នុងករណីដែលក្រសួង ស្ថាប័នទទួលបន្ទុកសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មានភស្តុតាង និងហេតុផលគ្រប់គ្រាន់ ដែលអាចជឿជាក់ថា បរធនបាលកំពុងតែប្រព្រឹត្តអំពើដែលមានទំនាស់ផលប្រយោជន៍ចំពោះមូលនិធិបរធនបាលកិច្ចបរិស្ថាន ឬកំពុងតែប្រព្រឹត្តផ្ទុយទៅនឹងផលប្រយោជន៍បរិស្ថាន ឬសាធារណៈ

ក្រសួង ស្ថាប័នទទួលបន្ទុកសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវសម្របសម្រួលជាមួយក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន ដើម្បីផ្តួចផ្តើមការស៊ើបអង្កេតទៅលើបញ្ហានេះ ។

ក្រសួង ស្ថាប័នទទួលបន្ទុកសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវព្យួរការទទួលខុសត្រូវរបស់បរធនបាល ក្នុងករណីដែលការស៊ើបអង្កេតរកឃើញថា បរធនបាលមានទំនាស់ផលប្រយោជន៍ ជាមួយនឹងបរធនបាលកិច្ចរបស់ខ្លួន ។ ក្នុងករណីនេះ ក្រសួង ស្ថាប័នទទួលបន្ទុកសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវតែងតាំងបរធនបាលបណ្តោះអាសន្ន ដោយគោរពតាមលក្ខខណ្ឌតម្រូវនៃក្រមនេះ និងស្របតាមលិខិតបរធនបាលកិច្ច ។

**មាត្រា៨២៤**._ បញ្ជីរបាយការណ៍ប្រចាំឆ្នាំដែលសាធារណជនអាចស្វែងរកបាន

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន ត្រូវរក្សាទុកបញ្ជីរបាយការណ៍ប្រចាំឆ្នាំ នៃគ្រប់បរធនបាលកិច្ចបរិស្ថាន ដែលអាចឱ្យសាធារណជនស្វែងរកបាន ។

**មាត្រា៨២៥**._ ការប្រើប្រាស់ទ្រព្យសម្បត្តិបរធនបាលកិច្ចបរិស្ថាន

បរធនបាលអាចប្រើប្រាស់ទ្រព្យសម្បត្តិបរធនបាលកិច្ចបរិស្ថាន ដើម្បី៖

១- ផ្តល់មូលនិធិដល់សកម្មភាព ឬគម្រោងនានា ដែលបំពេញតាមគោលបំណងនៃមូលនិធិបរធនបាលកិច្ចបរិស្ថាន ស្របតាមបទប្បញ្ញត្តិនៃក្រមនេះ ។

២- បង់ថ្លៃលើប្រតិបត្តិការនៃមូលនិធិបរធនបាលកិច្ចបរិស្ថាន ដែលរួមមានលាភការរបស់បរធនបាល និងថ្លៃចំណាយនានាក្នុងការគ្រប់គ្រងមូលនិធិបរធនបាលកិច្ចបរិស្ថាន។

៣- ចំណាយទៅលើសកម្មភាពសង្គម ស្របតាមគោលបំណងនៃលិខិតបរធនបាលកិច្ច និង

៤- ធ្វើការបណ្តាក់ទុនលើការវិនិយោគ និងមូលបត្រដែលទទួលខុសត្រូវផ្នែកបរិស្ថាន និងសង្គម ។

**មាត្រា៨២៦**._ ការបញ្ចប់បរធនបាលកិច្ចបរិស្ថាន

ដោយមានការយល់ព្រម និងអនុញ្ញាតពីក្រសួង ស្ថាប័នទទួលបន្ទុកសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បរធនបាលកិច្ចបរិស្ថាន ត្រូវបញ្ចប់មុនពេលកំណត់ ក្នុងករណីដូចខាងក្រោម ៖

១- សេចក្តីសម្រេចដោយឆន្ទានុសិទ្ធិ ឬភាគច្រើនដាច់ខាតនៃបរធនបាល ។

២- ការមកដល់នៃកាលវសាន ដែលកំណត់នៅក្នុងលិខិតបរធនបាលកិច្ច ឬ

៣- ការរំលោភបំពានធ្ងន់ធ្ងររបស់បរធនបាលទៅលើបរធនបាលកិច្ចហិរញ្ញវត្ថុ ។

ក្រសួង ស្ថាប័នទទួលបន្ទុកសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវទទួលបាននូវការជូនដំណឹងគ្រប់ដំណាក់កាលទាំងអស់ នៃដំណើរការបញ្ចប់បរធនបាលកិច្ចនេះ ។

**មាត្រា៨២៧ ._** ការត្រួតពិនិត្យបរធនបាលកិច្ចបរិស្ថានដែលត្រូវបានបញ្ចប់

ក្នុងករណីដែលបរធនបាលកិច្ចបរិស្ថានត្រូវបានបញ្ចប់ ដូចមានចែងក្នុងមាត្រា៨២៦ នៃក្រមនេះ បរធនបាលទាយក ត្រូវតែងតាំងបុគ្គលដែលទទួលខុសត្រូវត្រួតពិនិត្យបរធនបាលកិច្ច ដែលមានវិជ្ជាជីវៈ ដើម្បីគ្រប់គ្រង និងវាយតម្លៃបរធននោះ ។ បុគ្គលដែលទទួលខុសត្រូវត្រួតពិនិត្យបរធនបាលកិច្ចនេះ ត្រូវមានការទទួលខុសត្រូវ ដូចខាងក្រោម ៖

១- បំពេញ និងបញ្ចប់កិច្ចការដែលនៅសល់របស់បរធនបាល ។

២- ប្រមូល និងសងបំណុលដែលនៅសល់ និង

៣- វាយតម្លៃបរធនដែលសល់ ។

នៅពេលបំពេញតាមលក្ខខណ្ឌតម្រូវទាំងនេះរួចរាល់ហើយ បុគ្គលដែលទទួលខុសត្រូវត្រួតពិនិត្យបរធនបាលកិច្ច ត្រូវផ្តល់នូវគណនេយ្យចុងក្រោយ និងរបាយការណ៍ឱ្យទៅក្រសួង ស្ថាប័នទទួលបន្ទុកសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន ។ ទ្រព្យសម្បត្តិបរធនបាលកិច្ចបរិស្ថានដែលនៅសល់ ត្រូវបែងចែកស្របតាមលិខិតបរធនបាលកិច្ចបរិស្ថាន ។

ប្រាក់កម្រៃសម្រាប់បុគ្គលដែលទទួលខុសត្រូវត្រួតពិនិត្យបរធនបាលកិច្ច ត្រូវបានគណនាដោយផ្អែកលើមូលដ្ឋាននៃអត្រាវិជ្ជាជីវៈស្តង់ដារ និងត្រូវបង់ដោយយកពីទ្រព្យសម្បត្តិបរធនបាលកិច្ចបរិស្ថាន ។

**មាត្រា៨២៨ ._** លក្ខខណ្ឌតម្រូវនៅពេលបញ្ចប់បរធនបាលកិច្ចបរិស្ថាន

បរធនបាលកិច្ចបរិស្ថាន ត្រូវបញ្ចប់បន្ទាប់ពី៖

១- បំណុលនៃមូលនិធិបរធនបាលកិច្ចបរិស្ថាន ត្រូវបានសង ។

២- មូលនិធិដែលនៅសល់ក្នុងគណនីនៃបរធនបាលកិច្ចបរិស្ថាន និងទ្រព្យសម្បត្តិ បរធនបាលកិច្ចទាំងអស់ ត្រូវបានផ្ទេរ ស្របតាមបទប្បញ្ញត្តិនៃក្រមនេះ និងលិខិតបទដ្ឋាន គតិយុត្តពាក់ព័ន្ធផ្សេងទៀត ស្តីពីបរធនបាលកិច្ចនានា និង

៣-រាល់វិវាទទាំងអស់ដែលទាក់ទងនឹងគណនេយ្យចុងក្រោយត្រូវបានដោះស្រាយ ។បន្ទាប់ពីការបញ្ចប់បរធនបាលកិច្ចបរិស្ថាន បរធនបាលនៅតែទទួលខុសត្រូវ ចំពោះការបាត់បង់ ឬខូច

ខាតដែលបានបង្កឡើង ឬដែលបណ្តាលមកពីកំហុសដោយចេតនា ការធ្វេសប្រហែស ការក្លែងបន្លំ ឬភាពមិនស្មោះត្រង់របស់បរធនបាល ។

**មាត្រា៨២៩ ._** វិវាទពាក់ព័ន្ធនឹងប្រតិបត្តិការនៃបរធនបាលកិច្ចបរិស្ថាន

វិវាទពាក់ព័ន្ធនឹងប្រតិបត្តិការនៃបរធនបាលកិច្ចបរិស្ថាន ត្រូវដោះស្រាយតាមរយៈ ការផ្សះផ្សា ឬសន្ធានកម្មដោយក្រសួង ស្ថាប័នទទួលបន្ទុកសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

ចំពោះវិវាទពាក់ព័ន្ធនឹងប្រតិបត្តិការនៃបរធនបាលកិច្ចដែលមិនបានមកចុះបញ្ជី ក្រសួង ស្ថាប័នទទួលបន្ទុកសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវមានសិទ្ធិលុបចោលបរធនបាលកិច្ចនោះ ។

ភាគីណាមួយមិនពេញចិត្តនឹងសេចក្តីសម្រេចរបស់ក្រសួង ស្ថាប័នទទួលបន្ទុកសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អាចធ្វើបណ្តឹងតវ៉ា ស្របតាមបទប្បញ្ញត្តិដូចមានចែងក្នុងគន្ថីទី៩ នៃក្រមនេះ ។

លទ្ធផលនៃនីតិវិធីដោះស្រាយវិវាទទាំងអស់ ត្រូវដាក់ឱ្យសាធារណជនអាចស្វែងរកបាន ។

**មាត្រា៨៣០ ._** ការគ្រប់គ្រង ឬការប្រើប្រាស់មូលនិធិបរធនបាលកិច្ចបរិស្ថានមិនសមស្រប

បរធនបាលណាដែលគ្រប់គ្រង ឬប្រើប្រាស់មូលនិធិបរធនបាលកិច្ចបរិស្ថានមិនសមស្រប ឬផ្ទុយពីគោលបំណងនៃបរធនបាលកិច្ចបរិស្ថាន ដែលបណ្តាលឱ្យមានការខូចខាតដល់បរិស្ថាន ត្រូវទទួលខុសត្រូវចំពោះសកម្មភាពរបស់ខ្លួន ស្របតាមបទប្បញ្ញត្តិនៃក្រមនេះ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធផ្សេងទៀតស្តីពីបរធនបាលកិច្ច ។

## ផ្នែកទី២
## មូលនិធិសម្រាប់ការដោះស្រាយវិវាទបរិស្ថាន និងធនធានធម្មជាតិ

**មាត្រា៨៣១ ._** មូលនិធិសម្រាប់ការដោះស្រាយវិវាទបរិស្ថាន និងធនធានធម្មជាតិ

ក្រសួង ស្ថាប័នទទួលបន្ទុកមហាផ្ទៃ ត្រូវបង្កើតមូលនិធិដើម្បីដោះស្រាយវិវាទបរិស្ថាន និងធនធានធម្មជាតិ នៅថ្នាក់ឃុំ សង្កាត់ ពាក់ព័ន្ធនឹងកម្រៃសេវាលើការបំពេញមុខងារជាសន្ធានការីបរិស្ថាន ។

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន ត្រូវបង្កើតមូលនិធិដើម្បីដោះស្រាយវិវាទបរិស្ថាន និងធនធានធម្មជាតិ នៃគណៈកម្មការជាតិដោះស្រាយវិវាទបរិស្ថាន និងធនធានធម្មជាតិ ពាក់ព័ន្ធនឹងកម្រៃសេវាលើការបំពេញមុខងាររបស់អ្នកជំនាញបច្ចេកទេសបរិស្ថាន ។

**មាត្រា៨៣២ ._** ប្រភពមូលនិធិ

ប្រភពមូលនិធិដើម្បីដោះស្រាយវិវាទបរិស្ថាន និងធនធានធម្មជាតិ ដូចមានចែងនៅក្នុងមាត្រា ៨៣១ខាងលើនេះ បានមកពី៖

១- ថវិការជាតិដែលបានផ្ដល់ជូន ។

២- អំណោយពីនីតិបុគ្គលជាតិ និងអន្តរជាតិ ។

៣- វិភាគទានសប្បុរសធម៌ និងអំណោយផ្សេងទៀត និង

៤- ប្រភពផ្សេងៗទៀត ។

**មាត្រា៨៣៣ ._** ការប្រើប្រាស់មូលនិធិ

នីតិវិធីនៃការប្រើប្រាស់មូលនិធិ ដើម្បីដោះស្រាយវិវាទបរិស្ថាន និងធនធានធម្មជាតិ ត្រូវកំណត់ដោយលិខិតបទដ្ឋានគតិយុត្តអន្តរក្រសួងរវាងក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងក្រសួង ស្ថាប័នទទួលបន្ទុកមហាផ្ទៃ ។

## ផ្នែកទី៣
## មូលនិធិសម្រាប់លំហាបៃតង

**មាត្រា៨៣៤ ._** ការបង្កើតមូលនិធិលំហាបៃតង

ក្រសួង ស្ថាប័នទទួលបន្ទុករៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ត្រូវបង្កើតមូលនិធិ លំហាបៃតង សម្រាប់ការរៀបចំលំហាបៃតង ។ ការរៀបចំ គ្រប់គ្រង ប្រើប្រាស់ និងចាត់ចែងមូលនិធិលំហាបៃតងត្រូវកំណត់ដោយលិខិតបទដ្ឋានគតិយុត្តអន្តរក្រសួងរវាង ក្រសួង ស្ថាប័នទទួលបន្ទុករៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងក្រសួង ស្ថាប័នទទួលបន្ទុកសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្របតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពិសេសដោយឡែកស្ដីពីហិរញ្ញវត្ថុ ។

**មាត្រា៨៣៥ ._** ប្រភពចំណូលនៃមូលនិធិលំហាបៃតង

មូលនិធិលំហាបៃតង មានប្រភពចំណូល ដូចខាងក្រោម ៖

១- ប្រាក់កម្រៃដែលកំណត់ដោយក្រសួង ស្ថាប័នទទួលបន្ទុករៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ។

២- មូលនិធិពីម្ចាស់ជំនួយ និង

៣- ប្រភពផ្សេងៗទៀត ដែលបានកំណត់ដោយក្រសួង ស្ថាប័នទទួលបន្ទុករៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ។

ចំនួនទឹកប្រាក់ និងនីតិវិធីនៃការគណនា បុគ្គលទទួលខុសត្រូវ និងប្រភេទ និងទំហំនៃគម្រោង ដែលតម្រូវឱ្យបង់ថ្លៃលើប្រាក់កម្រៃនានា ត្រូវកំណត់នៅក្នុងលិខិតបទដ្ឋានគតិយុត្ត ស្ដីពីមូលនិធិលំហបៃតង ដូចមានចែងនៅក្នុងមាត្រា៨៣៤ ។ បុគ្គលទាំងអស់ដែលបានកំណត់នៅក្នុងលិខិតបទដ្ឋានគតិយុត្ត ស្ដីពីមូលនិធិលំហបៃតង ដូចមានចែងនៅក្នុងមាត្រា៨៣៤ ត្រូវទទួលខុសត្រូវ ចំពោះការបង់ថ្លៃលើមូលនិធិលំហបៃតងនេះ។

## ផ្នែកទី៤
## ហិរញ្ញប្បទានសម្រាប់ផែនការគ្រប់គ្រងបរិស្ថាន

**មាត្រា៨៣៦** ._ ធនធានហិរញ្ញវត្ថុសម្រាប់ផែនការគ្រប់គ្រងបរិស្ថាន

ម្ចាស់នៃគម្រោងដែលបានស្នើសុំ ដែលតម្រូវឱ្យមានផែនការគ្រប់គ្រងបរិស្ថាន ស្របតាមបទប្បញ្ញត្តិស្ដីពីការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន នៅក្នុងមាតិកាទី២ គន្ថីទី២នៃក្រមនេះ ត្រូវផ្ដល់ការធានាថា ខ្លួនមានធនធានហិរញ្ញវត្ថុគ្រប់គ្រាន់សម្រាប់ការអនុវត្តផែនការគ្រប់គ្រងបរិស្ថានរបស់គម្រោងជាមុនសិន មុនពេលមានការចេញលិខិត ឬវិញ្ញាបនបត្រឯកភាពលើគម្រោងនេះ ។

លក្ខណៈវិនិច្ឆ័យ និងនីតិវិធីសម្រាប់ការកំណត់ថាម្ចាស់គម្រោងបានផ្ដល់ការធានាគ្រប់គ្រាន់ ដែលរួមមានទម្រង់បែបបទនៃការធានាផ្នែកហិរញ្ញវត្ថុដែលអាចទទួលយកបាន ត្រូវកំណត់ដោយលិខិតបទដ្ឋានគតិយុត្តរបស់ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន ។

**មាត្រា៨៣៧** ._ ថវិកាសម្រាប់ផែនការគ្រប់គ្រងបរិស្ថាន

ថវិកាជាលម្អិត សម្រាប់តម្លៃដែលត្រូវបានប៉ាន់ប្រមាណ ពាក់ព័ន្ធនឹងការអនុវត្តផែនការគ្រប់គ្រងបរិស្ថាន ត្រូវដាក់បញ្ចូលក្នុងផែនការគ្រប់គ្រងបរិស្ថាន ។ ថវិកានេះ ត្រូវមានជាអាទិ៍ ដូចខាងក្រោម ៖

១- តម្លៃសម្រាប់វិធានការកាត់បន្ថយ ។

២- តម្លៃសម្រាប់ការអង្កេតតាមដាន ។

៣- តម្លៃពាក់ព័ន្ធនឹងយន្តការបណ្ដឹងពាក់ព័ន្ធនឹងប្រតិបត្តិការគម្រោង ។

៤- ការទទួលខុសត្រូវជាសក្តានុពលណាមួយសម្រាប់ការផ្លាស់ប្តូរទីតាំង និងសំណង ចំពោះបុគ្គលដែលរងផលប៉ះពាល់ដោយសារគម្រោង ។

៥- ការបង់ថ្លៃលើសេវាកម្មប្រព័ន្ធអេកូឡូស៊ីណាមួយដែលតម្រូវ ។

៦- តម្លៃជាសក្តានុពលពាក់ព័ន្ធនឹងការបិទ ការស្តារឡើងវិញ នីតិសម្បទា ដំណោះស្រាយ ឬការបញ្ឈប់សកម្មភាពគម្រោង និង

៧- តម្លៃផ្សេងទៀតណាមួយ ពាក់ព័ន្ធនឹងការអនុវត្តផែនការគ្រប់គ្រងបរិស្ថានរបស់គម្រោង ។

**មាត្រា៨៣៨**._ នីតិវិធីនៃការធានាផ្នែកហិរញ្ញវត្ថុ

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន ត្រូវរៀបចំលិខិតបទដ្ឋានគតិយុត្តស្តីពីលក្ខណៈវិនិច្ឆ័យ និងនីតិវិធីសម្រាប់ការកំណត់អំពីការផ្តល់ការធានាផ្នែកហិរញ្ញវត្ថុគ្រប់គ្រាន់ សម្រាប់ការអនុវត្តផែនការគ្រប់គ្រងបរិស្ថាននៃគម្រោងដែលបានស្នើសុំ មានជាអាទិ៍ ៖

១- វិសាលភាពនៃការធានាផ្នែកហិរញ្ញវត្ថុដែលតម្រូវសម្រាប់ការអនុវត្តផែនការ។

២- ទម្រង់បែបបទនៃការធានាផ្នែកហិរញ្ញវត្ថុដែលអាចទទួលយកបាន។

៣- ចំនួនទឹកប្រាក់សមស្របនៃការធានាផ្នែកហិរញ្ញវត្ថុ ដែលតម្រូវដោយផ្អែកលើ ទំហំខ្នាត ទីតាំង និងផលប៉ះពាល់ជាសក្តានុពល និង

៤- ក្របខ័ណ្ឌពេលវេលាសម្រាប់ការប្តឹងចំពោះធនធានហិរញ្ញវត្ថុដែលយកមកដាក់ធានា ឬបើគ្មានការប្តឹងណាមួយទេ ត្រូវដាក់ឱ្យធនធានហិរញ្ញវត្ថុនេះ អាចស្វែងរកបាន ។

**មាត្រា៨៣៩**._ ការធ្វើសវនកម្ម និងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ

ម្ចាស់គម្រោង ដែលតម្រូវឱ្យផ្តល់ការធានាផ្នែកហិរញ្ញវត្ថុសម្រាប់ការអនុវត្តផែនការគ្រប់គ្រងបរិស្ថាន ត្រូវអនុលោមតាមលក្ខខណ្ឌតម្រូវក្នុងការធ្វើសវនកម្ម និងការរៀបចំរបាយការណ៍ ស្របតាមលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ ស្តីពីការធ្វើសវនកម្ម និងការរៀបចំរបាយការណ៍ ។

ម្ចាស់គម្រោង ត្រូវធ្វើការពិនិត្យប្រចាំឆ្នាំឡើងវិញនូវការប៉ាន់ប្រមាណតម្លៃនានា ពាក់ព័ន្ធនឹងផែនការគ្រប់គ្រងបរិស្ថាន និងដាក់ជូនការប៉ាន់ប្រមាណនេះ មកក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន ។ ការប៉ាន់ប្រមាណនេះ ត្រូវធ្វើឡើងដោយអ្នកជំនាញការបច្ចេកទេសខាងវិស្វកម្ម ។

ក្នុងករណីដែលរបាយការណ៍សវនកម្មប្រចាំឆ្នាំ បង្ហាញថាពុំមានការគោរពតាមលក្ខខណ្ឌតម្រូវសម្រាប់ការធានាផ្នែកហិរញ្ញវត្ថុ ម្ចាស់គម្រោងត្រូវជូនដំណឹងទៅក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងក្រសួង ស្ថាប័នមានសមត្ថកិច្ចផ្សេងទៀត ។

ម្ចាស់គម្រោងត្រូវគោរពតាមលក្ខខណ្ឌតម្រូវសម្រាប់ការធានាផ្នែកហិរញ្ញវត្ថុដែលបានធ្វើបច្ចុប្បន្នភាព ក្នុងរយៈពេល ៣០ (សាមសិប) ថ្ងៃ បន្ទាប់ពីការជូនដំណឹងនេះ ។

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន អាចតម្រូវឱ្យមានរបាយការណ៍ ឬឯកសារបន្ថែមទៀតបាន ។

ក្នុងករណីដែលរបាយការណ៍សវនកម្មប្រចាំឆ្នាំ បង្ហាញថា មានការធានាផ្នែកហិរញ្ញវត្ថុ ដែលលើសពីលក្ខខណ្ឌតម្រូវនៃក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន អាចដាក់ សំណើមកក្រសួង ស្ថាប័នទទួលបន្ទុកសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីអនុញ្ញាតសុំបង្វិលសងមូលនិធិដែលលើស តាមការស្នើសុំរបស់ម្ចាស់គម្រោង ។

## គន្ថីទី៩

## នីតិវិធីដោះស្រាយបណ្តឹងបរិស្ថាន និងធនធានធម្មជាតិ

## មាតិកាទី១

## នីតិវិធីដោះស្រាយបណ្តឹងបរិស្ថាន និងធនធានធម្មជាតិ

## ជំពូកទី១

## ការដោះស្រាយបណ្តឹងបរិស្ថាន និងធនធានធម្មជាតិដែលមានលក្ខណៈរដ្ឋប្បវេណី និងរដ្ឋបាល

## ផ្នែកទី១

## បណ្តឹងបរិស្ថាន និងធនធានធម្មជាតិ

**មាត្រា៨៤០ .**_ បណ្តឹងរដ្ឋប្បវេណី

បណ្តឹងរដ្ឋប្បវេណី ធ្វើឡើងក្នុងគោលដៅដើម្បីធានានូវសិទ្ធិក្នុងការទាមទារសំណងការខូចខាតផ្នែកសម្ភារៈ ផ្នែករូបរាងកាយ និងផ្លូវចិត្ត ។

ចំពោះបណ្តឹងរដ្ឋប្បវេណី ដើមបណ្តឹងអាចប្រើប្រាស់សិទ្ធិ ដូចមានចែងក្នុងក្រមបរិស្ថាន និងធនធានធម្មជាតិ ក្រមនីតិវិធីរដ្ឋប្បវេណី និងក្រមនីតិវិធីព្រហ្មទណ្ឌជាធរមាន ។

**មាត្រា៨៤១**._ បណ្ដឹងអាជ្ញា

បណ្ដឹងអាជ្ញា ធ្វើឡើងក្នុងគោលដៅដើម្បីធានាដល់សណ្ដាប់ធ្នាប់សាធារណៈ ឬផលប្រយោជន៍សង្គមទូទៅ ដូច្នេះក្នុងករណីមានបទល្មើសបរិស្ថាន និងធនធានធម្មជាតិ ឬការមិនអនុវត្តបទប្បញ្ញត្តិណាមួយដែលបំពាននឹងវិធាននៃក្រមនេះ ជនរងគ្រោះ ឬសាធារណជនទូទៅ មានសិទ្ធិធ្វើបណ្ដឹងទៅតុលាការមានសមត្ថកិច្ចបាន ។

ចំពោះបែបបទ និងនីតិវិធីនៃការធ្វើបណ្ដឹងអាជ្ញា ត្រូវអនុលោមតាមក្រមបរិស្ថាន និងធនធានធម្មជាតិ និងក្រមនីតិវិធីព្រហ្មទណ្ឌជាធរមាន ។

**មាត្រា៨៤២**._ បណ្ដឹងប្រឆាំងសេចក្ដីសម្រេចរដ្ឋបាលបរិស្ថាន និងធនធានធម្មជាតិ

បណ្ដឹងប្រឆាំងសេចក្ដីសម្រេចរដ្ឋបាលបរិស្ថាន និងធនធានធម្មជាតិ ធ្វើឡើងក្នុងគោលដៅដើម្បីប្រឆាំងនឹងសេចក្ដីសម្រេចរដ្ឋបាលបរិស្ថាន និងធនធានធម្មជាតិ ដែលពាក់ព័ន្ធនឹងវិធានការការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិរបស់អាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធ ។

រូបវន្តបុគ្គល ឬនីតិបុគ្គលដែលរងគ្រោះ ឬសាធារណជនដែលរងផលប៉ះពាល់ដោយសារសេចក្ដីសម្រេចរដ្ឋបាលបរិស្ថាន និងធនធានធម្មជាតិ ដូចមានចែងក្នុងកថាខណ្ឌខាងលើនេះ អាចប្រើប្រាស់សិទ្ធិក្នុងការប្ដឹងតវ៉ាដោយអនុលោមតាមក្រមនេះ ។

**មាត្រា៨៤៣**._ បណ្ដឹងប្រឆាំងនឹងសកម្មភាពរដ្ឋបាលបរិស្ថាន និងធនធានធម្មជាតិ

បណ្ដឹងប្រឆាំងនឹងសកម្មភាពរដ្ឋបាលបរិស្ថាន និងធនធានធម្មជាតិ ធ្វើឡើងក្នុងគោលដៅដើម្បីទាមទារសំណងការខូចខាតបរិស្ថាន ឬធនធានធម្មជាតិ ដែលកើតឡើងដោយសារការបំពេញមុខងាររបស់មន្ត្រីរាជការសាធារណៈ ឬអាជ្ញាធរមានសមត្ថកិច្ច ដែលទទួលបន្ទុកពាក់ព័ន្ធនឹងកិច្ចការពារបរិស្ថាន និងគ្រប់គ្រងធនធានធម្មជាតិ ក្នុងការធ្វើសកម្មភាព ចំណាត់ការ ឬវិធានការលើសកម្មភាពបរិស្ថាន ឬការគ្រប់គ្រងធនធានធម្មជាតិ ដែលបង្កព្យសនកម្ម ឬបំពុលបរិស្ថាន ឬការបំពានសិទ្ធិ ឬផលប្រយោជន៍ណាដល់ភាគីទទួលរងផលប៉ះពាល់ ។

រូបវន្តបុគ្គល ឬនីតិបុគ្គល អាចប្រើប្រាស់សិទ្ធិក្នុងការដាក់ពាក្យបណ្ដឹង ដូចមានចែងក្នុងកថាខណ្ឌខាងលើនេះ ទៅអាជ្ញាធរមានសមត្ថកិច្ច ឬតុលាការមានសមត្ថកិច្ចបាន ដោយអនុលោមតាមក្រមនេះ ។

**មាត្រា៨៤៤**._ បណ្ដឹងដែលមានគោលដៅការពារផលប្រយោជន៍សាធារណៈ

បណ្តឹងដែលមានគោលដៅការពារផលប្រយោជន៍សាធារណៈ ធ្វើឡើងក្នុងគោលដៅដើម្បីការពារផលប្រយោជន៍សាធារណៈ ប្រឆាំងនឹងបទល្មើសបរិស្ថាន និងធនធានធម្មជាតិ ឬការមិនអនុវត្តបទប្បញ្ញត្តិ ដូចមានចែងក្នុងក្រមនេះ និងបទប្បញ្ញត្តិពាក់ព័ន្ធផ្សេងទៀត ។

រូបវន្តបុគ្គល ឬនិតីបុគ្គល អាចប្រើប្រាស់សិទ្ធិក្នុងការដាក់ពាក្យបណ្តឹង ដូចមានចែងក្នុងកថាខណ្ឌខាងលើនេះ ទៅតុលាការមានសមត្ថកិច្ច ឬស្ថាប័នមានសមត្ថកិច្ចដោយអនុលោមតាមក្រមនេះ ។

**មាត្រា៨៤៥** ._ បណ្តឹងជាយុទ្ធសាស្ត្រប្រឆាំងការចូលរួមជាសាធារណៈ

បណ្តឹងជាយុទ្ធសាស្ត្រប្រឆាំងការចូលរួមជាសាធារណៈ ធ្វើឡើងដោយរូបវន្តបុគ្គល ឬនីតិបុគ្គលក្នុងគោលដៅដើម្បីទប់ស្កាត់ ឬរារាំង ឬគៀបសង្កត់បណ្តឹងរបស់សាធារណជនទាំងឡាយ ដែលមានចេតនាទុច្ចរិត ក្នុងការធ្វើសកម្មភាពបណ្តឹងដែលធ្វើឱ្យខូចកេរ្តិ៍ឈ្មោះ ឬខូចផលប្រយោជន៍ហិរញ្ញវត្ថុរបស់រូបវន្ត ឬនីតិបុគ្គលនោះ ។

## ផ្នែកទី២
## ភាគីនៃបណ្តឹងបរិស្ថាន និងធនធានធម្មជាតិ

**មាត្រា៨៤៦** ._ ភាគីដែលទទួលរងផលប៉ះពាល់

បុគ្គលដែលទទួលរងផលប៉ះពាល់ដោយផ្ទាល់ ឬប្រយោល ពីបទល្មើសបរិស្ថាន និងធនធានធម្មជាតិ មានសិទ្ធិដាក់ពាក្យបណ្តឹងទៅស្ថាប័ន ឬតុលាការមានសមត្ថកិច្ច ដើម្បីបញ្ឈប់ ឬរារាំងសកម្មភាពណាមួយ ឬទាមទារសំណងការខូចខាត ឬសំណងជំងឺចិត្ត ដោយអនុលោមតាមក្រមនេះ និងក្រមនីតិវិធីរដ្ឋប្បវេណីជាធរមាន ។

បណ្តឹងនេះក៏អាចធ្វើឡើងដោយសហគមន៍ ដើម្បីប្រឆាំងនឹងបទល្មើសបរិស្ថាន និងធនធានធម្មជាតិ ឬការមិនអនុវត្តបទប្បញ្ញត្តិ ដូចមានចែងក្នុងក្រមនេះ និងក្រមនីតិវិធីរដ្ឋប្បវេណីជាធរមានបានផងដែរ តាមរយៈតំណាងរបស់ខ្លួន ។ អ្នកតំណាងសហគមន៍នេះ ត្រូវមានភស្តុតាង ដែលបញ្ជាក់ថាមានការប្រគល់សិទ្ធិត្រឹមត្រូវពីសហគមន៍ ។

**មាត្រា៨៤៧** ._ សមាគមន៍ ឬអង្គការដែលមាននីតិសម្បទា

គ្រប់សមាគមន៍ ឬអង្គការ ដែលបានចុះបញ្ជី និងទទួលស្គាល់ដោយអាជ្ញាធរស្របច្បាប់ត្រឹមត្រូវនៃព្រះរាជាណាចក្រកម្ពុជា អាចប្រើប្រាស់សិទ្ធិក្នុងការធ្វើបណ្ដឹងបរិស្ថាន និងធនធានធម្មជាតិទៅស្ថាប័ន និងតុលាការមានសមត្ថកិច្ចបាន ។

បណ្ដឹងរបស់សមាគមន៍ ឬអង្គការទាំងនេះ ត្រូវធ្វើឡើងក្នុងគោលបំណងដើម្បីបញ្ឈប់ ឬទប់ស្កាត់សកម្មភាពណាមួយ ឬទាមទារឱ្យមានការស្ដារបរិស្ថានឡើងវិញ ឬទាមទារសំណងការខូចខាត ឬសំណងជំងឺចិត្តជូនជនរងគ្រោះ ឬសហគមន៍តែប៉ុណ្ណោះ ។

ក្នុងករណីដែលបណ្ដឹងដែលធ្វើឡើងក្នុងគោលដៅដើម្បីទាមទារសំណងការខូចខាត ឬសំណងជំងឺចិត្ត ជូនជនរងគ្រោះ ឬសហគមន៍ ត្រូវមានមានភស្តុតាងបញ្ជាក់ថា បានទទួលការប្រគល់សិទ្ធិពីតំណាងសហគមន៍ ឬសហគមន៍ ។

**មាត្រា៨៤៨** ._ ភាពអាចទទួលយកបាននៃបណ្ដឹងរបស់សមាគមន៍ ឬអង្គការ

ក្នុងករណីដែលបណ្ដឹងដែលធ្វើឡើង ដូចមានចែងក្នុងមាត្រា៨៤០ខាងលើនេះ បណ្ដឹងរបស់សមាគមន៍ឬ អង្គការទាំងនោះ អាចទទួលយកបាន លុះត្រាតែមានភស្តុតាងដែលបញ្ជាក់ថា បានទទួលការយល់ព្រមពីជនរងគ្រោះ ឬអ្នកតំណាងស្របច្បាប់នៃជននេះ ឬសហគមន៍ ឬតំណាងសហគមន៍នេះចំពោះការទាមទារសំណងផ្នែករដ្ឋប្បវេណី ។

បណ្ដឹងរបស់សមាគមន៍ ឬអង្គការ ដែលមានចែងក្នុងកថាខណ្ឌខាងលើនេះ អាចធ្វើទៅបានដោយពុំចាំបាច់មានភស្តុតាងដែលបញ្ជាក់ថា បានទទួលការយល់ព្រមពីជនរងគ្រោះ ឬ សហគមន៍ ឬតំណាងសហគមន៍ឡើយ នៅក្នុងករណីដែលបណ្ដឹងនោះធ្វើឡើងក្នុងគោលបំណងដើម្បីឱ្យមានការបញ្ឈប់ ឬទប់ស្កាត់សកម្មភាពណាមួយ ឬទាមទារឱ្យមានកិច្ចការពារបរិស្ថាន អភិរក្សជីវៈចម្រុះ ឬការស្ដារបរិស្ថានឡើងវិញ ដើម្បីបម្រើផលប្រយោជន៍សាធារណៈទូទៅ ។

**មាត្រា៨៤៩** ._ បណ្ដឹងបរិស្ថាន និងធនធានធម្មជាតិដែលធ្វើឡើងដោយអាជ្ញាធរមានសមត្ថកិច្ច

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន ឬអាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធ អាចប្រើប្រាស់សិទ្ធិក្នុងការធ្វើសកម្មភាពប្ដឹងទាមទារសំណងការខូចខាតបរិស្ថាន និងធនធានធម្មជាតិ ឬស្ដារបរិស្ថានឡើងវិញ ឬប្ដឹងប្រឆាំងដើម្បីបញ្ឈប់ ឬទប់ស្កាត់សកម្មភាពណាមួយ ដែលបង្កផលប៉ះពាល់ ឬការបំពុលបរិស្ថាន និងធនធានធម្មជាតិ ឬមិនអនុវត្តបទប្បញ្ញត្តិ ដូចមានចែងក្នុងក្រមនេះ ទៅស្ថាប័ន ឬតុលាការមានសមត្ថកិច្ចបាន ។

## ផ្នែកទី៣
## ការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ

**មាត្រា៨៥០ .**_ គោលបំណងការដោះស្រាយបណ្តឹងបរិស្ថាន និងធនធានធម្មជាតិក្រៅប្រព័ន្ធតុលាការ

ការដោះស្រាយវិវាទបរិស្ថាន និងធនធានធម្មជាតិក្រៅប្រព័ន្ធតុលាការ មានគោលបំណងកំណត់អំពីវិធានដើម្បីដោះស្រាយបណ្តឹងបរិស្ថាន និងធនធានធម្មជាតិ ដែលមានលក្ខណៈរដ្ឋប្បវេណី និងរដ្ឋបាល ក្រៅប្រព័ន្ធតុលាការដោយស្ម័គ្រចិត្ត ។

**មាត្រា៨៥១ .**_ វិសាលភាពនៃការដោះស្រាយវិវាទបរិស្ថាន និងធនធានធម្មជាតិក្រៅប្រព័ន្ធតុលាការ

ការដោះស្រាយវិវាទបរិស្ថាន និងធនធានធម្មជាតិក្រៅប្រព័ន្ធតុលាការចំពោះបណ្តឹងបរិស្ថាន និងធនធានធម្មជាតិ មានវិសាលភាពអនុវត្តលើវិវាទបរិស្ថាន និងធនធានធម្មជាតិ ដែលមានលក្ខណៈរដ្ឋប្បវេណី ទៅលើបណ្តឹងទាមទារដូចខាងក្រោម៖

១- ការសងសំណងការខូចខាត ។

២- ការស្តារការខូចខាតបរិស្ថានឡើងវិញ ។

៣- ការកំណត់ពីវិធានការដើម្បីធានាថានឹងមិនបង្កការបំពុលបរិស្ថាន ឬការធ្វើឱ្យខូចខាតបរិស្ថានសាជាថ្មីឡើងវិញដោយអ្នកបង្ក ។

៤- កំណត់វិធានការទប់ស្កាត់ផលប៉ះពាល់ជាអវិជ្ជមាន ដែលកើតមានចំពោះបរិស្ថាន និងធនធានធម្មជាតិ ។

៥- ពុំមានវិសាលភាពអនុវត្តលើបណ្តឹងបរិស្ថាន និងធនធានធម្មជាតិដែលមានលក្ខណៈព្រហ្មទណ្ឌ ដែលបានកំណត់ដោយក្រមនេះ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធផ្សេងៗទៀតឡើយ ។

ការដោះស្រាយវិវាទបរិស្ថាន និងធនធានធម្មជាតិ ដូចមានចែងក្នុងកថាខណ្ឌខាងលើនេះ ត្រូវស្ថិតក្រោមសមត្ថកិច្ចរបស់គណៈកម្មការសន្ធានកម្មបរិស្ថាន និងធនធានធម្មជាតិថ្នាក់ឃុំ សង្កាត់ និងគណៈកម្មការជាតិដោះស្រាយវិវាទបរិស្ថាន និងធនធានធម្មជាតិ ។

**មាត្រា៨៥២ .**_ ការដោះស្រាយវិវាទប្រឆាំងសេចក្តីសម្រេចរដ្ឋបាលបរិស្ថាន ឬសកម្មភាពរដ្ឋបាលបរិស្ថាន និងធនធានធម្មជាតិ

បណ្តឹងប្រឆាំងនឹងសេចក្តីសម្រេចរដ្ឋបាលបរិស្ថាន ឬសកម្មភាពរដ្ឋបាលបរិស្ថាន និងធនធានធម្មជាតិ ដែលកើតចេញពីសេចក្តីសម្រេចរដ្ឋបាលបរិស្ថាន ឬសកម្មភាពរដ្ឋបាលបរិស្ថាន និងធនធានធម្មជាតិ ក្រោមបទប្បញ្ញត្តិនៃក្រមនេះ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានផ្សេងទៀត ត្រូវស្ថិតក្រោមសមត្ថកិច្ចដោះស្រាយរបស់គណៈកម្មាធិការជាតិដោះស្រាយវិវាទបរិស្ថាន និងធនធានធម្មជាតិ ។

**មាត្រា៨៥៣** ._ គណៈកម្មាធិការសន្ទានកម្មបរិស្ថាន និងធនធានធម្មជាតិថ្នាក់ឃុំ សង្កាត់

ក្រុមប្រឹក្សាឃុំ សង្កាត់នីមួយៗ ត្រូវបង្កើត និងរៀបចំដំណើរការប្រព្រឹត្តទៅនៃគណៈកម្មាធិការសន្ទានកម្មបរិស្ថាន និងធនធានធម្មជាតិមួយ ដើម្បីដោះស្រាយវិវាទបរិស្ថាន និងធនធានធម្មជាតិដែលមានលក្ខណៈជាបណ្តឹងរដ្ឋប្បវេណីនៅសាលាឃុំ សង្កាត់របស់ខ្លួន ។

សមត្ថកិច្ចរបស់គណៈកម្មាធិការសន្ទានកម្មនេះ ត្រូវកំណត់ដោយក្រមនេះ ។ ការរៀបចំថវិកាសម្រាប់ដំណើរការលើសេវាកម្មដោះស្រាយវិវាទបរិស្ថាន និងធនធានធម្មជាតិ ត្រូវកំណត់ដោយលិខិតបទដ្ឋានគតិយុត្តអន្តរក្រសួងរវាង ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងក្រសួង ស្ថាប័នទទួលបន្ទុកមហាផ្ទៃ ។

**មាត្រា៨៥៤** ._ សមត្ថកិច្ចរបស់គណៈកម្មាធិការសន្ទានកម្មបរិស្ថាន និងធនធានធម្មជាតិថ្នាក់ឃុំ សង្កាត់

គណៈកម្មាធិការសន្ទានកម្មបរិស្ថានថ្នាក់ឃុំ សង្កាត់ មានសមត្ថកិច្ច ដូចខាងក្រោម៖

១- ទទួលពាក្យបណ្តឹងបរិស្ថាន និងធនធានធម្មជាតិ ។

២- បញ្ជូនបន្តនូវបណ្តឹងបរិស្ថាន និងធនធានធម្មជាតិដែលមិនស្ថិតនៅក្រោមសមត្ថកិច្ចរបស់ខ្លួន ទៅកាន់អង្គភាព ឬស្ថាប័នមានសមត្ថកិច្ចផ្សេងទៀត ឬគណៈកម្មាធិការជាតិដោះស្រាយវិវាទបរិស្ថាន ក្នុងករណីដែលបណ្តឹងបរិស្ថាន និងធនធានធម្មជាតិ មិនអាចដោះស្រាយបាននៅដំណាក់កាលសន្ទានកម្ម ក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ។

៣- ផ្តល់សេវាពិគ្រោះយោបល់វិវាទបរិស្ថាន និងធនធានធម្មជាតិ និងរក្សាការសម្ងាត់ ។

៤- ធ្វើការចុះពិនិត្យទីតាំងទំនាស់ ។

៥- ទទួលដោះស្រាយវិវាទបរិស្ថាន និងធនធានធម្មជាតិដែលមានលក្ខណៈរដ្ឋប្បវេណី។

៦- ធ្វើការផ្សះផ្សាវិវាទបរិស្ថាន និងធនធានធម្មជាតិ ។

៧- រៀបចំកិច្ចព្រមព្រៀងតាមការឯកភាពរបស់គូភាគីវិវាទ និងតាមដានការអនុវត្តកិច្ចព្រមព្រៀងសះជា ។

៨- រក្សាទុកកំណត់ហេតុ ឬឯកសារ នៃដំណើរការរបស់គណៈកម្មាធិការសន្ទានកម្មបរិស្ថាន និងធនធានធម្មជាតិថ្នាក់ឃុំ សង្កាត់ ដូចជា សំណុំបែបបទ កិច្ចព្រមព្រៀងសះជានានា ឬឯកសារពាក់ព័ន្ធផ្សេងៗទៀត ។

៩- បញ្ជូនសំណុំរឿង និងកិច្ចព្រមព្រៀងសះជាទៅគណៈកម្មាធិការជាតិដោះស្រាយវិវាទ ក្នុងករណីដែលគូភាគីមានវិវាទមិនអនុវត្តតាមកិច្ចព្រមព្រៀងសះជាដោយគណៈកម្មាធិការសន្ទានកម្មបរិស្ថាន និងធនធានធម្មជាតិថ្នាក់ឃុំ សង្កាត់ ។

គណៈកម្មាធិការសន្ទានកម្មបរិស្ថាន និងធនធានធម្មជាតិថ្នាក់ឃុំ សង្កាត់ មិនអាចធ្វើការផ្សះផ្សាទៅលើបណ្តឹងបរិស្ថាន និងធនធានធម្មជាតិណាមួយ ដែលបាន ឬកំពុងដោះស្រាយស្របតាមនីតិវិធីក្រោមច្បាប់ដែលនៅជាធរមានកន្លងមកឡើយ ទោះបីជាបណ្តឹងនោះស្ថិតនៅក្នុងដែនសមត្ថកិច្ចរបស់គណៈកម្មាធិការសន្ទានកម្មបរិស្ថាន និងធនធានធម្មជាតិរបស់ខ្លួនក៏ដោយ ។

ការរៀបចំ និងការប្រព្រឹត្តទៅនៃនីតិវិធីដោះស្រាយវិវាទបរិស្ថាន និងធនធានធម្មជាតិរបស់គណៈកម្មាធិការសន្ទានកម្មបរិស្ថាន និងធនធានធម្មជាតិថ្នាក់ឃុំ សង្កាត់ ត្រូវកំណត់ដោយលិខិតបទដ្ឋានគតិយុត្តអន្តរក្រសួង រវាងក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងក្រសួង ស្ថាប័នទទួលបន្ទុកមហាផ្ទៃ។

**មាត្រា៨៩៥**._ សមាសភាពនៃគណៈកម្មាធិការសន្ទានកម្មបរិស្ថាន និងធនធានធម្មជាតិថ្នាក់ឃុំ សង្កាត់

គណៈកម្មាធិការសន្ទានកម្មបរិស្ថាន និងធនធានធម្មជាតិថ្នាក់ឃុំ សង្កាត់ មានសមាសភាពសមាជិកចំនួន៣(បី)រូប ដែលមាន១(មួយ)រូបជាប្រធានសម្រាប់ដឹកនាំនីតិវិធីនៃការដោះស្រាយបណ្តឹងបរិស្ថាន និងធនធានធម្មជាតិ និង២(ពីរ)រូបជាសមាជិក ។ សមាជិក២(ពីរ)រូប ត្រូវជ្រើសរើសដោយគូភាគីនៃវិវាទ ហើយសមាជិក២(ពីរ)រូបនេះ ជាអ្នកជ្រើសរើសសន្ទានការីម្នាក់ទៀតជាប្រធាន ។

ក្នុងករណីដែលឃុំសង្កាត់ណាមួយ មានចំនួនជនជាតិដើមភាគតិចរស់នៅភាគច្រើន គណៈកម្មាធិការសន្ទានកម្មបរិស្ថាន និងធនធានធម្មជាតិថ្នាក់ឃុំ សង្កាត់ ត្រូវមានយ៉ាងហោចណាស់ តំណាងជនជាតិដើមភាគតិច១(មួយ)នាក់ជាសមាជិក ។

គណៈកម្មាធិការសន្ទានកម្មបរិស្ថាន និងធនធានធម្មជាតិថ្នាក់ឃុំ សង្កាត់នីមួយៗ អាចជ្រើសរើសអ្នកជំនាញការបច្ចេសទេសមួយរូប ឬច្រើន ធ្វើជាអ្នកប្រឹក្សាយោបល់ផ្នែកបច្ចេកទេស តាមការចាំបាច់អាស្រ័យតាមលក្ខណៈស្មុគស្មាញនៃវិវាទ ។ អ្នកជំនាញបច្ចេកទេសត្រូវបំពេញការងារត្រឹមតែ

តាមការស្នើសុំរបស់គណៈកម្មាធិការសន្ទានកម្មបរិស្ថានថ្នាក់ឃុំ សង្កាត់ និងផ្តល់សេចក្តីសន្និដ្ឋានបច្ចេកទេសជូនគណៈកម្មាធិការសន្ទានកម្មបរិស្ថាន និងភាគី តែប៉ុណ្ណោះ ។

នីតិវិធីនៃការជ្រើសរើស និងរៀបចំបញ្ជីឈ្មោះអ្នកជំនាញបច្ចេកទេសបរិស្ថាន ត្រូវកំណត់ដោយលិខិតបទដ្ឋានគតិយុត្តរបស់ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន ។

នីតិវិធីនៃការរៀបចំជ្រើសរើស និងធ្វើបញ្ជីឈ្មោះសន្ទានការីបរិស្ថាន និងធនធានធម្មជាតិ ត្រូវកំណត់ដោយលិខិតបទដ្ឋានគតិយុត្តរបស់ក្រសួង ស្ថាប័នទទួលបន្ទុកមហាផ្ទៃ ។

**មាត្រា៨៥៦** ._ រយៈពេលនៃដំណើរការផ្សះផ្សារបស់គណៈកម្មាធិការសន្ទានកម្មបរិស្ថាន និងធនធានធម្មជាតិថ្នាក់ឃុំ សង្កាត់

គណៈកម្មាធិការសន្ទានកម្មបរិស្ថាន និងធនធានធម្មជាតិថ្នាក់ឃុំ សង្កាត់ មានរយៈពេលយ៉ាងយូរបំផុត៤៥(សែសិបប្រាំ)ថ្ងៃ នៃថ្ងៃធ្វើការ ដើម្បីធ្វើដំណើរការផ្សះផ្សាវិវាទបរិស្ថាន និងធនធានធម្មជាតិ ។ រយៈពេលនេះអាចពន្យាពេលបាន ក្នុងករណីដែលគូភាគីវិវាទបានព្រមព្រៀង តាមការស្នើសុំរបស់គណៈកម្មាធិការសន្ទានកម្មបរិស្ថាន និងធនធានធម្មជាតិថ្នាក់ឃុំ សង្កាត់ ។

ក្នុងករណីដែលដំណើរការនៃការផ្សះផ្សារបស់គណៈកម្មាធិការសន្ទានកម្មបរិស្ថាន និងធនធានធម្មជាតិថ្នាក់ឃុំ សង្កាត់ មិនអាចសម្រេចទៅបានក្នុងរយៈពេលដូចមានចែងក្នុងកថាខណ្ឌខាងលើនេះទេ គណៈកម្មាធិការសន្ទានកម្មបរិស្ថាន និងធនធានធម្មជាតិថ្នាក់ឃុំ សង្កាត់ ត្រូវបញ្ជូនបណ្តឹងនេះបន្តទៅគណៈកម្មាធិការជាតិដោះស្រាយវិវាទបរិស្ថាន និងធនធានធម្មជាតិ ដើម្បីធ្វើចំណាត់ការបន្ត យ៉ាងយូរបំផុតក្នុងរយៈពេល១៥(ដប់ប្រាំ)ថ្ងៃ នៃថ្ងៃធ្វើការ ។

**មាត្រា៨៥៧** ._ ការបញ្ចប់នៃដំណើរការសន្ទានកម្មបរិស្ថាន និងធនធានធម្មជាតិ

ដំណើរការសន្ទានកម្មបរិស្ថាន និងធនធានធម្មជាតិ ត្រូវបានបញ្ចប់ដោយមូលហេតុ ដូចខាងក្រោម៖

១- គូភាគីបានឯកភាពគ្នាបញ្ចប់នីតិវិធីនៃដំណើរការសន្ទានកម្មបរិស្ថាន និងធនធានធម្មជាតិ ។

២- ភាគីណាមួយមិនឯកភាព ឬសហការក្នុងការដោះស្រាយវិវាទតាមនីតិវិធីសន្ទានកម្មបរិស្ថាន និងធនធានធម្មជាតិ ។

៣- គូភាគីមិនអាចឈានដល់ការឯកភាពគ្នាលើវិវាទបរិស្ថាន និងធនធានធម្មជាតិ ក្នុង

រយៈពេល៩៥ ថ្ងៃ ឬក្នុងរយៈពេលដែលបានពន្យាតាមការព្រមព្រៀងរបស់គូភាគី បានកន្លងផុតទៅ ។

៤- គូភាគីបានឯកភាពលើកិច្ចព្រមព្រៀងជាលាយលក្ខណ៍អក្សរ តាមការផ្សះផ្សារបស់គណៈកម្មាធិការសន្ទានកម្មបរិស្ថាន និងធនធានធម្មជាតិថ្នាក់ឃុំ សង្កាត់ ។

កិច្ចព្រមព្រៀងសះជារបស់គណៈកម្មាធិការសន្ទានកម្មបរិស្ថាន និងធនធានធម្មជាតិថ្នាក់ឃុំ សង្កាត់ ត្រូវចងកាតព្វកិច្ចផ្លូវច្បាប់ ។

**មាត្រា៨៥៨**._ ដំណោះស្រាយរបស់គណៈកម្មាធិការសន្ទានកម្មបរិស្ថាន និងធានធម្មជាតិ

កិច្ចព្រមព្រៀងនីមួយៗដែលត្រូវបានផ្សះផ្សាដោយគណៈកម្មាធិការសន្ទានកម្មបរិស្ថាន និងធនធានធម្មជាតិថ្នាក់ឃុំ សង្កាត់ ដោយមានការឯកភាពពីភាគីចូលរួម ត្រូវបញ្ចូលចំណុចមួយចំនួន ដូចខាងក្រោម៖

១- កំណត់អំពីប្រាក់សំណងសម្រាប់ការខូចខាតបរិស្ថាន និងធនធានធម្មជាតិ ។

២- កំណត់អំពីវិធីសាស្ត្រនៅក្នុងការស្តារបរិស្ថាន និងធនធានធម្មជាតិឡើងវិញនៃការខូចខាតដែលបានកើតឡើង ។

៣- កំណត់អំពីវិធានការដើម្បីធានាថានឹងមិនមានគ្រោះថ្នាក់បន្ថែមទៀតទេ ចំពោះបរិស្ថាន និងធនធានធម្មជាតិ ។

៤- កំណត់អំពីវិធានដើម្បីទប់ស្កាត់ការខូចខាតបរិស្ថាន និងធនធានធម្មជាតិ ។

ការវាយតម្លៃលើការខូចខាតបរិស្ថាន និងធនធានធម្មជាតិ ត្រូវអនុវត្តស្របតាមមាត្រា៨២៣នៃក្រមនេះ ។

**មាត្រា៨៥៩**._ គណៈកម្មាធិការជាតិដោះស្រាយវិវាទបរិស្ថាន និងធនធានធម្មជាតិ

គណៈកម្មាធិការជាតិដោះស្រាយវិវាទបរិស្ថាន និងធនធានធម្មជាតិ ត្រូវបង្កើតដោយលិខិតបទដ្ឋានគតិយុត្ត តាមសំណើរបស់ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន ។ គណៈកម្មាធិការជាតិដោះស្រាយវិវាទបរិស្ថាន និងធនធានធម្មជាតិ ត្រូវមានលេខាធិការដ្ឋានអចិន្ត្រៃយ៍មួយជាសេនាធិការ នៅក្នុងក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន ។ លេខាធិការដ្ឋាននេះ ត្រូវដឹកនាំដោយអគ្គលេខាធិការមួយរូប និងអគ្គលេខាធិការរងមួយរូប ឬច្រើនរូបជាជំនួយការតាមការចាំបាច់ ។

ការរៀបចំ និងការប្រព្រឹត្តទៅនៃលេខាធិការដ្ឋានអចិន្ត្រៃយ៍ ដូចមានចែងក្នុងកថាខណ្ឌខាងលើនេះ ត្រូវកំណត់ដោយលិខិតបទដ្ឋានគតិយុត្ត តាមសំណើរបស់ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន។

គណៈកម្មាធិការជាតិដោះស្រាយវិវាទបរិស្ថាន និងធនធានធម្មជាតិនេះ មានក្រុមប្រឹក្សាពីរដាច់ដោយឡែកពីគ្នា ។ ក្រុមប្រឹក្សាជាតិទី១ ដើរតួនាទីជាក្រុមសន្ទានកម្មបរិស្ថាន និងធនធានធម្មជាតិ ដែលទទួលបន្ទុកដោះស្រាយបណ្ដឹង ឬវិវាទបរិស្ថាន និងធនធានធម្មជាតិ ដែលបញ្ជូនមកពីគណៈកម្មាធិការសន្ទានកម្មថ្នាក់ឃុំ សង្កាត់ ។ ក្រុមប្រឹក្សាជាតិ ទី២ ដើរតួនាទីជាក្រុមដោះស្រាយបណ្ដឹងប្រឆាំងនឹងសេចក្ដីសម្រេចរដ្ឋបាលបរិស្ថាន ឬសកម្មភាពរដ្ឋបាលបរិស្ថាន និងធនធានធម្មជាតិ ពាក់ព័ន្ធនឹងកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ ។

**មាត្រា៨៦០** ._ ក្រុមប្រឹក្សាជាតិសន្ទានកម្មបរិស្ថាន និងធនធានធម្មជាតិ

ការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាជាតិសន្ទានកម្មបរិស្ថាន និងធនធានធម្មជាតិ ត្រូវកំណត់ដោយលិខិតបទដ្ឋានគតិយុត្ត តាមសំណើរបស់ក្រសួងបរិស្ថាន ។

សមាសភាពនៃក្រុមប្រឹក្សាជាតិសន្ទានកម្មបរិស្ថាន និងធនធានធម្មជាតិខាងលើនេះ មានដូចខាងក្រោម៖

១- មន្ត្រីជំនាញនៃក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន ជាប្រធាន ។

២- មន្ត្រីជំនាញនៃក្រសួងពាក់ព័ន្ធពាក់ព័ន្ធនឹងវិវាទបរិស្ថាន និងធនធានធម្មជាតិ ជាសមាជិក ។

៣- ក្រុមអ្នកជំនាញបច្ចេកទេសវិទ្យាសាស្ត្រ តាមការចាំបាច់ ជាសមាជិក ។

៤- អង្គការសង្គមស៊ីវិលជាតិដែលធ្វើការពាក់ព័ន្ធបរិស្ថាន និងធនធានធម្មជាតិ តាមការចាំបាច់ ជាសមាជិក ។

សមាជិកនៃក្រុមប្រឹក្សាជាតិសន្ទានកម្មបរិស្ថាន និងធនធានធម្មជាតិ មានអាណត្តិ៥(ប្រាំ)ឆ្នាំ ត្រូវបានតែងតាំងសាជាថ្មី លើកលែងតែមានការលាលែង មរណភាព ដកហូតតំណែងដោយកំហុសណាមួយ ដែលមានចែងក្នុងក្រមប្រតិបត្តិ និងបទបញ្ជាផ្ទៃក្នុង ។

នីតិវិធីនៃការរៀបចំជ្រើសរើស និងកំណត់លក្ខណៈសម្បត្តិសន្ទានការីបរិស្ថាន និងធនធានធម្មជាតិនៃក្រុមប្រឹក្សាជាតិសន្ទានកម្មបរិស្ថាន និងធនធានធម្មជាតិ ត្រូវកំណត់ដោយលិខិតបទដ្ឋានគតិយុត្តរបស់ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន ។

**មាត្រា៨៦១** ._ សមត្ថកិច្ចនៃក្រុមប្រឹក្សាជាតិសន្ទានកម្មបរិស្ថាន និងធនធានធម្មជាតិ

ក្រុមប្រឹក្សាជាតិសន្ទានកម្មបរិស្ថាន និងធនធានធម្មជាតិ មានសមត្ថកិច្ចដូចខាងក្រោម៖

១- ដោះស្រាយបណ្តឹងបរិស្ថាន និងធនធានធម្មជាតិ ដែលបានបញ្ជូនមកពីគណៈកម្មាធិការសន្ទានកម្មបរិស្ថាន និងធនធានធម្មជាតិថ្នាក់ឃុំ សង្កាត់ ។

២- មានសិទ្ធិអំណាចក្នុងការស៊ើបអង្កេត និងសាកសួរព័ត៌មានពាក់ព័ន្ធនឹងវិវាទ ។

៣- រៀបចំកិច្ចព្រមព្រៀងសះជា ដោយមានការឯកភាពពីគូភាគី លើបណ្តឹងពាក់ព័ន្ធនឹងវិវាទបរិស្ថាន និងធនធានធម្មជាតិ ។

៤- ពិនិត្យដោះស្រាយសំណើដោះស្រាយវិវាទរបស់ភាគីវិវាទបរិស្ថាន និងធនធានធម្មជាតិ ។

៥- មានសិទ្ធិអំណាចបង្គាប់ឱ្យគូភាគីដាក់ ឬបង្ហាញឯកសារ ព័ត៌មានដែលពាក់ព័ន្ធនឹងចំណុចវិវាទ ។

៦- មានសិទ្ធិស្នើសុំជំនួយពីអ្នកជំនាញការផ្សេងៗពីក្រសួង ស្ថាប័ននានា ។

៧- មានសិទ្ធិស្នើសុំឱ្យមានការសហការពីក្រសួង ស្ថាប័នពាក់ព័ន្ធ ។

៨- រៀបចំ និងបង្កើតបទបញ្ជាផ្ទៃក្នុង និងក្រមប្រតិបត្តិ ។

**មាត្រា៨៦២** ._ រយៈពេលនៃដំណើរការផ្សះផ្សារបស់ក្រុមប្រឹក្សាជាតិសន្ទានកម្មបរិស្ថាន និងធនធានធម្មជាតិ

ក្រុមប្រឹក្សាជាតិសន្ទានកម្មបរិស្ថាន និងធនធានធម្មជាតិ មានរយៈពេលយ៉ាងយូរបំផុត ៦ (ប្រាំមួយ)ខែ ដើម្បីដំណើរការផ្សះផ្សាវិវាទ ដែលរយៈពេលនេះគិតចាប់ពីថ្ងៃទទួលបានពាក្យបណ្តឹង។

រយៈពេលដូចមានចែងក្នុងកថាខណ្ឌខាងលើនេះ អាចពន្យាពេលបាន ដោយមានការព្រមព្រៀងពីគូភាគី តាមការស្នើសុំរបស់ក្រុមប្រឹក្សាជាតិសន្ទានកម្មបរិស្ថាន និងធនធានធម្មជាតិ ។

ក្នុងករណីដែលដំណើរការនៃការផ្សះផ្សារបស់ក្រុមប្រឹក្សាជាតិសន្ទានកម្មបរិស្ថាន និងធនធានធម្មជាតិ មិនអាចសម្រេចបានក្នុងរយៈពេលដូចមានចែងក្នុងកថាខណ្ឌខាងលើនេះទេ ក្រុមប្រឹក្សាជាតិសន្ទានកម្មបរិស្ថាន និងធនធានធម្មជាតិ ឬគូភាគីអាចប្តឹងតវ៉ាទៅសាលាដំបូងដែលមានសមត្ថកិច្ចដើម្បីដោះស្រាយទៅតាមនីតិវិធីច្បាប់ជាធរមាន ។

**មាត្រា៨៦៣** ._ ការបញ្ចប់ដំណើរការសន្ទានកម្មបរិស្ថាន និងធនធានធម្មជាតិរបស់ក្រុមប្រឹក្សាជាតិសន្ទានកម្មបរិស្ថាន និងធនធានធម្មជាតិ

ដំណើរការសន្ទានកម្មបរិស្ថាន និងធនធានធម្មជាតិនៃក្រុមប្រឹក្សាជាតិសន្ទានកម្មបរិស្ថាន និងធនធានធម្មជាតិ ត្រូវបានបញ្ចប់ដោយមូលហេតុដូចខាងក្រោម៖

១- គូភាគីបានឯកភាពគ្នាបញ្ចប់នីតិវិធីនៃដំណើរការសន្ទានកម្មបរិស្ថាន និងធនធានធម្មជាតិ ។

២- ភាគីណាមួយមិនឯកភាព ឬសហការក្នុងការដោះស្រាយតាមនីតិវិធីសន្ទានកម្មបរិស្ថាន ។

៣- គូភាគីមិនអាចឈានដល់ការឯកភាពគ្នាលើវិវាទបរិស្ថាន និងធនធានធម្មជាតិ ក្នុងរយៈពេល៦(ប្រាំមួយ)ខែ ឬក្នុងរយៈពេលដែលបានពន្យាពេល តាមការព្រមព្រៀងរបស់គូភាគីបានកន្លងផុតទៅ ។

៤- គូភាគីបានឯកភាពលើកិច្ចព្រមព្រៀងជាលាយលក្ខណ៍អក្សរ តាមការផ្សះផ្សារបស់ក្រុមប្រឹក្សាជាតិសន្ទានកម្មបរិស្ថាន ។

កិច្ចព្រមព្រៀងសះជារបស់ក្រុមប្រឹក្សាជាតិសន្ទានកម្មបរិស្ថាន និងធនធានធម្មជាតិ ត្រូវចងកាតព្វកិច្ចផ្លូវច្បាប់ ។

**មាត្រា៨៦៤** ._ ការចំណាយលើការដោះស្រាយវិវាទបរិស្ថាន និងធនធានធម្មជាតិដោយគូភាគី

ក្នុងករណីដែលវិវាទបរិស្ថាន និងធនធានធម្មជាតិពាក់ព័ន្ធនឹងផលប្រយោជន៍បុគ្គលឯកជន គូភាគីនៃវិវាទត្រូវទទួលបន្ទុកលើការចំណាយចំពោះដំណើរការដោះស្រាយវិវាទបរិស្ថាន និងធនធានធម្មជាតិនេះ លើកលែងតែវិវាទនោះប្ដឹងឡើងដោយអាជ្ញាធរ ឬស្ថាប័នមានសមត្ថកិច្ច ឬសាធាណជនទូទៅ ដើម្បីការពារផលប្រយោជន៍សាធារណៈ ឬសហគមន៍ ដែលត្រូវប្រើប្រាស់មូលនិធិដោះស្រាយវិវាទបរិស្ថាន និងធនធានធម្មជាតិខាងលើ ។

នីតិវិធីនៃការកំណត់ប្រភេទចំណាយដែលត្រូវទូទាត់ ត្រូវកំណត់ដោយលិខិតបទដ្ឋានគតិយុត្តអន្តរក្រសួង រវាងក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងក្រសួង ស្ថាប័នទទួលបន្ទុកមហាផ្ទៃ ។

**មាត្រា៨៦៥** ._ ឯករាជ្យភាព និងអព្យាក្រឹត្យភាពនៃសន្ទានការីបរិស្ថាន

សន្ទានការីបរិស្ថាន និងធនធនធានធម្មជាតិ ដែលបានទទួលការតែងតាំង ត្រូវបំពេញមុខងាររបស់ខ្លួនដោយឯករាជ្យ និងអព្យាក្រឹត្យ ក្នុងព្រំដែននៃវិសាលភាពសមត្ថកិច្ចរបស់ខ្លួន តាមបទប្បញ្ញត្តិច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន ។

**មាត្រា៨៦៦** ._ កិច្ចព្រមព្រៀងសះជារបស់ក្រុមប្រឹក្សាជាតិសន្ទានកម្មបរិស្ថាន និងធនធានធម្មជាតិ

កិច្ចព្រមព្រៀងសះជារបស់ក្រុមប្រឹក្សាជាតិសន្ទានកម្មបរិស្ថាន និងធនធានធម្មជាតិ ត្រូវមានទម្រង់លាយលក្ខណ៍អក្សរ និងត្រូវធ្វើការផ្សព្វផ្សាយជាសាធារណៈ ។

**មាត្រា៨៦៧** ._ ការប្ដឹងជំទាស់ទៅនឹងកិច្ចព្រមព្រៀងសះជារបស់ក្រុមប្រឹក្សាជាតិសន្ទានកម្មបរិស្ថាន

គូភាគីវិវាទ មានសិទ្ធិប្ដឹងជំទាស់ទៅតុលាការមានសមត្ថកិច្ច ដើម្បីឱ្យពិនិត្យឡើងវិញលើអង្គច្បាប់ និងនីតិវិធីលើកិច្ចព្រមព្រៀងសះជា ដែលសម្របសម្រួលដោយក្រុមប្រឹក្សាជាតិសន្ទានកម្មបរិស្ថាន និងធនធានធម្មជាតិ ក្នុងរយៈពេល១៥(ដប់ប្រាំ)ថ្ងៃ ក្រោយពេលដែលដំណើរការសន្ទានកម្មបានបញ្ចប់ ។

ក្នុងករណីដែលគ្មានបណ្ដឹងជំទាស់ដែលធ្វើឡើង ក្នុងរយៈពេលដូចមានចែងក្នុងកថាខណ្ឌខាងលើនេះទេ ត្រូវចាត់ទុកថាកិច្ចព្រមព្រៀងសះជានេះចូលជាស្ថាពរ ហើយមានតម្លៃដូចកំណត់ហេតុសះជា ដែលក្លាយជាលិខិតអនុវត្តដោយបង្ខំ តាមបទប្បញ្ញត្តិនៃក្រមនីតិវិធីរដ្ឋប្បវេណីជាធរមាន ។

**មាត្រា៨៦៨** ._ ដំណោះស្រាយលើវិធានការស្ដារ និងជួសជុលបរិស្ថានឡើងវិញ

ក្រុមប្រឹក្សាជាតិសន្ទានកម្មបរិស្ថាន និងធនធានធម្មជាតិ ឬក្រុមប្រឹក្សាជាតិដោះស្រាយវិវាទរដ្ឋបាលបរិស្ថាន និងធនធានធម្មជាតិ ត្រូវជ្រើសរើសដំណោះស្រាយ និងវិធានការ ដែលមានចែងក្នុងក្រមបរិស្ថាន និងធនធានធម្មជាតិនេះ ។

ក្រុមប្រឹក្សាជាតិសន្ទានកម្មបរិស្ថាន ឬក្រុមប្រឹក្សាដោះស្រាយវិវាទរដ្ឋបាលបរិស្ថាន ត្រូវពិចារណានូវជម្រើសជាអាទិភាព លើបញ្ហានៃការស្ដារ និងជួសជុលបរិស្ថានឡើងវិញ ។

**មាត្រា៨៦៩** ._ អានុភាពនៃកិច្ចព្រមព្រៀងសះជារបស់ក្រុមប្រឹក្សាជាតិសន្ទានកម្មបរិស្ថាន និងធនធានធម្មជាតិ

កិច្ចព្រមព្រៀងសះជារបស់ប្រឹក្សាជាតិសន្ទានកម្មបរិស្ថាន និងធនធានធម្មជាតិ មានតម្លៃដូចកំណត់ហេតុសះជា ដែលក្លាយជាលិខិតអនុវត្តដោយបង្ខំតាមផ្លូវតុលាការដូចមានចែងតាមបទប្បញ្ញត្តិនៃក្រមនីតិវិធីរដ្ឋប្បវេណីជាធរមាន ក្នុងករណីដែលភាគីវិវាទមិនបានអនុវត្តតាមខ្លឹមសារនៃកិច្ចព្រមព្រៀងសះជា ដោយស្ម័គ្រចិត្ត ។

**មាត្រា៨៧០** ._ ក្រុមប្រឹក្សាជាតិដោះស្រាយវិវាទរដ្ឋបាលបរិស្ថាន និងធនធានធម្មជាតិ

ការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាជាតិដោះស្រាយវិវាទរដ្ឋបាលបរិស្ថាន និងធនធានធម្មជាតិ ត្រូវកំណត់ដោយលិខិតបទដ្ឋានគតិយុត្ត តាមសំណើរបស់ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន។

សមាសភាពនៃក្រុមប្រឹក្សាដោះស្រាយវិវាទរដ្ឋបាលបរិស្ថាន និងធនធានធម្មជាតិខាងលើនេះ មានដូចខាងក្រោម៖

១- រដ្ឋមន្ត្រីនៃទីស្តីការគណៈរដ្ឋមន្ត្រី ឬតំណាង ជាប្រធាន ។

២- រដ្ឋមន្ត្រីនៃក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន ឬតំណាង ជាអនុប្រធាន ។

៣- រដ្ឋមន្ត្រីនៃក្រសួង ស្ថាប័នពាក់ព័ន្ធពាក់ព័ន្ធនឹងវិវាទបញ្ហាបរិស្ថាន និងធនធានធម្មជាតិ ឬតំណាង ជាសមាជិក ។

៤- ក្រុមអ្នកជំនាញបច្ចេកទេសវិទ្យាសាស្ត្រ សម្រាប់ពិគ្រោះយោបល់បច្ចេកទេស តាមចាំបាច់ ឬតាមការស្នើសុំរបស់ក្រសួង ស្ថាប័នពាក់ព័ន្ធ ជាសមាជិក ។

៥- សមាជិកផ្សេងតាមការចាំបាច់ អាស្រ័យតាមករណីវិវាទ ជាសមាជិក ។

សមាជិកនៃក្រុមប្រឹក្សាជាតិដោះស្រាយវិវាទរដ្ឋបាលបរិស្ថាន និងធនធានធម្មជាតិ មានអាណត្តិ៥(ប្រាំ)ឆ្នាំ ត្រូវបានតែងតាំងសាជាថ្មី លើកលែងតែមានការលាលែង មរណភាព ដកហូតតំណែង ដោយកំហុសណាមួយ ដែលមានចែងក្នុងបទបញ្ជាផ្ទៃក្នុង ឬដោយបញ្ញត្តិច្បាប់ហាមឃាត់។

**មាត្រា៨៧១** ._ សមត្ថកិច្ចក្រុមប្រឹក្សាជាតិដោះស្រាយវិវាទរដ្ឋបាលបរិស្ថាន

ក្រុមប្រឹក្សាជាតិដោះស្រាយវិវាទរដ្ឋបាលបរិស្ថាន និងធនធានធម្មជាតិ មានសមត្ថកិច្ចត្រួតពិនិត្យ និងចេញសេចក្តីសម្រេចលើបណ្តឹងតវ៉ាចំពោះសេចក្តីសម្រេចរដ្ឋបាលបរិស្ថាន ឬសកម្មភាពរដ្ឋបាលបរិស្ថាន និងធនធានធម្មជាតិ ដែលពាក់ព័ន្ធនឹងបរិស្ថាន និងធនធានធម្មជាតិ។

សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាជាតិដោះស្រាយវិវាទរដ្ឋបាលបរិស្ថាន និងធនធានធម្មជាតិ អាចជាសេចក្តីសម្រេចបដិសេធ ឬលុបចោល ឬទទួលស្គាល់ ឬកែប្រែ សេចក្តីសម្រេចរដ្ឋបាលបរិស្ថាន ឬសកម្មភាពរដ្ឋបាលបរិស្ថាន និងធនធានធានធម្មជាតិ ឬសម្រេចលើបណ្តឹងទាមទារសំណងការខូចខាតបរិស្ថានរបស់ភាគីទទួលរងផលប៉ះពាល់ដែលពាក់ព័ន្ធនឹងបរិស្ថាន និងធនធានធម្មជាតិ ។ សេចក្តីសម្រេចនេះ ត្រូវធ្វើឡើងជាទម្រង់លាយលក្ខណ៍អក្សរ និងមានបញ្ជាក់ហេតុផលឱ្យបានត្រឹមត្រូវតាមច្បាប់ ។

ក្រុមប្រឹក្សាជាតិដោះស្រាយវិវាទរដ្ឋបាលបរិស្ថាន និងធនធានធម្មជាតិ ត្រូវចេញសេចក្តីសម្រេចរបស់ខ្លួនដែលមានរយៈពេលយ៉ាងយូរបំផុត៤៥(សែសិបប្រាំ)ថ្ងៃនៃថ្ងៃធ្វើការ គិតចាប់ពីថ្ងៃទទួលបានពាក្យបណ្តឹងតវ៉ា ។

រយៈពេលដូចមានចែងក្នុងវាក្យខណ្ឌខាងលើនេះ អាចពន្យាពេលបានយ៉ាងយូរបំផុតមិនឱ្យលើសពី៣(បី)ខែ ដោយមូលហេតុភាពស្មុគស្មាញនៃបច្ចេកទេសវិទ្យាសាស្ត្រនៃសេចក្តីសម្រេចរដ្ឋបាលបរិស្ថាន ឬសកម្មភាពរដ្ឋបាលបរិស្ថាន និងធនធានធម្មជាតិនោះ ។

**មាត្រា៨៧២** ._ នីតិវិធីនៃការសម្រេចសេចក្តីរបស់ក្រុមប្រឹក្សាជាតិដោះស្រាយវិវាទរដ្ឋបាលបរិស្ថាន និងធនធានធម្មជាតិ

ការសម្រេចសេចក្តីរបស់ក្រុមប្រឹក្សាជាតិដោះស្រាយវិវាទរដ្ឋបាលបរិស្ថាន និងធនធានធម្មជាតិ ត្រូវធ្វើឡើងដោយឆ្លងកាត់សវនាការជាសាធារណៈ ។ ការសម្រេចសេចក្តីត្រូវធ្វើឡើងដោយមតិភាគច្រើនក្នុងចំណោមសមាជិកវត្តមាន ។ សមាជិកក្រុមប្រឹក្សាជាតិដោះស្រាយវិវាទរដ្ឋបាលបរិស្ថាន និងធនធានធម្មជាតិ ត្រូវតែមានយ៉ាងតិច៣(បី)រូប ឬច្រើនរូប ប៉ុន្តែត្រូវតែជាចំនួនសេស ដែលចូលរួមក្នុងការធ្វើសវនាការជាសាធារណៈអាស្រ័យទៅតាមករណីប្រភេទនៃបណ្តឹងលើសេចក្តីសម្រេចរដ្ឋបាលបរិស្ថាន ឬសកម្មភាពរដ្ឋបាលបរិស្ថាន និងធនធានធម្មជាតិនីមួយៗ ដែលក្នុងនោះសមាជិកមកពីតំណាងគណៈរដ្ឋមន្ត្រីជាប្រធានដឹកនាំសវនាការជាសាធារណៈ ។

ការពិភាក្សាសម្រេចសេចក្តីរបស់ក្រុមប្រឹក្សាជាតិដោះស្រាយវិវាទរដ្ឋបាលបរិស្ថាន និងធនធានធម្មជាតិ ត្រូវធ្វើជាសម្ងាត់ ប៉ុន្តែការប្រកាសសេចក្តីសម្រេចរបស់ខ្លួន ត្រូវធ្វើឡើងជាសាធារណៈ និងដោយមានសំអាងហេតុត្រឹមត្រូវនៅក្នុងសាលសវនាការសាធារណៈ ។

**មាត្រា៨៧៣** ._ ការប្តឹងជំទាស់ប្រឆាំងនឹងសេចក្តីសម្រេចរដ្ឋបាលបរិស្ថាន និងធនធានធម្មជាតិ ឬសកម្មភាពរដ្ឋបាលបរិស្ថាន និងធនធានធម្មជាតិ

ក្នុងករណីដែលគូភាគីវិវាទមិនយល់ព្រមតាមសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាជាតិដោះស្រាយវិវាទរដ្ឋបាលបរិស្ថាន និងធនធានធម្មជាតិ ភាគីវិវាទមានសិទ្ធិប្តឹងជំទាស់ទៅសាលាដំបូងឱ្យពិនិត្យ និងសម្រេចឡើងវិញ ទៅតាមក្រមនីតិវិធីរដ្ឋប្បវេណីជាធរមាន ឬនីតិវិធីរដ្ឋបាលជាធរមាន ក្នុងករណីមានច្បាប់នីតិវិធីរដ្ឋបាល ក្នុងរយៈពេល៣០(សាមសិបប្រាំ)ថ្ងៃនៃថ្ងៃធ្វើការ គិតចាប់ពីថ្ងៃទទួលបានការជូនដំណឹងអំពីសេចក្តីសម្រេចនោះ ។

ក្នុងករណីគ្មានបណ្តឹងជំទាស់ក្នុងរយៈពេល៣០(សាមសិប)ថ្ងៃខាងលើនេះ ត្រូវចាត់ទុកថាសេចក្តីសម្រេចនេះចូលជាស្ថាពរ ហើយមានអានុភាពអនុវត្តភ្លាម ។

**មាត្រា៨៧៤ ._** កិច្ចសហការជាមួយគណៈកម្មាធិការជាតិដោះស្រាយវិវាទបរិស្ថាន និងធនធានធម្មជាតិ

អាជ្ញាធរគ្រប់លំដាប់ថ្នាក់ កងកម្លាំងប្រដាប់អាវុធ និងក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវផ្តល់កិច្ចសហការ សម្របសម្រួល និងផ្តល់ជំនួយដល់ការអនុវត្តតួនាទីរបស់គណៈកម្មាធិការជាតិដោះស្រាយវិវាទបរិស្ថាន ក្នុងករណីមានសំណើពីគណៈកម្មាធិការជាតិដោះស្រាយវិវាទបរិស្ថាន និងធនធានធម្មជាតិ។

**មាត្រា៨៧៥ ._** ឯករាជ្យភាព និងអព្យាក្រឹត្យភាពនៃក្រុមប្រឹក្សាជាតិដោះស្រាយវិវាទរដ្ឋបាលបរិស្ថាន

សមាជិកនៃក្រុមប្រឹក្សជាតិដោះស្រាយវិវាទរដ្ឋបាលបរិស្ថាន និងធនធានធម្មជាតិដែលត្រូវបានទទួលការតែងតាំង ត្រូវបំពេញមុខងាររបស់ខ្លួនដោយឯករាជ្យ និងអព្យាក្រឹត្យ ក្នុងព្រំដែននៃវិសាលភាពសមត្ថកិច្ចរបស់ខ្លួន ស្របតាមបទប្បញ្ញត្តិច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន ។

ក្នុងករណីដែលសមាជិកណាបំពានមុខងាររបស់ខ្លួន ដូចមានចែងក្នុងកថាខណ្ឌខាងលើនេះ ហើយប្រព្រឹត្តអំពើណាមួយដែលខុសនឹងច្បាប់ជាធរមាន សមាជិកនោះត្រូវទទួលខុសត្រូវទណ្ឌកម្មរដ្ឋបាល និង/ឬ ព្រហ្មទណ្ឌ ទៅតាមប្រភេទនៃកំហុសដែលមានចែងក្នុងបទប្បញ្ញត្តិច្បាប់ជាធរមាន ។

## ផ្នែកទី៤
## ការដោះស្រាយវិវាទបរិស្ថាន និងធនធានធម្មជាតិ ក្នុងប្រព័ន្ធតុលាការ

**មាត្រា៨៧៦ ._** តុលាការជំនាញបរិស្ថាន

ត្រូវបង្កើតឱ្យមានតុលាការជំនាញបរិស្ថាននៅសាលាដំបូងរាជធានី ខេត្ត និងសភាជំនាញបរិស្ថាននៅសាលាឧទ្ធរណ៍ និងតុលាការកំពូល ដើម្បីទទួលបន្ទុកដោះស្រាយវិវាទបរិស្ថាន និងធនធានធម្មជាតិ និងវិវាទប្រឆាំងសេចក្តីសម្រេចរដ្ឋបាលបរិស្ថាន ឬសកម្មភាពរដ្ឋបាលបរិស្ថាន និងធនធានធម្មជាតិ ។

**មាត្រា៨៧៧ ._** សមត្ថកិច្ចរបស់តុលាការជំនាញបរិស្ថាន

តុលាការជំនាញបរិស្ថានត្រូវចេញសេចក្តីសម្រេចចំពោះបណ្តឹងជំទាស់ដែលបញ្ជូនមកដោយក្រុមប្រឹក្សាជាតិសន្ទានកម្មបរិស្ថាន និងធនធានធម្មជាតិ ឬក្រុមប្រឹក្សាជាតិដោះស្រាយវិវាទប្រឆាំងសេចក្តីសម្រេចរដ្ឋបាលបរិស្ថាន ដោយយោងតាមក្រមនីតិវិធីរដ្ឋប្បវេណីជាធរមាន ឬនីតិវិធីរដ្ឋបាលជាធរមាន ក្នុងករណីមានច្បាប់នីតិវិធីរដ្ឋបាល ។

ក្នុងករណីមានបណ្តឹងពាក់ព័ន្ធវិវាទបរិស្ថាន និងធនធានធម្មជាតិដែលមានចរិកលក្ខណៈជាបទល្មើសព្រហ្មទណ្ឌ ដែលកំណត់ដោយក្រមនេះ និងបទប្បញ្ញត្តិនៃច្បាប់ផ្សេងទៀត ការដំណើរការនីតិវិធីនៃរឿងក្តីព្រហ្មទណ្ឌនេះ ត្រូវអនុលោមនីតិវិធីព្រហ្មទណ្ឌជាធរមាន ។

ការអនុវត្តនីតិវិធីក្នុងការដោះស្រាយបណ្តឹងបរិស្ថាន និងធនធានធម្មជាតិ ត្រូវអនុលោមតាមក្រមនីតិវិធីរដ្ឋប្បវេណី និងក្រមនីតិវិធីព្រហ្មទណ្ឌជាធរមាន លើកលែងតែមានបទប្បញ្ញត្តិពិសេសដែលកំណត់ដោយក្រមនេះ ។

**មាត្រា៨៧៨** ._ បណ្តឹងជំទាស់ប្រឆាំងកិច្ចព្រមព្រៀងសះជារបស់ក្រុមប្រឹក្សាជាតិសន្ទានកម្មបរិស្ថាន និងធនធានធម្មជាតិ

គូភាគី ឬសាធារណជនដែលមានគោលដៅការពារផលប្រយោជន៍សាធារណៈ ឬអាជ្ញាធរមានសមត្ថកិច្ចមានសិទ្ធិប្តឹងជំទាស់នឹងកិច្ចព្រមព្រៀងសះជារបស់ក្រុមប្រឹក្សាជាតិសន្ទានកម្មបរិស្ថាន និងធនធានធម្មជាតិ ឬក្រុមប្រឹក្សាជាតិដោះស្រាយវិវាទរដ្ឋបាលបរិស្ថាន និងធនធានធម្មជាតិ ទៅតុលាការជំនាញបរិស្ថាននៃសាលាដំបូង ដើម្បីពិនិត្យឡើងវិញនូវអង្គច្បាប់ និងនីតិវិធី ។

បុគ្គលគ្រប់រូបដែលមិនពេញចិត្តសាលក្រមរបស់តុលាការជំនាញបរិស្ថាននៃសាលាដំបូង មានសិទ្ធិប្តឹងឧទ្ធរណ៍នឹងសាលក្រម ទៅតុលាការជាន់ខ្ពស់បាន ។ ចំពោះបែបបទ និងនីតិវិធីនៃការប្តឹង ត្រូវអនុលោមតាមក្រមនីតិវិធីរដ្ឋប្បវេណីជាធរមាន ។

**មាត្រា៨៧៩** ._ សមត្ថកិច្ចពិនិត្យទិដ្ឋភាពច្បាប់របស់តុលាការជំនាញបរិស្ថាន

តុលាការជំនាញបរិស្ថានមានសមត្ថកិច្ចពិនិត្យទិដ្ឋភាពច្បាប់ដូចខាងក្រោម៖

១- ការពិចារណា វិធានការនិងដំណោះស្រាយនានាដែលបានកំណត់ក្នុងក្រមនេះ ត្រូវបានបញ្ចូលក្នុងកិច្ចព្រមព្រៀងសះជា ។

២- ត្រូវពិចារណាលើការស្តារ និងជួសជុលបរិស្ថាន និងធនធានធម្មជាតិជាអាទិភាព ។

៣- ដំណោះស្រាយ និងវិធានការនានា ត្រូវស្របនឹងគោលការណ៍ទូទៅ ដូចមានចែងក្នុងក្រមនេះ ។

៤- កម្មវត្ថុវិវាទបរិស្ថាន និងធនធានធម្មជាតិ អាចដោះស្រាយតាមរយៈយន្តការសន្ទានកម្មបរិស្ថាន និងធនធានធម្មជាតិ ។

៥- ខ្លឹមសារនៃកិច្ចព្រមព្រៀងសះជាបរិស្ថាន និងធនធានធម្មជាតិផ្ទុយនឹងសណ្តាប់ធ្នាប់សាធារណៈ ទំនៀមទម្លាប់ល្អរបស់សង្គម និងបទប្បញ្ញត្តិច្បាប់ផ្សេងៗទៀត ។

៦- ពិនិត្យភាពត្រឹមត្រូវនៃនីតិវិធីនៃសន្ធានកម្មបរិស្ថាន និងធនធានធម្មជាតិ ។
៧- សង្គតិភាពទៅនឹងគោលនយោបាយសាធារណៈរបស់ព្រះរាជាណាចក្រកម្ពុជា។

**មាត្រា៨៨០ ._** ការសម្រេចសេចក្តីរបស់តុលាការជំនាញបរិស្ថាននៃសាលាដំបូង

តុលាការជំនាញបរិស្ថាននៃសាលាដំបូង ត្រូវចេញសេចក្តីសម្រេចលើបណ្តឹងជំទាស់ ចំពោះកិច្ចព្រមព្រៀងសះជា របស់ក្រុមប្រឹក្សាជាតិសន្ធានកម្មបរិស្ថាន និងធនធានធម្មជាតិ ឬសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាជាតិដោះស្រាយវិវាទរដ្ឋបាលបរិស្ថាន និងធនធានធម្មជាតិដោយសាលក្រមក្នុងរយៈពេលយ៉ាងយូរបំផុត៣(បី)ខែ គិតចាប់ពីថ្ងៃទទួលបានពាក្យបណ្តឹង ។

រយៈពេលដូចមានកំណត់ក្នុងកថាខណ្ឌខាងលើនេះ មិនអាចពន្យាពេលបានឡើយ ។

**មាត្រា៨៨១ ._** បណ្តឹងជំទាស់ប្រឆាំងសេចក្តីសម្រេចរដ្ឋបាលបរិស្ថាន និងធនធានធម្មជាតិរបស់ក្រុមប្រឹក្សាជាតិដោះស្រាយវិវាទរដ្ឋបាលបរិស្ថាន និងធនធានធម្មជាតិ

គូភាគី ឬសាធារណជនដែលមានគោលដៅការពារផលប្រយោជន៍សាធារណៈ ឬអាជ្ញាធរមានសមត្ថកិច្ច មានសិទ្ធិប្តឹងជំទាស់ប្រឆាំងនឹងសេចក្តីសម្រេចរដ្ឋបាលបរិស្ថាន និងធនធានធម្មជាតិរបស់ក្រុមប្រឹក្សាជាតិដោះស្រាយវិវាទរដ្ឋបាលបរិស្ថាន និងធនធានធម្មជាតិទៅតុលាការជំនាញបរិស្ថាននៃសាលាដំបូង ដើម្បីពិនិត្យឡើងវិញអំពីនីត្យានុកូលភាពនៃសេចក្តីសម្រេច ។

បុគ្គលគ្រប់រូបដែលមិនពេញចិត្តសាលក្រមរបស់តុលាការជំនាញបរិស្ថាននៃសាលាដំបូង មានសិទ្ធិប្តឹងឧទ្ធរណ៍នឹងសាលក្រម ទៅតុលាការជាន់ខ្ពស់បាន ។ ចំពោះបែបបទ និងនីតិវិធីនៃការប្តឹង ត្រូវអនុលោមតាមក្រមនីតិវិធីរដ្ឋប្បវេណីជាធរមាន ។

**មាត្រា៨៨២ ._** សមត្ថកិច្ចពិនិត្យនីត្យានុកូលភាពនៃសេចក្តីសម្រេច ឬសកម្មភាពរដ្ឋបាលបរិស្ថាន និងធនធានធម្មជាតិ

តុលាការជំនាញបរិស្ថាន មានសមត្ថកិច្ចពិនិត្យលើបញ្ហានីត្យានុកូលភាពដូចខាងក្រោម៖

១- សុពលភាពនៃសេចក្តីសម្រេចរដ្ឋបាល មានជាអាទិ៍ សមត្ថកិច្ចចេញសេចក្តីសម្រេច វិការៈនៃទម្រង់ ឬនីតិវិធីនៃការចេញសេចក្តីសម្រេច ឬរំលោភអំណាច ។

២- ខ្លឹមសារជាសារវន្តនៃសេចក្តីសម្រេចដែលរំលោភគោលការណ៍ទូទៅនៃច្បាប់រួមមាន ការរំលោភច្បាប់ ឬបទបញ្ញាផ្សេងៗ ការភ័ណ្ឌច្រឡំផ្លូវច្បាប់ អង្គហេតុ ឬមូលហេតុនៃការចេញសេចក្តីសម្រេច ជាអាទិ៍ ។

ការពិនិត្យនីត្យានុកូលភាពនៃសេចក្ដីសម្រេច ឬសកម្មភាពរដ្ឋបាលបរិស្ថាន និងធនធានធម្មជាតិដូចមានចែងក្នុងកថាខណ្ឌខាងលើនេះ ត្រូវស្របទៅនឹងបទប្បញ្ញត្តិនៃក្រមនេះ និងបទដ្ឋានគតិយុត្តផ្សេងៗ ។

**មាត្រា៨៨៣** ._ រយៈពេលប្ដឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់

បណ្ដឹងឧទ្ធរណ៍ និងបណ្ដឹងសារទុក្ខ ត្រូវធ្វើឡើងក្នុងអំឡុងពេល១ (មួយ) ខែ គិតចាប់ពីថ្ងៃទទួលបានការបញ្ជូនលិខិតសាលក្រម ឬសាលដីកា ។ នីតិវិធីនៃការដោះស្រាយបណ្ដឹងឧទ្ធរណ៍ ឬបណ្ដឹងសារទុក្ខ ត្រូវអនុលោមតាមក្រមនីតិវិធីរដ្ឋប្បវេណីជាធរមាន លើកលែងតែមានបទប្បញ្ញត្តិពិសេសចែងក្នុងក្រមនេះ ។

**មាត្រា៨៨៤** ._ បណ្ដឹងឧទ្ធរណ៍នឹងសេចក្ដីសម្រេចរបស់តុលាការជំនាញបរិស្ថាននៃសាលាដំបូង

សាលាឧទ្ធរណ៍ ត្រូវចេញសេចក្ដីសម្រេចលើបណ្ដឹងឧទ្ធរណ៍ លើសាលក្រមតុលាការជំនាញបរិស្ថាននៃសាលាដំបូង ដោយសាលដីកា ក្នុងរយៈពេលយ៉ាងយូរបំផុត៦(ប្រាំមួយ)ខែ គិតចាប់ពីថ្ងៃទទួលបានពាក្យបណ្ដឹងឧទ្ធរណ៍ ។

រយៈពេលដូចមានចែងក្នុងកថាខណ្ឌខាងលើនេះ មិនអាចពន្យាបានឡើយ ។

**មាត្រា៨៨៥** ._ បណ្ដឹងសារទុក្ខនឹងសាលដីការបស់សាលាឧទ្ធរណ៍

តុលាការកំពូល ត្រូវចេញសេចក្ដីសម្រេចលើលើបណ្ដឹងសារទុក្ខ លើសាលដីការបស់សាលាឧទ្ធរណ៍ដោយសាលដីកា ក្នុងរយៈពេលយ៉ាងយូរបំផុត៩(ប្រាំបួន)ខែ គិតចាប់ពីថ្ងៃទទួលបានពាក្យបណ្ដឹងសារទុក្ខ ។ រយៈពេល៩(ប្រាំបួន)ខែនេះ មិនអាចពន្យាបានឡើយ ។

សម្រាប់បណ្ដឹងដែលមានគោលបំណងទាមទារសំណងផ្នែករដ្ឋប្បវេណី ឬសំណងខូចខាតបរិស្ថាន និងធនធានធម្មជាតិ ឬបណ្ដឹងទាក់ទងនឹងវិវាទរដ្ឋបាលបរិស្ថាន និងធនធានធម្មជាតិ តុលាការកំពូល ត្រូវចេញសេចក្ដីសម្រេចចុងក្រោយ ដោយមិនបញ្ជូនត្រឡប់មកឱ្យសាលាឧទ្ធរណ៍ធ្វើចំណាត់ការឡើងវិញទៅតាមនីតិវិធីដែលបានកំណត់ដោយក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាទេ លើកលែងតែបណ្ដឹងពាក់ព័ន្ធនឹងធនធានធម្មជាតិ និងបរិស្ថាននោះ មានចរិកលក្ខណៈព្រហ្មទណ្ឌ ទើបអាចបញ្ជូនត្រឡប់មកសាលាឧទ្ធរណ៍ឱ្យជំនុំជម្រះឡើងវិញបាន ។

**មាត្រា៨៨៦** ._ នីតិវិធីនៃបណ្ដឹងជាយុទ្ធសាស្ត្រប្រឆាំងនឹងការចូលរួមជាសាធារណជន

រូបបុគ្គល ឬនីតិបុគ្គលដែលទទួលរងការប្ដឹងចោទប្រកាន់ដោយមិនត្រឹមត្រូវពីរូបវន្តបុគ្គល ឬនីតិបុគ្គល ដែលធ្វើឱ្យទទួលរងផលប៉ះពាល់ដូចមានចែងក្នុងមាត្រា៨៥ អាចដាក់ពាក្យបណ្ដឹងតប ដើម្បីទាមទារសំណងរដ្ឋប្បវេណីទៅតុលាការមានសមត្ថកិច្ច ។

**មាត្រា៨៨៧** ._ លក្ខខណ្ឌនៃការទទួលយកបណ្ដឹងជាយុទ្ធសាស្ត្រប្រឆាំងនឹងការចូលរួមជាសាធារណៈ:

តុលាការជំនាញបរិស្ថាន ត្រូវត្រួតពិនិត្យលក្ខខណ្ឌនៃការទទួលយកបណ្ដឹងជាយុទ្ធសាស្ត្រប្រឆាំងនឹងការចូលរួមជាសាធារណៈ ដូចខាងក្រោម៖

១- សកម្មភាពនៃបណ្ដឹងតប មិនមានចេតនាក្នុងការបៀតបៀន ឬរារាំង ឬគៀបសង្កត់ដល់ការចូលរួមរបស់សាធារណជនលើសកម្មភាពបណ្ដឹង ។

២- គ្មានភស្តុតាងត្រឹមត្រូវ ឬច្បាស់លាស់ថាបណ្ដឹងរបស់សាធារណជនជាបណ្ដឹងដែលមានចេតនាបរិហារកេរ្តិ៍ ឬរារាំង ជ្រៀតជ្រែកដោយគំនិតទុច្ចរិតដល់ម្ចាស់បណ្ដឹងតប ។

តុលាការជំនាញបរិស្ថាន ត្រូវសម្រេចលើកបណ្ដឹងចោលដោយដីកាសម្រេចក្នុងករណីដែលបណ្ដឹងពុំគោរពតាមលក្ខខណ្ឌ ដូចចែងក្នុងកថាខណ្ឌខាងលើនេះ ។

ភាគីដែលមិនសុខចិត្តនឹងសេចក្ដីសម្រេចខាងលើនេះ មានសិទ្ធិប្ដឹងជំទាស់ទៅសាលាឧទ្ធរណ៍ក្នុងរយៈពេល១៥(ដប់ប្រាំ)ថ្ងៃ គិតចាប់ពីថ្ងៃទទួលបានការជូនដំណឹងអំពីដីកាសម្រេច ។ ការសម្រេចលើបណ្ដឹងឧទ្ធរណ៍របស់សាលាឧទ្ធរណ៍ បិទផ្លូវតវ៉ា ។

នីតិវិធីនៃការដោះស្រាយបណ្ដឹងជាយុទ្ធសាស្ត្រប្រឆាំងការចូលរួមជាសាធារណៈ ត្រូវអនុវត្តតាមនីតិវិធីដូចមានចែងក្នុងក្រមនីតិវិធីរដ្ឋប្បវេណីជាធរមាន លើកលែងតែមានបទប្បញ្ញត្តិចែងជាពិសេសក្នុងក្រមនេះ ។

**មាត្រា៨៨៨** ._ នីតិវិធីនៃការអនុវត្តសេចក្ដីសម្រេចរបស់តុលាការ

ការអនុវត្តដោយបង្ខំចំពោះសិទ្ធិទាមទារដែលមានគោលបំណងសងជាប្រាក់ ត្រូវអនុវត្តតាមនីតិវិធីនៃការអនុវត្តដោយបង្ខំ ដូចមានចែងក្នុងក្រមនីតិវិធីរដ្ឋប្បវេណីជាធរមាន ។

ការអនុវត្តសេចក្ដីសម្រេចនៃនីតិវិធីចាត់ចែងរក្សាការពារ ត្រូវអនុវត្តតាមនីតិវិធីនៃការអនុវត្តដោយបង្ខំចំពោះការចាត់ចែងរក្សាការពារ ដូចមានចែងក្នុងក្រមនីតិវិធីរដ្ឋប្បវេណីជាធរមាន ។

ការអនុវត្តដោយបង្ខំចំពោះសិទ្ធិទាមទារដែលគ្មានគោលបំណងសងជាប្រាក់ ជាការអនុវត្តដោយបង្ខំចំពោះសេចក្ដីសម្រេចរបស់តុលាការដែលបង្គាប់ឱ្យប្រគល់វត្ថុបី ឬបង្គាប់ឱ្យធ្វើ ឬមិនធ្វើ

សកម្មភាពណាមួយ ហើយត្រូវអនុវត្តទៅតាមនីតិវិធីអនុវត្តដោយបង្ខំ ដូចមានចែងក្នុងក្រមនីតិវិធីរដ្ឋប្បវេណីជាធរមាន ។ ក្រៅពីនេះ អ្នកដែលមិនអនុវត្តតាមសេចក្តីសម្រេចរបស់តុលាការ ត្រូវចោទប្រកាន់ និងផ្តន្ទាទោសតាមក្រមព្រហ្មទណ្ឌជាធរមាន ។

## ជំពូកទី២
## ការចាត់ចែងរក្សាការពារក្នុងរឿងក្តីបរិស្ថាន និងធនធានធម្មជាតិ

**មាត្រា៨៩** ._បទប្បញ្ញត្តិទូទៅ

នីតិវិធីនៃការចាត់ចែងរក្សាការពារ និងនីតិវិធីអនុវត្តរក្សាការពារ ត្រូវអនុវត្តតាមក្រមនីតិវិធីរដ្ឋប្បវេណីជាធរមាន លើកលែងតែមានបទប្បញ្ញត្តិពិសេសដែលមានចែងក្នុងក្រមនេះ ។

**មាត្រា៩០** ._ មូលដ្ឋាននៃការសម្រេចលើពាក្យសុំដីកាសម្រេចរក្សាការពារ

តុលាការចេញសេចក្តីសម្រេចលើពាក្យសុំចេញដីការក្សាការពារ ត្រូវផ្អែកលើគោលការណ៍ទូទៅនៃក្រមបរិស្ថាន និងត្រូវពិចារណាចំណុចដូចខាងក្រោម៖

១- មានមូលដ្ឋានច្បាប់គ្រប់គ្រាន់ដែលបង្ហាញពីសិទ្ធិ ឬទំនាក់ទំនងគតិយុត្ត ដែលត្រូវរក្សាការពារ។

២- មានការទទួលរងការខូចខាតដែលមិនអាចស្តារ ឬជួសជុលឡើងវិញបាន អំពីអំពើដែលបានប្រព្រឹត្ត ។

៣- ផលប្រយោជន៍សាធារណៈធំជាងផលប្រយោជន៍ឯកជន ឬ ផលប្រយោជន៍រួម ឬ ផលប្រយោជន៍សមូហភាពធំជាងផលប្រយោជន៍ឯកជន ។

**មាត្រា៩១** ._ រយៈពេលនៃការសម្រេចសេចក្តីរបស់តុលាការ

តុលាការជំនាញបរិស្ថាន ត្រូវសម្រេចលើពាក្យសុំចេញដីកាសម្រេចរក្សាការពារ ក្នុងរយៈពេលយ៉ាងយូរ៧(ប្រាំពីរ)ថ្ងៃ គិតពីថ្ងៃទទួលបានពាក្យសុំ ។ ក្នុងករណីដែលមានពាក្យសុំតវ៉ាចំពោះដីកាសម្រេចរក្សាការពារ តុលាការជំនាញបរិស្ថាន ត្រូវសម្រេចក្នុងរយៈពេលយ៉ាងយូរ២(ពីរ)សប្តាហ៍ គិតចាប់ពីថ្ងៃដែលគូភាគីបានទទួលលិខិតនីតិវិធីរបស់តុលាការចាប់មានអានុភាព ។

តុលាការនៃបណ្តឹងជំទាស់ ត្រូវសម្រេចលើបណ្តឹងជំទាស់នឹងដីកាសម្រេចលើពាក្យសុំតវ៉ា នឹងដីកាសម្រេចរក្សាការពារ ឬដីកាសម្រេចលើកចោលពាក្យសុំចេញដីកាសម្រេចរក្សាការពារ ក្នុងរយៈ

ពេលយ៉ាងយូរបំផុត២(ពីរ)សប្តាហ៍ គិតចាប់ពីថ្ងៃដែលគូភាគីបានទទួលលិខិតនីតិវិធីរបស់តុលាការចាប់មានអានុភាព ។

**មាត្រា៨៩២** ._ គោលការណ៍ការបញ្ជូន

នីតិវិធីនៃការបញ្ជូនត្រូវអនុវត្តតាមក្រមនីតិវិធីរដ្ឋប្បវេណីជាធរមាន លើកលែងតែមានចែងជាពិសេសក្នុងក្រមនេះ ។

ការបញ្ជូន ត្រូវធ្វើឡើងដោយឆន្ទានុសិទ្ធិរបស់តុលាការ ក្នុងការកំណត់ពីវិធីនៃការបញ្ជូន ឬទីកន្លែងដែលត្រូវបញ្ជូន ហើយដែលចាត់ទុកថាមានអានុភាពតាមផ្លូវច្បាប់ថាគូភាគីបានទទួលដំណឹងអំពីនីតិវិធីតុលាការ ឬអ្នកដែលទទួលបន្ទុកនៃការបញ្ជូន ។

ទីកន្លែងជាអាសយដ្ឋានដែលជាលំនៅដ្ឋាន ឬទីសំណាក់ ឬទីស្នាក់ការ ឬទីកន្លែងអាជីវកម្មរបស់នីតិបុគ្គលដែលគូភាគីបានបញ្ជាក់នៅក្នុងឯកសារជាផ្លូវការក្នុងការដាក់ពាក្យសុំ ឬពាក្យបណ្តឹង ។

**មាត្រា៨៩៣** ._ ការដាក់ប្រាតិភោគ

តុលាការអាចសម្រេចឱ្យអ្នកដាក់ពាក្យសុំដាក់ប្រាតិភោគ ឬមិនដាក់ប្រាតិភោគ ដោយពិចារណាលើមូលហេតុ ដូចខាងក្រោម៖

១- ពុំមានភស្តុតាង ឬមូលហេតុគ្រប់គ្រាន់ និងច្បាស់លាស់បង្ហាញពីទំហំនៃការខូចខាតបរិស្ថាន ឬផលប្រយោជន៍នៃភាគីដែលទទួលរងផលប៉ះពាល់ ។

២- លទ្ធភាពនៃធនធានសេដ្ឋកិច្ចរបស់ម្ចាស់បំណុល ។

៣- ឧត្តមភាពនៃកិច្ចការពារបរិស្ថាន ។

៤- កាលៈទេសៈផ្សេងៗទៀត ។

**មាត្រា៨៩៤** ._ បទប្បញ្ញត្តិដែលត្រូវអនុវត្តក្នុងរឿងបត្យាប័ន

បទប្បញ្ញត្តិនៃក្រមនីតិវិធីព្រហ្មទណ្ឌជាធរមាន ត្រូវយកមកអនុវត្តក្នុងរឿងបត្យាប័នពាក់ព័ន្ធនឹងបទល្មើសបរិស្ថាន និងធនធានធម្មជាតិ ដែលមានចរិកលក្ខណៈព្រហ្មទណ្ឌ ។

**មាត្រា៨៩៥** ._ ជំនួយផ្នែកច្បាប់ទៅវិញទៅមក

ក្នុងករណីមានបទល្មើសបរិស្ថាន និងធនធានធម្មជាតិដែលមានលក្ខណៈព្រហ្មទណ្ឌ អាជ្ញាធរតុលាការនៃព្រះរាជាណាចក្រកម្ពុជា អាចប្រគល់អំណាចឱ្យទៅអាជ្ញាធរខាងតុលាការមានសមត្ថកិច្ចនៃ

រដ្ឋបរទេសណាមួយ និងអាចទទួលអំណាចពីអាជ្ញាធរតុលាការនៃរដ្ឋបរទេសណាមួយតាមរយៈក្រសួងយុត្តធម៌ ដើម្បីៈ

១- ប្រមូលយកសក្ខីភាព ឬចម្លើយដែលឆ្លើយតាមផ្លូវតុលាការ ។

២- ឱ្យដំណឹងពីលិខិតផ្សេងៗរបស់តុលាការ ។

៣-ធ្វើការឆែកឆេរ ឃាត់ទុក និងដកហូត ។

៤- ធ្វើការពិនិត្យវត្ថុ និងទីកន្លែង ។

៥- ផ្តល់ព័ត៌មាន និងវត្ថុតាង ។

៦- ផ្តល់ឯកសារកំណត់ហេតុជាច្បាប់ដើម ឬសេចក្តីចម្លងដោយមានបញ្ជាក់ថាត្រឹមត្រូវតាមច្បាប់ដើមនៃឯកសារ និងសំណុំរឿង ។

៧- បង្ហាញ ឬផ្តល់សាក្សី អ្នកជំនាញ ឬជនដទៃទៀត រាប់ទាំងជនជាប់ឃុំខ្លួន ដែលយល់ព្រមជួយក្នុងការស៊ើបអង្កេត ឬយល់ព្រមចូលរួមក្នុងនីតិវិធី ។

៨- កំណត់អត្តសញ្ញាណ ឬស្រាវជ្រាវរកធនធាន ទ្រព្យសម្បត្តិ បរិក្ខារ និងសម្ភារៈទាំងដែលបានមកពីការប្រព្រឹត្តបទល្មើសដោយចេតនា និងមធ្យោបាយបទល្មើស ។

៩- ដាក់ក្រោមវិធានការរក្សាទុកជាបណ្តោះអាសន្ននូវផលិតផល និងទ្រព្យសម្បត្តិដែលបានមកពីបទល្មើសបរិស្ថាន និងធនធានធម្មជាតិ ដែលមានទាំងបរិក្ខារ សម្ភារៈដែលប្រើប្រាស់ ឬទុកសម្រាប់ប្រើប្រាស់ ដើម្បីប្រព្រឹត្តបទល្មើសដោយចេតនាបរិស្ថានដែលមានលក្ខណៈព្រហ្មទណ្ឌ ។

១០- ចាត់ឱ្យអនុវត្តសេចក្តីសម្រេចដែលបញ្ជាឱ្យធ្វើការរឹបអូស ដកហូត ឬយកមកវិញនូវផលិតផល ទ្រព្យសម្បត្តិ បរិក្ខារ សម្ភារៈទាំងឡាយ ដែលបានមកពីការប្រព្រឹត្តបទល្មើសបរិស្ថានដោយចេតនា ដែលមានលក្ខណៈព្រហ្មទណ្ឌ ។

១១- បញ្ជាឱ្យធ្វើការរឹបអូសវត្ថុទាំងឡាយ ដែលមានចែងក្នុងចំណុចខាងលើ ។

១២- ឱ្យដំណឹងអំពីការចោទប្រកាន់តាមនីតិវិធីព្រហ្មទណ្ឌ ។

១៣- សួរចម្លើយជនត្រូវចោទតាមនីតិវិធីព្រហ្មទណ្ឌ ។

១៤- រកឱ្យឃើញ និងកំណត់អត្តសញ្ញាណសាក្សី និងជនសង្ស័យ ។

**មាត្រា៨៩៦** ._ នីតិវិធីជំនួយផ្នែកច្បាប់ទៅវិញទៅមកផ្នែករដ្ឋប្បវេណី

នីតិវិធីនៃការអនុវត្តជំនួយផ្នែកច្បាប់ទៅវិញទៅមកផ្នែករដ្ឋប្បវេណី ត្រូវអនុវត្តតាមគោលការណ៍ទាំងឡាយ ដែលបានកំណត់ក្នុងអនុសញ្ញា ឬកិច្ចព្រមព្រៀងទ្វេភាគី និងពហុភាគី ដែលព្រះរាជាណាចក្រកម្ពុជាជាភាគីហត្ថលេខី និងច្បាប់ជាតិជាធរមាន ។

## ជំពូកទី៣
## នីតិវិធីដោះស្រាយបទល្មើសបរិស្ថាន និងធនធានធម្មជាតិ
## ដែលមានចរិកលក្ខណៈព្រហ្មទណ្ឌ
## ផ្នែកទី១
## នីតិវិធីនៃការស៊ើបអង្កេត ការស៊ើបសួរ ការចោទប្រកាន់ និងការជំនុំជម្រះ

**មាត្រា៤៩៧** ._ បទប្បញ្ញត្តិទូទៅ

បទប្បញ្ញត្តិនៃក្រមនីតិវិធីព្រហ្មទណ្ឌត្រូវយកមកអនុវត្តនៅក្នុងការស៊ើបអង្កេត ការចោទប្រកាន់បទល្មើសបរិស្ថាន និងធនធានធម្មជាតិ លើកលែងតែក្នុងករណីដែលមានចែងជាពិសេសក្នុងផ្នែកនេះ ។

**មាត្រា៤៩៨** ._ នីតិវិធីនៃការស៊ើបអង្កេត និងស៊ើបសួរ ការចោទប្រកាន់ និងការជំនុំជម្រះ

នីតិវិធីនៃការស៊ើបអង្កេត ការស៊ើបសួរ និងការជំនុំជម្រះ ត្រូវអនុវត្តតាមការក្រមនីតិវិធីព្រហ្មទណ្ឌជាធរមាន លើកលែងតែមានចែងជាពិសេសក្នុងក្រមនេះ ។

**មាត្រា៤៩៩** ._ ចេតនាប្រព្រឹត្តបទល្មើសបរិស្ថាន និងធនធានធម្មជាតិដោយចេតនា

ពុំមានបទល្មើសទេ ប្រសិនបើគ្មានចេតនាប្រព្រឹត្ត ប៉ុន្តែក្នុងការចោទប្រកាន់បទល្មើសបរិស្ថាន និងធនធានធម្មជាតិ បទល្មើសមួយអាចកើតចេញពីលក្ខខណ្ឌដូចខាងក្រោម៖

១- ចេទនាប្រព្រឹត្ត ឬបំណងប្រព្រឹត្ត ។

២- បានដឹងអំពីបទល្មើស ហើយគ្មានចាត់វិធានការទប់ស្កាត់ ។

៣- ការធ្វេសប្រហែស ឬខ្ជីខ្ជាក្នុងការបំពេញកាតព្វកិច្ចតាមច្បាប់កំណត់ ។

៤- មិនអនុវត្តតាមបទប្បញ្ញត្តិច្បាប់ ឬលក្ខខណ្ឌតម្រូវរបស់ច្បាប់ ឬបទបញ្ជាផ្សេងៗ ។

## ផ្នែកទី២
## ភស្តុតាងក្នុងរឿងក្តីបរិស្ថាន និងធនធានធម្មជាតិ

**មាត្រា៩០០ .**_ ភស្តុតាងនៃបណ្តឹងបរិស្ថាន និងធនធានធម្មជាតិដែលទាក់ទងផ្នែករដ្ឋប្បវេណី និង ព្រហ្មទណ្ឌ

ភស្តុតាងជាមូលដ្ឋាននៃបណ្តឹងបរិស្ថាន និងធនធានធម្មជាតិដែលទាក់ទងផ្នែករដ្ឋប្បវេណី និង ព្រហ្មទណ្ឌ មានដូចខាងក្រោម៖

១- ឯកសារ ។

២- កស្សិណសាក្សី ។

៣- វត្ថុនានា ។

៤- ការពន្យល់បកស្រាយ ។

៥- ការពិនិត្យផ្ទាល់របស់តុលាការ ។

**មាត្រា៩០១ .**_ ភស្តុតាងជាឯកសារ

ភស្តុតាងជាឯកសារមានដូចខាងក្រោម៖

១- លិខិតអនុញ្ញាត អាជ្ញាប័ណ្ណ កិច្ចព្រមព្រៀង វិញ្ញាបនបត្រផ្សេងៗ ។

២- របាយការណ៍នៃការត្រួតពិនិត្យផ្សេងៗ ។

៣- វិក័យបត្រ ។

៤- របាយការណ៍នៃការធ្វើការពិសោធន៍ ។

៥- ផែនទី ។

៦- រូបថត វីដេអូ ឬសំឡេង ។

៧- ផ្សេងៗ ។

**មាត្រា៩០២ .**_ ភស្តុតាងជាកស្សិណសាក្សី

ភស្តុតាងជាកសិណសាក្សី មានដូចខាងក្រោម៖

១- សាក្សីជាមនុស្សទូទៅ ។

២- សាក្សីជាអ្នកជំនាញ ។

៣- ផ្សេងៗ ។

**មាត្រា៩០៣**._ ភស្តុតាងជាវត្ថុដែលពាក់ព័ន្ធនឹងកម្មវត្ថុនៃវិវាទ

ភស្តុតាងជាវត្ថុដែលពាក់ព័ន្ធនឹងកម្មវត្ថុនៃវិវាទ មានដូចខាងក្រោម៖

១- សំណាក ។

២- ផ្សេងៗ ។

**មាត្រា៩០៤**._ ភស្តុតាងជាការពន្យល់បកស្រាយ

ភស្តុតាងជាការពន្យល់បកស្រាយ មានដូចខាងក្រោម៖

១- ដ្យាក្រាម ។

២- តារាងនានា ។

៣- ផ្សេងៗ ។

**មាត្រា៩០៥**._ ការពិនិត្យភស្តុតាងជាសម្ញូហារិធី

ការពិនិត្យភស្តុតាងដោយសម្ញូហារិធី មានដូចខាងក្រោម៖

១- ការអះអាងរបស់ភាគីនៃវិវាទ ។

២- ការអះអាងរបស់អ្នកជំនាញការបច្ចេកទេស ។

៣- ការអះអាងរបស់សាក្សី ។

៤- ការអះអាងរបស់មេធាវី ។

៥- ផ្សេងៗ ។

**មាត្រា៩០៦**._ ភស្តុតាងនៃបណ្ដឹងបរិស្ថាន និងធនធានធម្មជាតិ ដែលទាក់ទងនឹងវិវាទរដ្ឋបាលបរិស្ថាននិងធនធានធម្មជាតិ

ភស្តុតាងនៃបណ្ដឹងបរិស្ថាន និងធនធានធម្មជាតិ ដែលទាក់ទងនឹងផ្នែករដ្ឋបាលបរិស្ថាន និងធនធានធម្មជាតិ មានដូចខាងក្រោម៖

១- សេចក្ដីសម្រេចរដ្ឋបាលបរិស្ថាន ឬសកម្មភាពរដ្ឋបាលបរិស្ថាន និងធនធានធម្មជាតិ ។

២- ការអះអាងរបស់សាក្សី ។

៣- សេចក្ដីសន្និដ្ឋានរបស់អ្នកជំនាញបច្ចេកទេស ។

៤- ការអះអាងរបស់ភាគីវិវាទនៃវិវាទ ។

៥- ផ្សេងៗ ។

**មាត្រា៩០៧ ._** ការពិនិត្យភស្តុតាងក្នុងបណ្តឹងបរិស្ថាន និងធនធានធម្មជាតិ ដែលមានចរិកលក្ខណៈ រដ្ឋប្បវេណី ព្រហ្មទណ្ឌ ឬរដ្ឋបាលបរិស្ថាន និងធនធានធម្មជាតិ

ចំពោះការពិនិត្យភស្តុតាងក្នុងបណ្តឹងបរិស្ថាន និងធនធានធម្មជាតិ ដែលមានចរិកលក្ខណៈរដ្ឋប្បវេណី និងរដ្ឋបាលបរិស្ថាន និងធនធានធម្មជាតិ ត្រូវធ្វើឡើងដោយសេរី ។

ចំពោះការពិនិត្យភស្តុតាងក្នុងបណ្តឹងបរិស្ថាន និងធនធានធម្មជាតិ ដែលមានចរិកលក្ខណៈ ព្រហ្មទណ្ឌ ត្រូវអនុលោមតាមវិធានភស្តុតាង ដូចមានចែងក្នុងក្រមនីតិវិធីព្រហ្មទណ្ឌជាធរមាន ។

**មាត្រា៩០៨ ._** លក្ខខណ្ឌចាំបាច់នៃភស្តុតាងក្នុងរឿងក្តីបរិស្ថាន និងធនធានធម្មជាតិ

ភស្តុតាងក្នុងរឿងក្តីបរិស្ថាន និងធនធានធម្មជាតិ ត្រូវមានភស្តុតាងចាំបាច់ដាច់ខាត ជាសេចក្តីសន្និដ្ឋានរបស់ជំនាញបច្ចេកទេសវិទ្យាសាស្ត្រមកធ្វើជាមូលដ្ឋានក្នុងការពិចារណានិងសម្រេចសេចក្តី។

**មាត្រា៩០៩ ._** វត្ថុតាងដែលរឹបអូសបាន

វត្ថុតាងដែលរឹបអូសបាន ត្រូវគ្រប់គ្រង និងអនុវត្តតាមនីតិវិធីរដ្ឋប្បវេណី និងនីតិវិធីព្រហ្មទណ្ឌជាធរមាន លើកលែងតែមានចែងជាពិសេសនៅក្នុងក្រមនេះ ។

## មាតិកាទី២
## មន្ត្រីនគរបាលយុត្តិធម៌បរិស្ថាន និងធនធានធម្មជាតិ និងមន្ត្រីអធិការកិច្ចបរិស្ថាន និងធនធានធម្មជាតិ
## ជំពូកទី១
## នគរបាលយុត្តិធម៌បរិស្ថាន និងធនធានធម្មជាតិ

**មាត្រា៩១០ ._** មន្ត្រីនគរបាលយុត្តិធម៌បរិស្ថាន និងធនធានធម្មជាតិ

មន្ត្រីរាជការសាធារណៈ ឬមន្ត្រីក្រសួង ស្ថាប័នពាក់ព័ន្ធ ដែលទទួលបន្ទុកពាក់ព័ន្ធនឹងកិច្ចការពារបរិស្ថាន និងគ្រប់គ្រងធនធានធម្មជាតិ ដែលកំណត់ដោយក្រមនេះ និងច្បាប់ពិសេសផ្សេងទៀត ត្រូវទទួលបាននីតិសម្បទាជាមន្ត្រីនគរបាលយុត្តិធម៌បរិស្ថាន និងធនធានធម្មជាតិ ។

**មាត្រា៥១១**._ សមាសភាព និងលក្ខណៈសម្បត្តិមន្ត្រីនគរបាលយុត្តិធម៌បរិស្ថាន និងធនធានធម្មជាតិ

ក្រសួង ស្ថាប័នពាក់ព័ន្ធ ដែលទទួលបន្ទុកពាក់ព័ន្ធនឹងកិច្ចការពារបរិស្ថាន និងគ្រប់គ្រងធនធានធម្មជាតិ ត្រូវរៀបចំលិខិតបទដ្ឋានគតិយុត្ត ដើម្បីកំណត់ពីសមាសភាព និងមន្ត្រីរាជការសាធារណៈដែលទទួលបាននីតិសម្បទាជាមន្ត្រីនគរបាលយុត្តិធម៌បរិស្ថាន និងធនធានធម្មជាតិ ។

**មាត្រា៥១២**._ នីតិវិធីក្នុងការទទួលបាននីតិសម្បទាជាមន្ត្រីនគរបាលយុត្តិធម៌បរិស្ថាន និងធនធានធម្មជាតិ

មន្ត្រីនគរបាលយុត្តិធម៌បរិស្ថាន និងធនធានធម្មជាតិ ត្រូវធ្វើសម្បថនៅចំពោះមុខសាលាឧទ្ធរណ៍ ដើម្បីទទួលបាននីតិសម្បទាជាមន្ត្រីនគរបាលយុត្តិធម៌បរិស្ថាន និងធនធានធម្មជាតិ ។ សម្បថមិនចាំបាច់ធ្វើសាជាថ្មីម្តងទៀតឡើយ នៅពេលដែលទទួលបាននីតិសម្បទាជាមន្ត្រីនគរបាលយុត្តិធម៌បរិស្ថាន និងធនធានធម្មជាតិនៅពេលក្រោយទៀត ។

បែបបទ និងនីតិវិធីនៃការផ្តល់នីតិសម្បទាជាមន្ត្រីនគរបាលយុត្តិធម៌បរិស្ថាន និងធនធានធម្មជាតិ ត្រូវកំណត់ដោយលិខិតបទដ្ឋានគតិយុត្ត អន្តរក្រសួងរវាងក្រសួង ស្ថាប័នពាក់ព័ន្ធនឹងកិច្ចការពារបរិស្ថាន និងគ្រប់គ្រងធនធានធម្មជាតិ និងក្រសួង ស្ថាប័នទទួលបន្ទុកយុត្តិធម៌ ។

ចំពោះរូបមន្តនៃពាក្យសម្បថ ត្រូវកំណត់ដោយក្រសួង ស្ថាប័នទទួលបន្ទុកយុត្តិធម៌ ។

**មាត្រា៥១៣**._ បេសកកម្មមន្ត្រីនគរបាលយុត្តិធម៌បរិស្ថាន និងធនធានធម្មជាតិ

បេសកកម្មរបស់មន្ត្រីរាជការសាធារណៈ ឬមន្ត្រីរបស់ក្រសួង ស្ថាប័នពាក់ព័ន្ធនឹងកិច្ចការពារបរិស្ថាន និងធនធានធម្មជាតិដែលទទួលបាននីតិសម្បទាជានគរបាលយុត្តិធម៌បរិស្ថាន និងធនធានធម្មជាតិ ត្រូវអនុលោមតាមក្រមនីតិវិធីព្រហ្មទណ្ឌជាធរមាន លើកលែងតែមានចែងជាពិសេសនៅក្នុងក្រមនេះ ឬច្បាប់ពិសេសដទៃទៀតជាធរមាន ។

**មាត្រា៥១៤**._ សិទ្ធិអំណាចនៃការប្រើប្រាស់អាវុធ

មន្ត្រីរាជការសាធារណៈ ឬមន្ត្រីក្រសួង ស្ថាប័នពាក់ព័ន្ធដែលទទួលបន្ទុកពាក់ព័ន្ធនឹងកិច្ចការពារបរិស្ថាន និងគ្រប់គ្រងធនធានធម្មជាតិ ដែលមាននីតិសម្បទាជាមន្ត្រីនគរបាលយុត្តិធម៌បរិស្ថាន និងធនធានធម្មជាតិ មានសិទ្ធិប្រើប្រាស់អាវុធ ក្នុងអំឡុងពេលប្រតិបត្តិការរបស់ខ្លួន ។

ការប្រើប្រាស់អាវុធ ត្រូវអនុលោមតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តរបស់ក្រសួង ស្ថាប័នទទួលបន្ទុកមហាផ្ទៃ។

**មាត្រា៩១៥ ._** នីតិវិធីស៊ើបអង្កេតរបស់មន្ត្រីនគរបាលយុត្តិធម៌ចំពោះបទល្មើសបរិស្ថាន និងធនធានធម្មជាតិ

នីតិវិធីក្នុងការកសាងសំណុំរឿងរបស់មន្ត្រីរាជការសាធារណៈ ឬមន្ត្រីក្រសួង ស្ថាប័នពាក់ព័ន្ធនឹងកិច្ចការពារបរិស្ថាន និងធនធានធម្មជាតិ ដែលទទួលបាននីតិសម្បទាជាមន្ត្រីនគរបាលបរិស្ថាន និងធនធានធម្មជាតិ ត្រូវអនុលោមតាមក្រមនីតិវិធីព្រហ្មទណ្ឌជាធរមាន ។

ទម្រង់ និងបែបបទ ក្នុងការធ្វើកំណត់ហេតុរបស់មន្ត្រីនគរបាលយុត្តិធម៌បរិស្ថាន និងធនធានធម្មជាតិ ត្រូវកំណត់ដោយលិខិតបទដ្ឋានគតិយុត្តអន្តរក្រសួងរវាងក្រសួងស្ថាប័នពាក់ព័ន្ធនឹងកិច្ចការពារបរិស្ថាន និងគ្រប់គ្រងធនធនធម្មជាតិ និងក្រសួង ស្ថាប័នទទួលបន្ទុកយុត្តិធម៌ ។

**មាត្រា៩១៦ ._** កាតព្វកិច្ចរបស់អាជ្ញាធរពាក់ព័ន្ធក្នុងការសហការចំពោះការស៊ើបអង្កេតបទល្មើសបរិស្ថាន និងធនធានធម្មជាតិ

អាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ កងកម្លាំងប្រដាប់អាវុធ និងអាជ្ញាធរពាក់ព័ន្ធទាំងអស់ ត្រូវបង្កភាពងាយស្រួល ជួយសម្រួល និងជួយផ្តល់កម្លាំងសហការក្នុងការស្រាវជ្រាវ ស៊ើបអង្កេត ត្រួតពិនិត្យបទល្មើស និងបង្ក្រាបបទល្មើសបរិស្ថាន និងធនធានធម្មជាតិ ក្នុងករណីមានការស្នើសុំពីមន្ត្រីនគរបាលយុត្តិធម៌បរិស្ថាន និងធនធានធម្មជាតិ ។

**មាត្រា៩១៧ ._** ការប្រើប្រាស់ឯកសណ្ឋានក្នុងការស៊ើបអង្កេតលើបណ្តឹងបរិស្ថាន និងធនធានធម្មជាតិ

មន្ត្រីរាជការសាធារណៈ ឬមន្ត្រីក្រសួង ស្ថាប័នពាក់ព័ន្ធនឹងកិច្ចការពារបរិស្ថាន និងធនធានធម្មជាតិ ដែលទទួលបាននីតិសម្បទាជាមន្ត្រីនគរបាលយុត្តិធម៌បរិស្ថាន និងធនធានធម្មជាតិ ត្រូវមានប័ណ្ណសម្គាល់អត្តសញ្ញាណច្បាស់លាស់ នៅពេលចុះបំពេញបេសកកម្មក្នុងនាមជាមន្ត្រីនគរបាលយុត្តិធម៌បរិស្ថាន និងធនធានធម្មជាតិ ។

**មាត្រា៩១៨ ._** សិទ្ធិរបស់រូបវន្តបុគ្គល និងសហគមន៍មូលដ្ឋាន

រូបវន្តបុគ្គល ឬសហគមន៍មូលដ្ឋាន មានសិទ្ធិចូលរួមក្នុងកិច្ចការពារបរិស្ថាន និងធនធានធម្មជាតិ ដូចខាងក្រោម៖

១- ធ្វើការឃ្លាំមើលល្បាតដោយមានការសហការជាមួយមន្ត្រីមានសមត្ថកិច្ចពាក់ព័ន្ធ ។

២- ធ្វើការឃាត់ទុកជនល្មើសក្នុងបទល្មើសជាក់ស្តែង និងឃាត់វត្ថុតាងនៃបទល្មើស រួចបញ្ជូនទៅមន្ត្រីមានសមត្ថកិច្ចពាក់ព័ន្ធដែលនៅជិតបំផុត ។

៣- ផ្តល់វត្ថុតាង របាយការណ៍ និងព័ត៌មានដទៃទៀតពាក់ព័ន្ធនឹងបទល្មើសទៅកាន់ក្រសួង ស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធ ។

៤- ផ្តល់វត្ថុតាង និងព័ត៌មានពាក់ព័ន្ធនឹងបទល្មើសបរិស្ថាន និងធនធានធម្មជាតិទៅឱ្យស្ថាប័នតុលាការមានសមត្ថកិច្ច ។

## ជំពូកទី២
## មន្ត្រីអធិការកិច្ចបរិស្ថាន និងធនធានធម្មជាតិ

**មាត្រា៩១៩ .**_ ការតែងតាំងមន្ត្រីអធិការកិច្ចបរិស្ថាន និងធនធានធម្មជាតិ

ក្រសួង ស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធនឹងកិច្ចការពារបរិស្ថាន និងគ្រប់គ្រងធនធានធម្មជាតិ ត្រូវចាត់តាំងមន្ត្រីដោយឡែក ដើម្បីទទួលបន្ទុកកិច្ចការធ្វើអធិការកិច្ចពាក់ព័ន្ធនឹងកិច្ចការពារបរិស្ថាន និងគ្រប់គ្រងធម្មជាតិ ស្របតាមក្រមនេះ ច្បាប់ពិសេសដោយឡែក និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធផ្សេងទៀត ។

**មាត្រា៩២០ .**_ ភារកិច្ច និងតួនាទីរបស់មន្ត្រីអធិការកិច្ចបរិស្ថាន និងធនធានធម្មជាតិ

មន្ត្រីអធិការកិច្ចបរិស្ថាន និងធនធានធម្មជាតិ មានភារកិច្ច និងតួនាទី ដូចខាងក្រោម៖

១- ធ្វើអធិការកិច្ច តាមដាន និងត្រួតពិនិត្យការគោរពច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន ដែលពាក់ព័ន្ធនឹងកិច្ចការពារបរិស្ថាន និងធនធានធម្មជាតិ ដែលស្ថិតនៅក្រោមសមត្ថកិច្ចរបស់ខ្លួន ។

២- ធ្វើរបាយការណ៍ស្តីពីលទ្ធផលនៃការធ្វើអធិការកិច្ចដាក់ជូនថ្នាក់ដឹកនាំដើម្បីពិនិត្យ និងសម្រេច ។

៣- ចាត់វិធានការចាំបាច់ក្នុងករណីមានការបំពានក្រមនេះ ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធផ្សេងទៀត ។

៤- ចេញបទបញ្ជានានាតាមការចាំបាច់ ក្នុងករណីមានការគំរាមកំហែងដល់បរិស្ថាន និងធនធានធម្មជាតិកើតឡើង ។

៥- ជូនដំណឹងដល់សាធារណជន និងក្រសួង ស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធដទៃទៀត ក្នុងករណីមានការគំរាមកំហែងធ្ងន់ធ្ងរដល់បរិស្ថាន និងធនធានធម្មជាតិ ។

ក្រៅពីភារកិច្ច និងតួនាទីដែលកំណត់ក្នុងក្រមនេះ មន្ត្រីអធិការកិច្ចបរិស្ថាន និងធនធានធម្មជាតិ ត្រូវអនុវត្តភារកិច្ច និងតួនាទីរបស់ខ្លួន ដូចមានចែងក្នុងច្បាប់ពិសេសដោយឡែក និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធផ្សេងទៀតផងដែរ ។

**មាត្រា៩២១** ._ កិច្ចសហការចំពោះការធ្វើអធិការកិច្ចពាក់ព័ន្ធនឹងបរិស្ថាន និងធនធានធម្មជាតិ

ម្ចាស់គម្រោង ឬប្រតិបត្តិករ ឬស្ថាប័នពាក់ព័ន្ធ ត្រូវមានកាតព្វកិច្ចសហការជាមួយមន្ត្រីអធិការកិច្ចបរិស្ថាន និងធនធានធម្មជាតិ ក្នុងការធ្វើអធិការកិច្ចពាក់ព័ន្ធនឹងបរិស្ថាន និងធនធានធម្មជាតិ ។

**មាត្រា៩២២** ._ ការប្រើប្រាស់ឯកសណ្ឋានក្នុងការស៊ើបអង្កេតលើបណ្តឹងបរិស្ថាន និងធនធានធម្មជាតិ

មន្ត្រីអធិការកិច្ចបរិស្ថាន និងធនធានធម្មជាតិ ត្រូវមានលិខិតអនុញ្ញាត និងពាក់ប័ណ្ណសម្គាល់អត្តសញ្ញាណច្បាស់លាស់ និងពាក់ឯកសណ្ឋាន នៅពេលចុះបំពេញភារកិច្ច និងតួនាទីរបស់ខ្លួន ។

## មាតិកាទី៣
## ការស្តារឡើងវិញ និងសំណងលើការខូចខាតបរិស្ថាន
## ជំពូកទី១
## យន្តការវាយតម្លៃទំហំនៃការខូចខាតបរិស្ថាន

**មាត្រា៩២៣** ._ ការបង្កើតយន្តការសម្រាប់ការស្តារបរិស្ថានឡើងវិញ និងកំណត់ទំហំនៃសំណងការខូចខាត

នីតិវិធី និងបែបបទនៃបង្កើតយន្តការ ការវាយតម្លៃទំហំនៃការខូចខាតបរិស្ថាន ការស្តារបរិស្ថានឡើងវិញ និងការទូរទាត់សងការខូចខាតបរិស្ថាន និងការទូទាត់ការខូចខាតផ្នែកហិរញ្ញវត្ថុ ដែលកើតចេញពីការខូចខាតបរិស្ថាន ត្រូវកំណត់ដោយលិខិតបទដ្ឋានគតិយុត្តរបស់ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន ។

**មាត្រា៩២៤ ._** ការទទួលខុសត្រូវចំពោះការខូចខាតបរិស្ថាន

រូបវន្តបុគ្គល ឬនីតិបុគ្គលណា ដែលបានរកឃើញថា បានបង្កការខូចខាតបរិស្ថាន ឬការខូចខាតផ្នែកហិរញ្ញវត្ថុដែលកើតចេញពីការខូចខាតបរិស្ថាន ត្រូវទទួលខុសត្រូវក្នុងការស្តារបរិស្ថានឡើងវិញ ឬត្រូវទូទាត់សំណងការខូចខាត និងការបាត់បង់ទាំងអស់ដែលបានកើតឡើង ។

**មាត្រា៩២៥ ._** ការចូលរួមក្នុងដំណើរការនៃស្តារការខូចខាតបរិស្ថានឡើងវិញ

ក្រសួង ស្ថាប័នពាក់ព័ន្ធ អាជ្ញាធរមានសមត្ថកិច្ច ជនជាតិដើមភាគតិច សង្គមស៊ីវិល នីតិបុគ្គល និងរូបវន្តបុគ្គលដែលទទួលរងផលប៉ះពាល់ទាំងអស់ ត្រូវផ្តល់ព័ត៌មានបច្ចេកទេស ចំណេះដឹង បទពិសោធន៍ និងក្តីកង្វល់ ដែលពាក់ពាក់ព័ន្ធទាំងឡាយ ដើម្បីចូលរួមក្នុងការធ្វើសេចក្តីសម្រេចក្នុងការស្តារឡើងវិញនូវការខូចខាតបរិស្ថាន ។

## ជំពូកទី២
## ការទទួលខុសត្រូវបរិស្ថាន

**មាត្រា៩២៦ ._** ការទទួលខុសត្រូវសំណងផ្នែកបរិស្ថាន

រូបវន្តបុគ្គល ឬនីតិបុគ្គល ឬមន្ត្រីរាជការ ត្រូវទទួលខុសត្រូវចំពោះសំណងបរិស្ថាន ដោយមិនតម្រូវឱ្យមានបង្ហាញពីធាតុចេតនា និងការដឹងនោះទេ  ក្នុងករណីដូចខាងក្រោម៖

១- មិនបានធ្វើសកម្មភាព ឬការខកខានមិនបានចាត់វិធានការទប់ស្កាត់ ដែលបង្កឱ្យមានការខូចខាតបរិស្ថាន ។

២- បំពេញការងារលើសពីសិទ្ធិអំណាចរបស់ខ្លួន ឬប្រព្រឹត្តផ្ទុយនឹងក្រមនេះ ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានា ដែលបង្កឱ្យមានការខូចខាតបរិស្ថាន ។

**មាត្រា៩២៧ ._** ការរឹបអូសឧបករណ៍ដែលបង្កការខូចខាតបរិស្ថាន

រាល់ការប្រើប្រាស់ឧបករណ៍ដោយខុសច្បាប់ និងបង្កការខូចខាតបរិស្ថាន ត្រូវរឹបអូស និងប្រើប្រាស់សម្រាប់ការស្តារបរិស្ថានដែលទទួលរងការខូចខាតឡើងវិញ ស្របតាមនីតិវិធីដែលមានចែងក្នុងក្រមនេះ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធដោយឡែក ។

**មាត្រា៩២៨**._ ការទទួលខុសត្រូវនៃនីតិបុគ្គល

នាយកនៃនីតិបុគ្គល ត្រូវទទួលខុសត្រូវចំពោះសំណងផ្នែកបរិស្ថាន តាមលក្ខណៈ និងទំហំដូចគ្នាទៅនឹងការទទួលខុសត្រូវរបស់នីតិបុគ្គលនោះ ដូចមានចែងក្នុងមាត្រា៩២៦ នៃក្រមនេះ ។

**មាត្រា៩២៩**._ កាតព្វកិច្ចសាមគ្គី

បុគ្គលគ្រប់រូបត្រូវមានកាតព្វកិច្ចទទួលខុសត្រូវរួមគ្នា ចំពោះការខូចខាតបរិស្ថាន ក្នុងករណីដែលមានបុគ្គលទទួលខុសត្រូវលើសពី១(មួយ)នាក់ ។ បុគ្គលម្នាក់ៗ ត្រូវទទួលខុសត្រូវសងសំណងខូចខាតដោយពេញលេញ ដោយមិនគិតពីការចូលរួមចំណែកជាក់ស្តែងនៃបុគ្គលម្នាក់ៗដែលបង្កឱ្យមានការខូចខាតជាក់ស្តែងនោះទេ ។

## ជំពូកទី៣
## ការមិនទទួលខុសត្រូវចំពោះការខូចខាតបរិស្ថាន

**មាត្រា៩៣០**._ ការមិនទទួលខុសត្រូវ

រូបវន្តបុគ្គល ឬនីតិបុគ្គល មិនត្រូវទទួលខុសត្រូវឡើយ ក្នុងករណីដែលៈ

១- ការខូចខាតបរិស្ថាន ត្រូវបានបង្កឡើងទាំងស្រុងដោយសារតែគ្រោះមហន្តរាយធម្មជាតិធ្ងន់ធ្ងរ ដែលមិនបានរំពឹងទុកមុន ឬសកម្មភាពនៃសង្គ្រាម ។

៣- ការខូចខាតបរិស្ថាន ត្រូវបានបង្កឡើងទាំងស្រុងដោយសារតែទង្វើ ឬការខកខានរបស់តតិយជនក្រៅពីបុគ្គលិកនយោជិត ឬភ្នាក់ងាររបស់រូបវន្តបុគ្គល ឬនីតិបុគ្គលនោះ ។

៤- ការខូចខាតបរិស្ថាន ត្រូវបានបង្កឡើងទាំងស្រុងដោយសារតែសកម្មភាពដែលបានអនុញ្ញាតយ៉ាងច្បាស់លាស់ដោយច្បាប់ ។

៥- ការខូចខាតបរិស្ថាន ត្រូវបានបង្កឡើងទាំងស្រុងដោយសារតែសកម្មភាពដែលបានអនុញ្ញា ជាពិសេស និងដែលបានពណ៌នាពីភាពជាក់លាក់ទាក់ទងនឹងប្រភេទ និងទំហំនៃការខូចខាតនៅក្នុងផែនការគ្រប់គ្រងបរិស្ថាន ការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និង/ឬវិញ្ញាបនបត្រ និងលិខិតឯកភាពលើការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ។

**មាត្រា៩៣១**._ ការលើកលែងចំពោះការមិនទទួលខុសត្រូវការខូចខាតបរិស្ថាន

ការមិនទទួលខុសត្រូវការខូចខាតបរិស្ថាន ដូចមានចែងក្នុងមាត្រា៩៣០ នៃក្រមនេះ មិនត្រូវយកមកអនុវត្តឡើយ ក្នុងករណីដូចខាងក្រោម៖

១- សកម្មភាពដែលបង្កឱ្យមានការខូចខាតនោះ ត្រូវបានអនុវត្តដោយមានការរំលោភបំពានទាំងស្រុង ឬផ្នែកណាមួយនៃក្រមបរិស្ថាន ឬលិខិតបទដ្ឋានគតិយុត្តណាមួយផ្សេងទៀត ។

២- សកម្មភាពដែលបង្កឱ្យមានការខូចខាត ត្រូវបានធ្វើឡើងយោងតាមលក្ខខណ្ឌសម្បទាន អាជ្ញាប័ណ្ណ ឬការអនុញ្ញាតជាក់ស្ដែងផ្សេងទៀតដែលត្រូវបានផ្ដល់ឱ្យ មិនស្របតាមលិខិតបទដ្ឋានគតិយុត្ត មានជាអាទិ៍ ការអនុញ្ញាតដែលចេញដោយមន្ត្រីដែលគ្មានសិទ្ធិក្នុងការផ្ដល់ការអនុញ្ញាតនោះ ឬការខកខានមិនបានបំពេញតាមលក្ខខណ្ឌដែលច្បាប់តម្រូវ មុនពេលចេញការអនុញ្ញាតជាដើម ។

៣- សកម្មភាពដែលនាំឱ្យមានការខូចខាតបរិស្ថាន ត្រូវបានពិនិត្យឃើញថា មានចំនួនទំហំ ឬប្រភេទខុសៗគ្នា ក្រៅពីការកំណត់ចំនួន និងការអនុញ្ញាត ដែលបានកំណត់ជាក់លាក់នៅក្នុងផែនការគាំពារបរិស្ថាន ការវាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង ឬពេញលេញ ផែនការគ្រប់គ្រងបរិស្ថាន ឬលិខិត ឬវិញ្ញាបនបត្រឯកភាពលើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន ។

៤- ការខូចខាតដែលបង្កឡើងដោយសារការធ្វេសប្រហែស អំពើទុច្ចរិត ឬសកម្មភាពខុសច្បាប់ ក្នុងការអនុវត្ត ការធ្វើប្រតិបត្តិការ ឬការបំពេញសកម្មភាពដែលត្រូវបានអនុញ្ញាត ។

៥- សកម្មភាពទាំងឡាយដែលផ្ទុយទៅនឹងខចែង និងលក្ខខណ្ឌនៃលិខិតអនុញ្ញាត កិច្ចសន្យា ការអនុញ្ញាត ឬឯកសារពាក់ព័ន្ធទាំងឡាយផ្សេងទៀត ព្រមទាំងការខកខានមិនបានអនុវត្តសកម្មភាពជាក់លាក់នានា ដែលតម្រូវក្នុងលិខិតអនុញ្ញាត ។

## ជំពូកទី៤
## សំណងការខូចខាតបរិស្ថាន

**មាត្រា៩៣២** ._ សំណងការខូចខាតបរិស្ថាន

សំណងការខូចខាតបរិស្ថាន មានដូចខាងក្រោម៖

១- ថ្លៃពេញលេញក្នុងការស្ដារបរិស្ថានឡើងវិញឱ្យដូចស្ថានភាពដើម មុនពេលមានការខូចខាតកើតឡើង ។

២- ថ្លៃពេញលេញសម្រាប់ការអនុវត្តការស្តារឡើងវិញបន្ថែមទៀតដែលគ្រប់គ្រាន់ដើម្បីធ្វើការទូទាត់ចំពោះការខូចខាតទាំងមូល ដែលមិនបានទូទាត់សងដោយការស្តារឡើងវិញ ក្នុងចំណុចទី១ ខាងលើ ។

៣- តម្លៃនៃទិដ្ឋភាពនៃបរិស្ថានដែលទទួលរងការខូចខាត ដែលមិនអាចស្តារឡើងវិញបាន ក្នុងករណីដែលការស្តារឡើងវិញត្រូវបានធ្វើឡើង ប៉ុន្តែផ្នែក ឬទិដ្ឋភាពមួយចំនួននៃបរិស្ថានដែលទទួលរងការខូចខាត មិនងាយស្តារឡើងវិញបាន ។

៤- តម្លៃអេកូឡូស៊ី ឬតម្លៃមនុស្ស ដែលបានបាត់បង់ដោយសារការខូចខាតបរិស្ថាន មិនអាចត្រូវបានទូទាត់សងពេញលេញដោយសារកត្តាដែលមានក្នុងចំណុចទី១ ទី២ និងទី៣ ខាងលើ រួមមាន តម្លៃសេដ្ឋកិច្ចដែលកំណត់ដោយវិធីសាស្ត្រវាយតម្លៃសេដ្ឋកិច្ចលម្អិត ។

៥- ថ្លៃទាំងអស់ដែលដើមបណ្តឹងបានចំណាយក្នុងការប្តឹង ដើម្បីធ្វើការទាមទារសំណងសម្រាប់ការជួសជុលបរិស្ថាន ដែលរួមមាន៖

- ថ្លៃជាក់ស្តែង និងថ្លៃចំណាយផ្សេងទៀត របស់ក្រុមការងាររៀបចំផែនការស្តារឡើងវិញ
- ថ្លៃចំណាយលើការវាយតម្លៃសំណងការខូចខាត និងការស្តារឡើងវិញ និង
- ថ្លៃចំណាយទាំងអស់ដែលក្រុមការងាររៀបចំផែនការស្តារឡើងបានចំណាយ និង
- ថ្លៃចំណាយលើដំណើរការពិគ្រោះយោបល់ ។

៦- ថ្លៃអង្កេតតាមដាន និងថ្លៃធានាឱ្យបាននូវភាពជោគជ័យនៃសកម្មភាពស្តារឡើងវិញ ដូចបានកំណត់ពីមុនរួចមកហើយ ។

៧- ថ្លៃទូទាត់សងសម្រាប់ការបាត់បង់មុខរបរ និងសេដ្ឋកិច្ច ដែលបណ្តាលមកពីការខូចខាតបរិស្ថាន ។

៨- ថ្លៃទូទាត់សងតាមរយៈការស្តារឡើងវិញ ឬលើការបាត់បង់ស្ថិរភាពនៃការប្រើប្រាស់បរិស្ថាន ។

៩- ការបាត់បង់ថ្លៃសុទ្ធនៃសួយសារ ប្រាក់ឈ្នួល កម្រៃនានា ឬការបាត់បង់ភាគហ៊ុននៃប្រាក់ចំណេញសុទ្ធដោយសារការខូចខាតនោះ ។

១០- ការបាត់បង់ប្រាក់ចំណេញ ឬឱនភាពនៃសមត្ថភាពរកចំណូលដោយសារការខូចខាត ។

១១- ថ្លៃសុទ្ធនៃការផ្តល់សេវាសាធារណៈដែលមានការកើនឡើង និងបន្ថែម ក្នុងការឆ្លើយតបទៅនឹងការខូចខាតបរិស្ថាន ។

១២- ប្រាក់ប្រដាប់ក្តី សោហ៊ុយ និងការចំណាយផ្សេងៗ ដែលកើតឡើងក្នុងដំណើរការនៃបណ្តឹង ។

១៣- ការខាតបង់សុទ្ធលើកម្រៃសេវា សួយសារ បុព្វលាភ ពន្ធ ឬប្រាក់ចំណូលផ្សេងទៀត ដែលត្រូវបង់ទៅក្រសួង ស្ថាប័នមានសមត្ថកិច្ច ។

១៤- ថ្លៃផ្តល់សេវាក្នុងការយាមល្បាត ដែលសមភាពទៅនឹងសេវាកម្មយាមល្បាតនានាក្នុងអំឡុងពេលនៃការចាប់ខ្លួន និងការកាត់ទោសទៅលើការរំលោភបំពាន ។

**មាត្រា៩៣៣** ._ ការស្តារការខូចខាតបរិស្ថានឡើងវិញជាបន្ទាន់

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន ត្រូវរៀបចំលិខិតបទដ្ឋានគតិយុត្តស្តីពីលក្ខខណ្ឌតម្រូវ និងនីតិវិធីក្នុងការស្តារការខូចបរិស្ថានឡើងវិញជាបន្ទាន់ ក្នុងករណីដែលក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថានយល់ឃើញថាមានភាពចាំបាច់ ដែលតម្រូវឱ្យមានការចាត់វិធានការជាបន្ទាន់ និងទាន់ពេលវេលា ។

## ជំពូកទី៥
## ការរៀបចំផែនការស្តារការខូចខាតបរិស្ថានឡើងវិញ

**មាត្រា៩៣៤** ._ ក្រុមការងាររៀបចំផែនការស្តារឡើងវិញ

ក្នុងករណីមានបណ្តឹងទាមទារឱ្យមានការជួសជុលដោយការស្តារបរិស្ថានឡើងវិញ ដូចមានចែងក្នុងមាត្រា៩៣២ នៃក្រមនេះ ភាគីដែលមានសិទ្ធិធ្វើសកម្មភាពបណ្តឹង មានសិទ្ធិលើកជាសំណើទៅកាន់ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន ដើម្បីបង្កើតក្រុមការងាររៀបចំផែនការស្តារឡើងវិញនូវការខូចខាតបរិស្ថាននោះ ។

បុគ្គលដែលបានចាត់តាំង រដ្ឋបាលថ្នាក់ក្រោមជាតិ រូបវន្តបុគ្គល តំណាងអង្គការសង្គមស៊ីវិលជនជាតិដើមភាគតិច សហគមន៍មូលដ្ឋាន និងបុគ្គលដទៃទៀត ដែលអាចទទួលរងផលប៉ះពាល់ដល់ប្រយោជន៍របស់ខ្លួន អាចចូលរួមនៅក្នុងក្រុមការងាររៀបចំផែនការស្តារការខូចខាតបរិស្ថានឡើងវិញដូចមានចែងក្នុងកថាខណ្ឌខាងលើ ។

**មាត្រា៩៣៥ .**_ ភារកិច្ច និងតួនាទីរបស់ក្រុមការងាររៀបចំផែនការស្តារការខូចខាតបរិស្ថានឡើងវិញ

ភារកិច្ច និងតួនាទីរបស់ក្រុមការងាររៀបចំផែនការស្តារការខូចខាតបរិស្ថានឡើងវិញ រួមមាន៖

ក- វាយតម្លៃពីបរិមាណធម្មជាតិ និងវិសាលភាពនៃការខូចខាតដោយប្រើព័ត៌មានដែលមានស្រាប់ ។ ដោយស្របតាមការវាយតម្លៃនេះ ក្រុមការងារត្រូវកំណត់ចំណាត់ការ ដូចខាងក្រោម ៖

១- ធ្វើបណ្តឹងទាមទាសំណងលើការខូចខាតពីបុគ្គលមួយ ឬច្រើននាក់ ដែលអាចត្រូវទទួលខុសត្រូវតាមជំពូកទី២នៃមាតិកានេះ ។

២- បំពេញតាមលក្ខខណ្ឌតម្រូវ និងនីតិវិធីនៃការស្តារឡើងវិញ ដូចមានចែងក្នុងមាត្រា៩៣៣ នៃក្រមនេះ ។

៣- ធ្វើការវាយតម្លៃពីសំណងការខូខាតសម្រាប់ធ្វើការស្តារឡើងវិញ ។

៤- អនុវត្តជម្រើសនៃចំណាត់ការសមស្របទៅតាមស្ថានភាពជាក់លាក់នៃគ្រោះថ្នាក់ ឬការខូចខាត ។

ខ-បន្ទាប់ពីបានសម្រេចថាត្រូវរៀបចំធ្វើបណ្តឹងទាមទារឱ្យមានការជួសជុលបរិស្ថាននោះក្រុមការងារ ចាំបាច់ត្រូវ៖

១- បង្កើតសេចក្តីថ្លែងការអំពីឆន្ទៈក្នុងការរៀបចំបណ្តឹងទាមទារការជួសជុលបរិស្ថាន ដែលក្នុងនោះត្រូវមានចុះអំពីព័ត៌មានសង្ខេបអំពីហេតុការ និងការខូតខាតនាពេលខាងមុខ ឬដែលបានរំពឹងទុកជាមុន ។

២- កំណត់អំពីការអនុវត្តនូវសិទ្ធិអំណាចរបស់មន្ត្រីអធិការកិច្ចបរិស្ថាន និងធនធានធម្មជាតិទាក់ទងទៅនឹងហេតុការណ៍ ។

៣- ធ្វើការជូនដំណឹងដល់ភាគីដែលទទួលខុសត្រូវ

គ- រៀបចំប្រមូលព័ត៌មានពាក់ព័ន្ធទៅនឹងបណ្តឹងទាមទារការស្តារឡើងវិញនាពេលខាងមុខ ។

ឃ- ពាក់ព័ន្ធទៅនឹងការរៀបបណ្តឹងទាមឱ្យមានការស្តារឡើងវិញ ស្របតាមចរិកលក្ខណៈនៃគ្រោះថ្នាក់ ឬការខូចខាតដល់បរិស្ថាន ក្រុមការងារត្រូវបំពេញតាមដំណាក់កាលដូចខាងក្រោម ដោយ ៖

១- កំណត់ពីអត្តសញ្ញាណ និងបរិមាណនៃការខូចខាត ។

២- កំណត់ពីលក្ខណៈនៃការស្តារឡើងវិញ និង/ឬ ដំណោះស្រាយដោយសំណងជាប្រាក់ដែលគិតទាំងសំណងការខូចខាតនាពេលខាងមុខផងដែរ ។

៣- បង្កើតការថ្លឹងថ្លែង និងការបង្ហាញពីទំនាក់ទំនងរវាងការខូចខាត និង សំណងបច្ចុប្បន្ន និងអនាគត ។

៤- បង្ហាញពីការស្តារឡើងវិញ និង/ឬ ជម្រើសនៃសំណងការខូចខាត ប្រាក់ ដែលគិតទាំងសំណងការខូចខាតនាពេលខាងមុខ ។

ង- ប្រើប្រាស់ជំនាញ និងឯកទេសនៃសមាជិកក្នុងក្រុមការងារ និងក្រៅក្រុមការងារ រៀបចំផែនការស្តារឡើងវិញ និងជំនួយផ្នែកបច្ចេកទេសទៅតាមតម្រូវការ ក្នុងគ្រប់ដំណោះ ស្រាយ និងការរៀបចំបណ្តឹងទាមទារ ។

ច- កំណត់ពីភាពសមរម្យនៃភាគីដែលទទួលខុសត្រូវនាពេលខាងមុខ ក្នុងការអនុវត្ត ការស្តារឡើងវិញដែលបានឯកភាព ។

ឆ- ជូនដំណឹងដល់ភាគីដែលអាចទទួលខុសត្រូវ ឱ្យចូលរួមក្នុងដំណើរការនៃការចរចា អំពីការស្តារឡើ វិញ ដើម្បីផ្តល់ការទទួលខុសត្រូវតាមរយៈកិច្ចការស្តារឡើងវិញ ឬការបង់ សំណងលើការខូចខាត ។

**មាត្រា៩៣៦** ._ នីតិវិធីវាយតម្លៃលើសំណងការខូចខាតសម្រាប់ការស្តារឡើងវិញ

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន អាចរៀបចំលិខិតបទដ្ឋានគតិយុត្តស្តីពីនីតិវិធី វាយតម្លៃ សំណងការខូចខាតសម្រាប់ការស្តារឡើងវិញ និងសំណងការខូចខាតបរិស្ថាន ទៅតាមតំបន់ភូមិ សាស្ត្រជាក់ស្តែងនីមួយៗ ។

**មាត្រា៩៣៧** ._ ដំណើរការនៃកិច្ចចរចាអំពីការស្តារឡើងវិញ

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន ត្រូវរៀបចំលិខិតបទដ្ឋានគតិយុត្តស្តីពីលក្ខខណ្ឌតម្រូវនៃ ការទូទាត់ និងការចរចាអំពីការស្តារឡើងវិញ របស់ក្រុមការងាររៀបចំផែនការស្តារការខូចខាតបរិស្ថាន ឡើងវិញ និងនិងភាគីដែលអាចទទួលខុសត្រូវ ។

## ជំពូកទី៦
## សិទ្ធិអំណាចនៃការចេញបទបញ្ជាផ្នែករដ្ឋបាល

**មាត្រា៩៣៨** ._ បទបញ្ជារដ្ឋបាលទាក់ទងនឹងវិធានការហិរញ្ញវត្ថុ

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន មានភារកិច្ចចេញបទបញ្ជាឱ្យភាគីដែលអាចទទួលខុសត្រូវផ្តល់ការឧបត្ថម្ភផ្នែកហិរញ្ញវត្ថុជាបន្ទាន់សម្រាប់ការងាររបស់ក្រុមការងារ រៀបចំផែនការស្តារឡើងវិញ និងការបង្កើតឱ្យមាននូវការវាយតម្លៃអំពីការជួសជុលដោយការស្តារឡើងវិញ ក្នុងករណីដែលការខូចខាតបរិស្ថានស្ថិតនៅក្នុងកម្រិតនៃការខូចខាតបរិស្ថានធ្ងន់ធ្ងរ ។

**មាត្រា៩៣៩** ._ បទបញ្ជារដ្ឋបាលទាក់ទងនឹងវិធានការស្តារបរិស្ថានឡើងវិញ

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន មានភារកិច្ចចេញបញ្ជាឱ្យភាគីដែលទទួលខុសត្រូវប្រតិបត្តិលើវិធានការស្តារឡើងវិញជាកិច្ចសង្គ្រោះបន្ទាន់ ក្រោមការដឹកនាំរបស់ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន បន្ទាប់ពីរកឃើញថា តម្រូវឱ្យមានការទប់ស្កាត់ជាបន្ទាន់លើការខូចខាតបរិស្ថាន ឬដើម្បីជាសវាងពីការបាត់បង់ឱកាសសំខាន់ដល់ការស្តារឡើងវិញ ។

## ជំពូកទី៧
## ការទាមទារមកវិញនូវថ្លៃចំណាយលើការស្តារការខូចខាតបរិស្ថានឡើងវិញ

**មាត្រា៩៤០** ._ ការស្តារការខូចខាត និងការទាមទារមកវិញនូវថ្លៃចំណាយ

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន អាចធ្វើការស្តារឡើងវិញ ដែលចាំបាច់ចំពោះការខូចខាតបរិស្ថាន នៅក្នុងព្រះរាជាណាចក្រកម្ពុជា និងអាចធ្វើការទាមទារមកវិញនូវថ្លៃចំណាយទាំងអស់ ស្របតាមបទប្បញ្ញត្តិនៃក្រមនេះ និងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ ។

**មាត្រា៩៤១** ._ បណ្តឹងទាមទារសំណង និងថ្លៃចំណាយសម្រាប់ការស្តារការខូចខាតដល់បរិស្ថានឡើងវិញ

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន មានសិទ្ធិអនុវត្តសកម្មភាពបណ្តឹងទាមទារសំណាង និងថ្លៃចំណាយផ្សេងៗ សម្រាប់ការស្តារការខូចខាតបរិស្ថានឡើងវិញ ពីភាគីដែលបង្កការខូចខាតបរិស្ថាន ។

**មាត្រា៩៤២** ._ ការបង់ថ្លៃ ឬការបង់សងវិញនូវថ្លៃ និងចំណាយដែលបានកើតឡើង

ថវិកាប្រមូលបានសម្រាប់ការបំពេញតួនាទី ដូចមានចែងក្នុងមាតិកានេះ ដែលជាការចំណាយ និងការបង់សងវិញចំពោះថ្លៃ និងការចំណាយសម្រាប់ការវាយតម្លៃការជួសជុលបរិស្ថាន ដោយការ

ស្តារឡើងវិញ និងសកម្មភាពរបស់ក្រុមការងាររៀបចំផែនការស្តារបរិស្ថានឡើងវិញ ត្រូវបង់ជូនដោយផ្ទាល់ទៅកាន់ភាគីដែលបានធ្វើការចំណាយ ។

## គន្ថីទី១០
## ទោសប្បញ្ញត្តិ
## មាតិកាទី១
## បទប្បញ្ញត្តិទូទៅ
## ជំពូកទោល
## ទណ្ឌកម្ម

**មាត្រា៩៤៣**._ ប្រភេទនៃទណ្ឌកម្ម

ប្រភេទនៃទណ្ឌកម្ម ដែលកំណត់នៅក្នុងក្រមនេះ មានជាអាទិ៍ ការព្រមានជាលាយលក្ខណ៍អក្សរ ការលុបចោល ការផ្អាកការឯកភាព ឬលិខិតអនុញ្ញាត ការពិន័យអន្តរការណ៍ ការផ្តល់សំណងការខូចខាត និងទោសព្រហ្មទណ្ឌ ។

**មាត្រា៩៤៤**._ ការផ្អាក ឬលុបចោលលិខិតអនុញ្ញាត និងសំណងខូចខាតបរិស្ថាន

ការព្រមានជាលាយលក្ខណ៍អក្សរ ការផ្អាក ឬការលុបចោលវិញ្ញាបនបត្រចុះបញ្ជី ឬលិខិតអនុញ្ញាត ត្រូវស្ថិតក្រោមសមត្ថកិច្ចរបស់ក្រសួង ស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធនឹងកិច្ចការពារបរិស្ថាន និងគ្រប់គ្រងធនធានធម្មជាតិ ដូចមានចែងក្នុងក្រមនេះ និងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀត ។

សំណងការខូចខាតចំពោះការស្តារបរិស្ថាន និងធនធានធម្មជាតិឡើងវិញ និងសំណងកាខូចខាតបរិស្ថាន ក្រោមបទប្បញ្ញត្តិនៃក្រមនេះ ត្រូវស្ថិតក្រោមសមត្ថកិច្ចរបស់ក្រសួង ស្ថាប័នទទួលបន្ទុកពាក់ព័ន្ធនឹងកិច្ចការពារបរិស្ថាន និងគ្រប់គ្រងធនធានធម្មជាតិ ។

**មាត្រា៩៤៥**._ ការពិន័យអន្តរការណ៍

ក្រសួង ស្ថាប័នទទួលបន្ទុកពាក់ព័ន្ធនឹងកិច្ចការពារបរិស្ថាន និងគ្រប់គ្រងធនធានធម្មជាតិ មានសិទ្ធិក្នុងការអនុវត្តការពិន័យអន្តរការណ៍ ចំពោះបទល្មើសបរិស្ថាន និងធនធានធម្មជាតិ ដូចមានចែងក្នុងក្រមនេះ និងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀត ។ ការពិន័យអន្តរការណ៍ ត្រូវអនុវត្តក្នុង

ករណីដែលជនល្មើសសារភាពកំហុស និងយល់ព្រមបង់ថ្លៃពិន័យអន្តរការណ៍ ស្របតាមបទប្បញ្ញត្តិនៃក្រមនេះ ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធផ្សេងទៀត។ ការបង់ថ្លៃពិន័យអន្តរការណ៍នាំឲ្យរលត់បណ្តឹងអាជ្ញា ។

ក្នុងករណីដែលជនល្មើសបដិសេធមិនព្រមបង់ប្រាក់ពិន័យអន្តរការណ៍ ក្រសួង ស្ថាប័នទទួលបន្ទុកពាក់ព័ន្ធនឹងកិច្ចការពារបរិស្ថាន និងគ្រប់គ្រងធនធានធម្មជាតិ អាចដាក់ពាក្យបណ្តឹងទៅតុលាការដើម្បីទាមទារប្រាក់ពិន័យអន្តរការណ៍នោះបាន ។

នីតិវិធី និងបែបបទស្តីពីការពិន័យអន្តរការណ៍ ត្រូវបានកំណត់ដោយលិខិតបទដ្ឋានគតិយុត្តរបស់ក្រសួង ស្ថាប័នទទួលបន្ទុកពាក់ព័ន្ធនឹងកិច្ចការពារបរិស្ថាន និងគ្រប់គ្រងធនធានធម្មជាតិ ។

**មាត្រា៩៤៦** ._ ប្រាក់ចំណូលដែលបានមកពីការពិន័យអន្តរការណ៍

ប្រាក់ចំណូលដែលបានមកពីការពិន័យអន្តរការណ៍ ពិន័យដោយតុលាការ ឬវត្ថុផ្សេងទៀតដែលតុលាការបានសម្រេចឲ្យរឹបអូសលក់ ត្រូវបង់ចូលទៅក្នុងថវិកាជាតិ ។

ប្រាក់ចំណូលដែលទទួលបានដូចមានចែងក្នុងកថាខណ្ឌខាងលើនេះ អាចប្រើប្រាស់សម្រាប់ផ្តល់ជារង្វាន់ជូនមន្ត្រីរាជការ និងប្រជាពលរដ្ឋ ដែលចូលរួមក្នុងសកម្មភាពពង្រឹងការអនុវត្តច្បាប់ ។

នីតិវិធីនៃការកំណត់ការផ្តល់ប្រាក់រង្វាន់ និងប្រាក់ពិន័យ ដែលត្រូវបង់ចូលថវិកាជាតិ ត្រូវកំណត់ដោយលិខិតបទដ្ឋានគតិយុត្តអន្តរក្រសួងរវាងក្រសួង ស្ថាប័នទទួលបន្ទុកហិរញ្ញវត្ថុ និងក្រសួង ស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធនឹងកិច្ចការពារបរិស្ថាន និងធនធានធម្មជាតិ ។

**មាត្រា៩៤៧** ._ ការរំលោភបំពានទៅលើកាតព្វកិច្ចបញ្ចៀសការខូចខាតបរិស្ថាន

បុគ្គលគ្រប់រូបដែលរំលោភបំពានបទប្បញ្ញត្តិនៃក្រមនេះ ហើយបង្កឲ្យមានការខូចខាតបរិស្ថាន ឬប្រព្រឹត្តបទល្មើសបរិស្ថាន និងធនធានធម្មជាតិ ត្រូវផ្តន្ទាទោសថ្នាក់ទី១ ឬទី២ ឬទី៣ ឬទី៤ ឬទី៥ អាស្រ័យតាមអំពើប្រព្រឹត្ត និងកម្រិតព្យសនៈកម្មចំពោះបរិស្ថាន និងធនធានធម្មជាតិ ។

**មាត្រា៩៤៨** ._ ការអនុវត្តសកម្មភាពបណ្តឹងរដ្ឋប្បវេណី

ក្នុងករណីមានបណ្តឹងអាជ្ញាធ្វើឡើង ស្របតាមបទប្បញ្ញត្តិនៃក្រមនេះ និងច្បាប់ពិសេសផ្សេងទៀតនៅតុលាការមានសមត្ថកិច្ច ក្រសួង ស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធ អាចធ្វើសកម្មភាពបណ្តឹងរដ្ឋប្បវេណីក្នុងការទាមទារសំណងការខូចខាត ឬការស្តារការខូចខាតបរិស្ថានឡើងវិញ ប្រឆាំងទៅនឹងភាគីដែលបង្កការខូចខាត នៅតុលាការរដ្ឋប្បវេណីដោយឡែក ។

បណ្ដឹងទាមទារសំណងការខូចខាត និងស្ដារបរិស្ថានឡើងវិញនេះ ត្រូវតែដំណើរការចាត់ការទៅតាមនីតិវិធីរដ្ឋប្បវេណី ឬទៅតាមនីតិវិធីដោះស្រាយវិវាទបរិស្ថាន និងធនធានធម្មជាតិ ដែលកំណត់ក្នុងក្រមនេះ ដោយមិនរង់ចាំការសម្រេចសេចក្ដីជាស្ថាពរពីតុលាការព្រហ្មទណ្ឌឡើយ ។

**មាត្រា៩៤៩** ._ ការស្ដារបរិស្ថានឡើងវិញ

ក្រសួងទទួលបន្ទុកបរិស្ថាន មានសិទ្ធិធ្វើសកម្មភាពបណ្ដឹងទៅកាន់តុលាការ និងស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធ ដើម្បីទាមទារសំណងការខូចខាតលើការស្ដារបរិស្ថានឡើងវិញ ឬទ្រព្យសម្បត្តិសាធារណៈ ស្របតាមបទប្បញ្ញត្តិនៃក្រមនេះ និងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀត ។

**មាត្រា៩៥០** ._ មន្ត្រីសាធារណៈដែលខកខានមិនបានបំពេញភារកិច្ច

មន្ត្រីសាធារណៈដែលបំពាន ឬខកខានមិនបានបំពេញភារកិច្ចស្របតាមបទប្បញ្ញត្តិនៃក្រមនេះ និងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀត ត្រូវទទួលទណ្ឌកម្មវិន័យរដ្ឋបាល ដោយមិនទាន់គិតដល់ការចោទប្រកាន់បទល្មើសព្រហ្មទណ្ឌផ្សេងទៀត ។

ជនផ្ដើមគំនិត ឬសមគំនិត ត្រូវទទួលទណ្ឌកម្មដូចគ្នានឹងចារីដែរ ។

**មាត្រា៩៥១** ._ ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់មន្ត្រីរាជការ

មន្ត្រីរាជការសាធារណៈ ឬមន្ត្រីកងកម្លាំងប្រដាប់អាវុធ ដែលទទួលខុសត្រូវលើការគ្រប់គ្រង ឬប្រើប្រាស់ទ្រព្យសម្បត្តិសាធារណៈ ដើម្បីចូលរួមក្នុងការប្រព្រឹត្តបទល្មើសដោយចេតនា ក្នុងគោលបំណងទទួលបានផលប្រយោជន៍ផ្ទាល់ខ្លួន ដោយគ្មានការអនុញ្ញាតត្រឹមត្រូវតាមច្បាប់ ត្រូវទទួលខុសត្រូវព្រហ្មទណ្ឌ តាមបទល្មើសដែលខ្លួនបានចូលរួមប្រព្រឹត្ត ។

**មាត្រា៩៥២** ._ បទល្មើសដែលមិនតម្រូវឲ្យមានចេតនាប្រព្រឹត្ត

បទល្មើសបរិស្ថាន និងធនធានធម្មជាតិដែលមានចរិកលក្ខណៈព្រហ្មទណ្ឌ ស្របតាមបទប្បញ្ញត្តិនៃក្រមនេះ អាចកើតចេញពីការខ្វះការប្រុងប្រយ័ត្ន ការធ្វេសប្រហែស ការខ្ជីខ្ជា ឬការខកខានមិនបានបំពេញកាតព្វកិច្ច ទោះបីជាមាន ឬគ្មានចេតនា ក្នុងការប្រព្រឹត្តបទល្មើសក៏ដោយ ។

បទល្មើសបរិស្ថាន និងធនធានធម្មជាតិ មិនតម្រូវឲ្យមានភស្តុតាងនៃចេតនាប្រព្រឹត្តបទល្មើសទេ លើកលែងតែមានចែងជាក់លាក់នៅក្នុងបទប្បញ្ញត្តិនៃក្រមនេះ ។

**មាត្រា៩៥៣ ._** ការទទួលខុសត្រូវរបស់នីតិបុគ្គល

នីតិបុគ្គលត្រូវទទួលខុសត្រូវចំពោះបទល្មើសបរិស្ថាន និងធនធានធម្មជាតិ ដែលប្រព្រឹត្តឡើង ដោយភ្នាក់ងារ ឬតំណាងរបស់នីតិបុគ្គល ក្នុងនាមផលប្រយោជន៍របស់នីតិបុគ្គលនោះ ។

ការទទួលខុសត្រូវរបស់នីតិបុគ្គល ត្រូវធ្វើឡើងតាមរយៈតំណាង ឬភ្នាក់ងាររបស់ខ្លួន ។

**មាត្រា៩៥៤ ._** ទោសបន្ថែមចំពោះរូបវន្តបុគ្គល

ប្រភេទទោសបន្ថែមដែលកំណត់ក្នុងក្រមព្រហ្មទណ្ឌជាធរមាន ត្រូវយកមកអនុវត្តផងដែរ ចំពោះបទល្មើសបរិស្ថាន និងធនធានធម្មជាតិ ដែលប្រព្រឹត្តដោយរូបវន្តបុគ្គល ដូចមានចែងក្នុងក្រម នេះ និងច្បាប់ពិសេសផ្សេងទៀត ។

**មាត្រា៩៥៥ ._** ទោសបន្ថែមចំពោះនីតិបុគ្គល

ប្រភេទទោសបន្ថែម ត្រូវយកមកអនុវត្តចំពោះបទល្មើសបរិស្ថាន និងធនធានធម្មជាតិ ដែល ប្រព្រឹត្តដោយនីតិបុគ្គល មានដូចខាងក្រោម៖

១- ការរំលាយនីតិបុគ្គល ។

២- ការលុបចោលលិខិតអនុញ្ញាត ឬសិទ្ធិអនុញ្ញាត ។

៣- ការផ្អាកលិខិតអនុញ្ញាត ឬសិទ្ធិអនុញ្ញាត ។

៤- ការលុបចោលវិញ្ញាបនបត្រឯកភាពលើការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ។

៥- ការផ្អាកសម្បទានដីសេដ្ឋកិច្ចណាមួយ ឬសម្បទានដទៃទៀត ។

៦- ការលុបចោលសម្បទានដីសេដ្ឋកិច្ចណាមួយ ឬសម្បទានដទៃទៀត ។

៧- ការរឹបអូសបរិក្ខាពាក់ព័ន្ធនឹងបទល្មើស ។

៨- ការរឹបអូសគ្រប់ផលចំណេញ ឬផលចំណេញនីមួយៗដែលកើតចេញពីបទល្មើស។

៩- ការផ្សព្វផ្សាយបទល្មើស និងទោសទណ្ឌ ។

ក្រៅពីទោសបន្ថែម ដែលកំណត់ខាងលើនេះ ទោសបន្ថែមដែលមានចែងក្នុងក្រមព្រហ្មទណ្ឌ ជាធរមាន ក៏ត្រូវយកមកអនុវត្តផងដែរ ចំពោះបទល្មើសបរិស្ថាន និងធនធានធម្មជាតិ ដែលប្រព្រឹត្ត ដោយនីតិបុគ្គល ។

**មាត្រា៩៥៦ ._** ថ្នាក់នៃបទល្មើស

បទល្មើសបរិស្ថាន និងធនធានធម្មជាតិ ដែលកំណត់ក្នុងក្រមនេះ ត្រូវបែងចែកជា៥ថ្នាក់ ដូចខាងក្រោម៖

១- បទល្មើសថ្នាក់ទី១ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី១០(ដប់)ឆ្នាំ ទៅ ៣០(សាបសិប) ឆ្នាំ និងពិន័យជាប្រាក់ពី៤០០.០០០.០០០(បួនរយលាន)រៀល ទៅ ៨០០.០០០.០០០(ប្រាំបីរយលាន)រៀល ។

២- បទល្មើសថ្នាក់ទី២ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី០៥(ប្រាំ)ឆ្នាំ ដល់១០(ដប់)ឆ្នាំ និងត្រូវពិន័យជាប្រាក់ពី២០០.០០០.០០០(ពីររយលាន)រៀល ទៅ ៤០០.០០០.០០០(បួនរយលាន) រៀល ។

៣- បទល្មើសថ្នាក់ទី៣ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី០១(មួយ)ឆ្នាំ ទៅ ០៥(ប្រាំ)ឆ្នាំ និងពិន័យជាប្រាក់ពី២០.០០០.០០០(ម្ភៃលាន)រៀល ដល់ ២០០.០០០.០០០(ពីររយលាន) រៀល ។

៤- បទល្មើសថ្នាក់ទី៤ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី០៧(ប្រាំពីរ)ថ្ងៃ ទៅ០១(មួយ)ឆ្នាំ និង/ឬ ពិន័យជាប្រាក់ពី ២.០០០.០០០(ពីរលាន)រៀល ដល់ ២០.០០០.០០០(ម្ភៃលាន)រៀល ។

៥- បទល្មើសថ្នាក់ទី៥ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី០១(មួយ)ថ្ងៃ ទៅ ០៦(ប្រាំមួយ) ថ្ងៃ និង/ឬ ពិន័យជាប្រាក់ពី ២០.០០០(ម្ភៃពាន់)រៀល ដល់ ២០.០០០.០០០(ម្ភៃលាន)រៀល ។

**មាត្រា៩៥៧** ._ ការចាត់ចែងប្រាក់សំណង

ប្រាក់សំណង ដែលបានមកពីការធ្វើសកម្មភាពបណ្តឹងរដ្ឋប្បវេណី ត្រូវប្រើប្រាស់សម្រាប់ការស្តារបរិស្ថានឡើងវិញ និងស្តារជីវភាពរស់នៅរបស់សហគមន៍ ដែលទទួលរងផលប៉ះពាល់ជាអវិជ្ជមានឡើងវិញ ។

**មាត្រា៩៥៨** ._ លិខិតបទដ្ឋានគតិយុត្តស្តីពីការគ្រប់គ្រង និងការបែងចែកសំណងការខូចខាត

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន ត្រូវរៀបចំលិខិតបទដ្ឋានគតិយុត្តស្តីពីការគ្រប់គ្រង និងការចាត់ចែងប្រាក់សំណងការខូចខាតបរិស្ថាន និងធនធានធម្មជាតិ ។

**មាត្រា៩៥៩** ._ អាជ្ញាយុកាលនៃបណ្តឹងរដ្ឋប្បវេណី

សិទ្ធិទាមទារសំណងការស្តារបរិស្ថានឡើងវិញ និងសំណងការខូចខាតផ្សេងទៀត ត្រូវគិតអាជ្ញាយុកាល ដូចខាងក្រោម៖

១- ៥(ប្រាំ)ឆ្នាំ គិតចាប់ពីថ្ងៃដែលបានដឹងពីព្រឹត្តិការណ៍ដែលបង្កឲ្យ មានការខូចខាតបរិស្ថាន ឬពីថ្ងៃទទួលបានព័ត៌មានអំពីការបង្កឲ្យមានការជួសជុលបរិស្ថាន ឬការខូចខាតផ្សេងទៀត ឬ

២- ១០(ដប់)ឆ្នាំ គិតចាប់ពីថ្ងៃដែលសកម្មភាព ឬហេតុការណ៍នៃការខូចខាតបរិស្ថានបានកើតឡើង ។

**មាត្រា៩៦០ .**_ អាជ្ញាយុកាលនៃបណ្ដឹងអាជ្ញា

បទល្មើសបរិស្ថាន និងធនធានធម្មជាតិ ជាបទល្មើសនិរន្ត ដែលអាជ្ញាយុកាលត្រូវគិតចាប់ពីថ្ងៃរកឃើញបទល្មើស ។

អាជ្ញាយុកាលនៃបណ្ដឹងអាជ្ញាពាក់ព័ន្ធនឹងបទល្មើសបរិស្ថាន និងធនធានធម្មជាតិ ត្រូវអនុលោមតាមក្រមព្រហ្មទណ្ឌជាធរមាន ។

## មាតិកាទី២
## បទល្មើសពាក់ព័ន្ធនឹងបរិស្ថាន និងធនធានធម្មជាតិ
## ជំពូកទី១
## បទល្មើសពាក់ព័ន្ធនឹងការចូលរួមជាសាធារណៈ

**មាត្រា៩៦១ .**_ ការរារាំងសិទ្ធិក្នុងការចូលរួមជាសាធារណៈ

ត្រូវផ្ដន្ទាទោសក្នុងបទល្មើសថ្នាក់ទី៥ ចំពោះអំពើរបស់រូបវន្តបុគ្គល ឬនីតិបុគ្គល ដែលរារាំងសិទ្ធិក្នុងការចូលរួមជាសធារណៈ ដូចមានចែងក្នុងមាត្រា២១នៃក្រមនេះ ។

ក្នុងករណីដែលអំពើរារាំងនោះ ធ្វើឡើងដោយមន្ត្រីរាជការសាធារណៈ ឬមន្ត្រីរាជការមានសមត្ថកិច្ចដោយរំលោភអំណាច ឬប្រើប្រាស់សិទ្ធិដោយបំពាន ត្រូវផ្ដន្ទាទោសក្នុងបទល្មើសថ្នាក់ទី៤។

**មាត្រា៩៦២ .**_ អំពើរារាំង ឬគំរាមកំហែងចំពោះការចូលរួមជាសាធារណៈ

ត្រូវផ្ដន្ទាទោសក្នុងបទល្មើសថ្នាក់ទី៤ រាល់អំពើគំរាមកំហែង ឬសងសឹកតាមគ្រប់មធ្យោបាយរបស់រូបវន្តបុគ្គល ឬនីតិបុគ្គលទាំងឡាយណា ដែលរារាំង ឬគំរាមកំហែង ចំពោះសកម្មភាពនៃការចូលរួមជាសាធារណៈ ដូចមានចែងក្នុងមាត្រា២២នៃក្រមនេះ ។ ក្នុងករណីដែលអំពើរារាំង ឬគំរាមកំហែង

នោះ ប៉ះពាល់ដល់បូរណភាពរូបរាងកាយធ្ងន់ធ្ងរ ឬទ្រព្យសម្បត្តិ ត្រូវផ្តន្ទាទោសក្នុងបទល្មើសថ្នាក់ទី៣ ។

ត្រូវផ្តន្ទាទោសក្នុងបទល្មើសថ្នាក់ទី១ ក្នុងករណីដែលអំពើប្រព្រឹត្តដូចមានចែងក្នុងកថាខណ្ឌខាងលើនេះធ្វើឲ្យបាត់បង់អាយុជីវិត ។

**មាត្រា៩៦៣** ._ កាតព្វកិច្ចក្នុងការបង្ហាញព័ត៌មានបរិស្ថាន និងធនធានធម្មជាតិ

ត្រូវផ្តន្ទាទោសជាពិន័យជាប្រាក់ក្នុងបទល្មើសថ្នាក់ទី៤ ចំពោះអំពើរបស់រូបវន្តបុគ្គល ឬនីតិបុគ្គល ដែលមិនអនុវត្តកាតព្វកិច្ច ដូចមានចែងមាត្រា៣៣នៃក្រមនេះ ដែលចែងអំពីសិទ្ធិទទួលបានព័ត៌មានបរិស្ថាន និងធនធានធម្មជាតិ ។

ក្នុងករណីដែល រូបវន្តបុគ្គល ឬនីតិបុគ្គលនៅតែបន្តប្រព្រឹត្តបទល្មើស ត្រូវពិន័យជាប្រចាំថ្ងៃមួយថ្ងៃ ២.០០០.០០០(ពីរលាន)រៀល ។

**មាត្រា៩៦៤** ._ បញ្ជីនៃលិខិតអនុញ្ញាត និងការឯកភាព

ត្រូវផ្តន្ទាទោសជាពិន័យជាប្រាក់ក្នុងបទល្មើសថ្នាក់ទី៤ ចំពោះអំពើខកខានមិនបានផ្តល់ឲ្យសាធារណជនអាចស្វែងរកនូវបញ្ជីនៃលិខិតអនុញ្ញាត និងការឯកភាព ដូចមានចែងក្នុងមាត្រា៥១ ។

**មាត្រា៩៦៥** ._ បញ្ជីសវនកម្មបរិស្ថាន

ត្រូវផ្តន្ទាទោសជាពិន័យជាប្រាក់ក្នុងបទល្មើសថ្នាក់ទី៤ ចំពោះអំពើខកខានមិនបានផ្តល់ឲ្យសាធារណជនអាចស្វែងរកនូវបញ្ជីសវនកម្មបរិស្ថាន ដូចមានចែងក្នុងមាត្រា៥៥ ។

## ជំពូកទី២
## បទល្មើសពាក់ព័ន្ធនឹងការវាយតម្លៃ និងការអង្កេតតាមដានបរិស្ថាន

**មាត្រា៩៦៦** ._ ការធ្វើសកម្មភាពសាងសង់ ឬប្រតិបត្តិការគម្រោងបំពានការហាមឃាត់

ត្រូវផ្តន្ទាទោសពិន័យអន្តរការណ៍ជាប្រាក់ពី ២០.០០០.០០០(ម្ភៃលាន)រៀល ទៅ ៥០.០០០.០០០(ហាសិបលាន)រៀល និង/ឬ ផ្តន្ទាទោសក្នុងបទល្មើសថ្នាក់ទី៣ និងត្រូវជួសជុល ស្តារការខូចខាត ដែលបានបង្កឡើងចំពោះម្ចាស់គម្រោងដែលបានប្រព្រឹត្តល្មើសនឹងមាត្រា៨៤នៃក្រម

នេះ ។ ការចោទប្រកាន់ចំពោះបទល្មើសព្រហ្មទណ្ឌខាងលើដោយអយ្យការ ត្រូវធ្វើឡើងតាមបណ្តឹងពីក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន ។

ក្នុងករណីដែលគម្រោងមិនទាន់មានលិខិត និងវិញ្ញាបនបត្រឯកភាពលើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាននេះ បង្កផលប៉ះពាល់ជាអវិជ្ជមាន ដល់មនុស្ស សត្វ ទ្រព្យសម្បត្តិ បរិស្ថាន និងសង្គម ម្ចាស់គម្រោងត្រូវផ្តន្ទាទោសពិន័យជាប្រាក់ក្នុងបទល្មើសថ្នាក់ទី២ និងត្រូវសងសំណងខូចខាតដោយមិនទាន់គិតដល់ទោសព្រហ្មទណ្ឌផ្សេងទៀតដែលពាក់ព័ន្ធ ។

ក្រៅពីទណ្ឌកម្មខាងលើ ម្ចាស់គម្រោងអាចទទួលរងទណ្ឌកម្ម ជាអាទិ៍ ការផ្អាកគម្រោងជាបណ្តោះអាសន្ន ការលុបចោលលិខិតអនុញ្ញាត ឬវិញ្ញាបនបត្រ ការលុបចោលកិច្ចសន្យា ឬការដកហូតអាជ្ញាប័ណ្ណ និងទោសបន្ថែម ដូចមានកំណត់ក្នុងក្រមព្រហ្មទណ្ឌជាធរមាន ។

**មាត្រា៩៦៧** ._ អំពើមិនអនុវត្តតាមលក្ខខណ្ឌតម្រូវ

ត្រូវទទួលការព្រមានជាលាយលក្ខណ៍អក្សរ ពីមន្ត្រីវាយតម្លៃហេតុប៉ះពាល់បរិស្ថានចំពោះម្ចាស់គម្រោងទាំងឡាយណា ដែលមិនអនុវត្តតាមលក្ខខណ្ឌតម្រូវ ដូចមានកំណត់នៅក្នុងរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង ឬពេញលេញ ឬកិច្ចសន្យាការពារបរិស្ថាន ដូចមានចែងក្នុងមាត្រា៩៩នៃក្រមនេះ ។ ក្នុងករណីមិនរាងចាលត្រូវពិន័យអន្តរការណ៍ជាប្រាក់ពី ១០.០០០.០០០ (ដប់លាន) រៀល ទៅ ៣០.០០០.០០០ (សាមសិបលាន) រៀល និង/ឬ ផ្អាកសកម្មភាពគម្រោង ។

ក្នុងករណីដែលមិនគោរពលក្ខខណ្ឌខាងលើ ហើយបណ្តាលឲ្យបាត់បង់ជីវិតមនុស្ស ឬពិការអចិន្ត្រៃយ៍ដល់ជនរងគ្រោះ ត្រូវទទួលការផ្តន្ទាទោសក្នុងបទល្មើសថ្នាក់ទី៣ ។ ការព្រមានជាលាយលក្ខណ៍អក្សរមិនត្រូវអនុវត្តចំពោះករណីនេះឡើយ ។

ក្នុងករណីដែលមិនគោរពលក្ខខណ្ឌខាងលើ ហើយធ្វើឲ្យប៉ះពាល់ដល់ជីវិតសត្វ ទ្រព្យសម្បត្តិ និងបរិស្ថាន និងសង្គម ម្ចាស់គម្រោងត្រូវសងសំណងខូចខាតតាមសមាមាត្រនឹងទំហំនៃការខូចខាត ។

ក្នុងករណីដែលការប៉ះពាល់ដែលចែងក្នុងកថាខណ្ឌទី៣ខាងលើមានលក្ខណៈធ្ងន់ធ្ងរ ម្ចាស់គម្រោងអាចទទួលរងទណ្ឌកម្មបន្ថែម ជាអាទិ៍ ការផ្អាកគម្រោងជាបណ្តោះអាសន្ន ការលុបចោលលិខិតអនុញ្ញាត ឬវិញ្ញាបនបត្រ ការលុបចោលកិច្ចសន្យា ឬការដកហូតអាជ្ញាប័ណ្ណ និងអាចទទួលការចោទប្រកាន់ពីបទល្មើសព្រហ្មទណ្ឌផ្សេងទៀត ដូចមានកំណត់ក្នុងក្រមព្រហ្មទណ្ឌជាធរមាន ។ នីតិបុគ្គលអាចត្រូវប្រកាសឲ្យទទួលខុសត្រូវព្រហ្មទណ្ឌ និងទោសបន្ថែម តាមបញ្ញត្តិនៃក្រមព្រហ្មទណ្ឌ និងត្រូវផ្តន្ទាទោសពិន័យជាប្រាក់ក្នុងបទល្មើសថ្នាក់ទី២ ។

**មាត្រា៩៦៨ ._** ការបំពានកាតព្វកិច្ចនៃការជូនដំណឹង

ត្រូវផ្តន្ទាទោសពិន័យអន្តរការណ៍ជាប្រាក់ពី ២០.០០០.០០០ (ម្ភៃលាន) រៀល ទៅ ៥០.០០០.០០០ (ហាសិបលាន) រៀល ចំពោះម្ចាស់គម្រោងដែលមិនបានអនុវត្តការជូនដំណឹង ដូចមានចែងក្នុងមាត្រា១០០ ។

**មាត្រា៩៦៩ ._** ការប្រកបវិជ្ជាជីវៈរបស់ក្រុមហ៊ុនទីប្រឹក្សាវាយតម្លៃហេតុប៉ះពាល់បរិស្ថានដែលមិនបានចុះបញ្ជី

ត្រូវផ្តន្ទាទោសពិន័យអន្តរការណ៍ជាប្រាក់ ពី ៣០.០០០.០០០ (សាមសិបលាន) រៀល ទៅ ៦០.០០០.០០០(ហុកសិបលាន)រៀល ចំពោះក្រុមហ៊ុនទីប្រក្សាដែលពុំទាន់បានចុះបញ្ជី ឬទទួលស្គាល់ដោយក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន ហើយបានរៀបចំរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានដាក់ជូនក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន ស្របតាមមាត្រា១០៣ ។

ក្នុងករណីមិនរាងចាល ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារក្នុងបទល្មើសថ្នាក់ទី៣ ។

**មាត្រា៩៧០ ._** ការបំពានកាតព្វកិច្ចក្នុងការដាក់ព័ត៌មានឱ្យសាធារណជនស្វែងរកបាន

ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ក្នុងបទល្មើសថ្នាក់ទី៤ ចំពោះអំពើខកខានមិនបានដាក់ឱ្យសាធារណជនស្វែងរកបានព័ត៌មាន ដូចមានចែងក្នុងមាត្រា១១៩ ។

**មាត្រា៩៧១ ._** ការមិនធ្វើការវាយតម្លៃហេតុប៉ះពាល់ឆ្លងដែន

ត្រូវផ្តន្ទាទោសពិន័យអន្តរការណ៍ជាប្រាក់ពី ២០.០០០.០០០ (ម្ភៃលាន) រៀល ទៅ ៥០.០០០.០០០(ហាសិបលាន)រៀល និង/ឬ ត្រូវផ្តន្ទាទោសក្នុងបទល្មើសថ្នាក់ទី៣ និងត្រូវជួសជុលស្តារការខូចខាតដែលបានបង្កឡើង ចំពោះម្ចាស់គម្រោងដែលបានប្រព្រឹត្តល្មើសនឹងមាត្រា១៩២ នៃក្រមនេះ ។ ការចោទប្រកាន់ចំពោះបទល្មើសព្រហ្មទណ្ឌខាងលើដោយអយ្យការ ត្រូវធ្វើឡើងតាមបណ្តឹងពីក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន ។

ក្នុងករណីដែលគម្រោងមិនទាន់មានលិខិត និងវិញ្ញាបនបត្រឯកភាពលើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាននេះ បង្កផលប៉ះពាល់ជាអវិជ្ជមាន ដល់ មនុស្ស សត្វ ទ្រព្យសម្បត្តិ បរិស្ថាន និងសង្គម ម្ចាស់គម្រោងត្រូវផ្តន្ទាទោសពិន័យជាប្រាក់ក្នុងបទល្មើសថ្នាក់ទី២ និងត្រូវសងសំណងខូចខាតតាមទំហំខូចខាតដែលកំណត់ដោយក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន ដោយមិនទាន់គិតដល់ទោសព្រហ្មទណ្ឌផ្សេងទៀតដែលពាក់ព័ន្ធ ។

ក្រៅពីទណ្ឌកម្មខាងលើ ម្ចាស់គម្រោងអាចទទួលរងទណ្ឌកម្ម ជាអាទិ៍ ការផ្អាកគម្រោងជាបណ្ដោះអាសន្ន ការលុបចោលលិខិតអនុញ្ញាត ឬវិញ្ញាបនបត្រ ការលុបចោលកិច្ចសន្យា ឬការដកហូតអាជ្ញាប័ណ្ណ និងទោសបន្ថែម ដូចមានកំណត់ក្នុងក្រមព្រហ្មទណ្ឌជាធរមាន ។

បទប្បញ្ញត្តិនៃមាត្រានេះ ត្រូវយកមកអនុវត្តនៅពេលដែលមានកិច្ចព្រមព្រៀងទ្វេភាគី ឬសន្ធិសញ្ញាអន្តរជាតិ ដែលព្រះរាជាណាចក្រកម្ពុជាជាភាគី ។

**មាត្រា៩៧២ .**_ការបំពានចំពោះការរៀបចំ និងបញ្ជូនរបាយការណ៍អង្កេតតាមដានបរិស្ថាន

ម្ចាស់គម្រោងត្រូវទទួលការព្រមានជាលាយលក្ខណ៍អក្សរ ដោយបង្គាប់ឲ្យរៀបចំរបាយការណ៍អង្កេតតាមដានគម្រោង និងបញ្ជូនមកក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន ដូចមានកំណត់ក្នុងមាត្រា១៦០ និងមាត្រា១៦៤ នៃក្រមនេះ ។ ក្នុងករណីដែលម្ចាស់គម្រោងមិនបានរៀបចំ និងបញ្ជូនរបាយការណ៍មកក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន ក្រោយពីទទួលការព្រមាននេះទេ ម្ចាស់គម្រោងត្រូវទទួលទណ្ឌកម្មជាការពិន័យអន្តរការណ៍ពី ២០.០០០.០០០(ម្ភៃលាន) រៀល ទៅ ៥០.០០០.០០០ (សែសិបលាន) រៀល ឬ ផ្អាកគម្រោងជាបណ្ដោះអាសន្ន ការលុបចោលកិច្ចសន្យា ឬការដកហូតអាជ្ញាប័ណ្ណ ។

**មាត្រា៩៧៣ .**_ ដំណើរការសាងសង ឬប្រតិបត្តិការគម្រោងចំពោះគម្រោងមានស្រាប់ ឬកំពុងដំណើរការ

ត្រូវផ្តន្ទាទោសពិន័យអន្តរការណ៍ជាប្រាក់ពី ២០.០០០.០០០ (ម្ភៃលាន) រៀល ទៅ ៥០.០០០.០០០ (ហាសិបលាន) រៀល និង/ឬ ត្រូវផ្តន្ទាទោសក្នុងបទល្មើសថ្នាក់ទី៣ និងត្រូវជួសជុលស្តារការខូចខាតដែលបានបង្កឡើង ចំពោះម្ចាស់គម្រោងដែលមានស្រាប់ ឬកំពុងដំណើរការ ដែលបានប្រព្រឹត្តល្មើសនឹងមាត្រា១៣៧នៃក្រមនេះ ចាប់ពីក្រមនេះចូលជាធរមាន ។ ការចោទប្រកាន់ចំពោះបទល្មើសព្រហ្មទណ្ឌខាងលើដោយអយ្យការ ត្រូវធ្វើឡើងតាមបណ្ដឹងពីក្រសួងទទួលបន្ទុកបរិស្ថាន ។

ក្នុងករណីដែលគម្រោងមិនទាន់មានលិខិត និងវិញ្ញាបនបត្រឯកភាពលើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាននេះ បង្កផលប៉ះពាល់ជាអវិជ្ជមានដល់មនុស្ស សត្វ ទ្រព្យសម្បត្តិ បរិស្ថាន និងសង្គម ម្ចាស់គម្រោងត្រូវផ្តន្ទាទោសពិន័យជាប្រាក់ក្នុងបទល្មើសថ្នាក់ទី២ និងត្រូវសងសំណងខូចខាតតាមទំហំខូចខាតដែលកំណត់ដោយក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន ដោយមិនទាន់គិតដល់ទោសព្រហ្មទណ្ឌផ្សេងទៀតដែលពាក់ព័ន្ធ ។

ក្រៅពីទណ្ឌកម្មខាងលើ ម្ចាស់គម្រោងអាចទទួលរងទណ្ឌកម្ម ជាអាទិ៍ ការផ្អាកគម្រោងជាបណ្តោះអាសន្ន ការលុបចោលលិខិតអនុញ្ញាត ឬវិញ្ញាបនបត្រ ការលុបចោលកិច្ចសន្យា ឬការដកហូតអាជ្ញាប័ណ្ណ និងទោសបន្ថែម ដូចមានកំណត់ក្នុងក្រមព្រហ្មទណ្ឌជាធរមាន ។

**មាត្រា៩៧៤ ._** ការខកខានមិនបានផ្តល់ព័ត៌មានដល់សាធារណៈ

ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ក្នុងបទល្មើសថ្នាក់ទី៤ ចំពោះការខកខានមិនបានដាក់របាយការណ៍សវនកម្មបរិស្ថានឱ្យសាធារណជនអាចស្វែងរកបាន ដូចមានចែងក្នុងមាត្រា១៥៦ ។

**មាត្រា៩៧៥ ._** ការរារាំងក្នុងអនុវត្តការធ្វើសវនកម្មបរិស្ថាន

ត្រូវផ្តន្ទាទោសក្នុងបទល្មើសថ្នាក់ទី៤ ចំពោះអំពើរារាំង ឬមិនអនុញ្ញាតឲ្យមន្ត្រីសវនកម្មបរិស្ថានចូលធ្វើសវនកម្ម ដូចមានចែងក្នុងមាត្រា១៥៧ ។

ក្នុងករណីដែលអំពើនោះប្រព្រឹត្តដោយហិង្សាធ្វើឲ្យប៉ះពាល់ដល់បូរណភាពរាងកាយ ត្រូវផ្តន្ទាក្នុងបទល្មើសថ្នាក់ទី៣ ។

ក្នុងករណីដែលអំពើនោះប្រព្រឹត្តដោយហិង្សាបណ្តាលឲ្យបាត់បង់អាយុជីវិត ឬពិការអចិន្ត្រៃ ត្រូវផ្តន្ទាទោសថ្នាក់ទី២ ។

**មាត្រា៩៧៦ ._** អំពើរារាំង ឬមិនអនុញ្ញាតដល់មន្ត្រីអធិការកិច្ច

ត្រូវផ្តន្ទាទោសពិន័យអន្តរការណ៍ជាប្រាក់ពី៥.០០០.០០០ (ប្រាំលាន) រៀង ទៅ១០.០០០.០០០ (ដប់លាន)រៀល ចំពោះម្ចាស់គម្រោង ឬម្ចាស់ទីកន្លែង ដែលបញ្ជា ឬបង្ខំឲ្យបុគ្គលិក ឬអ្នកនៅក្រោមឱវាទរបស់ខ្លួនធ្វើការរារាំង ឬមិនអនុញ្ញាតឲ្យមន្ត្រីអធិការកិច្ច ចូលបំពេញភារកិច្ច និងតួនាទីស្របតាមបញ្ញត្តិនៃមាត្រា១៦៥ និងមាត្រា៩២០ នៃក្រមនេះ ។ ក្នុងករណីមិនរាងចាល ត្រូវផ្តន្ទាទោសក្នុងបទល្មើសថ្នាក់ទី៤ ។

ក្នុងករណីដែលអំពើនោះប្រព្រឹត្តដោយហិង្សាធ្វើឲ្យប៉ះពាល់ដល់បូរណភាពរាងកាយ ត្រូវផ្តន្ទាទោសក្នុងបទល្មើសថ្នាក់ទី៣ ។

ក្នុងករណីអំពើនោះប្រព្រឹត្តដោយហិង្សាបណ្តាលឲ្យបាត់បង់ជីវិតមនុស្ស ឬពិការអចិន្ត្រៃយ៍ដល់ជនរងគ្រោះ ត្រូវផ្តន្ទាទោសក្នុងបទល្មើសថ្នាក់ទី១ ។

**មាត្រា៩៧៧ ._** ការបំពាននឹងសេចក្តីសម្រេចបង្គាប់ឲ្យបង់ថ្លៃចំណាយ

ម្ចាស់គម្រោង ត្រូវទទួលការព្រមានជាលាយលក្ខណ៍អក្សរ ដោយបង្គាប់ឲ្យបង់ថ្លៃចំណាយ ដូចមានចែងក្នុងមាត្រា៨០៥ និងមាត្រា៨០៧ នៃក្រមនេះ ។

ក្នុងករណីដែលម្ចាស់គម្រោងមិនបានបង់ប្រាក់ ក្រោយពីទទួលការព្រមាននេះ ម្ចាស់គម្រោង ត្រូវទទួលទណ្ឌកម្ម ជាអាទិ៍ ការផ្អាកគម្រោងជាបណ្ដោះអាសន្ន ការលុបចោលកិច្ចសន្យា ឬការដកហូតអាជ្ញាប័ណ្ណ រួមទាំងពិន័យជាប្រាក់ចំនួន៣(បី)ដង នៃចំនួនទឹកប្រាក់ដែលត្រូវបង់ ។

**មាត្រា៩៧៨ ._** ការខកខានមិនបង់ប្រាក់មូលនិធិបរិស្ថាននិងសង្គម និងមូលនិធិទាយជ្ជទានបរិស្ថាន

ម្ចាស់គម្រោងត្រូវទទួលការព្រមានជាលាយលក្ខណ៍អក្សរ ចំពោះការខកខានមិនបានបង់ប្រាក់ចូលមូលនិធិបរិស្ថាននិងសង្គម និងមូលនិធិទាយជ្ជទានបរិស្ថាន ដូចមានកំណត់នៅក្នុងមាត្រា៨០៩ និងមាត្រា៨១១ នៃក្រមនេះ ។

នៅក្នុងករណីដែលម្ចាស់គម្រោងមិនបានបង់ប្រាក់ ក្រោយពីទទួលការព្រមាននេះ ម្ចាស់គម្រោងត្រូវទទួលទណ្ឌកម្ម ជាអាទិ៍ ការផ្អាកគម្រោងជាបណ្ដោះអាសន្ន ការលុបចោលកិច្ចសន្យា ឬការដកហូតអាជ្ញាប័ណ្ណ រួមទាំងពិន័យជាប្រាក់ចំនួន ៣ (បី)ដង នៃចំនួនទឹកប្រាក់ដែលត្រូវបង់ ។ ការដាក់ទណ្ឌកម្មនេះ ជាសមត្ថកិច្ចរបស់ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន ។

## ជំពូកទី៣
## បទល្មើសពាក់ព័ន្ធនឹងការគ្រប់គ្រងបរិស្ថាន និងយន្តការចីរភាព

**មាត្រា៩៧៩ ._** ការបំពានសិទ្ធិទទួលបានព័ត៌មានអំពីការកាត់បន្ថយគ្រោះមហន្តរាយ

ត្រូវផ្ដន្ទាទោសពិន័យជាប្រាក់ក្នុងបទល្មើសថ្នាក់ទី៤ ចំពោះអំពើខកខានមិនបានដាក់ឱ្យសាធារណជនទទួលបានព័ត៌មានស្ដីពីការរៀបចំផែនការ ការធ្វើបច្ចុប្បន្នភាព និងការចែករំលែកព័ត៌មានអំពីការកាត់បន្ថយគ្រោះមហន្តរាយ ដូចមានចែងក្នុងមាត្រា១៧១ ។

**មាត្រា៩៨០ ._** ការហាមឃាត់មិនឱ្យមានគម្រោងថាមពលនៅក្នុងតំបន់ហាមឃាត់

ត្រូវផ្ដន្ទាទោសពិន័យជាប្រាក់ក្នុងបទល្មើសថ្នាក់ទី៣ ចំពោះការតំឡើងសម្ភារៈបរិក្ខាសម្រាប់ផលិតអគ្គិសនី ការបញ្ជូនអគ្គិសនី ឬការចែកចាយអគ្គិសនី នៅក្នុងតំបន់ដែលមានតម្លៃអភិរក្សខ្ពស់ ដូចមានចែងក្នុងមាត្រា២៥៤ ។

**មាត្រា៩៨១ ._** គម្រោងឧស្សាហកម្មនិស្សារណកម្មនៅក្នុងតំបន់ហាមឃាត់

ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ក្នុងបទល្មើសថ្នាក់ទី៣ ចំពោះសកម្មភាពគម្រោងឧស្សាហកម្មនិស្សារណកម្ម ដែលស្ថិតនៅក្នុងតំបន់ហាមឃាត់ ដូចមានចែងក្នុងមាត្រា២៧៧ ។

## ជំពូកទី៤
## បទល្មើសពាក់ព័ន្ធនឹងការគ្រប់គ្រងធនធានធម្មជាតិដោយចីរភាព

**មាត្រា៩៨២ ._** សកម្មភាពអភិវឌ្ឍន៍ និងសកម្មភាពពាណិជ្ជកម្មនៅក្នុងសមាសភាគនៃប្រព័ន្ធតំបន់ការពារធម្មជាតិ

ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ក្នុងបទល្មើសថ្នាក់ទី៣ ចំពោះសកម្មភាពអភិវឌ្ឍន៍ និងសកម្មភាពពាណិជ្ជកម្មនៅក្នុងសមាសភាគនៃប្រព័ន្ធតំបន់ការពារធម្មជាតិ ដែលមិនទាន់មានផែនការគ្រប់គ្រងដែលទទួលបានការឯកភាព ដូចមានចែងក្នុងមាត្រា៣០១ ។

ក្នុងករណីដែលសកម្មភាពខាងលើធ្វើឱ្យខូចខាតធ្ងន់ធ្ងរចំពោះបរិស្ថាន និងធនធានធម្មជាតិ ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ក្នុងបទល្មើសថ្នាក់ទី២ ដោយមិនរាប់បញ្ចូលសំណងការខូចខាតលើការស្តារបរិស្ថានឡើងវិញ និងការខូចខាតជាក់ស្តែងដទៃទៀត ។

**មាត្រា៩៨៣ ._** សកម្មភាពហាមឃាត់នៅក្នុងតំបន់ការពារធម្មជាតិ

ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ក្នុងបទល្មើសថ្នាក់ទី២ ចំពោះការធ្វើសកម្មភាពនៅក្នុងតំបន់គ្រប់គ្រងនៃតំបន់ការពារធម្មជាតិ ដូចមានចែងក្នុងមាត្រា៣០៦ ។

**មាត្រា៩៨៤ ._** ការហាមឃាត់ចំពោះសកម្មភាពបំពានលើកិច្ចព្រមព្រៀងគ្រប់គ្រងរួមគ្នា

ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ក្នុងបទល្មើសថ្នាក់ទី៣ ចំពោះការធ្វើសកម្មភាពបំពានលើកិច្ចព្រមព្រៀងគ្រប់គ្រងរួមគ្នា ហើយបង្កឱ្យមានការខូចខាតបរិស្ថាន និងធនធានធម្មជាតិ ដូចមានចែងក្នុងមាត្រា៣២៤ ដោយមិនរាប់បញ្ចូលវិធានការដូចមានចែងក្នុងមាត្រា៣២៥ ។

**មាត្រា៩៨៥ ._** ការមិនអនុវត្តកាតព្វកិច្ចស្តារព្រៃឈើឡើងវិញ

ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ក្នុងបទល្មើសថ្នាក់ទី២ ចំពោះម្ចាស់គម្រោងដែលមិនបានអនុវត្តកាតព្វកិច្ចស្តារព្រៃឈើឡើងវិញ ដូចមានចែងក្នុងកថាខណ្ឌទី២នៃមាត្រា៣៣៩ ។

**មាត្រា៩៨៦ ._** ការធ្វើសកម្មភាពដោយពុំមានលិខិតអនុញ្ញាត

ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ក្នុងបទល្មើសថ្នាក់ទី៣ ចំពោះបុគ្គលណាដែលបានធ្វើសកម្មភាពដោយគ្មានលិខិតអនុញ្ញាត ដូចមានចែងក្នុងកថាខណ្ឌទី២នៃមាត្រា៣៥៥ ។

ក្នុងករណីដែលសកម្មភាពខាងលើ បង្កឱ្យមានផលប៉ះពាល់ធ្ងន់ធ្ងរចំពោះបរិស្ថាន និងធនធានធម្មជាតិ ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ក្នុងបទល្មើសថ្នាក់ទី២ ដោយមិនទាន់រាប់បញ្ចូលសំណងស្តារការខូចខាតបរិស្ថានឡើងវិញ និងសំណងការខូចខាតជាក់ស្តែងផ្សេងទៀត ។

**មាត្រា៩៨៧ ._** ការហាមឃាត់ការធ្វើសកម្មភាពនៅក្នុងជម្រកសត្វ រុក្ខជាតិព្រៃនៃក្រុមប្រភេទទី១ ឬទី២

ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ក្នុងបទល្មើសថ្នាក់ទី៣ ចំពោះការធ្វើសកម្មភាពបំផ្លាញ ការកែប្រែទីជម្រកធម្មជាតិរបស់ប្រភេទសត្វ រុក្ខជាតិព្រៃនៃក្រុមប្រភេទទី១ ឬទី២ ដូចមានចែងក្នុងមាត្រា៣៥៣ ។

ក្នុងករណីដែលសកម្មភាពខាងលើ បង្កឱ្យមានការខូចខាតធ្ងន់ធ្ងរដល់ទីជម្រកធម្មជាតិ របស់ប្រភេទសត្វ រុក្ខជាតិព្រៃនៃក្រុមប្រភេទទី១ ឬទី២ ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ក្នុងបទល្មើសថ្នាក់ទី២ ដោយមិនទាន់រាប់បញ្ចូលសំណងស្តារការខូចខាតបរិស្ថានឡើងវិញ និងសំណងការខូចខាតជាក់ស្តែងផ្សេងទៀត ។

**មាត្រា៩៨៨ ._** ការធ្វើសកម្មភាពដោយគ្មានលិខិតអនុញ្ញាត

ត្រូវផ្តន្ទាទោសក្នុងបទល្មើសថ្នាក់ទី៣ ចំពោះការធ្វើសកម្មភាពគ្មានមានលិខិតអនុញ្ញាត ដូចមានចែងក្នុងមាត្រា៣៦៨ ។

**មាត្រា៩៨៩ ._** ការធ្វើសកម្មភាពពាណិជ្ជកម្មអន្តរជាតិដោយគ្មានលិខិតអនុញ្ញាត

ត្រូវផ្តន្ទាទោសក្នុងបទល្មើសថ្នាក់ទី៣ ចំពោះការធ្វើសកម្មភាពពាណិជ្ជកម្មអន្តរជាតិដោយគ្មានលិខិតអនុញ្ញាត ដូចមានចែងក្នុងមាត្រា៣៦៨ ។

**មាត្រា៩៩០ ._** ការធ្វើសកម្មភាពនៅក្នុងសមាសភាគនៃប្រព័ន្ធតំបន់ការពារធម្មជាតិ

ត្រូវផ្តន្ទាទោសក្នុងបទល្មើសថ្នាក់ទី៣ ចំពោះការធ្វើសកម្មភាពនៅក្នុងសមាសភាគនៃប្រព័ន្ធតំបន់ការពារធម្មជាតិ ដូចមានចែងក្នុងមាត្រា៣៧១ ។

ក្នុងករណីដែលសកម្មភាពខាងលើ បង្កឱ្យមានការខូចខាតធ្ងន់ធ្ងរដល់បរិស្ថាន និងធនធានធម្មជាតិ ត្រូវផ្តន្ទាទោសក្នុងបទល្មើសថ្នាក់ទី២ ដោយមិនទាន់រាប់បញ្ចូលសំណងស្តារការខូចខាតបរិស្ថានឡើងវិញ និងសំណងការខូចខាតជាក់ស្តែងផ្សេងទៀត ។

**មាត្រា៩៩១ ._** ការធ្វើសកម្មភាពនៅក្រៅសមាសភាគនៃប្រព័ន្ធតំបន់ការពារធម្មជាតិ

ត្រូវផ្តន្ទាទោសក្នុងបទល្មើសថ្នាក់ទី៤ ចំពោះការធ្វើសកម្មភាពនៅក្រៅសមាសភាគនៃប្រព័ន្ធតំបន់ការពារធម្មជាតិ ដូចមានចែងក្នុងមាត្រា៣៧២ ។

ក្នុងករណីដែលសកម្មភាពខាងលើ បង្កឱ្យមានការខូចខាតធ្ងន់ធ្ងរដល់បរិស្ថាន និងធនធានធម្មជាតិ ត្រូវផ្តន្ទាទោសក្នុងបទល្មើសថ្នាក់ទី៣ ដោយមិនទាន់រាប់បញ្ចូលសំណងស្តារការខូចខាតបរិស្ថានឡើងវិញ និងសំណងការខូចខាតជាក់ស្តែងផ្សេងទៀត ។

**មាត្រា៩៩២ ._** ការធ្វើពាណិជ្ជកម្មក្នុងស្រុកលើប្រភេទសត្វ និងរុក្ខជាតិព្រៃដែលហាមឃាត់

ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ក្នុងបទល្មើសថ្នាក់ទី៣ ចំពោះការធ្វើពាណិជ្ជកម្មក្នុងស្រុកលើប្រភេទសត្វ និងរុក្ខជាតិព្រៃដែលហាមឃាត់ ដូចមានចែងក្នុងមាត្រា៣៧៣ ។

ក្នុងករណីដែលសកម្មភាពខាងលើ បង្កឱ្យមានការខូចខាតធ្ងន់ធ្ងរដល់ប្រភេទសត្វ រុក្ខជាតិព្រៃដែលហាមឃាត់ ត្រូវផ្តន្ទាទោសក្នុងបទល្មើសថ្នាក់ទី២ ។

**មាត្រា៩៩៣ ._** ការមិនអនុវត្តកាតព្វកិច្ចធ្វើចត្តាឡីស័ក

ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ក្នុងបទល្មើសថ្នាក់ទី៤ ចំពោះម្ចាស់សត្វព្រៃ ឬម្ចាស់កសិដ្ឋានចិញ្ចឹមសត្វព្រៃ ដែលបានប្តូរទីតាំង នាំចូល ឬផ្ទេររវាងទីបង្ខាំងសត្វព្រៃ ឬរវាងកសិដ្ឋានចិញ្ចឹមសត្វព្រៃដែលមិនបានធ្វើចត្តាឡីស័ក ដោយក្រសួង ស្ថាប័នមានសមត្ថកិច្ច ដូចមានចែងក្នុងមាត្រា៣៧៩ ។

**មាត្រា៩៩៤ ._** ការប្តូរទីតាំងសត្វព្រៃដោយគ្មានការអនុញ្ញាត

ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ក្នុងបទល្មើសថ្នាក់ទី៤ ចំពោះការប្តូរទីតាំងសត្វព្រៃក្នុងគោលបំណងបង្កាត់ពូជអភិរក្ស ឬគ្រប់គ្រងការអភិរក្ស ដោយគ្មានការអនុញ្ញាតពីក្រសួង ស្ថាប័នមានសមត្ថកិច្ច ដូចមានចែងក្នុងមាត្រា៣៨៣ ។

**មាត្រា៩៩៥ ._** ការចុះបញ្ជីទីតាំងរក្សាសត្វ រុក្ខជាតិព្រៃ

ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ក្នុងបទល្មើសថ្នាក់ទី៤ ចំពោះទីតាំងរក្សាសត្វ រុក្ខជាតិព្រៃ ដែលមិនបានចុះបញ្ជីទទួលស្គាល់ដោយក្រសួង ស្ថាប័នមានសមត្ថកិច្ច ដូចមានចែងក្នុងមាត្រា៣៨៨ ។

**មាត្រា៩៩៦ ._** ការរក្សាទុកសត្វ រុក្ខជាតិព្រៃដោយគ្មានការអនុញ្ញាត

ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ក្នុងបទល្មើសថ្នាក់ទី៤ ចំពោះទីតាំងរក្សាទុកសំណាកសត្វ រុក្ខជាតិព្រៃ ដោយគ្មានការអនុញ្ញាត ដូចមានចែងក្នុងមាត្រា៣៩១ ។

**មាត្រា៩៩៧ ._** ការបញ្ចេញរុក្ខជាតិព្រៃចូលទៅក្នុងបរិស្ថានធម្មជាតិ

ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ក្នុងបទល្មើសថ្នាក់ទី៤ ចំពោះប្រតិបត្តិករនៃគ្រឹស្ថានឧទ្យានសួនសត្វ អគារសន្និធិរុក្ខជាតិស្ងួត សួនរុក្ខជាតិ សួនភូតគាមសាស្ត្រ វិទ្យាស្ថានកសិកម្ម និងសាកវប្បកម្ម និងទីតាំងដទៃទៀតដែលធ្វើការអភិរក្សរុក្ខជាតិព្រៃ ដែលបានបញ្ចេញរុក្ខជាតិព្រៃរាតត្បាតចូលទៅក្នុងបរិស្ថានធម្មជាតិ ដោយគ្មានការអនុញ្ញាត ដូចមានចែងក្នុងមាត្រា៣៩៤ ។

**មាត្រា៩៩៨ ._** ការដោះលែងសត្វព្រៃចូលទៅក្នុងបរិស្ថានធម្មជាតិ

ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ក្នុងបទល្មើសថ្នាក់ទី៤ ចំពោះប្រតិបត្តិករនៃទីតាំងបង្កាត់ពូជអភិរក្ស មជ្ឈមណ្ឌលសង្គ្រោះសត្វព្រៃ គ្រឹះស្ថានឧទ្យានសួនសត្វព្រៃ និងទីតាំងរក្សាទុកសត្វព្រៃ ដែលបានលែងសត្វដែលបានកើតក្នុងទីរក្សាទុក ឬសត្វដែលបានរក្សាទុក ចូលទៅក្នុងបរិស្ថានធម្មជាតិ ដោយមិនត្រឹមត្រូវតាមលក្ខខណ្ឌដូចមានចែងក្នុងមាត្រា៣៩៥ ។

**មាត្រា៩៩៩ ._** ការបង្ខាំងប្រភេទសត្វព្រៃ

ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ក្នុងបទល្មើសថ្នាក់ទី៤ ចំពោះការរក្សាទុកប្រភេទសត្វព្រៃ នៃក្រុមប្រភេទទី១ ទី២ និងទី៣ ក្នុងគោលបំណងចិញ្ចឹម សម្តែង ឱ្យធ្វើការ ក្រៅពីទីតាំងបង្កាត់ពូជអភិរក្ស មជ្ឈមណ្ឌលសង្គ្រោះសត្វព្រៃ ឬគ្រឹះស្ថានឧទ្យានសួនសត្វព្រៃ ដូចមានចែងក្នុងមាត្រា៣៩៦ ។

**មាត្រា១០០០ ._** ការបោះបង់ចោលសំណាកនៃប្រភេទសត្វព្រៃ

ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ក្នុងបទល្មើសថ្នាក់ទី៤ ចំពោះការបោះបង់ចោលបំណែក សាច់ ឬវត្ថុតាំងលម្អ ដែលធ្វើពីសត្វព្រៃដែលងាប់ មិនស្របតាមលក្ខខណ្ឌដូចមានចែងក្នុងមាត្រា៣៩៨ ។

**មាត្រា១០០១ ._** ការហាមឃាត់ចំពោះសកម្មភាពរបស់កសិដ្ឋានចិញ្ចឹមសត្វព្រៃ

ត្រូវផ្តន្ទាទោសក្នុងបទល្មើសថ្នាក់ទី៣ ចំពោះសកម្មភាពហាមឃាត់ដែលធ្វើឡើងដោយកសិកដ្ឋានចិញ្ចឹមសត្វព្រៃ ដូចមានចែងក្នុងមាត្រា៣៩៩ ។

**មាត្រា១០០២ ._** ការបើកកសិដ្ឋានចិញ្ចឹមសត្វព្រៃដោយគ្មានការអនុញ្ញាត

ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ក្នុងបទល្មើសថ្នាក់ទី៣ ចំពោះកសិដ្ឋានចិញ្ចឹមសត្វព្រៃក្នុងគោលបំណងពាណិជ្ជកម្ម ដោយគ្មានការអនុញ្ញាតពីក្រសួង ស្ថាប័នមានសមត្ថកិច្ច ដូចមានចែងក្នុងមាត្រា ៤០០ ។

**មាត្រា១០០៣ ._** ការបើកកសិដ្ឋានចិញ្ចឹមសត្វព្រៃដោយគ្មានការអនុញ្ញាត

ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ក្នុងបទល្មើសថ្នាក់ទី៣ ចំពោះកសិដ្ឋានចិញ្ចឹមសត្វព្រៃក្នុងគោលបំណងពាណិជ្ជកម្ម ដោយគ្មានការអនុញ្ញាតពីក្រសួង ស្ថាប័នមានសមត្ថកិច្ច ដូចមានចែងក្នុងមាត្រា ៤០០ ។

**មាត្រា១០០៤ ._** ការបំពានកាតព្វកិច្ចរបស់ម្ចាស់កសិដ្ឋានចិញ្ចឹមសត្វព្រៃ

ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ក្នុងបទល្មើសថ្នាក់ទី៣ ចំពោះម្ចាស់កសិដ្ឋានចិញ្ចឹមសត្វព្រៃ ដែលមិនបានអនុវត្តកាតព្វកិច្ច ដូចមានចែងក្នុងមាត្រា៤០១ ។

**មាត្រា១០០៥ ._** ការហាមឃាត់ចំពោះការធ្វើពាណិជ្ជកម្មទាក់ទងនឹងសំណាក និងផលិតផល សត្វព្រៃ

ត្រូវផ្តន្ទាទោសក្នុងបទល្មើសថ្នាក់ទី៣ ចំពោះការទិញ ការលក់ ការធ្វើពាណិជ្ជកម្មលើ ផលិតផល ឬសំណាកសត្វព្រៃ ទៅឱ្យបុគ្គលណាមួយក្រៅពីកសិដ្ឋានចិញ្ចឹមសត្វព្រៃ ដែលមានលិខិតអនុញ្ញាត ដូចមានចែងក្នុងមាត្រា៤០៤ ។

**មាត្រា១០០៦ ._** ការធ្វើចត្តាឡីស័ក និងការអង្កេតតាមដានសុខភាពសត្វព្រៃ

ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ក្នុងបទល្មើសថ្នាក់ទី៣ ចំពោះកសិដ្ឋានចិញ្ចឹមសត្វព្រៃ ដែលមិនបានធ្វើចត្តាឡីស័ក និងអង្កេតតាមដានសុខភាពសត្វព្រៃ ដូចមានចែងក្នុងមាត្រា៤០៥ ។

**មាត្រា១០០៧ ._** ការធ្វើសត្តឃាតសត្វព្រៃចិញ្ចឹមដោយអមនុស្សធម៌

ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ក្នុងបទល្មើសថ្នាក់ទី៤ ចំពោះការធ្វើសត្តឃាតសត្វព្រៃចិញ្ចឹមដោយអមនុស្សធម៌ ដូចមានចែងក្នុងមាត្រា៤០៦ ។

**មាត្រា១០០៨ ._** សកម្មភាពហាមឃាត់នៅតំបន់ឆ្នេរ

ត្រូវផ្តន្ទាទោសក្នុងបទល្មើសថ្នាក់ទី៣ចំពោះសកម្មភាពសាងសង់ហេដ្ឋារចនាសម្ព័ន្ធ ការធ្វើអាជីវកម្មរ៉ែខ្សាច់ ដែលបង្កឲ្យមានការបាត់បង់ ឬការខូចខាតនៅក្នុងតំបន់ឆ្នេរ ដូចមានចែងក្នុងមាត្រា៤១៦ ។

**មាត្រា១០០៩ ._** ការបង្វែរទឹកឆ្លងកាត់ព្រំដែន

ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ក្នុងបទល្មើសថ្នាក់ទី៣ ចំពោះការបង្វែរទឹកឆ្លងដែនចេញពីដែនដីនៃព្រះរាជាណាចក្រកម្ពុជា ដោយគ្មានការអនុញ្ញាត ដូចមានចែងក្នុងមាត្រា៤២៥ ។

**មាត្រា១០១០ ._** សកម្មភាពដែលតម្រូវឲ្យមានការផ្តល់ការអនុញ្ញាត

ត្រូវផ្តន្ទាទោសក្នុងបទល្មើសថ្នាក់ទី៣ ចំពោះសកម្មភាពទាំងឡាយ ដែលគ្មានលិខិតអនុញ្ញាតដូចមានចែងក្នុងមាត្រា៤៦១ ។

**មាត្រា១០១១ ._** ការប្រកបសកម្មភាពអាជីវកម្មដោយគ្មានវិញ្ញាបនបត្រ

ត្រូវផ្តន្ទាទោសក្នុងបទល្មើសថ្នាក់ទី៤ ចំពោះការប្រកបសកម្មភាពអាជីវកម្ម ដោយគ្មានវិញ្ញាបនបត្រ ដូចមានចែងក្នុងមាត្រា៤៩១ ។

**មាត្រា១០១២ ._** ការខកខានមិនធ្វើរបាយការណ៍ទាក់ទងអាជីវកម្មខ្លងអណ្តូងខួង

ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ក្នុងបទល្មើសថ្នាក់ទី៤ ចំពោះការខកខានមិនធ្វើរបាយការណ៍ស្តីពីការងារលម្អិតនៃអណ្តូងខួង ដូចមានចែងក្នុងមាត្រា៤៩២ ។

**មាត្រា១០១៣ ._** ការអនុញ្ញាតចំពោះការផ្គត់ផ្គង់ និងប្រើប្រាស់ទឹក

ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ក្នុងបទល្មើសថ្នាក់ទី៤ ចំពោះការយក ការផ្គត់ផ្គង់ ឬ ការប្រើប្រាស់ទឹក ដោយគ្មានលិខិតអនុញ្ញាត ដូចមានចែងក្នុងមាត្រា៤៩៥ ។

**មាត្រា១០១៤ ._** ការបំពានលិខិតអនុញ្ញាត

ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ក្នុងបទល្មើសថ្នាក់ទី៣ ចំពោះអ្នកផ្គត់ផ្គង់ទឹក ឬអ្នកប្រើប្រាស់ទឹក មិនស្របតាមលិខិតអនុញ្ញាត ដូចមានចែងក្នុងមាត្រា៤៩៦ ។

**មាត្រា១០១៥ ._** ការហាមឃាត់មិនឱ្យមន្ត្រីមានសមត្ថកិច្ចចូលបរិវេណដីឯកជន

ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ក្នុងបទល្មើសថ្នាក់ទី៤ ចំពោះម្ចាស់កម្មសិទ្ធិ ឬអ្នកកាន់កាប់ដីឯកជន ដែលបដិសេធមិនឱ្យមន្ត្រីមានសមត្ថកិច្ចចូលបរិវេណដីឯកជនរបស់ខ្លួន ដើម្បីធ្វើការសិក្សាផ្នែកបច្ចេកទេស ការវាយតម្លៃ ឬការអង្កេតតាមដាន ដូចមានចែងក្នុងមាត្រា៤៩៧ ។

## ជំពូកទី៥
## បទល្មើសពាក់ព័ន្ធនឹងការអភិវឌ្ឍ និងការគ្រប់គ្រងបេតិកភណ្ឌវប្បធម៌ និងបេតិកភណ្ឌធម្មជាតិ

**មាត្រា១០១៦ ._** ការហាមឃាត់ចំពោះការប្រែ ឬធ្វើឱ្យខូចខាតតំបន់បេតិកភណ្ឌទីក្រុង

ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ក្នុងបទល្មើសថ្នាក់ទី៣ ចំពោះការកែប្រែ ឬផ្លាស់ប្តូររូបរាង ឬធ្វើឱ្យខូចខាតសោភណ្ឌភាពតំបន់ណាមួយ ឬតំបន់ទាំងមូលនៃតំបន់បេតិកភណ្ឌទីក្រុង ដោយគ្មានការអនុញ្ញាត ដូចមានចែងក្នុងមាត្រា៤៤៦ ។

**មាត្រា១០១៧ ._** ការហាមឃាត់ការប្រែ ឬធ្វើឱ្យខូចខាតសោភណ្ឌភាពចំពោះសំណង់នៃតំបន់បេតិកភណ្ឌទីក្រុង

ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ក្នុងបទល្មើសថ្នាក់ទី៣ ចំពោះការកែប្រែរូបរាង ឬផ្លាស់ប្តូររចនាបថ ឬធ្វើឱ្យខូចខាតសោភណ្ឌភាពគ្រង់កន្លែងណាមួយ នៃសំណង់សាធារណៈ ឯកជន សាសនា ហេដ្ឋារចនាសម្ព័ន្ធ និងលំហបៃតងនៃបេតិកភណ្ឌទីក្រុង ដោយគ្មានការអនុញ្ញាត ដូចមានចែងក្នុងមាត្រា៤៤៧ ។

**មាត្រា១០១៨ ._** ការជួសជុល ឬការកែប្រែរូបរាង និងកំទេចចោលសំណង់ក្នុងតំបន់បេតិកភណ្ឌទីក្រុង

ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ក្នុងបទល្មើសថ្នាក់ទី៣ ចំពោះម្ចាស់កម្មសិទ្ធិអចលនទ្រព្យ ម្ចាស់សំណង់ទូទៅ ឬលំនៅដ្ឋាន ដែលស្ថិតនៅក្នុងតំបន់បេតិកភណ្ឌទីក្រុងដែលបានធ្វើការជួសជុល កែប្រែរូបរាង ឬកំទេចចោលសំណង់ នៅក្នុងតំបន់បេតិកភណ្ឌទីក្រុង ដោយគ្មានការអនុញ្ញាត ដូចមានចែងក្នុងមាត្រា៥៤៨ ។

**មាត្រា១០១៩ ._** ការមិនអនុវត្តកាតព្វកិច្ចរាយការណ៍

ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ក្នុងបទល្មើសថ្នាក់ទី៤ ចំពោះរូបវន្តបុគ្គល ឬនីតិបុគ្គល ដែលបានដឹង ឬប្រទះឃើញដោយចៃដន្យនូវបេតិកភណ្ឌវប្បធម៌ ឬវត្ថុបុរាណ ឬទីតាំងបុរាណស្ថាន ហើយមិនរាយការណ៍ជាបន្ទាន់ជូនអាជ្ញាធរដែនដី និង/ឬ ក្រសួង ស្ថាប័នមានសមត្ថកិច្ច ដូចមានចែងក្នុងមាត្រា៥៥០ ។

**មាត្រា១០២០ ._** ការមិនអនុវត្តកាតព្វកិច្ចរាយការណ៍ដោយប្រតិបត្តិករសាងសង់

ត្រូវផ្តន្ទាទោសក្នុងបទល្មើសថ្នាក់ទី៣ ចំពោះរូបវន្តបុគ្គល ឬនីតិបុគ្គល ដែលប្រទះឃើញដោយចៃដន្យនូវវត្ថុបុរាណ ឬសម្បត្តិវប្បធម៌ ឬតំបន់បេតិកភណ្ឌវប្បធម៌ ក្នុងពេលដំណើរការសាងសង់ ចំពោះការមិនបានបញ្ឈប់សកម្មភាពសាងសង់ និងមិនបានរាយការណ៍ជូនអាជ្ញាធរមានសមត្ថកិច្ច ដូចមានចែងក្នុងមាត្រា៥៥១ ។

**មាត្រា១០២១ ._** ការហាមឃាត់ចំពោះការជីករុករក ឬស្រាវជ្រាវរកសម្បត្តិវប្បធម៌

ត្រូវផ្តន្ទាទោសក្នុងបទល្មើសថ្នាក់ទី៣ ចំពោះរូបវន្តបុគ្គល ឬនីតិបុគ្គល ដែលបានជីករុករក ឬស្រាវជ្រាវសម្បត្តិវប្បធម៌ ដោយគ្មានការអនុញ្ញាត ដូចមានចែងក្នុងមាត្រា៥៥៤ ។

**មាត្រា១០២២ ._** ការហាមឃាត់ចំពោះការជីករុករក ឬស្រាវជ្រាវរកសម្បត្តិវប្បធម៌ដោយស្ថាប័នវិទ្យាសាស្ត្រ ឬអ្នកសិក្សាស្រាវជ្រាវ

ត្រូវផ្តន្ទាទោសក្នុងបទល្មើសថ្នាក់ទី៣ ចំពោះស្ថាប័នវិទ្យាសាស្ត្រ ឬអ្នកសិក្សាស្រាវជ្រាវ ដែលមានបំណងជីករុករក ឬស្រាវជ្រាវនៅក្នុងដី ឬក្នុងទឹក ក្នុងគោលបំណងសិក្សាស្រាវជ្រាវ ដោយគ្មានការអនុញ្ញាត ដូចមានចែងក្នុងមាត្រា៥៥៥ ។

**មាត្រា១០២៣ ._** ការហាមឃាត់ចំពោះសកម្មភាពដែលធ្វើឱ្យខូចខាត ឬបង្កគ្រោះថ្នាក់ដល់សម្បត្តិវប្បធម៌

ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ក្នុងបទល្មើសថ្នាក់ទី៣ ចំពោះសកម្មភាពដែលធ្វើឱ្យខូចខាត ឬបំផ្លិចបំផ្លាញ ឬបង្កគ្រោះថ្នាក់ដល់សម្បត្តិវប្បធម៌ ដូចមានចែងក្នុងមាត្រា៥៦៣ ។

**មាត្រា១០២៤ ._** ការហាមឃាត់ចំពោះយកចេញ ឬបំផ្លាញបេតិកភណ្ឌ

ត្រូវផ្តន្ទាទោសក្នុងបទល្មើសថ្នាក់ទី៣ ចំពោះរូបវន្តបុគ្គល ឬនីតិបុគ្គល ដែលបានយកចេញ ឬបំផ្លាញសម្បត្តិវប្បធម៌ ឬវត្ថុបុរាណ នៅក្នុងទីតាំងដីកម្មសិទ្ធិឯកជន ដូចមានចែងក្នុងមាត្រា៥៦៨ ។

**មាត្រា១០២៥ ._** ការខកខានមិនបានធ្វើកំណត់ត្រា និងថតរូបសម្បត្តិវប្បធម៌

ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ក្នុងបទល្មើសថ្នាក់ទី៤ ចំពោះអំពើការខកខានមិនបានធ្វើកំណត់ត្រា និងថតរូបសម្បត្តិវប្បធម៌ ដូចមានចែងក្នុងបញ្ញត្តិនៃមាត្រា៥៦៩ ។

**មាត្រា១០២៦ ._** ការបំផ្លិចបំផ្លាញសម្បត្តិវប្បធម៌ ឬវត្ថុបុរាណ ដែលប្រទះឃើញដោយចៃដន្យ

ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ក្នុងបទល្មើសថ្នាក់ទី៣ ចំពោះការបំផ្លិចបំផ្លាញសម្បត្តិវប្បធម៌ ឬវត្ថុបុរាណ ដែលប្រទះឃើញដោយចៃដន្យ មុនពេលកំណត់អំពីតម្លៃបេតិកភណ្ឌ ដូចមានចែងក្នុងមាត្រា៥៧០ ។

**មាត្រា១០២៧ ._** កាតព្វកិច្ចរាយការណ៍ចំពោះការប្រទះឃើញបេតិកភណ្ឌវប្បធម៌ ឬវត្ថុក្រោមទឹក

ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ក្នុងបទល្មើសថ្នាក់ទី៣ ចំពោះការមិនរាយការណ៍អំពីការប្រទះឃើញវត្ថុក្រោមទឹក ដែលកំណត់អត្តសញ្ញាណជាសម្បត្តិវប្បធម៌ ដូចមានចែងក្នុងមាត្រា៥៧៣ ។

**មាត្រា១០២៨ ._** ការធ្វើឲ្យខូច ឬការបំផ្លិចបំផ្លាញ ឬការស្រង់ ឬរំខានបេតិកភណ្ឌវប្បធម៌ក្រោមទឹក

ត្រូវផ្តន្ទាទោសក្នុងបទល្មើសថ្នាក់ទី៣ ចំពោះអំពើធ្វើឲ្យខូច ឬការបំផ្លិចបំផ្លាញ ឬការស្រង់ ឬរំខានបេតិកភណ្ឌវប្បធម៌ក្រោមទឹក ដូចមានចែងក្នុងមាត្រា៥៧៤ ។

**មាត្រា១០២៩ ._** សកម្មភាពបង្កការខូចខាតដល់បេតិកភណ្ឌវប្បធម៌ និងទីតាំងបេតិកភណ្ឌវប្បធម៌របស់ម្ចាស់គម្រោង

ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ក្នុងបទល្មើសថ្នាក់ទី៣ ចំពោះម្ចាស់គម្រោងដែលធ្វើសកម្មភាពបង្កការខូចខាតដល់បេតិកភណ្ឌវប្បធម៌ និងទីតាំងបេតិកភណ្ឌវប្បធម៌ ដោយគ្មានការអនុញ្ញាត មុនចាប់ផ្តើមអនុវត្តគម្រោង ឬសកម្មភាព ដូចមានចែងក្នុងមាត្រា៥៧៧ ។

**មាត្រា១០៣០ ._** សកម្មភាពបង្កការខូចខាតដល់សម្បត្តិវប្បធម៌ ឬវត្ថុបុរាណ

ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ក្នុងបទល្មើសថ្នាក់ទី៣ ចំពោះបុគ្គលណាដែលធ្វើសកម្មភាពបង្កការខូចខាតដល់សម្បត្តិវប្បធម៌ ឬវត្ថុបុរាណ ដែលមានចុះបញ្ជី ដោយគ្មានការអនុញ្ញាត ដូចមានចែងក្នុងមាត្រា៥៧៨ ។

**មាត្រា១០៣១ ._** ការហាមឃាត់ចំពោះការនាំចេញសម្បត្តិវប្បធម៌

ត្រូវផ្តន្ទាទោសក្នុងបទល្មើសថ្នាក់ទី៣ ចំពោះការនាំចេញសម្បត្តិវប្បធម៌ ដោយគ្មានការអនុញ្ញាត ដូចមានចែងក្នុងមាត្រា៥៩១ ។

## ជំពូកទី៦
## បទល្មើសពាក់ព័ន្ធនឹងការគ្រប់គ្រងសំណល់ និងការបំពុល

**មាត្រា១០៣២ ._** ការបំពានកាតព្វកិច្ចទូទៅចំពោះការបំពុលខ្យល់ ទឹក ឬដី

ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ក្នុងបទល្មើសថ្នាក់ទី៤ ចំពោះរូបវន្តបុគ្គល ឬនីតិបុគ្គលទាំងឡាយណា ដែលបានធ្វើសកម្មភាពណាមួយ ដែលបង្កឲ្យមានការបំពុលខ្យល់ ឬទឹក ឬដី ដូចមានចែងក្នុងមាត្រា៥៩៦ ។

**មាត្រា១០៣៣ ._** ការបំពានសកម្មភាពហាមឃាត់ចំពោះសំណល់

ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ក្នុងបទល្មើសថ្នាក់ទី៣ ចំពោះរូបវន្តបុគ្គល ឬនីតិបុគ្គលទាំងឡាយណា ដែលបានធ្វើសកម្មភាពដោយគ្មានការអនុញ្ញាត ដូចមានចែងក្នុងមាត្រា៥៩៧ ។

**មាត្រា១០៣៤ ._** ការបង្កសកម្មភាពដែលនាំមានការបំពុលដោយសំឡេង ឬរំញ័រដែលលើសពីស្តង់ដារអនុញ្ញាត

ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ក្នុងបទល្មើសថ្នាក់ទី៣ ចំពោះរូបវន្តបុគ្គល ឬនីតិបុគ្គលទាំងឡាយណា ដែលបង្កសកម្មភាពណាមួយដែលបង្កឱ្យមានការបំពុលដោយសំឡេង ឬរំញ័រ ដែលលើសពីស្តង់ដារ ដូចមានចែងក្នុងមាត្រា៥៩៨ ។

**មាត្រា១០៣៥ ._** ការមិនអនុវត្តតាមលក្ខខណ្ឌនៃលិខិតអនុញ្ញាត ឬការឯកភាព

ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ក្នុងបទល្មើសថ្នាក់ទី៣ ចំពោះរូបវន្តបុគ្គល ឬនីតិបុគ្គលទាំងឡាយណាដែលមិន គោរពតាមលក្ខខណ្ឌនានានៃលិខិតអនុញ្ញាត ឬការឯកភាព ដូចមានចែងក្នុងមាត្រា៥៩៩ ។

ក្នុងករណីដែលអំពើមិនគោរពតាមលក្ខខណ្ឌនានានៃលិខិតអនុញ្ញាត ឬការឯកភាពខាងលើនេះ បង្កឲ្យមានព្យសនកម្មកើតឡើងដល់បូរណភាពរូបរាងកាយ ទ្រព្យសម្បត្តិ សត្វ និងបរិស្ថានធ្ងន់ធ្ងរ ត្រូវផ្តន្ទាទោសក្នុងបទល្មើសថ្នាក់ទី៣ ។

ត្រូវផ្តន្ទាទោសក្នុងបទល្មើសថ្នាក់ទី២ ចំពោះអំពើរបស់រូបវន្តបុគ្គល ឬនីតិបុគ្គលដែលមិនគោរពតាមលក្ខខណ្ឌនៃលិខិតអនុញ្ញាត ឬការឯកភាពខាងលើនេះ បង្កឲ្យបាត់បង់ជីវិតអាយុជីវិត ឬពិការអចិន្ត្រៃយ៍ ។

**មាត្រា១០៣៦ ._** ការប្រើប្រាស់សារធាតុហាមឃាត់ ឬសារធាតុគ្រោះថ្នាក់

ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ក្នុងបទល្មើសថ្នាក់ទី៣ ចំពោះរូបវន្តបុគ្គល ឬនីតិបុគ្គលទាំងឡាយណា ដែលធ្វើសកម្មភាពហាមឃាត់ ដូចមានចែងក្នុងមាត្រា៦២១ ។

ក្នុងករណីដែលការធ្វើសកម្មភាពហាមឃាត់ខាងលើ បង្កឲ្យមានព្យសនកម្មកើតឡើងដល់បូរណភាពរូបរាងកាយ ទ្រព្យសម្បត្តិ សត្វ និងបរិស្ថានធ្ងន់ធ្ងរ ត្រូវផ្តន្ទាទោសក្នុងបទល្មើសថ្នាក់ទី៣ ។

ត្រូវផ្តន្ទាទោសក្នុងបទល្មើសថ្នាក់ទី២ ចំពោះការធ្វើសកម្មភាពខាងលើរបស់រូបវន្តបុគ្គល ឬនីតិបុគ្គល ដែលបង្កឲ្យបាត់បង់ជីវិតអាយុជីវិត ឬពិការអចិន្ត្រៃយ៍ ។

**មាត្រា១០៣៧ ._** ការហាមឃាត់ចំពោះសារធាតុបំពុលសរីរាង្គមិនងាយបំបែកធាតុ

ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ក្នុងបទល្មើសថ្នាក់ទី៣ ចំពោះរូបវន្តបុគ្គល ឬនីតិបុគ្គលទាំងឡាយណា ដែលបានផលិត ប្រើប្រាស់ ឬចែកចាយសារធាតុបំពុលសរីរាង្គមិនងាយបំបែកធាតុ ដែលត្រូវហាមឃាត់ ដូចមានចែងក្នុងមាត្រា៦២២ ។

ក្នុងករណីដែលការធ្វើសកម្មភាពហាមឃាត់ខាងលើ បង្កឲ្យមានព្យសនកម្មកើតឡើងដល់បូរណភាពរូបរាងកាយ ទ្រព្យសម្បត្តិ សត្វ និងបរិស្ថានធ្ងន់ធ្ងរ ត្រូវផ្តន្ទាទោសក្នុងបទល្មើសថ្នាក់ទី៣ ។

ត្រូវផ្តន្ទាទោសក្នុងបទល្មើសថ្នាក់ទី២ ចំពោះការធ្វើសកម្មភាពខាងលើរបស់រូបវន្តបុគ្គល ឬនីតិបុគ្គល ដែលបង្កឲ្យបាត់បង់ជីវិតអាយុជីវិត ឬពិការអចិន្ត្រៃយ៍ ។

**មាត្រា១០៣៨ ._** ការហាមឃាត់ចំពោះសំណនៅក្នុងថ្នាំពណ៌ និងផលិតផលសម្រាប់កុមារ

ត្រូវផ្តន្ទាទោសពិន័យក្នុងបទល្មើសថ្នាក់ទី៣ ចំពោះរូបវន្តបុគ្គល ឬនីតិបុគ្គលទាំងឡាយណាដែលបានប្រើប្រាស់សំណ ឬសមាសធាតុសំណក្នុងទឹកថ្នាំពណ៌ និងផលិតផលសម្រាប់កុមារ ដូចមានចែងក្នុងមាត្រា៦២៣ ។

ក្នុងករណីដែលការធ្វើសកម្មភាពហាមឃាត់ខាងលើ បង្កឲ្យមានព្យសនកម្មកើតឡើងដល់បូរណភាពរូបរាងកាយ ទ្រព្យសម្បត្តិ សត្វ និងបរិស្ថានធ្ងន់ធ្ងរ ត្រូវផ្តន្ទាទោសក្នុងបទល្មើសថ្នាក់ទី៣ ។

ត្រូវផ្តន្ទាទោសក្នុងបទល្មើសថ្នាក់ទី២ ចំពោះការធ្វើសកម្មភាពខាងលើរបស់រូបវន្តបុគ្គល ឬនីតិបុគ្គល ដែលបង្កឲ្យបាត់បង់ជីវិតអាយុជីវិត ឬពិការអចិន្ត្រៃយ៍ ។

**មាត្រា១០៣៩ ._** ការហាមឃាត់ចំពោះសារធាតុដែលមិនបានចុះបញ្ជី

ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ក្នុងបទល្មើសថ្នាក់ទី៣ ចំពោះរូបវន្តបុគ្គល ឬនីតិបុគ្គលទាំងឡាយណា ដែលបានធ្វើសកម្មភាពហាមឃាត់ ដូចមានចែងក្នុងមាត្រា៦២៧ ។

ក្នុងករណីដែលការធ្វើសកម្មភាពហាមឃាត់ខាងលើ បង្កឲ្យមានព្យសនកម្មកើតឡើងដល់បូរណភាពរូបរាងកាយ ទ្រព្យសម្បត្តិ សត្វ និងបរិស្ថានធ្ងន់ធ្ងរ ត្រូវផ្តន្ទាទោសក្នុងបទល្មើសថ្នាក់ទី៣ ។

ត្រូវផ្តន្ទាទោសក្នុងបទល្មើសថ្នាក់ទី២ ចំពោះការធ្វើសកម្មភាពខាងលើរបស់រូបវន្តបុគ្គល ឬនីតិបុគ្គល ដែលបង្កឲ្យបាត់បង់ជីវិតអាយុជីវិត ឬពិការអចិន្ត្រៃយ៍ ។

**មាត្រា១០៤០ ._** ការហាមឃាត់ចំពោះការវេចខ្ចប់ដែលមិនត្រឹមត្រូវ

ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ក្នុងបទល្មើសថ្នាក់ទី៣ ចំពោះរូបវន្តបុគ្គល ឬនីតិបុគ្គលទាំងឡាយណា ដែលបានមិនបានវេចខ្ចប់ត្រឹមត្រូវនូវផលិតផល ឬសារធាតុគ្រោះថ្នាក់ ដូចមានចែងក្នុងមាត្រា៦២៨ ។

**មាត្រា១០៤១ ._** ការហាមឃាត់ចំពោះការវេចខ្ចប់ និងការផ្សព្វផ្សាយពាណិជ្ជកម្មមិនពិត ឬនាំឲ្យមានការភាន់ច្រឡំ

ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ក្នុងបទល្មើសថ្នាក់ទី៣ ចំពោះរូបវន្តបុគ្គល ឬនីតិបុគ្គលទាំងឡាយណា ដែលបានវេចចខ្ចប់មិនត្រឹមត្រូវ ឬផ្សព្វផ្សាយពាណិជ្ជកម្មអំពីផលិតផល ឬសារធាតុគ្រោះថ្នាក់មិនពិត ឬធ្វើឲ្យមានការភាន់ច្រឡំ ដូចមានចែងក្នុងមាត្រា៦២៩ ។

**មាត្រា១០៤២ ._** ការប្រើប្រាស់សារធាតុដែលបង្កឲ្យមានរបួសស្នាម

ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ក្នុងបទល្មើសថ្នាក់ទី២ ចំពោះរូបវន្តបុគ្គល ឬនីតិបុគ្គលទាំងឡាយណា ដែលបានប្រើប្រាស់សារធាតុដែលបង្កឲ្យមានរបួសស្នាម ដោយគ្មានការអនុញ្ញាត ដូចមានចែងក្នុងមាត្រា៦៣០ ។

ក្នុងករណីដែលការប្រើប្រាស់សារធាតុខាងលើ បង្កឲ្យមានព្យសនកម្មកើតឡើងដល់បូរណភាពរូបរាងកាយ ទ្រព្យសម្បត្តិ សត្វ និងបរិស្ថានធ្ងន់ធ្ងរ ត្រូវផ្តន្ទាទោសក្នុងបទល្មើសថ្នាក់ទី៣ ។

ត្រូវផ្តន្ទាទោសក្នុងបទល្មើសថ្នាក់ទី២ ក្នុងករណីដែលការប្រើប្រាស់សារធាតុខាងលើ របស់រូបវន្តបុគ្គល ឬនីតិបុគ្គល បង្កឲ្យបាត់បង់ជីវិតអាយុជីវិត ឬពិការអចិន្ត្រៃយ៍ ។

**មាត្រា០១៤៣ ._** ការចុះបញ្ជីផលិតផល និងសារធាតុគ្រោះថ្នាក់

ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ក្នុងបទល្មើសថ្នាក់ទី៣ ចំពោះរូបវន្តបុគ្គល ឬនីតិបុគ្គលទាំងឡាយណា ដែលមិនបានចុះបញ្ជីតាមការកំណត់របស់ច្បាប់ សម្រាប់ការកាន់កាប់រាល់ផលិតផល និងសារធាតុគ្រោះថ្នាក់ ដើម្បីផលិត ចែកចាយ លក់ និងប្រើប្រាស់ ដូចមានចែងក្នុងមាត្រា៦៣១។

**មាត្រា១០៤៤ ._** ការមិនដាក់ស្លាកសញ្ញាលើសារធាតុគ្រោះថ្នាក់

ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ក្នុងបទល្មើសថ្នាក់ទី៤ ចំពោះផលិតករ ឬអ្នកនាំចូលទាំងឡាយណា ដែលនាំចូលសារធាតុគ្រោះថ្នាក់ ហើយមិនបានដាក់ស្លាកសញ្ញាសារធាតុគ្រោះថ្នាក់ លើផលិតផល ឬសារធាតុគ្រោះថ្នាក់ ដូចមានចែងក្នុងមាត្រា៦៣៧ ។

ក្នុងករណីដែលអំពើនៃការផលិត ឬការនាំចូលសារធាតុគ្រោះថ្នាក់ ដូចមានចែងក្នុងកថាខណ្ឌខាងលើ បង្កឲ្យមានព្យសនកម្មដល់បូរណភាពរូបរាងកាយ ទ្រព្យសម្បត្តិ សត្វ ឬបរិស្ថានធ្ងន់ធ្ងរ ត្រូវផ្តន្ទាទោសក្នុងបទល្មើសថ្នាក់ទី៣ ។

**មាត្រា១០៤៥ ._** ការបំពានកាតព្វកិច្ចការដឹកជញ្ជូនសារធាតុគ្រោះថ្នាក់

ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ក្នុងបទល្មើសថ្នាក់ទី៣ ចំពោះរូបវន្តបុគ្គល ឬនីតិបុគ្គលទាំងឡាយណា ដែលមិនគោរពតាមកាតព្វកិច្ចដឹកជញ្ជូនសារធាតុ ឬផលិតផលគ្រោះថ្នាក់ ដូចមានចែងក្នុងមាត្រា៦៩០ ។

**មាត្រា១០៤៦ ._** ការហាមឃាត់ការប្រើប្រាស់សារធាតុគ្រោះថ្នាក់

ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ក្នុងបទល្មើសថ្នាក់ទី៣ ចំពោះរូបវន្តបុគ្គល ឬនីតិបុគ្គលទាំងឡាយណា ដែលប្រើប្រាស់សារធាតុគ្រោះថ្នាក់ បង្កផលប៉ះពាល់ដល់សុខភាពមនុស្ស ដូចមានចែងក្នុងមាត្រា៦៩៣។

ក្នុងករណីដែលការប្រើប្រាស់សារធាតុគ្រោះថ្នាក់ខាងលើនេះ បង្កឲ្យមានព្យសនកម្មកើតឡើងដល់បូរណភាពរូបរាងកាយធ្ងន់ធ្ងរ ត្រូវផ្តន្ទាទោសក្នុងបទល្មើសថ្នាក់ទី៣ ។

ត្រូវផ្តន្ទាទោសក្នុងបទល្មើសថ្នាក់ទី២ ចំពោះអំពើរបស់រូបវន្តបុគ្គល ឬនីតិបុគ្គលដែលប្រើប្រាស់សារធាតុគ្រោះថ្នាក់ខាងលើនេះ បង្កឲ្យបាត់បង់អាយុជីវិត ឬពិការអចិន្ត្រៃយ៍ ។

**មាត្រា១០៤៧ ._** ការបោះបង់ចោលសារធាតុគ្រោះថ្នាក់

ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ក្នុងបទល្មើសថ្នាក់ទី៣ ចំពោះរូបវន្តបុគ្គល ឬនីតិបុគ្គលទាំងឡាយណា ដែលបានដុតចោល ឬបោះបង់ចោលរាល់សារធាតុគ្រោះថ្នាក់ចូលទៅក្នុងបរិស្ថានដោយគ្មានការអនុញ្ញាត ដូចមានចែងក្នុងមាត្រា៦៩៥ ។

ក្នុងករណីដែលអំពើដុតចោល ឬបោះបង់ចោលរាល់សារធាតុគ្រោះថ្នាក់ ចូលទៅក្នុងបរិស្ថានដោយគ្មានការអនុញ្ញាតខាងលើនេះ បង្កឲ្យមានព្យសនៈកម្មកើតឡើងដល់បូរណភាពរូបរាងកាយ ទ្រព្យសម្បត្តិ សត្វ និងបរិស្ថានធ្ងន់ធ្ងរ ត្រូវផ្តន្ទាទោសក្នុងបទល្មើសថ្នាក់ទី២ ។

ត្រូវផ្តន្ទាទោសក្នុងបទល្មើសថ្នាក់ទី១ ចំពោះអំពើរបស់រូបវន្តបុគ្គល ឬនីតិបុគ្គល ដែលដុតចោល ឬបោះបង់ចោលរាល់សារធាតុគ្រោះថ្នាក់ចូលទៅក្នុងបរិស្ថាន ដោយគ្មានការអនុញ្ញាតខាងលើនេះ បង្កឲ្យបាត់បង់អាយុជីវិត ឬពិការអចិន្ត្រៃយ៍ ។

**មាត្រា១០៤៨ ._** ការចុះបញ្ជីផលិតសារធាតុ ឬផលិតផលគ្រោះថ្នាក់

ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ក្នុងបទល្មើសថ្នាក់ទី៣ ចំពោះរូបវន្តបុគ្គល ឬនីតិបុគ្គលទាំងឡាយណា ដែលមិនបានចុះបញ្ជីនូវផលិតផល ឬសារធាតុគ្រោះថ្នាក់ ដូចមានចែងក្នុងមាត្រា៦៤៨ ។

**មាត្រា១០៤៩ ._** កាតព្វកិច្ចជូនដំណឹងអំពីគ្រោះថ្នាក់

ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ក្នុងបទល្មើសថ្នាក់ទី៣ ចំពោះរូបវន្តបុគ្គល ឬនីតិបុគ្គលទាំងឡាយណា ដែលមិនបានជូនដំណឹងភ្លាមដល់អាជ្ញាធរមានសមត្ថកិច្ច និងក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងត្រូវចាត់វិធានការសមរម្យ ស្របតាមផែនការទប់ស្កាត់ និងឆ្លើយតបក្នុងករណីសង្គ្រោះបន្ទាន់ ដើម្បីកាត់បន្ថយផលប៉ះពាល់ដល់សុខភាពមនុស្ស និងបរិស្ថាន និងទ្រព្យសម្បត្តិ ដូចមានចែងក្នុងមាត្រា ៦៥១ ។

**មាត្រា១០៥០ ._** ការបញ្ចេញសារធាតុបំពុលពីប្រភពបំពុលជាក់លាក់

ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ក្នុងបទល្មើសថ្នាក់ទី៣ ចំពោះរូបវន្តបុគ្គល ឬនីតិបុគ្គលទាំងឡាយណា ដែលបញ្ចេញសារធាតុបំពុលពីប្រភពបំពុលទឹកជាក់លាក់ ចូលទៅក្នុងទឹកលើដី ឬទឹកក្រោមដី ដូចមានចែងក្នុងមាត្រា៦៦៨ ។

ក្នុងករណីដែលការបញ្ចេញសារធាតុបំពុលដោយប្រភពបំពុលជាក់លាក់ខាងលើ បង្កឲ្យមានព្យសនកម្មកើតឡើងដល់មនុស្ស សត្វ និងបរិស្ថានទឹកធ្ងន់ធ្ងរ ត្រូវផ្តន្ទាទោសក្នុងបទល្មើសថ្នាក់ទី៣ ។

ត្រូវផ្តន្ទាទោសក្នុងបទល្មើសថ្នាក់ទី១ ចំពោះរូបវន្តបុគ្គល ឬនីតិបុគ្គល ដែលប្រព្រឹត្តអំពើខាងលើ បង្កឲ្យមានព្យសនកម្មបាត់បង់អាយុជីវិត ឬពិការអចិន្ត្រៃយ៍ ។

**មាត្រា១០៥១ ._** កាតព្វកិច្ចទទួលខុសត្រូវចំពោះការធ្វើប្រព្រឹត្តកម្ម និងការបញ្ចេញចោលសារធាតុបំពុល

ត្រូវផ្តន្ទាទោសក្នុងបទល្មើសថ្នាក់ទី៣ ចំពោះរូបវន្តបុគ្គល ឬនីតិបុគ្គលទាំងឡាយណា ដែលបញ្ចេញសារធាតុបំពុលពីប្រភពបំពុលទឹកជាក់លាក់ ចូលទៅក្នុងបរិស្ថានដោយមិនបានធ្វើប្រព្រឹត្តកម្ម ដូចមានចែងក្នុងមាត្រា៦៦៩ ។

ក្នុងករណីដែលការបញ្ចេញសារធាតុបំពុលដោយប្រភពបំពុលជាក់លាក់ខាងលើ បង្កឲ្យមានព្យសនកម្មកើតឡើងដល់មនុស្ស សត្វ និងបរិស្ថានទឹកធ្ងន់ធ្ងរ ត្រូវផ្តន្ទាទោសក្នុងបទល្មើសថ្នាក់ទី២ ។

ត្រូវផ្តន្ទាទោសក្នុងបទល្មើសថ្នាក់ទី១ ចំពោះរូបវន្តបុគ្គល ឬនីតិបុគ្គល ដែលប្រព្រឹត្តអំពើខាងលើ បង្កឲ្យមានព្យសនកម្មបាត់បង់អាយុជីវិត ឬពិការអចិន្ត្រៃយ៍ ។

**មាត្រា១០៥២ ._** ការបញ្ចេញសារធាតុបំពុលដោយគ្មានលិខិតអនុញ្ញាត

ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ក្នុងបទល្មើសថ្នាក់ទី៣ ចំពោះរូបវន្តបុគ្គល ឬនីតិបុគ្គលទាំងឡាយណា ដែលបញ្ចេញសារធាតុបំពុលដោយគ្មានលិខិតអនុញ្ញាត ដូចមានចែងក្នុងមាត្រា៦៧០ ។

ក្នុងករណីដែលការបញ្ចេញសារធាតុបំពុល ដោយគ្មានលិខិតអនុញ្ញាតខាងលើនេះ បង្កឲ្យមានព្យសនកម្មកើតឡើងដល់បូរណភាពរូបរាងកាយសត្វ និងបរិស្ថានធ្ងន់ធ្ងរ ត្រូវផ្តន្ទាទោសក្នុងបទល្មើសថ្នាក់ទី២ ។

ត្រូវផ្តន្ទាទោសក្នុងបទល្មើសថ្នាក់ទី១ ចំពោះអំពើរបស់រូបវន្តបុគ្គល ឬនីតិបុគ្គលដែលការបញ្ចេញសារធាតុបំពុលដោយគ្មានលិខិតអនុញ្ញាត បង្កឲ្យមានព្យសនកម្មបាត់បង់ជីវិតអាយុជីវិត ឬពិការអចិន្ត្រៃយ៍ ។

**មាត្រា១០៥៣ ._** លក្ខខណ្ឌតម្រូវក្នុងការជូនដំណឹង

ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ក្នុងបទល្មើសថ្នាក់ទី៣ ចំពោះរូបវន្តបុគ្គល ឬនីតិបុគ្គលទាំងឡាយណា ដែលកាន់កាប់លិខិតអនុញ្ញាត ហើយខកខានមិនបានជូនដំណឹង ដូចក្នុងករណីដែលមានចែងក្នុងមាត្រា៦៧៥ ។

**មាត្រា១០៥៤ ._** ការបញ្ចេញសារធាតុបំពុលខ្យល់ពីប្រភពចល័ត

ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ក្នុងបទល្មើសថ្នាក់ទី៣ ចំពោះរូបវន្តបុគ្គល ឬនីតិបុគ្គលទាំងឡាយណា ដែលបានបញ្ចេញសារធាតុបំពុលខ្យល់ពីប្រភពចល័តដោយគ្មានការអនុញ្ញាត ដូចមានចែងក្នុងមាត្រា៦៩២ ។

ក្នុងករណីដែលការបញ្ចេញសារធាតុបំពុលខ្យល់ខាងលើនេះ បង្កឲ្យមានព្យសនកម្មកើតឡើងដល់មនុស្ស សត្វ និងបរិយាកាសធ្ងន់ធ្ងរ ត្រូវផ្តន្ទាទោសក្នុងបទល្មើសថ្នាក់ទី៣ ។

ត្រូវផ្តន្ទាទោសក្នុងបទល្មើសថ្នាក់ទី១ ចំពោះអំពើរបស់រូបវន្តបុគ្គល ឬនីតិបុគ្គល ដែលបញ្ចេញសារធាតុបំពុលខ្យល់ខាងលើនេះ បង្កឲ្យមានព្យសនកម្មបាត់បង់អាយុជីវិតមនុស្ស ឬពិការអចិន្ត្រៃយ៍ ។

**មាត្រា១០៥៥ .**_ ការនាំចូល ការប្រើប្រាស់ និងការផលិតយានយន្តដែលបញ្ចេញសារធាតុបំពុល ខ្យល់លើសពីស្តង់ដារកំណត់

ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ក្នុងបទល្មើសថ្នាក់ទី៣ ចំពោះរូបវន្តបុគ្គល ឬនីតិបុគ្គលទាំងឡាយណា ដែលបានផលិត ប្រើប្រាស់ នាំចូលយានយន្ត និងគ្រឿងចក្រ ដែលបញ្ចេញសារធាតុបំពុលខ្យល់លើសពីស្តង់ដារកំណត់ ដូចមានចែងក្នុងមាត្រា៦៩៣ ។

**មាត្រា១០៥៦ .**_ ការបញ្ចេញសារធាតុបំពុលខ្យល់ពីប្រភពអចល័ត

ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ក្នុងបទល្មើសថ្នាក់ទី៣ ចំពោះរូបវន្តបុគ្គល ឬនីតិបុគ្គលទាំងឡាយណា ដែលបានបញ្ចេញសារធាតុបំពុលខ្យល់ពីប្រភពអចល័តដោយគ្មានការអនុញ្ញាត ដូចមានចែងក្នុងមាត្រា៦៩៦ ។

ក្នុងករណីដែលការបញ្ចេញសារធាតុបំពុលខ្យល់ខាងលើនេះ បង្កឲ្យមានព្យសនកម្មកើតឡើងដល់មនុស្ស សត្វ និងបរិយាកាសធ្ងន់ធ្ងរ ត្រូវផ្តន្ទាទោសក្នុងបទល្មើសថ្នាក់ទី៣ ។

ត្រូវផ្តន្ទាទោសក្នុងបទល្មើសថ្នាក់ទី១ ចំពោះអំពើរបស់រូបវន្តបុគ្គល ឬនីតិបុគ្គល ដែលបញ្ចេញសារធាតុបំពុលខ្យល់ខាងលើនេះ បង្កឲ្យមានព្យសនកម្មបាត់បង់អាយុជីវិតមនុស្ស ឬពិការអចិន្ត្រៃយ៍ ។

**មាត្រា១០៥៧ .**_ ការបំពានកាតព្វកិច្ចក្នុងការធ្វើតេស្តលើសំណាកនៃការបញ្ចេញសារធាតុបំពុលខ្យល់ពីប្រភពអចល័ត

ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ក្នុងបទល្មើសថ្នាក់ទី៣ ចំពោះរូបវន្តបុគ្គល ឬនីតិបុគ្គលទាំងឡាយណា ដែលមិនបានធ្វើតេស្តលើសំណាកនៃការបញ្ចេញសារធាតុបំពុលខ្យល់ពីប្រភពអចល័ត ដូចមានចែងក្នុងមាត្រា៧១៤ ។

**មាត្រា១០៥៨ .**_ អំពើរារាំងមន្ត្រីអធិការកិច្ច

ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ក្នុងបទល្មើសថ្នាក់ទី៣ ចំពោះរូបវន្តបុគ្គល ឬនីតិបុគ្គលទាំងឡាយណា ដែលដែលបានរារាំងមន្ត្រីអធិការកិច្ច ក្នុងការចូលធ្វើអធិការកិច្ចក្នុងបរិវេណ ឬអាគារ នៃប្រភពបំពុល ដូចមានចែងក្នុងមាត្រា៩២០ ។

ក្នុងករណីដែលរូបវន្តបុគ្គល ឬនីតិបុគ្គលបានរារាំងមន្ត្រីអធិការខាងលើនេះ បង្កឲ្យមានព្យសនកម្មដល់បូរណភាពរូបរាងកាយ ត្រូវផ្តន្ទាទោសក្នុងបទល្មើសថ្នាក់ទី២ ។

ត្រូវផ្តន្ទាទោសក្នុងបទល្មើសថ្នាក់ទី១ ចំពោះរូបវន្តបុគ្គល ឬនីតិបុគ្គល ដែលរារាំងមន្ត្រីអធិការកិច្ចខាងលើនេះបង្កឲ្យមានព្យសនកម្មដល់អាយុជីវិតមនុស្ស ឬពិការអចិន្ត្រៃយ៍ ។

## ជំពូកទី៧
## បទល្មើសពាក់ព័ន្ធនឹងមន្ត្រីនគរបាលយុត្តិធម៌ និងមន្ត្រីអធិការកិច្ចបរិស្ថាន និងធនធានធម្មជាតិ

**មាត្រា១០៥៩ .**_ ការមិនបំពេញបេសកកម្មរបស់មន្ត្រីនគរបាលយុត្តិធម៌បរិស្ថាន និងធនធានធម្មជាតិ

ត្រូវផ្តន្ទាទោសពិន័យរដ្ឋបាលចំពោះមន្ត្រីនគរបាលយុត្តិធម៌ និងធនធានធម្មជាតិ ដែលប្រព្រឹត្តបំពាន ឬមិនបំពេញបេសកកម្មរបស់ខ្លួន ដូចមានចែងក្នុងមាត្រា៩១៣ ដោយមិនរាប់បញ្ចូលការចោទប្រកាន់បទល្មើសព្រហ្មទណ្ឌដទៃទៀត ។

**មាត្រា១០៦០ .**_ ការមិនបំពេញភារកិច្ច និងតួនាទីរបស់មន្ត្រីអធិការកិច្ចបរិស្ថាន និងធនធានធម្មជាតិ

ត្រូវផ្តន្ទាទោសពិន័យរដ្ឋបាលចំពោះមន្ត្រីអធិការកិច្ចបរិស្ថាន និងធនធានធម្មជាតិ ដែលប្រព្រឹត្តបំពាន ឬមិនបំពេញភារកិច្ច និងតួនាទីរបស់ខ្លួន ដូចមានចែងក្នុងមាត្រា៩២០ ដោយមិនរាប់បញ្ចូលការចោទប្រកាន់បទល្មើសព្រហ្មទណ្ឌដទៃទៀត ។

# គន្ថីទី១១
# អន្តរប្បញ្ញត្តិ
## ជំពូកទោល
## អន្តរប្បញ្ញត្តិ

**មាត្រា១០៦១ .**_ ការអនុវត្តបទប្បញ្ញត្តិនៃក្រមនេះ

បទប្បញ្ញត្តិនៃច្បាប់ពិសេស និងលិខិតបទដ្ឋានគតិយុត្តដោយឡែក ដែលពាក់ព័ន្ធតាមវិស័យនីមួយៗ ដែលកំពុងនៅជាធរមាន នៅតែមានអានុភាពអនុវត្ត ។

ក្នុងករណីបទប្បញ្ញត្តិនៃច្បាប់ពិសេស និងលិខិតបទដ្ឋានគតិយុត្តដោយឡែកដែលពាក់ព័ន្ធតាមវិស័យនីមួយៗដែលកំពុងនៅជាធរមាន មិនស្របគ្នានឹងបទប្បញ្ញត្តនៃក្រមនេះ ក្រោយពេលក្រមនេះចូលជាធរមាន បទប្បញ្ញត្តិនៃក្រមនេះមានអានុភាពអនុវត្តជាអាទិភាព ។

**មាត្រា១០៦២ .**_ នីតិវិធី ដំណើរការ និងយន្តការផ្សេងៗនៃការអនុវត្តដែលមានស្រាប់

នីតិវិធីដំណើរការ និងយន្តការផ្សេងៗនៃការអនុវត្តដែលមានស្រាប់ ទាក់ទងនឹងកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ នៅបន្តអានុភាពអនុវត្ត រហូតដល់នីតិវិធី ដំណើរការ និងយន្តការផ្សេងៗនៃការអនុវត្តថ្មី ដែលបង្កើតឡើងក្រោមបទប្បញ្ញត្តិនៃក្រមនេះ បានបង្កើតឡើង ។

## គន្ថីទី១២
## អវសានប្បញ្ញត្តិ
## ជំពូកទោល
## អវសានប្បញ្ញត្តិ

**មាត្រា១០៦៣ .**_ និរាករណ៍នៃបទប្បញ្ញត្តិច្បាប់ពាក់ព័ន្ធ

រាល់បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងក្រមនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា១០៦៤ .**_ ការអនុវត្តក្រមនេះ

ក្រោយពីក្រមនេះចូលជាធរមាននៅទូទាំងប្រទេស ក្រមនេះត្រូវផ្សព្វផ្សាយរយៈពេល៦ (ប្រាំមួយ)ខែ ទើបអនុវត្ត លើកលែងតែបទប្បញ្ញត្តិស្តីពីការចូលរួមជាសាធារណៈ និងសិទ្ធិទទួលបានព័ត៌មានបរិស្ថាន និងធនធានធម្មជាតិ ដែលត្រូវមានអានុភាពអនុវត្តភ្លាម ។

ក្រមនេះត្រូវបានរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា
អនុម័តនៅថ្ងៃទី...... ខែ....... ឆ្នាំ............ នាសម័យប្រជុំរដ្ឋសភា
លើកទី......... នីតិកាលទី........ ។

រាជធានីភ្នំពេញ ថ្ងៃទី........ ខែ.............. ឆ្នាំ ២០១៨

**ប្រធានរដ្ឋសភា**

# ឯកសារជំនួយស្មារតី

## លើការប្រើប្រាស់ពាក្យបច្ចេកទេស

## ក្នុងសេចក្តីព្រាងក្រមបរិស្ថាន និងធនធានធម្មជាតិ

## កំណែទី១

**ការដាំព្រៃឈើថ្មី** : ការដាំព្រៃឈើថ្មីនៅលើដីដែលជាប្រវត្តិមកមិនដែលមានព្រៃឈើទេ។

**កសិរុក្ខកម្ម** : ប្រព័ន្ធគ្រប់គ្រងធនធានធម្មជាតិ ដែលរួមមានការប្រើប្រាស់ដីធ្លីជាលក្ខណៈប្រពៃណី ឬបែបទំនើប និងដែលព្រៃឈើត្រូវបានគ្រប់គ្រងជាមួយគ្នានឹងដំណាំ និង/ឬផលិតកម្មសត្វនៅជុំវិញទីកន្លែងកសិកម្មនោះ ។

**សារធាតុបំពុលខ្យល់** : សារធាតុបំពុលផ្សេងៗ ដែលរួមមានជាអាទិ៍ ផ្សែង លំអងផ្សេង ធូលី ផេះ ភាគល្អិតនៃសំណល់ ឧស្ម័ន ចំហាយទឹក អ័ព្ទ ក្លិន និងសារធាតុវិទ្យុសកម្ម ដែលបង្កឱ្យមានផលប៉ះពាល់ជាអវិជ្ជមាន ដែលអាចបង្កការខូចខាតដល់សុខភាពមនុស្ស ទ្រព្យសម្បត្តិ និងបរិស្ថាន ។

**ប្រភពបំពុលខ្យល់អចល័ត** : ប្រភពបំពុលខ្យល់ដែលស្ថិតនៅលើទីតាំងអចិន្ត្រៃយ៍មួយកន្លែងជាអាទិ៍មាន : ការដ្ឋានសំណង់ គ្រឿងកសិកម្ម និងកសិដ្ឋាន ទីតាំងនៃឧស្សាហកម្មនិស្សារណកម្ម ទីតាំង ផលិតថាមពល ស៊ីម៉ង់ កញ្ចក់ ឡដុតសំរាម រោងចក្រស្លប្រងកាត រោងចក្រផលិតសារធាតុគីមី រោងចក្រកែច្នៃចំណីអាហារ រោងចក្រវាយនភណ្ឌ និងប្រភពឧស្សាហកម្ម និងមិនមែនឧស្សាហកម្មផ្សេងទៀត ។

**ប្រភពបំពុលខ្យល់ចល័ត** : ប្រភពបំពុលខ្យល់ដែលស្ថិតនៅលើទីតាំងមិនអចិន្ត្រៃយ៍ជាអាទិ៍មាន : យន្តហោះ នាវាដឹកជញ្ជូន យានយន្ត អយស្ម័យយាន និងគ្រឿងម៉ាស៊ីន ឧបករណ៍ និងគ្រឿងចក្រ ផ្សេងទៀតនដែលអាចផ្លាស់ទីពីកន្លែងមួយទីកន្លែងមួយបាន ។

**ប្រភេទក្រៅស្រុក** : ប្រភេទដែលបាននាំមកដោយមនុស្ស ដោយចេតនា ឬអចេតនាក្តី ចេញពីរបាយធម្មជាតិនៅអតីតកាល ឬបច្ចុប្បន្នកាលរបស់វា ។

**សត្វ** : សំណាកណាមួយនៃជាប្រភេទថលជលិក បក្សី ថនិកសត្វ ឧរគសត្វ មច្ឆា ជ្លិកសត្វ ព្រមទាំងស៊ុត គភ៌ និងកូនរបស់វា ។

**ម្ចាស់សំណើ** : នៅក្នុងបរិបទនៃជីវសុវត្ថិភាព សំដៅទៅលើបុគ្គលដែលជូនដំណឹងអំពីគោលបំណងរបស់ខ្លួនក្នុងការប្រើប្រាស់សារពាង្គការកែច្នៃរស់ និង/ឬបុគ្គលដែលដាក់ពាក្យស្នើសុំការឯកភាពលើការនាំចូល ឬនាំចេញសារពាង្គការកែច្នៃរស់ពីព្រះរាជាណាចក្រកម្ពុជាសម្រាប់គោលបំណងណាមួយ។

**វារីវប្បកម្ម:** ដំណើរការនៃការភ្ញាស់ បង្កាត់ពូជ ចិញ្ចឹម និងផ្តល់ចំណីដល់ស៊ុតមច្ឆា កូនមច្ឆា មច្ឆា ឬមច្ឆជាតិនានា ឬការដាំដុះរាវិជាតសម្រាប់គោលបំណងនៃការបង្កាត់ពូជ និងការចិញ្ចឹមមច្ឆជាតិ និងសម្រាប់គោលបំណងនៃបង្កាត់ពូជ ឬផ្សាំ និងរាវិជាតនានា ។

**ជលសីលា:** ផ្ទាំងថ្មដែលមានលក្ខណៈភូគព្ភសាស្ត្រនៅក្រោមដី ដែលផ្ទុកទឹក ឬអនុញ្ញាតឱ្យទឹកហូរកាត់វាបាន ។

**ច្រាំង** : ផ្ទៃដីទាក់ទងទៅនឹងសមុទ្រ ទន្លេ ស្ទឹង ជាអាទិ៍ ត្រូវបានជន់លិចដោយទឹក ជាមួយគ្នានឹង ខ្សាច់ ដី ថ្ម ឬវត្ថុធាតុដទៃណាមួយដែលនៅជាប់គ្នានោះ ប៉ុន្តែមិនរាប់បញ្ចូលនូវដីណាមួយដែលត្រូវបានជន់លិចម្តងម្កាលដោយទឹកនោះទេ ។

**លក្ខខណ្ឌមូលដ្ឋាន:** លក្ខខណ្ឌនៃសេវាកម្មធនធានធម្មជាតិ និងប្រព័ន្ធអេកូឡូស៊ី ដែលផ្អែកលើព័ត៌មានដែលអាចទុកចិត្តបំផុតផ្នែកវិទ្យាសាស្ត្រដែលអាចស្វែងរកបាន និងទទួលស្គាល់ដោយអាជ្ញាធរមានសមត្ថកិច្ចនៅពេលធ្វើការវាយតម្លៃ ដែលបានកើតមានឡើងមុនពេលមានការខូចខាតណាមួយបានកើតឡើង ។

**អាង** : ចំណែកមួយនៃផ្ទៃដីទាក់ទងនឹងសមុទ្រ ទន្លេ ស្ទឹង ជាអាទិ៍ ដែលកំណត់ព្រំដែនដោយច្រាំងរបស់វា និងជាធម្មតា ត្រូវបានគ្របដណ្តប់ដោយទឹក ។

**អត្ថគាហក:**: រូបវន្តបុគ្គល ឬនីតិបុគ្គលម្នាក់ ឬច្រើននាក់ដែលមានសិទ្ធិក្នុងការទទួលផលប្រយោជន៍ពីបរធនបាលកិច្ច ។ អត្ថគាហក: អាចជានីតិបុគ្គល ឬអ្នកតំណាងនៃសហគមន៍ណាមួយដែលរងផលប៉ះពាល់ដោយផ្ទាល់ពីការអភិវឌ្ឍ ឬដែលចូលរួមក្នុងការគ្រប់គ្រងរួមគ្នា ។

**ការបែងចែងផលប្រយោជន៍** : គោលការណ៍ គំរូ និងដំណើរការដែលបានរៀបចំ និងអនុវត្ត ដើម្បីធ្វើការបែងចែកផលប្រយោជន៍នានានៃសកម្មភាពរបស់គម្រោង ដែលរួមមាន ការផ្តល់មូលនិធិដល់គម្រោង រវាងអ្នកចូលរួម និងអ្នកពាក់ព័ន្ធផ្សេងៗគ្នា ។

**ភស្តុតាងផ្នែកវិទ្យាសាស្ត្រប្រសើរបំផុតដែលអាចស្វែងរកបាន** : ភស្តុតាងដែលពាក់ព័ន្ធបំផុតនិង សំអាងលើការពិសោធន៍ចុងក្រោយបង្អស់ ដែលទទួលបានតាមមរយៈការស្រាវជ្រាវផ្នែកវិទ្យាសាស្ត្រដែលបានត្រួតពិនិត្យដែលមានលក្ខណៈសត្យានុម័ត ត្រឹមត្រូវ និងដោយក្រុមមនុស្សដែលមានឋានៈស្មើគ្នា ។

**បច្ចេកវិទ្យា/បច្ចេកទេសប្រសើរបំផុតដែលអាចស្វែងរកបាន** : ដំណាក់កាលក្នុងការអភិវឌ្ឍជឿនលឿន និងប្រកបដោយប្រសិទ្ធភាពបំផុតនៃសកម្មភាពមួយ ឬវិធីសាស្ត្រនៃប្រតិបត្តិការរបស់សកម្មភាពនោះ ដែលរួមមានបច្ចេកទេសដែលត្រូវបានប្រើប្រាស់សម្រាប់ការរចនា ការបង្កើត ការរក្សាទុក ការធ្វើប្រតិបត្តិការ និងការបញ្ចប់វិធីនៃការដំឡើង ដែលអនុញ្ញាតឱ្យមានការអនុវត្តនៅក្នុង វិស័យពាក់ព័ន្ធ

ក្រោមលក្ខខណ្ឌសេដ្ឋកិច្ច និងបច្ចេកទេសដែលអាចសម្រេចបាន ដែលពិចារណាទៅលើតម្លៃ និងគុណសម្បត្តិ ដរាបណាលក្ខខណ្ឌទាំងនោះមានលក្ខណៈសមស្រប និងអាចស្វែងរកបាន ។

**ទម្លាប់នៃការអនុវត្តការគ្រប់គ្រងល្អបំផុត** : ជាទម្លាប់នៃការអនុវត្តមួយ ឬជាធម្មតា ជាការបញ្ចូលគ្នានៃទម្លាប់អនុវត្តផ្សេងៗដែលបានកំណត់ដោយឧស្សាហកម្ម ឬស្ថាប័នពាក់ព័ន្ធនៃរដ្ឋាភិបាល ថាជាមធ្យោបាយប្រកបដោយប្រសិទ្ធភាពបំផុត និងដែលអាចអនុវត្តបាន (រួមមាន ការពិចារណាផ្សេងៗផ្នែកបច្ចេកវិទ្យា សេដ្ឋកិច្ច និងជាលក្ខណៈស្ថាប័ន) នៃការសម្រេចឲ្យបាននូវស្តង់ដារ និងគោលដៅចីរភាព ។

**ជីវៈចម្រុះ** : ភាពទីទៃពីគ្នាក្នុងចំណោមសារពាង្គកាយរស់ផ្សេងៗមកពីប្រភពទាំងអស់ ដែលរួមមានជាអាទិ៍ ប្រព័ន្ធអេកូឡូស៊ីនៃដែនគោក ដែនសមុទ្រ និងប្រព័ន្ធអេកូឡូស៊ីនៃដែនទឹកដទៃទៀត ព្រមទាំងទីតាំងអេកូឡូស៊ីមួយចំនួនដែលសារពាង្គកាយទាំងនោះជាផ្នែកមួយនៃវានេះ រួមមានភាពចម្រុះនៅក្នុងប្រភេទ រវាងប្រភេទ និងនៃប្រព័ន្ធអេកូឡូស៊ីផ្សេងៗ ។

**ការអភិរក្សជីវៈចម្រុះ សត្វព្រៃ និងធនធានធម្មជាតិ** : ការធានាឱ្យមានការអភិរក្សធនធានធម្មជាតិ រួមមាន ជីវៈចម្រុះ និងចីរភាពរយៈពេលវែងនៃធនធានទាំងនេះ តាមរយៈការគ្រប់គ្រងត្រឹមត្រូវ ការស្រាវជ្រាវ និងការបង្កើនការយល់ដឹង ដែលទាក់ទងនឹងការគ្រប់គ្រងនៃរបៀងអភិរក្សជីវៈចម្រុះ និងតំបន់ការពារធម្មជាតិ ។

**ជីវសុវត្ថិភាព** : កិច្ចខំប្រឹងប្រែងក្នុងការកាត់បន្ថយ និងលុបបំបាត់ហានិភ័យជាសក្តានុពល ដែលកើតចេញពីជីវបច្ចេកវិទ្យា ។

**ផលិតផលសម្រាប់កុមារ:** ផលិតផលផ្សេងៗ ដែលមានជាអាទិ៍ ប្រដាប់ក្មេងលេង និងផលិតផលផ្សេងទៀតដែលត្រូវបានរចនាឡើងសម្រាប់ ឬក្នុងគោលបំណងជាបឋមផ្គាក់ផ្ទុកឱ្យ ឬប្រើប្រាស់ដោយកុមារដែលមានអាយុចាប់ពី ១២ឆ្នាំ (ដប់ពីរ) ចុះក្រោម ។

**ផលិតកម្មស្អាត** : ការអនុវត្តជាបន្តនូវយុទ្ធសាស្ត្របរិស្ថានដែលមានលក្ខណៈទប់ស្កាត់ និងចម្រុះចំពោះដំណើរការ ទំនិញ និងសេវាកម្មផ្សេងៗ ដើម្បីបង្កើននូវប្រសិទ្ធផលជារួម និងកាត់បន្ថយហានិភ័យនានាទៅលើមនុស្ស និងបរិស្ថាន។

**ដីឆ្នេរ** : ដីដែលផុសឡើងទាំងឡាយដែលលាតសន្ធឹងទៅកាន់ដីគោកឆ្ងាយពីបន្ទាត់ទឹកជោរ ៥ (ប្រាំ) គីឡូម៉ែត្រ ដែលរួមមាន តំបន់ដែលមានទឹកជោរនាចទៅវិញទៅមក ។

**ទឹកនៅតាមឆ្នេរសមុទ្រ** : ទឹកទាំងឡាយដែលលាតសន្ធឹងទៅកាន់សមុទ្រឆ្ងាយពីបន្ទាត់ទឹកជោរ ៥ (ប្រាំ)គីឡូម៉ែត្រ ដែលរួមមាន ដីដែលលិចចុះទៅក្នុងទឹកដែលពាក់ព័ន្ធ ។

**តំបន់ឆ្នេរ** : ផ្ទៃដីដែលលាតសន្ធឹងឆ្ងាយពីបន្ទាត់ឆ្នេរសមុទ្រទៅកាន់ដីគោកឆ្ងាយពីបន្ទាត់ទឹកជោរ ៥ (ប្រាំ) គីឡូម៉ែត្រ និងផ្ទៃសមុទ្រដែលលាតសន្ធឹងទៅកាន់សមុទ្រឆ្ងាយពីបន្ទាត់ទឹកនាច ៥ (ប្រាំ) គីឡូម៉ែត្រ ។

**ការគ្រប់គ្រងរួមគ្នា** : យន្តការដោយស្ម័គ្រចិត្តនៃការគ្រប់គ្រងដីធ្លី និងធនធានធម្មជាតិ និងការអភិវឌ្ឍជីវភាពរស់នៅនៅតាមមូលដ្ឋាន ដែលអាជ្ញាធរថ្នាកជាតិ និងថ្នាក់ក្រោមជាតិ ជនជាតិដើម ភាគតិច សហគមន៍មូលដ្ឋាន និងដៃគូបច្ចេកទេសនានា រួមចំណែកក្នុងការទទួលខុសត្រូវទៅលើការប្រើប្រាស់ ការគ្រប់គ្រង និងការការពារធនធានធម្មជាតិ និងជីវៈចម្រុះដោយចីរភាព ។

**អាណត្តិនៃបរធនបាលទៅលើការប្រើប្រាស់ដីធ្លីសម្រាប់ការគ្រប់គ្រងរួមគ្នា** : សិទ្ធិគ្រប់គ្រង និងប្រើប្រាស់ជាពិសេសលើដីសាធារណៈរបស់រដ្ឋ ដែលកាន់កាប់ដោយអាជ្ញាធរគ្រប់គ្រងរួមគ្នាមួយ សម្រាប់គោលបំណងនៃការអនុវត្តការគ្រប់គ្រងរួមគ្នា ។ អាណត្តិនៃបរធនបាលទៅលើការប្រើប្រាស់ដីធ្លីសម្រាប់ការគ្រប់គ្រងរួមគ្នា ត្រូវទទួលស្គាល់ដោយ និងចុះបញ្ជីនៅរដ្ឋបាលសុរិយោដីទទួលបន្ទុកចុះបញ្ជីដីធ្លី ។

**ការប្រើប្រាស់ជាលក្ខណៈពាណិជ្ជកម្ម** : ការប្រើប្រាស់ណាមួយ ដែលលើសពីការប្រើប្រាស់ សម្រាប់ការចិញ្ចឹមជីវិត ដែលមានគោលបំណងជាបឋម ដើម្បីទទួលបានប្រាក់ចំណេញ ឬផលប្រយោជន៍ផ្នែកសេដ្ឋកិច្ច ។

**អេកូទេសចរណ៍ដែលពឹងផ្អែកលើសហគមន៍** : អេកូទេសចរណ៍ដែលក្នុងនោះ សហគមន៍មូលដ្ឋានមួយ គឺជាម្ចាស់ និងជាអ្នកគ្រប់គ្រងដ៏សំខាន់នៃហេដ្ឋរចនាសម្ព័ន្ធ និងសកម្មភាពទេសចរណ៍ ហើយសកម្មភាពទេសចរណ៍ទាំងនោះ ត្រូវធ្វើប្រតិបត្តិការដោយផ្អែកលើមូលដ្ឋាននៃការបែងចែកផលប្រយោជន៍ដោយផ្ទាល់ជាមួយនឹងសហគមន៍ ។

**ការគ្រប់គ្រងធនធានធម្មជាតិដែលពឹងផ្អែកលើសហគមន៍** : វិធីសាស្ត្រនៃការគ្រប់គ្រងធនធានធម្មជាតិដែលស្ថិតនៅក្រោមកិច្ចការដែលសហគមន៍បានបំពេញ ឬយ៉ាងហោចណាស់ស្ថិតនៅក្រោមការត្រួតពិនិត្យ និងការចូលរួមភាគច្រើនរបស់សហគមន៍ក្នុងការគ្រប់គ្រងធនធានរបស់ខ្លួន ឬធនធាននានា និងផលប្រយោជន៍ទាំងអស់ ឬយ៉ាងហោចណាស់ ផលប្រយោជន៍ភាគច្រើន ត្រូវបន្សល់ទុកនៅក្នុងសហគមន៍ ។

**តំបន់ការពារសហគមន៍** : ផ្នែកជាក់លាក់មួយនៃតំបន់ការពារធម្មជាតិ ដែលកំណត់ដោយក្រសួង ស្ថាប័នទទួលបន្ទុកគ្រប់គ្រងប្រព័ន្ធតំបន់ការពារថ្នាក់ជាតិ ដែលត្រូវគ្រប់គ្រងដោយសហគមន៍មូលដ្ឋាន ឬសហគមន៍ជនជាតិដើមភាគតិច ដែលមានរចនាសម្ព័ន្ធរដ្ឋបាលរបស់ខ្លួនដែលរៀបចំឡើងតាមរយៈការបោះឆ្នោត ដែលមានគោលបំណងរួមក្នុងការប្រើប្រាស់ធនធានធម្មជាតិប្រកបដោយចីរភាព និងលើកកម្ពស់ស្តង់ដារនៃការរស់នៅរបស់សហគមន៍មូលដ្ឋាន និងសហគមន៍ជនជាតិដើមភាគតិច ។

**ការបង្កាត់ពូជអភិរក្ស** : ការបង្កាត់ពូជនៃប្រភេទសត្វព្រៃដែលបង្ខាំងទុក សម្រាប់គោលបំណងចម្បងក្នុងការការបញ្ចៀសការផុតពូជនៃប្រភេទសត្វនេះនៅក្នុងព្រៃ និងមិនមែនសម្រាប់គោលបំណងពាណិជ្ជកម្មឡើយ ដែលការបង្កាត់ពូជនេះ អាចពាក់ព័ន្ធនឹងការនាំមកវិញជាថ្មីនូវសត្វបង្ខាំដែលគេបង្កាត់ពូជឲ្យចូលទៅក្នុងព្រៃវិញ ។

**ការគ្រប់គ្រងការអភិរក្ស** : ការផ្លាស់កន្លែងរបស់សត្វព្រៃណាមួយទៅកាន់ជម្រកសមស្របដែលជាជម្រើសមួយ សម្រាប់គោលបំណងនៃការនាំមកវិញជាថ្មី ការស្តុកទុកឡើងវិញ ឬការបំពេញបន្ថែមនៃចំនួនសត្វព្រៃ ឬដើម្បីទប់ស្កាត់ការផុតពូជនៃចំនួនសត្វព្រៃដែលមិនអាចជៀសផុតបាន ការស្រាវជ្រាវ ឬការគ្រប់គ្រងចំនួនសត្វព្រៃដោយគ្មានការសម្លាប់ ឬការបំផ្លិចបំផ្លាញសត្វព្រៃ និងការចាប់សត្វព្រៃសម្រាប់គោលបំណងច្បាស់លាស់នៃការបង្កើត និងការរក្សានូវចំនួនសត្វដែលបង្កាត់ពូជសម្រាប់ការអភិរក្សប្រកបដោយសុវត្ថិភាពមួយនៃប្រភេទសត្វដែលរងការគំរាមកំហែងជាសកលនៅក្នុងទីតាំងបង្កាត់ពូជដើម្បីអភិរក្សដែលបានចុះបញ្ជីមួយ និងផលិតកម្មសត្វបង្ខាំងដែលគេបានបង្កាត់ពូជ សម្រាប់ការប្រលែងចូលទៅក្នុងព្រៃវិញ ។

**ការអភិរក្សតម្លៃ ទំនិញ និងសេវាកម្មនៃប្រព័ន្ធអេកូឡូស៊ី** : ការធានាឱ្យមានការពិចារណាដ៏ពេញលេញអំពីតម្លៃ ទំនិញ និងសេវាកម្មផ្សេងៗ ដែលប្រព័ន្ធអេកូឡូស៊ីផ្តល់ឱ្យ ដែលមានជាអាទិ៍ ការផ្គត់ផ្គង់ទឹក និងបូរណភាពនៃទីជម្រាល ផលិតផលធនធានធម្មជាតិ ការរោយលំអង ការច្រោះការបំពុល ការធ្វើឲ្យមានស្ថិរភាពអាកាសធាតុ និងការកាត់បន្ថយការប្រែប្រួលអាកាសធាតុ ការទប់ស្កាត់ការហូរច្រោះដី ការផ្គត់ផ្គង់ទឹកស្អាត និងបូរណភាពទីជម្រាល និងការធានាឲ្យមានការប្រើប្រាស់ជាប្រយោជន៍រយៈពេលវែងនៃទំនិញ និងសេវាកម្មទាំងនេះ ដែលទាក់ទងទៅនឹងការគ្រប់គ្រងរបៀងអភិរក្សជីវៈចម្រុះ និងតំបន់ការពារធម្មជាតិ ។

**ការប្រើប្រាស់ក្នុងដែនកំណត់** : ប្រតិបត្តិការ ឬសកម្មភាពណាមួយដែលទាក់ទងនឹងសារពាង្គកាយកែច្នៃរស់ដែលធ្វើឡើងនៅក្នុងទីកន្លែង ឬមធ្យបាយ ឬឧបករណ៍ណាមួយ ហើយស្ថិតនៅក្រោមវិធានការជាក់លាក់ ដែលតបើស្កាត់មិនឱ្យសារពាង្គកាយកែច្នៃរស់ទាំងនោះប៉ះពាល់ទៅដល់បរិស្ថាន ខាងក្រៅ ។

**បេតិកភណ្ឌវប្បធម៌** : សម្បត្តិរូបី និងអរូបីដែលកសាងឡើងដោយកិច្ចខំប្រឹងប្រែងរបស់មនុស្ស ដែលមានលក្ខណៈជាវិទ្យាសាស្ត្រ ប្រវត្តិសាស្ត្រ សិល្បៈ ឬសាសនា និងមានការបង្ហាញអំពីរបៀបរស់នៅ

របស់សហគមន៍មួយ និងបានបញ្ជូនបន្តពីជំនាន់មួយទីជំនាន់មួយទៀត ដែលរួមមាន ទំនៀមទំលាប់ ទម្លាប់ការអនុវត្ត វត្ថុ ការសម្តែង និងតម្លៃខាងសិល្បៈនានា ។

**ទំនប់ទឹក** : ការងារផ្សេងៗ ដែលរួមមាន របាំងការពារ ទោះជាអចិន្ត្រៃ ឬបណ្តោះអាសន្នក៏ដោយ ដែល ធ្វើ ឬ អាច ឬនឹងឃាំងទឹកទុក និងទីតាំងស្តុកទុកដែលបានបង្កើតឡើងដោយការងារទាំងឡាយនោះ។

**ការខូចខាត** : ក្នុងបរិបទនៃជីវសុវត្ថិភាព សំដៅទៅលើផលប៉ះពាល់អវិជ្ជមានទៅលើលារអភិរក្សជីវៈចម្រុះ និងការប្រើប្រាស់ធនធានធម្មជាតិដោយចីរភាព ដែលរួមមានទាំងហានិភ័យណាមួយដល់សុខភាពមនុស្ស ដែលបង្កដោយសារពាង្គកាយកែច្នៃរស់ និងដែលអាចវាស់វែងបាន ឬអង្កេតមើលបាន ។

**ប្រព័ន្ធគ្រប់គ្រងទិន្នន័យ** : ការប្រមូលទិន្នន័យដែលពាក់ព័ន្ធប្រកបដោយលក្ខណៈគ្រប់ជ្រុងជ្រោយមួយដែលគេបានរៀបចំឡើងសម្រាប់ការប្រើប្រាស់ដោយភាពងាយស្រួល ជាទូទៅនៅក្នុងប្រព័ន្ធកុំព្យូទ័រ ។

**ប្រព័ន្ធគាំទ្រការធ្វើសេចក្តីសម្រេចចិត្ត** : បណ្តុំនៃកម្មវិធីកំព្យូទ័រ និងទិន្នន័យដែលពាក់ព័ន្ធដែលតម្រូវឱ្យមាន ដើម្បីជួយដល់ការវិភាគ និងការធ្វើសេចក្តីសម្រេចចិត្តនៅក្នុងស្ថាប័នមួយ ។

**ផែនការគោលអភិវឌ្ឍន៍** : ផែនការអភិវឌ្ឍន៍នានាដែលបានរៀបចំដោយអាជ្ញាធរថ្នាក់ក្រោមជាតិសម្រាប់ការរៀបចំឡើងវិញ និងការរៀបចំសមត្ថកិច្ចរបស់ពួកគេរៀងៗខ្លួន ។

**ផលប៉ះពាល់ផ្ទាល់ និងប្រយោល** : ផលប៉ះពាល់ផ្ទាល់ សំដៅលើផលប៉ះពាល់ដែលបណ្តាលមកពីគម្រោង ឬសកម្មភាពមួយ និងកើតឡើងក្នុងពេល និងទីកន្លែងតែមួយ ដូចគ្នានឹងគម្រោង ឬសកម្មភាពនោះ ខណៈដែលផលប៉ះពាល់ប្រយោល សំដៅលើផលប៉ះពាល់ដែលអាចព្យាករណ៍ទុកមុនបាន និងដែលបណ្តាលមកពីគម្រោង ឬសកម្មភាពមួយ ប៉ុន្តែនៅក្នុងពេល និងទីកន្លែងខុសគ្នាពីគម្រោង ឬសកម្មភាពនោះ ។

**ការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ** : ទម្លាប់អនុវត្តនៃការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយតាមរយៈការវិភាគ និងការគ្រប់គ្រងជាប្រព័ន្ធនូវកត្តាបង្កគ្រោះមហន្តរាយនានា រួមមានតាម រយៈការប្រឈមទៅនឹងគ្រោះថ្នាក់ដែលបានកាត់បន្ថយ ការបន្ថយចុះនូវភាពងាយរងគ្រោះរបស់ប្រជាពលរដ្ឋ និងទ្រព្យសម្បត្តិ ការគ្រប់គ្រងដីធ្លី និងបរិស្ថាន និងការត្រៀមលក្ខណៈដែលប្រសើរឡើង និងព្រមានជាមុនសម្រាប់ព្រឹត្តិការណ៍អវិជ្ជមាន រួមទាំងការប្រែប្រួលអាកាសធាតុ ។

**ការបង្ហូរចេញ** : ការបន្ថែមសារធាតុបំពុលទឹកមួយដោយប្រភពជាក់លាក់ ឬប្រភពមិនជាក់លាក់ទៅលើទឹកនៅលើដី ឬធនធានទឹកក្រោមដី ដែលទាក់ទងទៅនឹងការបំពុលទឹក ។

**សមាគមន៍ក្នុងស្រុក** : ស្ថាប័នសមាជិកភាពមួយដែលបង្កើតឡើងក្រោមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា ដោយរូបវន្តបុគ្គល ឬនីតិបុគ្គល ក្នុងគោលបំណងធ្វើជាតំណាង ឬការពារប្រយោជន៍នៃសមាជិករបស់ខ្លួន ដោយពុំគិតពីការបង្កើត ឬបែងចែកផលចំណេញ ។

**ពាណិជ្ជកម្មក្នុងស្រុក** : ការដោះដូរទំនិញជាលក្ខណៈពាណិជ្ជកម្ម ដែលរួមមានសំណាកនៃសត្វ និងរុក្ខជាតិព្រៃ ដែលមានប្រភព ឬបង្កើតនៅក្នុងព្រំដែននៃព្រះរាជាណាចក្រកម្ពុជា ។

**ប្រព័ន្ធផ្តល់សញ្ញា/ព្រមានជាមុន** : បណ្តុំនៃសមត្ថភាពផ្សេងៗដែលត្រូវការក្នុងការបង្កើត និងផ្សព្វផ្សាយព័ត៌មានដែលជាការផ្តល់សញ្ញាជាមុន ទាន់ពេលវេលានិងមានអត្ថន័យ ដើម្បីជួយដល់បុគ្គល សហគមន៍ និងស្ថាប័នទាំងឡាយដែលរងការគំរាមកំហែងដោយគ្រោះថ្នាក់ដើម្បីត្រៀមលក្ខណៈក្នុងការឆ្លើយតបប្រកបដោយប្រសិទ្ធភាព និងប្រតិកម្មភ្លាមៗ និងដោយសមស្របក្នុងការកាត់បន្ថយនូវលទ្ធភាពនៃការខូចខាត និងការបាត់បង់ ។

**សូចនាករផ្នែកអេកូឡូស៊ី** : សារធាតុ/វត្ថុធាតុ សមាសធាតុ ឬស្ថានភាពនៃប្រព័ន្ធអេកូឡូស៊ីមួយជាក់លាក់ និងអាចវាស់វែងបាន ដែលមានលក្ខណៈឆាប់ទទួលរងទៅនឹងការប្រែប្រួលផ្សេងៗនៅក្នុងលក្ខណៈសំខាន់ៗនៃប្រព័ន្ធអេកូឡូស៊ី ដែលនៅក្នុងសូចនាករផ្នែកអេកូឡូស៊ីនោះនឹងមានចំនួននៃការប្រែប្រួលដែលអាចទទួលយកបានជាលក្ខណៈអេកូឡូស៊ី ។ ឧទាហរណ៍ផ្សេងៗ រួមមាន ចំនួនសរុបនៃសត្វ/រុក្ខជាតិទាំងឡាយដែលធំពេញវ័យក្នុងចំនួនមួយ ឬអត្រានៃសារពើរុក្ខជាតិធម្មជាតិធៀបនឹងអត្រានៃសារពើរុក្ខជាតិដែលមិនមែនធម្មជាតិ ។

**បូរណភាពផ្នែកអេកូឡូស៊ី** : សមត្ថភាពនៃប្រព័ន្ធអេកូឡូស៊ីមួយដើម្បីគាំពារ និងថែរក្សានូវសហគមន៍នៃសារពាង្គកាយទាំងឡាយដែលមានសមាសភាព ភាពចម្រុះ និងដំណើរការនៃប្រភេទនានា ដែលប្រហាក់ប្រហែលទៅនឹងជម្រកធម្មជាតិទាំងឡាយនៅក្នុងតំបន់មួយ។

**លទ្ធផលផ្នែកអេកូឡូស៊ី** : ផលវិបាកសម្រាប់ប្រព័ន្ធអេកូឡូស៊ីមួយនៅក្នុងផ្នែកផ្សេងៗនៃសមាសធាតុរបស់វាដែលបានកំណត់ សម្រាប់ជលសីលា អាងរំដោះទឹក ទីរងទឹកភ្លៀង ទីរងទឹកភ្លៀងតូចៗ

និងផ្លូវទឹកផ្សេងៗ ។

**ការគំរាមកំហែងផ្នែកអេកូឡូស៊ី** : កត្តាណាមួយដែលបានបង្កើតឡើង នាំមកដោយមនុស្ស ឬដែលមិនមែនធម្មជាតិ ដែលមានសក្តានុពលក្នុងការបន្ទុចបង្អាក់ប្រព័ន្ធអេកូឡូស៊ីធម្មជាតិមួយ និង/ឬ បណ្តាលឱ្យសូចនាករផ្នែកអេកូឡូស៊ី មានតម្លៃ នៅក្រៅកម្រិតប្រែប្រួលដែលអាចទទួលយកបានផ្នែកអេកូឡូស៊ី ។

**ចំនួនប្រភេទដែលមានដំណើរការតាមលក្ខណៈអេកូឡូស៊ី** : ចំនួនប្រភេទនៃទំហំ និងឌីណាមិចមួយ ដែលវាមិនគ្រាន់តែអាចរស់រានទៅបាននោះទេ ប៉ុន្តែថែមទាំងអាចផ្តល់នូវសេវាកម្មអេកូឡូស៊ី និង តួនាទីនៃចំនួនប្រភេទតាមបែបធម្មជាតិ ដែលគ្មានការរំខាន ទៅដល់ប្រព័ន្ធអេកូឡូស៊ីដែលនៅជុំវិញ ។

**ប្រព័ន្ធអេកូឡូស៊ី** : ជាការរួមផ្សំបញ្ចូលគ្នាដ៏ពេញដោយសក្តានុពលនៃរុក្ខជាតិ សត្វ និងប្រភេទមីក្រូសារពាង្គកាយ និងបរិស្ថានឥតជីវិតរបស់ពួកវា និងដំណើរការផ្នែកអេកូឡូស៊ីនានា រវាងប្រភេទទាំងនោះ ដែលធ្វើអន្តរកម្ម ជាអង្គភាពដែលមានកិច្ចដំណើរការមួយ ។

**សេវាកម្មប្រព័ន្ធអេកូឡូស៊ី** : សេវាកម្មធនធានធម្មជាតិ និងផលប្រយោជន៍ផ្សេងៗ ដែលប្រជាពលរដ្ឋ ទទួលបានពីប្រព័ន្ធអេកូឡូស៊ីដែលផលិត និងទ្រទ្រង់ធនធានធម្មជាតិ តាមរយៈវដ្តនៃ ជីវសាស្ត្រ ភូមិសាស្ត្រ និងគីមីសាស្ត្រដែលមានតម្លៃជារូបីយវត្ថុ និងមិនមែនជារូបីយវត្ថុដល់បុគ្គល ឬសង្គមជាធំ ។ តម្លៃទាំងនេះ រួមមាន:

១) ការផ្តល់សេវកម្មផ្សេងៗ រួមមានជាអាទិ៍ ចំណីអាហារ ផលិតផលព្រៃឈើ និងទឹក ។

២) និយ័កម្មលើសេវាកម្មផ្សេងៗ រួមមានជាអាទិ៍ និយ័តកម្មទឹកជំនន់ គ្រោះរាំងស្ងួត ការខូចគុណភាពដី គុណភាពខ្យល់ អាកាសធាតុ និងជម្ងឺ ។

៣) ការគាំទ្រដល់សេវាកម្មផ្សេងៗ រួមមានជាអាទិ៍ ការបង្ករជាដីឡើង និងការវិលជុំនៃសារធាតុចិញ្ចឹម និង

៤) សេវាកម្ម និងតម្លៃវប្បធម៌ផ្សេងៗ រួមមានជាអាទិ៍ ផលប្រយោជន៍ផ្នែកការកំសាន្តសប្បាយ ព្រលឹងវិញ្ញាណ សាសនា និងផលប្រយោជន៍មិនមែនជាសម្ភារៈដទៃទៀត ។

**អេកូទេសចរណ៍** : ទេសចរណ៍ប្រកបដោយចីរភាព និងមានការទទួលខុសត្រូវលើបរិស្ថាន វប្បធម៌ និងសង្គម ដែលលើកកម្ពស់ការអភិរក្ស ដែលមានទំហំភ្ញៀវទេសចរណ៍និងផលប៉ះពាល់ក្នុងកម្រិតទាប ដែលមានការពាក់ព័ន្ធ និងមានផលប្រយោជន៍ដល់សហគមន៍មូលដ្ឋាន ហើយពាក់ព័ន្ធដល់ការបកស្រាយ និងការអប់រំរបស់ភ្ញៀវទេសចរណ៍ និងម្ចាស់ផ្ទះ ។

**ប្រភេទសត្វ និងរុក្ខជាតិដែលកំពុងរងគ្រោះថ្នាក់** : សារពាង្គកាយទាំងឡាយ ដែលចាត់ទុកថា ប្រឈមមុខនឹងហានិភ័យខ្ពស់បំផុតនៃការផុតពូជនៅក្នុងព្រៃ យោងទៅតាមភស្តុតាងប្រសើរបំផុតដែលអាចស្វែងរកបាន ។

**បរិស្ថាន** : សមាសធាតុមានជីវិត និងឥតជីវិតទាំងអស់ រួមមានទ្រង់ទ្រាយ និងលក្ខខណ្ឌរូបសាស្ត្រ ជីវសាស្ត្រ សង្គម វិញ្ញាណ និងវប្បធម៌ រួមមានជាអាទិ៍ ដី ខ្យល់ ទឹក រុក្ខជាតិ សត្វ និងភាវៈមានជីវិតដែលមិនមែនជាមនុស្ស មនុស្សជាតិ សហគមន៍របស់ពួកគេ ព្រមទាំងអ្វីៗដែលនៅជុំវិញដែលបាន

បង្កើតឡើង និងទំនាក់ទំនងផ្នែករូបសាស្ត្រ និងមនមៃនរូប ដែលកើតមានរវាង ឬក្នុងចំណោមសមាធាតុណាមួយ ឬទាំងអស់នៃសមាសធាតុតទាំងនោះ ។

**សវនកម្មបរិស្ថាន** : ការវាយតម្លៃឯករាជ្យដែលបានចងក្រងជាឯកសារមួយ អំពីគម្រោង ឬសកម្មភាពមួយ មានជាអាទិ៍ ការវាយតម្លៃនៃទម្លាប់អនុវត្តនៃការគ្រប់គ្រង ប្រព័ន្ធនៃការគ្រប់គ្រង និងកិច្ចប្រតិបត្តិការរបស់រោងចក្រ ។

**លំហូរបរិស្ថាន** : លំហូរទឹកចាំបាច់សម្រាប់ចីរភាពប្រព័ន្ធអេកូឡូស៊ី និងជីវភាពរស់នៅនិងសុខុមាលភាពរបស់មនុស្ស ដែលពឹងផ្អែកលើប្រព័ន្ធអេកូឡូស៊ីនេះ ។

**គោលដៅលំហូរបរិស្ថាន** : គោលដៅលំហូរមួយចាំបាច់សម្រាប់ចីរភាពប្រព័ន្ធអេកូឡូស៊ី និងជីវភាពរស់នៅនិងសុខុមាលភាពរបស់មនុស្ស ដែលពឹងផ្អែកលើប្រព័ន្ធអេកូឡូស៊ីនេះ ។ គោលដៅលំហូរនៃបរិស្ថាន អាចរួមមាន ព័ត៌មានលម្អិតអំពីពេលវេលា រយៈពេល ភាពញឹកញាប់ អត្រា និងទំហំនៃលំហូរ។

**ការខូចខាតបរិស្ថាន** : ផលប៉ះពាល់អវិជ្ជមានលើបរិស្ថាន ដែលរួមមានការធ្វើឱ្យអន់ថយ ការបំផ្លិចបំផ្លាញ ការបាត់បង់ ឬការបាត់បង់នៃការប្រើប្រាស់សមាសភាគរបស់បរិស្ថាន រួមមាន ធនធានធម្មជាតិ និងបេតិកភណ្ឌវប្បធម៌ និងផលប៉ះពាល់អវិជ្ជមានលើសុខភាព និងសុខុមាលភាពរបស់មនុស្ស រួមមានការបាត់បង់ប្រាក់ឈ្នួល ប្រាក់ចំណូល ប្រាក់ចំណេញ ពន្ធ និងប្រាក់កម្រៃ ចំណូល ឬសួយសារនានារបស់រដ្ឋាភិបាល ។

**ហេតុប៉ះពាល់បរិស្ថាន** : ហេតុប៉ះពាល់ណាមួយទៅលើបរិស្ថាន ដោយផ្ទាល់ក្តី ឬដោយប្រយោលក្តី ដោយបានបង្កឡើង មានលក្ខណៈអវិជ្ជមាន វិជ្ជមាន ដែលមានការបង្គរឡើង ឬមានលក្ខណៈឆ្លងដែនក៏ដោយ រួមមានជាអាទិ៍ហេតុប៉ះពាល់ជាលក្ខណៈរូបវន្ត ជីវសាស្ត្រ អេកូឡូស៊ី ធនធានធម្មជាតិ ទំនិញ ឬសេវាកម្មធនធានធម្មជាតិ ធនធានវប្បធម៌រូបវន្ត សុខភាព សោភ័ណភាព វប្បធម៌ សង្គម ឬហេតុប៉ះពាល់សេដ្ឋកិច្ចសង្គម និងរាប់បញ្ចូលផងដែរ និងរួមមានជាអាទិ៍ ហេតុប៉ះពាល់បែបនេះណាមួយទៅលើស្ត្រី ជនជាតិដើមភាគតិច ឬជនដែលងាយរងគ្រោះដទៃទៀត ។

**ផលប៉ះពាល់ខាងក្រៅ** : ផលប៉ះពាល់ជាវិជ្ជមាន និងអវិជ្ជមាននៃសកម្មភាពផ្សេងៗទៅលើអ្នកពាក់ព័ន្ធនានាដែលមិនមានការពាក់ព័ន្ធដោយផ្ទាល់នៅក្នុងសកម្មភាពទាំងនោះ ឬទៅលើធនធានធម្មជាតិ ឬបរិស្ថាន ដែលជាធម្មតា មិនចូលទៅក្នុងប្រព័ន្ធគណនេយ្យចំណាយជាស្តង់ដារឡើយ ក្នុងន័យដែលថា តម្លៃទីផ្សារនៃផលិតផលនៃសកម្មភាពទាំងនោះ មិនឆ្លុះបញ្ចាំងពីថ្លៃចំណាយ ឬផលចំណេញពេញលេញនោះទេ ។

**ការខាតបង់ខាងផ្នែកហិរញ្ញវត្ថុ** : ការបាត់បង់ប្រាក់ឈ្នួល ប្រាក់ចំណូល ប្រាក់ចំណេញ និងពន្ធ ឬប្រាក់កម្រៃសេវារដ្ឋាភិបាលដែលបាត់បង់ ដែលបណ្តាលមកពីការខូចខាតបរិស្ថាន ។

**ការនេសាទ** : ការចាប់ ការយក ឬ ការទទួលបានការកាន់កាប់ត្រីរស់ ឬធនធានទឹកសាប ឬធនធានទឹកសមុទ្រដែលមានជីវិតដទៃទៀត ការប៉ុនប៉ងចាប់ យក ឬទទួលបានការកាន់កាប់ត្រីរស់ ឬធនធានទឹកសាប ឬធនធានទឹកសមុទ្រដែលមានជីវិតដទៃទៀត សកម្មភាពដទៃផ្សេងទៀតដែលអាចរំពឹងថាជាសមហេតុផលលក្នុងការបណ្តាលឲ្យមានការចាប់ ការយក ឬ ការទទួលបានការកាន់កាប់ត្រីរស់ ឬធនធានទឹកសាប ឬធនធានទឹកសមុទ្រដែលមានជីវិតដទៃទៀត និងប្រតិបត្តិការណាមួយក្នុងការគាំទ្រ ឬការត្រៀមរៀបចំណាមួយ សម្រាប់សកម្មភាពណាមួយដែលបានរៀបរាប់ខាងលើ ។ និយមន័យនេះ មិនបានបញ្ចូលនូវសកម្មភាពស្រាវជ្រាវជាលក្ខណៈវិទ្យាសាស្ត្រណាមួយដែលបានធ្វើឡើងដោយអ្នកស្រាវជ្រាវ ឬនាវាស្រាវជ្រាវដែលមានការឯកភាពពីក្រសួង/ស្ថាប័នសមស្របណាមួយឡើយ ។

**សមាគមន៍បរទេស** : ស្ថាប័នស្របច្បាប់មួយដែលបង្កើតឡើងនៅក្រៅប្រទេស ក្នុងគោលបំណងធ្វើសកម្មភាពនានា ដើម្បីបម្រើប្រយោជន៍សាធារណៈ ដោយពុំបង្កើតប្រាក់ចំណេញ ។

**ព្រៃឈើ** : ផ្ទៃដីដែលមានទំហំលើសពី ០.៥ (សូន្យក្បៀសប្រាំ) ហិចតា ជាមួយនឹងគម្របស្រទាប់លើនៃដើមឈើធម្មជាតិដែលពុំបានដាំដោយមនុស្ស លើសពី១០ (ដប់) ភាគរយនៃផ្ទៃដីសរុប ដែលជាចម្បងមិនស្ថិតនៅក្រោមការប្រើប្រាស់ដីព្រៃកសិកម្ម ឬការប្រើប្រាស់ដីដែលមិនមែនជាដីព្រៃជាក់លាក់ផ្សេងឡើយ ។

**ផលិតផលព្រៃឈើ** : វត្ថុធាតុណាមួយដែលបានមកពីព្រៃឈើ សម្រាប់ការប្រើប្រាស់ដោយផ្ទាល់ ឬការប្រើប្រាស់ជាលក្ខណៈពាណិជ្ជកម្ម រួមមានជាអាទិ៍ ផលព្រៃឈើ និងអនុផលព្រៃឈើ និងចំណីសត្វ ។

**កម្រិតផ្គត់ផ្គង់ពេញលេញ** : កម្រិតផ្ទៃទឹកនៃទំនប់ស្តុកទឹក នៅពេលដែលការស្តុកទឹកស្ថិតនៅក្នុងកម្រិតប្រតិបត្តិការអតិបរមាមួយ ដោយគ្មានការរងការប៉ះពាល់ដោយទឹកជំនន់ ។

**តំបន់គ្រោះថ្នាក់ដោយទឹកជំនន់នាពេលអនាគតតត** : ចំណែកណាមួយនៃដីឆ្នេររបស់កម្ពុជាបច្ចុប្បន្ន ដែលមានការព្យាករណ៍ថា នឹងទទួលរងទឹកជំនន់ ដោយការកើនឡើងនីវ៉ូទឹកសមុទ្រពី ១ (មួយ)ម៉ែត្រ លើសពីនីវ៉ូនៃបន្ទាត់ឆ្នេរបច្ចុបន្ន ។

**ដែលកែច្នៃសេណេទិច** : មានសារធាតុហ្សែន (**ឌី អ៊ិន អេ**) ដែលត្រូវបានកែច្នៃក្នុងលក្ខណៈមួយដែលមិនបានកើតឡើងតាមធម្មជាតិទេ ឧទាហរណ៍ តាមរយៈការនាំចូលហ្សែនមួយ ចេញពីសារពាង្គកាយផ្សេងគ្នា ។

**ប្រព័ន្ធព័ត៌មានភូមិសាស្ត្រ** : ប្រព័ន្ធកុំព្យូទ័រដែលមានសមត្ថភាពនៃការចាប់យក ការរក្សាទុក ការវិភាគ និងការបង្ហាញព័ត៌មានអំពីភូមិសាស្ត្រដែលយោង ។

**ព័ត៌មានភូមិសាស្ត្រនៃការប្រើប្រាស់ដី** : ទិន្នន័យដែលយោងទៅលើបណ្តុំជាក់លាក់នៃកូអរឌីណេរភូមិសាស្ត្រដែលអាចប្រមូល ប្រើប្រាស់ និងបង្ហាញបាន តាមរយៈប្រើប្រាស់ប្រព័ន្ធព័ត៌មានភូមិសាស្ត្រមួយ ។ ព័ត៌មានភូមិសាស្ត្រនៃការប្រើប្រាស់ដីនៃព្រះរាជាណាចក្រកម្ពុជា រួមមានជាអាទិ៍ ព័ត៌មានអំពីប្រព័ន្ធអេកូឡូស៊ី ជីវៈចម្រុះ ធនធានធម្មជាតិ រួមមានជាអាទិ៍ ដី ទឹក និងព្រៃឈើ បរិស្ថាន មានជាអាទិ៍ គុណភាពទឹក ដី និងខ្យល់ ។ សកម្មភាពអភិវឌ្ឍន៍ មានជាអាទិ៍ កសិកម្ម ការធ្វើអាជីវកម្មរ៉ែ សម្បទានដីសេដ្ឋកិច្ច ថាមពលវារីអគ្គិសនី ហេដ្ឋារចនាសម្ព័ន្ធផ្សេងទៀត និងសហគមន៍នានា មានជាអាទិ៍ ទីតាំងរបស់ជនជាតិដើមភាគតិច និងកម្មសិទ្ធិរបស់សហគមន៍មូលដ្ឋាន ។

**ទម្លាប់អនុវត្តល្អ (ទម្លាប់អនុវត្តល្អជាអន្តរជាតិ)** : នីតិវិធីមួយដែលទទួលយក និងទទួលស្គាល់ជាអន្តរជាតិ ដែលធ្វើការបានល្អ និងនាំមកនូវលទ្ធផលល្អ ហើយត្រូវបានណែនាំក្នុងការប្រើ ជាគំរូ ។ វា គឺជាបទពិសោធន៍ជោគជ័យមួយណាដែលបានសាកល្បង និងធ្វើសុពលកម្ម ធ្វើម្តងហើយម្តងទៀត និងសាកសមនៅក្នុងការចែករំលែកទម្លាប់នេះ ទៅកាន់មនុស្សជាច្រើនទៀតអនុវត្ត ។

**ឧស្ម័នផ្ទះកញ្ចក់** : សារធាតុឧស្ម័នទាំងឡាយនៃបរិយាកាស ទាំងធម្មជាតិ និងបង្កឡើងដោយមនុស្សដែលស្រូប និងបញ្ចេញមកវិញនូវកាំរស្មីក្រហមអាំងហ្វ្រា ។

**លទ្ធកម្មសាធារណៈបៃតង** : ដំណើរការនៃលទ្ធកម្មសាធារណៈដែលប្រឹងប្រែងកាត់បន្ថយផលប៉ះពាល់ទៅលើបរិស្ថាន និងសុខភាពមនុស្ស និងព្យាយមសម្រេចឱ្យបាននូវតុល្យភាពសមស្របមួយរវាងសសរស្តម្ភទាំងបីនៃការអភិវឌ្ឍដោយចីរភាព កត្តាសេដ្ឋកិច្ច សង្គម និងបរិស្ថាន ។ កត្តាសេដ្ឋកិច្ច រួមមានតម្លៃនៃទំនិញ និងសេវាកម្មពេញវដ្តជីវិតទាំងមូលរបស់ពួកវា ដូចជាតម្លៃលើលទ្ធកម្ម ការថែរក្សា ប្រតិបត្តិការនានា និងការគ្រប់គ្រងនៅចុងគ្រារបស់វា (ដែលរួមទាំងការបោះបង់ចោលសំណល់) ដែលស្របតាមការគ្រប់គ្រងល្អផ្នែកហិរញ្ញវត្ថុ ។ កត្តាសង្គម រួមមាន យុត្តិធម៌និងសមធម៌សង្គម សុវត្ថិភាពនិងសន្តិសុខ សិទ្ធិមនុស្សនិងលក្ខខណ្ឌការងារនានា ។ កត្តាបរិស្ថាន រួមមានការបញ្ចេញខ្យល់ ដីនិងទឹក ការប្រែប្រួលអាកាសធាតុ ជីវៈចម្រុះ ការប្រើប្រាស់ធនធានធម្មជាតិ និង កង្វះខាតទឹកពេញវដ្តជីវិតទាំងមូលនៃផលិតផល ។

**ទឹកក្រោមដី** : ទឹកដែលហូរ តាមរយៈជលសីលា ឬនៅក្នុងដីដែលជោគដោយទឹក សារធាតុថ្ម កំទិចកំទី ឬល្អាងផ្សេងៗទៀតនៅក្នុងដី ។

**ជម្រក** : ទីកន្លែង ឬប្រភេទនៃទីតាំងដែលប្រភេទសត្វ ឬរុក្ខជាតិកកើតឡើងពីធម្មជាតិ ស្វែងរកកន្លែងស្នាក់នៅ ផ្តល់ចំណី និងបង្កាត់ពូជ ។

**ការយាយីរំខាន** : ធ្វើឲ្យរំខាន ធ្វើឲ្យខ្វាយខ្វល់ ធ្វើឲ្យខ្សោះ ធ្វើឲ្យអស់កម្លាំង ធ្វើឲ្យខ្មាន់ខ្មាញ់ រុកគួនឆាឆៅ លលេង ឬធ្វើទារុណកម្មលើសត្វណាមួយ ឬបើមិនដូច្នោះទេ ធ្វើឲ្យប៉ះពាល់ដល់ទង្វើជាធម្មជាតិរបស់សត្វណាមួយ កូនចៅ ឬស៊ុតទាំងឡាយរបស់វា ។ មិនរាប់បញ្ចូលនូវការបរបាញ់ ការដាក់អន្ទាក់ ឬការចាប់សត្វព្រៃស្របច្បាប់ឡើយ ។

**សារធាតុ ឬផលិតផលគ្រោះថ្នាក់** : សារធាតុសរីរាង្គ និងអសរីរាង្គនៃអត្តសញ្ញាណជាលក្ខណៈម៉ូលីគុលជាក់លាក់មួយ រួមទាំង ការរួមបញ្ចូលគ្នានៃសារធាតុទាំងឡាយបែបនេះដែលកើតឡើងទាំងមូល ឬដោយផ្នែកដែលជាលទ្ធផលមួយនៃប្រតិកម្មគីមីដែលបានដំណើការ ឬកើតឡើងនៅក្នុងធម្មជាតិ ហើយដែលសារធាតុរបស់វា រាប់ទាំង សារធាតុដែលមានជាតិពុល ដែលបង្កការឆាបឆេះ ដែលបង្កការច្រេះស៊ី  ជាសារធាតុដែលបង្កការរលាក ឬបើមិនដូច្នោះទេ បង្កគ្រោះថ្នាក់ដល់សុខភាពមនុស្ស ឬដល់បរិស្ថាន ។ សារធាតុ និងផលិតផលគ្រោះថ្នាក់ផ្សេងៗ អាចមានរូបភាពជាវត្ថុធាតុរឹង រាវ ឧស្ម័ន សំណើម ឬជាចំហាយ ។

**សំណល់គ្រោះថ្នាក់** : សំណល់ទាំងឡាយដែលស្ថិតនៅក្នុងប្រភេទសំណល់មួយ ឬច្រើនក្នុងឧបសម្ព័ន្ធទី១ នៃអនុសញ្ញាបាសែល ស្តីពីការត្រួតពិនិត្យចលនាដឹកជញ្ជូន និងការបោះបង់ចោលសំណល់គ្រោះថ្នាក់ឆ្លងដែន និងមានលក្ខណៈគ្រោះថ្នាក់មួយ ឬច្រើន នៅក្នុងឧបសម្ព័ន្ធទី៣ នៃអនុសញ្ញានោះ ។ សំណល់គ្រោះថ្នាក់ មានជាអាទិ៍ អង្គធាតុរឹង អង្គធាតុរាវ ឧស្ម័ន សារធាតុវិទ្យុសកម្ម សំណល់ជាតិផ្ទុះ សារធាតុដែលអាចឆេះ សារធាតុចម្លងមេរោគ ឬសារធាតុដែលបង្កឱ្យមានការឆាបឆេះ ច្រេះស៊ី អុកស៊ីដកម្ម ការបំពុល ជម្ងឺមហារីក ឬសារធាតុពុលផ្សេងៗទៀតដែលបង្កគ្រោះថ្នាក់ដល់សុខភាពមនុស្ស ទ្រព្យសម្បត្តិ ឬបរិស្ថាន ។  ប្រភពនៃសំណល់ ត្រូវរួមមានជាអាទិ៍ លំនៅដ្ឋាន ទីផ្សារ ផ្សារទំនើប កន្លែងកំសាន្ត អគារសាធារណៈ ស្ថាប័នអប់រំ សកម្មភាពធុរកិច្ចសាធារណៈ និងឯកជន សេវាកម្ម សិប្បកម្ម រោងចក្រ និងកន្លែងផលិតផលិតផល សកម្មភាពកសិកម្ម និងសកម្មភាពអាជីវកម្មរ៉ែ ។

**ប្រព័ន្ធតាមដានសុខភាព** : ដំណើរការនៃការបង្កើត ប្រមូល វិភាគ និងផ្លាស់ប្តូរព័ត៌មានអំពីសុខភាពដើម្បីការពារ លើកកម្ពស់ និងគាំទ្រដល់ការសម្រេចចិត្តផ្សេងៗដែលប៉ះពាល់ទៅលើសុខភាពសត្វព្រៃ មនុស្ស និងបសុសត្វ ព្រមទាំងតម្លៃសង្គមដែលពាក់ព័ន្ធផ្សេងៗរបស់ពួកគេ។

**តម្លៃអភិរក្សខ្ពស់** : ការមានតម្លៃជីវសាស្ត្រ សង្គម ឬវប្បធម៌នៃសារៈសំខាន់ដ៏ខ្ពស់បំផុត ឬសារៈសំខាន់ដ៏ស៊ីជម្រៅបំផុតមួយ ។

**ការប្រើប្រាស់ក្នុងការចិញ្ចឹមជីវិតជាលក្ខណៈគ្រួសារ** : ការបរបាញ់ ការនេសាទ ការប្រមូលរុក្ខជាតិព្រៃ និងអនុផលព្រៃឈើផ្សេងទៀត និងការដោះដូរទំនិញជាលក្ខណៈប្រពៃណី សម្រាប់គោលបំណងផ្គត់ផ្គង់ស្បៀងអាហារដល់បុគ្គលម្នាក់ ឬគ្រួសាររបស់គេ នៅក្នុងកម្រិតអប្បបរមាដែលចាំបាច់សម្រាប់ការរស់រានមានជីវិត និងមិនរាប់បញ្ចូលនូវការលក់ ឬការធ្វើពាណិជ្ជកម្មនៃសំណាកប្រភេទសត្វឬរុក្ខជាតិនានាដែលបានបរបាញ់ នេសាទ ឬប្រមូលបាន ។

**គ្រោះមហន្តរាយដែលបង្កឡើងដោយមនុស្ស** : គ្រោះមហន្តរាយទាំងនេះ រួមមាន ការបំផ្លិចបំផ្លាញទៅលើជីវិតមនុស្សនិងជីវភាពរស់នៅ សុវត្ថិភាពនិងការអប់រំ ទ្រព្យសម្បត្តិ ហេដ្ឋារចនាសម្ព័ន្ធ និងបរិស្ថាន ដោយសារតែមានចេតនា ការធ្វេសប្រហែស ឬចៃដន្យ ។ គ្រោះមហន្តរាយដែលបង្កឡើងដោយមនុស្ស មានជាអាទិ៍ គ្រោះមហន្តរាយ និងការគ្រោះថ្នាក់ពីឧស្សាហកម្ម ការខ្ចាយកំពុបកាកសំណល់គីមី ឬកាកសំណល់គ្រោះថ្នាក់ ការខ្ចាយកំពុបប្រេង ការលេចធ្លាយឧស្ម័នធម្មជាតិ គ្រោះមហន្តរាយនៅទីតាំងចោលសំរាម គ្រោះមហន្តរាយនៅទីតាំងផលិត និងស្តុកទុកថាមពល រួមមាន គ្រោះថ្នាក់នុយក្លេអែរ ការវាយប្រហារដោយអាវុធជីវសាស្ត្រ បញ្ហាអគ្គីភ័យផ្សេងៗ និងអំពើហិង្សា និងការបះបោរប្រដាប់អាវុធផ្សេងៗ ជាដើម។

**ការបរបាញ់** : រាប់បញ្ចូលទាំង ការយាយី ការចាប់ ការសម្លាប់ ការដាក់ថ្នាំបំពុល ការដេញចាប់ ការដាក់អន្ទាក់ ការបាញ់ ការដាក់អន្ទាក់ ការដាក់នុយបញ្ឆោត ការដាក់សំណាញ់ និងការជន្លសត្វព្រៃណាមួយ និងការប៉ុនប៉ងណាមួយក្នុងការពាក់ព័ន្ធក្នុងទង្វើបែបនេះ និងការធ្វើឲ្យរបួសស្នាម ការធ្វើឲ្យឈឺចាប់ ឬការបំផ្លិចបំផ្លាញ ឬការយកបំណែកណាមួយនៃសត្វ ឬកូនសត្វ រាប់ទាំង ការប្រមូលយក ការធ្វើឱ្យខូច ឬការរំខានទៅលើស៊ុត ឬសំបុករបស់សត្វ ជាដើម។

**ជនជាតិដើមភាគតិច** : ក្រុមមនុស្សដែលរស់នៅក្នុងទឹកដីនៃព្រះរាជាណាចក្រកម្ពុជា ដែលសមាជិករបស់ពួកគេ បង្ហាញឱ្យឃើញពីជាតិសាន៍ សង្គម វប្បធម៌ និងសេដ្ឋកិច្ច និងការអនុវត្តរបៀបនៃជីវិតបែបប្រពៃណី និងក្រុមមនុស្សដែលប្រើប្រាស់ដីធ្លី និងទឹកក្នុងការកាន់កាប់តាមទំនៀមទំលាប់របស់ពួកគេ យោងទៅតាមវិធានជាប្រពៃណីនានានៃការប្រើប្រាស់ជាសមូហភាព ។

**សម្បត្តិវប្បធម៌អរូបី** : សមិទ្ធផលរបស់មនុស្សដែលត្រូវបានផ្ទេរពីជំនាន់មួយទៅជំនាន់មួយទៀតតាមរយៈប្រតិបត្តិការ ការបង្ហាញ ការសំដែង ការជជែកគ្នា ឬការធ្វើអត្ថាធិបាយ និងប្រពៃណីផ្ទាល់មាត់ ដូចជារឿងនិទាន កំណាព្យ និងពាក្យប្រដៅរបស់អ្នកស្រុក ការសម្ដែងសិល្បៈ ដូចជារបាំ និងល្ខោន ការអនុវត្តក្នុងសង្គម ពិធីបុណ្យសាសនា ព្រឹត្តិការណ៍បុណ្យចំណេះដឹង និងការអនុវត្តនានាដែលពាក់ព័ន្ធទៅនឹងធម្មជាតិ និងសកលលោក និងចំណេះដឹង និងជំនាញដើម្បីបង្កើតជារបរបែបប្រពៃណី ។

**ការបញ្ចូលសារពាង្គកាយកែច្នៃរស់ទៅក្នុងបរិស្ថានដោយចេតនា** : ការប្រើប្រាស់សារពាង្គកាយកែច្នៃរស់ដោយចេតនាក្រៅពីព្រំដែនកំណត់ ដែលមានដូចជាការយកទៅដាំ ឬសាបព្រោះនៅទីស្រែចំការ ឬដក់ចូលទៅក្នុងទឹក ឬបញ្ចេញទៅក្នុងបរិយាកាស ការដាក់លក់នៅទីផ្សារ ការធ្វើអំណោយ ឬការផ្តល់ឱ្យតែពុំមែនជាសារពាង្គកាយកែច្នៃរស់ប្រើប្រាស់ក្នុងព្រំដែនកំណត់ ឬដែលនាំចូលសម្រាប់ប្រើប្រាស់ផ្ទាល់ជាមួយអាហារ ឬចំណីសត្វ ឬសម្រាប់ធ្វើការកែច្នៃទៅជាអ្វីផ្សេងទៀតឡើយ ។

**ទឹកផ្ទៃក្នុង** : ទឹកសមុទ្រដែលលាតសន្ធឹងទៅកាន់ច្រាំងសមុទ្រ ចាប់ពីខ្សែបន្ទាត់គោល ដែលបានប្រើប្រាស់ដើម្បីវាស់ព្រំដែននៃដែនសមុទ្រ ដែលព្រះរាជាណាចក្រកម្ពុជាមានសមត្ថកិច្ចពេញលេញក្នុងការគ្រប់គ្រង ។

**ការចេញវិញ្ញាបនបត្របញ្ជាក់ពីផលិតផលព្រៃឈើ និងការគ្រប់គ្រងជាអន្តរជាតិ** : វិញ្ញាបនបត្របញ្ជាក់មួយដែលធានាដល់អ្នកទិញទាំងឡាយថា ឈើបានចេញមកពីព្រៃដែលត្រូវបានវាយតម្លៃ និងចេញវិញ្ញាបនបត្របញ្ជាក់ថាផលឈើមានប្រភពមកពីព្រៃឈើដែលបានវាយតម្លៃ និងបញ្ជាក់ថាមានការគ្រប់គ្រង ស្របតាមស្តង់ដារសង្គម សេដ្ឋកិច្ច និងបរិស្ថានត្រឹមត្រូវ ។

**ទន្លេអន្តរជាតិ** : ទន្លេមួយដែលមានទីតាំងភូមិសាស្ត្រនៅក្នុងដែនដីនៃប្រទេសពីរ ឬច្រើន ។

**ពាណិជ្ជកម្មជាអន្តរជាតិ** : ការនាំចេញ ការនាំចេញបន្ត ការនាំចូល និងការនាំមកពីសមុទ្រ ។

**ប្រភេទក្រៅស្រុករាតត្បាត** : ប្រភេទសត្វ ឬរុក្ខជាតិដែលនាំមកដោយមនុស្ស ដោយចេតនា ឬអចេតនាក្តី ចេញក្រៅពីរបាយធម្មជាតិនៅអតីតកាល ឬបច្ចុប្បន្នរបស់វា ដែលមានសមត្ថភាព និង/ឬ ទំនោរក្នុងការរីករាលដាលដល់កម្រិតមួយ ដែលអាចបង្កឲ្យមានភាពគ្រោះថ្នាក់ទៅលើបរិស្ថាន សេដ្ឋកិច្ច និងសុខភាពរបស់មនុស្ស ។

**ផែនការគោលប្រើប្រាស់ដីធ្លី** : ផែនការប្រើប្រាស់ដីធ្លីដែលរៀបចំឡើងដោយអាជ្ញាធរថ្នាក់ក្រោមជាតិដែលត្រូវស្របតាមផែនការអភិវឌ្ឍន៍គោល ។

**ថ្នាំលាបដែលមានជាតិសំណ** : ថ្នាំលាប ឬសារធាតុសម្រាប់លាបលើផ្ទៃខាងលើប្រហាក់ប្រហែលគ្នាដទៃទៀត ដែលមានជាតិសំណ ឬសមាសធាតុសំណមួយចំនួន ហើយដែលបរិមាណជាតិសំណ (គណនាជាលោហៈសំណ) គឺលើសពី ៩០ភាគនៃមួយលានឯកត្តាដោយទម្ងន់នៃបរិមាណថ្នាំលាបដែលមិនឡើងចុះ ឬទម្ងន់នៃហ្វីលថ្នាំលាបស្ងួត ។

**ការអភិវឌ្ឍជីវភាពរស់នៅរបស់សហគមន៍មូលដ្ឋាន** : ទាក់ទងទៅនឹងការគ្រប់គ្រងប្រព័ន្ធតំបន់ការពារជាតិ សំដៅដល់ការធានាឲ្យមានការទទួលស្គាល់ដ៏ត្រឹមត្រូវពីសិទ្ធិជាប្រពៃណីទៅលើការប្រើប្រាស់ធនធានធម្មជាតិដែលមិនបម្រើឱ្យគោលបំណងពាណិជ្ជកម្ម និងការកាន់កាប់របស់សហគមន៍មូលដ្ឋាន និងសហគមន៍ជនជាតិដើមភាគតិច និងការពិចារណាអំពីលក្ខខណ្ឌតម្រូវនៃជីវភាពដោយចីរភាពរបស់សហគមន៍មូលដ្ឋាន និងសហគមន៍ជនជាតិដើមភាគតិចដែលជីវភាពរបស់គេមតភ្ជាប់ទៅនឹង និងពឹងផ្អែកទៅលើតំបន់ទាំងនេះ ព្រមទាំងធនធានធម្មជាតិទាំងឡាយរបស់ពួកគេដើម្បីធ្វើការថែរក្សា និងបង្កើនឲ្យកាន់តែប្រសើរឡើងនូវសិទ្ធិជាប្រពៃណី និងជីវភាពរបស់ពួកគេក្នុងលក្ខណៈមួយស្របតាមចីរភាពរយៈពេលវែងនៃការអភិរក្ស និងតម្លៃសេវាកម្មប្រព័ន្ធអេកូឡូស៊ីនៃតំបន់ទាំងនោះ ។

**សារពាង្គកាយកែច្នៃរស់** : អង្គជីវៈចម្រុះទាំងឡាយណាដែលមានសមត្ថភាពក្នុងការផ្ទេរ ឬផលិតឡើងវិញនូវសារធាតុសេនេទិច រួមទាំងសារពាង្គកាយដែលមិនអាចបន្តពូជបាន វីរុស និងវីរូអ៊ីត ។

**សហគមន៍មូលដ្ឋាន** : ក្រុមមនុស្សមួយក្រុម ក្នុងចំនួនណាមួយក៏បាន ដែលមានសមាជិករស់នៅ និងមានអន្តរកម្មជាមួយគ្នាក្នុងទីកន្លែងជាកលាក់ ចែករំលែកជាមួយគ្នានូវបរិស្ថានធម្មជាតិ និង/ឬ បរិស្ថានដែលបង្កើតឡើង និងដែលមានបុគ្គលិកលក្ខណៈដោយផ្អែកលើក្រុមសង្គមរបស់ពួកគេ ផលប្រយោជន៍រួម និង/ឬ បេតិភណ្ឌវប្បធម៌ និងប្រវត្តិសាស្ត្ររួម ។

**អេកូទេសចរណ៍ដែលមានផលប៉ះពាល់តិច** : ការគ្រប់គ្រងអេកូទេសចរណ៍ដែលធានាថា សកម្មភាពនានា កាត់បន្ថយផលប៉ះពាល់ទៅលើសត្វ និងរុក្ខជាតិព្រៃ ផ្លូវទឹក គុណភាពដី និងការប្រើប្រាស់ដីធ្លីដែលមាន មិនបង្កឱ្យមានការបាត់បង់សុទ្ធនៃសារពើរុក្ខជាតិ ផ្តល់ជូននូវសេវាកម្មដោយពុំមានការសាងសង់ហេដ្ឋារចនាសម្ព័ន្ធ មានផលប៉ះពាល់ដែលអាចមើលឃើញតិចតួចទៅលើទីតាំង និងដែលតំបន់ដែលនៅជុំវិញ និងមានផលប៉ះពាល់ជាអាវិជ្ជមានតិចតួចទៅលើបរិស្ថាន និងសង្គមទៅលើទីតាំងផ្សេង ។

**អាជ្ញាធរគ្រប់គ្រង** : អង្គភាពដែលផ្តល់អំណាចដោយរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា យោងទៅតាមអនុសញ្ញាស្តីពីពាណិជ្ជកម្មអន្តរជាតិ លើប្រភេទសត្វ និងរុក្ខជាតិព្រៃដែលកំពុងរងគ្រោះថ្នាក់នៅក្នុងការផ្តល់លិខិតអនុញ្ញាត និងវិញ្ញាបនបត្រសម្រាប់ពាណិជ្ជកម្មអន្តរជាតិលើប្រភេទដែលមាននៅក្នុងឧបសម្ព័ន្ធនៃអនុសញ្ញានេះ ។

**ទឹកសមុទ្រ** : ទឹកទាំងឡាយដែលមាន ឬភ្ជាប់ទៅនឹងមហាសមុទ្រ ដែលមានកម្រិតជាតិប្រៃអាចតាមដានបាន និងបង្ហាញពីភាពឡើងចុះនៃជំនោរទឹកជាប្រចាំថ្ងៃ។

**មធ្យោបាយដឹកជញ្ជូន** : យានយន្តណាមួយដែលបានប្រើប្រាស់សម្រាប់ការធ្វើដំណើរ ឬចលនានៃទំនិញផ្សេងៗ ដែលមានជាអាទិ៍ ម៉ូតូ កង់ ត្រាក់ទ័រ ឡានតូច រទេះ ឡានដឹកជញ្ជូន ទូក កប៉ាល់ ឬប្រភេទយានយន្តដទៃទៀត ។

**ប្រតិបត្តិការធនធានរ៉ែ** :ប្រតិបត្តិការណាមួយដែលរួមមានការធ្វើសកម្មភាព បុរេសេនា ស្វែងរុករក ឬអាជីវកម្មធនធានរ៉ែ ។

**ជីវបច្ចេកវិទ្យាទំនើប** : ការអនុវត្តនូវ :

ក- បច្ចេកទេសអាស៊ីតនុក្លេអ៊ិកអាំងវីត្រូ រួមមានការប្រមូលផ្តុំអាស៊ីតឌីអុកស៊ីរីបូនុយក្លេអ៊ិក និងការចាក់អាស៊ីតនុយក្លេអ៊ិកដោយផ្ទាល់ទៅក្នុងកោសិកា ឬសរីរាង្គ ។

ខ- ការរលាយចូលគ្នានៃកោសិកាដែលមិនមែនជាគ្រួសារតែមួយ ដែលមានលទ្ធភាពយកឈ្នះនូវការផលិតឡើងវិញតាមលក្ខណៈរូបសាស្ត្រធម្មជាតិ ឬជាឧបសគ្គដល់ការផ្តុំបញ្ចូលឡើងវិញ ហើយក៏មិនមែនជាបច្ចេកទេសប្រើប្រាស់នៅក្នុងការបង្កាត់ពូជ ឬការជ្រើសរើសតាមរបៀបបុរាណ ។

**ប្រភេទក្នុងស្រុក** : ប្រភេទសត្វ/រុក្ខជាតិទាំងឡាយណា ដែលបានរស់ ឬនៅតែរស់ ឬមានផ្នែកណាមួយនៃរបាយរបស់វា ឬការផ្លាស់ទីជាប្រចាំនៅក្នុងតំបន់ភូមិសាស្ត្រនៃប្រទេសកម្ពុជា និងមិនមែនជាលទ្ធផលនៃការនាំចូលមកថ្មីទេ ទោះជាមានចេតនា ឬមិនមានចេតនាក៏ដោយ។

**គ្រោះមហន្តរាយធម្មជាតិ** : គ្រោះមហន្តរាយទាំងនេះ រួមមាន ការបំផ្លិចបំផ្លាញដល់ជីវិត និងទ្រព្យសម្បត្តិ ជីវភាព ហេដ្ឋារចនាសម្ព័ន្ធ សុវត្ថិភាព ការអប់រំ និងសុខភាពរបស់បរិស្ថានដោយសារតែការប្រែប្រួលអាកាសធាតុ និងឧប្បត្តិហេតុធម្មជាតិដទៃទៀត មានជាអាទិ៍បញ្ហាអគ្គីភ័យ ការរអិលដី ខ្យល់ព្យុះ ទឹកជំនន់ រន្ទះបាញ់ ភាពរាំងស្ងួត រញ្ជួយផែនដី ព្យុះស៊ូណាមិ ផ្ទាំងទឹកកក រលកកំដៅ ឬរលកត្រជាក់ ការផ្ទុះភ្នំភ្លើង ការបាក់ច្រោះដីមាត់ច្រាំង មាត់សមុទ្រ គ្រោះថ្នាក់ក្នុងលំហ សមុទ្រ ការខូចខាតទៅលើដំណាំផ្សេងៗដែលបណ្តាលមកពីថ្នាំសម្លាប់សត្វល្អិត ឬជម្ងឺរុក្ខជាតិ ផ្សេងៗ គ្រោះទុរភិក្ស និងការផ្ទុះឡើងនូវជម្ងឺឆ្លងរបស់មនុស្ស ឬជម្ងឺឆ្លងរបស់សត្វផ្សេងៗ ។ គ្រោះមហន្តរាយធម្មជាតិ សម្រាប់គោលបំណងនៃជំពូកនេះ ត្រូវបញ្ចូលផងដែរនូវគ្រោះថ្នាក់ដទៃណាមួយដែលបានកំណត់ថាជាគ្រោះមហន្តរាយធម្មជាតិមួយ ដោយគណកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ ។

**បេតិកភណ្ឌធម្មជាតិ** : វត្ថុនិទស្សន៍ទាំងឡាយនៅលើដី និង/ឬ នៅក្នុងទឹកដែលក្នុងនោះមានការកកើតលក្ខណៈរូបសាស្ត្រ និងជីវសាស្ត្រ ឬក្រុមនៃការកកើតទាំងនេះ កកើតលក្ខណៈភូគព្ភសាស្ត្រ និងតំបន់នានាដែលបានរៀបរាប់យ៉ាងច្បាស់ដែលបង្កើតជាជម្រកប្រភេទសត្វ និងរុក្ខជាតិដែលរងការគំរាម

កំហែង និងទីតាំងធម្មជាតិផ្សេងទៀត ឬតំបន់នានាដែលបានរៀបរាប់យ៉ាងច្បាស់ ដែលអ្នកវិទ្យាសាស្ត្រយល់ឃើញថា មានតម្លៃជាសកលល្អជាទីបំផុតចំពោះការអភិរក្ស និងសម្ផស្សធម្មជាតិ ។

**តំបន់ការពារធម្មជាតិ** : តំបន់មួយដែលត្រូវមានការអភិរក្សជាពិសេស ប្រព័ន្ធអេកូឡូស៊ី និងសារៈសំខាន់សម្រាប់ជីវភាពរស់នៅ ដែលត្រូវបានកំណត់ជាពិសេសដោយច្បាប់ និងជាកម្មវត្ថុនៃការដាក់កំហិតក្នុងការប្រើប្រាស់ និងការរៀបចំគ្រប់គ្រងជាក់លាក់ ដើម្បីថែរក្សា និងលើកកម្ពស់តម្លៃនៃជីវៈចម្រុះ និងធនធានធម្មជាតិ ប្រព័ន្ធអេកូឡូស៊ី និងជីវភាពរស់នៅ ។

**ធនធានធម្មជាតិ :** សមាសធាតុដែលមានជីវិត និងឥតជីវិតទាំងអស់នៃបរិស្ថាន ដែលផ្តល់លំហូរនៃទំនិញ និងសេវាកម្មដែលមានតម្លៃ ដល់ប្រជាពលរដ្ឋ ។

**យន្តការទូទាត់ថាមពលអគ្គិសនី :** យន្តការនៃការចេញវិក្កយបត្រដែលផ្តល់ឥណទានដល់ម្ចាស់ប្រព័ន្ធថាមពលពន្លឺព្រះអាទិត្យ សម្រាប់ថាមពលអគ្គិសនីដែលគេបន្ថែមទៅលើបណ្តាញថាមពលអគ្គិសនី។ វាអនុញ្ញាតឲ្យអ្នកប្រើប្រាស់ដែលផលិតថាមពលអគ្គិសនីរបស់ខ្លួនខ្លះ ឬទាំងអស់ ដើម្បីប្រើប្រាស់ថាមពលអគ្គិសនីនោះនៅពេលណាក៏បាន ជំនួសឲ្យតែនៅពេលដែលថាមពលនោះ ត្រូវបានផលិតតែប៉ុណ្ណោះ ។

**បរិមាណទឹកដែលបានកំណត់ :** ដូចមានចែងអំពីការបែងចែកទឹក គឺជាចំនួនទឹកអតិបរមា ដែលអាចយកបានក្នុងអំឡុងពេលជាក់លាក់មួយ ឬក្នុងកាលៈទេសៈជាក់លាក់មួយ ដោយអនុលោមទៅតាមវិធាននៃការចែកចាយទឹក ដែលបានបង្កើតឡើងដោយផែនការធនធានទឹកអាងទន្លេ ដែលអនុវត្តទៅលើសិទ្ធិទទួលបានទឹក ។

**ប្រភពអចល័ត** : ទាក់ទងនឹងការបំពុលទឹក គឺជាប្រភពនៃការបំពុលដែលមិនអាចសន្មតបានដោយងាយស្រួលទៅលើទីតាំងបញ្ចេញចោល និងជាញឹកញយ បង្ករឡើងទៅលើទីតាំងដ៏ធំមួយ រួមមាន ទឹកដែលហូរចេញពីតំបន់កសិកម្ម និងតំបន់ទីប្រជុំជន ។

**ប្រភេទសត្វ និងរុក្ខជាតិដែលមិនមានដើមកំណើតនៅប្រទេសកម្ពុជា :** ប្រភេទសត្វ រុក្ខជាតិណាមួយដែលមិនមានដើមកំណើតដំបូងនៅប្រទេសកម្ពុជាទេ ប៉ុន្តែបាននាំមកដោយមនុស្ស ទោះជាដោយចៃដន្យ ឬដោយមានចេតនាក៏ដោយ រួមមាន សត្វព្រៃដែលរស់ និងស្លាប់ ព្រមទាំងផ្នែកផ្សេងៗរបស់សត្វព្រៃ និងរុក្ខជាតិទាំងឡាយដែលត្រូវបានប្រមែប្រមូលមក(ឧទាហរណ៍: រុក្ខជាតិ និងសត្វព្រៃដែលគេបានធ្វើការជួញដូរ ព្រមទាំងផលិតផលរបស់វា) ។

**អនុផលព្រៃឈើ :** ផលិតផល ឬសេវាកម្មណាមួយ ក្រៅពីឈើអារដែលត្រូវបានផលិតនៅក្នុងព្រៃ រួមមានជាអាទិ៍ ផ្លែឈើ និងគ្រាប់ផ្លែឈើ បន្លែ ពពួកផ្សិត ត្រី និងសត្វដែលគេបរបាញ់បាន រុក្ខជាតិដែល

ប្រើជាឱសថ ជ័រឈើ ខ្លឹម និងសម្បកឈើ និងសសៃឈើមួយចំនួន ដែលមាន ជាអាទិ៍ឫស្សី ផ្តៅ និង ពពួកតាលព្រឹក្ស និងស្មៅមួយចំនួនផ្សេងទៀត ។

**ប្រតិបត្តិករ :** នៅក្នុងបរិបទនៃជីវសុវត្ថិភាព សំដៅដល់បុគ្គលណាមួយដែលជាប់ពាក់ព័ន្ធដោយផ្ទាល់ ឬប្រយោលទៅនឹងសារពាង្គកាយកែច្នៃរស់ រួមមានអ្នកកាន់លិខិតអនុញ្ញាត អ្នកលក់សារពាង្គកាយកែច្នៃរស់នៅក្នុងទីផ្សារ អ្នកអភិវឌ្ឍ អ្នកផលិត អ្នកផ្តល់ការជូនដំណឹង អ្នកនាំចេញ អ្នកនាំចូល អ្នកចែកចាយ ឬអ្នកផ្គត់ផ្គង់ ។

**សារពាង្គកាយ :** ប្រព័ន្ធមានជីវិតដាច់ពីគ្នាមួយ មានជាអាទិ៍ សត្វ រុក្ខជាតិ អម្បូរផ្សិត ឬសារពាង្គកាយតូចៗ ។

**ថ្នាំលាប :** ការលាយបញ្ចូលគ្នានៃជ័រឈើដែលងាយឆាបឆេះ ជាតិពណ៌ សារធាតុបន្ថែម សារធាតុរំលាយ និងសារធាតុបន្ថែមដទៃទៀតដែលមានលក្ខណៈអម្បូរតែមួយដែលបង្កើតនូវផលិតផលសម្រេចមួយ រាប់ទាំង ថ្នាំលាបវានីស ម្រ័ក្សណ៍ខ្មុក ថ្នាំលាយ ថ្នាំលាបការពារ ថ្នាំលបឲ្យរលោង ថ្នាំទ្រនាប់ សម្ភារៈលាបលើផ្ទៃរាបប្រហាក់ប្រហែលដទៃទៀតដែលគេប្រើសម្រាប់គោលបំណងណាមួយ ។

**ការបង់ថ្លៃសម្រាប់សេវាកម្មប្រព័ន្ធអេកូឡូស៊ី :** យន្តការដែលអ្នកប្រើប្រាស់ និងអ្នកទទួលផលពីសេវាកម្មប្រព័ន្ធអេកូឡូស៊ី ធ្វើការទូទាត់សំណងដោយការជួយជាសកម្មភាពគ្រប់គ្រងមួយចំនួន រួមមានជាអាទិ៍ ការផ្គត់ផ្គង់ ការថែរក្សា ការស្តារឡើងវិញ ឬការលើកម្ពស់ ដើម្បីបង្កើតបាននូវសេវាកម្មប្រព័ន្ធអេកូឡូស៊ី ។

**សូចនករកាងារ :** ទាក់ទងទៅនឹងការគ្រប់គ្រងធនធានទឹកតាមអាងទន្លេ គឺជាការវាស់វែងដែលអាចត្រូវបានគណនា ដើម្បីធ្វើការវាយតម្លៃពីផលប៉ះពាល់នៃការសម្រេចចិត្តលើការបែងចែក និងការគ្រប់គ្រង ឬសំណើ ស្តីពីសិទ្ធិទទួលបានទឹក និងប្រព័ន្ធអេកូឡូស៊ីធម្មជាតិផ្សេងៗ ។

**បុគ្គល :** រូបវន្តបុគ្គល ឬនីតិបុគ្គល ។

**ចម្ការព្រៃឈើ :** ព្រៃផ្តល់ផល ជាបឋមមានប្រភេទពូជឈើតែមួយប្រភេទ ឬប្រភេទពូជឈើពី ឬបីប្រភេទតែប៉ុណ្ណោះ ជាញឹកញយ មានតិចតួចជាប្រភេទពូជឈើដែលមិនដុះនៅពីក្រោមគេ ត្រូវបានបង្កើតឡើងដោយប្រើគ្រាប់ពូជសិប្បនិម្មិត ហើយជាទូទៅត្រូវបានគ្រប់គ្រងដោយលក្ខណៈវិលជុំដែលមានរយៈពេលខ្លី ។

**ប្រភពជាក់លាក់ :** ប្រភពនៃការបញ្ចេញចោលទឹកដែលពុលតែមួយប្រភព ដែលអាចកំណត់បានណាមួយ ទៅលើប្រភពទឹកលើដី ឬធនធានក្រោមដីមួយ មានជាអាទិ៍ បំពង់បង្ហូរ លេណដ្ឋាន ប្រលាយ លូ ឬអាងស្តុកទឹកលើដី ដែលអាចមកពីសកម្មភាពទាំងឡាយ រួមទាំង អាងប្រព្រឹត្តកម្មទឹកលូ ប្រតិបត្តិនៃ

ការផលិត សណ្ឋាគារ មន្ទីរពេទ្យ ទីតាំងចាក់សម្រាម កសិដ្ឋានចិញ្ចឹមត្រី ឬសត្វសន្តាន ហាងបោះពុម្ព និងសកម្មភាពសំណង់ ។

**ប្រព័ន្ធស្តីពីសារធាតុបំពុលដែលសាយភាយ និងផ្លាស់ទី** : ជាប្រព័ន្ធគ្រប់គ្រងទិន្នន័យ ឬសន្និធិ ដែលសាធារណជនអាចស្វែងរកបាន អំពីសារធាតុគីមី ឬសារធាតុពុលផ្សេងៗដែលត្រូវបានគេបញ្ចេញទៅក្នុងខ្យល់អាកាស ទឹក ដី និងទីតាំងដែលគេបញ្ជូនចេញ សម្រាប់ប្រព្រឹត្តកម្ម។

**ក្រុមអាទិភាព** : ក្នុងបរិបទនៃការគ្រប់គ្រងធនធានទឹក សម្រាប់ការបែងចែកទឹកដែលបានគ្រប់គ្រងក្រោមអាជ្ញាប័ណ្ណប្រតិបត្តិការធនធានមួយ មានន័យថា ការបែងចែកទាំងឡាយដែលមានគោលដៅសន្តិសុខនៃការបែងចែកទឹកដូចគ្នា។

**ការរក្សាទុកជាលក្ខណៈឯកជន** : ការរក្សាទុកសត្វព្រៃនៅក្នុងទីបង្ខាំងមួយដែលមិនបានបើកចំហរដល់សាធារណជន ហើយជាធម្មតា គឺមិនមែនសម្រាប់គោលបំណងនៃការអភិរក្សជាចម្បងនោះទេ។

**អាវុធ និងឧបករណ៍បរបាញ់ដែលហាមឃាត់** : រួមមានជាអាទិ៍ អន្ទាក់ អង្គប់ និងឧបករន៍ផ្សេងទៀតដែលចាប់យកសត្វព្រៃដោយមិនរើសមុខ ខ្សែ ប្រហ៊ាំងកង់ ឬម៉ូតូ គ្រឿងផ្ទុះ គ្រាប់រំសេវ ថ្នាំពុល និងសារធាតុគីមីដទៃទៀតរួមមានថ្នាំសំលាប់សត្វល្អិត សំណាញ់ ខ្សែសន្ទូច នុយដែលប្រើប្រាស់នៅលើដី ការថតចម្លងសំឡេង ឬគ្រឿងទាក់ចិត្តដទៃទៀត កំបោរ ឬការចាប់បក្សី និងឧបករណ៍ឆក់ ។

**គម្រោង** : សកម្មភាព កម្មវិធី ធុរកិច្ច សេវាកម្ម ឬការប្រព្រឹត្តផ្សេងទៀតណាមួយ ជាសាធារណៈ ឬឯកជន ដែលការបំពេញសកម្មភាពទាំងនោះ តម្រូវឱ្យមានលិខិតអនុញ្ញាត ឬការឯកភាព ឬមិនដូច្នោះទេ គ្រប់គ្រងដោយរដ្ឋាភិបាល ។

**ម្ចាស់គម្រោង** : រូបវន្តបុគ្គល ឬនីតិបុគ្គលណាម្នាក់ ដែលដាក់ពាក្យស្នើសុំ បង្កើត ផ្តល់ហិរញ្ញប្បទាន ឬផ្តល់ជំនួយជាសម្ភារៈ សម្រាប់ការអនុវត្តគម្រោងអភិវឌ្ឍន៍របស់រដ្ឋ ឬឯកជនមួយដែលអាចបង្កឱ្យមានផលប៉ះពាល់ផ្សេងៗទៅលើបរិស្ថាន សុខភាព សង្គម សេដ្ឋកិច្ច និងវប្បធម៌។

**យន្តការរេដបូក (REDD+)** : ការកាត់បន្ថយការបញ្ចេញឧស្ម័នពីការបាត់បង់ និងការរេចរឹលព្រៃឈើ (រេដ) គឺជាយន្តការមួយ ដែលបានបង្កើតឡើងដោយអនុសញ្ញាក្របខណ្ឌអង្គការសហប្រជាជាតិ ស្តីពីការប្រែប្រួលអាកាសធាតុ(UNFCCC) ដោយមានគោលដៅក្នុងការបន្ថយការប្រែប្រួលអាកាសធាតុតាមរយៈការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ តាមរយៈការលើកកម្ពស់ការគ្រប់គ្រងព្រៃឈើប្រកបដោយចីរភាព ការអភិរក្ស និងការលើកកម្ពស់កាបូនស្តុកព្រៃឈើ និងការកាត់បន្ថយការបម្លែងព្រៃឈើ និងការបាត់បង់ព្រៃឈើនៅក្នុងប្រទេសដែលកំពុងអភិវឌ្ឍ ។ យន្តការរេដបូកមានដំណើរការលើសពីអ្វីដែលបានលើកឡើងខាងលើនេះ ដើម្បីដាក់បញ្ចូលនូវតួនាទីនៃការអភិរក្ស ការគ្រប់គ្រងព្រៃឈើប្រកបដោយចីរភាព និងការលើកកម្ពស់កាបូនស្តុកព្រៃឈើផ្សេងៗ ។

**ការដាំព្រៃឈើឡើងវិញ** : ការដាំដើមឈើទាំងឡាយនៅលើដីដែលព្រៃឈើត្រូវបានកាប់បំផ្លាញ ក្នុងរយៈពេល ៥០ (ហាសិប) ឆ្នាំ ឬមានតាំងពីយូរលង់ណាស់មកហើយ ។

**ការស្តារឡើងវិញ** : សកម្មភាពមួយ ឬបណ្តុំនៃសកម្មភាពផ្សេងៗជាច្រើនដែលបានដំណើរការដើម្បីដាក់ត្រលប់មកវិញនូវទិដ្ឋភាពទាំងស្រុងមួយដែលបានបាត់បង់ដោយសារការខូចខាត តាមរយៈការធ្វើឱ្យមានសម្បទាឡើងវិញ ការលើកកម្ពស់ ការដាក់ជំនួស ការកសាងឡើងវិញ ដោយសារតែវាក្យស័ព្ទនេះ ត្រូវបានប្រើប្រាស់ជាទូទៅ ឬជាការទទួលបាន និងការការពារដែលគ្រប់គ្រាន់ដើម្បីទូទាត់សងវិញចំពោះការបាត់បង់ទាំងអស់នៃការខូចខាត នាពេលកន្លងទៅ ។

**ការបញ្ចេញ** : ទាក់ទងទៅនឹងឧស្សាហកម្មនិស្សារណកម្ម គឺជាការបញ្ចេញ ការកំពប់ខ្ចាយ

ការបំភាយ ការលេចធ្លាយ ការបូម ការដាក់បញ្ចូល ការដាក់ទុកមួយរយៈ ការបញ្ចេញចោល ការចាក់ចេញឲ្យអស់ ការចាក់ចោល ការរសាត់ចេញ ការហៀរចេញ ឬការជ្រាបចេញណាមួយទៅក្នុងបរិស្ថាន ទោះជាដោយចេតនា ឬដោយអចេតនាក៏ដោយ ។

**មជ្ឈមណ្ឌលសង្គ្រោះ** : ទីតាំងមួយដែលមានគោលបំណង : ធ្វើឱ្យសត្វព្រៃដែលរងរបួសមានសម្បទាឡើងវិញ និងលែងសត្វព្រៃនោះទៅកាន់ព្រៃវិញ នៅពេលដែលពួកវាមានសុខភាពល្អ ទទួលសត្វព្រៃដែលរឹមអូសបាន និងថែទាំពួកវា រហូតដល់ពេលមួយដែលពួកវាអាចនាំទៅកាន់កន្លែងដើមរបស់វា ឬអាចលែងបាន ផ្តល់ការថែទាំសត្វព្រៃរយៈពេលវែងដែលមិនអាចបញ្ជូនសត្វព្រៃត្រលប់ទៅព្រៃវិញ និងអនុវត្តការបង្កាត់ពូជសត្វបង្ខាំងទុកសម្រាប់គោលបំណងអភិរក្ស ។

**វិធានការឆ្លើយតប** : នៅក្នុងបរិបទនៃជីវសុវត្ថិភាព គឺជាចំណាត់ការសមស្របទាំងឡាយដើម្បី ៖

ក- ទប់ស្កាត់ កាត់បន្ថយជាអប្បបរមា ទប់ទល់ កាត់បន្ថយ ឬបញ្ចៀសការខូចខាត ដែលសមស្រប ។

ខ- ស្តារឡើងវិញនូវជីវៈចម្រុះតាមរយៈចំណាត់ការនានាដែលត្រូវអនុវត្តតាមការបញ្ជា ដូចខាងក្រោម ៖

១- ការស្តារឡើងវិញនូវជីវៈចម្រុះទៅកាន់លក្ខខណ្ឌដែលមាន មុនពេលមានការខូចខាតកើតឡើង

២- ការស្តារឡើងវិញដោយការដាក់ជំនួសការបាត់បង់នៃជីវៈចម្រុះ ដោយសមាសធាតុនៃជីវៈចម្រុះសម្រាប់ប្រភេទនៃការប្រើប្រាស់ដូចគ្នា ឬដទៃទៀត ដែលសមស្រប នៅក្នុងទីតាំងដដែល ឬទីតាំងដែលជាជម្រើស ។

**មូលនិធិបរធនបាលកិច្ចដែលអាចដកបាន** : មូលនិធិបរធនបាលកិច្ច ដែលអាចមានការកែប្រែទៅលើគោលបំណង និងរយៈពេល ដោយមានការអនុញ្ញាតពីនិយ័តករដែលពាក់ព័ន្ធ និងដោយមានការជូនដំណឹងទៅកាន់ក្រសួងសេដ្ឋកិច្ច និងហរញ្ញវត្ថុ ។

**អាងទន្លេ** : តំបន់ភូមិសាស្ត្រមួយដែលបានកំណត់តាមរយៈដែនកម្រិតនៃទីជម្រាលនៃប្រព័ន្ធទឹកផ្សេងៗ រួមមាន ទឹកលើដី និងទឹកក្រោមដី ។

**ឯកសារព័ត៌មានអំពីសុវត្ថិភាព** : ឯកសារមួយដែលមានព័ត៌មានអំពីភាពអាចបង្កគ្រោះថ្នាក់ (សុខភាព អគ្គិភ័យ ប្រតិកម្ម ឬបរិស្ថាន) នៃផលិតផលគីមី និងអំពីរបៀបដើម្បីធ្វើការប្រកបដោយសុវត្ថិភាពជាមួយនឹងផលិតផលគីមី ។

**អាជ្ញាធរវិទ្យាសាស្ត្រ** : អង្គភាពដែលផ្តល់អំណាចដោយរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា យោងទៅតាមអនុសញ្ញាស្តីពីពាណិជ្ជកម្មអន្តរជាតិលើប្រភេទសត្វ និងរុក្ខជាតិព្រៃដែលកំពុងរងគ្រោះថ្នាក់ ដើម្បីផ្តល់ជាយោបល់ទៅឱ្យអាជ្ញាធរគ្រប់គ្រង ថាតើការនាំចេញនៃសំណាកទាំងឡាយ នឹងបង្កគ្រោះថ្នាក់ដល់ការរស់រានមានជីវិតនៃប្រភេទនៅក្នុងព្រៃ និងបញ្ហាវិទ្យាសាស្ត្រផ្សេងទៀត ពាក់ព័ន្ធនឹងពាណិជ្ជកម្មអន្តរជាតិលើប្រភេទសត្វ និងរុក្ខជាតិព្រៃដែលមាននៅក្នុងឧបសម្ព័ន្ធនៃអនុសញ្ញានេះ ។

**បរធនបាលទាយក** : រូបវន្តបុគ្គល ឬនីតិបុគ្គលដែលបង្កើតនូវគោលបំណងផ្សេងៗ និងលក្ខខណ្ឌមួយចំនួនអំពីមូលនិធិបរធនបាលកិច្ចមួយ និងផ្តល់មូលនិធិដំបូងមួយចំនួន សម្រាប់មូលនិធិបរធនបាលកិច្ចនេះ ។

**ខ្សែឆ្នេរ** : ព្រំប្រទល់ រវាងដី និងទឹកនៅកម្ពស់ជាមធ្យមនៃទឹកជំនោរដែលខ្ពស់ជាងគេជាប្រចាំថ្ងៃនៅតាមមាត់ច្រាំងដីដែលជាប់ទៅនឹងទឹកដោយមានកម្រិតនៃជាតិប្រៃដែលអាចតាមដានបានណាមួយ។ សមមូលទៅនឹងពាក្យនេះថា ទឹកខ្ពស់ដែលឡើងខ្ពស់ជាមធ្យម ដូចដែលគេប្រើនៅក្នុងប្រទេសដទៃទៀត ។

**ឆ្នេរ** : ដីដែលគ្របដណ្តប់ដោយខ្សាច់ ដី ឬថ្ម និងមានភាពទេរទៅរកទឹកនៅក្នុងផ្ទៃទឹក

ដែលម្តងម្កាល ត្រូវបានជន់លិចដោយផ្ទៃទឹកនោះ ។

**ការខូចខាតជាសក្តានុពល** : ដីដែលនៅក្នុងបរិបទនៃជីវសុវត្ថិភាព សំដៅលើការផ្លាស់ប្តូររយៈពេលវែង ឬអចិន្ត្រៃយ៍ ដែលរួមមានផលប៉ះពាល់ជាអវិជ្ជមានទៅលើសុខភាពមនុស្ស ដែលបង្កឡើងដោយសារពាង្គកាយកែច្នៃរស់ ដែលនឹងត្រូវសងសំណងតាមរយៈការបានមកវិញនូវលក្ខណៈធម្មជាតិ នៅក្នុងពេលវេលាសមរម្យមួយ ។ ការខូចខាតជាសក្តានុពុល ត្រូវកំណត់ដោយទំហំនៃការផ្លាស់ប្តូរបែបគុណភាព និងបរិមាណដែលមានផលប៉ះពាល់ជាអវិជ្ជមានដល់ជីវៈចម្រុះ ដែលរួមមានការកាត់បន្ថយសម្ថភាពនៃធនធានធម្មជាតិក្នុងការផ្តល់ជូននូវទំនិញ និងសេវាកម្មនានា ។

**វុក្ខវប្បកម្ម** : ទម្លាប់អនុវត្តនៃការគ្រប់គ្រងលើការបង្កើត ការដាំដុះ សមាសភាព សុខភាព និងគុណភាពនៃព្រៃឈើ និងដីព្រៃឈើផ្សេងៗ ដើម្បីបំពេញគោលបំណងដែលបានកំណត់រួចហើយ ។

**សំណល់រឹង** : សំណល់ទាំងឡាយ មានជាអាទិ៍ វត្ថុរឹង សារធាតុរឹង ផលិតផល ឬកំទេចកំទី សម្ភារៈដែលលែងត្រូវការប្រើប្រាស់ ដោយគ្មានការទាញយកធនធានទៀតទេ ហើយដែលត្រូវបានគេបោះបង់ចោល មានបំណងនឹងបោះបង់ចោល ឬតម្រូវឱ្យបោះបង់ចោល ។ សំណល់រឹង អាចជាអាទិ៍ សំណល់ដែលមានទម្រង់រឹង ឬសំណល់ដែលមានលក្ខណៈខាប់ ដូចជាសំណល់ភក់ជាដើម ។ ប្រភពនៃសំណល់ទាំងនេះ ត្រូវរួមមានជាអាទិ៍ លំនៅស្ថាន ទីផ្សារ ផ្សារទំនើប កន្លែងកំសាន្ត អាគារសាធារណៈគ្រឹះស្ថានអប់រំ សកម្មភាពពាណិជ្ជកម្មសាធារណៈ ឬឯកជន សេវាកម្មន សិប្បកម្ម រោងចក្រ និងកន្លែងផលិត សកម្មភាពកសិកម្ម និងសកម្មភាពអាជីវកម្មរ៉ែ ។

**ប្រភេទ** : សារពាង្គកាយរស់មួយក្រុម ដែលមានលក្ខណៈប្រហាក់ប្រហែលគ្នា និងមានសមត្ថភាពនៃការបង្កាត់ពូជជាមួយគ្នាបាន ដើម្បីបង្កើតកូនចៅដែលអាចរស់រានមានជីវិតបាន ។

**សំណាក** : សត្វ ឬរុក្ខជាតិណាមួយ រស់ ឬងាប់ក្តី និងផ្នែកណាមួយដែលអាចសម្គាល់បាន ឬជាបំណែកដែលកែច្នៃចេញពីផ្នែកនៃប្រភេទសត្វ ឬរុក្ខជាតិនេះ ។

**ការប្រើប្រាស់ដើម្បីចិញ្ចឹមជីវិត** : ការប្រើប្រាស់ធនធានធម្មជាតិ ត្រឹមតែដើម្បីបំពេញសន្តិសុខស្បៀង និងតម្រូវការចិញ្ចឹមជីវិតរបស់សហគមន៍មូលដ្ឋានប៉ុណ្ណោះ។ ការប្រើប្រាស់ដើម្បីចិញ្ចឹមជីវិត មិនសំដៅដល់ការប្រើប្រាស់ធនធានធម្មជាតិ សម្រាប់ការលក់ដូរ ការធ្វើអំណោយ ពាណិជ្ជកម្ម ប្រយោជន៍ផ្នែកសេដ្ឋកិច្ច ឬការប្រើប្រាស់ផ្សេងទៀតឲ្យលើសពីការប្រើប្រាស់របស់សហគមន៍មូលដ្ឋាន ។

**ទឹកលើដី** : បឹង ទន្លេ ស្ទឹង ទឹកផុះពីក្នុងដី ដីសើម ដៃទន្លេឬសមុទ្រ ទឹកសមុទ្រដែលលាតសន្ធឹង ៥ (ប្រាំ) គីឡូម៉ែត្រពីឆ្នេរ ឬទឹកដទៃទៀតដែលនៅលើស្រទាប់ខាងលើនៃផែនដី ។

**ការប្រើប្រាស់ និងផលិតកម្មដោយចីរភាព** : ការប្រើប្រាស់សេវាកម្ម និងផលិតផលពាក់ព័ន្ធនានា ដែលឆ្លើយតបទៅនឹងសេចក្តីត្រូវការជាមូលដ្ឋាន និងនាំមកនូវគុណភាពជីវិតដ៏ប្រសើរដែលធ្វើការបន្ថយជាអប្បបរមានូវការប្រើប្រាស់ធនធានធម្មជាតិ និងសារធាតុពុល ក៏ដូចជា ការបញ្ចេញសំណល់ និងសារធាតុបំពុលនានានៅក្នុងវដ្តជីវិតនៃសេវាកម្ម ឬផលិតផល ដើម្បីកុំឱ្យបង្កជាហានិភ័យដល់តម្រូវការរបស់ជំនាន់ នាពេលអនាគត ។

**ការអភិវឌ្ឍដោយចីរភាព** : ការលើកកម្ពស់លទ្ធផលសេដ្ឋកិច្ច ដែលបំពេញឱ្យតម្រូវការផ្នែកការអភិវឌ្ឍ និងផ្នែកបរិស្ថានរបស់ជំនាន់បច្ចុប្បន្ន និងអនាគតប្រកបដោយសមធម៌ ដែលនៅក្នុងនោះ កិច្ចការពារបរិស្ថាន គឺជាផ្នែកមួយចាំបាច់នៅក្នុងដំណើរការនៃការអភិវឌ្ឍ និងមិនអាចធ្វើការពិចារណាដាច់ដោយឡែកពីគ្នាបានឡើយ ។

**ថាមពលដោយចីរភាព** : ប្រភពថាមពលដែលបម្រើដល់សេចក្តីត្រូវការផ្សេងៗនាពេលបច្ចុប្បន្នដោយគ្មានការធ្វើឱ្យប៉ះពាល់ដល់សមត្ថភាពរបស់ជំនាន់នាពេលអនាគតក្នុងការបំពេញសេចក្តីត្រូវការរបស់គេ ដែលរួមមាន ប្រព័ន្ធថាមពលទាំងឡាយដែលទទួលបានថាមពលមកពីពន្លឺព្រះអាទិត្យ

ខ្យល់ ថាមពលវារីអគ្គិសនីខ្នាតតូច (ក្រោម១៥ មេហ្គាវ៉ាត់) ជីវម៉ាសដែលមានការចេញវិញ្ញាបនបត្របញ្ជាក់ថា ទទួលបានមកពីប្រភពដោយចីរភាព ថាមពលកំដៅពីក្នុងដី រលកទឹក ជំនោរទឹក និងបច្ចេកវិទ្យាផលិតថាមពលពីការដុតសំណល់ ហើយប្រភពទាំងនេះ មិនរួមបញ្ចូលនូវធ្យូងថ្ម ឧស្ម័នធម្មជាតិ ប្រេងម៉ាស៊ូត ថាមពលវារីអគ្គិសនីខ្នាតធំ (លើសពី ១៥ មេហ្គាវ៉ាត់) ។

**ហិរញ្ញវត្ថុដោយចីរភាព** : យន្តការនៃការផ្តល់មូលនិធិរយៈពេលវែងទៅដល់តំបន់ការពារ មានជាអាទិ៍ ការបង់ថ្លៃលើសេវាកម្មប្រព័ន្ធអេកូឡូស៊ី យន្តការរេដបូក និងមូលនិធិបរធនបាលកិច្ចសម្រាប់ការអភិរក្ស ។ យន្តការនៃការផ្តល់មូលនិធិទាំងនេះ ជាទូទៅ ផ្តល់ជូននូវការបង់ថ្លៃដែលផ្អែកលើការអនុវត្តការងារ ដូចដែលបានកំណត់នៅក្នុងកិច្ចព្រមព្រៀងចងកាតព្វកិច្ចតាមផ្លូវច្បាប់ ។

**ការប្រើប្រាស់ដោយចីរភាព** : ការប្រើប្រាស់ធនធានធម្មជាតិក្នុងលក្ខណៈ ឬអត្រាមួយ ដែលមិនឈានទៅដល់ការធ្លាក់ចុះក្នុងរយៈពេលវែងនៃធនធានធម្មជាតិ តាមរយៈការរក្សាឱ្យបាននូវសក្តានុពលរបស់វាដើម្បីបំពេញសេចក្តីត្រូវការ និងសេចក្តីប្រាថ្នារបស់ជំនាន់នាពេលបច្ចុប្បន្ន និងអនាគត ។

**កសិកម្មព្រៃដុត** : បច្ចេកទេសនៃការធ្វើកសិកម្មជាលក្ខណៈវិលជុំ ដែលដី ត្រូវបានឈូសឆាយសម្រាប់ការដាំដុះ ហើយបន្ទាប់មកក៏ទុកចោលរយៈពេលជាច្រើនឆ្នាំ ដើម្បីឱ្យដីនោះមានជីវជាតិសារជាថ្មី ។

**សម្បត្តិវប្បធម៌រូបី** : ស្នាដៃស្ថាបត្យកម្ម ស្នាដៃរូបចម្លាក់នៃបូជនីយដ្ឋាន គំនូរ សមាសធាតុ និងរចនាសម្ព័ន្ធខាងបុរាណវត្ថុវិទ្យា សិលាចារឹក លំនៅដ្ឋាន ល្អាងភ្នំ និងការបញ្ចូលគ្នានៃទ្រង់ទ្រាយនានា ក្រុមនៃអគារមួយចំនួនដែលដាច់ពីគ្នា ឬតភ្ជាប់គ្នា ស្នាដៃរបស់មនុស្ស ឬការច្របល់ចូលគ្នារវាងស្នាដៃរបស់មនុស្ស និងធម្មជាតិ តំបន់នានាដែលរួមមាន បុរាណស្ថានដែលមានតម្លៃជាសកលជាទីបំផុតខាងផ្នែកប្រវត្តិសាស្ត្រ សិល្បៈ វិទ្យាសាស្ត្រ ជាតិពន្ធុវិទ្យា ឬនរវិទ្យា វត្ថុបុរាណ ឯកសារ និងការផលិតនូវប្រជាប្រិយសិល្បៈ ដែលមានជាអាទិ៍ ការគូររូប ការលាបពណ៌ ការឆ្លាក់ រូបចម្លាក់ នាវាសមុទ្រ ចម្បាំងគំនូរវិចិត្រដោយផ្គុំរូបតូចៗ ស្នាដៃដែលធ្វើអំពីឈើ ផលិតផលពីលោហៈ គ្រឿងអលង្ការ ការត្បាញកន្ត្រក ស្នាដៃដេរប៉ាក់ វាយនភណ្ឌ កំរាលព្រំ សម្លៀកបំពាក់ និងឧបករណ៍តន្ត្រីនានា ។

**អ្នកជំនាញបច្ចេកទេស** : រូបវន្តបុគ្គលដែលមិនលម្អៀង និងមានឯករាជ្យភាពម្នាក់ដោយមានការអប់រំ និងបទពិសោធន៍ក្នុងវិស័យឯកទេសផ្នែកបច្ចេកទេស និងវិទ្យាសាស្ត្រដែលតម្រូវឱ្យមាន ដើម្បីយល់ដឹងអំពីបញ្ហាជាក់លាក់មួយ។

**ដៃគូបច្ចេកទេស** : ស្ថាប័នសិក្សា និងស្រាវជ្រាវជាតិ និងអន្តរជាតិ និងបណ្តាអង្គការសម្រាប់ការអភិរក្ស ដែលមានបទពិសោធន៍ក្នុងការស្រាវជ្រាវ ការពារ និងគ្រប់គ្រងធនធានធម្មជាតិនៃព្រះរាជាណាចក្រកម្ពុជា ។

**ប្រភេទដែលបានទទួលរងនូវការគំរាមកំហែង** : គ្រប់ប្រភេទសត្វ និងរុក្ខជាតិ ដែលបានចុះជាប្រភេទដែលបានទទួលរងនូវការគំរាមកំហែងឈានទៅរកការវិនាសផុតពូជ ដែលកំពុងរងគ្រោះថ្នាក់ ឬអាចទទួលការប៉ះពាល់ មាននៅក្នុងបញ្ជីក្រហមនៃប្រភេទសត្វដែលបានទទួលរងនូវការគំរាមកំហែង របស់សហភាពអន្តរជាតិ ។

**ឈើ** : ឈើ ក្រៅពីអូសដុត ដែលអាចប្រើប្រាស់បានសម្រាប់ជាឈើអារ ឈើដែលកាត់រួច ឬឈើហ៊ុប ។

**សកម្មភាពទេសចរណ៍** : រួមមានជាអាទិ៍ ការដឹកជញ្ជូន កន្លែងស្នាក់នៅ សេវាកម្មចំណីអាហារ ការកំសាន្ត មគ្គុទេសន៍ សេវាកម្មជួល ការអប់រំ និងការបណ្តុះបណ្តាលនៃក្រុមហ៊ុនផ្តល់សេវាកម្មទេសចរណ៍ទាំងឡាយដែលមានការពឹងផ្អែកទៅលើធនធានធម្មជាតិ ប្រវត្តិសាស្ត្រ និងវប្បធម៌នៃព្រះរាជណាចក្រកម្ពុជាឡើយ។

**ការប្រើប្រាស់ជាលក្ខណៈប្រពៃណី** : ការប្រើប្រាស់ជាលក្ខណៈប្រពៃណីទៅលើធនធានធម្មជាតិ គឺការអនុវត្តសកម្មភាពទាំងឡាយ ដែលធជាផ្នែកមួយនៃវប្បធម៌ ទៅនៀមទំលាប់ ប្រពៃណី នៅក្នុងគោលបំណងបំពេញតម្រូវការផ្ទាល់ខ្លួន គ្រួសារ និងសហាគមន៍ ។

**ការផ្លាស់ប្តូរទីតាំង** : ការធ្វើចលនាសត្វព្រៃមួយពីជម្រករបស់វា ទៅកាន់តំបន់មួយដែលថ្មី ជាធម្មតានៅក្នុងចម្ងាយមួយដែលអាចពិចារណាបាន ពីកន្លែងដែលសត្វនោះ ត្រូវបានគេរកឃើញ ។

**បរធនបាល** : រូបវន្តបុគ្គល ឬនីតិបុគ្គលដែលមានសិទ្ធិអំណាចក្នុងការគ្រប់គ្រងមូលនិធិបរធនបាលកិច្ច សម្រាប់ជាប្រយោជាន៍របស់អត្ថគាហកៈ ស្របទៅតាមលិខិតបទដ្ឋានស្តីពីបរធនបាលកិច្ច ។ មូលនិធិបរធនបាលកិច្ច អាចមានបុគ្គលម្នាក់ ឬច្រើននាក់ ជាអ្នកគ្រប់គ្រង ។ ដើម្បីភាពច្បាស់លាស់ បរធនបាលចំពោះគោលបំណងនៃក្រមនេះ អាចរួមបញ្ចូលទាំង អ្នកតំណាងផ្សេងៗពីសហាគមន៍ណាមួយដែលរងផលប៉ះពាល់ដោយផ្ទាល់ដោយការអភិវឌ្ឍ ឬដោយនីតិបុគ្គលដទៃទៀត ។

**បេតិកភណ្ឌវប្បធម៌ក្រោមទឹក** : សម្បត្តិវប្បធម៌ ដែលលិចចូលទៅក្នុងទឹកដោយផ្នែក ឬទាំងស្រុង មួយរយៈកាល ឬជានិរន្តរ អស់រយៈពេលយ៉ាងហោចណាស់ស្ថិតក្នុងបុរេប្រវត្តិសាស្ត្រ សម័យមុនអង្គរ សម័យអង្គរ សម័យក្រោយអង្គរ សម័យអាណាព្យាបាលបារាំង និងសម័យទំនើប រួមមានជាអាទិ៍ ទីតាំង រចនាសម្ព័ន្ធ អគារ វត្ថុបុរាណ ឬសំណល់អដ្ឋិធាតុរបស់មនុស្ស និងសំណល់សត្វ សំពៅ ទូក នាវា

យន្តហោះ យានយន្តដទៃទៀត ឬបំណែករបស់វា និងវត្ថុនានាដែលមានតម្លៃផ្នែកបុរេប្រវត្តិសាស្ត្រ ប្រវត្តិសាស្ត្រឬសិល្បៈ ។

**តំបន់បេតិកភណ្ឌទីក្រុង** : បណ្តុំនៃសំណង់ស្ថាបត្យកម្មប្រវត្តិសាស្ត្រ និងហេដ្ឋារចនាសម្ព័ន្ធ រួមទាំងលំហបៃតង ដែលជាផ្នែក ឬក៏ទាំងស្រុងនៃទីប្រជុំជន ឬទីក្រុង ហើយដែលរក្សាបាននូវលក្ខណៈដើម និងបង្ហាញពីទេពកោសល្យ និងគំនិតច្នៃប្រឌិតក្នុងខាងស្ថាបត្យកម្ម ឬជីវិតរស់នៅរបស់សហគមន៍ ។

**តម្លៃ/គុណម្លៃ** : ការពិពណ៌នាជារូបិយវត្ថុ និងមិនមែនជារូបិយវត្ថុទាំងអស់ នៃកម្រិតមួយអំពីអត្ថប្រយោជន៍ ឬសារៈសំខាន់ ដែលរួមមាន តម្លៃផ្នែកសេដ្ឋកិច្ច សង្គម វប្បធម៌ និងតម្លៃដែលមិនមែនជាតម្លៃទីផ្សារផ្សេងៗ ។

**យានយន្ត** : រួមមានជាអាទិ៍ យន្តហោះ និងយានណាមួយនៅលើទឹក ឬដីដែលបំពាក់ដោយម៉ាស៊ីនដើម្បីធ្វើប្រតិបត្តិការ ។

**ជនងាយរងគ្រោះ** : ជនដែលមិនត្រូវបានគេយកចិត្តទុកដាក់ ឬដកចេញ ដោយសារក្រុមសង្គម ឬក្រុមភាគតិចរបស់ពួកគេ យេនឌ័រ អាយុ សុខភាពផ្លូវកាយ និង/ឬចិត្ត និង/ឬភាពក្រីក្រ ដែលពួកគេពុំមានលទ្ធភាពក្នុងការរំពឹងទុក ដោះស្រាយ តទល់នឹង និងការស្រោកស្រាន្តពីផលប៉ះពាល់ជាអវិជ្ជមាន ទៅលើបរិស្ថាន និងជីវភាពរស់នៅរបស់ពួកគេ ។

**ភាពងាយរងគ្រោះ** : កម្រិតដែលប្រព័ន្ធ ឬអង្គភាពមួយ មានភាពងាយរង ឬមិនអាចទប់ទល់បាននូវផលប៉ះពាល់ជាអវិជ្ជមាននៃការផ្លាស់ប្តូរ ឬការប្រែប្រួលបរិស្ថាន ។ ភាពងាយរងគ្រោះ ផ្អែកទៅលើធម្មជាតិ ទំហំ និងល្បឿននៃការប្រែប្រួលដែលប្រព័ន្ធ ឬអង្គភាពមួយត្រូវបានប្រឈម និងភាពងាយទទួលរង ព្រមទាំងសមត្ថភាពរបស់ប្រព័ន្ធ/អង្គភាពនោះ សម្រាប់ការបន្សាំ។

**ទឹក** : ទឹកលើដី ទឹកក្រោមដី និងទឹកនៅក្នុងបរិយាកាស។

**ផ្លូវទឹក** : ប្រព័ន្ធមួយនៃទឹកលើដីជាច្រើនទាក់ទងគ្នា ដែលទឹកហូរជាអចិន្ត្រៃយ៍ ឬមិនមានអាក់ នៅក្នុងបណ្តាញ ឬខ្សែទឹកធម្មជាតិ ឬសប្បនិម្មិត ។

**ទិសដៅសន្តិសុខនៃសិទ្ធិទទួលបានទឹក** : ទិសដៅនានាដែលអាចសម្តែងចេញក្នុងរូបភាពជាសូចនករនៃការអនុវត្ត និងទិសដៅផ្សេងៗដែលបានចែងនៅក្នុងផែនការធនធានទឹកអាងទន្លេ សម្រាប់ការពារលទ្ធភាពទទួលបានទឹក ស្របតាមទៅតាមសិទ្ធិទទួលបានទឹក ។

**ហេដ្ឋារចនាសម្ព័ន្ធទឹក** : ទំនប់ធំ និងតូច ទ្វារទឹក ប្រឡាយបង្វែរទឹក ភ្លឺទប់ទឹក ឬយឿនការពារទឹក ប្រព័ន្ធរំដោះទឹកធំ និងតូច ប្រព័ន្ធធារាសាស្ត្រ អាងស្តុកទឹកធំ និងតូច បំពង់បង្ហូរ ឬលូបង្ហូរទឹក អណ្តូងគ្រប់ប្រភេទ ទំនប់វារីអគ្គិសនីផ្សេងៗ និងរចនាសម្ព័ន្ធដទៃទៀតបែបនេះ ឬឧបករណ៍តម្លើងផ្សេងៗ ដែលត្រូវបានសាងសង់ ឬប្រើប្រាស់សម្រាប់គោលបំណងនៃការបង្វែរទិស ស្តុកទុកបញ្ជូន រាំងខ្ទប់ ប្រើប្រាស់ អភិរក្ស និងការពារធនធានទឹកនានា ដើម្បីរំដោះទឹកចេញពីតំបន់ដែលជន់លិចទាំងឡាយ ឬដើម្បីទប់ស្កាត់ និងកាត់បន្ថយជាអប្បរមានូវផលប៉ះពាល់ពីទឹកជំនន់ និងពីស្ថានភាពអាសន្នដទៃទៀតដែលទាក់ទងទៅនឹងទឹក ។

**សារធាតុបំពុលទឹក៖** សំណល់រាវ រឹង ឬឧស្ម័នណាមួយ ដែលត្រូវបានគេបញ្ចេញចោលតាមរយៈប្រភពជាក់លាក់ ឬប្រភពមិនជាក់លាក់មួយ ទៅកាន់ទឹកលើដី និងធនធានទឹកក្រោមដី ។

**ធនធានទឹក** : ទឹកលើដី ឬទឹកក្រោមដី រួមមានជាអាទិ៍ ទន្លេ ស្ទឹង ទឹកជ្រោះ ប្រឡាយ ទឹកផុសចេញពីដី ដីសើម បឹង ត្រពាំង និងអាងស្តុកទឹក ឬមធ្យោបាយនៃការស្តុកទឹកផ្សេងទៀត ។

**ឆ្នាំការិយបរិច្ឆេទនៃទឹក** : រយៈពេលផ្នែកគណនេយ្យ ដែលបានកំណត់ក្នុងផែនការធនធានទឹកអាងទន្លេ លិខិតបទដ្ឋានគតិយុត្ត ឬផែនការស្តីពីសិទ្ធិប្រើប្រាស់ទឹក ។

**តំបន់ដីសើម** : តំបន់ទាំងឡាយដែលទឹកគ្របដណ្តប់ទៅលើដី ឬទឹកមានវត្តមាននៅតំបន់នោះឬ នៅក្បែរផ្ទៃខាងលើនៃដីពេញមួយឆ្នាំ ឬក្នុងរយៈពេលខុសៗគ្នានៃពេលវេលាមួយឆ្នាំ រាប់បញ្ចូលទាំងក្នុងអំឡុងពេលនៃរដូវដាំដុះផងដែរ ។ ភាពឆ្អែតនៃទឹក ជាចម្បង កំណត់ពីរបៀបនៃការអភិវឌ្ឍដី និងប្រភេទនៃសហគមន៍រុក្ខជាតិ និងសត្វដែលរស់នៅក្នុង និងនៅលើដីនោះ ។ ដីសើម អាចទ្រទ្រង់ទាំងប្រភេទដែលរស់នៅក្នុងទឹក និងលើគោក ។

**សត្វព្រៃ** : ប្រភេទសត្វទាំងឡាយណាដែលកកើតឡើងនៅក្នុងប្រព័ន្ធអេកូឡូស៊ី និងជម្រកធម្មជាតិរដោយពុំមានឥទ្ធិពលរបស់មនុស្ស ក្នុងការកកើតមាន និងបន្តពូជ រាប់ទាំងប្រភេទសត្វព្រៃដែលគេចាប់បង្ខាំងផងដែរ ។

**ការចិញ្ចឹមសត្វព្រៃ** : ការបង្កាត់ពូជ ការឱ្យចំណី ការរក្សាទុកសត្វព្រៃនៅក្នុងទីបង្ខាំង សម្រាប់គោលបំណងជាបឋមសម្រាប់លក់ ធ្វើពាណិជ្ជកម្ម និងទទួលបានប្រាក់ចំណូលពីសំណាកទាំងនេះ ។

**សុខភាពសត្វព្រៃ** : លក្ខណៈនៃសត្វព្រៃដែលអាចមានសមត្ថភាពក្នុងការបំពេញនូវសេចក្តីត្រូវការផ្នែករូបរាងកាយ អាកប្បកិរិយា និងសង្គមរបស់វា និងមានភាពធន់ទៅនឹងការផ្លាស់ប្តូរពីធម្មជាតិ ឬដែលបង្កឡើងដោយមនុស្ស ទៅលើកត្តាកំណត់ជាលក្ខណៈជីវសាស្ត្រ និងបរិស្ថាន មានជាអាទិ៍ជម្ងឺផ្សេងៗ ។

**រុក្ខជាតិព្រៃ** : ប្រភេទរុក្ខជាតិដែលមិនត្រូវបានគេដាំ រួមទាំងកូនចៅរបស់វា ដែលកកើតឡើងនៅក្នុង

ប្រព័ន្ធអេកូឡូស៊ី និងជម្រកធម្មជាតិដោយពុំមានឥទ្ធិពលរបស់មនុស្ស ក្នុងការកកើតមាន និងបន្តពូជរបស់វា ។

**ប្រភេទព្រៃ** : សត្វព្រៃ រុក្ខជាតិព្រៃ និងសារពាង្គកាយព្រៃមានជីវិតផ្សេងទៀត នៅក្នុងប្រព័ន្ធអេកូឡូស៊ី និងជម្រកធម្មជាតិ ដែលមិនស្ថិតនៅក្រោមការកាន់កាប់ និងត្រួតពិនិត្យដោយមនុស្ស ។

**ស្ថាប័នសត្វវិទ្យា** : ទីកន្លែងកាន់កាប់នូវសត្វព្រៃ និងសត្វក្នុងស្រុក នៅក្នុងទីបង្ខាំង ឬការដាក់បង្ហាញជាសាធារណៈនូវប្រភេទសត្វទាំងនេះ សម្រាប់គោលបំណងនៃការអភិរក្ស និងការអប់រំ ។